ថ្មគ្រឹះនៃសេចក្តីពិត

Cornerstones of Truth

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

សិក្សាអំពីតារាជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

ថ្មគ្រឹះនៃសេចក្តីពិត

Cornerstones of Truth

ការសិក្សាអំពីគោលលទ្ធិនៃព្រះគម្ពីរ

បោះពុម្ពផ្សាយ លើកទីមួយ

ដោយ លោក Floyd C. Woodworth, Jr .

ជាមួយលោក David D. Duncan

សៀវភៅសម្រាប់សិក្សាដោយខ្លួនឯង

បង្កើតឡើង ដោយសហប្រតិបត្តិការជាមួយបុគ្គលិក សាកលវិទ្យាល័យ គ្លូបល

GLOBAL UNIVERSITY

Address of the Global University office in your area:

Global University – Battambang CAM Office
Salaa Hope Battambang – AOG
Phom Romcheck 4, Khum Ratanak
Srok Battambang
Battambang, CAMBODIA

Developed in cooperation with Global University Staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Third Edition 1997 (English)
First edition 2025 (Khmer)
© 2025 Global University

All right reserved
Khmer: *Cornerstones of Truth* by Floyd C. Woodworth, Jr. With David D. Duncan

Unless otherwise indicated, Scripture quotations are from The Khmer Standard Version © 2005 United Bible Societies.
Used by permission. All rights reserved.

PN 01.25.01 KHM

www.globaluniversity.edu
www.globalreach.org (Free pdf download)

Khmer version by Battambang CAM Translation office
Project Editor: Kelly Robinette
Head Translator: សែម សិទ្ធី (Sem Sithee)
Translation Staff:
សិទ្ធី ធីម៉ូថេ (Sithee Thimothay)

Additional Proofreading: សែម សិទ្ធី (Sem Sithee)

តើមានអ្វីថ្មីក្នុងការបោះពុម្ពនេះ៖

- និស្សិតត្រូវដាក់ពាក្យ និង ចុះឈ្មោះជាផ្លូវការ ដើម្បីទទួលបានការទទួលស្គាល់
- និស្សិតអាចចុះឈ្មោះដោយផ្ញើអ៊ីមែល ទៅកាន់ globaluniversitycambodia@gmail.com

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity

ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory

ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth

ក្រុមជំនុំគ្រិស្តបរិស័ទ ទាក់ទងនឹងព័ន្ធកិច្ច The Christian Church in Ministry

អំណោយទានខាងឯវិញ្ញាណ Spiritual Gifts

ការដោះស្រាយបញ្ហាជីវិត Solving Life's Problems

ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship

ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces

ជីវិតនៅក្នុងព្រះគ្រិស្ត Alive in Christ

ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches

ការអធិប្បាយ និង ការបង្រៀន Preaching and Teaching

មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals

គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវThe Responsible Christian

ការស្វែងយល់ព្រះគម្ពីរ Understanding the Bible

ទីប្រឹក្សា គ្រូបង្រៀន និង មគ្គទេសក៍ Counselor, Teacher and Guide

ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow

ការចែកចាយដំណឹងល្អ Sharing the Good New

ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

The Christian Service Series

ថ្មគ្រឹះនៃសេចក្តីពិត (Cornerstones of Truth) គឺជាមុខវិជ្ជាទីបីក្នុងចំណោមមុខវិជ្ជាទាំង១៨ ហើយដែល ស្ថិត នៅក្នុងវគ្គសិក្សាទីមួយ។ ក្នុងកម្មវិធីនៃភាពជាសាវ័កដ៏ជាក់ស្តែងមួយនេះ សម្រាប់អ្នកដឹកនាំថ្មីៗ។ កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ គឺជាការសិក្សាមួយដើម្បីជួយសិស្សឲ្យបានលូតលាស់ នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះគ្រិស្ត និង ទំនាក់ទំនងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងឲ្យបានយល់កាន់តែប្រសើរឡើង អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

សិស្សនឹងបានសិក្សា អំពីប្រធានបទមូលដ្ឋានគ្រឹះនៃគ្រិស្តបរិស័ទ ដោយមានការបែងចែកជាមូលបទប្រាំមួយយ៉ាង នៅក្នុងវគ្គនីមួយៗ។ វគ្គសិក្សាទាំងនេះ សរសេរតាមបែបសន្ទនា និង មានភាពងាយស្រួលក្នុងការអាន។ តារាងខាងក្រោមនេះ បង្ហាញពីការរៀបចំវគ្គសិក្សានីមួយៗ សម្រាប់កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ។

មូលបទ Theme	វគ្គទី១ Unit One	វគ្គទី២ Unit Two	វគ្គទី៣ Unit Three
ជីវិតខាងឯវិញ្ញាណ Spiritual Life	ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity	ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship	គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវ The Responsible Christian
ព្រះគម្ពីរ The Bible	ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory	ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces	ការស្វែងយល់ព្រះគម្ពីរ Understanding the Bible
ទេវសាស្ត្រ Theology	ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth	ជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ	ទីប្រឹក្សា គ្រូបង្រៀន និង មគ្គទេសក៏ Counselor, Teacher and Guide
ក្រុមជំនុំ The Church	ក្រុមជំនុំគ្រិស្តបរិស័ទ ទាក់ទងនឹងព័ន្ធកិច្ច The The Christian Church in Ministry	ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches	ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow
ការបម្រើ Service	អំណោយទានខាងឯវិញ្ញាណ Spiritual Gifts	ការអធិប្បាយ និង ការបង្រៀន Preaching and Teaching	ការចែកចាយដំណឹងល្អ Sharing the Good News
ក្រមសីលធម៌របស់គ្រិស្តបរិស័ទ Christian Ethics	ការដោះស្រាយបញ្ហាជីវិត Solving Life´s Problems	មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals	ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

តារាងមាតិកា

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ច របស់គ្រិស្តបរិស័ទ ៦
សេចក្តីណែនាំ ៧

ជំពូកទី១: ព្រះជាម្ចាស់ដ៏ជាមហាក្សត្រ

១. ព្រះជាម្ចាស់៖ និស្ស័យ និង លក្ខណសម្បត្តិធម្មជាតិរបស់ទ្រង់ ១៦
២. ព្រះជាម្ចាស់៖ លក្ខណសម្បត្តិខាងឯសីលធម៌ និង កិច្ចការរបស់ទ្រង់ ៤៨
៣. ព្រះគ្រិស្ត៖ ការបង្ហាញឲ្យឃើញ អំពីព្រះជាម្ចាស់ដែលគេមិនអាចឃើញ ៧៧
៤. ព្រះវិញ្ញាណដ៏វិសុទ្ធ៖ អ្នកគ្រប់គ្រងដែលប្រកបដោយប្រាជ្ញាញាណ ១០៦

ជំពូកទី២: ប្រធានបទអំពីព្រះជាម្ចាស់

៥. ទេវតា៖ កងទ័ពនៃភាពងងឹត និង កងទ័ពនៃពន្លឺ ១៣៥
៦. មនុស្សជាតិ ៖ ប្រធានបទនៃព្រះអាទិករ ១៦១
៧. អំពើបាប និង សេចក្តីសង្គ្រោះ៖ បញ្ហា និង ដំណោះស្រាយ ១៨៧

ជំពូកទី៣: ប្រព័ន្ធរបស់ព្រះជាម្ចាស់

៨. បទគម្ពីរ៖ ការបើកបង្ហាញជាសំណេរ របស់ព្រះជាម្ចាស់ ២១៣
៩. ក្រុមជំនុំ៖ សហគមន៍នៃប្រជារាស្ត្រ របស់ព្រះជាម្ចាស់ ២៣៩
១០. អនាគត៖ ការបើកបង្ហាញ រង្វាន់ និង ការសម្រាក ២៦៥

អក្ខរានុក្រម ២៩៨
ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន ៣១១
ការប្រឡងតាមជំពូក ៣១៧
អវសានកថា ៣៣២
សំណួរសម្រាប់និស្សិត ៣៣៤

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

សៀវភៅសិក្សាផ្ទាល់ខ្លួននេះ គឺជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅចំនួន១៨ក្បាល(មុខវិជ្ជា) ដែលជាមុខវិជ្ជាបណ្តុះបណ្តាល ក្នុងការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ នៃសាកលវិទ្យាល័យ គ្លូបល។ សញ្ញាសម្គាល់នៅខាងឆ្វេងដៃនេះ សម្រាប់បង្ហាញអំពីលំដាប់លំដោយនៃការសិក្សា មុខវិជ្ជានេះ ដែលត្រូវបែងចែកជា ៣វគ្គដែលមាន ៦ មុខវិជ្ជានៅក្នុងវគ្គនីមួយៗ។ *ថ្មគ្រឹះនៃសេចក្តីពិត* (Cornerstones of Truth) ជាមុខវិជ្ជាទី៣ ក្នុងជំពូកទី១ ។

ជំពូកទាំងអស់ ត្រូវបានរៀបចំ ដើម្បីនាំអ្នក ឲ្យសិក្សាមុខវិជ្ជានេះ ជាលក្ខណៈប្រព័ន្ធសម្រាប់កម្មវិធីសិក្សាទាំងអស់នេះ ។ ប៉ុន្តែ អ្នកក៏អាចសិក្សា តែមុខវិជ្ជានេះមួយ ឬក៏អាចសិក្សា មុខវិជ្ជាផ្សេងៗទៀតបាននៅក្នុងកម្មវិធីសិក្សានេះ តាមរបៀបណាក៏បាន។

សម្ភារសិក្សានៅក្នុងកម្មវិធី ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទនេះ ត្រូវបានបង្កើតឡើង ទៅតាមរបៀបមួយ ដែលឲ្យអ្នកបម្រើព័ន្ធកិច្ចគ្រិស្តបរិស័ទ គ្រប់ជាតិសាសន៍ និង គ្រប់វប្បធម៌ អាចរៀនដោយខ្លួនឯងបាន។ កម្មវិធីនេះនឹង ផ្តល់ជូននិស្សិត នូវចំណេះដឹង និង ជំនាញខាងព្រះគម្ពីរ សម្រាប់ការបម្រើយ៉ាងជាក់ស្តែងរបស់គ្រិស្តបរិស័ទ។

កំណត់សម្គាល់

សូមអានការណែនាំដំបូង នៃមុខវិជ្ជានេះដោយប្រុងប្រយ័ត្នបំផុត។ ដោយធ្វើតាម ការណែនាំនេះ អ្នកនឹងអាចសម្រេចគោលដៅមុខវិជ្ជារបស់អ្នក ហើយអ្នកនឹងគ្មានការលំបាកក្នុងការវាយតម្លៃ ក្នុងជំពូករបស់អ្នកឡើយ។

សេចក្តីណែនាំ

តើអ្វីជាការសិក្សាអំពីគោលលទ្ធិ?

តើអ្វីទៅ ដែលបិតានៃឥណ្ឌាសម័យថ្មីលោកមហាត្មៈ គន្ធី ចាត់ទុកថាជាជំងឺនៃសតវត្សទីម្ភៃនេះ? ហេតុអ្វីបានជាលោកបែនីតូ ហ្វាវែស ជ្រើសបំបែកក្រុមជំនុំចេញពីរដ្ឋនៅក្នុងប្រទេស មិចស៊ីកូ?

ដើម្បីស្វែងយល់អំពីអ្វីដែលអ្នកទាំងនេះ និង មនុស្សល្បីល្បាញដទៃទៀត បានបង្រៀនអំពីប្រធានបទណាមួយ តាមធម្មតាយើងអាចនឹងត្រូវអានស្នាដៃសំណេររបស់ពួកគាត់ទាំងអស់។ នៅក្នុងករណីរបស់លោកមហាត្មៈ គន្ធី យើងអាចនឹងត្រូវអានសៀវភៅដល់ទៅ៨០ក្បាល! សាកគិតទៅមើលថា តើវាមានភាពងាយស្រួលកម្រិតណាសម្រាប់យើង ប្រសិនបើយើងអាចរកបានសៀវភៅមួយក្បាល ដែលបែងចែកអ្វីដែលគាត់បង្រៀនទៅតាមប្រធានបទនោះ។

យើងបានជួបបញ្ហាដូចគ្នានេះ នៅក្នុងការព្យាយាមសិក្សាប្រធានបទជាច្រើនដែលមានរៀបរាប់នៅក្នុងព្រះគម្ពីរ។ ដូចដែលអ្នកប្រហែលបានដឹងហើយថា សេចក្តីបង្រៀននៅបទគម្ពីរ មិនត្រូវបានបង្ហាញដោយយោងទៅតាមប្រធានបទឡើយ។ ឧទាហរណ៍ កណ្ឌគម្ពីរលោកុប្បត្តិ មិនផ្តល់នូវការបកស្រាយពេញលេញអំពី ភាពពេញលេញនៃព្រះត្រៃឯក ហើយក៏គ្មានសៀវភៅមួយក្បាលណាទៀតដែរ។

ដូច្នេះ របៀបមួយដ៏សំខាន់បំផុត ដើម្បីសិក្សាព្រះគម្ពីរ គឺត្រូវមើលទៅលើព្រះគម្ពីរទាំងមូល ដើម្បីស្វែងរកសេចក្តីបង្រៀនដែលទាក់ទងនឹងប្រធានបទណាមួយ។ ការនេះ ជួយយើងឲ្យបានឃើញពីផ្នត់គំនិតទាំងមូលយ៉ាងរហ័ស ក៏ដូចជារៀបចំព័ត៌មានតាមរបៀបមួយដែលសមហេតុសមផល។ វាគឺជារបៀបជាក់ស្តែងមួយ ដើម្បីរៀបចំការគិតរបស់យើង និង ដាក់ជីវិតរបស់យើងឲ្យនៅលើខ្សែបន្ទាត់នៃគោលការណ៍របស់ព្រះគម្ពីរ។

ឈ្មោះបច្ចេកទេសមួយសម្រាប់ការសិក្សាព្រះគម្ពីរបែបនេះ គឺ*ទេវវិទ្យាបែបប្រព័ន្ធ* ។ នៅក្នុងមុខវិជ្ជានេះ យើងនឹងដើរតាមគម្រោងបែបនេះ នៅពេលដែលយើងសិក្សាស្រាវជ្រាវ បទគម្ពីរដើម្បីឲ្យបានឃើញពីអ្វីដែលបទគម្ពីរទាំងនោះបង្រៀនអំពីសកលលោក អ្នកគ្រប់គ្រងសកលលោក ប្រធានបទ និង រចនាសម្ព័ន្ធដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីបង្កើតសកលលោកនេះឡើង ។ យើងក៏នឹងស្វែងរកឲ្យឃើញនូវអ្វីដែលព្រះគម្ពីររៀបរាប់អំពីថ្ងៃអនាគតផងដែរ។

ការពិនិត្យពិច័យជាប្រព័ន្ធមួយ ទៅលើអ្វីដែលព្រះគម្ពីរបានចែងអំពីបញ្ហាសំខាន់ៗ នឹងជួយយើងឲ្យបានដឹងពីអ្វីដែលយើងអាចរំពឹងបានពីព្រះជាម្ចាស់ និង អ្វីដែលទ្រង់រំពឹងពីយើង។ ជាលទ្ធផល យើងនឹងបានលូតលាស់នៅខាងឯវិញ្ញាណ។

ការរៀបរាប់អំពីមុខវិជ្ជា

ថ្មគ្រឹះនៃសេចក្តីពិត ។ ការសិក្សាអំពីគោលលទ្ធិនៃព្រះគម្ពីរ គឺជាការសិក្សាតាមបែបប្រព័ន្ធជាលើកដំបូង ទៅលើមូលដ្ឋានគ្រឹះនៃគោលលទ្ធិនៅក្នុងព្រះគម្ពីរ។ ប្រធានបទចម្បងៗ រួមមាននិស្ស័យរបស់ព្រះជាម្ចាស់ កិច្ចការរបស់ព្រះជាម្ចាស់ សកម្មភាព និង ភាពមានកម្រិតរបស់ពួកទេវតា ការបង្កើតលោក ការធ្លាក់ចុះរបស់មនុស្សជាតិ ផែនការនៃការប្រោសលោះរបស់ព្រះជាម្ចាស់ ប្រភពដើមនៃបទគម្ពីរ ក្រុមជំនុំ និង ផែនការចុងក្រោយរបស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិ។ មុខវិជ្ជានេះ គឺជាការសិក្សាមូលដ្ឋានជាក់ស្តែងអំពីសេចក្តីបង្រៀននៅក្នុងព្រះជាម្ចាស់ និង ការប្រើប្រាស់សេចក្តីបង្រៀននោះនៅក្នុងជីវិតរបស់អ្នកជឿ។ ប្រធានបទដ៏ល្អៗនៃព្រះគម្ពីរ ត្រូវបានសិក្សា និង គាំទ្រដោយបទគម្ពីរយោងជាច្រើន។

ឥតគ្មំណាងមេរៀន

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ អ្នកអាចនឹង៖

១. រៀបរាប់អំពីលក្ខណសម្បត្តិជាព្រះ និង ជាបុគ្គលរបស់ព្រះដែលជាផ្នែករបស់ ភាពពេញលេញនៃព្រះត្រៃឯក។

២. រៀបរាប់ពីការបង្កើតមនុស្សជាតិ ការធ្លាក់ចុះរបស់មនុស្សជាតិ និង ដំណោះស្រាយដែលព្រះជាម្ចាស់ប្រទានមកដើម្បីស្រោចស្រង់ទំនាក់ទំនងរបស់មនុស្សជាតិជាមួយនឹងទ្រង់ឡើងវិញ។

៣. ប្រាប់អ្វីដែលយើងអាចដឹងអំពី ទេវតាល្អ និង ទេវតាអាក្រក់និង សកម្មភាពរបស់ពួកគេ។

៤. បកស្រាយគោលបំណង និង សកម្មភាពរបស់ក្រុមជំនុំ និង ផែនការរបស់ព្រះជាម្ចាស់សម្រាប់អនាគតដ៏អស់កល្បរបស់ក្រុមជំនុំនោះ។

៥. ប្តេជ្ញាចិត្ត ដើម្បីឲ្យគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់អ្នក ទទួលបានការដឹកនាំ ដោយខ្ជាតគំរូនៃជំនឿ និង ឥរិយាបថ ដែលផ្អែកទៅលើសេចក្តីពិតតាមព្រះគម្ពីរ។

សៀវភៅមេរៀន

អ្នកនឹងប្រើប្រាស់សៀវភៅ *ថ្មគ្រឹះនៃសេចក្តីពិត* និពន្ធដោយលោក Floyd C. Woodworth, Jr, និង លោក David D. Duncan ទុកជាសៀវភៅមេរៀន និង ជាសៀវភៅមគ្គុទេសក៍ក្នុងការសិក្សា មុខវិជ្ជានេះផង។ ក្រៅពីនោះ អ្នកត្រូវការ តែព្រះគម្ពីរតែប៉ុណ្ណោះ។

មុនពេលដែលអ្នកចាប់ផ្តើម

របៀបរៀនមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឲ្យអ្នកអាចយកទៅសិក្សាដោយខ្លួនឯងបាន។ យ៉ាងណាក៏ដោយអ្នកអាចរៀនមុខវិជ្ជានេះតាមការរៀបចំក្រុមផ្សេងៗ។ ប្រសិនបើអ្នករៀនដោយខ្លួនឯង ការរៀនរបស់អ្នក អាចបានចប់គ្រប់ជ្រុងជ្រោយ ដោយធ្វើតាមការណែនាំ នៅក្នុងសេចក្តីណែនាំនេះ។ ប្រសិនបើអ្នករៀនជាក្រុម សូមធ្វើតាមការណែនាំបន្ថែមផ្សេងដែលគ្រូរបស់អ្នកដាក់ឲ្យ ដោយយកចិត្តទុកដាក់។

វិធីប្រើប្រាស់សៀវភៅនេះ

ពេលវេលាដែលអ្នកត្រូវការ សម្រាប់រៀនមេរៀននីមួយៗ អាស្រ័យទៅតាមផ្នែកខុសៗគ្នា ទៅលើចំណេះដឹងរបស់អ្នកចំពោះមុខវិជ្ជា និង ភាពស្ទាត់ជំនាញរបស់អ្នកក្នុងការសិក្សារៀនសូត្រ មុនពេលចាប់ផ្តើមមុខវិជ្ជានោះ។ ពេលវេលាដែលអ្នកត្រូវចំណាយ ក៏អាស្រ័យទៅលើ ថាតើអ្នកអាចធ្វើតាមការណែនាំបានខ្ជាប់ខ្ជួនប៉ុនណា ហើយតើអ្នកបានបង្កើនភាពស្ទាត់ជំនាញ ដែលចាំបាច់ក្នុងការសិក្សាដោយខ្លួនឯងនេះ បានល្អប៉ុនណាដែរ។ ការដាក់គម្រោងកាលវិភាគសិក្សារបស់អ្នក ជាប្រយោជន៍ឲ្យអ្នកអាចចំណាយពេលវេលាគ្រប់គ្រាន់ដើម្បីសម្រេចបានគោលដៅដែលអ្នកនិពន្ធបានដាក់ឲ្យ ក៏ដូចជាគោលដៅផ្ទាល់ខ្លួនរបស់អ្នកផងដែរ។

មេរៀននីមួយៗ រួមបញ្ចូលទាំងសេចក្តីណែនាំ គម្រោង និងវត្ថុបំណងដើម្បីនាំផ្លូវការសិក្សារបស់អ្នក មានទាំងសកម្មភាពក្នុងការរៀន ពាក្យសំខាន់ លំហាត់អនុវត្តន៍ក្នុងមេរៀន និងលំហាត់សាកល្បងផ្ទាល់ខ្លួននៅចុងមេរៀននីមួយៗ។ ចម្លើយនៃលំហាត់អនុវត្តន៍ មាននៅចុងបញ្ចប់មេរៀននីមួយៗ ហើយចម្លើយនៃលំហាត់សាកល្បងផ្ទាល់ខ្លួន មាននៅខាងចុងបញ្ចប់នៃសៀវភៅ ដូច្នេះអ្នកអាចរំឭកដំណើរការនៃការរៀនសូត្ររបស់អ្នកបាន។

គំនិតយោបល់សម្រាប់ការសិក្សា

១. ញែកពេលវេលាឲ្យបានស្ងប់ស្ងាត់ និង ទៀងទាត់ សម្រាប់ការសិក្សារបស់អ្នក។ វាមានភាពងាយស្រួលក្នុងការផ្តោតអារម្មណ៍ជាជាង ប្រសិនបើការសិក្សាជាផ្នែកមួយនៃទម្លាប់របស់អ្នក។

២. អធិស្ឋានមុនពេលដែលអ្នកចាប់ផ្តើមការសិក្សារៀនសូត្ររបស់អ្នក។ ដោយមានព្រះគម្ពីរមួយ រួមទាំងព្រះវិញ្ញាណដ៏វិសុទ្ធ និង មុខវិជ្ជានេះ អ្នកនឹងបាននៅក្នុងថ្នាក់រៀននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ទូលសូម ព្រះជាម្ចាស់ដើម្បីឲ្យទ្រង់ជួយអ្នក ស្វែងយល់មេរៀននេះ ហើយយកវានៅដាក់ក្នុងជីវិតរបស់អ្នក។

៣. អានសេចក្តីណែនាំ គម្រោង និងគោលដៅ។ វានឹងផ្តល់ជូនអ្នកនូវសេចក្តីសង្ខេបទូទៅរបស់មេរៀន ជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើចំណុចសំខាន់ក្នុងពេលដែលអ្នកកំពុងសិក្សា ហើយវានឹងប្រាប់អ្នកពីអ្វីដែលអ្នកត្រូវរៀន។

៤. អានមេរៀនដោយប្រុងប្រយ័ត្ន។ បើកមើលខគម្ពីរយោង និងធ្វើការកត់ត្រាក្នុងសៀវភៅកត់ត្រារបស់អ្នក ដែលអាចមានប្រយោជន៍។ ខគម្ពីរ ជួយបញ្ជាក់បន្ថែមពីលើចំណុចសំខាន់របស់មេរៀន។

៥. ឆ្លើយលំហាត់អនុវត្តន៍ នៅក្នុងចន្លោះដែលបានដាក់ឲ្យ។ ចម្លើយដែលវែងអាចសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នកក៏បាន។ ពេលអ្នកសរសេរ ចម្លើយរបស់អ្នកសូម កត់ត្រាលេខរៀង និងចំណងជើងមេរៀនផងដែរ។ **សូមកុំមើលចម្លើយ ភ្លាមៗឡើយ។** ការឆ្លើយចម្លើយដោយខ្លួនឯង នឹងជួយឲ្យអ្នកចងចាំមេរៀនដែលអ្នកបានរៀន។ បន្ទាប់ពីឆ្លើយលំហាត់អនុវត្តន៍រួចហើយ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយចម្លើយដែលបានផ្តល់ជូននៅខាងចុងនៃមេរៀន បន្ទាប់មកពិនិត្យមើលសាឡើងវិញនូវចម្លើយដែលអ្នកឆ្លើយខុស។ ចម្លើយដែលយើងឲ្យ គឺមិននៅតាមលំដាប់លំដោយលេខរៀងទេ ដូច្នេះអ្នកនឹងមិនអាចមើលឃើញចម្លើយនៃសំណួរបន្ទាប់ដោយចៃដន្យឡើយ។ លំហាត់អនុវត្តន៍ទាំងនេះពិតជាសំខាន់ខ្លាំងណាស់។ ពួកវានឹងជួយឲ្យអ្នកបានចងចាំគំនិតសំខាន់របស់មេរៀន ហើយប្រើប្រាស់គោលការណ៍ដែលអ្នកបានរៀនហើយ។

៦. នៅចុងបញ្ចប់នៃមេរៀននីមួយៗ ចូរធ្វើលំហាត់សាកល្បងផ្ទាល់ខ្លួន បន្ទាប់មកពិនិត្យមើលចម្លើយរបស់អ្នកដោយប្រើ តារាងចម្លើយនៅផ្នែកខាងក្រោយនៃសៀវភៅ។

៧. នៅចុងបញ្ចប់នៃជំពូកនីមួយៗ សូមឆ្លើយសំណួរនៃការប្រឡងតាមជំពូកនោះ។

៨. ចំណាយពេលវេលារបស់អ្នក និង រៀននៅកន្លែងស្ងប់ស្ងាត់។

របៀបឆ្លើយសំណួរសិក្សា

មានលំហាត់សិក្សា និង សំណួរសាកល្បងខ្លួនឯងជាច្រើនប្រភេទនៅក្នុងសៀវភៅនេះ។ នៅខាងក្រោមនេះជាមួយឧទាហរណ៍នៃប្រភេទសំណួរនីមួយៗ និងរបៀបឆ្លើយសំណួរ។ ការពន្យល់បញ្ជាក់បន្ថែមនឹងផ្តល់ជូនសម្រាប់ប្រភេទសំណួរផ្សេងៗទៀត។

សំណួរពហុជម្រើស

សំណួរពហុជម្រើសតម្រូវឲ្យអ្នកជ្រើសរើសចម្លើយមួយក្នុងចំណោមចម្លើយដែលបានឲ្យ។

ឧទាហរណ៍

១. កណ្ឌគម្ពីរសរុបមានចំនួន

ក. ១០០កណ្ឌ

(ខ.) ៦៦កណ្ឌ

គ. ២៧កណ្ឌ

ចម្លើយត្រឹមត្រូវគឺ ខ. ៦៦កណ្ឌ។ អ្នកអាចគូសរង្វង់ជុំវិញ អក្សរ ខ. ដូចដែលបានបង្ហាញនៅខាងលើ។

(សម្រាប់សំណួរពហុជម្រើសខ្លះ មានចម្លើយត្រឹមត្រូវលើសពីមួយ។ ក្នុងករណីនេះ ចូរគូសរង្វង់ជុំវិញអក្សរ នៃចម្លើយត្រឹមត្រូវនីមួយៗ។)

ចម្លើយត្រូវ/ខុស

ចំណុចឬ សំណួរត្រូវ/ខុស តម្រូវឲ្យអ្នកជ្រើសរើសចម្លើយពីរ ឬ បី ដែលត្រឹមត្រូវ។

ឧទាហរណ៍

១. តើឃ្លាប្រយោគខាងក្រោមនេះ ប្រយោគណាខ្លះ ដែលត្រឹមត្រូវ?

(ក.) ព្រះគម្ពីរជាព្រះរាជសារសម្រាប់ ពួកអ្នកជឿនៅសព្វថ្ងៃនេះ។

ខ. ព្រះគម្ពីរសរុបទាំងអស់ មាន១២០កណ្ឌ។

(គ.) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យអ្នកនិពន្ធតាក់តែងព្រះគម្ពីរ

ប្រយោគ ក. និង គ. គឺជាចម្លើយត្រឹមត្រូវ។ អ្នកត្រូវគូសរង្វង់ពីលើអក្សរ ទាំងពីរនេះ ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

សំណួរផ្គូផ្គង

សំណួរផ្គូផ្គង តម្រូវឲ្យអ្នកផ្គូផ្គងអ្វីដែលត្រូវគ្នា។

ឧទាហរណ៍

៣. ចូរសរសេរលេខនៃឈ្មោះអ្នកដឹកនាំ នៅពីមុខប្រយោគដែលនិយាយពីសកម្មភាពពួកគេបានធ្វើ។

1 ក) បានទទួលក្រឹត្យវិន័យ នៅលើភ្នំស៊ីណៃ ១) ម៉ូសេ

2 ខ) បានដឹកនាំជនជាតិអ៊ីស្រាអែល ឆ្លងកាត់ទន្លេយ័រដាន់ ២) យ៉ូស្វេ

2 គ) បានដើរក្បួនជុំវិញ ក្រុងយេរីខូ

1 ឃ) បានរស់នៅក្នុងវាំងរបស់ស្តេចផារ៉ោន

ឃ្លា ក) និង ឃ) និយាយអំពី លោកម៉ូសេ ហើយ ឃ្លា ខ) និង គ) និយាយអំពីលោកយ៉ូស្វេ។ អ្នកត្រូវតែ សរសេរលេខ ១ នៅត្រង់ ក) និង ឃ) ហើយសរសេរលេខ ២ នៅត្រង់ ខ) និង គ) ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

ការប្រឡងតាមជំពូក

នៅចុងបញ្ចប់នៃ មុខវិជ្ជានេះ អ្នកនឹងឃើញការប្រឡងតាមជំពូក និង តារាងចម្លើយ។ សូមធ្វើតាមការណែនាំដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។ ឆ្លើយសំណួរទាំងអស់ រួចផ្ញើតារាងចម្លើយរបស់អ្នកទៅឲ្យគ្រូរបស់អ្នកធ្វើការកែតម្រូវ។ បន្ទាប់មកអ្នកអាចធ្វើការ រំឭកសាឡើងវិញនូវមុខវិជ្ជានេះ ហើយ និងសំណួរដែលទាក់ទងជាមួយព្រះគម្ពីរដែលគិតថាពិបាកសម្រាប់អ្នក ។ ការរំឭកសាឡើងវិញ នូវរឹតុបំណងសំណួរនិងចម្លើយលំហាត់អនុវត្តន៍ និងការប្រឡងផ្ទាល់ខ្លួននិងចម្លើយរបស់វានៅក្រោយសៀភៅនេះ វាជួយអ្នកឲ្យត្រៀមខ្លួនសម្រាប់ការប្រឡងតាមជំពូក។ សម្រាប់និស្សិតដែលរៀនតាមរយៈការិយាល័យជាតិ ឬ ក្រុមសិក្សាតាមតំបន់ អាចទាក់ទងគ្រូ ឬ អ្នកដឹកនាំរបស់ពួកគេ ដើម្បីទទួលបានព័ត៌មានអំពីការប្រឡងតាមជំពូក។ ប្រសិនបើ អ្នកមិនបានរៀនជាផ្លូវការតាមរយៈសាកលវិទ្យាល័យគ្លូបល ឬក្រុមសិក្សាទេ អ្នកនៅតែអាចទទួលបានផលប្រយោជន៍ពីការប្រឡងតាមជំពូកនេះដែរ។

អំពីអ្នកនិពន្ធ

លោក Floyd C. Woodworth, Jr.,ត្រូវបានជ្រើសតាំងជាព្រឹទ្ធបូជាចារ្យតាំងពីឆ្នាំ១៩៥១ មក។ ថ្មីៗនេះ លោកគឺជាអ្នកត្រួតពិនិត្យឯកសារអប់រំសម្រាប់ Christian Training Network ហើយលោកជាសាស្ត្រាចារ្យនៅក្នុងthe Latin American Advanced School of Theology ។ លោក Woodworth ធ្លាប់បានបម្រើការនៅប្រទេស គុយបា រហូតដល់ឆ្នាំ១៩៦៣។ នៅឆ្នាំ ១៩៦៤ លោកបានក្លាយជានាយកនៃសាលាព្រះគម្ពីរCentral នៅប្រទេសColombia នៃអាមេរិកខាងត្បូង។ នៅឆ្នាំ ១៩៧៣ លោកត្រូវបានគេចាត់បញ្ជូនទៅប្រទេស មិចស៊ីកូ ដែលនៅទីនោះលោកបានចូលរួម ក្នុងការបង្កើតឯកសារអប់រំគ្រិស្តបរិស័ទ តាមរយៈកម្មវិធីអប់រំគ្រិស្តបរិស័ទជាន់ខ្ពស់ ដែលមកដល់សព្វថ្ងៃត្រូវបានគេស្គាល់ថា Christian Training Network។

លោក Woodworth បានសិក្សានៅក្នុងមហាវិទ្យាល័យព្រះគម្ពីរ Central នៅទីក្រុង Springfield, Missouri និង នៅក្នុងមហាវិទ្យាល័យ Bethany Peniel នៅទីក្រុងBethany, នៅរដ្ឋOklahoma ជាកន្លែងដែលលោកទទួលបានសញ្ញាប័ត្រ BA។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតខាងសិល្បៈអក្សរសាស្ត្រ Spanish-American ពីសាកលវិទ្យាល័យ Southern California នៅរដ្ឋLos Angeles។ លោកធ្វើការនិពន្ធ ចេញពីបទពិសោធន៍ដ៏ច្រើនរបស់គាត់ ដូចជាគ្រូបង្រៀននៅក្នុងសាលាព្រះគម្ពីរ ជាគ្រូគង្វាល និង ជាអ្នកផ្សាយដំណឹងល្អម្នាក់។ ការបង្រៀនរបស់លោកផ្អែកទៅលើមូលដ្ឋានគ្រឹះឆ្លងវប្បធម៌ផ្សេងៗ បានផ្តល់លក្ខណៈ និង ចំណេះដឹងយ៉ាងពិសេសទៅដល់ការនិពន្ធរបស់លោក។

លោក David Duncan បានធ្វើជាបេសកជនតាំងពីឆ្នាំ ១៩៦៨។ លោកបានបម្រើការជាគ្រូបង្រៀន និង ជានាយក នៅវិទ្យាស្ថានព្រះគម្ពីរ Calvary, នៅទីក្រុងMajuro, Marshall Islands, អស់រយៈពេលប្រាំបីឆ្នាំ ហើយលោកបានបង្រៀននៅមហាវិទ្យាល័យព្រះគម្ពីរContinental នៅទីក្រុងBrussels, រដ្ឋBelgium និង បានបម្រើជាអ្នកគ្រប់គ្រង ការរៀបចំសំណេរសំណៅដើមនៅសាកលវិទ្យាល័យ ICI ចាប់តាំងពីឆ្នាំ ១៩៨0 ទៅដល់ឆ្នាំ១៩៨៣។ លោកមានទាំងសញ្ញាប័ត្រ BA និង MA ពីសាកលវិទ្យាល័យ Fullerton នៃរដ្ឋ California ។ លោកក៏បានបញ្ចប់វគ្គសិក្សាដែលជាការកំណត់នូវកម្រិតសិក្សា Doctor of ministry នៅGraduate school of theology នៃរដ្ឋCalifornia។

ជំពូកទី មួយ :
ព្រះជាម្ចាស់ដ៏ជាមហាក្សត្រ

<u>មេរៀន</u>

១. ព្រះជាម្ចាស់៖ និស្ស័យ និង លក្ខណសម្បត្តិធម្មជាតិរបស់ទ្រង់
២. ព្រះជាម្ចាស់៖ លក្ខណសម្បត្តិខាងឯសីលធម៌ និង កិច្ចការរបស់ទ្រង់
៣. ព្រះគ្រិស្ត៖ ការបង្ហាញឲ្យឃើញ អំពីព្រះជាម្ចាស់ដែលគេមិនអាចឃើញ
៤. ព្រះវិញ្ញាណដ៏វិសុទ្ធ៖ អ្នកគ្រប់គ្រងដែលប្រកបដោយប្រាជ្ញាញាណ

ជំពូក ១ ព្រះជាម្ចាស់៖ និស្ស័យ និង លក្ខណសម្បត្តិ ធម្មជាតិរបស់ទ្រង់

ជាការឆ្លើយតបទៅនឹងសំណួរដ៏ចំណាស់មួយដែលសួរថា "តើអ្នកអាចស្វែងយល់ជំរៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ឬស្គាល់លក្ខណៈដ៏ប្រសើរឥតខ្ចោះនៃព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុតបានឬទេ?" (គម្ពីរយ៉ូប ១១:៧) យើងសូមឆ្លើយថា "ទេ"! បញ្ហាដ៏ធំដែលយើងប្រឈមមុខនៅក្នុងការខិតខំប្រឹងប្រែងស្វែងយល់ពីព្រះជាម្ចាស់ គឺថាមនុស្សជាតិដែលនៅមានដែនកំណត់ មិនអាចយល់ពីភាពគ្មានដែនកំណត់បាននោះទេ!

ក្រៅពីការបើកបង្ហាញដែលយើងមាន ទាក់ទងអំពីនិស្ស័យ និង លក្ខណសម្បត្តិ ឬ គុណលក្ខណៈរបស់ព្រះជាម្ចាស់ យើងគ្មានមធ្យោបាយណាផ្សេង ដើម្បីដឹងពីភាពជាព្រះជាម្ចាស់បានឡើយ។ យើងអាចយល់ដឹងខ្លះៗ អំពីភាពជាព្រះរបស់ព្រះអង្គបានតែនៅពេលដែលទ្រង់បង្ហាញពីនិស្ស័យ និង លក្ខណសម្បត្តិរបស់ទ្រង់ ដោយអង្គទ្រង់ផ្ទាល់តែប៉ុណ្ណោះ។ ដូច្នេះ អ្វីដែលទ្រង់បើកបង្ហាញឲ្យយើងឃើញអំពីអង្គទ្រង់ គឺមានភាពសុក្រឹត ប៉ុន្តែគ្រាន់តែជាការបង្ហាញតែមួយផ្នែកនៃអត្ថិភាពរបស់ទ្រង់តែប៉ុណ្ណោះ។

យើងក៏អាចស្គាល់ព្រះជាម្ចាស់ នៅពេលដែលទ្រង់មានទំនាក់ទំនងជាមួយយើង។ យើងទទួលបានចំណេះដឹងអំពីទ្រង់តាមរយៈការសិក្សាពី និស្ស័យ និង លក្ខណសម្បត្តិរបស់ទ្រង់ ដ្បិតទាំងនេះបានបង្ហាញពីផ្នែកមួយនៃអត្ថិភាពរបស់ទ្រង់។ ដើម្បីទទួលបាននូវចំណេះដឹងដ៏គួរឲ្យទុកចិត្តបានទាំងស្រុងអំពីនិស្ស័យ និង លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ យើងត្រូវចាប់ផ្តើមពីការសិក្សាទៅលើការបើកបង្ហាញរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ ដែលមាននៅក្នុងព្រះគម្ពីរជាមុនសិន។ នៅពេលដែលយើងទទួលបានចំណេះដឹងទូទៅខ្លះៗអំពីព្រះជាម្ចាស់ ពីការសង្កេតមើលស្នាព្រះហស្តរបស់ទ្រង់នៅក្នុងធម្មជាតិហើយ យើងត្រូវងាកទៅរកព្រះបន្ទូលរបស់ទ្រង់ដើម្បីទទួលបាននូវការយល់ដឹង ពីនិស្ស័យ និងលក្ខណសម្បត្តិរបស់ទ្រង់។

នៅពេលអ្នកសិក្សាអំពីព្រះអាទិករនៃយើង សូមឲ្យអ្នកយល់ឃើញកាន់តែច្បាស់ថា ដោយសារតែទ្រង់យកព្រះទ័យទុកដាក់នឹងអ្នក ទើបនាំឲ្យមានការបើកបង្ហាញអង្គទ្រង់ កាន់តែច្រើនឡើង នៅទូទាំងសម័យកាលកន្លងមកនេះ។ ការបើកបង្ហាញដោយអង្គទ្រង់ផ្ទាល់នេះ បានឈានទៅដល់ភាពពេញលេញនៅពេលដែលទ្រង់បានមានព្រះបន្ទូលជាលើកចុងក្រោយ តាមរយៈព្រះបុត្រារបស់ទ្រង់។ (គម្ពីរហេប្រឺ ១:២)។

គម្រោងមេរៀន

ក. និស្ស័យរបស់ព្រះជាម្ចាស់

ខ. គុណលក្ខណៈធម្មជាតិរបស់ព្រះជាម្ចាស់

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកនឹងអាច៖

១. សរសេរអំពីគុណសម្បត្តិនៃបុគ្គលិកលក្ខណៈដែលព្រះជាម្ចាស់មាន។

២. បកស្រាយនិស្ស័យខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់។

៣. រៀបរាប់ និង កំណត់ន័យ ការរួបរួម និង ភាពតែមួយ របស់ព្រះជាម្ចាស់។

៤. បកស្រាយសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរអំពីព្រះត្រៃឯក។

៥. បង្ហាញពីការជាប់ពាក់ព័ន្ធសម្រាប់គ្រិស្តបរិស័ទទៅនឹងភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់។

៦. ប្រាប់អំពីអត្ថន័យនៃភាពមិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់ សម្រាប់អ្នកទៅតាមការយល់ដឹង និង បទពិសោធន៍ជាគ្រិស្តបរិស័ទរបស់អ្នក។

៧. សរសេរ និង កំណត់ន័យគុណលក្ខណៈរបស់ព្រះជាម្ចាស់។

សកម្មភាពក្នុងការសិក្សា

១. អានសេចក្តីណែនាំ និង វត្ថុបំណងនៃមុខវិជ្ជា ដោយយកចិត្តទុកដាក់។

២. សិក្សាគម្រោងមេរៀន និង វត្ថុបំណងមេរៀន។ ការទាំងនេះ នឹងជួយអ្នកឲ្យស្គាល់ពីអ្វីដែលអ្នកគួរដឹងនៅពេលដែលអ្នកសិក្សាមេរៀននេះ។

៣. អានមេរៀន និង ធ្វើលំហាត់ទៅតាមដំណើរវិវឌ្ឍរបស់មេរៀន។ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយចម្លើយដែលបានផ្តល់ជូននៅចុងបញ្ចប់នៃមេរៀន។ វាជារឿងដ៏សំខាន់ណាស់ដែលអ្នកត្រូវស្វែងរក និង អានរាល់បទគម្ពីរដែលបានផ្តល់ជូននៅក្នុងមេរៀន។

៤. ពាក្យជាច្រើននៅក្នុងមេរៀននេះ អាចជាពាក្យថ្មីសម្រាប់អ្នក។ មានពាក្យខ្លះត្រូវបានយកមករៀបរាប់នៅខាងក្រោមនេះទុកជាពាក្យសំខាន់ៗ។ ពិនិត្យមើលអក្ខរានុក្រមនៅក្នុងចុងបញ្ចប់នៃសៀវភៅនេះ ដើម្បីមើលនិយមន័យពាក្យសំខាន់ណា ដែលអ្នកមិនទាន់យល់។ ក៏មានពាក្យជាច្រើនទៀត ត្រូវបានបកស្រាយនៅក្នុងមេរៀនផងដែរ។ ចូរប្រើប្រាស់ វាចនានុក្រម ដើម្បីស្វែងរកនិយមន័យពាក្យផ្សេងទៀតដែលអ្នកមិនយល់។

៥. ធ្វើការប្រឡងផ្ទាល់ខ្លួននៅចុងបញ្ចប់នៃមេរៀននេះ ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកដោយយកចិត្តទុកដាក់ ជាមួយនឹងចម្លើយដែលបានផ្តល់ជូននៅផ្នែកខាងក្រោយនៃសៀវភៅមេរៀននេះ។ ចូររំឭកផ្នែកណាដែលអ្នកបានធ្វើខុស។

ពាក្យសំខាន់

គុណលក្ខណៈ	ខ្ជាប់ខ្ជួន	ភាពសាមញ្ញ
ដោយឡែក	ការសម្តែងបង្ហាញ	ព្រះមហាក្សត្រ
ភាពវិសេស	សម្ភារ	សារធាតុ
សមាសភាព	រូបធាតុ	ដែលមានសារៈសំខាន់
អស់កល្បជានិច្ច	សព្វានុភាព	ព្រះត្រៃឯក
អរូប	សព្វត្ថិភាព	ភាពខុសប្លែកពីគេ
អមតៈ	សព្វញ្ញុតញ្ញាណ	ការរួបរួម

ក. និស្ស័យរបស់ព្រះជាម្ចាស់

នៅពេលដែលអ្នកវិទ្យាសាស្ត្រធ្វើការសិក្សាទៅលើសារធាតុផ្សំនៅក្នុងឈាម ពួកគេបានរកឃើញថា ឈាមបង្កើតមកពីសារធាតុផ្សេងៗគ្នា និង ភាគល្អិតដ៏តូចៗដែលមានតួនាទីខុសៗពីគ្នា នៅក្នុងការរក្សាជីវិត។ វត្ថុរាវដ៏ស្មុគស្មាញនេះ ត្រូវបានច្របាច់ទៅពាសពេញប្រព័ន្ធបំពងដ៏សាំញ៉ាំមួយ ទាំងថ្ងៃទាំងយប់ ដោយម៉ាស៊ីនមាំមួនមួយ (បេះដូង) ដែលចេះបង្អន់ឲ្យទន់បន្ទាប់ពីចលនាច្របាច់ម្តងៗ។ ឈាមគឺជាលំហូរជីវិតនៃរូបកាយ។ ឈាមដឹកនាំអុកស៊ីសែន និង អាហារទៅគ្រប់កន្លែងក្នុងខ្លួនប្រាណ វាប្រឆាំងនឹងមេរោគដែលអាចចូលមកក្នុងខ្លួនប្រាណ និងជួយខ្លួនប្រាណសំអាតកាកសំណល់។ ដើម្បីធ្វើការទាំងនេះបាន គឺទាមទារឲ្យមានការសហប្រតិបត្តិការរវាងសួត តម្រងនោម និង សរីរាង្គផ្សេងៗ បន្ថែមពីលើបេះដូងទៀត។

នេះគ្រាន់តែជាឧទាហរណ៍មួយនៅក្នុងចំណោមប្រព័ន្ធជីវសាស្ត្រជាច្រើនទៀត ដែលមានការរៀបចំយ៉ាងល្អ អនុញ្ញាតឲ្យជីវិតអាចកើតមានឡើងបាន។ ប្រាកដណាស់ ការនេះទាមទារឲ្យមានព្រះដែលមានអំណាច និង ប្រាជ្ញាញាណអស្ចារ្យ ដើម្បីធ្វើការទាំងនេះឲ្យកើតមានឡើងបាន។ តើយើងដឹងអ្វីខ្លះអំពីព្រះអង្គនេះ? ចូរយើងក្រឡេកទៅមើលពីសេចក្តីពិតខ្លះៗ ដែលយើងបានដឹងអំពីព្រះអាទិករបស់យើង គឺព្រះជាម្ចាស់។

ព្រះជាម្ចាស់គឺជាព្រះដែលមានភាពជាបុគ្គល

វត្ថុបំណងទី១. *សរសេរអំពីគុណសម្បត្តិនៃបុគ្គលិកលក្ខណៈ ដែលព្រះជាម្ចាស់មាន។*

តើអ្វីដែលអ្នកគិតថាជាផ្នែកសំខាន់ៗរបស់មនុស្ស? ដៃ? សម្លេង? ភ្នែក? ប្រសិនបើបុគ្គលម្នាក់បាត់បង់របស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គាត់ក៏នៅតែជាបុគ្គលម្នាក់ដដែល។ យើងប្រហែលជាអាចយល់ឃើញដូចគ្នា ថា*មនុស្សម្នាក់* គឺជាអ្វីផ្សេង មិនមែនគ្រាន់តែជា*ខ្លួនប្រាណ* តែប៉ុណ្ណោះទេ។ មនុស្សម្នាក់មានសមត្ថភាព គិត ទទួលអារម្មណ៍ និង ធ្វើការសម្រេចចិត្ត។ បើទោះបីជាព្រះជាម្ចាស់គ្មានព្រះកាយក៏ដោយ ទ្រង់ក៏ពិតមានព្រះប្រាជ្ញាញាណ ព្រះតម្រិះ និង ទទួលអារម្មណ៍ និង មានហេតុផលដែរ។ ព្រះគម្ពីរបានបង្ហាញថា ទ្រង់ធ្វើការទាក់ទងជាមួយអ្នកដទៃ (គម្ពីរទំនុកតម្កើង ២៥:១៤) ហើយទ្រង់ទទួលបានឥទ្ធិពលពីការឆ្លើយតបរបស់ពួកគេមកកាន់ទ្រង់ផងដែរ (គម្ពីរអេសាយ ១:១៨) ។ ទ្រង់ព្រះតម្រិះ (គម្ពីរអេសាយ ៥៥:៨) ហើយទ្រង់ធ្វើការសម្រេចព្រះទ័យ (គម្ពីរលោកុប្បត្តិ ២:១៨)។ ការទាំងអស់នេះ ជាលក្ខណសម្បត្តិនៃភាពបុគ្គល ដូច្នេះព្រះជាម្ចាស់ជាព្រះដែលមានភាពជាបុគ្គល។

យើងអាចដឹងអ្វីម្យ៉ាងទៀត អំពីបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់បាន នៅពេលយើងពិចារណាអំពីបុគ្គលិកលក្ខណៈរបស់យើង ដោយសារតែយើងបានបង្កើតមក ឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់។ ប្រាកដណាស់ ការធ្វើបែបនេះមានដែនកំណត់របស់វា។ យើងមិនត្រូវចាត់ទុកបុគ្គលិកលក្ខណៈរបស់យើង ជាខ្នាតគំរូដែលយើងអាចយកទៅវាស់វែងបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់បាននោះទេ ដ្បិតបុគ្គលិកលក្ខណៈដើមដំបូង គឺឃើញមានតែនៅក្នុងព្រះជាម្ចាស់តែប៉ុណ្ណោះ មិនមែននៅក្នុងមនុស្សនោះទេ។ បុគ្គលិកលក្ខណៈរបស់យើង គឺគ្រាន់តែជាលំនាំមួយនៃរបស់ដើមតែប៉ុណ្ណោះ។ បុគ្គលិកលក្ខណៈរបស់យើងក៏មិនមែនដូចគ្នាបេះបិទ ជាមួយនឹងបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ដែរ ប៉ុន្តែបុគ្គលិកលក្ខណៈរបស់យើងមានផ្នែកនូវលក្ខណៈដែលស្រដៀងនឹងបុគ្គលិកលក្ខណៈរបស់

ទ្រង់។ ដូច្នេះ អ្វីដែលមើលទៅមិនល្អឥតខ្ចោះនៅក្នុងបុគ្គលិកលក្ខណៈរបស់យើង គឺយើញមានរបស់ព្រះជាម្ចាស់ថាជាការល្អឥតខ្ចោះទៅវិញ។

ប្រសិនបើអ្នកមានទំនាក់ទំនងរាប់អានជាមួយមនុស្ស ដែលមិនអនុញ្ញាតឲ្យអ្នកដឹងថាគេមានអារម្មណ៍បែបណា មិនដែលចែករំលែកគំនិតរបស់គេជាមួយអ្នក និង មិនដែលបង្ហាញនូវការចាប់អារម្មណ៍មកលើអ្នក អ្នកអាចនិយាយបានថា គេគ្មានភាពជាបុគ្គលនោះទេ។ នោះក៏ដោយសារតែ គេមិនសម្តែងលក្ខណសម្បត្តិនៃភាពបុគ្គលម្នាក់មកឲ្យអ្នកឃើញ។ ប៉ុន្តែព្រះជាម្ចាស់គឺមិនយ៉ាងដូច្នេះទេ ។ ទ្រង់គាប់ព្រះហឫទ័យនឹងអ្នក។ ទ្រង់មានអារម្មណ៍សម្រាប់មនុស្ស ហើយទ្រង់មានទំនាក់ទំនងជាមួយពួកគេ។ លើសពីនេះ ទ្រង់ធ្វើការសម្រេចព្រះទ័យដោយយល់ដល់ពួកគេផង។

មនុស្សជាច្រើននាក់ជឿថា ព្រះដ៏ខ្ពស់ឧត្តម ដែលបានបង្កើតផែនដីមកនេះ ទ្រង់គង់នៅដាច់ឆ្ងាយពីរឿងរ៉ាវរបស់មនុស្ស ពួកគេជឿថាវិញ្ញាណរបស់បុព្វបុរស ឬ វិញ្ញាណរបស់ធម្មជាតិមានជាប់ទាក់ទងជាមួយមនុស្សពីមួយថ្ងៃទៅមួយថ្ងៃ ជាជាងព្រះជាម្ចាស់ទៅទៀត។ ពិតណាស់ ការនេះគឺជាការយល់ច្រឡំមួយ។ ព្រះជាម្ចាស់ ទ្រង់យកព្រះហឫទ័យទុកដាក់ចំពោះរឿងរ៉ាវរបស់មនុស្សណាស់ ហើយទ្រង់ពិតជាទាក់ទងជាមួយយើងរាល់គ្នាដោយផ្ទាល់តែម្តង។

លំហាត់អនុវត្តន៍

១ តើមនុស្សនៅក្នុងសហគមន៍របស់អ្នក មានការយល់ឃើញពីព្រះជាម្ចាស់យ៉ាងដូចម្តេចដែរ?

.....

.....

២ ប្រសិនបើព្រះជាម្ចាស់គឺជាបុគ្គលមួយរូប តើអ្នកគិតថា អ្នកអាចស្គាល់ទ្រង់ បែបផ្ទាល់ខ្លួនបានដោយរបៀបណា? ចូរប្រើសៀវភៅកត់ត្រារបស់អ្នកដើម្បីសរសេរចម្លើយនេះ។

៣ (ចូរជ្រើសរើសឃ្លាបំពេញត្រឹមត្រូវ)។ លក្ខណៈរបស់ព្រះជាម្ចាស់ដែលសម្តែងឲ្យឃើញពីលក្ខណៈជាបុគ្គលរបស់ទ្រង់ គឺ

ក) រូបកាយ សង្គមធម៌ និង គុណលក្ខណៈខាងឯវិញ្ញាណរបស់ទ្រង់។

ខ) សមត្ថភាពក្នុងការធ្វើព្រះតម្រិះ ទទួលអារម្មណ៍ និង ធ្វើការសម្រេចព្រះទ័យរបស់ទ្រង់។

គ) សមត្ថភាពដែលអាចឲ្យគេចូលទៅរកបាន ឲ្យគេអាចឃើញ និងយល់បានពេញរបស់ទ្រង់។

ព្រះជាម្ចាស់ជាវិញ្ញាណ

វត្ថុបំណងទី២. *បកស្រាយនិស្ស័យខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់។*

តើអ្នកគិតយ៉ាងដូចម្តេច នៅពេលដែលអ្នកបិទភ្នែករបស់អ្នក ហើយព្យាយាមនឹងស្រមៃពីរូបភាពរបស់ព្រះជាម្ចាស់? ប្រសិនបើអ្នកគិតឃើញរូបភាពណាមួយសម្រាប់ព្រះជាម្ចាស់នៅក្នុងគំនិតរបស់អ្នក នោះការគិតរបស់អ្នកគិតមិនដូចជាអ្វីដែលបទគម្ពីរបានបង្រៀននោះទេ។ ព្រះជាម្ចាស់គ្មានទម្រង់អ្វីសោះ

ឡើយ ព្រោះទ្រង់គឺជា*វិញ្ញាណ* (គម្ពីរយ៉ូហាន ៤:២៤) ហើយវិញ្ញាណគឺមិនអាចមើលឃើញនោះទេ។ គម្ពីរយ៉ូហាន១:១៨ ប្រាប់ពួកយើងថា "បកស្រាយនិស្ស័យខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់។"

ព្រះជាម្ចាស់ជាវិញ្ញាណ! នេះគឺជាពាក្យដែលយើងមានប្រយោគមួយប្រាប់យើងថាអ្វីជាព្រះជាម្ចាស់។ ដើម្បីយល់ប្រយោគនេះ យើងត្រូវគិតថា តើជា*វិញ្ញាណ* មានន័យយ៉ាងណា។ តើ*លក្ខណៈខាងឯវិញ្ញាណ* ឬ គុណសម្បត្តិដែលមានភាពជាវិញ្ញាណមានទាក់ទងទៅនឹងអ្វីខ្លះ? នេះមិនមែនជាគោលគំនិតដែលងាយស្រួលបកស្រាយនោះទេ ។ដូចដែលយើងបាននិយាយខាងលើ ព្រះគម្ពីរបានផ្តល់ឲ្យយើងបានឃើញពីការបើកបង្ហាញពីនិស្ស័យរបស់ព្រះជាម្ចាស់តែ*មួយចំណែក* តែប៉ុណ្ណោះ។ នៅពេលដែលយើងខិតខំប្រឹងប្រែងរៀបរាប់អំពីនិស្ស័យខាងឯវិញ្ញាណរបស់ទ្រង់ យើងប្រហែលជាប្រើពាក្យដែលថ្មីសម្រាប់អ្នក។ យើងនឹងព្យាយាម ផ្តល់និយមន័យសម្រាប់ពាក្យនីមួយៗ ពេលណាដែលយើងឃើញពាក្យទាំងនោះ។

១. ដំបូង ការស្រាវជ្រាវរបស់យើង នៅក្នុងបទគម្ពីរបង្ហាញឲ្យឃើញថា ព្រះជាម្ចាស់មានលក្ខណៈពិសេស និង មានសារៈសំខាន់ខុសប្លែកពីអ្វីដែលមាននៅក្នុងលោកីយ៍ (គម្ពីរអេភេសូ ៤:៦ គម្ពីរកូឡូស ១:១៥-១៧)។

ការមានលក្ខណៈ*ពិសេស* មានន័យថាមានតែមួយគត់។ ការមាន*សារៈសំខាន់* មានន័យថា មាន*សារធាតុ* ឬ មាន*លក្ខណៈសំខាន់* មាន*សមាសភាព*។ ពាក្យថា*សារធាតុ* និង *សមាសភាព* មានន័យស្រដៀងគ្នា នៅពេលណាដែលប្រើសំរាប់ព្រះជាម្ចាស់។ ពាក្យទាំងនេះ សំដៅទៅលើគុណសម្បត្តិ និងគុណលក្ខណៈដែលបង្កើតបានជានិស្ស័យរបស់ទ្រង់ ហើយក៏ជាមូលដ្ឋានគ្រឹះនៃការបើកសម្តែងមកខាងក្រៅទាំងអស់របស់ទ្រង់។

២. ព្រះជាម្ចាស់ដែលមានសារៈសំខាន់នេះ គឺ*មិនអាចមើលឃើញ អរូប និង មិនផ្សំឡើងដោយផ្នែកណាមួយឡើយ*។

យើងបាននិយាយរួចម្តងហើយថា ព្រះជាម្ចាស់មានសារធាតុ ប៉ុន្តែទ្រង់មិនមែនជាសារធាតុដែលមាន*រូប*នោះទេ បាននិយាយថាទ្រង់មិនផ្សំឡើងពីរូបធាតុដូចយើងនោះទេ។ ព្រះជាម្ចាស់ជាសារធាតុ*ខាងឯវិញ្ញាណ* ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា "ខ្មោចគ្មានសាច់ គ្មានឆ្អឹង ដូចខ្ញុំទេ" (គម្ពីរលូកា ២៤:៣៩) ។ ដោយហេតុថា ព្រះជាម្ចាស់គឺជាវិញ្ញាណដែលមានន័យបរិសុទ្ធបំផុត ពេលលើកជាពាក្យទ្រង់មិនមានដែនកំណត់ដែលអាចគិតដល់ នៅពេលដែលអ្នកគិតអំពីមនុស្សនោះទេ។ ទ្រង់មិនមានសម្បត្តិ ឬ លក្ខណសម្បត្តិដែលមាននៅក្នុងរូបធាតុនោះទេ។ លោកប៉ុលរៀបរាប់ថាទ្រង់ជា "ព្រះមហាក្សត្រដែលគង់នៅអស់កល្បជានិច្ច ជាព្រះជាម្ចាស់តែមួយ ព្រះអង្គមានព្រះជន្មមិនចេះសាប សូន្យដែលមនុស្សមើលពុំឃើញ (គម្ពីរ១ធីម៉ូថេ ១:១៧) និងជា "ព្រះអង្គជាព្រះមហាក្សត្រធំលើសមហាក្សត្រនានាជាព្រះអម្ចាស់ធំលើសអម្ចាស់នានា មានតែព្រះអង្គមួយគត់ដែលមានព្រះជន្មអមតៈ ព្រះអង្គគង់នៅក្នុងពន្លឺ ដែលគ្មាននរណា អាចចូលជិតបានឡើយ ហើយក៏គ្មានមនុស្សណាបានឃើញ និងអាចឃើញព្រះអង្គបានដែរ" (គម្ពីរ១ធីម៉ូថេ ៦:១៥-១៦)។

ប្រសិនបើព្រះជាម្ចាស់ពិតជាវិញ្ញាណ ហើយមិនអាចមើលឃើញមែន តើយើងយល់យ៉ាងដូចម្តេចអំពីហេតុការណ៍នៅក្នុងព្រះគម្ពីរ ដូចជាហេតុការណ៍មួយដែលបានរៀបរាប់នៅក្នុងគម្ពីរ និក្ខមនំ ៣៣:១៩-

២៣ ដែលបានប្រាប់យើងថា លោកម៉ូសេបានឃើញព្រះជាម្ចាស់? រឿងនេះមិនមែនជាការប្រឆាំងនឹងការពិតដែលថាព្រះជាម្ចាស់ ជាព្រះដែលមិនអាចមើលឃើញ និង អរូបនោះឡើយ។ នៅហេតុការណ៍ខ្លះមនុស្សគ្រាន់បានឃើញពីរូបភាពឆ្លុះបញ្ចាំងនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ប៉ុន្តែពួកគេមិនបានឃើញពីសមាសភាពរបស់ទ្រង់នោះទេ។ ហេតុការណ៍ផ្សេងទៀត បានបង្ហាញថា វិញ្ញាណអាចបង្ហាញរូបជាទម្រង់ដែលអាចមើលឃើញ។ ព្រះជាម្ចាស់អាចបង្ហាញអង្គទ្រង់តាមរយៈការបង្ហាញព្រះកាយជារូបយ៉ាងល្អតតខ្ចោះ។ ការនេះបានកើតឡើង នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើព្រះយេស៊ូ ក្រោមទម្រង់ជាសត្វព្រាប នៅពេលព្រះយេស៊ូបានជ្រមុជទឹកហើយ (គម្ពីរយ៉ូហាន ១:៣២-៣៤)។ នៅពេលលោកយ៉ូហានបាទីស្តបានឃើញទីសំគាល់នេះ លោកក៏បានជឿថាព្រះយេស៊ូគឺពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់មែន។ ព្រះវិញ្ញាណដែលជារបស់ព្រះជាម្ចាស់ដែលមិនអាចមើលឃើញ បានបង្ហាញអង្គទ្រង់ក្នុងទម្រង់ជាសត្វព្រាប ដើម្បីឲ្យលោកយ៉ូហានអាចដឹងយ៉ាងប្រាកដពីអត្តសញ្ញាណរបស់ព្រះយេស៊ូ ដែលនឹងបានជ្រមុជយើងជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងឧទាហរណ៍ក្នុងគម្ពីរនិក្ខមនំជំពូក៣៣ លោកម៉ូសេក៏ត្រូវការការអះអាងពីព្រះជាម្ចាស់ ដើម្បីឲ្យលោកប្រឈមមុខនឹងកិច្ចការជាអ្នកដឹកនាំ ដែលព្រះជាម្ចាស់បានប្រទានមកសម្រាប់លោក ដូច្នេះ ព្រះជាម្ចាស់បានប្រទានឲ្យលោកបានឃើញពីទីសំគាល់មានរូបនោះ។

អ្នកប្រហែលជាកំពុងគិតថា "ប្រសិនបើព្រះជាម្ចាស់ទ្រង់អរូប ហេតុអ្វីបានជាព្រះគម្ពីរថ្លែងពីព្រះហស្ត ព្រះបាទា ព្រះកាណ៌ ព្រះឱស្ឋ ព្រះនាសា ឬ ព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ដែរ? ហេតុអ្វីបានជាមានបទគម្ពីរដែលថ្លែងអំពីការដែលព្រះជាម្ចាស់បានធ្វើអ្វីដែលមនុស្សអាចធ្វើដែរ?" ជាឧទាហរណ៍ គម្ពីរទំនុកតម្កើង ៩៨ បានថ្លែងអំពី "ព្រះហស្តស្តាំ និងព្រះពាហុដ៏បរិសុទ្ធរបស់ទ្រង់" (ខ១ ពគប=ព្រះគម្ពីរបរិសុទ្ធបកប្រែនៅឆ្នាំ១៩៥៤) គម្ពីរទំនុកតម្កើង ៩៩:៥(ពគប) បាននិយាយអំពីការថ្វាយបង្គំ "ថ្វាយបង្គំនៅទៀបកំណល់កល់ព្រះបាទទ្រង់" គម្ពីរទំនុកតម្កើង ៩១(ពគប) និយាយអំពី "ស្លាបទ្រង់" និង "ចំអេងស្លាបរបស់ទ្រង់" (ខ៤) ។

ដោយសារតែការស្វែងយល់ពីសមាសភាពរបស់ព្រះជាម្ចាស់ មានការពិបាកសម្រាប់យើង ទ្រង់បានជំរុញចិត្តអ្នកនិពន្ធបទគម្ពីរ ឲ្យប្រើប្រាស់វត្ថុដែលយើងធ្លាប់ស្គាល់ ហើយប្រើប្រាស់លក្ខណៈខ្លះៗនៃវត្ថុទាំងនោះដើម្បីតំណាងឲ្យព្រះជាម្ចាស់។ ដោយធ្វើបែបនេះ យើងអាចទទួលបានការយល់ដឹងខ្លះៗ អំពីអ្វីដែលយើងមិនធ្លាប់ស្គាល់ តាមរយៈអ្វីដែលបានស្គាល់ហើយ។ នៅពេលដែលមានការតំណាងនេះត្រូវបានធ្វើឡើង យើងហៅការនេះថា ភាសានិមិត្តរូប ។ ក្នុងករណីនេះ ផ្នត់គំនិតនេះ មិនត្រូវចាត់ទុកជារឿងពិតមែនឬ សេចក្តីពិតនោះទេ ប៉ុន្តែត្រូវចាត់ទុកជានិមិត្តសញ្ញាដើម្បីតំណាងឲ្យគំនិតដែលពិតប្រាកដមួយ។ ការនេះអាចបញ្ជាក់ឲ្យច្បាស់នៅក្នុងលំហាត់ខាងក្រោម។

លំហាត់អនុវត្តន៍

៤ ចូរអានគម្ពីរទំនុកតម្កើង ៣៤:១៥ ហើយគូសរង្វង់ជុំវិញព្យញ្ជនៈដែលនៅខាងមុខការបកស្រាយត្រូវសម្រាប់ខគម្ពីរនេះ។

ក) ការបង្ហាញអំពីព្រះជាម្ចាស់ ថាមាន ព្រះនេត្រ ព្រះកាណ៌ និង ព្រះភក្ត្រ បញ្ជាក់ថាទ្រង់ពិតជាអាចទតឃើញ ស្តាប់ឮ និង មានទម្រង់ដែលអាចមើលឃើញនៅពេលដែលទ្រង់ទាក់ទងជាមួយមនុស្ស។

ខ) ព្រះជាម្ចាស់ជ្រាប និង យកព្រះទ័យទុកដាក់ ចំពោះតម្រូវការយុត្តិធម៌ ហើយទ្រង់ជ្រាប និងយកព្រះទ័យទុកដាក់នឹងភាពមានបាបរបស់អ្នកដែលធ្វើអំពើអាក្រក់។ ការទាំងនេះបង្ហាញឡើងតាមរបៀបនិមិត្តរូប។

៥ (ចូរជ្រើសរើសចម្លើយមួយដែលត្រឹមត្រូវ)។ នៅពេលយើងអានបទគម្ពីរដែលថា ព្រះជាម្ចាស់ជាវិញ្ញាណ យើងអាចយល់បានថា

ក) ទ្រង់គ្មានព្រះកាយទេ។

ខ) ព្រះជាម្ចាស់មិនមានទម្រង់ជារូបកាយទេ ប៉ុន្តែទ្រង់អាចបង្ហាញអង្គទ្រង់តាមរយៈទម្រង់ដែលមានរូបបាន។

គ) ឯកសារយោងនៅក្នុងព្រះគម្ពីរដែលបង្ហាញថាព្រះជាម្ចាស់កំពុងធ្វើអ្វីដែលមនុស្សអាចធ្វើដោយប្រើភាសានិមិត្តរូប។

ឃ) ចម្លើយ ក) , ខ) និង គ) ជាចម្លើយត្រឹមត្រូវ។

ង) មានតែចម្លើយ ក) និង គ) ជាចម្លើយត្រឹមត្រូវ។

ព្រះជាម្ចាស់មានតែមួយ

វត្ថុបំណងទី៣. *ពិបាក់ និង កំណត់ន័យ ការរួបរួម និង ភាពតែមួយ របស់ព្រះជាម្ចាស់។*

នៅពេលដែលយើងនិយាយថា ព្រះជាម្ចាស់គឺមាន*តែមួយ* យើងចង់សំដៅទៅលើផ្នត់គំនិតបីយ៉ាង ៖ ទី១) *ការរួបរួម* ខាងឯចំនួនរបស់ព្រះជាម្ចាស់ ទី២) ភាព*ពិសេសប្លែក* របស់ព្រះជាម្ចាស់ និង ទី៣) *ពិសេសសាមញ្ញ* របស់ព្រះជាម្ចាស់។

ការរួបរួមខាងឯចំនួនរបស់ព្រះជាម្ចាស់

ដំបូងឡើយ នៅពេលដែលយើងនិយាយអំពីការរួបរួមរបស់ព្រះជាម្ចាស់ យើងសំដៅទៅលើសេចក្តីពិតដែលថា ទ្រង់គឺជាព្រះដែលមានចំនួនតែមួយ។ ដោយសារតែមានព្រះជាម្ចាស់តែមួយយ៉ាងដូច្នេះហើយ សភាវៈផ្សេងៗទៀតដែលចាត់កំណើតឡើងតាមរយៈទ្រង់តែមួយ សម្រាប់ទ្រង់តែមួយ និងទៅកាន់ទ្រង់តែមួយ។ លោកប៉ូលមានប្រសាសន៍នៅក្នុងគម្ពីរ១កូរិនថូស៨:៦ " ក៏យើងជឿថា មានព្រះជាម្ចាស់តែមួយព្រះអង្គប៉ុណ្ណោះ។ ព្រះអង្គជាព្រះបិតាដែលបានបង្កើតអ្វីៗសព្វសារពើមក ហើយយើងមានជីវិតរស់សំរាប់ព្រះអង្គ។ យើងជឿទៀតថា មានព្រះអម្ចាស់តែមួយព្រះអង្គប៉ុណ្ណោះ គឺព្រះយេស៊ូគ្រិស្ត*។

អ្វីៗសព្វសារពើកើតមកដោយសារព្រះអង្គ ហើយយើងមានជីវិតរស់ក៏ដោយសារព្រះអង្គដែរ។" ផ្នែកទីពីរនៃខគម្ពីរនេះ ហាក់ដូចជាផ្ទុយនឹងគំនិតដែលថាព្រះជាម្ចាស់មានចំនួនតែមួយគត់។ ការនេះនឹងត្រូវលើកយកទៅបកស្រាយនៅពេលក្រោយក្នុងការពិភាក្សារបស់យើងស្តីពី *ព្រះត្រៃឯក* ។

ស្តេចសាឡូម៉ូន បានលើកឡើងពីភាពរួបរួមខាងឯចំនួន របស់ព្រះជាម្ចាស់នៅក្នុងគម្ពីរ១ពង្សាវតារក្សត្រ ៨:៦០ នៅពេលដែលទ្រង់សុំឲ្យ "ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងទទួលស្គាល់ថា មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលពិតជាព្រះជាម្ចាស់ គឺគ្មានព្រះឯណាទៀតឡើយ។" ពេលខ្លះប្រជាជនអ៊ីស្រាអែលការលំបាកក្នុងការរក្សានូវគំនិតដែលថា ព្រះជាម្ចាស់គឺមានតែមួយ ព្រោះនៅជុំវិញប្រទេសគ្រប់ទិសទាំងអស់ មានប្រទេសជាច្រើនដែលនាំចូលព្រះជាច្រើនប្រភេទដែលអាចឲ្យពួកគេជ្រើសរើសបាន។ ជារឿយៗ ពួកព្យាការីធ្វើការស្រែកប្រកាសទាំងប្រចុយប្រចាន ទៅកាន់មនុស្សម្នាដើម្បីរំឭកពួកគេថា ព្រះយេហូវ៉ាគឺជាព្រះជាម្ចាស់តែមួយគត់ (គម្ពីរទុតិយកថា ៤:៣៥,៣៩)។

តើការជឿថាមានព្រះច្រើន គឺជាផ្នែកមួយនៅក្នុងសង្គមរបស់អ្នកដែរឬទេ? តើអ្នកបានស្គាល់សេចក្តីបង្រៀនណាទាក់ទងនឹងព្រះដែលកើតពីការសន្និដ្ឋាន និងទំនាក់ទំនងរបស់ព្រះទាំងនេះជាមួយមនុស្សដែរឬទេ? ខ្ញុំបានសំគាល់ឃើញថា នៅប្រទេសជាច្រើន ប្រជាជនបានថ្វាយបង្គំព្រះ ឬ អ្វីដែលគេចាត់ទុកថាជាព្រះយ៉ាងច្រើន។ ពេលខ្លះព្រះទាំងនោះ *ហាក់បីដូចជា* មានតែនៅក្នុងវប្បធម៌របស់ក្រុមកុលសម្ព័ន្ធ និងសម្រាប់ផ្នែកណាមួយនៅក្នុងជីវិតរបស់ពួកគេតែប៉ុណ្ណោះ ដែលបានន័យថាមានព្រះជាច្រើន ប៉ុន្តែនៅក្នុងព្រះគម្ពីរបានបង្រៀនអំពី *លក្ខណៈពិសេសតែមួយ* របស់ព្រះជាម្ចាស់ ដូច្នេះព្រះជាម្ចាស់អាចមានតែ *មួយអង្គគត់* ។

លក្ខណៈពិសេសតែមួយរបស់ព្រះជាម្ចាស់

ខគម្ពីរផ្សេងទៀតនៅក្នុងព្រះគម្ពីរ ដូចជាគម្ពីរទុតិយកថា ៦:៤ និយាយពីលក្ខណៈពិសេសតែមួយរបស់ព្រះជាម្ចាស់ ៖ "មានតែព្រះអម្ចាស់ ជាព្រះរបស់យើង មួយព្រះអង្គគត់ ដែលពិតជាព្រះអម្ចាស់។" ពាក្យហេប្រឺដែលបកប្រែពាក្យថា *មួយ* ក៏អាចបកប្រែថា *តែមួយគត់* ដែលមើលទៅដូចជាការបកប្រែដែលល្អជាង។ ដូច្នេះ ព្រះយេហូវ៉ាតែមួយគត់ គឺជាព្រះតែមួយដែលទទួលបានព្រះនាម ថា ព្រះយេហូវ៉ានេះ។ នេះគឺជាសារក្នុងគម្ពីរសាការី ១៤:៩ "នៅថ្ងៃនោះ មនុស្សគ្រប់ៗគ្នានឹងថ្វាយបង្គំព្រះអម្ចាស់តែមួយព្រះអង្គគត់ គឺមានតែព្រះនាមព្រះអង្គប៉ុណ្ណោះ។ គំនិតដូចគ្នានេះក៏ត្រូវបានលើកយកទៅបង្ហាញយ៉ាងច្បាស់នៅក្នុងគម្ពីរនិក្ខមនំ ១៥:១១ "ព្រះអម្ចាស់អើយ តើមានព្រះណាអាចផ្ទឹមនឹងព្រះអង្គបាន? តើនរណាមានភាពថ្កុំថ្កើងដ៏វិសុទ្ធដូចព្រះអង្គ។ ព្រះអង្គជាព្រះគួរអោយកោតស្ញប់ស្ញែងគួរសរសើរតម្កើង ព្រះអង្គសំដែងឫទ្ធិបាដិហារិយ៍ដ៏អស្ចារ្យ។" ប្រាកដណាស់ ចម្លើយសម្រាប់សំណួរនេះគឺថា គ្មានព្រះណាទៀតទេ។ ទ្រង់គឺជាព្រះជាម្ចាស់តែមួយ ហើយមានតែព្រះអង្គមួយតែប៉ុណ្ណោះ។

ខគម្ពីរទាំងនេះ បានច្រានចោលការដែលថាព្រះជាម្ចាស់គឺជាព្រះមួយក្នុងចំណោមព្រះជាច្រើននោះ។ ទ្រង់គឺជាព្រះមហាក្សត្រនៃសាកលលោក ហើយក្រៅពីទ្រង់គ្មានព្រះណាទៀតនោះទេ។ នៅពាសពេញកំណត់ត្រាក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់បានក្រើនរំឭកប្រជារាស្ត្ររបស់ទ្រង់ថាទ្រង់គឺជា *ព្រះជាម្ចាស់តែមួយអង្គគត់។*

លំហាត់អនុវត្តន៍

៦ ចូរអានបទគម្ពីរខាងក្រោម ហើយប្រាប់ពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីអង្គទ្រង់។

ក) គម្ពីរលោកុប្បត្តិ ១៧:១៖ "យើងជា....."

ខ) គម្ពីរនិក្ខមនំ ២០:២-៣ ៖ "យើង..... មិនត្រូវ....."។

គ) គម្ពីរនិក្ខមនំ ២០:២៣(ពគប១៩៥៤) ៖ "ដូច្នេះមិនត្រូវ....."

ឃ) គម្ពីរអេសាយ ៤៣:១០-១១; ៤៤:៦,៨; ៤៥:៥,២១។ សារនៅក្នុងបទគម្ពីរនីមួយៗខាងក្រោមនេះគឺ ....."

នៅពេលដែលខ្ញុំសុំឲ្យសិស្សរបស់ខ្ញុំ ផ្តល់និយមន័យផ្តល់ខ្លួនមួយអំពីព្រះជាម្ចាស់ ពួកគេតែងតែចាប់ផ្តើមដោយនិយាយថា៖ "ព្រះជាម្ចាស់ជាវិញ្ញាណមួយ ដែលមានភាពអស់កល្ប ដែលបានបង្កើតផ្ទៃមេឃ និង ផែនដី។" មិនថានាមអ្វីដែលពួកគេប្រើសម្រាប់ផ្តល់និយមន័យឲ្យព្រះជាម្ចាស់នោះទេ ពួកគេស្ទើតែគ្រប់គ្នាបានប្រើ គុណនាមវិសេសន៍មិនទៀងទាត់នៅពីក្រោយ។ ពួកគេនិយាយថា៖ "ព្រះជាម្ចាស់គឺជាវិញ្ញាណ*មួយ (a)* " ។ ការនិយាយបែបនេះបានធ្វើឲ្យយើងគិតថា អាចមានវិញ្ញាណផ្សេងទៀតដែលហាន:ស្មើគ្នាជាមួយព្រះអង្គ។ សូមមើលពីភាពខុសគ្នា ទៅលើនិយមន័យនេះ នៅពេលណាដែលយើងប្រើគុណនាមវិសេសន៍ទៀងទាត់ "*មួយគត់" (the)* ទៅជំនួសកន្លែងគុណនាមវិសេសន៍មិនទៀងទាត់ "មួយ (a)វិញ" ៖ "ព្រះជាម្ចាស់ជាវិញ្ញាណតែមួយគត់ ដែលមានភាពអស់កល្ប ដែលបានបង្កើតផ្ទៃមេឃ និងផែនដី"។ និយមន័យត្រូវតែឲ្យរបៀបបែបនេះ ដោយសារគ្មានមនុស្ស ឬ អំណាចណាដែលស័ក្តិសមនៅក្នុងចំណាត់ថ្នាក់នេះឡើយ។ ព្រះជាម្ចាស់គឺជាព្រះតែមួយគត់។

តាពសាមញ្ញរបស់ព្រះជាម្ចាស់

លើសពីការរួបរួម និង លក្ខណៈពិសេសតែមួយ ការរួបរួមរបស់ព្រះជាម្ចាស់សំដៅទៅលើការរួបរួម*ផ្ទៃកខាងក្នុង*របស់ព្រះជាម្ចាស់។ ជារឿយ ការរួបរួមនៅក្នុងផ្ទៃកនេះ ត្រូវបានគេហៅថា *ភាពសាមញ្ញ។* ពាក្យថា ភាពសាមញ្ញមានន័យថាសភាព ឬ ស្ថានភាពដែលគ្មានការបែងចែកទៅជាផ្ទៃក។ ព្រះជាម្ចាស់ជា *វិញ្ញាណ* ដូច្នេះហើយទ្រង់មិនអាចមាននរណាបែងចែកបានឡើយ។ ផ្ទុយទៅវិញភាពជាមនុស្សរបស់យើង គឺជាការបណ្តុំមួយ ៖ យើងគឺជាវត្ថុធាតុ (ខ្លួនប្រាណ) និង ជារបស់អរូប (វិញ្ញាណ)។

អ្វីៗគ្រប់យ៉ាងអំពីព្រះជាម្ចាស់គឺល្អឥតខ្ចោះ។ យើងអាចនិយាយម្យ៉ាងទៀតបានថា លក្ខណសម្បត្តិរបស់ព្រះគឺជា*ភាពល្អឥតខ្ចោះ*របស់ទ្រង់។ ការគិតអំពីភាពរួបរួមនៅខាងក្នុង ឬ ភាពសាមញ្ញ នៅបន្ទាប់ពីភាពឥតខ្ចោះផ្សេងៗទៀតរបស់ព្រះជាម្ចាស់។ ឧទាហរណ៍ អត្ថិភាពរបស់ព្រះជាម្ចាស់ គឺមិនផ្អែកទៅលើអ្វីដែលនៅខាងក្រៅទ្រង់នោះទេ ។ ព្រះជាម្ចាស់គឺ*កើតឡើងដោយអង្គឯង* ដែលមានន័យថា អត្ថិភាពនៅអស់កល្បជានិច្ច គឺជាផ្ទៃកមួយនៃលក្ខណៈរបស់ទ្រង់ផ្ទាល់។ ដូច្នេះ អត្ថិភាពដោយអង្គឯងរបស់ទ្រង់នេះ ច្រានចោលនូវផ្នត់គំនិតដែលថា មានអ្វីម្យ៉ាងបានបង្កើតទ្រង់ឡើង ដូចនៅក្នុងករណីរបស់

ភាវៈដែលកើតពីបណ្តុំ ដូចជាមនុស្សជាដើម។ *ភាពសាមញ្ញ* របស់ព្រះជាម្ចាស់បញ្ជាក់ឲ្យឃើញពីរឿងមួយចំនួន ។ រឿងមួយគឺថា អង្គទាំងបីនៃត្រៃឯកភាពពេញលេញ(ភាពពេញលេញរបស់ព្រះត្រៃឯក) គឺមិនគ្រាន់តែជាផ្នែកមួយដែល មករួមគ្នាបង្កើតបានជាសមាសភាពរបស់ព្រះជាម្ចាស់នេះឡើយ។ រឿងនេះក៏មិនឲ្យមាន ការចែកដាច់ភាពឥតខ្ចោះរបស់ព្រះជាម្ចាស់ ចេញពីសមាសភាពរបស់ទ្រង់ ឬ ការបន្ថែមលក្ខណសម្បត្តិរបស់ទ្រង់ទៅលើសមាសភាពរបស់ព្រះជាម្ចាស់ផងដែរ។ សមាសភាពរបស់ព្រះជាម្ចាស់ និង ភាពឥតខ្ចោះរបស់ទ្រង់ គឺតែមួយ និង ជារបស់ដូចគ្នា។ ដូច្នេះ បទគម្ពីរដែលនិយាយអំពីព្រះជាម្ចាស់ ថាទ្រង់ជាពន្លឺ និង ជាជីវិត ភាពសុចរិត និង សេចក្តីស្រឡាញ់ ហើយតាមរបៀបនេះ បានរាប់ទ្រង់ចូលជាមួយភាពឥតខ្ចោះរបស់ទ្រង់ដែរ។ ម្យ៉ាងទៀត យើងមិននិយាយថាព្រះជាម្ចាស់ *មាន* ភាពសុចរិតនោះទេ ប៉ុន្តែយើងនិយាយថា ទ្រង់*គឺជា* ភាពសុចរិតវិញ។ ទ្រង់*គឺជា* ភាពល្អឥតខ្ចោះ!

លំហាត់អនុវត្តន៍

---

៧ ចូរផ្គូផ្គងគំនិតដែលប្រើដើម្បីរៀបរាប់អំពីភាពរួបរួមរបស់ព្រះជាម្ចាស់ ទៅជាមួយនឹងនិយមន័យនៃគំនិតនីមួយៗ។

.....ក) ទ្រង់គឺជាព្រះជាម្ចាស់តែមួយ និង គ្មានព្រះឯណាដូចទ្រង់ឡើយ។

.....ខ) មានព្រះជាម្ចាស់មួយអង្គ ហើយសភាវៈផ្សេងៗទៀតកើតមានឡើងតាមរយៈទ្រង់។

.....គ) គំនិតនេះច្រានចោល អ្វីដែលអាចបណ្តាលឲ្យពហុភាពនៃព្រះជាម្ចាស់។

.....ឃ) អត្ថិភាពរបស់ព្រះជាម្ចាស់មិនផ្អែកទៅលើអ្វីដែលនៅខាងក្រៅទ្រង់នោះទេ។

.....ង) នេះគឺជារបៀបមួយទៀតដែលរៀបរាប់អំពីភាពរួបរួមផ្នែកខាងក្នុងរបស់ព្រះជាម្ចាស់។

.....ច) យើងគឺជាបណ្តុំ ដែលមានន័យថា យើងគឺជាខ្លួនប្រាណ និង វិញ្ញាណ ផ្ទុយពីព្រះជាម្ចាស់ដែលទ្រង់ជាវិញ្ញាណ។

.....ឆ) ព្រះជាម្ចាស់គឺជាវិញ្ញាណដ៏អស់កល្បជានិច្ច។

១) ភាពរួបរួមខាងឯចំនួន

២) ភាពពិសេសតែមួយ

៣) ភាពសាមញ្ញ

ព្រះជាម្ចាស់ជាព្រះបីរួមមកតែមួយ

វត្ថុបំណងទី៤. *បកស្រាយសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរអំពីព្រះត្រៃឯក។*

យើងបានឃើញហើយថា ព្រះជាម្ចាស់ជាវិញ្ញាណ ទ្រង់ជាព្រះដែលមានភាពជាបុគ្គល ហើយទ្រង់មានតែមួយ។ ឥឡូវនេះយើងពិចារណាទៅលើផ្នែកទីបួននៅក្នុងនិស្ស័យរបស់ទ្រង់៖ នោះគឺព្រះត្រៃឯក ។ ព្រះជាម្ចាស់គឺជា*បីរួមមកតែមួយ* ។ ការនេះប្រហែលជាគួរឲ្យងឿងឆ្ងល់បន្តិចសម្រាប់អ្នក។ តើព្រះជាម្ចាស់ជា*ព្រះមួយអង្គ* និង ជា*ព្រះបីអង្គរួមមកតែមួយ* យ៉ាងដូចម្តេចបាន? ពាក្យថា*បីរួមតែមួយ* ឬ *ត្រៃឯក* មានផ្ទុកនូវផ្នត់គំនិតពីភាពតែមួយ ឬ បី (ត្រី) និង ភាពតែមួយ ឬ សភាពដែលមាន*បីក្នុងមួយ* ។ នៅពេលដែលយើងសិក្សាមុខវិជ្ជាដ៏សំខាន់មួយនេះ យើងឃើញថា យើងអាចដឹងសេចក្តីពិតនេះ តាមរយៈការបើកបង្ហាញរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ដូច្នេះ យើងបែរទៅមើលអ្វីដែលព្រះជាម្ចាស់បានបង្ហាញ នៅក្នុងបទគម្ពីរ ទុកជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សារបស់ទៅលើសំណួរខាងក្រោមដែលទាក់ទងនឹងព្រះត្រៃឯក។

១. *តើព្រះត្រៃឯកជាអ្វី?*

ដូចដែលយើងបានឃើញហើយថា មានសមាសភាពតែមួយគត់នៅក្នុងភាពជាព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់មួយអង្គគត់នេះ គឺជាបុគ្គលិកលក្ខណៈបីយ៉ាង ឬ ព្រះត្រៃឯក។ នៅក្នុងទ្រង់មានព្រះ*បី*អង្គ ៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ អ្នកប្រាជ្ញដែលព្យាយាមរៀបរាប់យ៉ាងក្បោះក្បាយ ពីភាពខុសគ្នាទាំងនេះនៅក្នុងត្រៃឯកភាពពេញលេញ បានប្រើប្រាស់ពាក្យខុសៗគ្នា។ ពាក្យខុសៗគ្នាដែលពួកគេបានប្រើ បានប្រាប់ឲ្យដឹងថា អ្នកប្រាជ្ញទាំងនេះ បានយល់ពីភាពលំបាកក្នុងការរៀបរាប់ពីព្រះត្រៃឯក។ យើងបានកំណត់និយមន័យនៃពាក្យ *បុគ្គល* រួចមកហើយ។ បុគ្គល គឺជាអ្នកដឹង ទទួលអារម្មណ៍ និង ធ្វើការសម្រេចចិត្ត។

បទពិសោធន៍របស់មនុស្សបង្រៀនយើង ថាកន្លែងណាមានមនុស្ស កន្លែងនោះមានសមាសភាពខុសៗគ្នា។ ដូច្នេះ មនុស្សគ្រប់រូបគឺខុសពីគ្នា ហើយការដកចេញភាពជាបុគ្គលដែលមាននៅក្នុងពួកគេបានបង្ហាញឲ្យឃើញពីនិស្ស័យរបស់មនុស្ស។ ប៉ុន្តែនៅក្នុងព្រះបីរួមមកតែមួយ គឺគ្មានបុគ្គលបីផ្សេងៗគ្នាដែលរស់នៅជាមួយគ្នា ឬ អាចចែកដាច់ចេញពីគ្នានោះឡើយ។ ផ្ទុយទៅវិញ មានតែអ្វីម្យ៉ាងដែលយើងអាចហៅថា *ភាពខុសគ្នាកើតឡើងដោយខ្លួនឯង* ដែលមាននៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់ ។ ពាក្យនេះនឹងត្រូវលើកទៅបកស្រាយនៅក្នុងកថាខណ្ឌបន្ទាប់ទៀតនេះ។

២. *តើបុគ្គលម្នាក់ៗនោះគឺជានរណា?*

ដូចដែលយើងបានដឹងហើយថា មានតែព្រះ ឬ អត្ថិភាពបីយ៉ាងតែប៉ុណ្ណោះនៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះទាំងបីព្រះអង្គនេះ ត្រូវបានគេស្គាល់តាមរយៈ*លក្ខណៈសម្បត្តិ* (គុណសម្បត្តិ ឬ លក្ខណៈពិសេសដែលជារបស់បុគ្គលម្នាក់ និង ចម្លែកសម្រាប់បុគ្គលម្នាក់)។ នៅក្នុងបទគម្ពីរ លក្ខណសម្បត្តិទាំងនេះត្រូវបានគេស្គាល់តាមរយៈ ងារ សព្វនាម គុណសម្បត្តិ និង សកម្មភាព ដែលចាំបាច់សម្រាប់ធ្វើការឲ្យហេតុផល សម្រាប់បញ្ជា និង បុគ្គលខុសប្លែកគ្នា។ លក្ខណៈសម្បត្តិផ្ទាល់ខ្លួនទាំងនេះ មានលក្ខណៈដោយឡែកទៅតាមបុគ្គលម្នាក់ៗ

(ទាំងនេះគឺ *ភាពខុសគ្នាកើតឡើងដោយខ្លួនឯង*) ហើយលក្ខណៈសម្បត្តិទាំងនេះ បង្ហាញពីទំនាក់ទំនងរបស់មនុស្សម្នាក់ទៅកាន់អ្នកដទៃផ្សេងទៀត។ ក៏ដូចគ្នាផងដែរ លក្ខណសម្បត្តិនីមួយនៅក្នុងទ្រង់ផ្ទាល់បង្ហាញឲ្យឃើញពីសមាសភាពរបស់ព្រះជាម្ចាស់។

ដូច្នេះ មានព្រះបីអង្គនៅក្នុងត្រៃឯកភាពពេញលេញ៖ ព្រះជាម្ចាស់ព្រះវរបិតា ព្រះជាម្ចាស់ព្រះរាជបុត្រា និង ព្រះជាម្ចាស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះទាំងបីព្រះអង្គមានសារធាតុដូចគ្នា ទ្រង់មានសិរីរុងរឿង ឫទ្ធានុភាព ព្រះតេជៈ និង ភាពអស់កល្បជានិច្ចស្មើគ្នា ហើយទ្រង់គឺជាព្រះតែមួយ។

លំហាត់អនុវត្តន៍

---

៨ ចូរអានបទគម្ពីរនៅខាងក្រោម ហើយសរសេរចម្លើយត្រឹមត្រូវ ក្នុងការបំពេញប្រយោគខាងក្រោមនេះដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) នៅក្នុងគម្ពីរយ៉ូហាន ៦:២៧ ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះជាម្ចាស់ជា.....

ខ) នៅក្នុងគម្ពីរហេប្រឺ ១:៨ ព្រះជាម្ចាស់ព្រះវរបិតា មានព្រះបន្ទូលថាព្រះរាជបុត្រា ជា.....

គ) គម្ពីរកិច្ចការ ៥:៣-៤ ថ្លែងប្រកាសថា អំពើបាបទាស់នឹងព្រះវិញ្ញាណដ៏វិសុទ្ធគឺដូចជាអំពើបាបទាស់នឹង.....

ឃ)តាមរយៈបទគម្ពីរនេះយើងអាចធ្វើការសន្និដ្ឋានបានថានៅក្នុងត្រៃឯកភាពពេញលេញមាន.....

---

៣. *តើមានភស្តុតាងអ្វីសម្រាប់បង្ហាញពីព្រះត្រៃឯក?*

ស្របពេលដែលពាក្យថា *ព្រះត្រៃឯក* គ្មាននៅព្រះគម្ពីរ មានសេចក្តីបង្រៀនជាច្រើនអំពីព្រះត្រៃឯកត្រូវបានបង្ហាញឲ្យឃើញនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ផង និង គម្ពីរសម្ពន្ធមេត្រីថ្មីផង។ ចូរឲ្យយើងបានក្រឡេកទៅមើលពីភស្តុងតាងខ្លះៗ ដែលយើងរកឃើញនៅក្នុងបទគម្ពីរ។

ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ត្រូវបានសរសេរឡើង ជាភាសាហេប្រឺ។ នៅក្នុងភាសាហេប្រឺ ព្រះនាមសម្រាប់ប្រើជាមួយព្រះជាម្ចាស់គឺ *អ៊ីឡូហ៊ីម (Elohim)* ជាទម្រង់ពហុវចនៈ ជាឧទាហរណ៍ នៅក្នុងគម្ពីរលោកុប្បត្តិ ១:២៦ "ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងបង្កើតមនុស្សជាតំណាងរបស់យើង មានលក្ខណៈដូចយើង"។ ខគម្ពីរចង្អុលទៅកាន់ភាពដោយឡែកគ្នាខាងឯអង្គព្រះ នៅក្នុងព្រះជាម្ចាស់ និងទៅកាន់ពហុភាពនៃអង្គព្រះ នៅក្នុងត្រៃឯកភាពពេញលេញ។ យើងរកឃើញភស្តុតាងកាន់តែច្បាស់អំពីភាពដោយឡែកគ្នានៃអង្គព្រះ នៅក្នុងបទគម្ពីរសម្ពន្ធមេត្រីចាស់ ដែលនិយាយអំពីទេវតារបស់ព្រះយេហូវ៉ា។ នៅក្នុងករណីខ្លះ ទេវតារបស់ព្រះអម្ចាស់អាចសំដៅទៅលើសភាវៈមួយប្រភេទដែលត្រូវបានចាត់មកជាអ្នកនាំសាររបស់ព្រះអម្ចាស់ ចំណែកឯនៅក្នុងករណីផ្សេងទៀត ទេវតានោះត្រូវបានគេជឿថា ជាបុត្ររបស់ព្រះជាម្ចាស់ (សូមមើលគម្ពីរលោកុប្បត្តិ ១៦:៧-១៣; ១៨:១-២១; ១៩:១-២៨)។ ដូចនេះ ទេវតានេះក៏ត្រូវបានសំគាល់រួមជាមួយព្រះយេហូវ៉ា ប៉ុន្តែលោកត្រូវបានគេឃើញថាដាច់ដោយឡែក ឬ ខុសពីព្រះយេហូវ៉ា។

មានពេលខ្លះ នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ មាននិយាយអំពីព្រះច្រើនជាងមួយអង្គ (សូមមើលគម្ពីរទំនុកតម្កើង ៤៥:៦-៧ ហើយប្រៀបធៀបជាមួយនឹងគម្ពីរហេប្រឺ ១:៨-៩)។ នៅពេលខ្លះទៀត ព្រះជាម្ចាស់

ដែលជាអ្នកមានព្រះបន្ទូលយ៉ាងច្បាស់នោះ បានមានព្រះបន្ទូលអំពីព្រះមេស្ស៊ី (ព្រះរាជបុត្រា) និង ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរអេសាយ ៤៨:១៦; ៦១:១; ៦៣:៨-១០)។

ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីផ្តល់នូវការបើកបង្ហាញយ៉ាងច្បាស់ អំពីការចាត់ព្រះរាជបុត្រារបស់ទ្រង់មកក្នុងពិភពលោក (គម្ពីរយ៉ូហាន ៣:១៦ គម្ពីរកាឡាទី ៤:៤ គម្ពីរ១យ៉ូហាន ៤:៩)។ គម្ពីរនេះក៏បានបង្ហាញឲ្យឃើញពីព្រះវរបិតា និង ព្រះរាជបុត្រាដែលបានចាត់បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:២៦; ១៥:២៦;១៦:៧)។ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី យើងបានឃើញថា ព្រះវរបិតាមានព្រះបន្ទូលទៅកាន់ព្រះរាជបុត្រា (គម្ពីរម៉ាកុស១:១១ គម្ពីរលូកា៣:២២) ព្រះរាជបុត្រាមានទំនាក់ទំនងជាមួយព្រះវរបិតា (គម្ពីរម៉ាថាយ១១:២៥-២៦ គម្ពីរយ៉ូហាន ១១:៤១; ១២:២៧-២៨) និង ព្រះវិញ្ញាណដ៏វិសុទ្ធអធិស្ឋានទៅកាន់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់អ្នកជឿ (គម្ពីររ៉ូម៨:២៦-២៧) ។ ដូច្នេះ នៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី អង្គព្រះដែលចែកដាច់គ្នានៅក្នុងព្រះត្រៃឯក បានបង្ហាញពីភាពដោយឡែកគ្នារបស់ព្រះជាម្ចាស់នៅចំពោះមុខយើង។

នៅក្នុងបទគម្ពីរខ្លះ មាននិយាយអំពី អង្គព្រះទាំងបីនៃត្រៃឯកភាពពេញលេញតែម្តង។ នៅក្នុងសាច់រឿងនៃការជ្រមុជទឹករបស់ព្រះរាជបុត្រា (គម្ពីរម៉ាថាយ ៣:១៦-១៧) ព្រះវរបិតាមានព្រះបន្ទូលពីស្ថានបរមសុខមក ហើយព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកនៅក្នុងសណ្ឋានជាសត្វព្រាប។ នៅក្នុងសាច់រឿងមហាបេសកម្ម (គម្ពីរម៉ាថាយ ២៨:១៩) ព្រះយេស៊ូបានមានព្រះបន្ទូលអំពីព្រះបីអង្គ៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ។ ការថ្លែងពីព្រះនាមព្រះទាំងបីអង្គនៅជាប់ៗគ្នានេះ ក៏មាននៅក្នុងគម្ពីរ១កូរិនថូស ១២:៤-៦ គម្ពីរ២កូរិនថូស ១៣:១៤ និងគម្ពីរ១ពេត្រុស ១:២ ។ តាមរយៈឧទាហរណ៍ទាំងនេះ យើងអាចរកឃើញភស្តុតាងជាច្រើន សម្រាប់គោលលទ្ធិអំពីព្រះត្រៃឯក។

លំហាត់អនុវត្តន៍

---

៩ ចូរផ្គូផ្គងឃ្លាបង្គ្រប់(ខាងស្តាំ) ទៅនឹងខគម្ពីរយោងដែលត្រឹមត្រូវ (ខាងឆ្វេង)។

.....ក) គម្ពីរលោកុប្បត្តិ ១:២៦ ចង្អុលទៅកាន់.....	១) ព្រះវិញ្ញាណដ៏វិសុទ្ធ
.....ខ) គម្ពីរអេសាយ៦៣:៨-១០ បង្ហាញថាព្រះយេហូវ៉ាមាន ទំនាក់ទំនងជាមួយនឹង.....	២) ព្រះប្រោសលោះ ឬ ព្រះសង្គ្រោះ
.....គ) គម្ពីរយ៉ូហាន ៣:១៦ បង្ហាញថា ព្រះជាម្ចាស់បានចាត់ បញ្ជូនព្រះរាជបុត្រាមកដើម្បីជា.....	៣) ព្រះសង្គ្រោះ និង ព្រះវិញ្ញាណដ៏វិសុទ្ធ
.....ឃ) គម្ពីរយ៉ូហាន១៤:២៦ និង ១៥:២៦ បញ្ជាក់ថាព្រះវរបិតា និង ព្រះរាជបុត្រា បានចាត់បញ្ជូន..... ដែលសណ្ឋិតនៅក្នុងអ្នកជឿ។	៤) អង្គព្រះនៅក្នុងព្រះត្រៃឯក ៥) ពហុភាពនៃអង្គព្រះ
.....ង) គម្ពីរម៉ាថាយ ៣:១៦-១៧ និង ២៨:១៩ បង្ហាញ និង ប្រាប់ពីនាមរបស់.....។	

៤. *តើអ្វីខ្លះជាការលំបាកនៅក្នុងគោលលទ្ធិ?*

ហេតុអ្វីបានជាសេចក្តីបង្រៀនអំពីព្រះត្រៃឯកមានការលំបាកសម្រាប់ឲ្យពួកយើងស្វែងយល់ម្ល៉េះ? នៅក្នុងបទពិសោធន៍ជាមនុស្សយើងគ្មានអ្វី ដើម្បីយកមកប្រៀបធៀប ទៅនឹង*ព្រះត្រៃឯកដែលរួមមកតែមួយ ឬ ការរួមមកតែមួយរបស់ព្រះត្រៃឯក។* យើងដឹងថាគ្មានមនុស្សបីនាក់ផ្សេងគ្នាណា ដែលមានរូបរាងជាមនុស្សតែមួយនោះទេ។ គ្មានមនុស្សបីនាក់ ដែលអាចដឹងពីអ្វីដែលពួកគេធ្វើ និង គិតទៅវិញទៅមកនោះទេ។ បុគ្គលម្នាក់ៗនៅក្នុងចំណោមពួកគេ គឺសុទ្ធតែមានរនាំងផ្ទាល់ខ្លួនរបស់ពួកគេ។ គ្មានមនុស្សណាអាចមាន លក្ខណៈបីរួមមកតែមួយដូចជាព្រះជាម្ចាស់នោះទេ។ មនុស្សមិនបកស្រាយ សេចក្តីបង្រៀនទាក់ទងនឹងព្រះត្រៃឯកបាន ដោយផ្អែកទៅលចំណេះដឹង និង បទពិសោធន៍ជាមនុស្សរបស់ពួកគេបាននោះទេ។

៥. *តើយើងអាចដោះស្រាយការលំបាកនោះបានដោយរបៀបណា?*

បញ្ហាគោលនៅក្នុងការព្យាយាមបកស្រាយអំពីព្រះត្រៃឯក គឺផ្អែកទៅលើទំនាក់ទំនងនៃអង្គព្រះនៅក្នុងត្រៃឯកភាពពេញលេញ ទៅនឹងសមាសភាពរបស់ព្រះជាម្ចាស់ និង ទៅនឹងអង្គព្រះនីមួយៗ ទៅវិញទៅមក។ បញ្ហានេះគឺជាបញ្ហាមួយដែលក្រុមជំនុំមិនអាចដកចេញបាននោះទេ។ ក្រុមជំនុំអាចត្រឹមតែព្យាយាមកាត់បន្ថយបញ្ហាដោយការផ្តល់នូវនិយមន័យសមរម្យទៅឲ្យពាក្យនីមួយៗតែប៉ុណ្ណោះ។ ទោះបីជា ក្រុមជំនុំមិនធ្លាប់បានព្យាយាមបកស្រាយ អាថ៌កំបាំងនៃព្រះត្រៃឯកក៏ដោយ ក៏ពួកគេនៅតែបានព្យាយាមរៀបចំសេចក្តីបង្រៀនយ៉ាងច្បាស់លាស់អំពីការនោះផងដែរ ជាចម្បងគឺដើម្បីលុបបំបាត់កំហុសដែលចោទជាការគំរាមកំហែង ទៅដល់ក្រុមជំនុំទាំងមូលតែម្តង។ តាមរយៈការប្រៀបធៀបបទគម្ពីរ ទៅនឹងបទគម្ពីរ យើងអាចឃើញពីគោលលទ្ធិនៃព្រះត្រៃឯក ក្នុងកម្រិតមួយដែលព្រះជាម្ចាស់បានបើកបង្ហាញពីសេចក្តីបង្រៀននោះនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ទោះបីជាយើងនឹងមិនទាន់អាចស្វែងយល់ពីសេចក្តីបង្រៀនពេញលេញក៏ដោយ។

នៅក្នុងអត្ថិភាព ដែលមានកម្រិត (មានដែនកំណត់)របស់យើង យើងមិនអាចបកស្រាយឲ្យបានក្បោះក្បាយពីភាពគ្មានកម្រិត (ដែលគ្មានដែនកំណត់)បាននោះទេ។ លោកប៉ូលបានរៀបរាប់ភាពមានកម្រិតរបស់មនុស្សមួយនេះ នៅក្នុងសំបុត្រទីមួយរបស់លោកទៅកាន់អ្នកក្រុងកូរិនថូសថា៖ "សព្វថ្ងៃនេះយើងស្គាល់ព្រះជាម្ចាស់មិនច្បាស់ទេ គឺស្គាល់ព្រាលៗដូចជាមើលក្នុងកញ្ចក់ នៅពេលខាងមុខ ទើបយើងឃើញព្រះអង្គទល់មុខគ្នា។ សព្វថ្ងៃ ខ្ញុំស្គាល់ព្រះអង្គបានត្រឹមតែមួយផ្នែកប៉ុណ្ណោះ ពេលខាងមុខទើបខ្ញុំស្គាល់ព្រះអង្គច្បាស់ ដូចព្រះអង្គស្គាល់ខ្ញុំយ៉ាងច្បាស់ដែរ។" (គម្ពីរ១កូរិនថូស ១៣:១២)។

លំហាត់អនុវត្តន៍

---

១០ នៅក្នុងចំណោមប្រយោគខាងក្រោមនេះ ចូររើសរើសប្រយោគណាដែលត្រឹមត្រូវ ដោយយោងទៅតាមបទគម្ពីរដែលទាក់ទងនឹងព្រះត្រៃឯក និង យោងទៅតាមការយល់ដឹងរបស់យើងអំពីព្រះត្រៃឯកនោះ។

ក) ព្រះគម្ពីរបានបង្ហាញពីមានអង្គព្រះចំនួនបីអង្គនៅក្នុងលក្ខណៈវិសេសន៍របស់ព្រះជាម្ចាស់។

ខ) ព្រះទាំងបីអង្គ ដែលមានព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ មានលក្ខណៈដោយឡែកពីគ្នា ដែលបានរៀបរាប់ដោយប្រើប្រាស់ងារ សព្វនាម គុណសម្បត្តិ និង សកម្មភាព ដែលយកទៅប្រើលើអង្គព្រះដោយឡែកផ្សេងគ្នានោះ។

គ) ព្រះគម្ពីរសម័ន្ធមេត្រីចាស់ មិនបានថ្លែងអំពីពហុភាពនៃអង្គព្រះនៅក្នុងត្រៃឯកភាពពេញលេញនោះទេ តែគម្ពីរនេះគ្រាន់តែថ្លែងអំពីព្រះជាម្ចាស់ព្រះយេហូវ៉ាតែប៉ុណ្ណោះ។

ឃ) ព្រះគម្ពីរសម័ន្ធមេត្រីថ្មី បង្ហាញពីអង្គព្រះនៅក្នុងព្រះត្រៃឯក បានពេញលេញជាងព្រះគម្ពីរសម័ន្ធមេត្រីចាស់ទៅទៀត។

ង) ព្រះគម្ពីរសម័ន្ធមេត្រីថ្មី ផ្តល់មូលដ្ឋានគ្រឹះដែលដកស្រង់ពីបទគម្ពីរយ៉ាងគ្រប់គ្រាន់ សម្រាប់គោលិទ្ធិអំពីព្រះត្រៃឯក។

ច) បញ្ហាចម្បង ជាមួយនឹងការយល់ដឹងរបស់យើងអំពីអង្គព្រះទាំងបីអង្គដែលមាននៅក្នុងព្រះជាម្ចាស់ គឺថាយើងគ្មានអ្វីមួយដែលនៅក្នុងបទពិសោធន៍ ដើម្បីធ្វើការប្រៀបធៀបជាមួយភាពដោយឡែកគ្នានៃលក្ខណៈបីរួមមកតែមួយរបស់ព្រះជាម្ចាស់បានឡើយ។

ឆ) យើងអាចដោះស្រាយបញ្ហាអំពីព្រះត្រៃឯកបានយ៉ាងល្អ តាមរយៈការដឹងថា ដោយបញ្ហានេះមិនអាចបកស្រាយបានយ៉ាងពេញលេញ យើងមិនគួរព្យាយាមបង្កើតគោលលទ្ធិ (សេចក្តីបង្រៀន) អំពីបញ្ហានេះសោះឡើយ។

ការសិក្សាយ៉ាងយកចិត្តទុកដាក់ទៅលើព្រះបន្ទូល បង្ហាញឲ្យយើងបានឃើញយ៉ាងច្រើនអំពីភាពបីរួមមកតែមួយរបស់ព្រះជាម្ចាស់។ ការសិក្សាប្រកបដោយការផ្ចង់ចិត្ត ទៅលើគោលិទ្ធិនេះ ជួយឲ្យយើងយល់ដឹងកាន់តែប្រសើរឡើងអំពី ការបើកបង្ហាញរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ ទោះបីជាការយល់ដឹងបានត្រឹមតែមួយផ្នែកក៏ដោយ។ វាក៏ជួយយើងឱ្យយល់កាន់តែច្បាស់អំពីលក្ខណៈនៃព្រះ និងមធ្យោបាយដែលទ្រង់បានផ្តល់សម្រាប់យើងដើម្បីចូលទៅរកទ្រង់ដោយសេចក្តីស្រឡាញ់ ការថ្វាយបង្គំ និងការបម្រើដោយលះបង់។

ព្រះជាម្ចាស់គឺជាព្រះដែលមានភាពអស់កល្បជានិច្ច

វត្ថុបំណងទី៥. បង្ហាញពីការជាប់ពាក់ព័ន្ធសម្រាប់គ្រិស្តបរិស័ទទៅនឹងភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់។

មានមនុស្សជាច្រើននាក់ ចាប់អារម្មណ៍ទៅលើការស្វែងរកឲ្យដឹងថាតើដូនតារបស់ពួកគេមកពីណា។ តើអ្នកនឹងគិតយ៉ាងណាដែរ ប្រសិនបើខ្ញុំប្រាប់អ្នកថាខ្ញុំគ្មានដូនតានោះទេ។ អ្នកអាចនឹងមិនទទួលស្គាល់ការនោះថាជាការពិតនោះទេ ហើយអ្នកពិតជាត្រឹមត្រូវហើយ។ ខ្ញុំក៏មានដូនតា ដូចជាមនុស្សគ្រប់គ្នាដែរ។

ខ្ញុំសូមនិយាយថា មនុស្សគ្រប់គ្នាសុទ្ធតែមានដូនតារៀងៗខ្លួន ប៉ុន្តែខ្ញុំមិនរាប់បញ្ចូលព្រះជាម្ចាស់នៅក្នុងចម្លើយនោះទេ។ ទ្រង់គ្មានដូនតាអ្វីឡើយ។ ដូច្នេះ តើទ្រង់មានប្រភពកំណើតមកពីណា? សំណួរនេះមានចម្លើយដ៏សាមញ្ញមួយ។ ទ្រង់គ្មានប្រភពកំណើតអ្វីនោះទេ! ទ្រង់បានមានព្រះជន្មគង់នៅ រហូតមក ហើយ តាំងពីដរាបមកម្ល៉េះ។ ហេតុនោះហើយបានជាយើងអាចនិយាយបានថា *ព្រះជាម្ចាស់គឺព្រះដែលមានភាពអស់កល្បជានិច្ច*។

១. *តើអ្វីជាភាពអស់កល្បជានិច្ច?*

ការស្រមៃគិតពីអនាគតដែលគ្មាននរណាម្នាក់អាចដឹង ជាការពិបាកសម្រាប់យើងខ្លាំងណាស់ ប៉ុន្តែយើងប្រហែលជាអាចគិតស្រមៃត្រឡប់ទៅរកអតីតកាលឲ្យបានឆ្ងាយតាមតែគំនិតរបស់យើងអាចគិតដល់ ហើយព្យាយាមគិតពីភាពអស់កល្បជានិច្ច។ យើងចាត់ទុកថាគម្ពីរលោកុប្បត្តិជាគម្ពីរអំពីការចាប់ផ្តើម ។ នៅក្នុងគម្ពីរនេះ យើងសិក្សាអំពីទីចាប់ផ្តើមនៃរបស់សព្វសារពើ ការចាប់ផ្តើមរបស់មនុស្សជាតិ និង ការចាប់ផ្តើមនៃប្រជាជាតិទាំងអស់។ ប៉ុន្តែការចាប់ផ្តើមដ៏នៅសែនឆ្ងាយនេះ មិនមែនជា*ការចាប់ផ្តើមដំបូងបង្អស់*នោះទេ។

យើងអាចត្រឡប់ទៅមើលពីអតីតកាលកាន់តែឆ្ងាយថែមទៀត ជាពេលដែលទេវតាត្រូវបានបង្កើតឡើង គឺបុត្រដ៏ពិសេស នៅស្ថានសួគ៌(ស្ថានបរមសុខ) របស់ព្រះជាម្ចាស់ ដែលស្រែកឡើងទាំងអំណរ នៅកាលដែលគ្រឹះនៃផែនដីបានចាក់ឡើង តាំងពីមុនការចាប់ផ្តើមនៃប្រវត្តិសាស្ត្រ (គម្ពីរយ៉ូប ៣៨:៤-៧)។ នោះក៏មិនមែនជាការចាប់ផ្តើមដំបូងបង្អស់នោះដែរ។ នៅក្នុងគំនិតរបស់យើង យើងប្រហែលជាយល់ឃើញថាភាពអស់កល្បជានិច្ច គឺជាភាពមិនចេះចប់មិនចេះហើយ គ្មានដែនកំណត់ (គ្មានព្រំដែន) ដែលរបស់សព្វសារពើមានតែនៅក្នុងព្រះតម្រិះរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ នេះហើយដែលជាគំនិតដែលមានកម្រិត (មានដែនកំណត់) របស់យើង ដែលឃើញថា ការស្វែងយល់ពីគំនិតនៃភាពមិនចេះចប់ចេះហើយគ្មានកម្រិត ឬ គ្មានដែនកំណត់ គឺមិនអាចទៅរួចនោះទេ។ ការពិត គឺថាភាពអស់កល្បជានិច្ច គឺជាទំនាក់ទំនងដ៏គ្មានព្រំដែនរបស់ព្រះជាម្ចាស់ជាមួយនឹងពេលវេលា។

២. *តើអ្នកណាបានរស់នៅក្នុងភាពអស់កល្បជានិច្ច?*

មនុស្ស និង ទេវតាគឺជាភាវៈដែលព្រះជាម្ចាស់បានបង្កើតមក ប៉ុន្តែមានតែទ្រង់មួយប៉ុណ្ណោះ ជាព្រះដែលគ្មានទីចាប់ផ្តើម។ ដូច្នេះ មានតែទ្រង់ប៉ុណ្ណោះដែលអាចគង់នៅក្នុងភាពអស់កល្បជានិច្ចបាន។ យើងមានអតីតកាល មានបច្ចុប្បន្នកាល និង អនាគតកាល ប៉ុន្តែព្រះជាម្ចាស់គង់នៅតែក្នុងបច្ចុប្បន្នកាលតែប៉ុណ្ណោះ។ ទាំងអតីតកាល និង អនាគតកាលគឺដូចជា *ពេលឥឡូវនេះ* សម្រាប់ទ្រង់។

ព្រះជាម្ចាស់គឺជាភាពអស់កល្បជានិច្ចនៅក្នុងរបៀបពីរយ៉ាង៖ ទី១) ទ្រង់មិនដែលមានការចាប់បដិសន្ធិ អ្វីឡើយ ទ្រង់មានព្រះវត្តមានតាំងពីដើមមក (គម្ពីរទំនុកតម្កើង ៩០:២) ។ ទី២ អត្ថិភាពរបស់ទ្រង់នឹងគ្មានទីបញ្ចប់ឡើយ (គម្ពីរទុតិយកថា ៣២:៤០ គម្ពីរទំនុកតម្កើង ១០២:២៧) ។ ដោយព្រះជាម្ចាស់ជាភាពអស់កល្បជានិច្ច ទ្រង់គ្មានវិវឌ្ឍទៅតាមពេលវេលានោះទេ។

៣. *តើយើងអាចយល់ពីគំនិតដែលថាព្រះជាម្ចាស់ជាភាពអស់កល្បជានិច្ចបានយ៉ាងដូចម្តេច?*

ក្រៅពីការយោងតាមបទគម្ពីរ យើងអាចធ្វើការសន្និដ្ឋានថា ព្រះជាម្ចាស់តែងតែមានព្រះវត្តមាន បានព្រោះតែមានគំនិតបែបតក្កវិជ្ជា។ មនុស្សគ្រប់គ្នាដឹងថា របស់មួយមិនអាចកើតឡើងចេញពីភាពទទេនោះ

ទេ។ សុញ្ញាអាកាស មិនអាចបង្កើតបានរបស់អ្វីមួយឡើយ។ ដូច្នេះ ប្រសិនបើនៅទីចាប់ផ្តើមនៃចក្រវាឡ គ្មានអ្វីទាល់តែសោះ និងប្រសិនបើមានតែសុញ្ញាអាកាសប៉ុណ្ណោះ អ៊ុចឹងចក្រវាឡទាំងមូលនឹងនៅមានតែប៉ុននោះទេ។ ប៉ុន្តែដោយហេតុតែ នៅពេលដែលយើងសង្កេតមើលទៅចក្រវាឡទាំងមូលដែលនៅជុំវិញយើង យើងក៏ត្រូវតែទទួលស្គាល់ ដោយផ្អែកលើតក្កភាពទៅលើការសន្និដ្ឋានដែលថា មានរបស់ម្យ៉ាងនៅអតីតកាល មិនដែលមានទីចាប់ផ្តើមនោះទេ ហើយរបស់នោះមានវត្តមានតាំងពីដើមមក។ *របស់ម្យ៉ាង* នោះគឺជាព្រះជាម្ចាស់!

ភាពអស់កល្បរបសព្រះជាម្ចាស់ គឺត្រូវបានបង្ហាញឲ្យឃើញ នៅពាសពេញបទគម្ពីរ។ ព្រះជាម្ចាស់ត្រូវបានបទគម្ពីរថ្វាយនាមថា ព្រះដ៏គង់នៅអស់កល្បជានិច្ច (គម្ពីរលោកុប្បត្តិ ២១:៣៣)។ អ្នកនិពន្ធ បានថ្លែងថា "ព្រះអង្គជាព្រះជាម្ចាស់តាំងពីអស់កល្បរៀងមក" (គម្ពីរទំនុកតម្កើង ៩០:២) ហើយថ្លែងថា "ព្រះអង្គនៅតែដដែល ព្រះជន្មាយុរបស់ព្រះអង្គគ្មានទីបញ្ចប់ទេ" (គម្ពីរទំនុកតម្កើង ១០២:២៧)ពាក្យពេចន៍ដ៏គួរឲ្យជំរុញចិត្តរបស់លោកអេសាយបានចែងថា ព្រះជាម្ចាស់គឺជាព្រះតែមួយអង្គគត់ "ដែលគង់នៅអស់កល្បជានិច្ច" (គម្ពីរអេសាយ ៥៧:១៥) ក្នុងពេលជាមួយគ្នា លោកប៉ូលអះអាងប្រាប់លោកធីម៉ូថេថា ព្រះជាម្ចាស់តែមួយគត់ ជាប្រភពនៃភាពអមតៈ (គម្ពីរ១ធីម៉ូថេ ៦:១៦)។

លំហាត់អនុវត្តន៍

---

១១ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) ភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ បានផ្តល់ឲ្យយើងនូវទំនុកចិត្ត ដែលដឹងថាព្រះមួយអង្គដែលយើងជឿនឹងមិនបាត់ទៅណាឡើយ។

ខ) ភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ លើកទឹកចិត្តយើង នៅពេលយើងមានការលំបាក។ យើងដឹងថាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលតែងតែស្ថិតស្ថេរនៅ នឹងបន្តស្ថិតស្ថេរនៅជារៀងរហូត។ បំណងព្រះហឫទ័យទាំងនេះ រួមបញ្ចូលទាំងបំណងព្រះហឫទ័យដែលទាក់ទងនឹងជីវិតរបស់យើងផ្ទាល់ផងដែរ។

គ) ការយល់ដឹងអំពីភាពគ្មានដែនកំណត់របស់ព្រះជាម្ចាស់ ដោយធៀបជាមួយនឹងពេលវេលា ធ្វើឲ្យយើងដឹងថាការសម្រេចចិត្តផ្ទាល់ខ្លួនរបស់យើង គឺមិនសំខាន់នោះទេ ព្រោះការទាំងនោះគឺផ្អែកតែទៅលើពេលវេលាតែប៉ុណ្ណោះ។

ព្រះជាម្ចាស់ទ្រង់ខ្ជាប់ខ្ជួន (មិនប្រែប្រួល)

វត្ថុបំណងទី៦. *ប្រាប់អំពីអត្ថន័យនៃភាពមិនចេះប្រែប្រួលរបស់ព្រះជាម្ចាស់ សម្រាប់អ្នកទៅតាមការយល់ដឹង និង បទពិសោធន៍ជាគ្រិស្តបរិស័ទរបស់អ្នក។*

យើងរាល់គ្នាមានកំហុសដែលត្រូវការការកែប្រែ ឬ ការកែតម្រូវ ប៉ុន្តែព្រះជាម្ចាស់គឺមិនមានកំហុសអ្វីនោះទេ។ ទ្រង់គឺល្អឥតខ្ចោះ។ទ្រង់មិនត្រូវការអ្វីមួយមកបំពេញលក្ខណសម្បត្តិ ឬ គុណលក្ខណៈរបស់ទ្រង់នោះទេ។ ទ្រង់គឺល្អឥតខ្ចោះ គ្រប់ផ្នែកទាំងអស់។

លំហាត់អនុវត្តន៍

១២ ចូរអានបទគម្ពីរខាងក្រោម ហើយធ្វើការបំពេញប្រយោគ។

ក) នៅក្នុងគម្ពីរទំនុកតម្កើង ១០២:២៥-២៧ .....ដែលមិនប្រែប្រួលរបស់យើងគឺផ្ទុយជាមួយនឹង.....ដែលតែងតែប្រែប្រួល។

ខ) គម្ពីរអេសាយ ៤៦:៩-១០ គម្ពីរទំនុកតម្កើង៣៣:១១ និងគម្ពីរទំនុកតម្កើង ១១៩:១៦០ បង្ហាញថា ព្រះជាម្ចាស់គឺមិនប្រែប្រួលសោះឡើយ ទៅលើ..... និង .....របស់ទ្រង់។

គ) គម្ពីរម៉ាឡាគី ៣:៦ បញ្ជាក់ថា ដោយព្រោះតែព្រះជាម្ចាស់មិនដែលផ្លាស់ប្តូរ ទ្រង់នឹងមានព្រះហឫទ័យមេត្តាករុណាទៅលើកូនចៅរបស់លោកយ៉ាកុប ដើម្បីកុំឲ្យពួកគេត្រូវបាន..... .....។

ឃ) គម្ពីរទំនុកតម្កើង ១០៣:១៧ និយាយអំពី.....និង ..... ដែលមិនប្រែប្រួលរបស់ព្រះជាម្ចាស់។

បទគម្ពីរដែលមានចែងអំពីភាពខ្ជាប់ខ្ជួន ឬ និស្ស័យមិនប្រែប្រួលរបស់ព្រះជាម្ចាស់ បង្រៀនយើងអំពីគោលការណ៍ដ៏ច្បាស់លាស់អំពីព្រះជាម្ចាស់ដែលយើងបម្រើ។ លោក ធាសិន (Thiessen) [1] បង្ហាញអំពីគោលការណ៍ទាំងនេះ (១៩៧៩, ៨៣) ហើយយើងនឹងរៀបរាប់គោលការណ៍ទាំងនេះ ដើម្បីជួយឲ្យអ្នកឃើញកាន់តែច្បាស់ថែមទៀត៖

១. ដោយព្រះជាម្ចាស់ទ្រង់គ្មានទីបញ្ចប់ កើតឡើងដោយអង្គឯង និង ឯករាជ្យ ទ្រង់គឺលើសផុតពីបុព្វហេតុ និង លទ្ធភាពនៃការប្រែប្រួល។

២. ព្រះជាម្ចាស់មិនអាចត្រូវ ដំឡើង ឬ បញ្ចុះបាននោះទេ ហើយទ្រង់ក៏មិនត្រូវបានដាក់ឲ្យរងការអភិវឌ្ឍបន្ថែមទៀតផងដែរ។

៣. ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ មិនអាចកើនកាន់តែច្រើនឡើង ឬ ចុះកាន់តែតិចជាងនេះឡើយ ហើយទ្រង់មិនអាចមានព្រះប្រាជ្ញាញាណជាងនេះ ឬ វិសុទ្ធជាងនេះឡើងដែរ។

៤. ព្រះជាម្ចាស់ មិនអាចកាន់តែយុត្តិធម៌ មានក្តីមេត្តាករុណា និង ប្រកបដោយក្តីស្រឡាញ់ជាងអ្វីដែលទ្រង់មានពីមុន ឬ នឹងមាននៅថ្ងៃអនាគតផងដែរ។

៥. ទ្រង់មិនអាចផ្លាស់ប្តូរទំនាក់ទំនងរវាងទ្រង់ជាមួយមនុស្សបាននោះទេ ។ ទ្រង់បំពេញព្រះរាជ្យកិច្ចដោយផ្អែកទៅតាមគោលការណ៍ដ៏អស់កល្បដែលមិនអាចត្រូវ កែប្រែទៅតាមការផ្លាស់ប្តូរប្រចាំថ្ងៃនោះទេ។

ដោយសារតែព្រះជាម្ចាស់ មិនប្រែប្រួល យើងអាចផ្ញើជីវិតរបស់យើងទាំងស្រុងទៅលើទ្រង់ដូចដែលយើងបានពឹងផ្អែកទៅលើព្រះបន្ទូលរបស់ទ្រង់ដែរ។ យើងអាចប្រឈមមុខជាមួយនឹងស្ថានភាពនៅក្នុងជីវិតគ្រប់ទាំងអស់ ប្រកបដោយទំនុកចិត្ត ដោយដឹងច្បាស់ថា ទ្រង់ធ្វើកិច្ចការគ្រប់បែបយ៉ាងគឺដើម្បីផលល្អរបស់យើង (គម្ពីររ៉ូម៨:២៨)។

អ្នកប្រហែលជាបានកត់សំគាល់ពីបទគម្ពីរ ដូចជាគម្ពីរជនគណនា ២៣:១៩និង គម្ពីរ ១សាំយូអែល ១៥:២៩ ដែលបានថ្លែងថា ព្រះជាម្ចាស់មិនផ្លាស់ប្តូរព្រះតម្រិះរបស់ព្រះអង្គឡើយ ហើយបទគម្ពីរផ្សេងៗទៀតបែរជាថ្លែងថាទ្រង់ បានបន្ទូរបន្ថយ ឬ សោកស្តាយចំពោះរឿងអ្វីមួយដែលទ្រង់បានធ្វើ (គម្ពីរ១សាំយូអែល ១៥:១១ គម្ពីរយ៉ូណាស ៣:៩-១០) ។ ឥរិយាបថរបស់ព្រះជាម្ចាស់នេះ មិនបង្ហាញឲ្យឃើញពីការផ្លាស់ប្តូរជាមូលដ្ឋានទៅលើលក្ខណសម្បត្តិ ឬ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ ។ ទ្រង់តែងតែមិនគាប់ព្រះហឫទ័យចំពោះអំពើបាប ហើយទ្រង់តែងតែគាប់ព្រះហឫទ័យចំពោះមនុស្សមានបាប។ ឥរិយាបថនេះ គឺនៅតែជាការពិត មិនថាមុនពេល ឬ ក្រោយពេលមនុស្សមានបាបធ្វើការលន់តួនោះទេ។ ទោះជាយ៉ាងណា ព្រះជាម្ចាស់អាចនឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ទ្រង់ទៅតាមការជាក់ស្តែងនៃការផ្លាស់ប្តូររបស់មនុស្ស។

---

1 Thiessen, Henry C. Lectures in Systematic Theology. Grand Rapids, MI; Eerdmans, 1979

ឧទាហរណ៍មួយសម្រាប់ការនេះ យើងឃើញថាឥរិយាបថរបស់ព្រះជាម្ចាស់ទៅលើអំពើបាបរបស់សាសន៍អ៊ីស្រាអែល គ្មានការប្រែប្រួលនោះទេ។ ទ្រង់មិនសព្វព្រះហឫទ័យចំពោះអំពើបាបរបស់សាសន៍នេះឡើយ។ ដោយសារប្រជារាស្ត្ររបស់ទ្រង់នៅតែចេសបន្តប្រព្រឹត្តិអំពើបាប ពួកគេបានទទួលការដាក់ទោសសម្រាប់អំពើបាបរបស់ពួកគេ។ ទោះជាយ៉ាងណា នៅពេលដែលពួកគេបានលន់តួ ហើយផ្តាច់ខ្លួនចេញពីការប្រព្រឹត្តិអំពើបាបរបស់ពួកគេ អាកប្បកិរិយារបស់ព្រះជាម្ចាស់ទៅលើពួកគេក៏បានផ្លាស់ប្តូរផងដែរ។

មានមនុស្សម្នាក់បាននិយាយថា ព្រះអាទិត្យមិនដែលបង្ហាញភាពលំអៀង ឬ ការប្រែប្រួលនៅទៅលើការរំលាយក្រមួន និង ធ្វើឲ្យដីឥដ្ឋរឹងនោះទេ ដ្បិតការផ្លាស់ប្តូរគឺមិនមែននៅក្នុងព្រះអាទិត្យនោះឡើយ តែវាស្រេចទៅតាមវត្ថុធាតុដែលព្រះអាទិត្យចាំងជះរស្មីទៅលើតែប៉ុណ្ណោះ។ យើងអាចផ្អែកលើភាពខ្ជាប់ខ្ជួននៃបំណងព្រះហឫទ័យ ព្រះបន្ទូល និង និស្ស័យរបស់ព្រះជាម្ចាស់បាន។ ដូចដែលព្រះអាទិត្យរំលាយក្រមួន និងធ្វើឲ្យដីឥដ្ឋរឹង ភាពខ្ជាប់ខ្ជួនរបស់ព្រះជាម្ចាស់ធ្វើឡើងដើម្បីតែផលល្អរបស់អស់អ្នកដែលបានបន្ទន់ចិត្តដើម្បីជាការឆ្លើយតបដែលគាប់ព្រះហឫទ័យរបស់ទ្រង់ និង សម្រាប់កំទេច អស់អ្នកដែលមានដួងចិត្តមិនឆ្លើយតបគាប់ព្រះហឫទ័យទ្រង់ តែបែបជារឹងទទឹងទៅវិញ។

លំហាត់អនុវត្តន៍

---

១៣ ដើម្បីរំឭកពីគុណសម្បត្តិនៃនិស្ស័យរបស់ព្រះជាម្ចាស់ ដែលមានបកស្រាយនៅក្នុងផ្នែកមួយនេះ ចូរផ្គូផ្គង់គុណសម្បត្តិនីមួយៗ (ខាងស្តាំ) ទៅនឹងការរៀបរាប់របស់គុណសម្បត្តិនោះ (ខាងឆ្វេង)។

.....ក) មានសភាពជាសារធាតុ និង សមាសភាពតែមួយ	១) បុគ្គលិកលក្ខណៈ
.....ខ) មិនចេះចប់មិនចេះហើយ គ្មានទីចាប់ផ្តើម ឬទីបញ្ចប់	២) ភាពជាវិញ្ញាណ

.....គ) មានភាពគ្មានដែនកំណត់ទៅលើទម្រង់ ឬ រូបធាតុដើម។
.....ឃ) ពហុភាពនៃបុគ្គល (អង្គ)។
.....ង) ភាពដូចគ្នាទៅលើបំណង ពាក្យពេចន៍ និង លក្ខណសម្បត្តិ។
.....ច) ភាពដែលអាចគិត ទទួលអារម្មណ៍ និង សម្រេចចិត្តបាន។

៣) ភាពរួបរួម
៤) ព្រះត្រៃឯក
៥) ភាពអស់កល្បជានិច្ច
៦) ភាពខ្ជាប់ខ្ជួន

ខ. គុណលក្ខណៈធម្មជាតិរបស់ព្រះជាម្ចាស់

វគ្គបំណែងទី៧. *រៀបរាប់ និង កំណត់ន័យគុណលក្ខណៈរបស់ព្រះជាម្ចាស់។*

យើងហៅអស់អ្នកដែលមានជំនាញទៅលើការសិក្សាអំពីព្រះជាម្ចាស់ថា *សាសនវិទូ។*អ្នក និង ខ្ញុំ ប្រហែលជាមិនអាចចាត់ទុកជាសាសនវិទូបាននោះទេ ប៉ុន្តែយើងមានសិទ្ធិដើម្បីសិក្សា និង វិភាគអំពីគោលលទ្ធិ ឬសេចក្តីបង្រៀនអំពីព្រះជាម្ចាស់ ដើម្បីឲ្យយើងអាចយល់ពីទ្រង់កាន់តែច្បាស់ និងស្រឡាញ់ទ្រង់កាន់តែច្រើនឡើង។ ជារឿងដ៏សំខាន់ ដែលយើងមិនត្រូវពិចារណាតែទៅលើនិស្ស័យរបស់ទ្រង់នោះទេ ប៉ុន្តែយើងត្រូវពិចារណាអំពីលក្ខណសម្បត្តិរបស់ទ្រង់ផងដែរ នៅក្នុងដំណើរផ្សងព្រេងដើម្បីស្គាល់ទ្រង់កាន់តែប្រសើរមួយនេះ។ សាសនវិទូបានហៅលក្ខណសម្បត្តិទាំងនេះថា *គុណលក្ខណៈ (attributes)* ។ គុណលក្ខណៈសាមញ្ញ គឺសំដៅទៅលើគុណសម្បត្តិទាំងឡាយណាដែលទាក់ទងនឹង ឬ រៀបរាប់អំពីនរណាម្នាក់ ឬ អ្វីមួយ ហើយនៅក្នុងករណីនេះ គឺព្រះជាម្ចាស់នោះឯង។ គុណលក្ខណៈរបស់ព្រះជាម្ចាស់បកស្រាយពីមូលហេតុដែលទ្រង់ធ្វើអ្វីដែលទ្រង់ធ្វើ ដូច្នេះយើងអាចដឹងពីអ្វីដែលយើងរំពឹងទុកពីទ្រង់។ គុណលក្ខណៈរបស់ព្រះជាម្ចាស់រួមមាន សព្វានុភាព សព្វត្ថិភាព សព្វញ្ញុតញ្ញាណ និង ព្រះប្រាជ្ញាញាណ។ ដំបូងយើងនឹងពិចារណាទៅលើ សព្វានុភាពរបស់ព្រះជាម្ចាស់ជាមុនសិន។

សព្វានុភាពរបស់ព្រះជាម្ចាស់

ភរិយារបស់លោកអប្រាហាំ លោកស្រីសារ៉ាយ បានធ្វើដំណើរជាច្រើនលើកច្រើនសានៅក្នុងជីវិតរបស់លោកស្រី។ លោកស្រីបានឃើញព្រះយេហូវ៉ាធ្វើការអស្ចារ្យ និង គួរឲ្យស្ងប់ស្ងែងជាច្រើនសម្រាប់ប្តីរបស់លោកស្រី និង លោកស្រីផ្ទាល់។ លោកស្រីមានសម្រស់ដែលអាចយកឈ្នះការប្រកួតប្រជែងភាពស្រស់ស្អាតបានកាលលោកស្រីនៅជាកូនក្រមុំទើបរៀបការ ប៉ុន្តែមកដល់ពេលនេះ ស្ត្រីចំណាស់មានស្បែកជ្រួញម្នាក់នេះ អង្គុយចុះក៏ត្រូវប្រុងប្រយ័ត្នដែរ។ លោកស្រីបានសើច នៅពេលដែលលោកស្រីបានឮថាមានបុរសបីនាក់បានប្រាប់ប្តីលោកស្រីថា លោកស្រីនឹងមានផ្ទៃពោះឆាប់ៗ។ មិនអាចទៅរួចទេ! តើអ្នកគួរតែបន្ទោសលោកស្រីសារ៉ាយចំពោះការដែលលោកស្រីសើចនោះដែរឬទេ? ប៉ុន្តែបុរសទាំងបីដែលមកពីស្ថានបរមសុខនោះបានសួរថា៖ "តើមានការអ្វីអស្ចារ្យពេកដែលព្រះអម្ចាស់ធ្វើមិនកើត?" (គម្ពីរលោកុប្បត្តិ ១៨:១-១៥)។

តើលក្ខណសម្បត្តិជាព្រះ ណាមួយដែលព្រះអម្ចាស់បានរំឭកទៅដល់លោកអប្រាហាំ និង លោកស្រីសារ៉ាយ? សព្វានុភាពរបស់ទ្រង់ ជាការពិតដែលថាទ្រង់មានគ្រប់ព្រះចេស្តា ឬ គ្រប់ឫទ្ធានុភាព។ ទ្រង់

អាចធ្វើអ្វីៗគ្រប់បែបយ៉ាង! ឫទ្ធានុភាពដ៏ពេញបរិបូរណ៌របស់ព្រះជាម្ចាស់មួយនេះបានបង្ហាញឲ្យយើងឃើញនៅក្នុងបទគម្ពីរ ទាក់ទងនឹង៖

១. ការបង្កើត (គម្ពីរលោកុប្បត្តិ ១:១)
២. ការទ្រទ្រង់របស់គ្រប់យ៉ាងដោយព្រះបន្ទូលដ៏មានឫទ្ធានុភាពរបស់ទ្រង់ (គម្ពីរហេប្រឺ១:៣)
៣. ការព្រោសលោះមនុស្ស (គម្ពីរលូកា ១:៣៥, ៣៧)
៤. ការអស្ចារ្យ (គម្ពីរលូកា ៩:៤៣)
៥. ការសង្គ្រោះមនុស្សមានបាប (គម្ពីរ១កូរិនថូស ២:៥ គម្ពីរ២កូរិនថូស ៤:៧)
៦. ការសម្រេចបំណងព្រះហឫទ័យរបស់ព្រះអង្គសម្រាប់នគររបស់ព្រះអង្គ(គម្ពីរ១ពេត្រុស ១:៥)

យើងត្រូវតែចងចាំថា ទោះបីជាព្រះជាម្ចាស់មិនអាចធ្វើរឿងដែលមិនសមហេតុផល (រឿងដែលគួរឲ្យអស់សំណើច ឬ គ្មានហេតុផល) ដូចជាបង្កើតទឹកដែលសួត ។ ទ្រង់ក៏មិនធ្វើអ្វីដែលមិនសមស្របទៅនឹងនិស្ស័យរបស់ទ្រង់ផងដែរ។

ការពិតមួយដែល មានភាពស្របទៅតាមនិស្ស័យរបស់ព្រះជាម្ចាស់គឺ ការពិតដែលថាទ្រង់អាចកំណត់ការប្រព្រឹត្តិទៅនៃឫទ្ធានុភាពរបស់ទ្រង់ ប្រសិនបើទ្រង់សព្វព្រះហឫទ័យ។ ជាឧទាហរណ៍ ព្រះជាម្ចាស់ប្រទានមនុស្សម្នាក់ៗ នូវសេរីភាពក្នុងការជ្រើសរើស រវាងទ្រង់នឹងសាតាំង។ ព្រះជាម្ចាស់មិនបង្ខិតបង្ខំមនុស្សឲ្យបម្រើទ្រង់ ទាស់នឹងឆន្ទៈផ្ទាល់ខ្លួនរបស់ពួកគេនោះទេ។ទ្រង់កំណត់អង្គទ្រង់ដើម្បីអនុញ្ញាតឲ្យមនុស្សធ្វើការសម្រេចចិត្តដោយខ្លួនឯង។

គម្ពីរយេរេមា ៣២:១៧ ថ្លែងទៅកាន់ ព្រះអម្ចាស់ថា៖ "ព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដីដោយមហិទ្ធិឫទ្ធិ និងព្រះបារមីរបស់ព្រះអង្គ។ តើមានការអស្ចារ្យអ្វីដែលព្រះអង្គធ្វើមិនកើត?" ក្រោយមកទៀតព្រះអម្ចាស់បានមានព្រះបន្ទូលសួរទៅកាន់លោកយេរេមាថា៖ "តើមានការអ្វីដែលពិបាកពេកដល់អញដែរឬ?"(ខ២៧ នៃគម្ពីរបកប្រែឆ្នាំ១៩៥៤)។ នៅពេលយើងយល់ពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៃយើងហើយ យើងមិនគួរមានភាពស្ទាក់ស្ទើរក្នុងការទៅសូមជំនួយពីទ្រង់ នៅក្នុងគ្រប់កាលៈទេសៈដែលយើងប្រឈមមុខម្តងទៀតឡើយ។

លំហាត់អនុវត្តន៍

១៤ ចូរអានគម្ពីរនិក្ខមនំ៣:១១-១២ តើអ្វីជាពាក្យទាំងប្រាំម៉ាត់ដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកម៉ូសេដើម្បីរំឭកលោកពីសព្វានុភាពរបស់ទ្រង់?

.....

សព្វត្ថិភាពរបស់ព្រះជាម្ចាស់

ក្មេងតូចម្នាក់ចង់ធ្វើរឿងអាក្រក់មួយ ប៉ុន្តែគេសម្រេចចិត្តថា គេគួរតែចូលទៅក្រោមដំបូលផ្ទះដើម្បីធ្វើរឿងនោះ ដើម្បីនៅពេលដែលព្រះជាម្ចាស់ទតមើលពីលើស្ថានសួគ៌មក មិនឃើញអ្វីដែលគេកំពុងធ្វើ។ តើលក្ខណសម្បត្តិជាព្រះណាមួយដែលក្មេងតូចម្នាក់មិនបានដឹង? ការពិតដែលថាព្រះជាម្ចាស់គឺ សព្វត្ថិភាព មានន័យថា ទ្រង់គឺគង់នៅគ្រប់ទីកន្លែងគ្រប់ពេលវេលា។ អ្នកនិពន្ធបាននិយាយអំពីការនេះ នៅក្នុងគម្ពីរទំនុកតម្កើង ១៣៩:៧-១០៖

តើទូលបង្គំអាចទៅណាឆ្ងាយពីព្រះអង្គបាន? តើទូលបង្គំគេចចេញអោយឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គដូចម្តេចបាន? បើទូលបង្គំឡើងទៅលើមេឃព្រះអង្គគង់នៅទីនោះបើទូលបង្គំទៅនៅស្ថានមនុស្សស្លាប់ក៏ព្រះអង្គនៅទីនោះដែរ។ ទោះបីទូលបង្គំពាក់ស្លាបហោះទៅកន្លែងព្រះអាទិត្យរះឬទោះបីទូលបង្គំទៅរស់នៅខាងនាយសមុទ្រក្តី ក៏ព្រះអង្គគង់នៅទីនោះ ដើម្បីដឹកនាំទូលបង្គំហើយជួយទូលបង្គំ ដោយព្រះបារមីរបស់ព្រះអង្គ។

សព្វត្ថិភាពរបស់ព្រះជាម្ចាស់មិនមែនមានន័យថា ទ្រង់មានទំនាក់ទំនងដូចគ្នានេះ ជាមួយមនុស្សគ្រប់គ្នានោះទេ។ ទ្រង់នឹងបង្ហាញអង្គទ្រង់ ទ្រង់នឹងប្រទានពរ និង លើកទឹកចិត្តអស់អ្នកណាដែលស្រឡាញ់ និង បម្រើទ្រង់ ប៉ុន្តែទ្រង់នឹងស្តីបន្ទោស និង ដាក់ទោសអ្នកណាដែលទាស់ប្រឆាំងនឹងទ្រង់ ។ ទ្រង់យាងមកនៅក្នុងព្យុះ ប៉ុន្តែទ្រង់នឹងមិនយ៉ាងដូច្នោះទេ ប្រសិនបើមានបុត្ររបស់ទ្រង់ពីរ ឬ បីនាក់ជុំគ្នាអធិស្ឋានដើម្បីទូលសូមការនាំផ្លូវមកពីទ្រង់ (គម្ពីរណាហ៊ូម ១:៣ គម្ពីរម៉ាថាយ១៨:២០)។

ការដឹងថាព្រះជាម្ចាស់តែងតែគង់នៅក្បែរ បានផ្តល់ឲ្យយើងនូវកម្លាំងចិត្តនៅពេលមានបញ្ហា ព្រោះយើងដឹងថាព្រះជាម្ចាស់នៅទីនោះដើម្បីផ្តល់កម្លាំង និង នាំផ្លូវយើង។ ការនេះក៏រំឭកយើងឲ្យមានការប្រុងប្រយ័ត្នជាមួយនឹងរបៀបដែលយើងរស់នៅ ព្រោះព្រះជាម្ចាស់ទតឃើញអ្វីៗគ្រប់បែបយ៉ាងដែលយើងធ្វើ មិនថាការល្អ ឬ ការអាក្រក់។ យើងមានទំនួលខុសត្រូវក្នុងការបម្រើព្រះជាម្ចាស់ ឲ្យបានដិតដល់នៅគ្រប់ទីកន្លែង និងនៅគ្រប់ពេលវេលា ដ្បិតទ្រង់គង់នៅគ្រប់កន្លែងទាំងនោះ។

យើងក៏គួរតែរំឭកខ្លួនឯងថា យើងមិនអាចប្រើប្រាស់អារម្មណ៍ផ្ទាល់ខ្លួនរបស់យើង ធ្វើជារង្វាស់សម្រាប់ព្រះវត្តមានរបស់ព្រះជាម្ចាស់នៅជាមួយយើងនោះឡើយ។ មិនថាយើងមានអារម្មណ៍បែបណា ព្រះជាម្ចាស់ក៏គង់នៅជាមួយយើង។ ឧបមាថា មានក្មេងស្រីម្នាក់កំពុងតែយំនៅក្នុងទីងងឹត ហើយម្តាយរបស់នាងប្រាប់នាងថា គាត់នៅជាមួយនាង។ ក្មេងស្រីនោះប្រហែលជាគិតថា នាងត្រូវតែមើលឃើញម្តាយរបស់នាងជាមុនសិនដើម្បីដឹងថាគាត់នៅទីនោះពិតមែន។ មិនថានាងមើលឃើញម្តាយរបស់នាង,ឬមិនឃើញ ក៏ការនោះមិនអាចផ្លាស់ប្តូរការពិតដែលថាម្តាយរបស់នាងគាត់នៅទីនោះយ៉ាងពិតប្រាកដបានដែរ។ ដូច្នេះជាមួយពួកយើងវិញ។ មិនថាយើងមាន*អារម្មណ៍ដឹង* ព្រះវត្តមានរបស់ព្រះជាម្ចាស់ ឬមិនដឹងក៏ដោយ ក៏ព្រះគម្ពីរបានប្រាប់យើងថាទ្រង់គង់នៅគ្រប់ទីកន្លែង។ គ្រាន់តែដឹងប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់យើង ក្នុងរក្សានូវតរិយាបថនៃការសរសើរតម្កើង និង មានកម្លាំងចិត្តគ្រប់ពេលបានទៅហើយ។

លំហាត់អនុវត្តន៍

១៥ នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរប្រាប់មូលហេតុពីរយ៉ាង ដែលការស្គាល់ពីសព្វត្ថិភាពរបស់ព្រះជាម្ចាស់ ត្រូវតែមានឥទ្ធិពលមកលើរបៀបដែលយើងរស់នៅ។

សព្វញ្ញុតញ្ញាណរបស់ព្រះជាម្ចាស់

បើយើងសិក្សាទៅមុខមួយជំហានពីសព្វត្ថិភាពរបស់ព្រះជាម្ចាស់ យើងនឹងទៅដល់សព្វញ្ញុតរបស់ព្រះជាម្ចាស់ ដែលជាចំណេះដឹងរបស់ព្រះជាម្ចាស់អំពីអ្វីៗគ្រប់បែបយ៉ាង។ មនុស្សតែងតែខិតខំធ្វើការយ៉ាងខ្លាំងដើម្បីបកស្រាយការពិត។ នៅពេលដែលយើងសិក្សា ដើម្បីទទួលបានចំណេះដឹង យើងប្រមូលបានសេចក្តីពិត ប៉ុន្តែមើលទៅហាក់បីដូចជា នៅពេលដែលយើងកាន់តែរៀន យើងកាន់តែដឹងថា យើងដឹងតែបន្តិចបន្តួចតែប៉ុណ្ណោះ។

ព្រះជាម្ចាស់គ្មានបញ្ហាដូចនេះទេ។ ទ្រង់ជ្រាបដឹងគ្រប់យ៉ាង។ អ្នកគ្រប់គ្រងនៃសាកលលោក ទ្រង់មានការត្រាស់ដឹងដ៏គ្មានដែនកំណត់។ ការពិតនេះ គឺជាការដែលយើងគ្មានថ្ងៃស្វែងយល់ពេញលេញនោះទេ ប៉ុន្តែវាគឺជាការចាំបាច់សម្រាប់ជំនឿរបស់យើង ទៅលើភាពឥតខ្ចោះរបស់ព្រះជាម្ចាស់។ ជាក់ស្តែង ទ្រង់ច្បាស់ជាជ្រាបដឹងពីអ្វីគ្រប់យ៉ាងដែលជាក់លាក់ និង អ្វីគ្រប់យ៉ាងដែលអាចកើតឡើង។ បើពុំនោះទេ ទ្រង់មុខជាត្រូវរៀនអំពីរឿងដែលទ្រង់មិនជ្រាបដឹងពីមុនមកជាប់រហូត ហើយទ្រង់មុខជាត្រូវកែប្រែផែនការ និង បំណងព្រះហឫទ័យរបស់ទ្រង់ទៅតាមនោះ។

ដោយព្រះជាម្ចាស់ជ្រាបដឹងគ្រប់ការទាំងអស់ ទ្រង់អាចប្រាប់ពីអ្វីដែលនឹងកើតឡើងនាពេលអនាគត តាំងពីមុនការនោះកើតឡើងទៅទៀត។ ដូច្នេះ យើងឃើញពីហេតុការណ៍ជាច្រើនដែលមានប្រាប់ទុកមុននៅក្នុងបទគម្ពីរ។ នេះមិនមែនមានន័យថាព្រះដ៏អស់កល្បជានិច្ច ទ្រង់ធ្វើការសម្រេចព្រះទ័យអំពីអ្វីដែលនឹងកើតឡើងមកលើយើងនោះទេ។ ទ្រង់គ្រាន់តែដឹងពីអ្វីដែលនឹងជាការសម្រេចចិត្តរបស់យើងមុនពេលដែលយើងធ្វើការសម្រេចចិត្តនោះតែប៉ុណ្ណោះ។ ដោយសារទ្រង់ទតឃើញជាមុន ទ្រង់អាចមានព្រះបន្ទូលប្រាប់ទុកមុន នូវអ្វីៗដែលនឹងកើតឡើងនាពេលអនាគត។ ការដែលទ្រង់អាចប្រាប់មកនេះមិនមែនមានន័យថាទ្រង់*កំណត់ទុកមុន* ឬ ធ្វើការសម្រេចជាមុន ទៅលើអ្វីដែលអាចនឹងកើតឡើងនោះទេ។

ការពិតដែលថា ព្រះជាម្ចាស់ជ្រាបដឹងគ្រប់អ្វីៗទាំងអស់នេះ គួរតែជាការពង្រឹងកម្លាំងសម្រាប់ជំនឿរបស់យើង នៅពេលណាដែលយើងស្ថិតនៅក្នុងបញ្ហាដ៏ធ្ងន់ធ្ងរមួយ ដ្បិតទ្រង់ជ្រាប់ដឹងច្រើនជាងអ្វីដែលយើងបានដឹងអំពីបញ្ហារបស់យើង។ ទ្រង់ជ្រាបអំពីមូលហេតុ និងអ្វីដែលនឹងកើតឡើងជាមួយនឹងដំណោះស្រាយនីមួយៗដែលយើងអាចគិតឃើញ។ យើងអាចទទួលបានការធានាដ៏អស្ចារ្យមួយ ចេញពីការពិតមួយនេះ នៅពេលដែលយើងស្វែងរកការដឹកនាំរបស់ទ្រង់ ដើម្បីរកដំណោះស្រាយសម្រាប់បញ្ហារបស់យើង។

លំហាត់អនុវត្តន៍

១៦ ចូរអានគម្ពីរទំនុកតម្កើង ១៣៩:១-១៩ ហើយបំពេញប្រយោគទាំងនេះ។

ក) ខទី..... ថ្លែងអំពីសព្វញ្ញាណញាណរបស់ព្រះជាម្ចាស់។

ខ) ខទី.....ថ្លែងអំពីសព្វានុភាពរបស់ព្រះជាម្ចាស់។

គ) ខទី.....ថ្លែងអំពីសព្វត្ថិភាពរបស់ព្រះជាម្ចាស់។

១៧ តើប្រយោគណាមួយត្រឹមត្រូវ ទាក់ទងនឹងនឹងសព្វញ្ញាណញាណរបស់ព្រះជាម្ចាស់?

ក) ដោយសារព្រះជាម្ចាស់ជ្រាបដឹងការសម្រេចចិត្តដែលខ្ញុំនឹងធ្វើ នោះការសម្រេចចិត្តទាំងអស់របស់ខ្ញុំគឺជាការសម្រេចព្រះទ័យរបស់ទ្រង់។

ខ) ការដឹងថាព្រះជាម្ចាស់ជ្រាបគ្រប់អ្វីៗទាំងអស់ នឹងនាំឲ្យខ្ញុំឲ្យចូលទៅកាន់ទ្រង់ ដើម្បីទទួលបានការនាំផ្លូវពីទ្រង់ នៅពេលដែលខ្ញុំត្រូវធ្វើការសម្រេចអ្វីមួយ។

គ) ការប្រាប់ទុកមុនមានន័យថា ការកំណត់ទុកមុន។

ឃ) ប្រសិនបើព្រះជាម្ចាស់មិនជ្រាបដឹងគ្រប់ការនោះទេ ទ្រង់នឹងមិនសូវមានភាពឥតខ្ចោះនោះទេ។

ង) សព្វញ្ញាណញាណមានន័យថា ការដឹងគ្រប់យ៉ាងដែលត្រូវដឹង រួមទាំងចំណេះដឹងឥតខ្ចោះអំពីអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល។

ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់

អ្នកវិទ្យាសាស្ត្រជាច្រើននាក់ ដឹងអំពីការពិតជាច្រើន ប៉ុន្តែដំណោះដឹងអំពីពិភពលោកទាំងអស់នោះមិនបានដោះស្រាយបញ្ហាក្នុងសង្គមនោះទេ។ មនុស្សគ្មានប្រាជ្ញាសមស្របដែលអាចឲ្យពួកគេដឹងអំពីរបៀបប្រើប្រាស់ចំណេះដឹងដែលពួកគេមានដើម្បីដោះស្រាយបញ្ហា ទៅតាមរបៀបមួយដែលអនុញ្ញាតឲ្យមនុស្សគ្រប់រូបរស់នៅរួមគ្នាប្រកបដោយសុខសន្តិភាព និង ភាពរីកចម្រើនបានឡើយ។

ប្រាជ្ញាមិនដូចជាចំណេះដឹងនោះទេ។ ដើម្បីទទួលបានប្រាជ្ញា យើងត្រូវស្វែងរកតាមរយៈចំណេះដឹងដើម្បីឲ្យឃើញពីគោលបំណងដ៏ខ្ពស់បំផុត ហើយប្រើប្រាស់ទៅតាមរបៀបមួយដែលល្អប្រសើរបំផុត។ ដោយសារព្រះជាម្ចាស់ ទ្រង់មានប្រាជ្ញាគ្រប់ទាំងអស់ ទ្រង់ធ្វើការគ្រប់បែបយ៉ាងបានយ៉ាងល្អ។ ដោយប្រើព្រះប្រាជ្ញាញាណដ៏ឥតខ្ចោះរបស់ទ្រង់ ព្រះជាម្ចាស់បានប្រទានព្រះបន្ទូលរបស់ទ្រង់មកឲ្យយើងនៅក្នុងព្រះគម្ពីរ ដើម្បីនាំផ្លូវយើងក្នុងគ្រប់ការទាំងអស់ដែលយើងធ្វើ។ ប្រសិនបើយើងរស់នៅ ស្របតាមការដឹកនាំរបស់ទ្រង់ ដូចមានកត់ត្រាទុកនៅក្នុងព្រះបន្ទូលរបស់ទ្រង់ យើងនឹងទទួលបានប្រយោជន៍ ពីប្រាជ្ញារបស់ទ្រង់ និង ទទួលបានព្រះពរពីទ្រង់។

ពេលខ្លះ យើងមិនអាចមើលឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ក្នុងការដែលទ្រង់អនុញ្ញាតឲ្យមានរឿងអ្វីមួយកើតឡើងនៅក្នុងជីវិតរបស់យើងបាននោះទេ។ ដំបូង យើងត្រូវចាំថា ព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន ហើយប្រសិនបើជម្រើសទាំងនោះមិនស្របទៅតាម

បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ យើងអាចនឹងនាំបញ្ហាមកដាក់លើខ្លួនឯង។ ដូចគ្នាដែរ យើងត្រូវចាំថា យើងរស់នៅក្នុងលោកីយ៍ដែលពេញដោយអំពើបាប ហើយមានពេលខ្លះ មិនថាគ្រិស្តបរិស័ទ ឬ អ្នកមិនមែនគ្រិស្តបរិស័ទ អាចនឹងក្លាយជាជនរងគ្រោះពីគ្រោះមហន្តរាយ ឬ ទង្វើអាក្រក់របស់អ្នកដទៃ ក្នុងលោកីយ៍ដែលបានខូចបង់ដោយអំពើបាបមួយនេះ។ ព្រះជាម្ចាស់គ្មានកាតព្វកិច្ចយាងមកឯយើងរាល់គ្នា ហើយបកស្រាយមូលហេតុដែលអ្វីគ្រប់យ៉ាងកើតឡើងតាមរបៀបដែលវាកើតឡើងនោះទេ។ ទ្រង់ប្រហែលជាអនុញ្ញាតឲ្យរឿងរ៉ាវកើតឡើងដោយសារមូលហេតុមួយដែលយើងមិនដឹងសោះ ប៉ុន្តែដូចដែលគម្ពីរ១យ៉ូហាន ៤:១៨ ថ្លែងថា "សេចក្តីស្រឡាញ់ដ៏គ្រប់លក្ខណៈ បណ្តេញការភ័យខ្លាចអោយចេញផុតទៅ"។ យើងអាចជឿទុកចិត្តព្រះជាម្ចាស់យ៉ាងពេញលេញ នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ដោយដឹងថាតាមរយៈព្រះប្រាជ្ញាញាណ ទ្រង់នឹងធ្វើការគ្រប់បែបយ៉ាងដើម្បីផលល្អរបស់យើង និង ដើម្បីសិរីរុងរឿងរបស់ទ្រង់ (គម្ពីររ៉ូម ៨:២៨)។

បទគម្ពីរដូចជាគម្ពីរទំនុកតម្កើង ១០៤:២៤-៣០ និងគម្ពីរយេរេមា ១០:១២ បានរំឭកយើងថា យើងអាចឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់តាមរយៈស្នាព្រះហស្តរបស់ទ្រង់។ ការសម្រេចបាននូវរចនាបទដ៏ស្មុគស្មាញរបស់ធម្មជាតិ គឺទាមទារឲ្យមានការបង្កើតយ៉ាងប៉ិនប្រសព្វ។ នៅពេលដែលខ្ញុំពិនិត្យមើលទៅស្លាបសត្វបក្សីមួយ ខ្ញុំគ្មានពាក្យអ្វីនិយាយបានទេ។ គ្រប់ផ្នែកដ៏តូចល្អិត គឺត្រូវបានរចនាឡើងដើម្បីតួនាទីពិសេសមួយ មិនថាការហោះហើរ ឬ ការការពារបក្សីនោះឲ្យផុតពីអាកាសធាតុនោះទេ។ បើនៅពេលដែលខ្ញុំពិនិត្យមើលទៅលើគ្រោងឆ្អឹងរបស់សត្វបក្សី ខ្ញុំឃើញថាឆ្អឹងធំៗគឺមានប្រហោង ហើយពេញដោយខ្យល់ លក្ខណៈនេះធ្វើឲ្យសត្វតូចនេះអាចហោះទៅលើអាកាសបាន។ កូនចៅជំនាន់ក្រោយរបស់បក្សីនោះ នឹងមានរចនាបទដូចគ្នានោះដែរ។ នេះគឺជាឧទាហរណ៍ដ៏តូចមួយនៃព្រះប្រាជ្ញាញាណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នៃយើង។

ខ្ញុំមានពរណាស់ នៅពេលដែលខ្ញុំចាំថាព្រះជាម្ចាស់ក៏បានប្រទានព្រះប្រាជ្ញាញាណរបស់ទ្រង់ មកឲ្យយើងនៅពេលដែលយើងត្រូវការផងដែរ។ អ្វីដែលសំខាន់គឺមិនមែនអ្វីដែលយើងប្រឈមមុខនៅថ្ងៃនេះ ថ្ងៃស្អែក សប្តាហ៍ក្រោយ ឬខែក្រោយនោះទេ។ គម្ពីរយ៉ាកុប១:៥បានប្រាប់យើងកុំឲ្យសង្ស័យ ប៉ុន្តែត្រូវទូលសូមប្រាជ្ញា ដ្បិតព្រះជាម្ចាស់ទ្រង់មានក្តីសប្បុរស និង ក្តីមេត្តា ក្នុងការប្រទានប្រាជ្ញានោះមកឲ្យប្រជារាស្ត្ររបស់ទ្រង់។

លំហាត់អនុវត្តន៍

១ដ ដោយផ្អែកទៅលើការពិភាក្សារបស់យើងអំពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ តើប្រយោគណាខ្លះដែលនៅខាងក្រោមនេះ ជាឧទាហរណ៍ល្អអំពីព្រះប្រាជ្ញាញាណរបស់ទ្រង់?

ក) ប្រសិនបើខ្ញុំមានការចំណាយដែលមិនបានព្រៀងទុកមុន ហើយមិនដឹងធ្វើយ៉ាងណាដើម្បីរៀបចំផែនការ ដោះស្រាយបញ្ហានោះទេ ខ្ញុំអាចទូលសូមព្រះជាម្ចាស់ឲ្យទ្រង់ដឹកនាំ ហើយដឹងថាទ្រង់អាចប្រទានប្រាជ្ញាដែលខ្ញុំត្រូវការដើម្បីដោះស្រាយបញ្ហានេះ។

ខ) ក្មេងស្រីដែលជាគ្រិស្តបរិស័ទម្នាក់ ដែលជាគំរូដ៏ល្អ និងជាទីបន្ទាល់នៃសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត បានស្លាប់ដោយមិនបានព្រៀងទុកនៅក្នុងឧបទ្ទវហេតុមួយ។ ដោយសារតែការ

ស្លាប់របស់នាង បាននាំមនុស្សជាច្រើននៅក្នុងសហគមន៍មករកព្រះអម្ចាស់ យើងដឹងថាតាមរយៈព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ទ្រង់បានរៀបចំផែនការនេះឡើងសម្រាប់រឿងដ៏ល្អប្រសើរមួយ។

គ) ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះគម្ពីរ គឺជាមគ្គុទេសក៍មួយសម្រាប់បង្ហាញខ្ញុំអំពីរបៀបរស់នៅជីវិតដ៏ល្អ និង ប្រកបដោយផលផ្លែមួយ។

ឃ) ព្រះជាម្ចាស់ប្រទានប្រាជ្ញាដល់អ្នកដឹកនាំក្រុមជំនុំ ដើម្បីធ្វើការខាងឯវិញ្ញាណនៅក្នុងក្រុមជំនុំ ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ង) ការរៀបចំប្រមូលផ្តុំសិរីរាង្គកាយរបស់មនុស្ស បង្ហាញឲ្យឃើញពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។

ច) ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ មិនអនុញ្ញាតឲ្យគ្រិស្តបរិស័ទធ្វើខុសនៅក្នុងការវិនិច្ឆ័យទោសឡើយ។

១៩ ដើម្បីរឭកផ្នែកនេះឡើងវិញ ចូរផ្គូផ្គងគុណលក្ខណៈបួនយ៉ាងរបស់ព្រះជាម្ចាស់ ទៅនឹងនិយមន័យនៃគុណលក្ខណៈនីមួយៗ។

.....ក)	គុណសម្បត្តិមួយរបស់ព្រះជាម្ចាស់ដែលទ្រង់អាចមានវត្តមាននៅក្នុងគ្រប់ទីកន្លែង។	១)	សព្វានុភាព
		២)	សព្វញ្ញាណញាណ
		៣)	សព្វត្ថិភាព
.....ខ)	របៀបដែលព្រះជាម្ចាស់ធ្វើការដើម្បីផ្តល់គោលបំណងដ៏ខ្ពង់ខ្ពស់ តាមមធ្យោបាយដ៏ល្អបំផុត សម្រាប់ការៈរស់ដែលទ្រង់បានបង្កើត និង ស្នាព្រះហស្តទាំងអស់របស់ទ្រង់។	៤)	ព្រះប្រាជ្ញាញាណ
.....គ)	គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលទ្រង់ជ្រាបដឹងរឿងគ្រប់យ៉ាង។		
.....ឃ)	គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលទ្រង់មានគ្រប់ឫទ្ធានុភាពទាំងអស់។		

នៅក្នុងមេរៀននេះ យើងបានពិភាក្សាអំពីនិស្ស័យរបស់ព្រះជាម្ចាស់ និង គុណលក្ខណៈធម្មជាតិរបស់ទ្រង់។ នៅក្នុងមេរៀនបន្ទាប់ យើងនឹងសិក្សាអំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ និង កិច្ចការដែលប្រកបដោយព្រះចេស្តារបស់ទ្រង់។ ការនេះនឹងត្រៀមយើង ដើម្បីសិក្សាអំពីព្រះជាម្ចាស់ព្រះរាជបុត្រ និង ព្រះជាម្ចាស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលដែលអ្នកបានយល់ដឹងកាន់តែច្រើនឡើង អំពីព្រះអាទិករបស់យើង និង ទំនាក់ទំនងរបស់អ្នកជាមួយទ្រង់ អ្នកនឹងអាចបម្រើទ្រង់កាន់តែល្អប្រសើរ ព្រមទាំងធ្វើជាសក្ខីភាពទៅកាន់អ្នកដទៃ អំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស។ ចូរជ្រើសរើសចម្លើយមួយដែលល្អបំផុតសម្រាប់ប្រយោគនីមួយៗ។

១ គ្រិស្តបរិស័ទថ្វាយបង្គំតាមរបៀបរបស់ពួកគេ ដោយមិនថ្វាយបង្គំទីកន្លែងណាមួយ តាមទម្រង់ណាមួយ ឬ ការកំណត់ណាមួយនោះទេ ព្រោះព្រះជាម្ចាស់គឺជា

ក) វិញ្ញាណ

ខ) ការរួបរួម

គ) សព្វានុភាព

ឃ) ភាពអស់កល្បជានិច្ច

២ ប្រសិនបើខ្ញុំដឹងថាព្រះជាម្ចាស់ត្រាស់ដឹងគ្រប់ការ មានឫទ្ធានុភាពគ្រប់ទាំងអស់ និង គង់នៅគ្រប់ទីកន្លែង ខ្ញុំនឹង

ក) រស់នៅក្នុងជីវិតមួយដែលជាទីសព្វព្រះហឫទ័យសម្រាប់ព្រះជាម្ចាស់ និង ទុកចិត្តទ្រង់ថាជួយខ្ញុំនៅក្នុងគ្រប់បញ្ហាគ្រប់បែបយ៉ាងដែលខ្ញុំប្រឈមមុខ។

ខ) ដឹងថា ទោះបីខ្ញុំធ្វើជ្រើសរើសបែបណា ជម្រើសទាំងនោះគឺជាជម្រើសដែលព្រះជាម្ចាស់ជ្រើសរើសសម្រាប់ខ្ញុំ ហើយគ្មានអ្វីដែលខ្ញុំអាចធ្វើបានដើម្បីផ្លាស់ប្តូរវានៅក្នុងជីវិតរបស់ខ្ញុំបានទេ។

គ) ដោះស្រាយបញ្ហា និង តម្រូវការប្រចាំថ្ងៃរបស់ខ្ញុំ តាមរបៀបផ្ទាល់ខ្លួនរបស់ខ្ញុំ ព្រោះខ្ញុំគួរតែយាងព្រះជាម្ចាស់មកក្នុងជីវិតរបស់ខ្ញុំ តែនៅពេលណាដែលមានបញ្ហាធំៗប៉ុណ្ណោះ។

៣ ដោយនិស្ស័យ និង គុណលក្ខណៈរបស់ព្រះជាម្ចាស់ ទ្រង់មិនត្រឹមតែមានសមត្ថភាពដឹងអ្វីដែលយើងត្រូវការប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏

ក) គង់នៅឆ្ងាយ មិនអាចយាងមកដោះស្រាយបញ្ហានោះបានទេ។

ខ) ជ្រាបថា ដោយសារយើងគ្មាននិស្ស័យ និង គុណលក្ខណៈដូចជាទ្រង់ ទ្រង់មិនអាចទាក់ទងជាមួយយើងឲ្យបានប្រកបអត្ថន័យជ្រាលជ្រៅនោះទេ។

គ) អាចប្រទានឲ្យយើងនូវគ្រប់តម្រូវការដែលយើងមានផងដែរ។

៤ នៅពេលដែលយើងដឹងថា ព្រះជាម្ចាស់ធ្វើការគ្រប់យ៉ាងដើម្បីផលល្អរបស់យើង និង សិរីរុងរឿងរបស់ទ្រង់ យើងនឹងមើលឃើញពី

ក) បុគ្គលិកលក្ខណៈរបស់ទ្រង់

ខ) ភាពអស់កល្បជានិច្ចរបស់ទ្រង់

គ) ព្រះប្រាជ្ញាញាណរបស់ទ្រង់

ឃ) សព្វញ្ញុតញ្ញាណរបស់ទ្រង់

ត្រូវ- ខុស។ ចូរសរសេរអក្សរ ត នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគដែលមិនត្រឹមត្រូវ។

.....៥ គុណសម្បត្តិមួយរបស់ព្រះជាម្ចាស់ដែលបង្ហាញថា យើងអាចចូលទៅរកទ្រង់បាន និង ដែលថាទ្រង់ខ្វល់ព្រះហឫទ័យអំពីតម្រូវការជាមនុស្សរបស់យើង គឺភាពរួបរួម។

.....៦ ភាពជាគ្រិស្តបរិស័ទ គឺខុសពីការថ្វាយបង្គំព្រះជាច្រើន ព្រោះព្រះជាម្ចាស់នៅខាងឯវិញ្ញាណ។

.....៧ ព្រះគម្ពីរបង្រៀនយើងថា មានព្រះបីអង្គនៅក្នុងសមាសភាពរបស់ព្រះជាម្ចាស់៖ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងអាចហៅគុណសម្បត្តិនេះថា ភាពរួបរួមរបស់ព្រះជាម្ចាស់។

.....៨ គុណសម្បត្តិរបស់ព្រះជាម្ចាស់ដែលរៀបរាប់ពី អត្ថិភាពរបស់ទ្រង់ដែលគ្មានទីចាប់ផ្តើម ឬ ទីបញ្ចប់ និង គុណសម្បត្តិដែលមិនប្រែប្រួលរបស់ទ្រង់ គឺភាពអស់កល្បជានិច្ច និង ភាពខ្ជាប់ខ្ជួនរបស់ទ្រង់។

.....៩ មនុស្សដែលមិនអាចមើលគោលបំណងនៅក្នុងបញ្ហានៅក្នុងជីវិតរបស់ពួកគេ ប្រហែលជាមិនអាចស្គាល់ច្បាស់ពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់បានទេ។

.....១០ ភស្តុតាងនៃគោលលិទ្ធអំពីព្រះត្រៃឯកជាច្រើន ត្រូវបានគេឃើញមាននៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។

ចម្លើយសម្រាប់សំណួរអនុវត្តន៍

១១ ក) និង ខ) ជាចម្លើយត្រឹមត្រូវ។

១ ចម្លើយរបស់អ្នក

១២ ក) ព្រះជាម្ចាស់ ; ពិភពលោក

ខ) បំណងព្រះហឫទ័យ ; ព្រះបន្ទូល

គ) វិនាស

ឃ) សេចក្តីស្រឡាញ់ ; ភាពសុចរិត

២ ចម្លើយរបស់អ្នក។ ខ្ញុំបានសំគាល់ឃើញថាយើងស្គាល់អ្នកដទៃ តាមរយៈការនិយាយទៅកាន់ពួកគេ ស្តាប់ពួកគេ និង សិក្សាអំពីពួកគេ។ ដើម្បីស្គាល់ព្រះជាម្ចាស់ យើងត្រូវចំណាយពេលវេលាដើម្បីធ្វើរឿងទាំងអស់នេះដូចគ្នា។

១៣ ក) ៣) ភាពរួបរួម

ខ) ៥) ភាពអស់កល្បជានិច្ច

គ) ២) ភាពជាវិញ្ញាណ

ឃ) ៤) ព្រះត្រៃឯក

ង) ៦) ភាពខ្ជាប់ខ្ជួន

ច) ១) បុគ្គលិកលក្ខណៈ

៣ ខ) សមត្ថភាពក្នុងការធ្វើព្រះតម្រិះ ទទួលអារម្មណ៍ និង ធ្វើការសម្រេចព្រះទ័យរបស់ទ្រង់។

១៤ យើងនៅជាមួយអ្នកហើយ

៤ ខ) ព្រះជាម្ចាស់ជ្រាប និង យកព្រះទ័យទុកដាក់ ចំពោះតម្រូវការយុត្តិធម៌ ហើយទ្រង់ជ្រាប និង យកព្រះទ័យទុកដាក់នឹងភាពមានបាបរបស់អ្នកដែលធ្វើអំពើអាក្រក់។ ការទាំងនេះបង្ហាញឡើងតាមរបៀបនិមិត្តរូប។

១៥ យើងដឹងថាព្រះជាម្ចាស់តែងតែគង់នៅ ដើម្បីផ្តល់កម្លាំង និង លើកទឹកចិត្តយើងនៅក្នុងពេលមានបញ្ហា។ យើងដឹងថាទ្រង់ទតឃើញអ្វីៗគ្រប់យ៉ាងដែលយើងធ្វើ មិនថាល្អឬអាក្រក់ក៏ដោយ ហើយយើងមានទំនួលខុសត្រូវក្នុងការបម្រើទ្រង់គ្រប់ពេលវេលា។

៥ ឃ) ចម្លើយ ក) , ខ) និង គ) ជាចម្លើយត្រឹមត្រូវ។

១៦ ក) ខទី១ដល់ទី៦.....

ខ) ខទី១៣ដល់ទី១៩.....

គ) ខទី៧ដល់ទី១២....

៦ ក) យើងជាព្រះដ៏មានឫទ្ធានុភាពខ្ពង់ខ្ពស់បំផុត។
ខ) ព្រះអម្ចាស់ជាព្រះរបស់អ្នក ; កុំគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ
គ) ឲ្យមានព្រះណាទៀតនៅជាមួយនឹងអញ(ពគប១៩៥៤)។
ឃ) ព្រះអម្ចាស់នៃយើងគឺជាព្រះជាម្ចាស់តែមួយគត់ ហើយក្រៅពីទ្រង់ គ្មានព្រះណាផ្សេងទៀតឡើយ។

៧ ប្រាកដណាស់ ផ្នត់គំនិតទាំងនេះគឺមានទាក់ទងគ្នា នៅពេលណាដែលរៀបរាប់អំពីភាពតែមួយ ឬភាពរួបរួមរបស់ព្រះជាម្ចាស់។ យើងបានផ្គូផ្គងគំនិតទាំងនេះតាមរបៀបដូចតទៅនេះ៖
ក) ២) ភាពពិសេសតែមួយ
ខ) ១) ភាពរួបរួមខាងឯចំនួន
គ) ២) ភាពពិសេសតែមួយ
ឃ) ៣) ភាពសាមញ្ញ
ង) ៣) ភាពសាមញ្ញ
ច) ៣) ភាពសាមញ្ញ
ឆ) ១) ភាពរួបរួមខាងឯចំនួន ឬ ២) ភាពពិសេសតែមួយ

១៧ ចម្លើយខ) ឃ) និង ង) ជាចម្លើយត្រឹមត្រូវ។

៨ ក) ព្រះជាម្ចាស់ព្រះវរបិតា
ខ) ព្រះជាម្ចាស់
គ) ព្រះជាម្ចាស់
ឃ) អង្គព្រះបីដោយឡែកពីគ្នា (ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ)។

១៨ ចម្លើយ ក) គ) ឃ) និង ង) ជាឧទាហរណ៍ដ៏ល្អអំពីព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។ ចម្លើយ ខ) គឺមិនមែនជាឧទាហរណ៍ដ៏ល្អនោះទេ ព្រោះឧបទ្ទវហេតុរបស់ក្មេងស្រីនោះ គឺជាលទ្ធផលដែលមកពីកំហុសរបស់មនុស្ស ហើយមិនមែនព្រះជាម្ចាស់ធ្វើឲ្យកើតឡើងនោះទេ។ ប៉ុន្តែព្រះជាម្ចាស់បានធ្វើការសម្រាប់ការល្អនៅក្នុងស្ថានភាពនោះដោយប្រើប្រាស់ស្ថានភាពនោះដើម្បីនាំមនុស្សឲ្យចូលមកឯទ្រង់ ហើយតាមរយៈការនេះ គេបានឃើញពីព្រះប្រាជ្ញាញាណរបស់ទ្រង់។ ចម្លើយ ច) ក៏មិនមែនជាឧទាហរណ៍ដ៏ល្អមួយដែរ ព្រោះតាមរយៈព្រះប្រាជ្ញាញាណព្រះជាម្ចាស់អនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តដោយខ្លួនឯង។ យើងអាចជ្រើសរើសយក ការទូលសូមទ្រង់ នូវប្រាជ្ញាក្នុងការធ្វើការសម្រេចចិត្ត។

៩ ក) ៥) ពហុភាពនៃអង្គព្រះ
ខ) ៣) ព្រះសង្គ្រោះ និង ព្រះវិញ្ញាណដ៏វិសុទ្ធ
គ) ២) ព្រះប្រោសលោះ ឬ ព្រះសង្គ្រោះ
ឃ) ១) ព្រះវិញ្ញាណដ៏វិសុទ្ធ
ង) ៤) អង្គព្រះនៅក្នុងព្រះត្រៃឯក

១៩ ក) ៣) សព្វត្តិភាព

ខ) ៤) ព្រះប្រាជ្ញាញាណ

គ) ២) សព្វញ្ញុណញាណ

ឃ) ១) សព្វានុភាព

១០ ចម្លើយ ក) ខ) ឃ) ង) និង ច) ជាចម្លើយត្រឹមត្រូវ។

មេរៀនទី ២

ព្រះជាម្ចាស់៖ លក្ខណសម្បត្តិខាងឯសីលធម៌ និង កិច្ចការរបស់ទ្រង់

ពេលខ្លះតើអ្នកឆ្ងល់ខ្លាំងណាស់មែនទេ នៅពេលអ្នកអានការសែត ហើយឃើញមានសោកនាដកម្មដ៏អស្ចារ្យបានកើតលើជីវិតរបស់គ្រិស្តបរិស័ទ? តើអ្នកធ្លាប់ឃើញមនុស្សអាក្រក់ ទទួលបានការជោគជ័យ និង មានទ្រព្យសម្បត្តិយ៉ាងអស្ចារ្យតាមរយៈការធ្វើរឿងមិនស្មោះត្រង់ ហើយធ្លាប់គិតទេថា ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យមានរឿងទាំងនេះកើតមានឡើង? ជារឿយៗ យើងអំពល់ចិត្តយ៉ាងខ្លាំង នៅពេលយើងឃើញពីអ្វីដែលហាក់ដូចជាមិនយុតិធម៌ ហើយយើងតែងតែទូលសួរទៅកាន់ព្រះជាម្ចាស់។

នៅពេលយើងយល់កាន់តែច្បាស់អំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ ដែលមានសេចក្តីស្រឡាញ់ និង ភាពបរិសុទ្ធរបស់ទ្រង់ ព្រមទាំងយល់ពីរបៀបដែលទ្រង់ធ្វើការនៅក្នុងលោកីយ៍សព្វថ្ងៃនេះ យើងនឹងឃើញថា អ្វីៗទាំងអស់ដែលកើតមានឡើងមកលើយើង គឺសុទ្ធតែមានគោលបំណងរបស់វា។ គោលដៅរបស់ព្រះជាម្ចាស់ គឺដើម្បីរៀបចំយើងសម្រាប់ព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់ ហើយទ្រង់ធ្វើសកម្មភាពនៅក្នុងជីវិតរបស់យើងសព្វថ្ងៃ គឺដើម្បីសម្រេចគោលដៅនោះ។

នៅក្នុងមេរៀននេះ យើងនឹងសិក្សាអំពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់ ហើយយើងនឹងឃើញថាព្រះជាម្ចាស់ដែលបានបង្កើតយើងរាល់គ្នា ទ្រង់ធ្វើការយ៉ាងសកម្មក្នុងការថែរក្សា ស្នាព្រះហស្តរបស់ទ្រង់ និង ប្រទានគ្រប់បែបយ៉ាងដែលត្រូវការ ដើម្បីនាំយើងឲ្យចូលទៅក្នុងព្រះរាជ្យរបស់ទ្រង់។ ទោះជាយ៉ាងណា ទ្រង់នៅតែអនុញ្ញាតឲ្យយើងធ្វើការសម្រេចចិត្តដោយខ្លួនឯង ហើយទទួលរ៉ាប់រងគ្រប់យ៉ាង ទៅលើការសម្រេចចិត្តរបស់យើង។ ចូរយើងបើកចិត្តរបស់យើងទៅកាន់ទ្រង់ ស្របពេលដែលយើងគិតពិចារណា នៅក្នុងការសិក្សាផ្នែកមួយនេះ ថាទ្រង់ស្រឡាញ់យើងដល់កម្រិតណា ព្រមទាំងពិចារណាអំពីរបៀបដែលទ្រង់គ្រប់គ្រងស្នាព្រះហស្តរបស់ទ្រង់ផងដែរ។

គម្រោងមេរៀន

ក. លក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់
ខ. រាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់
គ. រាជកិច្ចនៃការគ្រងរាជ្យជាស្តេចរបស់ព្រះជាម្ចាស់

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. បកស្រាយពីសារៈសំខាន់នៃភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។
២. ប្រាប់ថា និយមន័យនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើងជាអ្វី និង ប្រាប់ពីរបៀបដែលសេចក្តីស្រឡាញ់នោះស្តែងចេញមក។
៣. បកស្រាយសកម្មភាពនៃការបង្កើតរបស់ព្រះជាម្ចាស់ និង សារៈសំខាន់នៃការបង្កើតនោះសម្រាប់យើង។
៤. យកគោលការណ៍ទៅប្រើប្រាស់នៅក្នុងស្ថានភាពជីវិត និង ប្រាប់ពីនិយមន័យនៃការគ្រងរាជ្យជាស្តេចនៃសាកលលោករបស់ព្រះជាម្ចាស់។
៥. លើកឧទាហរណ៍អំពីគោលបំណង ធាតុមូលដ្ឋាន និង ឥទ្ធិពលនៃឧបការគុណរបស់ព្រះជាម្ចាស់។

សកម្មភាពនៃការសិក្សា

១. សិក្សាតាមដំណើរវិវឌ្ឍរបស់មេរៀន ធ្វើតាមដំណើរការដូចនឹងមេរៀនទី១។ នៅពេលអ្នកឆ្លើយសំណួរក្នុងមេរៀន ត្រូវឲ្យប្រាកដថាអ្នកសរសេរចម្លើយរបស់អ្នក មុនពេលបើកមើលចម្លើយនៅចុងបញ្ចប់មេរៀន។
២. នៅពេលអ្នកបានបញ្ចប់មេរៀននេះ ចូរធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកដោយយកចិត្តទុកដាក់ ជាមួយនឹងចម្លើយដែលយើងបានផ្តល់ជូននៅផ្នែកខាងក្រោយនៃសៀវភៅសិក្សានេះ។ ចូររំឭកចំណុចណាដែលអ្នកចម្លើយមិនបានត្រឹមត្រូវ។

ពាក្យសំខាន់

ការរំដោះបាប	អន្តរាគមន៍	ការការពារ
ការសម្របសម្រួល	ភាពយុត្តិធម៌	ឧបការគុណ (គុណូបការៈ)
ការយល់ស្រប	ការថែរក្សា	ភាពសុចរិត
បង្កើត	សេចក្តីមេត្តាករុណា	កំពូល
ឧត្តម	សីលធម៌	ភាពទៀងត្រង់
ភាពវិសុទ្ធ		

ក. លក្ខណសម្បត្តិខាងឯសីលធម៌របស់ព្រះជាម្ចាស់

នៅក្នុងមេរៀនទី១ យើងបានសិក្សាអំពីលក្ខណសម្បត្តិនៃនិស្ស័យរបស់ព្រះជាម្ចាស់ និង គុណលក្ខណៈជាធម្មជាតិរបស់ទ្រង់។ ឥឡូវនេះយើងនឹងពិចារណាទៅលើ លក្ខណសម្បត្តិខាងឯ*សីលធម៌*របស់ព្រះជាម្ចាស់។ ទាំងនេះ គឺជាលក្ខណសម្បត្តិដែលព្រះជាម្ចាស់សម្តែងឲ្យឃើញនៅពេលទ្រង់ ទាក់ទងជាមួយមនុស្ស។ លក្ខណៈទាំងនោះរួមមាន *ភាពវិសុទ្ធ*របស់ទ្រង់ និង*សេចក្តីស្រឡាញ់*របស់ទ្រង់។ ដំបូងយើងនឹងមើលទៅលើ*ភាពវិសុទ្ធ*របស់ព្រះជាម្ចាស់។

ភាពវិសុទ្ធរបស់ព្រះជាម្ចាស់

វគ្គបំណងទី១. *បកស្រាយពីសារៈសំខាន់នៃភាពបរិសុទ្ធរបស់ព្រះជាម្ចាស់។*

តើអ្នកចង់ឲ្យអ្នកជិតខាងរបស់អ្នកស្គាល់អ្នកថាជាមនុស្សដែលមានលក្ខណៈយ៉ាងដូចម្តេច? ជាមនុស្សកំណាញ់ម្នាក់? មនុស្សម្នាក់ដែលពូកែនិយាយដើមគេ? មនុស្សល្អម្នាក់? ជាមិត្តសម្លាញ់ម្នាក់? ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យ ប្រជាជាតិនានាស្គាល់ទ្រង់ដោយលក្ខណៈពិសេសមួយ។ ទ្រង់សព្វព្រះហឫទ័យឲ្យគេហៅទ្រង់ថា *ព្រះដ៏វិសុទ្ធ។* (គម្ពីរអេសេគាល ៣៩:៧)។

យើងបានដឹងថា ព្រះជាម្ចាស់មិនអាចមានកំហុសខាងឯគំនិតបញ្ញាបាននោះទេ ព្រោះទ្រង់ជ្រាបគ្រប់ការទាំងអស់។ ដោយសារតែភាពវិសុទ្ធរបស់ទ្រង់ ទ្រង់មិនអាចមានកំហុសខាងឯសីលធម៌នោះទេ។ ភាពវិសុទ្ធគឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលសម្តែងពីភាពឥតខ្ចោះដែលជារបស់ទ្រង់។ ភាពវិសុទ្ធគឺជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពទាំងអស់របស់ទ្រង់។ដូច្នេះ អ្វីៗគ្រប់យ៉ាងដែលទ្រង់ធ្វើ គឺត្រឹមត្រូវ និង ល្អ។

ពាក្យថា*ភាពវិសុទ្ធ* មានភ្ជាប់មកជាមួយគំនិតនៃ*ការបែងចែក* ។ ព្រះដ៏ល្អឥតខ្ចោះគឺត្រូវតែបែងចែកឲ្យដាច់ និង ឧដុង្គឧត្តម (លើកឲ្យខ្ពស់ឡើង) លើសផុតមនុស្សមានបាប និង ការអាក្រក់។ ប៉ុន្តែ ទោះបីទ្រង់វិសុទ្ធឥតខ្ចោះ និង បែងចែកដាច់ពីស្នាព្រះហស្តរបស់ទ្រង់យ៉ាងណា ទ្រង់នៅតែរក្សាទំនាក់ទំនងមួយជាមួយនឹងមនុស្ស ដែលនៅក្នុងទំនាក់ទំនងនោះទ្រង់បានជិតស្និទ្ធជាមួយពួកគេ។ បន្ទាប់ទៀតយើងនឹងមើលថាតើការនេះអាចកើតឡើងដោយរបៀបណា។

យើងអាចមើលឃើញ ភាពវិសុទ្ធរបស់ព្រះជាម្ចាស់នៅក្នុងឥរិយាបថ និង សកម្មភាពរបស់ទ្រង់។ នៅក្នុងភាពវិសុទ្ធរបស់ទ្រង់ រួមមានការសព្វព្រះហឫទ័យនឹងអ្វីដែលល្អ និង មិនសព្វព្រះហឫទ័យនឹងការអាក្រក់។ ដូច្នេះ ព្រះជាម្ចាស់គាប់ព្រះទ័យជាមួយនឹងភាពទៀងត្រង់ និង ភាពល្អត្រឹមត្រូវ ហើយទ្រង់កាត់អង្គទ្រង់ចេញពីមនុស្សអាក្រក់ និង ផ្តន្ទាទោសមនុស្សអាក្រក់។

ការកាត់ផ្តាច់អង្គព្រះជាម្ចាស់ ចេញពីមនុស្សគឺមានភាពចាំបាច់ណាស់ ដោយសារតែភាពមានបាបរបស់មនុស្ស។ សេចក្តីពិតនេះ ត្រូវបានបង្ហាញឲ្យឃើញជាច្រើនលើក នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ។ ព្រះជាម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេ កំណត់ព្រំដែននៅជុំវិញភ្នំស៊ីណៃ (គម្ពីរនិក្ខមនំ ១៩:១២-១៣, ២១-២៥) ។ ទ្រង់សព្វព្រះហឫទ័យឲ្យប្រជាជាតិអ៊ីស្រាអែលដឹងថាមនុស្សអាក្រក់ត្រូវតែកាត់ឲ្យដាច់ចេញពីព្រះជាម្ចាស់ដ៏វិសុទ្ធ។

ការកាត់ផ្តាច់ព្រះជាម្ចាស់ចេញពីមនុស្សមានបាប ក៏ត្រូវបានគេឃើញមាននៅក្នុងសញ្ញារបស់ជំរំ ឬ ព្រះពន្លា ដែលព្រះជាម្ចាស់បានបង្គាប់ឲ្យលោកម៉ូសេសាងសង់នៅក្នុងវាលរហោស្ថាន។ កន្លែងពិសេសមួយនៃជំរំនោះ ត្រូវបានគ្របដោយវាំងនន (សូមមើលគម្ពីរនិក្ខមនំ ២៦:៣៣)។ មានតែមនុស្សម្នាក់តែប៉ុណ្ណោះ អាចត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងកន្លែងមួយនោះ ម្នាក់នោះគឺបូជាចារ្យដ៏វិសុទ្ធម្នាក់ដែលត្រូវបានអនុញ្ញាតឲ្យចូល មួយឆ្នាំម្តងដើម្បីប្រោះឈាមនៅលើគម្របហិប (សូមមើលគម្ពីរលេវីវិន័យ ១៦)។ លោកបានធ្វើដូច្នេះ ដើម្បីរំដោះបាបរបស់មនុស្ស នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ។ ដោយធ្វើរបៀបនេះ ព្រះជាម្ចាស់សម្តែងឲ្យមនុស្សឃើញថា ទ្រង់មិនសព្វព្រះហឫទ័យចំពោះអំពើបាបរបស់ពួកគេកម្រិតណា។

នៅក្នុងគម្ពីរសម័ន្ធមេត្រីចាស់ មានភស្តុតាងជាច្រើនដែលបង្ហាញពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់។ គម្ពីរអេសាយ ៥៩:២ និង គម្ពីរហាបាគូក១:១៣ បង្រៀនថាអំពើបាបកាត់ផ្តាច់ព្រះជាម្ចាស់ចេញពីមនុស្សមានបាប ហើយវាកាត់ផ្តាច់មនុស្សមានបាបពីព្រះជាម្ចាស់ ។ គម្ពីរយ៉ូប៤០:៣-៥ និងគម្ពីរអេសាយ ៦:៥-៧ បង្ហាញយើងថាប្រសិនបើយើងមានការយល់ដឹងយ៉ាងពិតប្រាកដអំពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ នោះយើងក៏នឹងដឹងថាអំពើបាបគួរឲ្យខ្លាចយ៉ាងណា។ ពេលដែលយើងឃើញពីភាពវិសុទ្ធដែលគ្មានដែនកំណត់របស់ព្រះជាម្ចាស់ នោះយើងមានអារម្មណ៍សោកសៅចំពោះអំពើបាប យើងនឹងលន់តួបាប ហើយធ្វើឲ្យយើងម្នាក់ៗបានចេះបន្ទាបខ្លួន។

លំហាត់អនុវត្តន៍

១ ចូរបំពេញចន្លោះបន្ទាត់ខាងក្រោម ដោយយោងទៅតាមខគម្ពីរខាងលើ។

ក) ព្រះជាម្ចាស់មិនអាចប៉ះពាល់អ្វីដែលមិនបរិសុទ្ធបានឡើយ ព្រោះទ្រង់.....។

ខ) អំពើបាបបណ្តាលឲ្យយើង .....ពីព្រះជាម្ចាស់។

គ) ការយល់ដឹងអំពីភាពវិសុទ្ធឥតខ្ចោះរបស់ព្រះជាម្ចាស់ អាចធ្វើឲ្យយើងដឹងថា.....
.....។

ភាពវិសុទ្ធរបស់ព្រះជាម្ចាស់ក៏ជាប្រធានបទនៅក្នុងបទគម្ពីរសម័ន្ធមេត្រីថ្មីជាច្រើនផងដែរ។ យើងបានឃើញនៅក្នុងឧទាហរណ៍នៃគម្ពីរសម័ន្ធមេត្រីចាស់រួចមកហើយ ថាមនុស្សគ្មានសិទ្ធិចូលទៅកាន់ព្រះជាម្ចាស់ដោយផ្ទាល់នោះទេ ពួកគេក៏មិនអាចចូលទៅកាន់ព្រះជាម្ចាស់ដោយប្រើការខិតខំប្រឹងប្រែងផ្ទាល់ខ្លួនរបស់ពួកគេបានដែរ។ នៅក្នុងគម្ពីរសម័ន្ធមេត្រីចាស់ បូជាចារ្យម្នាក់បានចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ដើម្បីធ្វើពិធីរំដោះបាប សម្រាប់ប្រជាជន។ តែឥឡូវនេះការរំដោះបាប បានធ្វើឡើងតាមរយៈការបូជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ គឺព្រះយេស៊ូគ្រិស្ត។ យោងទៅតាមគម្ពីររ៉ូម៥:២ និង គម្ពីរអេភេសូ ២:១៣-១៨ ប្រសិនបើយើងចង់ចូលទៅកាន់ព្រះជាម្ចាស់ ត្រូវតែចូលទៅតាមរយៈគុណូបការៈរបស់ព្រះយេស៊ូ ។ គម្ពីរ១ពេត្រុស៣:១៨ ប្រាប់យើងថា ភាពមិនស្អាត និង ភាពទុច្ចរិតទាំងអស់របស់យើង ត្រូវបានគ្របដណ្តប់និង លើកលែងឲ្យដោយព្រះសង្គ្រោះដ៏សុចរិតរបស់យើង ដើម្បីនាំយើងឲ្យចូលទៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ។

លំហាត់អនុវត្តន៍

២ បទគម្ពីរទាំងនេះបានបង្រៀនយើងថា មធ្យោបាយតែមួយគត់ដែលអាចឲ្យយើងចូលទៅកាន់ព្រះវត្តមានរបស់ព្រះជាម្ចាស់ដ៏វិសុទ្ធ គឺតាមរយៈការរំដោះបាប ដែលបានប្រទានមកដោយ

ក) បូជាចារ្យម្នាក់

ខ) ការព្យាយាមឲ្យបានវិសុទ្ធរបស់យើង។

គ) ព្រះសង្គ្រោះរបស់យើងគឺព្រះយេស៊ូគ្រិស្ត។

យើងមិនអាចនិយាយអំពីព្រះជាម្ចាស់ ដោយមិននិយាយអំពីភាពសុចរិត និង ភាពយុត្តិធម៌របស់ទ្រង់បាននោះទេ។ អ្នកប្រាជ្ញខាងព្រះគម្ពីរជាច្រើនរូប បានញែកលក្ខណៈទាំងនេះ ជាគុណលក្ខណៈដោយឡែកផ្សេងទៀតនៃត្រៃឯកភាពពេញលេញ ប៉ុន្តែភាពសុចរិត និង ភាពយុត្តិធម៌គឺជាលទ្ធផលដែលបានមកពីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ផ្ទាល់តែម្តង។ លក្ខណៈទាំងនេះគឺជាផ្នែកមួយនៃភាពវិសុទ្ធរបស់ទ្រង់ ដែលយើញមាននៅក្នុងការដែលទ្រង់ធ្វើទៅលើមនុស្សលោក។

ទីមួយ ភាពវិសុទ្ធរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញឲ្យឃើញតាមរយៈ*ភាពសុចរិត* ។ ទ្រង់បានបង្កើតរដ្ឋាភិបាលដែលមានសីលធម៌នៅក្នុងពិភពលោក។ នេះមានន័យថា ទ្រង់បានប្រទានច្បាប់យុត្តិធម៌ (ភាពស្មើគ្នា និង ភាពត្រឹមត្រូវ) ដើម្បីឲ្យមនុស្សរស់នៅក្រោមច្បាប់នោះ។ ទីពីរ ភាពវិសុទ្ធរបស់ទ្រង់ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈ *ភាពយុត្តិធម៌* ។ ទ្រង់គ្រប់គ្រង ច្បាប់របស់ទ្រង់យ៉ាងយុត្តិធម៌ ទ្រង់ប្រទានរង្វាន់ឲ្យអ្នកស្តាប់បង្គាប់តាមច្បាប់របស់ទ្រង់ ហើយទ្រង់ដាក់ទោសអស់អ្នកដែលធ្វើល្មើសច្បាប់ទាំងនេះ។

ភាពសុចរិតរបស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឲ្យឃើញតាមរយៈការសព្វព្រះហឫទ័យភាពវិសុទ្ធដែលមាននៅក្នុងមនុស្សលោក។ ទ្រង់មិនត្រឹមតែជាព្រះជាម្ចាស់ដ៏វិសុទ្ធប៉ុណ្ណោះទេ ប៉ុន្តែទ្រង់តម្រូវឲ្យមនុស្សរបស់ទ្រង់បានវិសុទ្ធផងដែរ។ ភាពយុត្តិធម៌របស់ទ្រង់ ត្រូវបង្ហាញឲ្យឃើញតាមរយៈការនិច្ឆ័យទោសបាប។ ដោយសារតែទ្រង់មិនអាចទ្រាំទ្រជាមួយនឹងអំពើបាបបាន ទ្រង់ត្រូវតែដាស់ទោសអស់អ្នកដែលប្រព្រឹត្តិអំពើបាប។

លំហាត់អនុវត្តន៍

៣ ចូរអានគម្ពីរហេប្រឺ១២:១០,១៤ ហើយឆ្លើយនឹងសំណួរនេះ៖ តើព្រះជាម្ចាស់តម្រូវឲ្យធ្វើអ្វីខ្លះ បន្ទាប់ពីខ្ញុំបានក្លាយជាគ្រិស្តបរិស័ទម្នាក់ និងបានបែរចេញពីជីវិតដែលពេញដោយបាបរបស់ខ្ញុំហើយ?

.....

ភាពវិសុទ្ធដែលមាននៅក្នុងគុណសម្បត្តិនៃជីវិតរបស់គ្រិស្តបរិស័ទគឺមិនគ្រាន់តែជាការ *មិនធ្វើអ្វីដែលខុសនោះទេ។* វាក៏ជា *ការធ្វើរឿងត្រឹមត្រូវ* ផងដែរ។ នៅក្នុងសកម្មភាពជាក់ស្តែង វាគឺជាការបង្ហាញនៅក្នុងការរស់នៅ និង ការធ្វើអ្វីដែលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នាំយើងឲ្យធ្វើទៅចំពោះអ្នកដទៃ។ វាធ្វើឲ្យយើងមានចិត្ត និង ចេះបារម្ភពីអ្នកដទៃដែលនៅជុំវិញយើង។

ឧទាហរណ៍ យើងអាចរក្សាការស្តាប់បង្គាប់ព្រះជាម្ចាស់ នៅពេលដែលយើងជួយបំពេញតម្រូវការរបស់មនុស្ស។ យើងមិនចាំបាច់ត្រូវធ្វើឲ្យខុសគោលការណ៍របស់គ្រិស្តបរិស័ទ ដើម្បីគ្រាន់តែចង់ជួយអ្នកដទៃប៉ុណ្ណោះទេ។ រឿងប្រស្នារបស់ព្រះយេស៊ូនៅក្នុងគម្ពីរលូកា ១០:២៩-៣៧ បានបង្ហាញពីឧត្តមគតិរបស់គ្រិស្តបរិស័ទ (ខ្នាតគំរូនៃភាពឥតខ្ចោះ) ដែលយើងគប្បីយកមកឆ្លុះបញ្ចាំងមកកាន់យើងខ្លួនឯង។ ក្នុងពេលជាមួយគ្នានោះដែរ ភាពវិសុទ្ធស្តែងបញ្ជាក់ពីសកម្មភាពដែលបង្ហាញនូវឧត្តមគតិរបស់យើងក្នុងរបៀបជាក់ស្តែងទៅកាន់អ្នកជិតខាងរបស់យើង។

លំហាត់អនុវត្តន៍

៤ ចូរអានគម្ពីរលូកា១០:២៩-៣៧ ។ ចូរប្រាប់ពីថានរណាម្នាក់នៅក្នុងចំណោមអ្នកខាងក្រោមនេះដែលបង្ហាញពីឧត្តមគតិនៃភាពវិសុទ្ធរបស់គ្រិស្តបរិស័ទតាមរយៈទង្វើ? ហេតុអ្វី? ៖ បុរសម្នាក់ពីក្រុមលេវី សាសន៍សាម៉ារី ឬ បូជាចារ្យ។

ដូចដែលយើងបានឃើញនៅក្នុងគម្ពីរហេប្រឺ១២:១០ និង ខ១៤ ហើយថា ព្រះគម្ពីរបានជំរុញឲ្យយើងរាល់គ្នារស់នៅក្នុងជីវិតដែលវិសុទ្ធ ឬ ជីវិតដាច់ពីគេ។ មនុស្សអាចស្តាប់បង្គាប់តាមបទបញ្ជានេះបាន ហើយក្នុងពេលជាមួយគ្នា គេក៏អាចចូលរួមជាមួយជីវិតក្នុងសហគមន៍ ដូចដែលព្រះយេស៊ូបានបង្រៀននៅក្នុងគម្ពីរម៉ាថាយ ៥:១៣-១៦ ដែរ។ បទគម្ពីរនេះបង្រៀនថា យើងមិនត្រូវបាត់ភាពវិសុទ្ធរបស់យើងឡើយ ប៉ុន្តែយើងត្រូវធ្វើជាគំរូសម្រាប់អ្នកដទៃវិញ។ ដូច្នេះ គ្រិស្តបរិស័ទនឹងមិនយកខ្លួនពួកគេទៅបៀត អ្វីដែលព្រះគម្ពីរសម្ព័ន្ធមេត្រីបានហាមឃាត់នោះទេ។ ប៉ុន្តែពួកគេនឹងធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីបម្រើគ្រួសាររបស់ពួកគេ និង អ្នកជិតខាងរបស់ពួកគេ ព្រមទាំងបង្ហាញថាពួកគេពិតជាយកចិត្តទុកដាក់ជាមួយនឹងអ្នកទាំងនោះមែន។

លំហាត់អនុវត្តន៍

៥ នៅពេលយើងគិតពីភាពសុចរិត និង ភាពយុត្តិធម៌របស់ព្រះជាម្ចាស់ យើងទទួលបានគំរូល្អៗអំពីរបៀបដែលយើងគួរធ្វើទៅលើកូនៗរបស់យើង។ តើចម្លើយមួយណា នៅខាងក្រោមនេះជាអ្វីដែលយើងនឹងធ្វើ? (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ យើងនឹង.....

ក) ដាក់ទោសកូនរបស់យើងឲ្យបានញឹកញាប់ ដើម្បីរឹពកពួកគេថា ពួកគេត្រូវតែល្អគ្រប់ពេល។

ខ) មានយុត្តិធម៌នៅក្នុងការទាមទាររបស់យើង ឲ្យរង្វាន់ពួកគេនៅពេលពួកគេស្តាប់បង្គាប់ ហើយដាក់ទោសពួកគេនៅពេលពួកគេមិនស្តាប់បង្គាប់។

គ) ព្រមានពួកគេថា ពួកគេនឹងត្រូវទទួលការដាក់ទោស ប្រសិនបើពួកគេមិនស្តាប់បង្គាប់ ប៉ុន្តែមិនដែលធ្វើការដាក់ទោសណាមួយឡើយ ដ្បិតធ្វើដូច្នោះនឹងធ្វើឲ្យពួកគេមានការសង្ស័យចំពោះក្តីស្រឡាញ់របស់យើងសម្រាប់ពួកគេ។

សំណួរទី៥ នេះរំឭកយើងថា យើងត្រូវស្គាល់ និង យល់ គោលការណ៍នៅក្នុងព្រះគម្ពីរទាក់ទងនឹងវិន័យ។ យោងទៅតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឪពុកម្តាយដែលមិនប្រដៅកូនរបស់ខ្លួនពួកគេឲ្យបានជាប់លាប់នោះទេ គឺដូចនាំឲ្យពួកគេស្លាប់យ៉ាងដូច្នោះដែរ។ (គម្ពីរសុភាសិត ១៩:១៨) ។ គម្ពីរហេប្រឺ ១២:៦ និងគម្ពីរវិវរណៈ ៣:១៩ បង្រៀនថាព្រះជាម្ចាស់ប្រដៅអ្នកដែលទ្រង់ស្រឡាញ់។ ប្រសិនបើយើងពិតជាស្រឡាញ់កូនរបស់យើងមែន យើងត្រូវប្រដៅពួកគេដើម្បីឲ្យពួកគេបានល្អ (សូមមើលគម្ពីរហេប្រឺ១២:៥-១១)។

លំហាត់អនុវត្តន៍

---

៦ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលនិយាយអំពីសារៈសំខាន់នៃភាពវិសុទ្ធរបស់ព្រះជាម្ចាស់។

ក) ភាពវិសុទ្ធគឺលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបង្ហាញឲ្យឃើញពីភាពឥតខ្ចោះខាងឯសីលធម៌របស់ទ្រង់។

ខ) ដោយសារតែភាពវិសុទ្ធដ៏គ្មានដែនកំណត់របស់ទ្រង់ ព្រះជាម្ចាស់មិនអាចរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយប្រជារាស្ត្ររបស់ទ្រង់ឡើយ។

គ) ផ្នត់គំនិតនៃភាពវិសុទ្ធ រួមមានការស្រឡាញ់អ្វីដែលល្អ និង ប្រកបខ្ជាប់នូវក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ និង ការស្អប់អំពើអាក្រក់។

ឃ) នៅក្នុងជំនាន់សម័ន្ធមេត្រីចាស់ ព្រះជាម្ចាស់បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ទ្រង់នឹងមិនផ្តាច់អង្គទ្រង់ចេញពីប្រជារាស្ត្ររបស់ទ្រង់ឡើយ ទោះបីជាពួកគេប្រព្រឹត្តិអំពើបាបក៏ដោយ។

ង) របៀបដែលព្រះជាម្ចាស់គ្រប់គ្រងមនុស្សរបស់ទ្រង់ គឺជាលទ្ធផលដែលបានមកពីលក្ខណសម្បត្តិខាងឯសីលធម៌របស់ទ្រង់។

ច) ដោយសារព្រះជាម្ចាស់យុត្តិធម៌ ទ្រង់មិនត្រឹមតែប្រទានយុត្តិធម៌ដ៏វិសុទ្ធនោះទេ ប៉ុន្តែទ្រង់ក៏បានប្រទានមធ្យោបាយនៃការរំដោះបាប ប្រសិនបើប្រជារាស្ត្ររបស់ទ្រង់ខកខានមិនស្តាប់បង្គាប់ទ្រង់។

ឆ) ផ្នត់គំនិតនៃភាពវិសុទ្ធ មានន័យថាមិនធ្វើអ្វីដែលខុស។

សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

វត្ថុបំណងទី២. *ប្រាប់ថា និយមន័យនៃស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើងជាអ្វី និង ប្រាប់ពីរបៀបដែលសេចក្តីស្រឡាញ់នោះស្តែងចេញមក។*

ឧបមាថា មានបុរសម្នាក់បានប្រាប់ទៅនារីម្នាក់ថាគាត់ស្រឡាញ់នាង ប៉ុន្តែក្រោយពីពួកគេបានរៀបការហើយ អ្វីដែលគាត់ធ្វើមានតែអ៊ូរទាំដាក់នាង។ គាត់មិនបានបង្ហាញការចាប់អារម្មណ៍ទៅលើអ្វីដែល

មានសារៈសំខាន់សម្រាប់នាងនោះទេ ហើយគាត់មិនខិតខំធ្វើល្អចំពោះនាងសូម្បីតែបន្តិច។ តើអ្នកគិតយ៉ាងណាចំពោះក្តីស្រឡាញ់របស់គាត់សម្រាប់នាង?

ព្រះជាម្ចាស់ទ្រង់មិនយ៉ាងដូច្នេះទេ។ ទ្រង់ស្រឡាញ់អ្នក និង ខ្ញុំក្រៃលែង ហើយទ្រង់មិនត្រឹមតែបង្ហាញក្តីស្រឡាញ់នោះតាមរយៈព្រះបន្ទូល និង ការសន្យារបស់ទ្រង់នោះទេ តែទ្រង់ក៏បង្ហាញតាមរយៈអ្វីដែលទ្រង់ធ្វើផងដែរ។

គ្មានអ្វីដែលយើងអាចធ្វើបានដើម្បី សមនឹងទទួល ឬ រកបានសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់នោះឡើយ។ គ្មានអ្វីដែលយើងអាចនិយាយ ឬ ធ្វើដើម្បីតម្រូវឲ្យព្រះជាម្ចាស់មកស្រឡាញ់យើងបាននោះទេ។ ការស្រឡាញ់គឺជាផ្នែកមួយនៃនិស្ស័យរបស់ទ្រង់។ ទ្រង់ស្រឡាញ់ពិភពលោក ។ ទ្រង់ស្រឡាញ់យើង។

ព្រះជាម្ចាស់បានបង្ហាញយ៉ាងជាក់ស្តែង ថាទ្រង់ស្រឡាញ់យើងកម្រិតណា។ មានអ្នកខ្លះចាត់ទុក *ភាពល្អ សេចក្តីមេត្តាករុណា ការអត់ធ្មត់* និង *ភាពស្មោះត្រង់* ថាជាគុណលក្ខណៈដោយឡែករបស់ព្រះជាម្ចាស់ ប៉ុន្តែខ្ញុំចាត់ទុកលក្ខណៈទាំងនេះថាជាផ្នែកមួយនៃក្តីស្រឡាញ់របស់ទ្រង់។ អ្នកប្រហែលជានឹងគិតឃើញពីផ្នែកផ្សេងទៀតនៃក្តីស្រឡាញ់របស់ទ្រង់ ដែលអាចបន្ថែមនៅក្នុងគុណលក្ខណៈទាំងនេះ។ គុណលក្ខណៈទាំងនេះ បង្ហាញយើងថា យើងសំខាន់យ៉ាងណាសម្រាប់ទ្រង់។ គុណលក្ខណៈទាំងនេះក៏រំឭកយើងថា ទ្រង់យកព្រះទ័យទុកដាក់ចំពោះយើងយ៉ាងណាដែរ។

លំហាត់អនុវត្តន៍

---

៧ ចូរអានគម្ពីរយ៉ូហាន៣:១៦; ១៧:២៤ គម្ពីរ១យ៉ូហាន៤:៩-១០ និងគម្ពីរវិវរណៈ១:៤-៥។ ខគម្ពីរទាំងនេះបង្ហាញថា សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មានសកម្មភាព។ តើទង្វើបែបណាដែលបង្ហាញពីសេចក្តីស្រឡាញ់នេះ?

.....

៨ ចូរអានគម្ពីរយ៉ូហាន១៣:៣៤-៣៥; ១៤:១៥; ១៥:១៣-១៤ និងគម្ពីរ១យ៉ូហាន៥:២-៣ ។ ចូរប្រាប់ពីមធ្យោបាយពីរយ៉ាងដែលយើងបង្ហាញក្តីស្រឡាញ់របស់យើងសម្រាប់ព្រះជាម្ចាស់។

.....

.....

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់តែងតែត្រូវបានបង្ហាញថាជាអ្នកចម្បងដ៏អស្ចារ្យ និង មានឫទ្ធានុភាពម្នាក់។ ខ្ញុំរីករាយក្រៃលែង ដែលឃើញទ្រង់ក៏ត្រូវបានគេបង្ហាញថាជាព្រះជាម្ចាស់ដែលពេញដោយក្តីស្រឡាញ់។ ឧទាហរណ៍មួយដ៏អស្ចារ្យជាងគេ អំពីសេចក្តីស្រឡាញ់របស់ទ្រង់ បង្ហាញថាព្រះអង្គម្ចាស់ជាមេបំផ្លាញដែលពេញដោយកំហឹង ដែលហៀបនឹងដាក់ទោសទីក្រុងអាក្រក់ ប៉ុន្តែទ្រង់រារែក ទ្រង់ស្នាក់ស្ទើរនឹងបំផ្លាញទីក្រុងនោះ។ ហេតុអ្វីបានជាទ្រង់មិនធ្វើតាមផែនការរបស់ព្រះអង្គតែម្តងទៅ? ទោះជាយ៉ាងណាក្តី កំពែងបានស្រុតទៅហើយ និង គ្មានអ្វីទៅរាំងផ្លូវទៀតនោះទេ។ ប៉ុន្តែមានអ្វីម្យ៉ាង ធ្វើឲ្យទ្រង់ស្នាក់ស្ទើរ នោះគឺក្តីស្រឡាញ់របស់ទ្រង់សម្រាប់មនុស្សអាក្រក់ទាំងនោះ។ ទ្រង់មានព្រះបន្ទូលថា៖ "

យើងស្វែងរកក្នុងចំណោមពួកគេ ក្រែងលោឃើញនរណាម្នាក់មានគំនិតសង់កំពែងការពារក្រុង ហើយឈរនៅចំពោះមុខយើងត្រង់កន្លែងបាក់បែក ដើម្បីការពារស្រុកទេសកុំអោយវិនាស តែយើងរកពុំបានសោះ" (គម្ពីរអេសេគាល ២២:៣០)។ ប្រសិនបើមានមនុស្សសុចរិតណាម្នាក់ បានទៅទីនោះហើយទូលអង្វរសុំក្តីមេត្តាពីទ្រង់ ទ្រង់ប្រហែលជាអាចលើកលែងឲ្យទីក្រុងនោះ។ ការនេះពិតជាបានបង្ហាញពីក្តីស្រឡាញ់របស់ទ្រង់យ៉ាងខ្លាំង។

លោកដាវីឌ លោកអេសាយ និង លោកយេរេមា បង្ហាញអំពីព្រះជាម្ចាស់ថាជា *ឪពុក* ។ តើមានអ្វីទាក់ទងនឹង ឪពុកដ៏ល្អម្នាក់សម្រាប់កូនៗរបស់គាត់ ដែលនាំឲ្យពួកលោកធ្វើការប្រៀបធៀបមួយនេះ? លោកដាវីឌបានមានប្រសាសន៍ថា៖ ព្រះជាម្ចាស់មានព្រះទ័យអាណិតអាសូរចំពោះបុត្ររបស់ទ្រង់។ ទ្រង់ជ្រាបថា ពួកគេទន់ខ្សោយមិនអាចជួយខ្លួនឯងបានទេ (គម្ពីរទំនុកតម្កើង ១០៣:១៣-១៤) ។ លោកអេសាយបានចាត់ទុកព្រះជាម្ចាស់ដូចជាឪពុកមាន *ក្តីមេត្តាករុណា* (គម្ពីរអេសាយ៦៣:១៦; ៦៤:៨)។ លោកយេរេមាមើលទៅកាន់ព្រះជាម្ចាស់ថាជាឪពុកដែល បន្ទាប់ពីដាក់ទោសកូនណាដែលមិនស្តាប់បង្គាប់ ហើយនាំពួកគេទៅផ្ទះវិញដោយទន់ភ្លន់ (គម្ពីរយេរេមា ៣១:៧-៩)។

នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី យើងមានឧទាហរណ៍ដ៏ឧត្តមអស្ចារ្យ អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ នៅពេលដែលព្រះយេស៊ូបានយាងមកលើផែនដី ដើម្បីបង់លោះទោសបាបរបស់យើង ទ្រង់បានបង្ហាញពីថ្លៃឈ្នួលដ៏អាក្រក់នៃអំពើបាប (សេចក្តីស្លាប់)។ ទ្រង់បានប្រទានការសង្គ្រោះមកឲ្យយើង ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន នោះគឺព្រះជន្មទ្រង់ផ្ទាល់ (គម្ពីរយ៉ូហាន ៤:១៦-១៧) ។ ដ្បិតព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងខ្លាំង យើងដឹងថាទ្រង់នឹងមិនអនុញ្ញាតឲ្យមានរឿងអ្វីកើតឡើងនៅក្នុងជីវិតរបស់យើង ដែលមិនអាចផ្តល់ប្រយោជន៍សម្រាប់យើងបាននោះទេ ប្រសិនបើយើងស្រឡាញ់ទ្រង់។ យើងអាចទុកចិត្តលើក្តីស្រឡាញ់របស់ទ្រង់ មិនថាកាលៈទេសៈរបស់យើងទៅជាយ៉ាងណាក៏ដោយ។ ក្តីស្រឡាញ់របស់ទ្រង់រំដោះយើងពីភាពភ័យខ្លាច និង ទារណកម្មនៃភ័យខ្លាច (គម្ពីរ១យ៉ូហាន ៤:១៨ គម្ពីរ២ធីម៉ូថេ ១:៧)។

លំហាត់អនុវត្តន៍

៩ ដោយសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូររៀបរាប់អំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលអ្នកអាចរកឃើញនៅក្នុងគម្ពីរអេសាយ ៤៣:១-៥។ ចូរអ្នករកឲ្យបានគុណលក្ខណៈធម្មជាតិរបស់ទ្រង់បីយ៉ាង និង គុណលក្ខណៈខាងឯសីលធម៌របស់ទ្រង់ពីរយ៉ាង។

១០ តើអ្នកមានមិត្តភក្តិណាដែលមិនដឹងថា ព្រះជាម្ចាស់ស្រឡាញ់ពួកគេដែរឬទេ? ចូរអានគម្ពីរម៉ាថាយ ២៤:១៤; ២៨:១៩ និង គម្ពីរកិច្ចការ ១:៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ តើអ្វីជាទំនួលខុសត្រូវរបស់អ្នកសម្រាប់អស់អ្នកដែលមិនដឹងអំពីក្តីស្រឡាញ់របស់ព្រះជាម្ចាស់? ចូរសរសេរចម្លើយដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

គម្ពីរអេសេគាល ១៨:១-៣២ បង្ហាញពីក្តីស្រឡាញ់ដ៏អស្ចារ្យដែលព្រះជាម្ចាស់មានសម្រាប់ប្រជារាស្ត្ររបស់ទ្រង់។ នៅពេលខ្លះពួកគេមិនបានឃើញពីមូលហេតុនៃទុក្ខលំបាករបស់ពួកគេ ព្រះជាម្ចាស់មានព្រះបន្ទូលថា អ្វីដែលទ្រង់សព្វព្រះទ័យចង់បានពីពួកគេគឺការបម្រើដោយស្តាប់បង្គាប់។ ការដាក់ទោសត្រូវ

បានធ្វើឡើង ដើម្បីបង្ហែរអារម្មណ៍របស់ពួកគេមករកទ្រង់ និងដើម្បីនាំឲ្យមានការផ្សះផ្សា និង ព្យាបាលទំនាក់ទំនងរបស់ពួកគេជាមួយនឹងទ្រង់។ ខទី៣១ និង ទី៣២ បញ្ជាក់ពីកម្រិតនៃក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលមានចំពោះសាសន៍អ៊ីស្រាអែល និង បំណងព្រះហឫទ័យដ៏អស់កល្បជានិច្ចរបស់ទ្រង់សម្រាប់ការសង្គ្រោះប្រជាជនរបស់ទ្រង់៖

> ចូរបោះបង់ចោលអំពើទុច្ចរិតទាំងអស់ដែលអ្នករាល់គ្នាបានប្រព្រឹត្ត។ ចូរមានចិត្តគំនិតថ្មី និងវិញ្ញាណថ្មី! ជនជាតិអ៊ីស្រាអែលអើយអ្នករាល់គ្នាមិនគួរស្លាប់ឡើយ ដ្បិតយើងមិនសប្បាយចិត្តនឹងអោយនរណាម្នាក់ស្លាប់ទេ ចូរវិលមករកយើងវិញ នោះអ្នករាល់គ្នានឹងរស់រានមានជីវិត» -នេះជាព្រះបន្ទូលរបស់ព្រះជាអម្ចាស់ -។

លំហាត់អនុវត្តន៍

---

១១ ចូរជ្រើសរើសចម្លើយត្រឹមត្រូវ ដែលនិយាយអំពីអត្ថន័យនៃក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើង និង របៀបដែលក្តីស្រឡាញ់នោះត្រូវបានបង្ហាញមក។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

ក) បង្ហាញថា ទោះបីមនុស្សធ្វើយ៉ាងណាតបទៅចំពោះទ្រង់ ទ្រង់នឹងទតរំលងអំពើបាបរបស់ពួកគេ។

ខ) បង្ហាញពីសេចក្តីល្អ សេចក្តីមេត្តាករុណា ការអត់ធ្មត់ និង ព្រះគុណ នៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ទ្រង់ជាមួយមនុស្ស និង សេចក្តីស្រឡាញ់នេះ បានស្តែងឡើងនៅតាមរបៀបជាក់ស្តែងមួយ ដូចជាអត់ទោសបាប។

គ) បណ្តាលឲ្យមានការដាក់ទោស ហើយសេចក្តីស្រឡាញ់នេះបង្ហាញឲ្យឃើញតាមរយៈភាពមិនស្ទាក់ស្ទើររបស់ទ្រង់ ហើយប្រទានឱកាសមួយទៀតឲ្យមនុស្សដើម្បីឲ្យពួកគេបានបម្រើទ្រង់។

ខ. រាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់

វត្ថុបំណងទី៣. *បកស្រាយសកម្មភាពនៃការបង្កើតរបស់ព្រះជាម្ចាស់ និង សារសំខាន់នៃការបង្កើតនោះសម្រាប់យើង។*

ពេលនេះយើងនឹងពិចារណាអំពីព្រះរាជកិច្ចរបស់ព្រះជាម្ចាស់៖ ១) *ព្រះរាជ្យកិច្ចនៃការបង្កើត* របស់ទ្រង់ ២) ការគ្រងរាជ្យរបស់ទ្រង់នៅលើសាកលលោក ដែលរួមបញ្ចូល *ការថែរក្សា* ឬ *ការការពារ* របស់ទ្រង់ចំពោះស្នាព្រះហស្តរបស់ទ្រង់ និង ៣) *ការផ្គត់ផ្គង* របស់ទ្រង់ ដែលនាំឲ្យមានបំណងព្រះហឫទ័យដ៏អស់កល្បជានិច្ចរបស់ទ្រង់។ ទីមួយ យើងនឹងមើលទៅលើអ្វីដែលព្រះគម្ពីរបង្រៀនអំពីការបង្កើតរបស់សព្វសារពើរបស់ទ្រង់។

មនុស្សតែងតែមានឈ្មោះល្បីនៅក្នុងប្រវត្តិសាស្ត្រ មិនដោយសារតែពួកគេ*ជានរណា* នោះទេ ប៉ុន្តែដោយសារតែអ្វីដែលពួកគេបាន*ធ្វើ*។ ជាឧទាហរណ៍ លោកស្រី ម៉ារី ឃឺរី (Madame Marie Curie) មិនល្បីល្បាយដោយសារតែគាត់ជាសមាជិកនៅក្នុងពង្សាវតារក្សត្រនោះទេ ប៉ុន្តែដោយសារគាត់ជារូបវិទូ និង ជាគីមីវិទូ ដែលបានធ្វើរបកគំហើញ រេឌីយ៉ូម (Radium) និង ភូលូញ៉ូម (Polonium)។

ផ្ទុយទៅវិញ ភាវៈដ៏ខ្ពង់ខ្ពស់ឧត្តមនៅក្នុងសាកលលោក មានសារៈសំខាន់សម្រាប់យើង ព្រោះទ្រង់គឺជាទ្រង់។ ស្របពេលជាមួយគ្នា អ្វីដែលទ្រង់*ធ្វើ* (ព្រះរាជ្យកិច្ចរបស់ទ្រង់) គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើង។ ព្រះរាជ្យកិច្ចទីមួយរបស់ព្រះជាម្ចាស់ គឺការបង្កើតសាកលលោក (គម្ពីរលោកុប្បត្តិ ជំពូក១ និង ជំពូក២)

តាមរយៈការសម្តែងឫទ្ធានុភាពនៃការបង្កើតរបស់ទ្រង់ ព្រះជាម្ចាស់បានបង្កើតឲ្យមានទាំងសាកលលោកដែលអាចមើលឃើញ និង មិនអាចមើលឃើញ។ ទាំងនេះរួមមានប្រព័ន្ធនៃពិភពលោកដែលមានរូប (ព្រះអាទិត្យ ព្រះច័ន្ទ ដួងតារា ភព និង របស់ជាច្រើនផ្សេងទៀត) និង ភាវៈគ្រប់ជាន់ថ្នាក់រួមទាំងភាវៈជាវិញ្ញាណទាំងអស់ លើកលែងព្រះអង្គផ្ទាល់។ ការបង្កើតនេះ គឺថ្លែងប្រាប់យ៉ាងច្បាស់នៅក្នុងបទគម្ពីរដូចដែលយើងបានឃើញស្រេច។

ព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរបានបង្ហាញ សកម្មភាពនៃការបង្កបង្កើតតាមលំដាប់ ដែលនៅពេលបូកបញ្ចូលគ្នាបង្កើតបានទៅជាដំណើររឿងដ៏អស្ចារ្យ នៃការបង្កបង្កើត (គម្ពីរលោកុប្បត្តិ ១និង២ គម្ពីរទំនុកតម្កើង ៣៣:៦) ។ ការពិតនៃការបង្កបង្កើតមានអត្ថន័យសម្រាប់ជីវិតរបស់យើង តាមរបៀបជាច្រើនយ៉ាង៖

១. ការដឹងថាព្រះអាទិករនៃសាកលលោក ទ្រង់គង់នៅតាំងពីមុនអ្វីៗទាំងអស់ផ្សេងទៀត នឹងអាចធ្វើឲ្យយើងស្ងប់ស្ងែងភាពអស្ចារ្យ និង ព្រះតេជៈដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ និង អាចឲ្យយើងដឹងពីភាពមិនសំខាន់របស់យើង ដោយធៀបជាមួយនឹងទ្រង់។

២. ព្រះអម្ចាស់នៃរបស់សព្វសារពើ ទ្រង់មានសិទ្ធិទទួលបានការថ្វាយបង្គំ និង ការបម្រើដោយការស្តាប់បង្គាប់ ពីរបស់ដែលទ្រង់បានបង្កើត។

៣. នៅក្នុងការបង្កើតពិភពលោក យើងឃើញការបើកបង្ហាញជាទូទៅមួយរបស់ព្រះអាទិករ ដែលតាមរយៈការនេះ ព្រះប្រាជ្ញាញាណ ព្រះឫទ្ធានុភាព និង ការយកព្រះទ័យទុកដាក់ទៅលើស្នាព្រះហស្តរបស់ទ្រង់ ក៏ត្រូវបានបង្ហាញឲ្យឃើញ (គម្ពីររ៉ូម ១:១៨-២០)។

៤. សេចក្តីបង្រៀនរបស់ព្រះគម្ពីរទៅលើការបង្កើតពិភពលោក គឺជាមូលដ្ឋានគ្រឹះនៃជំនឿរបស់យើង ដ្បិតយើងមិនអាចថ្វាយខ្លួនរបស់យើងទៅព្រះណាផ្សេងទៀតដែលមានឫទ្ធានុភាពតិចជាងព្រះអាទិករដែលបានបង្ហាញនៅក្នុងបទគម្ពីរ ដើម្បីទទួលការសង្គ្រោះដ៏អស់កល្បជានិច្ចបានឡើយ។

យើងមិនចាំបាច់ឆ្ងល់ថា*ហេតុអ្វី* បានជាព្រះជាម្ចាស់រចនា និង បង្កើតរបស់គ្រប់យ៉ាងមកនោះទេ។ ទ្រង់ធ្វើយ៉ាងដូច្នេះ ដើម្បីសិរីរុងរឿងរបស់ទ្រង់ (សូមមើលគម្ពីរទំនុកតម្កើង ១៩:១គម្ពីរអេសាយ ៤៣:៧; ៤៨:១១ គម្ពីរវិវរណៈ ៤:១១)។ មនុស្សមានដំណើរជីវិតដោយការស្វែងរកសុភមង្គលទុកជាគោលដៅតែមួយគត់របស់ពួកគេ ប៉ុន្តែសុភមង្គលដ៏ពិតប្រាកដបានមក ពេលណាដែលយើងស្វែងរកការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តែមួយគត់ប៉ុណ្ណោះ។ យើងត្រូវបានបង្កើតឡើងដើម្បីបង្ហាញគោលបំណងមួយនោះ ហើយបំណងនោះគឺជាគន្លឹះរបស់យើងឆ្ពោះទៅរកសុភមង្គល។ មិត្តរបស់ខ្ញុំម្នាក់ បានតួញក្បែរដាក់ខ្ញុំថា គាត់មិនសប្បាយចិត្តទេ ព្រោះគាត់មិនទាន់អាចធ្វើរឿងអស្ចារ្យសម្រាប់ព្រះជាម្ចាស់។ ខ្ញុំបានសួរទៅកាន់គាត់ថា៖ "តើគោលដៅខ្ពស់បំផុតរបស់អ្នកគឺជាការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមរយៈអ្វីដែលអ្នកធ្វើមែនទេ? តើអ្នកហ៊ានអនុញ្ញាតឲ្យ*អ្វីៗគ្រប់យ៉ាង* កើតឡើងដើម្បីឲ្យគោលដៅនេះសម្រេចបានដែរ

ឬទេ? មិត្តរបស់ខ្ញុំបានដឹងថាមហិច្ឆតារបស់គាត់ ក្នុងការធ្វើអ្វីដែលអស្ចារ្យកន្លងមក ពិតជាគោលដៅសំខាន់នៅក្នុងជីវិតរបស់គាត់មែន។ គាត់គ្រាន់តែកុហកខ្លួនឯង ឲ្យគិតថាគាត់ចង់ធ្វើការទាំងនោះសម្រាប់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ដ្បិតអ្នកណាចង់បានរួចជីវិត អ្នកនោះនឹងបាត់បង់ជីវិតពុំខាន រីឯអ្នកដែលបាត់បង់ជីវិត ព្រោះតែខ្ញុំ និងព្រោះតែដំណឹងល្អ* នឹងបានជីវិតវិញ" (គម្ពីរម៉ាកុស ៨:៣៥) ។ យើងត្រូវបានបង្កើតឡើងមកដើម្បីនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់។

នៅក្នុងក្រុមមនុស្សខ្លះ គេមើលឃើញសាកលលោកនេះថាមានតាំងយូរលុងមកហើយ ជាមួយនឹងប្រវត្តិសាស្ត្រដែលវិលជុំនៅក្នុងវដ្តនៃការបង្កើត ការបំផ្លាញ និង ការបង្កើតឡើងវិញ គ្មានទីបញ្ចប់។ គោលដៅពិតតែមួយសម្រាប់មនុស្សដែលរស់នៅក្នុងក្រុមនេះ គឺដើម្បីរួចផុតពីអត្ថិភាពដែលពេញដោយភាពសោកសៅ។ គំនិតនៅក្នុងព្រះគម្ពីរ អំពីសាកលលោក គឺមានការចាប់ផ្តើម (ការបង្កើតរបស់សព្វសារពើ) មានគោលបំណង (ការសង្គ្រោះមនុស្សជាតិតាមរយៈព្រះយេស៊ូគ្រិស្ត) និង សេចក្តីសន្យាថាមានជីវិតអស់កល្បជានិច្ចនៅក្នុងនគររបស់ព្រះជាម្ចាស់។

ទស្សនៈទាំងពីរនេះ មានបង្ហាញនៅក្នុងគំនូសបម្លែងខាងក្រោម៖



ទស្សនៈវិលជុំ

ទស្សនៈក្នុងព្រះជាម្ចាស់

លំហាត់អនុវត្តន៍

១២ ដោយសរសេរនៅក្នុងសៀវភៅរបស់អ្នក ចូរបកស្រាយពីរបៀបដែលទស្សនៈទាំងនេះ ធៀបជាមួយនឹងទស្សនៈដែលយល់ឃើញដោយមនុស្សភាគច្រើនដែលអ្នកស្គាល់។ តើទស្សនៈរបស់ក្រុមមនុស្សនៅក្នុងសង្គមដែលអ្នករស់នៅ ប្រៀបធៀបជាមួយនឹងទស្សនៈនៅក្នុងព្រះគម្ពីរយ៉ាងដូចម្តេច?

ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺមិនត្រូវបានកំណត់ដោយអ្វីដែលទ្រង់បានធ្វើនៅក្នុងអតីតកាលនោះទេ ។ គម្ពីរយ៉ូហាន ៣:៣ គម្ពីរ២កូរិនថូស ៥:១៧ គម្ពីរកាឡាទី ៦:១៥ និង គម្ពីរទំនុកតម្កើង ៥១:១០ ប្រាប់ថា ព្រះជាម្ចាស់បានបន្សុទ្ធដួងចិត្តអ្នកណាដែលលន់តួអំពើបាបរបស់ពួកគេ ហើយចូលមករកទ្រង់ដោយជំនឿ។ បទគម្ពីរទាំងនេះ ក៏ប្រាប់យើងថា នៅពេលណាដែលមនុស្សបែរទៅរកព្រះជាម្ចាស់ ដើម្បីទទួលការសង្គ្រោះ ពួកគេនឹងបានកើតជាថ្មី ហើយក្លាយជាភាវៈថ្មីមួយទៀត ឬ ជាស្នាព្រះហស្តថ្មីមួយទៀត។ ដូច្នេះព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ រួមមាន ការបង្កើតខាងឯវិញ្ញាណ ដែលធ្វើឡើងនៅពេលមនុស្សម្នាក់ទទួលយកព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់ពួកគេ។

លំហាត់អនុវត្តន៍

១៣ ចូរគូសរង្វង់ជុំវិញអក្សរនៅមុខចម្លើយត្រឹមត្រូវ។

ក) ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ បង្ហាញពីលក្ខណសម្បត្តិរបស់ទ្រង់នៅក្នុងរបៀបទូទៅមួយ ទៅកាន់ភាវៈដែលទ្រង់បានបង្កើត។

ខ) ការបង្កើតពិភពលោក ធ្វើឲ្យយើងដឹងពីភាពអស្ចារ្យ និង ព្រះតេជៈដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ និង អំពីភាពមិនសំខាន់របស់យើង បើធៀបជាមួយនឹងទ្រង់។

គ) ការបើកសម្តែងរបស់ព្រះជាម្ចាស់នៅក្នុងព្រះរាជកិច្ចនៃការបង្កើតរបស់ទ្រង់ មិនមែនជាការទាមទារឲ្យមានការឆ្លើយតបពីភាវៈដែលទ្រង់បានបង្កើតនោះទេ។

ឃ) ចំណេះដឹងអំពីឫទ្ធានុភាព និង និស្ស័យរបស់ព្រះជាម្ចាស់ ដូចដែលបានបង្ហាញនៅក្នុងការបង្កើតរបស់សព្វសារពើរបស់ទ្រង់ អាចនាំឲ្យយើងថ្វាយសិរីរុងរឿងទៅកាន់ទ្រង់។

ង) ព្រះរាជកិច្ចនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺមិនត្រូវបានកំណត់ត្រឹមព្រឹត្តិការណ៍ដែលមានកត់ត្រានៅក្នុងគម្ពីរលោកុប្បត្តិជំពូក១ និងជំពូក២នោះទេ។

គ. រាជកិច្ចនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះជាម្ចាស់

វត្ថុបំណងទី៤. *យកគោលការណ៍ទៅប្រើប្រាស់នៅក្នុងស្ថានភាពជីវិត និង ប្រាប់ពីនិយមន័យនៃការគ្រងរាជ្យជាស្តេចនៃសាកលលោករបស់ព្រះជាម្ចាស់។*

ព្រះអាទិករនៃសាកលលោកដ៏ឧត្តម មានអំណាចគ្រប់គ្រងលើអ្វីទាំងអស់ ដែលទ្រង់បានបង្កើតមក។ តើការនេះមានន័យយ៉ាងដូចម្តេច? ពាក្យថា *ឧត្តម* មានន័យថា "ឋានៈ ឬ អំណាចខ្ពស់បំផុត កម្រិត និង គុណសម្បត្តិ ខ្ពស់បំផុត"។ ព្រះជាម្ចាស់ទ្រង់ខ្ពង់ខ្ពស់ជាងអ្វីៗទាំងអស់នៅក្នុងពិភពលោកនេះ ក្នុងគ្រប់ផ្នែកទាំងអស់។ ពាក្យថា *ព្រះអធិបតី* មានន័យថា "មិនស្ថិតនៅអំណាចគ្រប់គ្រង និង ឫទ្ធានុភាពក្នុងការធ្វើអ្វីៗតាមតែទ្រង់សព្វព្រះហឫទ័យ" ។

ដូច្នេះ អធិបតីភាពរបស់ព្រះជាម្ចាស់ រៀបរាប់អំពីអំណាចគ្រប់គ្រងយ៉ាងឧត្តមរបស់ទ្រង់ នៅលើសាកលលោកទាំងមូល (គម្ពីរ១ធីម៉ូថេ ៦:១៥)។ អធិបតីភាពរបស់ព្រះជាម្ចាស់ គឺត្រូវបានបង្ហាញនៅក្នុងការដឹកនាំរបស់ទ្រង់ទៅលើព្រឹត្តិការណ៍ទាំងអស់នៅក្នុងសាកលលោក ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរអេភេសូ ១:១១)។ បទគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗ អំពីអធិបតីភាពរបស់ព្រះជាម្ចាស់ ៖ ១) ក្នុងនាមជាព្រះអាទិកររបស់យើង ទ្រង់មានសិទ្ធិគ្រប់គ្រងលើយើង (គម្ពីរ ១របាក្សត្រ ២៩:១១ គម្ពីរម៉ាថាយ ២០:១៥ គម្ពីរអេសេគាល ១៨:៤) ២) ទ្រង់ធ្វើអ្វីៗគ្រប់បែបយ៉ាង ដែលទ្រង់សព្វព្រះហឫទ័យ (គម្ពីរទំនុកតម្កើង ១១៥:៣ គម្ពីរដានីយ៉ែល ៤:៣៥) ៣) អ្វីៗទាំងអស់ដែលទ្រង់ធ្វើគឺសុទ្ធតែមានគោលបំណង (គម្ពីររ៉ូម ៨:២៨ គម្ពីរអេសាយ ៤៨:១១)។

មានថ្ងៃមួយ ខ្ញុំបានអានកាសែតដែលនិយាយអំពី អំពើឃាតកម្មយ៉ាងសាហាវមួយទៅលើក្មេងស្រីវ័យ៥ឆ្នាំដ៏គួរឲ្យស្រឡាញ់ម្នាក់។ តើរឿងនេះអាចកើតឡើងបានយ៉ាងដូចម្តេច ប្រសិនបើព្រះជាម្ចាស់ពិតជាព្រះល្អ ពិតជាព្រះអធិបតី និង ជាព្រះដែលមានឫទ្ធានុភាពធ្វើអ្វីដែលទ្រង់សព្វព្រះហឫទ័យមែននោះ? ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យមានរឿងបែបនេះកើតឡើងបាន? យើងនឹងស្វែងចម្លើយសម្រាប់សំណួរទាំងនេះ នៅពេលយើងពិចារណាទៅលើផ្នែកផ្សេងៗនៃការគ្រងរាជ្យជាអធិបតីរបស់ព្រះជាម្ចាស់ នៅលើសាកលលោក។ អធិបតីភាពរបស់ព្រះជាម្ចាស់ រួមមាន *ការការពារ* ឬ *ការថែរក្សា* សាកលលោក និង *ឧបការគុណ* ។ ដំបូង យើងនឹងពិចារណាអំពីការការពារ ឬ ការថែរក្សា សាកលលោករបស់ព្រះអង្គ។

ការការពារ(ការថែរក្សា) សាកលលោក

គ្មានស្ថាបត្យករដ៏ឆ្លាតវៃណាម្នាក់ អាចរចនាផ្ទះដែលមិនទាមទារឲ្យមានការជួសជុលសោះនោះទេ។ គ្មានអ្នកថែសួនណាម្នាក់អាចដាំគ្រាប់ពូជនៃផ្កាដ៏ស្រស់ស្អាត ដោយគ្មានការថែរក្សា ដូចជាលស់មែកជម្រះស្មៅ និង ស្រោចទឹកនោះទេ។ ព្រះគម្ពីរបានបង្រៀនយើងថា សាកលលោកនេះក៏ត្រូវការការពារ ឬ ការថែរក្សាផងដែរ (គម្ពីរកិច្ចការ ១៧:២៨ គម្ពីរហេប្រឺ ១:៣)។

ព្រះជាម្ចាស់ទ្រង់ថែរក្សា ឬ មើលថែ សាកលោកនេះយ៉ាងសកម្ម។ បទគម្ពីរបានបង្ហាញថា ក្រោយពេលទ្រង់បង្កើតរបស់សព្វសារពើហើយ ព្រះជាម្ចាស់បន្ត សកម្មភាពរបស់ទ្រង់ដោយមើលថែរបស់សព្វសារពើទាំងអស់ (គម្ពីរទំនុកតម្កើង ១០៤)។ របស់ទាំងនេះរួមទាំងមនុស្ស និង សត្វ (គម្ពីរទំនុកតម្កើង ៣៦:៦) និង ការពារអស់អ្នកដែលត្រឹមត្រូវ និង មនុស្សសុចរិត (គម្ពីរសុភាសិត ២:៨)។

លោកសាវ័កប៉ូលបានប្រកាសថា៖ "ដ្បិតយើងមានជីវិត មានចលនា និងមានភាវៈជាមនុស្ស ដោយសារព្រះអង្គ" (គម្ពីរកិច្ចការ ១៧:២៨) ។ ព្រះជាម្ចាស់មិនអាចជាព្រះអធិបតីបាននោះទេ ប្រសិនបើអ្វីៗដែលមាន ឬ កើតឡើងនៅក្នុងសាកលលោកស្ថិតនៅដាច់ឆ្ងាយពីបំណងព្រះហឫទ័យ និង ឫទ្ធានុភាពរបស់ទ្រង់។ បទគម្ពីរដូចជាគម្ពីរនេហេមា៩:៦ និង គម្ពីរទំនុកតម្កើង ១៤៥:១៤-១៦ បង្រៀនថា ព្រះជាម្ចាស់ទ្រង់ចូលរួមយ៉ាងសកម្ម នៅក្នុងការការពាររបស់សព្វសារពើ។ បទគម្ពីរខ្លះទៀត ប្រកាសថា ព្រះអម្ចាស់ការពារប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរទុតិយកថា ១:៣០-៣១ គម្ពីរទំនុកតម្កើង ៣១:២០; ៣៤:១៥,១៧,១៩ គម្ពីរអេសាយ ៤៣:២)។

យើងត្រូវតែដឹងថា ការការពារពីព្រះជាម្ចាស់គឺមានភាពចាំបាច់ណាស់ ព្រោះអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់បានបង្កើតមក គឺត្រូវពឹងផ្អែកទាំងស្រុងលើទ្រង់ ទាំងការរស់រានមានជីវិត និង ការធ្វើសកម្មភាព។ ភាវៈទាំងអស់គ្មានអំណាចអ្វីដែលអាចបន្តអត្ថិភាពដោយខ្លួនឯងបានឡើយ។ ភាវៈទាំងនោះមានជីវិត និង បន្តមានជីវិតទៅមុខទៀត ដោយព្រោះតែបំណងព្រះហឫទ័យរបស់ព្រះអាទិករ។ ដោយសារតែអំណាចនៃព្រះបន្ទូលរបស់ទ្រង់ ភាវៈទាំងអស់ និង សាកលលោកទាំងមូល ទទួលបានការគាំពារ និង ថែរក្សា (គម្ពីរហេប្រឺ ១:៣)។

នៅពេលរបស់សព្វសារពើ បន្តមានអត្ថិភាពដោយសារការធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទ្រង់បានប្រទានលក្ខណៈពិសេសៗ ទៅផ្នែកនីមួយៗនៃស្នាព្រះហស្តរបស់ទ្រង់ ដើម្បីជាប្រយោជន៍ដល់ការថែរក្សារបស់នោះ។ នៅក្នុងពិភពមានរូប ទ្រង់ធ្វើការតាមរយៈលក្ខណៈមានរូបរាង និង ច្បាប់ ដែលពេលខ្លះយើងសំដៅទៅលើ "ច្បាប់ធម្មជាតិ" ។ នៅក្នុងពិភពខាងឯប្រាជ្ញា ទ្រង់ធ្វើការតាមរយៈលក្ខណៈ និង សមត្ថភាពនៃគំនិត ទ្រង់បានប្រទានឲ្យយើងនូវសមត្ថភាពក្នុងការគិត ឆន្ទៈនិងធ្វើការសម្រេចចិត្ត។ ព្រះជាម្ចាស់ធ្វើការតាមរយៈលក្ខណៈទាំងនេះ នៅក្នុងទំនាក់ទំនងជាមួយយើងរាល់គ្នា។ នៅក្នុងការការពារ ពិភពលោក ព្រះជាម្ចាស់មិនរំខានប៉ះពាល់អ្វីដែលទ្រង់បានធ្វើហើយជាមួយនឹងស្នាព្រះហស្តរបស់ទ្រង់ឡើយ។ ទ្រង់គ្រាន់តែថែរក្សាអ្វីដែលទ្រង់បានបង្កើតមកតែប៉ុណ្ណោះ។

លំហាត់អនុវត្តន៍

១៤ (ចូរជ្រើសរើសចម្លើយត្រឹមត្រូវ)។ ការថែរក្សារបស់ព្រះជាម្ចាស់ចំពោះស្នាព្រះហស្តរបស់ទ្រង់មានន័យថា

ក) ទ្រង់មានឫទ្ធានុភាពដែលមានកម្រិតមួយ ដើម្បីផ្លាស់ប្តូររបស់ណាដែលបានរងការខូចខាត។

ខ) ទ្រង់បានចូលរួមយ៉ាងសកម្មនៅក្នុងការការពាររបស់សព្វសារពើ។

គ) គ្រប់ផ្នែកទាំងអស់នៃស្នាព្រះហស្តរបស់ទ្រង់មានសមត្ថភាពក្នុងការថែរក្សាខ្លួនឯង។

ឃ) ទ្រង់បានប្រទានលក្ខណៈចាំបាច់ទៅកាន់គ្រប់ផ្នែកនៃស្នាព្រះហស្តរបស់ទ្រង់ ហើយទ្រង់ធ្វើការតាមរយៈលក្ខណៈទាំងនេះដើម្បីថែទាំរបស់សព្វសារពើ។

ង) ដោយបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ របស់សព្វសារពើនៅក្នុងសាកលលោកនេះបានបន្តនៅមាន។

ច) ទ្រង់ប្រទានការថែទាំ និង ការការពារសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។

ឆ) ទ្រង់បានខ្វល់ព្រះទ័យតែពីរឿងការការពារមនុស្សទៀងត្រង់។

ខ្ញុបការគុណ

វត្ថុបំណងទី៥. *លើកឧទាហរណ៍អំពីគោលបំណង ធាតុមូលដ្ឋាន និង ឥទ្ធិពលនៃឧបការគុណរបស់ព្រះជាម្ចាស់។*

ផ្នែកមួយទៀតនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះជាម្ចាស់ គឺ*ឧបការគុណរបស់*ព្រះអង្គ។ ទោះបីជាផ្នែកនេះមានទាក់ទងនឹងការការពារ ប៉ុន្តែវាគឺលើសពីនោះទៅទៀត។ ឧបការគុណនេះ ក៏មានន័យសំដៅទៅលើសមត្ថភាពរបស់ព្រះជាម្ចាស់ក្នុងការទតទៅពេលខាងមុខ ការទាយដឹងមុន និង ការរៀបចំផែនការទុកជាមុន។ វាសំដៅទៅក្នុងសមត្ថភាពរបស់ព្រះជាម្ចាស់ក្នុងការបំពេញបំណងព្រះហឫទ័យដែលធំបំផុតរបស់ទ្រង់នៅក្នុងស្នាព្រះហស្តរបស់ទ្រង់ ដែលជាការកសាងព្រះរាជ្យរបស់ទ្រង់ នៅក្រោមការគ្រប់គ្រងរបស់ព្រះយេស៊ូគ្រិស្ត។ ការនេះ និយាយអំពីសកម្មភាពរបស់ព្រះជាម្ចាស់ ដែលតាមរយៈសកម្មភាពនោះ ទ្រង់ថែរក្សា ថែទាំ និង គ្រប់គ្រង អ្វីដែលទ្រង់បានបង្កើត។ របៀបដែលទ្រង់អាចធ្វើការ

ទាំងនេះបាន គឺនៅតែជាអាថ៌កំបាំង ប៉ុន្តែមានរឿងមួយចំនួនដែលយើងអាចដឹង អំពីឧបការគុណរបស់ព្រះជាម្ចាស់ដែលទាក់ទងជាមួយយើង៖

១. ព្រះជាម្ចាស់ចូលរួមដោយផ្ទាល់ ទៅក្នុងពិភពលោកដែលទ្រង់បានបង្កើត។
២. ទ្រង់បណ្តាលឲ្យអ្វីៗទាំងអស់នៅក្នុងធម្មជាតិ ធ្វើចលនាតាមព្រះហឫទ័យរបស់ព្រះអង្គ។
៣. ទ្រង់ផ្តល់អំណាច និង បណ្តាលឲ្យមនុស្សមានតួនាទីជា ភ្នាក់ងារដែលមានសីលធម៌ និង ទំនួលខុសត្រូវ ជាមួយនឹងសេរីភាពក្នុងការជ្រើសរើសរវាងត្រូវ និង ខុស។
៤. ប្រសិនបើយើងជ្រើសរើស ទទួលយកការសង្គ្រោះដែលទ្រង់បានប្រទានមក ព្រះជាម្ចាស់នឹងប្រទានឲ្យយើងនូវជីវិតដ៏អស់កល្បជានិច្ច ជាមួយនឹងសេចក្តីអំណរ និង ភាពរុងរឿងគ្រប់ទាំងអស់ដែលព្រះតេជៈរបស់ទ្រង់បានប្រទានឲ្យ។

គោលបំណងនៃឧបការគុណ

មានគោលបំណងជាច្រើន ចំពោះការគ្រប់គ្រងតាមរយៈឧបការគុណរបស់ព្រះជាម្ចាស់ ដែលជាប់ក្នុងទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយនឹងស្នាព្រះហស្តរបស់ទ្រង់ ដែលស្រឡាញ់ និង ស្តាប់បង្គាប់ទ្រង់៖

១. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ គឺត្រូវបានសំគាល់ដោយ ព្រះទ័យទុកដាក់សម្រាប់យើង។*

បទគម្ពីរជាច្រើនបង្ហាញថា *ព្រះជាម្ចាស់ទ្រង់គ្រប់គ្រង ក្នុងបំណងសម្រាប់ភាពរីករាយនៃប្រជារាស្ត្ររបស់ទ្រង់ ។* គម្ពីរទំនុកតម្កើង ៨៤:១១ ថ្លែងថា៖ "ព្រះអង្គតែងតែប្រទានសុភមង្គលអោយអស់អ្នកដែលរស់នៅ ដោយគ្មានសៅហ្មង។" បទគម្ពីរផ្សេងទៀតដូចជា គម្ពីរកិច្ចការ១៤:១៧ និង គម្ពីរ៉ូម ៨:២៨ ក៏បានបង្ហាញពីការខ្វល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ភាពរីករាយ និង សេចក្តីសុខរបស់យើងផងដែរ។

២. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់គឺត្រូវបានសំគាល់ដោយការខ្វល់ព្រះហឫទ័យចំពោះការអភិវឌ្ឍខាងឯគំនិត និង សីលធម៌នៃប្រជារាស្ត្ររបស់ទ្រង់។*

ទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយប្រជារាស្ត្ររបស់ទ្រង់ នៅទូទាំងប្រវត្តិសាស្ត្រ មានរួមបញ្ចូលការបង្រៀនពួកគេ ដើម្បីឲ្យពួកគេដឹងថា ១) អ្វីដែលទ្រង់ត្រូវការពីពួកគេ ២) និស្ស័យរបស់ទ្រង់គឺវិសុទ្ធ ៣) អំពើបាបគឺជាការប្រមាថទៅចំពោះព្រះអង្គ និង ៤) ទ្រង់ប្រទានការអត់ទោសបាប និង ការផ្សះផ្សាជាមួយនឹងទ្រង់វិញ។ នៅក្នុងជំនាន់មុន ទ្រង់បានអនុញ្ញាតឲ្យធ្វើរឿងមួយចំនួន ដូចជាការលែងលះ ប្តីប្រពន្ធ ព្រោះមនុស្សគឺមិនទាន់ដឹងក្តី (គ្មានការលូតលាស់) ។ គម្ពីរម៉ាកុស ១០:៥ បានចែងអំពីការទាំងនេះ ។ ក្រឹត្យវិន័យនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ប្រព័ន្ធរដ្ឋាភិបាលរបស់ពួកលេវី គឺជាផ្នែកមួយនៃដំណើរការក្នុងការអភិវឌ្ឍនេះ។ ក្រឹត្យវិន័យ និងប្រព័ន្ធទាំងនេះ បានរៀបចំផ្លូវសម្រាប់ការបើកសំដែងរបស់កូនចៀមនៃព្រះជាម្ចាស់ (ព្រះយេស៊ូ) ដែលដកយកអំពើបាបចេញពីពិភពលោកនេះ។ ឧបការគុណរបស់ព្រះជាម្ចាស់ទាំងអស់ នៅក្នុងការដឹកនាំប្រជារាស្ត្ររបស់ទ្រង់ចូលទៅក្នុងភាពពេញវ័យ ខាងឯវិញ្ញាណ គឺដើម្បីគោលបំណងក្នុងការរៀបចំពួកគេឲ្យក្លាយជាសម្បត្តិពិសេសរបស់ទ្រង់។

៣. *ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ មានគោលដៅចម្បង ដែលជាសិរីរុងរឿងរបស់ទ្រង់ផ្ទាល់។* (គម្ពីរអេភេសូ ១:១១-១៤)។

ភាពឥតខ្ចោះរបស់ទ្រង់ទាំងអស់ គឺត្រូវបានបង្ហាញឲ្យឃើញតាមរយៈការគ្រប់គ្រងរបស់ទ្រង់។ នេះមានន័យថាឧបការគុណដ៏វិសុទ្ធរបស់ទ្រង់ បង្ហាញមកកាន់យើងពីគុណសម្បត្តិនៃអង្គទ្រង់។ ឧទាហរណ៍ *សេចក្តីស្រឡាញ់* របស់ទ្រង់ត្រូវបានបង្ហាញឲ្យនៅការផ្គត់ផ្គង់សម្រាប់ភាវៈដែលទ្រង់បានបង្កើត ជាពិសេសនៅក្នុងការផ្តល់ជូនសម្រាប់ការប្រោសលោះពួកគេតាមរយៈព្រះបុត្រារបស់ទ្រង់។ *សេចក្តីពិត* របស់ទ្រង់ ត្រូវបានបង្ហាញទាំងនៅក្នុងច្បាប់ធម្មជាតិ និង នៅក្នុងភាពស្មោះត្រង់របស់ទ្រង់ក្នុងការបំពេញតាមព្រះបន្ទូលសន្យារបស់ទ្រង់។ *ភាពវិសុទ្ធ* និង *ភាពសុចរិត* របស់ទ្រង់ត្រូវបានបង្ហាញនៅក្នុងការស្អប់អំពើបាបរបស់ព្រះអង្គ។ *ឫទ្ធានុភាព* របស់ទ្រង់ត្រូវបានសម្តែងឲ្យឃើញនៅក្នុងកិច្ចការរបស់ទ្រង់នៅក្នុងការបង្កើត ការប្រោសលោះ និង ឧបការគុណរបស់ទ្រង់។ *ព្រះប្រាជ្ញា* ញាណរបស់ទ្រង់ត្រូវបានឃើញនៅក្នុងរបៀបដែលទ្រង់ធ្វើការដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់។ នៅពេលយើងស្គាល់ពីភាពអស្ចារ្យនៃព្រះអាទិករបស់យើង យើងថ្វាយការគោរព និង ការតម្កើងសិរីរុងរឿងទៅកាន់ទ្រង់។

លំហាត់អនុវត្តន៍

---

១៥ តើចម្លើយណាមួយនៅខាងក្រោមនេះជានិយមន័យត្រឹមត្រូវនៃពាក្យថា *ឧបការគុណ*?

ឧបការគុណគឺ

ក) ការការពារ របស់សព្វសារពើ ដែលព្រះជាម្ចាស់បានប្រទានឲ្យគ្រប់ផ្នែកនីមួយៗនៃស្នាព្រះហស្តរបស់ទ្រង់ នូវសមត្ថភាពក្នុងការបំពេញតម្រូវការផ្ទាល់ខ្លួន ដោយគ្មានការពឹងផ្អែកណាមួយពីទ្រង់នោះឡើយ។

ខ) ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលទ្រង់រក្សា ថែទាំ និង ដឹកនាំ ស្នាព្រះហស្តរបស់ទ្រង់ គឺដើម្បីរៀបចំរបស់ទាំងនោះដើម្បីព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់។

១៦ ចូរផ្គូផ្គងបំណងនៃឧបការគុណ (ខាងស្តាំ) ទៅនឹងការរៀបរាប់អំពីបំណងនោះ (ខាងឆ្វេង)។

.....ក) ព្រះជាម្ចាស់ធ្វើការនៅក្នុងរបស់សព្វសារពើ ជាមួយនឹងការខ្វល់ព្រះហឫទ័យសម្រាប់ភាពសុខសប្បាយរបស់មនុស្ស។	១) សិរីរុងរឿងរបស់ព្រះជាម្ចាស់
	២) ការអភិវឌ្ឍផ្នែកគំនិត និង សីលធម៌របស់មនុស្ស
.....ខ) ព្រះជាម្ចាស់ប្រទានឲ្យមានការអប់រំទៅកាន់មនុស្ស អំពីអង្គទ្រង់ និង ការទាមទាររបស់ព្រះអង្គ ដើម្បីឲ្យពួកគេបានក្លាយជាសម្បត្តិដ៏ពិសេសរបស់ទ្រង់។	៣) ភាពរីករាយរបស់មនុស្ស
.....គ) ការបើកសំដែងរបស់ព្រះជាម្ចាស់ អំពីគុណសម្បត្តិរបស់អង្គទ្រង់ បង្ហាញឲ្យឃើញបំណងមួយនេះ។	

ធាតុផ្សំនៃឧបការគុណ

តើអ្វីខ្លះជាធាតុផ្សំនៃឧបការគុណ? អ្នកប្រាជ្ញខាងឯព្រះគម្ពីរជាច្រើនបានលើកឡើងថា ឧបការគុណរបស់ព្រះជាម្ចាស់មានបីផ្នែក។ ប៉ុន្តែ ពួកគាត់ដឹងថាមានចំណុចដដែលជាន់គ្នាខ្លះៗ និង ដឹងថាផ្នែកទាំងបីនឹងមិនត្រូវចែកដាច់គ្នាបាន នៅក្នុងព្រះរាជកិច្ចរបស់ព្រះជាម្ចាស់នោះទេ។ ធាតុផ្សំទាំងនោះមាន *ការការពារ ការយល់ស្រប* និង *ការគ្រប់គ្រង*។

១. *ការការពារ*

ការបានពិភាក្សាគ្នាអំពីការការពារឬ ការថែរក្សារបស់ព្រះជាម្ចាស់ ទៅចំពោះសាកលលោក ជាផ្នែកមួយនៃការគ្រងរាជ្យជាព្រះអធិបតីរបស់ព្រះអង្គទៅលើរបស់សព្វសារពើរួចមកហើយ។ព្រះជាម្ចាស់ទ្រង់ចូលរួមយ៉ាងសកម្មនៅក្នុងការការពារស្នាព្រះហស្តរបស់ទ្រង់។ អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតគឺសុទ្ធតែផ្អែកទៅលើទ្រង់ ប៉ុន្តែទ្រង់នៅតែប្រទានលក្ខណៈមួយទៅគ្រប់ផ្នែកនីមួយៗនៃការបង្កើតរបស់ទ្រង់ដើម្បីប្រទានការថែរក្សាសម្រាប់ផ្នែកទាំងនោះ។ គម្ពីរលោកុប្បត្តិ ១:២៤-២៥ ចង្អុលបង្ហាញថា ព្រះជាម្ចាស់បានប្រោសប្រទានឲ្យសត្វនីមួយៗ នូវលក្ខណៈធម្មជាតិជាក់លាក់ ដែលមានពិសេសសម្រាប់ពូជសត្វនោះ។ សត្វនីមួយៗ លូតលាស់ អភិវឌ្ឍ ពេញវ័យ និង បន្តពូជដោយយោងទៅតាមប្រភេទរបស់វា។

២. *ការយល់ស្រប*

ពាក្យថា *ការយល់ស្រប* មានន័យថា៖ "ការព្រមព្រៀង ការសហប្រតិបត្តិការណ៍ ឬ ការយល់ព្រម"។ ពាក្យនេះប្រាប់ពីគំនិតដែលថា គ្មានសកម្មភាពទៅលើបញ្ហាណាមួយ ឬ គំនិតណាមួយអាចធ្វើឡើងបានឡើយ បើគ្មានការយល់ព្រមរបស់ព្រះជាម្ចាស់ និង គំនិតដែលថាឫទ្ធានុភាពរបស់ទ្រង់សហការណ៍ជាមួយនឹងអំណាចផ្សេងៗទៀតដែលនៅក្រោមទ្រង់។ នៅក្នុងគម្ពីរកិច្ចការ ១៧:២៨ និង គម្ពីរ១កូរិនថូស ១២:៦ លោកសាវ័កប៉ូលបានបញ្ជាក់ថា បើគ្មានការយល់ស្របពីព្រះជាម្ចាស់ គ្មានកម្លាំងណា ឬ មនុស្សម្នាក់ណាអាចបន្តជីវិត ឬ ធ្វើសកម្មភាពបាននោះទេ។ ដូច្នេះ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអំណាចរបស់យើង ដោយគ្មានការបំផ្លាញ ឬ ដកហូតសេរីភាពរបស់យើងឡើយ។ យើងបានរក្សា និង ប្រើប្រាស់អំណាចពីធម្មជាតិរបស់យើង ស្របពេលដែលព្រះជាម្ចាស់ការពារគំនិត និង រូបកាយរបស់យើងឲ្យបំពេញតួនាទីពីធម្មជាតិរបស់វា។

ដោយសារព្រះជាម្ចាស់ជាគ្រឹះនៃអត្ថិភាពរបស់យើង យើងមិនអាចនិយាយថាចំណែករបស់យើងស្មើនឹងចំណែករបស់ព្រះជាម្ចាស់បាននោះទេ។ សាជាថ្មីម្តងទៀត យើងឃើញពីអាថ៌កំបាំងយ៉ាងជ្រាលជ្រៅ ៖ ព្រះជាម្ចាស់បានប្រទានអំណាចពីធម្មជាតិមកឲ្យយើង ដែលយើងអាចប្រើប្រាស់សម្រាប់ការល្អ ឬ ការអាក្រក់។ នៅពេលដែលអំណាចពីធម្មជាតិទាំងនេះ ត្រូវបានយកទៅប្រើប្រាស់នៅក្នុងផ្លូវអាក្រក់ យើងនឹងទទួលខុសត្រូវតែម្នាក់ឯងគត់ ដ្បិតព្រះជាម្ចាស់មិនបានបណ្តាយឲ្យយើងធ្វើទង្វើអាក្រក់នោះទេ (គម្ពីរយេរេមា ៤:៤៤ គម្ពីរយ៉ាកុប ១:១៣-១៤)។ ព្រះជាម្ចាស់*យល់ស្រប* តាមទង្វើយើង តាមរយៈការប្រទានឲ្យយើងនូវអំណាចពីធម្មជាតិ ប៉ុន្តែផ្លូវអាក្រក់នៃអំណាចទាំងនេះ គឺបង្កឡើងដោយយើងខ្លួនឯង។ ឧទាហរណ៍មួយអំពីការយល់ស្រប គឺនៅក្នុងករណីរបស់លោកយ៉ូសែប (គម្ពីរលោកុប្បត្តិ ៤៥:៥; ៥០:២០) ។ នៅត្រង់នេះ យើងឃើញថា នៅពេលដែលបងប្អូនរបស់គាត់បានប្រើប្រាស់អំណាចធម្មជាតិរបស់

ពួកគេដើម្បីធ្វើការអាក្រក់ ព្រះជាម្ចាស់ប្រឆាំងនឹងទង្វើនោះដើម្បីការល្អ។ ទ្រង់ស្រប ឬ អនុញ្ញាត សកម្មភាពរបស់ពួកគេ ប៉ុន្តែទ្រង់ធ្វើការតាមរយៈសកម្មភាពនោះ ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។

លោកប៉ូលបានមានប្រសាសន៍ថាព្រះជាម្ចាស់ "បានតំរូវយើងទុកជាមុនដូច្នេះ ស្របតាមផែនការរបស់ព្រះអង្គ ដែលសំរេចគ្រប់កិច្ចការទាំងអស់តាមព្រះហឫទ័យរបស់ព្រះអង្គ" (គម្ពីរអេភេសូ ១:១១) និងថា ព្រះជាម្ចាស់ធ្វើការនៅក្នុងយើង "ធ្វើអោយបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្តតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ។" (គម្ពីរភីលីព ២:១៣) ។ ទ្រង់ប្រទានឲ្យយើងនូវចំណេះដឹងជ្រៅជ្រះ នៅក្នុងស្ថានភាពជីវិត និង នាំផ្លូវយើងដោយព្រះវិញ្ញាណរបស់ទ្រង់។ ទ្រង់ព្រមានយើងអំពីផលវិបាក នៃភាពបរាជ័យ និង ព្យាយាមយកឈ្នះយើង យ៉ាងទន់ភ្លន់។ ប៉ុន្តែទ្រង់មិនបានចំអកសេរីភាពរបស់យើង ដោយការបង្ខំឲ្យយើងតាមបំណងព្រះហឫទ័យរបស់ព្រះអង្គឡើយ។ នៅក្នុងការសង្គ្រោះ ទ្រង់ចាប់ផ្តើមកិច្ចការដ៏ស្រស់ស្អាតរបស់ទ្រង់ ដោយឈរនៅខាងក្រៅទ្វារនៃដួងចិត្តរបស់យើង ទាំងគោះទ្វារនោះផង ប៉ុន្តែយើងត្រូវបើកទ្វារនោះ (គម្ពីរវិវរណៈ ៣:២០)។ បន្ទាប់មកព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅក្នុងយើង។ ទ្រង់រក្សាការគ្រប់គ្រងនៅលើជីវិតរបស់យើង ដរាបណាយើងនៅបន្តចុះចូលក្រោមភាពជាព្រះអម្ចាស់របស់ទ្រង់។ ទំនាក់ទំនងរបស់យើងជាមួយទ្រង់ ជាព្រះអម្ចាស់នៃយើង បន្តទៅមុខលើមូលដ្ឋានគ្រឹះនៃក្តីស្រឡាញ់របស់យើងសម្រាប់ទ្រង់ និង ជម្រើសរបស់យើងក្នុងការថ្វាយឲ្យទ្រង់មានការគ្រប់គ្រងមកលើជីវិតរបស់យើង។

៣. *ការគ្រប់គ្រង*

ការនេះសំដៅទៅលើសកម្មភាពនៃការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ជាមួយនឹងគោលបំណងដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់។ ដូចដែលយើងបានឃើញហើយថា ព្រះជាម្ចាស់គ្រប់គ្រងពិភពលោកដែលមានរូបនេះ តាមមធ្យោបាយនៃច្បាប់ដែលទ្រង់បានបង្កើតឡើង។ ទ្រង់គ្រប់គ្រងមនុស្សតាមរយៈច្បាប់ និង លក្ខណៈនៃគំនិត និងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការ។ នៅក្នុងការធ្វើរឿងទាំងនេះ ទ្រង់ប្រើប្រាស់ឥទ្ធិពលគ្រប់ប្រភេទ ដូចជាកាលៈទេសៈ ការជំរុញ ការណែនាំ ការបញ្ចុះបញ្ចូល និង គំរូ។ ទ្រង់ធ្វើការដោយផ្ទាល់តាមរយៈ ការប្រើប្រាស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីជះឥទ្ធិពលទៅលើគំនិតបញ្ញា អារម្មណ៍ និង ឆន្ទៈរបស់យើង។

ព្រះជាម្ចាស់គ្រប់គ្រងតាមរយៈមធ្យោបាយយ៉ាងតិចបួនយ៉ាង។ ការស្វែងយល់ពីមធ្យោបាយទាំងនេះ ជួយឲ្យយើងឃើញទំនាក់ទំនងរវាងបំណងព្រះហឫទ័យដ៏ឧត្តមបំផុតរបស់ព្រះជាម្ចាស់ នៅក្នុងការសម្រេច ផែនការដ៏វិសុទ្ធរបស់ទ្រង់ ជាមួយនឹងឆន្ទៈរបស់យើងនៅក្នុងការធ្វើសកម្មភាពដោយមានសេរីភាព។

ក. ពេលខ្លះព្រះជាម្ចាស់ *មិនធ្វើអ្វីម្យ៉ាង* ដើម្បីរារាំងយើងមិនឲ្យធ្វើអ្វីដែលយើងបានជ្រើសរើសធ្វើឡើយ។ នេះមិនមែនមានន័យថាព្រះជាម្ចាស់ យល់ស្របឲ្យមនុស្សម្នាក់ធ្វើអំពើបាបនោះទេ ប៉ុន្តែទ្រង់ក៏ប្រើប្រាស់ឫទ្ធានុភាពរបស់ទ្រង់ដើម្បីរារាំងការនោះផងដែរ។ ឧទាហរណ៍ អំពីការនេះមាននៅក្នុង គម្ពីរកិច្ចការ ១៤:១៥-១៦ និង គម្ពីរទំនុកតម្កើង ៨១:១២-១៣។

ខ. ពេលខ្លះ ព្រះជាម្ចាស់*រារាំង* មនុស្សពីការធ្វើអំពើបាប ដោយជះឥទ្ធិពលទៅលើពួកគេមិនឲ្យប្រព្រឹត្តិអំពើបាប។ ឧទាហរណ៍មាននៅក្នុងគម្ពីរលោកុប្បត្តិ ២០:៦, ៣១:២៤ និង គម្ពីរហូសេ ២:៦។ អ្នកនិពន្ធបានអធិស្ឋានសម្រាប់ជំនួយបែបនេះ នៅក្នុងគម្ពីរទំនុកតម្កើង ១៩:១៣ ៖ "សូមការពារទូលបង្គំអោយ.....ឥតជាប់ជំពាក់នឹងអំពើបាបដ៏ធ្ងន់នេះទេ។

គ. ពេលខ្លះ ដោយមានការ*ដឹកនាំ* ដ៏វិសុទ្ធ ព្រះជាម្ចាស់បាន *គ្រប់គ្រង* លើទង្វើរបស់មនុស្សអាក្រក់ ដោយប្រើប្រាស់ពួកគេដើម្បីសម្រេចបានលទ្ធផលល្អ។ យើងបានឲ្យឧទាហរណ៍អំពីការនេះ រួចមកហើយនៅក្នុងចំណុចដែលនិយាយអំពីលោកយូសែប។ បងប្អូនរបស់គាត់បានធ្វើអំពើបាប ប៉ុន្តែព្រះជាម្ចាស់បានប្រើប្រាស់ការនោះដើម្បីសម្រេចបាននូវអ្វីម្យ៉ាងដែលល្អ។

ឃ. ចុងក្រោយ ពេលខ្លះព្រះជាម្ចាស់ *បានសម្រេចព្រះទ័យធ្វើការកំណត់អំពើបាប* និង ភាពទុច្ចរិត ។ បទគម្ពីរដូចជាគម្ពីរយ៉ូប១:១២ និង ២:៦ បានបញ្ជាក់ថា ព្រះជាម្ចាស់បានដាក់កំណត់ទៅលើសកម្មភាពរបស់សាតាំង។ នៅក្នុងគម្ពីរ១កូរិនថូស ១០:១៣ លោកប៉ូលបានប្រកាសថាព្រះជាម្ចាស់ក៏បានដាក់កំណត់មួយ ទៅលើការល្បួងល និង ការល្បួង ដែលគ្រិស្តបរិស័ទត្រូវ អត់ទ្រាំជាមួយ។

ឧបការគុណបានផ្តល់គំនិតឲ្យយើងដឹងថាព្រះជាម្ចាស់គ្រប់គ្រងលើរបស់សព្វសារពើ ដោយក្តីស្រឡាញ់។ សេចក្តីស្រឡាញ់នេះ ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់បំផុតនៅក្នុងពាក្យរបស់លោកសាវ័ក ៖ " យើងដឹងទៀតថា អ្វីៗទាំងអស់ធ្សំគ្នាឡើង ដើម្បីអោយអស់អ្នកស្រឡាញ់ព្រះជាម្ចាស់ បានទទួលផលល្អ គឺអ្នកដែលព្រះអង្គបានត្រាស់ហៅមក ស្របតាមគំរោងការរបស់ព្រះអង្គ"
(គម្ពីររ៉ូម ៨:២៨)។

លំហាត់អនុវត្តន៍

---

១៧ ចូរផ្គូផ្គងធាតុធ្សំនៃឧបការគុណ (ខាងស្តាំ) ទៅនឹងការរៀបរាប់របស់ធាតុធ្សំ (ខាងឆ្វេង)។

.....ក) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ធ្វើការជាមួយនឹងអំណាចផ្សេងៗដែលនៅក្រោមទ្រង់ ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់អនុញ្ញាតឲ្យអំណាចទាំងនោះធ្វើការសម្រេចចិត្តដោយខ្លួនឯង ទ្រង់មិនបានធ្វើឲ្យមានទង្វើអាក្រក់កើតឡើងសោះឡើយ។

.....ខ) ព្រះជាម្ចាស់គ្រប់គ្រងតាមរបៀបមួយដែលនឹងអាចឲ្យសម្រេចបានគំរោងការដ៏វិសុទ្ធរបស់ទ្រង់។ នេះមានន័យថាពេលខ្លះទ្រង់មិនធ្វើអ្វីសោះ ពេលខ្លះទ្រង់រារាំង ពេលខ្លះទៀតទ្រង់គ្រប់គ្រង ហើយពេលខ្លះ ទ្រង់ដាក់កំណត់សកម្មភាពណាដែលធ្វើឡើងមានបំណងអាក្រក់។

១) ការការពារ
២) ការយល់ស្រប
៣) ការគ្រប់គ្រង

.....គ) ព្រះជាម្ចាស់បានប្រទានឲ្យសត្វលោកដែលជារបស់ទ្រង់នូវ
លក្ខណៈធម្មជាតិ តាមរយៈលក្ខណៈទាំង
នេះ ទ្រង់ធ្វើការដើម្បីប្រទានការថែរក្សាសម្រាប់
ពួកគេ អ្វីៗដែលទ្រង់បានបង្កើត មានលក្ខណៈ
ដោយផ្អែកទៅលើទ្រង់ជាដាច់ខាតដើម្បីមានជីវិត
រស់។

ឥទ្ធិពលនៃខ្ជបការគុណ

តើឧបការគុណមានឥទ្ធិពលទៅលើបទពិសោធន៍ផ្ទាល់ខ្លួនយ៉ាងដូចម្តេច? បទគម្ពីរជាច្រើនបង្ហាញពីការសន្យារបស់ព្រះជាម្ចាស់ ដើម្បីប្រទានពរសម្រាប់មនុស្សសុចរិត (សូមមើលគម្ពីរលេវីវិន័យ ២៦:៣-១៣ គម្ពីរទុតិយកថា ២៨:១-១៤)។ ទ្រង់ប្រទានពរមនុស្សរបស់ទ្រង់។ ព្រះពររបស់ទ្រង់ គឺមានច្រើនលើសជាងការដែលយើងអាចនិយាយបាន។

ប៉ុន្តែមនុស្សសុចរិតតែងតែឆ្ងល់ថា " ហេតុអ្វីបានជាមនុស្សអាក្រក់ក៏ទទួលបានការរីកចម្រើនដែរ? ហេតុអ្វីបានជាពួកគេមិនត្រូវទទួលទោស?" អ្នកនិពន្ធកណ្ឌគម្ពីរទំនុកដំកើងបានឆ្លើយតបថា ១) ការរីកចម្រើនរបស់ពួកគេគឺតែមួយរយៈពេលប៉ុណ្ណោះ ហើយ ២) ព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសភាពទុច្ចរិតរបស់ពួកគេនៅថ្ងៃណាមួយ (គម្ពីរទំនុកតម្កើង ៣៧:១៦-២២; ៧៣:១-២៨ ហើយសូមមើលនៅក្នុងគម្ពីរម៉ាឡាគី ៣:១៣-៤:៣)។

ដូច្នេះ នៅពេលមាននរណាម្នាក់សួរអ្នក "ហេតុអ្វីបានជាព្រះជាម្ចាស់មិន បញ្ឈប់អំពើហិង្សាទាំងអស់?" អ្នកអាចឆ្លើយតបទៅវិញប្រកបដោយទំនុកចិត្តថា "សូមចាំមើលពីឈុតចុងក្រោយនៃល្ខោននេះទៅ ។ ព្រះជាម្ចាស់បានចាប់ផ្តើមផែនការរបស់ទ្រង់ក្នុងការលុបបំបាត់ភាពអាត្មានិយម ភាពអស់សង្ឃឹម ការបះបោរ និង ភាពពុករលួយ។ នៅក្នុងផែនការដ៏អស់កល្បជានិច្ចរបស់ទ្រង់ នឹងមានការប្រទានពរ និងការរីកចម្រើន សម្រាប់អស់អ្នកណាដែលស្រឡាញ់ទ្រង់។" នៅក្នុងពេលនេះ ព្រះជាម្ចាស់ពន្យារពេលវិនិច្ឆ័យទោស ដើម្បីផ្តល់ឱកាសម្តងទៀតទៅដល់មនុស្សអាក្រក់ដើម្បីធ្វើការ លន់តួ (គម្ពីររ៉ូម ២:៤ គម្ពីរ២ ពេត្រុស ៣:៩)។

សំណួរមួយទៀតដែលគ្រិស្តបរិស័ទតែងតែសួរគឺ "ហេតុអ្វីបានជាអ្នកជឿត្រូវរងការសាកល្បងច្រើនខ្លាំងម្ល៉េះ ប្រសិនបើព្រះជាម្ចាស់មានការគ្រប់គ្រងយ៉ាងពេញលេញទៅលើព្រឹត្តិការណ៍នៅក្នុងជីវិត ពិតមែននោះ?" ព្រះគម្ពីរបានបង្ហាញមូលហេតុជាច្រើន៖

១. ការអនុញ្ញាតឲ្យមានការល្បងលនេះ គឺដើម្បីការអភិវឌ្ឍខាងឯវិញ្ញាណរបស់អ្នកជឿ (គម្ពីរទំនុកតម្កើង ៩៤:១២ និងគម្ពីរហេប្រឺ ១២:៥-១៣) ។

២. ការល្បងលប្រហែលជាតំណាងឲ្យការសាកល្បង ការរៀបចំខ្លួនសម្រាប់ឱកាសនៃការបម្រើ (គម្ពីរ ១ កូរិនថូស ១៦:៩ គម្ពីរយ៉ាកុប ១:២-១២)។

៣. ការរងទុក្ខវេទនា ក៏នឹងនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់ ប្រសិនបើយើងឆ្លើយតបតាមរបៀបត្រឹមត្រូវ (សូមមើលគម្ពីរ យ៉ូប១,២ និង ៤២)

៤. ការល្បងលគឺជាផ្នែកនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះក្រុមជំនុំ (គម្ពីរយ៉ូហាន ១៥:១៨;១៦:៣៣ គម្ពីរកិច្ចការ១៤:២២ គម្ពីរ១ពេត្រុស ៤:១២-១៩)

ដោយសារពេលខ្លះព្រះជាម្ចាស់លុកព្រះហស្តយ៉ាងសកម្ម នៅក្នុងកិច្ចការរបស់មនុស្ស យើងដឹងថាយើងអាចមានតួនាទីយ៉ាងមានប្រសិទ្ធភាពមួយនៅក្នុងជីវិតរបស់អ្នកដទៃ នៅពេលដែលយើងឮការអធិស្ឋាន។ លោកម៉ូសេបានទូលអង្វរជាមួយព្រះជាម្ចាស់ ហើយអ៊ីស្រាអែលក៏បានសង្គ្រោះឲ្យផុតពីការបំផ្លិចបំផ្លាញ។ លោកអេលីយ៉ាបានអធិស្ឋាន ហើយរាជវាំងក៏ត្រូវបានគេអុកឡុក។ ទាំងនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ថ្មី មានឧទាហរណ៍ជាច្រើនពីការចូលអន្តរាគមន៍របស់ព្រះជាម្ចាស់ នៅពេលដែលមនុស្សបានអធិស្ឋាន។ ព្រះជាម្ចាស់បានធ្វើអ្វីម្យ៉ាង ដែលជាការឆ្លើយតបទៅនឹងការអធិស្ឋានរបស់មនុស្សដោយផ្ទាល់។ ទ្រង់ធ្វើកិច្ចការខ្លះទៀត ដោយគ្មាននរណាម្នាក់អធិស្ឋានសូមទ្រង់ដែរ។ ពេលខ្លះទ្រង់ធ្វើរឿងដែលហាក់បីដូចជាផ្ទុយទៅនឹងអ្វីដែលយើងអធិស្ឋានទូលសូម ដោយព្រោះអធិបតីភាពរបស់ទ្រង់ ទ្រង់ធ្វើការដើម្បីផលល្អបំផុតរបស់យើង។ លោក ហិនរី ស៊ី ថៃសិន(Henry C. Thiessen (1979))[1] បាននិយាយសរុបការនេះ ដូចខាងក្រោមនេះ៖

> ប្រសិនបើយើងមិនអធិស្ឋានសម្រាប់រឿងដែលយើងអាចទទួលបានដោយការអធិស្ឋាននោះទេ យើងនឹងមិនទទួលបានវាឡើយ។ ប្រសិនបើទ្រង់សព្វព្រះហឫទ័យឲ្យរឿងអ្វីមួយកើតឡើងដោយគ្មាននរណាម្នាក់អធិស្ឋានសម្រាប់រឿងនោះ ទ្រង់នឹងធ្វើរឿងទាំងនោះដោយមិនចាំបាច់មាននរណាម្នាក់អធិស្ឋានទូលសូមឡើយ។ ប្រសិនបើយើងអធិស្ឋានសម្រាប់រឿងដែលផ្ទុយទៅនឹងបំណងព្រះហឫទ័យរបស់ទ្រង់ ទ្រង់នឹងបដិសេធមិនប្រទានឲ្យយើងឡើយ។ ដូច្នេះ មានភាពចុះសម្រុងគ្នាដ៏ល្អឥតខ្ចោះមួយ រវាងបំណងព្រះហឫទ័យរបស់ទ្រង់ និង ឧបការគុណ និង ឆន្ទៈសេរីរបស់មនុស្ស ។ (១២៩)

ដូច្នេះ យើងបានឃើញហើយថា ពេលខ្លះ គ្រិស្តបរិស័ទក៏បានរងទុក្ខដោយសារតែការរស់នៅក្នុងលោកីយ៍ដ៏អាក្រក់នេះផងដែរ។ ព្រះជាម្ចាស់ ដែលគង់នៅគ្រប់គ្រង មិនបានរារាំងមនុស្សពីការធ្វើអំពើអាក្រក់គ្រប់ពេលនោះទេ។ ទាំងគ្រិស្តបរិស័ទ និង អ្នកមិនមែនគ្រិស្តបរិស័ទ អាចនឹងរងទុក្ខ ជាលទ្ធផលដែលមកពីឧបទ្ទវហេតុ ឬ ការឆ្វេសប្រហែសដូចគ្នា។ ព្រះជាម្ចាស់មិនលូកព្រះហស្តរបស់ទ្រង់មកក្នុងច្បាប់ធម្មជាតិធម្មតា ឬ ជម្រើសនៃឆន្ទៈផ្ទាល់ខ្លួនរបស់យើងគ្រប់ពេលនោះទេ។ មនុស្សគ្រប់រូបរស់នៅក្នុងពិភពលោក មនុស្សម្នាក់ៗជាអ្នករងគ្រោះដោយសារឧបទ្ទវហេតុ និង ពេលខ្លះដល់ថ្នាក់ស្លាប់ទៀតផង។ គោលដៅរបស់យើង គឺមិនមែនដើម្បីបំពេញតាមគំនិតរបស់យើងទាក់ទងនឹងជីវិតនោះឡើយ ប៉ុន្តែគឺដើម្បីរស់នៅក្នុងរបៀបមួយដែលនឹងនាំសិរីរុងរឿងថ្វាយទៅព្រះជាម្ចាស់។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់យើង មិនដែលផ្លាស់ប្រែ ហើយទ្រង់បានមានព្រះបន្ទូលសន្យាថា ប្រសិនបើយើងស្រឡាញ់ទ្រង់ ទ្រង់នឹងធ្វើការសម្រាប់ផលល្អរបស់យើង នៅក្នុងគ្រប់ការទាំងអស់។ ជាមួយនឹងចំណេះដឹងនេះ យើងអាចទុកចិត្តដោយខ្លួនឯង ទៅលើព្រះជាម្ចាស់ដ៏ជាក្សត្ររបស់យើងរាល់គ្នា ដោយជឿថាហេតុផលសម្រាប់កាលៈទេ

ស:ទាំងអស់ ដែលទ្រង់នាំមក ដែលទ្រង់អនុញ្ញាត ដែលទ្រង់កំណត់ ឬ រារាំង នឹងបានបង្ហាញជាក់ច្បាស់មកកាន់យើង នៅថ្ងៃណាមួយ ដូចដែលទ្រង់បានឈ្វេងយល់អំពីការទាំងនោះដែរ។

លំហាត់អនុវត្តន៍

១៨ ដោយប្រើពាក្យរបស់អ្នកផ្ទាល់ ចូរឆ្លើយសំណួរដែលបានលើកឡើងនៅចំណុចចាប់ផ្តើមនៃផ្នែកនេះ អំពីការគ្រប់គ្រងជាអធិបតី៖ "តើព្រះជាម្ចាស់អាចបណ្តាលឲ្យមានអំពើឃាតកម្មទៅលើក្មេងតូចដែលគ្មានកំហុសម្នាក់ ទៅបានយ៉ាងដូចម្តេច?" ចូរសរសេរចម្លើយក្នុងសៀវភៅកត់ត្រារបស់អ្នក។

១៩ ចូរអានបទគម្ពីរខាងក្រោម ហើយសរសេរលេខ ១ នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគនោះគឺជាឧទាហរណ៍មួយអំពីឧបការគុណរបស់ព្រះជាម្ចាស់នៅក្នុងការទាក់ទងជាមួយមនុស្ស។ ចូរសរសេរលេខ ២ ប្រសិនបើប្រយោគនោះជាឧទាហរណ៍អំពីជម្រើសផ្ទាល់ខ្លួនរបស់មនុស្ស ដែលគ្មានការលូកព្រះហស្តពីព្រះជាម្ចាស់នោះទេ។

.....ក) គម្ពីរចៅហ្វាយ ១៥:១៦-១៩៖ ការប្រទានទឹកសម្រាប់លោកសាំសុនដែលកំពុងតែហត់។

.....ខ) គម្ពីរកិច្ចការ ២៤:២៤-២៦ ៖ លោកភេលិចបានពន្យាពេលធ្វើការសម្រេចចិត្តទទួលដំណឹងល្អ។

.....គ) គម្ពីរដានីយ៉ែល២:១០-២៣ ៖ ការបើកសំដែងទៅកាន់លោកដានីយ៉ែល

.....ឃ) គម្ពីរលោកុប្បត្តិ ២២:១៣ ៖ ចៀមឈ្មោលមួយជាប់ស្នែងនឹងគុម្ពោតឈើ។

.....ង) គម្ពីរចៅហ្វាយ ១១:៣០-៣៦ ៖ លោកយែបថាបានធ្វើការសន្យាយ៉ាងលង់ខ្លៅមួយទៅកាន់ព្រះជាម្ចាស់។

២០ ចូរបកស្រាយពីឥទ្ធិពលនៃការគ្រប់គ្រងជាអធិបតី និង តាមបែបឧបការគុណរបស់ព្រះជាម្ចាស់ នៅក្នុងកាល:ទេស:នីមួយៗខាងក្រោមនេះ ។ ចូរឆ្លើយចម្លើយរបស់អ្នកដោយផ្អែកលើគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ។ ចូរសរសេរចម្លើយក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) លោកចន ធ្លាប់ជាអ្នកបម្រើម្នាក់នៅក្នុងសហគមន៍ដែលពេញដោយក្រុមជនពាលមួយ។ ជាលទ្ធផលដែលបានមកគំរូរបស់លោក មានយុវជនប្រុសស្រីជាច្រើននាក់ដែលរស់នៅតាមដងផ្លូវ បានស្គាល់ព្រះគ្រិស្ត។

ខ) លោករ៉ូបឺត (Robert) បានហៀបនឹងស្លាប់ ដោយសារជំងឺមហារីក ប៉ុន្តែតាមរយៈសេចក្តីអធិស្ឋានរបស់មិត្តភក្តិរបស់លោក លោកបានជាសះស្បើយយ៉ាងអស្ចារ្យ។

គ) លោកចេម បានឡើងលើភ្នំដ៏មានគ្រោះថ្នាក់មួយ ជាមួយនឹងមិត្តរបស់លោក ពេលនោះលោកបានដួល ហើយជើងរបស់លោកក៏បានបាក់។

ឃ) នាងស៊ីម៉ូន ត្រូវបានគេស្តាក់វាយយ៉ាងដំណាំ នៅពេលនាងដើរពីព្រះវិហារទៅផ្ទះរបស់នាង ។ តាមរយៈបទពិសោធន៍មួយនេះ នាងក៏បង្កើនការខិតខំប្រឹងដើម្បីនាំមនុស្សមកឯព្រះគ្រិស្ត។

ង) រ៉េម៉ន (Raymond) គឺជាក្មេងដែលមានអំណាយទានម្នាក់ ដែលបានរត់ចេញពីផ្លូវមុខភោជនីដ្ឋាន ចូលទៅក្នុងផ្លូវរបស់ឡានដែលកំពុងតែមានល្បឿនលឿន ហើយក៏ត្រូវឡានបុកស្លាប់ទៅ។

ច) ហេនរី (Henry) រស់នៅដោយខ្វល់តែពីខ្លួនឯង និង មានកេរ្តិ៍ឈ្មោះមិនល្អនៅក្នុង ការព្រមព្រៀងធ្វើជំនួញ ប៉ុន្តែគាត់ហាក់បីដូចជារីកចម្រើននៅក្នុងគ្រប់អ្វីៗដែលគាត់បានធ្វើ។

ឆ) ឡានរបស់បេសកជនម្នាក់ បានបែកកង់នៅតាមផ្លូវទៅចំណតយន្តហោះ ហើយគាត់ក៏បានខកជើងហោះហើររបស់គាត់។ ក្រោយមកគាត់បានដឹងថា យន្តហោះនោះបានធ្លាក់ ហើយមនុស្សគ្រប់គ្នានៅលើយន្តហោះនោះបានបាត់បង់ជីវិតទាំងអស់។

ការប្រឡងផ្ទាល់ខ្លួន

ត្រូវ/ខុស។ ចូរសរសេរ ត នៅខាងមុខប្រយោគណាដែលត្រឹមត្រូវ និង សរសេរអក្សរ ខ នៅខាងមុខប្រយោគណាដែលមិនត្រឹមត្រូវ។

.....១ ភាពវិសុទ្ធ គឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដែលបង្ហាញឲ្យឃើញពីភាពឥតខ្ចោះទាំងអស់របស់ទ្រង់។

.....២ ដោយសារតែព្រះជាម្ចាស់គឺ គ្មានទីបំផុត ហើយមនុស្សគឺពេញដោយបាប ទំនាក់ទំនងរវាងទ្រង់នឹងមនុស្ស គឺគ្មានភាពស្និទ្ធស្នាលនោះទេ។

.....៣ បើទោះបីភាពវិសុទ្ធរបស់ព្រះជាម្ចាស់ ទាមទារឲ្យមានការកាត់ផ្តាច់ពីអ្វីដែលមានបាប ទ្រង់នៅតែមានសេចក្តីមេត្តាករុណា និង សេចក្តីស្រឡាញ់ដែលបង្កើតបានជាផ្លូវសម្រាប់បញ្ចប់ការកាត់ផ្តាច់នេះ ដោយប្រទានឲ្យមានការបូជាមួយ។

.....៤ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ត្រូវបានបង្ហាញឲ្យឃើញច្បាស់បំផុត តាមរយៈអ្វីដែលទ្រង់មានព្រះបន្ទូល។

.....៥ តម្លៃនៃក្តីស្រឡាញ់ គឺសរបញ្ជាក់តាមរយៈអ្វីដែលមនុស្សម្នាក់ធ្វើ ដែលនោះមានន័យថាទង្វើរបស់មនុស្សម្នាក់ បង្ហាញពីក្តីស្រឡាញ់របស់គេ។

.....៦ ប្រសិនបើមនុស្សពិតជាស្រឡាញ់ព្រះជាម្ចាស់ពិតមែន ពួកគេនឹងបង្ហាញក្តីស្រឡាញ់នោះតាមរយៈការស្តាប់បង្គាប់របស់ពួកគេ។

.....៧ ការបង្កើតសាកលលោកដែលជា កិច្ចការរបស់ព្រះជាម្ចាស់ គឺមានសារៈសំខាន់តែនៅពេលណាដែលវា បង្ហាញពីព្រះតេជៈ នៃឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ ការនេះមិនទាមទារឲ្យមានការឆ្លើយតបអ្វីនៅក្នុងស្មារតីរបស់ទ្រង់ឡើយ។

.....៨ ការគ្រប់គ្រងជាអធិបតីរបស់ព្រះជាម្ចាស់ មានន័យថាទ្រង់មិនស្ថិតនៅក្រោមការគ្រប់គ្រងដែលមកពីខាងក្រៅណាមួយ ហើយមានន័យថាទ្រង់អាចធ្វើអ្វីៗគ្រប់យ៉ាងដែលទ្រង់សព្វព្រះហឫទ័យ។

.....៩ នៅពេលដែលយើងនិយាយដល់ការដែលព្រះជាម្ចាស់ថែរក្សាសាកលលោក យើងយល់ថាទ្រង់ គឺកំពុងការពារយ៉ាងសកម្ម នូវអ្វីដែលទ្រង់បានបង្កើត។

.....១០ ឧបការគុណសំដៅទៅលើសមត្ថភាពរបស់ព្រះជាម្ចាស់ ក្នុងការទតឃើញជាមុននូវអ្វីៗគ្រប់យ៉ាង និង ក្នុងការដឹកនាំភាវៈដែលទ្រង់បានបង្កើតឆ្ពោះទៅចុងបញ្ចប់ដែលទ្រង់បានកំណត់សម្រាប់ភាវៈទាំងនោះ ដែលនោះគឺជាការបង្កើតនគរមួយនៅក្រោមព្រះយេស៊ូគ្រិស្ត។

.....១១ ការគ្រប់គ្រងរបស់ព្រះជាម្ចាស់រាប់បញ្ចូលគំនិតដែលថា ពេលខ្លះទ្រង់បានដាក់កំណត់ទៅលើអំពើបាប និង ភាពទុច្ចរិត និង ទៅលើការល្បងលដែលគ្រិស្តបរិស័ទត្រូវឆ្លង។

.....១២ ស្របពេលដែលការអធិស្ឋានគឺជាសកម្មភាពដែលនឹងនាំយើងឲ្យកាន់តែជិតព្រះជាម្ចាស់ ការអធិស្ឋានមិនអាចមានឥទ្ធិពលទៅលើសកម្មភាពជាអធិបតីរបស់ទ្រង់បានឡើយ។

.....១៣ ស្របពេលដែលព្រះជាម្ចាស់បានបង្កើតច្បាប់ធម្មជាតិ និង ប្រទានឲ្យមនុស្សនូវសេរីភាពនៃការជ្រើសរើស ទ្រង់បានធ្វើការតាមរយៈមធ្យោបាយនេះដើម្បីនាំឲ្យបំណងព្រះហឫទ័យរបស់ទ្រង់បានសម្រេច។

.....១៤ ឧបការគុណរបស់ព្រះជាម្ចាស់ រាប់បញ្ចូល គោលការណ៍ដែលថាគ្រិស្តបរិស័ទត្រូវតែរងទុក្ខនៅក្នុងពិភពលោកនេះ នៅពេលណាដែលមនុស្សមានបាបអាចរំពឹកទុកថាគេនឹងបានរីកចម្រើន។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១០ នៅក្នុងបទគម្ពីរទាំងនេះ ព្រះយេស៊ូបានបង្គាប់ឲ្យពួកសាវ័ករបស់ទ្រង់ នាំដំណឹងអំពីសេចក្តីស្រឡាញ់ និង ការសង្គ្រោះរបស់ព្រះជាម្ចាស់ ទៅកាន់មនុស្សគ្រប់គ្នា ។ ព្រះជាម្ចាស់បានជ្រើសរើសប្រើប្រាស់យើងដើម្បីប្រាប់អ្នកដទៃអំពីក្តីស្រឡាញ់របស់ទ្រង់។

១ ក) វិសុទ្ធ
ខ) បែកចេញ
គ) អំពីបាបអាក្រក់យ៉ាងណា

១១ ខ) បង្ហាញពីសេចក្តីល្អ សេចក្តីមេត្តាករុណា ការអត់ធ្មត់ និង ព្រះគុណ នៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ទ្រង់ជាមួយមនុស្ស និង សេចក្តីស្រឡាញ់នេះ បានស្តែងឡើងនៅតាមរបៀបជាក់ស្តែងមួយ ដូចជាអត់ទោសបាប។

២ គ) ព្រះសង្គ្រោះរបស់យើងគឺព្រះយេស៊ូគ្រិស្ត។

១២ ចម្លើយរបស់អ្នក។ នៅក្នុងក្រុមមនុស្សជាច្រើន មានភាពមិនប្រាកដប្រជាជាច្រើនអំពីការបង្កើតសាកលលោក អត្ថន័យនៃជីវិត សេចក្តីស្លាប់ និង ការវិនិច្ឆ័យទោស។ គ្មានទស្សនៈណាផ្សេងទៀតដែលមានហេតុផលសមរម្យ និង គួរឲ្យគាប់ចិត្តដូចជាទស្សនៈដែលមាននៅក្នុងព្រះគម្ពីរឡើយ។

៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយនេះ៖ ទ្រង់តម្រូវឲ្យខ្ញុំបានវិសុទ្ធ។ ទ្រង់សព្វព្រះហឫទ័យឲ្យខ្ញុំចែករំលែកភាពវិសុទ្ធរបស់ទ្រង់។

១៣ ក) ត្រូវ
ខ) ត្រូវ
គ) ខុស
ឃ) ត្រូវ
ង) ខុស (ព្រះរាជកិច្ចនៃការបង្កើត របស់ទ្រង់បន្តក្រោមទម្រង់នៃការបង្កើតខាងឯវិញ្ញាណដែលធ្វើឡើងនៅពេលមនុស្សម្នាក់ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ)។

៤ យើងគួរតែឆ្លើយយ៉ាងដូច្នេះថា៖ "សាសន៍សាម៉ារី" ព្រោះគាត់បានបង្ហាញពីការធ្វើអ្វីដែលត្រឹមត្រូវ។ គាត់បានយកគោលការណ៍ដែលគាត់ប្រកាន់ខ្ជាប់ ទៅប្រើប្រាស់នៅក្នុងជីវិត។

១៤ ខ) ទ្រង់បានចូលរួមយ៉ាងសកម្មនៅក្នុងការការពាររបស់សព្វសារពើ។
ឃ) ទ្រង់បានប្រទានលក្ខណៈចាំបាច់ទៅកាន់គ្រប់ផ្នែកនៃស្នាព្រះហស្តរបស់ទ្រង់ ហើយទ្រង់ធ្វើការតាមរយៈលក្ខណៈទាំងនេះដើម្បីថែទាំរបស់សព្វសារពើ។
ង) ដោយបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ របស់សព្វសារពើនៅក្នុងសាកលលោកនេះបានកើតមានឡើង។
ច) ទ្រង់ប្រទានការថែទាំ និង ការការពារសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។

៥ ខ) មានយុត្តិធម៌នៅក្នុងការទាមទាររបស់យើង ឲ្យរង្វាន់ពួកគេនៅពេលពួកគេស្តាប់បង្គាប់ ហើយដាក់ទោសពួកគេនៅពេលពួកគេមិនស្តាប់បង្គាប់។

១៥ ខ) ការគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលទ្រង់រក្សា ថែទាំ និង ដឹកនាំ ស្នាព្រះហស្តរបស់ទ្រង់ គឺដើម្បីរៀបចំរបស់ទាំងនោះដើម្បីព្រះរាជ្យដ៏អស់កល្បជានិច្ចរបស់ទ្រង់។

៦ ក), គ), ង) និង ច) ជាចម្លើយត្រឹមត្រូវ។

១៦ ក) ៣) ភាពរីករាយរបស់មនុស្ស

ខ) ២) ការអភិវឌ្ឍផ្នែកគំនិត និង សីលធម៌របស់មនុស្ស

គ) ១) សិរីរុងរឿងរបស់ព្រះជាម្ចាស់

៧ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ត្រូវបានបង្ហាញតាមរយៈការប្រទានអ្វីម្យ៉ាង ទៅកាន់មនុស្សរបស់ទ្រង់។

១៧ ក) ២) ការយល់ស្រប

ខ) ៣) ការគ្រប់គ្រង

គ) ១) ការការពារ

១៨ ចម្លើយរបស់អ្នក។ ខ្ញុំចង់ចង្ហាញប្រាប់ថា ព្រះជាម្ចាស់បានប្រទានឲ្យយើងនូវសេរីភាពក្នុងការសម្រេចចិត្ត ដូច្នេះ យើងអាចជ្រើសរើសធ្វើអំពើបាបបានប្រសិនបើយើងចង់។ នៅពេលដែលមានការនេះកើតឡើង មនុស្សគ្មានកំហុសក៏ត្រូវរងទុក្ខដូចជាមនុស្សទុច្ចរិតដែរ។ ព្រះគម្ពីរប្រាប់យើងថា នៅពេលណាមួយ មនុស្សទុច្ចរិតនឹងទទួលការកាត់ទោស និង ការផ្តន្ទាទោសពីព្រះជាម្ចាស់ ដោយសារតែអំពើអាក្រក់ដែលពួកគេបានធ្វើ។

៨ យើងបង្ហាញក្តីស្រឡាញ់របស់យើង សម្រាប់ព្រះជាម្ចាស់ តាមរយៈការស្តាប់បង្គាប់របស់យើងទៅចំពោះទ្រង់ និង ក្តីស្រឡាញ់របស់យើងសម្រាប់មនុស្សដទៃទៀតដែរ។ (យើងអាចឃើញយ៉ាងច្បាស់នៅត្រង់នេះ ថា ក្តីស្រឡាញ់គឺជាកម្លាំងដ៏សកម្មមួយ)។

១៩ ក) ១) ឧបការគុណរបស់ព្រះជាម្ចាស់

ខ) ២) ការជ្រើសរើសផ្ទាល់ខ្លួនរបស់មនុស្ស

គ) ១) ឧបការគុណរបស់ព្រះជាម្ចាស់

ឃ) ១) ឧបការគុណរបស់ព្រះជាម្ចាស់

ង) ២) ការជ្រើសរើសផ្ទាល់ខ្លួនរបស់មនុស្ស

៩ ខ១៖ ព្រះប្រាជ្ញាញាណ និង សព្វានុភាព (ធម្មជាតិ) និង សេចក្តីស្រឡាញ់ (សីលធម៌)

ខ២៖ សព្វានុភាព និង សព្វដ្ឋភាព(សព្វត្ថិភាព) (ធម្មជាតិ) និង សេចក្តីស្រឡាញ់ (សីលធម៌)

ខ៣៖ ភាពវិសុទ្ធ (សីលធម៌)

ខ៤៖ សេចក្តីស្រឡាញ់ (សីលធម៌)

២០ ឧទាហរណ៍ ក) ឆ្លុះបញ្ចាំងឲ្យឃើញគោលការណ៍ពីរយ៉ាង៖ ការរងទុក្ខអាចជាលទ្ធផលបានមកពីការរស់នៅសម្រាប់ព្រះជាម្ចាស់ នៅក្នុងលោកីយ៍ដ៏អាក្រក់ ពេលខ្លះព្រះជាម្ចាស់ប្រើប្រាស់សកម្មភាពរបស់មនុស្សអាក្រក់ដើម្បីសម្រេចបាននូវលទ្ធផលល្អមួយ។ ឧទាហរណ៍ ខ) គូសបង្ហាញថា ព្រះជាម្ចាស់ធ្វើអ្វីម្យ៉ាង ជាការឆ្លើយតបផ្ទាល់ទៅនឹងការអធិស្ឋាន និង បំណងព្រះហឫទ័យរបស់ទ្រង់គឺដើម្បីនាំសិរីរុងរឿងមកឯទ្រង់។ ឧទាហរណ៍ គ) និង ង) បង្ហាញថាមនុស្សគ្រប់គ្នា គឺជាអ្នករងឥទ្ធិពលពីច្បាប់ធម្មជាតិ និង គ្រោះថ្នាក់ដែលមាននៅក្នុងជីវិត។ ឧទាហរណ៍ ឃ) គូសបង្ហាញថា ពេលខ្លះការល្បងល រៀបចំមនុស្សម្នាក់ដើម្បីការបម្រើដ៏អស្ចារ្យមួយដល់ព្រះជាម្ចាស់ និង អាចនាំសិរីរុងរឿងទៅឲ្យទ្រង់។ ឧទាហរណ៍ ច) បង្ហាញថា សូម្បីតែអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ក៏អាចទទួលផលប្រយោជន៍ពីព្រះគុណរបស់ព្រះជាម្ចាស់ដែរ។ ប៉ុន្តែប្រសិនបើលោកហេនរី (Henry) មិនថ្វាយជីវិតរបស់គាត់ទៅព្រះជាម្ចាស់ទេនោះ គាត់នឹងត្រូវរស់នៅដាច់ពីព្រះជាម្ចាស់ជារៀងរហូត ហើយគាត់នឹងត្រូវបានវិនិច្ឆ័យទោស ដោយសារទង្វើអាក្រក់របស់គាត់។ ឧទាហរណ៍ ឆ) គូសបង្ហាញថា ពេលខ្លះនៅពេលដែលផែនការរបស់យើងហាក់បីដូចជាមិនអាចសម្រេចបាន ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងកាល:ទេស:នោះសម្រាប់ផលល្អរបស់យើង។

ជំពូក ៣ ព្រះគ្រិស្ត៖ ការបើកសំដែងឲ្យមើលឃើញ នៃព្រះជាម្ចាស់ ដែលគេមិនអាចមើលឃើញ

"គាត់ពិតជាដូចឪពុកគាត់ណាស់" ។ តើអ្នកធ្លាប់ឮនរណាម្នាក់និយាយអំពីក្មេងប្រុសម្នាក់យ៉ាងដូច្នេះដែរឬទេ? ពេលខ្លះយើងសួរខ្លួនឯងថា៖ "តើគាត់ទាំងពីរនាក់ដូចគ្នាយ៉ាងណា?" ប្រសិនបើឪពុកហើយនឹងកូនពីរនាក់ *មើលទៅ* ដូចគ្នា យើងអាចឃើញយ៉ាងងាយ ប៉ុន្តែពេលខ្លះភាពស្រដៀងគ្នានេះមិនសូវជាច្បាស់ប៉ុន្មានទេ។ ឧទាហរណ៍ ពួកគេប្រហែលជាមានទង្វើដូចគ្នា ឬ របៀបគិតដូចគ្នា ឬ មានបុគ្គលិកលក្ខណៈដូចគ្នាខ្លាំង។ តាមរយៈការមើលទៅកាន់ក្មេងម្នាក់ អ្នកអាចមើលឃើញជាច្រើនចំណុចអំពីឪពុករបស់គេ។

ព្រះយេស៊ូបានយាងមកក្នុងលោកីយ៍នេះដើម្បីបង្ហាញយើងថា ព្រះជាម្ចាស់ព្រះវរបិតាទ្រង់មានសណ្ឋានយ៉ាងដូចម្តេច? ទ្រង់គឺជាអ្នកតំណាងដែលគេអាចមើលឃើញ សម្រាប់ព្រះវរបិតាដែលគេមិនអាចមើលឃើញ។ ព្រះយេស៊ូស្នងលក្ខណសម្បត្តិធម្មជាតិ និងខាងឯសីលធម៌របស់ព្រះជាម្ចាស់។ តាមរយៈការអស្ចារ្យនៃការមានព្រះជន្មរស់ឡើងវិញ ទ្រង់បានយកនិស្ស័យ និង សណ្ឋានជាមនុស្សមកលើអង្គទ្រង់។ ធ្វើដូច្នេះ ទ្រង់បានបើកសំដែងឲ្យឃើញពីគុណសម្បត្តិរបស់ព្រះជាម្ចាស់ និង ផ្សាភ្ជាប់គុណសម្បត្តិទាំងនេះទៅកាន់មនុស្សផងដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "អ្នកណាបានឃើញខ្ញុំ ក៏បានឃើញព្រះបិតាដែរ។" (គម្ពីរយ៉ូហាន ១៤:៩)

នៅក្នុងមេរៀននេះ យើងនឹងពិចារណាទៅលើគោលិទ្ធិដែលទាក់ទងនឹងព្រះយេស៊ូគ្រិស្ត ដែលជា "រស្មីនៃសិរីរុងរឿងរបស់ព្រះជាម្ចាស់ និងមានលក្ខណៈដូចព្រះអង្គបេះបិទ។" (គម្ពីរហេប្រឺ ១:៣)។ នៅពេលដែលយើងគិតអំពីពេលវេលាដែលទ្រង់គង់នៅលើផែនដី និង អំពីរបៀបដែលទ្រង់ឆ្លុះបញ្ចាំងពីព្រះវរបិតា សូមឲ្យយើងធ្វើដោយស្មោះអស់ពីចិត្ត ដើម្បីឲ្យយើងអាចឆ្លុះបញ្ចាំងពីភាពស្រស់ស្អាតនៃព្រះបុត្រាទៅកាន់អ្នកដទៃ តាមរបៀបដូចគ្នានោះដែរ។

គម្រោងមេរៀន

ក. ភាពជាមនុស្សរបស់ព្រះគ្រិស្ត
ខ. ភាពជាព្រះរបស់ព្រះគ្រិស្ត
គ. ការរួមមកតែមួយនៃភាពជាព្រះ និង ភាពជាមនុស្សនៅក្នុងព្រះគ្រិស្ត
ឃ. រាជកិច្ចរបស់ព្រះគ្រិស្ត

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖
១. ផ្តល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពពេញវ័យរបស់ព្រះយេស៊ូ។
២. ផ្តល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពជាព្រះរបស់ព្រះយេស៊ូ។
៣. រៀបរាប់គុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិ ដែលបង្ហាញថាព្រះយេស៊ូជាព្រះជាម្ចាស់។
៤. ពិភាក្សាអំពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងការចាប់បដិសន្ធិ។
៥. បកស្រាយពីមូលហេតុដែលកិច្ចការរបស់ព្រះគ្រិស្ត មានសារៈសំខាន់សម្រាប់មនុស្សជាតិ។

សកម្មភាពក្នុងការសិក្សា

១. សិក្សាតាមដំណើរវិឌ្ឍន៍របស់មេរៀន ដោយយោងទៅតាមដំណើរការនៃគម្រោងមេរៀន នៅក្នុងមេរៀនទី១ និង ទី២។
២. ត្រូវធ្វើឲ្យប្រាកដថា អ្នកបានឆ្លើយសំណួរនៅក្នុងមេរៀនដោយខ្លួនឯង មុនពេលអ្នកបើកមើលចម្លើយដែលបានផ្តល់ជូននៅចុងបញ្ចប់នៃមេរៀន។ រំឭកឡើងវិញនូវលំហាត់ទាំងឡាយណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។ បន្ទាប់មកធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់ៗ

បុព្វបុរស	អ្នកសម្រុះសម្រួល	ផ្សះផ្សា
ការលើកឡើងទៅស្ថានសួគ៌	ខ្សែស្រឡាយ	ការប្រោសលោះ
ភាពជាព្រះ	អ្នកសម្របសម្រួល	អ្នកតំណាង
ចម្លែក	ជីវិតដែលអាចស្លាប់	រងឥទ្ធិពល
មនុស្សជាតិ	ពិន័យ	អធិធម្មជាតិ
ការចាប់បដិសន្ធិ		

ក. ភាពជាមនុស្សរបស់ព្រះយេស៊ូ

វគ្គបំណងទី១. *ផ្តល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពពេញវ័យរបស់ព្រះយេស៊ូ។*

នៅក្នុងចំណោមធាតុផ្សំផ្សេងៗនៃជំនឿរបស់គ្រិស្តបរិស័ទ *ការចាប់បដិសន្ធិ*របស់ព្រះយេស៊ូគ្រិស្តជាអម្ចាស់នៃយើង គឺពិតជាមូលដ្ឋានគ្រឹះដំបូងបំផុតដែលមិនអាចប្រកែកបាន។ *ការចាប់បដិសន្ធិ* សំដៅទៅលើការរួមតែមួយនៃភាពជាព្រះ ជាមួយនឹងភាពជាមនុស្សនៅក្នុងអង្គព្រះយេស៊ូគ្រិស្ត។ បទគម្ពីរបានបង្រៀនយ៉ាងច្បាស់ថា ទ្រង់ដែលជាបុត្រដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ បានក្លាយជាមនុស្សដើម្បីបំណងព្រះហឫទ័យក្នុងការសង្គ្រោះយើងរាល់គ្នា។ ព្រះជាម្ចាស់បានធ្វើការតាមរបៀបមួយថ្មី នៅក្នុងលោកីយ៍នេះ នៅពេលបុត្ររបស់ទ្រង់ចាប់កំណើតជា "សាច់ឈាម" ។ ព្រះយេស៊ូបានចាប់ទំផ្ទៃនាងក្រមុំព្រហ្មម៉ារី ដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងកិច្ចការនៃការបង្កើតដ៏ពិសេសនេះ ព្រះជាម្ចាស់បានបំបែកច្រវ៉ាក់ខ្សែស្រឡាយមនុស្ស ហើយបាននាំមកនូវភាវៈដ៏អស្ចារ្យមួយ។

អាថ៌កំបាំងនៅជុំវិញហេតុការណ៍ដ៏អស្ចារ្យនេះ នឹងត្រូវសាបរលាបទៅ នៅពេលណាយើងដឹងថានេះគឺជាផ្នែកមួយនៃសកម្មភាពថ្មីរបស់ព្រះជាម្ចាស់។ ព្រះបុត្រារបស់ព្រះជាម្ចាស់យាងមកដើម្បីសង្គ្រោះមនុស្ស ដែលជាភាវៈមានសាច់ឈាម ដោយការយាងមកចាប់កំណើតមកមានសាច់ឈាមដោយព្រះអង្គផ្ទាល់។ ទ្រង់បានធ្វើកិច្ចការ ដើម្បីប្រទានការសង្គ្រោះដល់មនុស្សជាតិ ដោយការសុគតរបស់ទ្រង់។ ជាមួយនឹងការចាប់បដិសន្ធិនេះ ព្រះជាម្ចាស់ដាក់ឲ្យផែនការនៃការប្រោសលោះនៅលើផែនដី ចាប់ដំណើរការទៅមុខ៖ "ប៉ុន្តែ លុះដល់ពេលកំណត់ហើយ ព្រះជាម្ចាស់ក៏ចាត់ព្រះបុត្រារបស់ព្រះអង្គអោយមកប្រសូតចេញពីស្ត្រី ហើយប្រសូតក្រោមអំណាចរបស់វិន័យផង" (គម្ពីរកាឡាទី៤:៤) ។ គ្មានមធ្យោបាយណាផ្សេងទៀត ដែលអាចឲ្យទ្រង់សម្រេចបំណងព្រះហឫទ័យក្នុងការសង្គ្រោះ បានឡើយ។

ដូច្នេះ ការចាប់បដិសន្ធិ គឺជាចំណុចផ្លាស់ប្តូរសម្រាប់មនុស្សជាតិដែលពោរពេញដោយអំពើបាប ដ្បិតការនេះធ្វើឲ្យមានការផ្សះផ្សា (នាំមកជួបគ្នាម្តងទៀត) រវាងព្រះជាម្ចាស់ និង មនុស្សជាតិ កើតឡើងបាន។ ដោយសារភាពជាមនុស្សរបស់ព្រះយេស៊ូ មានសារៈសំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់ដល់ម្ល៉េះ ដែលយើងចាំបាច់ត្រូវពិចារណាអំពីភស្តុតាងខ្លះៗអំពីភាពជាមនុស្សរបស់ទ្រង់។ ភស្តុតាងទាំងនោះ រួមមានបុព្វបុរសជាមនុស្សរបស់ទ្រង់ ការរីកធំធាត់ជាមនុស្ស ទិដ្ឋភាពជាមនុស្ស ដែនកំណត់ជាមនុស្ស និង ឈ្មោះជាមនុស្សរបស់ទ្រង់។

បុព្វបុរស និង ការរីកធំធាត់ជាមនុស្ស

អ្នកនិពន្ធដំណឹងល្អពីរនាក់ មានលោកម៉ាថាយ និង លោកលូកា បានតាមដានបុព្វបុរសរបស់ព្រះគ្រិស្ត។ តាមពិតទៅ លោកម៉ាថាយ បានតាមដានខ្សែស្រឡាយរបស់ទ្រង់ រហូតទៅដល់ស្តេចដាវីឌ និងលើសពីនោះទៅទៀត រហូតដល់លោកអប្រាហាំជាអយ្យកោរបស់ទ្រង់
(គម្ពីរម៉ាថាយ ១:១-១៧)។ វគ្គបំណងពីរយ៉ាងរបស់លោកគឺ៖

១. ដើម្បីបញ្ជាក់ថាព្រះយេស៊ូ គឺមកពីខ្សែស្រឡាយព្រះបាទដាវីឌ និង ជាអ្នកស្នងរាជបល្ល័ង្កនៃសាសន៍អ៊ីស្រាអែល។ បើមិនដូច្នោះទេ គ្មានសាសន៍យូដាណាម្នាក់អាចទទួលស្គាល់ទ្រង់ជាស្តេច ឬ ជាព្រះមេស្ស៊ីរបស់ពួកគេបានឡើយ។

២. ដើម្បីបញ្ជាក់ថាព្រះយេស៊ូ ជាគ្រាប់ពូជរបស់លោកអប្រាហាំ ជាបុត្រដែលតាមរយៈបុត្រនេះ គ្រួសារទាំងអស់នៅលើផែនដីបានទទួលព្រះពរ (សូមមើលគម្ពីរលោកុប្បត្តិ ២២:១៧-១៨)។

លោកលូកាតាមដានខ្សែស្រឡាយរបស់ព្រះយេស៊ូ បកក្រោយរហូតដល់លោកអាដាំ ដែលជាមនុស្សដំបូងគេបង្អស់ (គម្ពីរលូកា៣:២៣-៣៨)។ ទោះជាយ៉ាងណា គោលបំណងរបស់លោកម៉ាថាយ និង លោកលូកា គឺដើម្បីសង្កត់ន័យទៅលើកការពិតនៃជីវិតជាមនុស្សរបស់ព្រះយេស៊ូ៖ ទ្រង់បាន "មកប្រសូតចេញពីស្ត្រី" (គម្ពីរកាឡាទី៤:៤)។

នៅពេលដែលយើងនិយាយថា ព្រះយេស៊ូមានបុព្វបុរសជាមនុស្ស យើងត្រូវបញ្ជាក់បង្ហាញឲ្យបានច្បាស់ៗ ថា ទ្រង់មិនមានឪពុកដែលមាននិស្ស័យជាមនុស្សនោះទេ។ ការប្រសូតរបស់ទ្រង់ គឺខុសពីការកើតរបស់មនុស្សទាំងអស់។ លោកលូកាបានកត់ត្រាឈុតឆាក ដែលទេវតាប្រាប់នាងម៉ារីថា នាងនឹងមានគភ៌ឆាប់ៗ ។ ការឆ្លើយតបភ្លាមៗរបស់នាងគឺ៖ "តើធ្វើដូចម្តេចនឹងអោយការនេះកើតឡើងបាន បើនាងខ្ញុំមិនរួមរស់ជាមួយបុរសណាផងដូច្នេះ?" (គម្ពីរលូកា ១:៣៤) ។ ជាការឆ្លើយតបទៅនឹងសំណួររបស់នាងទាក់ទងនឹងការចាប់កំណើតដ៏អស្ចារ្យរបស់ព្រះយេស៊ូ ដែលហាក់ដូចជាមិនអាចកើតឡើងបាននោះ ទេវតាបានរំឭកនាងម៉ារីថា "គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះឡើយ" (ខ៣៧)។ ការប្រសូតរបស់ព្រះយេស៊ូ គឺជាអព្ភូតហេតុដ៏អស្ចារ្យ ប៉ុន្តែកំណើតនោះជាកំណើតរបស់*មនុស្ស* ។

ការរីកធំធាត់ខាងឯរូបកាយ និង គំនិតរបស់ព្រះយេស៊ូគឺផ្អែកទៅលើច្បាប់នៃការលូតលាស់របស់មនុស្សធម្មតា។ តាមពិតទៅ ការលូតលាស់ និង ការរីកធំធាត់របស់ទ្រង់ ជាសមាជិកសាមញ្ញម្នាក់នៃស្រុកណាសារ៉ែត ត្រូវបានទទួលស្គាល់ដោយមនុស្សដែលរស់នៅរួមក្រុងជាមួយទ្រង់ផងដែរ (គម្ពីរម៉ាថាយ ១៣:៥៥)។ លោកលូកាបាននិយាយថាព្រះយេស៊ូ "មានវ័យចំរើនឡើងជាលំដាប់ មានកម្លាំងកាន់តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញាញាណ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងព្រះកុមារនេះណាស់" (គម្ពីរលូកា២:៤០) ។ យើងដឹងថា ការរីកចម្រើនខាងឯព្រះតម្រិះរបស់ទ្រង់ គឺមិនមែនជាលទ្ធផលដែលបានមកពីការបង្ហាត់បង្រៀនដែលទ្រង់ទទួលនៅក្នុងសាលាក្នុងជំនាន់នោះទេ (គម្ពីរយ៉ូហាន៧:១៥) ។ ផ្ទុយទៅវិញ ការរីកចម្រើននោះបានមកពីការបណ្តុះបណ្តាលដែលទ្រង់ទទួលបានពី ឪពុកម្តាយដែលគោរពកោតខ្លាចព្រះជាម្ចាស់ ការទៅសាលាប្រជុំជាប្រចាំ (គម្ពីរលូកា ៤:១៦) ការចូលទៅក្នុងព្រះវិហារប្រកបដោយជំនឿ (គម្ពីរលូកា ២:៤១) ការសិក្សា និង ការអនុវត្តតាមបទគម្ពីរដោយជំនឿ និង ការអធិស្ឋាន (គម្ពីរម៉ាកុស ១:៣៥ គម្ពីរយ៉ូហាន៤:៣២-៣៤)។

លំហាត់អនុវត្តន៍

១ ចូរអានគម្ពីរលូកា២:៥២ ។ ខនេះបង្ហាញថា ព្រះជន្មរបស់ព្រះយេស៊ូបានរីកចម្រើនខាងឯ
   ក) សតិបញ្ញា
   ខ) វិញ្ញាណ
   គ) រូបកាយ
   ឃ) សង្គម

សណ្ឋាន និង ដែនកំណាត់ជាមនុស្ស

ភស្តុតាងគ្រប់ទាំងអស់បានបង្ហាញថា លក្ខណៈរូបកាយរបស់ព្រះយេស៊ូក៏ស្រដៀងទៅនឹងមនុស្សដទៃទៀតដែរ។ តាមពិតទៅ ទ្រង់មានលក្ខណៈដូចមនុស្សដទៃទៀត ទាំងនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេ ដែលនៅពេលទ្រង់ប្រកាសថាទ្រង់គឺតែមួយជាមួយនឹងព្រះជាម្ចាស់ ធ្វើឲ្យអ្នកស្តាប់ទ្រង់ ខឹងសម្បារនឹងទ្រង់យ៉ាងខ្លាំង ។ ពួកគេបានឆ្លើយតបទាំងកំហឹងថា ទ្រង់គឺ "ជាមនុស្ស" ហើយគ្មានសិទ្ធិអ្វីនឹងមកប្រកាសថាខ្លួនជាព្រះជាម្ចាស់យ៉ាងដូច្នេះឡើយ (គម្ពីរយ៉ូហាន ១០:៣៣)។

នៅពេលដែលទេសាភិបាលប៉ុនទាំង លោកពីឡាត នាំព្រះយេស៊ូមកឈរនៅចំពោះមុខពួកយូដាមុនធ្វើការប្រកាសទោសរបស់ទ្រង់។លោកពីឡាតមានប្រសាសន៍ថា៖ "មើល៍ មនុស្សហ្នឹងហើយ" (គម្ពីរយ៉ូហាន ១៩:៥) ។ នៅពេលដែលព្រះយេស៊ូទទួលការកាត់ទោសនៅចំពោះមុខអ្នកកាត់ក្តីប៉ុនទាំង គ្មាននរណាម្នាក់សួរពីភាពជាមនុស្សរបស់ព្រះអង្គឡើយ។ ក្រោយមកលោកសាវ័កប៉ុលបានបញ្ជាក់ទៅកាន់ពិភពលោកនៅក្នុងសតវត្សរ៍ទីមួយនោះថា "ឃើញទ្រង់មានភាពជាមនុស្ស" (គម្ពីរភីលីព ២:៨ គម្ពីរបកប្រែចាស់)។

គ្មានមិត្តសម្លាញ់របស់ព្រះយេស៊ូ ម្នាក់ណាដែលសង្ស័យថា ទ្រង់គឺជាមនុស្សនោះឡើយ។ ជារឿយៗ ពួកគេស្ងប់ស្ងែងជាមួយនឹងរឿងដែលថា ទ្រង់គឺជាបុរសដ៏អស្ចារ្យម្នាក់៖ "តើលោកនេះជានរណាបានជាខ្យល់ព្យុះ និងសមុទ្រស្តាប់បង្គាប់លោកដូច្នេះ?" (គម្ពីរម៉ាកុស ៤:៤១)។

នៅពេលដែលព្រះយេស៊ូមកចាប់កំណើតជាមនុស្ស ទ្រង់ស្ម័គ្រព្រះទ័យ ដាក់អង្គទ្រង់នៅក្នុងដែនកំណត់របស់មនុស្ស។ ជាលទ្ធផល ពេលខ្លះទ្រង់ក៏មានការនឿយព្រះកាយ (គម្ពីរយ៉ូហាន៤:៦) ឃ្លាន (គម្ពីរម៉ាកុស ១១:១២) និង ស្រេក (គម្ពីរយ៉ូហាន ១៩:២៨) ។ ទ្រង់បានឆ្លងកាត់សេចក្តីល្បួង (គម្ពីរម៉ាថាយ ៤:១-១១) និង ទទួលបានកម្លាំងពីព្រះវរបិតា ក្នុងពេលទ្រង់អធិស្ឋាន (គម្ពីរលូកា ២២:៤២-៤៤) ។ ទ្រង់ក៏បានឆ្លងកាត់ការឈឺចាប់ (គម្ពីរ១ពេត្រុស ៤:១) និង ចុងក្រោយទ្រង់ក៏បានឆ្លងកាត់សេចក្តីស្លាប់ (គម្ពីរ ១កូរិនថូស ១៥:៣)។ នេះគឺជាភស្តុតាងដ៏អស្ចារ្យបំផុតអំពីដែនកំណត់នៃមនុស្សរបស់ទ្រង់បានធ្វើទៅចំពោះទ្រង់។

ព្រះនាមជាមនុស្ស

ព្រះនាមដែលព្រះយេស៊ូទទួលបានក៏បញ្ជាក់ពីភាពជាមនុស្សរបស់ព្រះអង្គផងដែរ។ នៅពេលដែលទេវតាបានប្រាប់លោកយ៉ូសែបអំពីបុត្រដែលនឹងត្រូវប្រសូតមក ទេវតានោះបានបង្គាប់ឲ្យលោកយ៉ូសែបដាក់ឈ្មោះបុត្រនោះថា *យេស៊ូ* ដែលស្រដៀងទៅនឹងឈ្មោះនៅក្នុងភាសាក្រិកនៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ គឺ *យ៉ូស្វេ* (គម្ពីរម៉ាថាយ១:២១) ដែលមានន័យថា "អ្នកសង្គ្រោះ" ។ ទ្រង់ក៏ត្រូវបានគេហៅថា "ព្រះរាជវង្សរបស់ព្រះបាទដាវីឌ" និង "ពូជពង្សរបស់លោកអប្រាហាំ" (គម្ពីរម៉ាថាយ ១:១)។ ប៉ុន្តែព្រះនាមដែលទ្រង់គាប់ព្រះទ័យឲ្យគេហៅទ្រង់នៅក្នុងបទគម្ពីរ គឺ *បុត្រមនុស្ស* ជានាមដែលសំដែងយ៉ាងច្បាស់អំពីភាពជាមនុស្សរបស់ទ្រង់។ ព្រះយេស៊ូបានប្រើនាមនេះ នៅពេលទ្រង់មានព្រះបន្ទូលអំពីអង្គទ្រង់ (គម្ពីរម៉ាថាយ ២៦:៦៤-៦៥)។ អ្នកនឹងសំគាល់ឃើញថា ទោះបីជា ទ្រង់មិនបានប្រកាសថាទ្រង់គឺជាបុត្រមនុស្ស*អ្នក*នោះទេ តែទ្រង់បានប្រកាសថាទ្រង់គឺជាបុត្ររបស់មនុស្ស ។ ពាក្យនេះ មិនគ្រាន់តែបញ្ជាក់ថាទ្រង់គឺជាមនុស្សម្នាក់នោះទេ ប៉ុន្តែក៏បញ្ជាក់ថាទ្រង់គឺជាអ្នកតំណាងឲ្យមនុស្សជាតិទាំងអស់។

លំហាត់អនុវត្តន៍

---

២ ចូរអានគម្ពីរលូកា ២:៤០, ៥១; ៨:១៩-២១ និងគម្ពីរយ៉ូហាន ៧:១-៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ ចូរគូសរង្វង់ជុំវិញអក្សរខាងមុខចម្លើយត្រឹមត្រូវ។

ក) ព្រះយេស៊ូបានឆ្លងកាត់កុមារភាព និង ដំណាក់កាលនៃការអភិវឌ្ឍន៍ធម្មតា ទ្រង់បង្ហាញឲ្យឃើញពីការរីកចម្រើនខាងឯរូបកាយ គំនិត និង ខាងឯវិញ្ញាណ។

ខ) ទោះបីជាទ្រង់បង្ហាញឲ្យឃើញពីសមត្ថភាពមិនធម្មតាតាំងពីវ័យក្មេង ព្រះយេស៊ូនៅតែស្ថិតនៅក្រោមការដឹកនាំរបស់ឪពុកម្តាយរបស់ទ្រង់។

គ) នៅពេលដែលព្រះយេស៊ូ ទទួលបានចំណាប់អារម្មណ៍នៅពេលទ្រង់បង្រៀន ឪពុកម្តាយរបស់ទ្រង់បានយល់ច្បាស់ពីបេសកកម្មរបស់ទ្រង់ ហើយមិនបានទាមទារអ្វីពីទ្រង់វិញឡើយ។

ឃ) បងប្អូនរបស់ព្រះយេស៊ូ បានទទួលស្គាល់ថាទ្រង់គឺលើសពីមនុស្សធម្មតា តាមរយៈកិច្ចការដ៏អស្ចារ្យរបស់ទ្រង់ ហើយពួកគេបានគាំទ្រព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់។

៣ ចូរផ្គូផ្គងភស្តុតាងនៃភាពជាមនុស្សរបស់ព្រះយេស៊ូ (ខាងស្តាំ) ទៅនឹងការរៀបរាប់អំពីភស្តុតាងនោះ (ខាងឆ្វេង)។

.....ក) ព្រះយេស៊ូបានឆ្លងកាត់ការនឿយហត់ ការឃ្លាន ការស្រេក ការឈឺចាប់ និង ទីបំផុតការសុគត។	១) បុព្វបុរសជាមនុស្ស
	២) ការអភិវឌ្ឍន៍ជាមនុស្ស
.....ខ) ព្រះយេស៊ូត្រូវបានគេហៅថា ដោយប្រើទម្រង់ភាសាក្រិកនៃពាក្យថា *យ៉ូស្វេ* នៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ បូករួមទាំងនាមដទៃទៀតដែរ។	៣) សណ្ឋានជាមនុស្ស
	៤) ដែនកំណត់ជាមនុស្ស
	៥) ព្រះនាមជាមនុស្ស
.....គ) អ្នកនិពន្ធព្រះគម្ពីរ បានរៀបរាប់ពីខ្សែស្រឡាយរបស់ព្រះយេស៊ូ រហូតដល់ព្រះបាទដាវីឌ លោក	

អប្រាហាំ និង លោកអដាំ។

.....ឃ) ពួកទេសាភិបាលរ៉ូម៉ាំង ដែលបានកាត់ទោសព្រះយេស៊ូ បានសំគាល់ទ្រង់ដោយនិយាយថា "មើល៍ មនុស្សហ្នឹងហើយ" (គម្ពីរយ៉ូហាន ១៩:៥)។

.....ង) ព្រះយេស៊ូបង្ហាញពីការរីកចម្រើនខាង ឯគំនិត រូបកាយ វិញ្ញាណ និង សង្គម។

ខ. ភាពជាព្រះរបស់ព្រះគ្រិស្ត

វគ្គបំណែងទី២. *ផ្តល់ភស្តុតាងដែលយោងតាមព្រះគម្ពីរ ទៅលើភាពជាព្រះរបស់ព្រះយេស៊ូ។*

យើងបានពិនិត្យទៅលើភស្តុតាងក្នុងព្រះគម្ពីរ សម្រាប់ភាពជាមនុស្សរបស់ព្រះគ្រិស្ត ហើយយើងឃើញថា ភស្តុតាងនេះគឺពិតជាមានភាពប្រាកដប្រជាមែន។ ឥឡូវនេះ យើងនឹងពិចារណាទៅលើការពិតក្នុងព្រះគម្ពីរដែលទាក់ទងនឹងភាពជាព្រះរបស់ព្រះគ្រិស្ត និង សារៈសំខាន់នៃផ្នែកមួយនេះរបស់ទ្រង់វិញម្តង។

សិទ្ធិជាព្រះជាម្ចាស់

ភស្តុតាងដំបូងដែលយើងនឹងពិចារណា សម្រាប់ភាពជាព្រះរបស់ព្រះគ្រិស្តគឺថា *ទ្រង់ប្រើប្រាស់សិទ្ធិដែលមានតែព្រះជាម្ចាស់មានសិទ្ធិនោះ។* សិទ្ធិជាព្រះជាម្ចាស់ រួមមាន *ការទទួលបាននូវការថ្វាយបង្គំពីមនុស្ស ការអត់ទោសបាប ការប្រោសមនុស្សស្លាប់ឲ្យរស់* និង *សិទ្ធិក្នុងការវិនិច្ឆ័យទោស។*

ដោយសារតែព្រះជាម្ចាស់បានហាមឃាត់នៅក្នុង ក្រឹត្យវិន័យទាំងដប់ប្រការ នូវការថ្វាយបង្គំព្រះដទៃ (គម្ពីរនិក្ខមនំ ២០:៣-៥) នោះការថ្វាយបង្គំនេះ គឺជាទង្វើប្រមាថ ប្រសិនបើព្រះយេស៊ូមិនមែនជាព្រះដទៃទេនោះ។ (*ការប្រមាថ* គឺជាការ មើលងាយ ឬ ការថ្លែងប្រកាសយ៉ាងខុសឆ្គងថាខ្លួនជាព្រះជាម្ចាស់)។ នៅពេលដែលព្រះយេស៊ូត្រូវបានល្បួងលដោយអារក្ស ទ្រង់បានបញ្ជាក់ម្តងហើយម្តងទៀត អំពីក្រឹត្យវិន័យ ដែលតម្រូវឲ្យថ្វាយបង្គំព្រះអម្ចាស់ និង បម្រើទ្រង់តែមួយ(គម្ពីរម៉ាថាយ ៤:១០)។ ប៉ុន្តែទ្រង់បានប្រកាស ពីសិទ្ធិទទួលបានការថ្វាយបង្គំរបស់ទ្រង់។

ព្រះគម្ពីរបានបង្ហាញថា នៅពេលដែលមនុស្សមានភាពល្ងង់ខ្លៅ បានព្យាយាមថ្វាយបង្គំពួកសាវ័កមនុស្សរបស់ព្រះជាម្ចាស់ទាំងនេះ បដិសេធយ៉ាងខ្លាំង ដោយមិនព្រមទទួលការថ្វាយបង្គំរបស់ពួកគេឡើយ (គម្ពីរកិច្ចការ ១០:២៥- ២៦; ១៤:១១-១៨)។ សូម្បីតែពួកទេវតាដ៏វិសុទ្ធដ៏បដិសេធមិនទទួលការថ្វាយបង្គំដែលបានផ្តល់ទៅឲ្យពួកគេ យ៉ាងខុសឆ្គងនោះដែរ (គម្ពីរវិវរណៈ ១៩:១០; ២២:៨-៩)។ នៅពេលដែលពួកគេសាវ័កដែលជាមនុស្សសាមញ្ញ និង ពួកទេវតាដ៏មានឫទ្ធិ បដិសេធមិនទទួលការថ្វាយបង្គំ ព្រះយេស៊ូបានទទួលយកការថ្វាយបង្គំវិញ ដ្បិតនោះជាសិទ្ធិរបស់ព្រះអង្គ។ ទ្រង់បានប្រកាសថា ការតម្កើងទ្រង់គឺជាកាតព្វកិច្ចរបស់មនុស្សទាំងអស់ (គម្ពីរយ៉ូហាន៥:២៣)។

ម្យ៉ាងវិញទៀត យើងឃើញថា ព្រះយេស៊ូបានប្រើប្រាស់សិទ្ធិរបស់ទ្រង់ ដើម្បីអត់ទោសបាប ដែលជាសិទ្ធិ ទុកសម្រាប់តែព្រះជាម្ចាស់តែមួយគត់ (គម្ពីរម៉ាកុស ២:៥-៧) ។ ព្រះយេស៊ូមិនបានស្ទាក់ស្ទើរក្នុងការប្រើប្រាស់សិទ្ធិមួយនេះឡើយ ទោះបីជាសត្រូវរបស់ទ្រង់ ថ្នាំងថ្នាក់ជាមួយនឹងរឿងនេះយ៉ាងខ្លាំង (គម្ពីរម៉ាថាយ ៩:២-៦)។

ព្រះយេស៊ូក៏បានប្រើប្រាស់សិទ្ធិនេះដើម្បីប្រទានជីវិត (គម្ពីរយ៉ូហាន ៥:២១;១០:១០)។ យ៉ាងហោចមានបីលើក ដែលព្រះយេស៊ូបានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ (គម្ពីរលូកា ៧:១១-១៧; ៨:៤០-៥៦ គម្ពីរយ៉ូហាន ១១:១-៤៤)។ នៅពេលអនាគត អស់អ្នកដែលបានស្លាប់ទៅ នឹងរស់រានមានជីវិតឡើងវិញ ដោយព្រះបន្ទូលដ៏មានឫទ្ធានុភាពរបស់ព្រះអង្គ (គម្ពីរយ៉ូហាន ៥:២១-៣០) ។ ជាក់ស្តែង សិទ្ធិក្នុងការផ្តល់ជីវិត គឺជាសិទ្ធិដែលគ្មានមនុស្សធម្មតាម្នាក់ណា អាចធ្វើបានដោយអំណាចផ្ទាល់ខ្លួនបានឡើយ។

ឧទាហរណ៍ទីបួន អំពីសិទ្ធិជាព្រះជាម្ចាស់របស់ព្រះយេស៊ូ គឺសិទ្ធិរបស់ទ្រង់ក្នុងការវិនិច្ឆ័យទោស៖ "ព្រះបិតាមិនដាក់ទោសនរណាឡើយ គឺព្រះអង្គបានប្រគល់អំណាចដាក់ទោសទាំងអស់អោយព្រះបុត្រាវិញ" (គម្ពីរយ៉ូហាន ៥:២២) ។ បទគម្ពីរខាងក្រោមនេះ ផ្តល់ឲ្យយើងនូវចំណេះដឹងបន្ថែម អំពីវិសាលភាពនៃសិទ្ធិក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់៖ គម្ពីរម៉ាថាយ ២៥:៣១-៤៦ គម្ពីរកិច្ចការ ១០:៤២;១៧:៣១ និង គម្ពីរ២កូរិនថូស ៥:១០។

ព្រះយេស៊ូបានប្រើប្រាស់សិទ្ធិទាំងអស់នេះ ហើយនឹងសិទ្ធិដទៃទៀតរបស់ទ្រង់ ដោយគ្មានភាពស្ទាក់ស្ទើរសោះឡើយ។ បើទ្រង់បានប្រើប្រាស់សិទ្ធិទាំងនេះ ដោយទ្រង់មិនមែនជាព្រះជាម្ចាស់ នោះច្បាស់ជាទង្វើឥតកោតក្រែង (ហួសពីអ្វីដែលជារឿងត្រឹមត្រូវ) និង ជាការប្រមាថ។

លំហាត់អនុវត្តន៍

៤ ចូររៀបរាប់ដោយប្រើការចងចាំរបស់អ្នក នូវអ្វីដែលព្រះយេស៊ូបានធ្វើនៅក្នុងអំឡុងពេល ដែលទ្រង់មានព្រះជន្មគង់នៅលើផែនដី ដែលបង្ហាញថាទ្រង់បានប្រើប្រាស់សិទ្ធិជាព្រះជាម្ចាស់របស់ទ្រង់។ ចូរសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

លក្ខណាសម្បត្តិជាព្រះជាម្ចាស់

វត្ថុបំណងទី៣. *រៀបរាប់គុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិ ដែលបង្ហាញថាព្រះយេស៊ូជាព្រះជាម្ចាស់។*

គុណលក្ខណៈខាងសីលធម៌

លក្ខណសម្បត្តិរបស់ព្រះយេស៊ូធ្វើឲ្យមនុស្សងឿងឆ្ងល់។ ពួកគេបានសូប៉ស្ងែង នឹងអាកប្បកិរិយា និង គុណលក្ខណៈរបស់ទ្រង់នៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ការឆ្លើយតបរបស់ទ្រង់ទៅនឹងស្ថានភាពនៅក្នុងជីវិត បានបង្ហាញយ៉ាងច្បាស់ថាទ្រង់មិនដូចគេនោះទេ។ ទ្រង់មានគុណលក្ខណៈខាងឯសីលធម៌ និង ធម្មជាតិ ដូចជាព្រះជាម្ចាស់ព្រះវរបិតារបស់ទ្រង់។

ព្រះយេស៊ូបានរស់នៅក្នុងជីវិតវិសុទ្ធដ៏ល្អប្រសើរ ដល់ថ្នាក់អ្នកដែលជិតស្និទ្ធទ្រង់ និយាយថា៖ "ព្រះអង្គពុំដែលបានប្រព្រឹត្តអំពើបាបសោះ ហើយក៏ពុំដែលមានព្រះបន្ទូលវៀចវេរណា ចេញពីព្រះឱស្ឋរបស់ព្រះអង្គឡើយ។" (គម្ពីរ១ពេត្រុស ២:២២)។ សត្រូវរបស់ទ្រង់ មិនអាចអះអាងថាទ្រង់មានបាបបានឡើយ ព្រោះទ្រង់គ្មានបាបសោះ (គម្ពីរយ៉ូហាន៨:៤៦)។ គ្មានមនុស្សធម្មតាម្នាក់ណា អាចមានឥរិយាបថកម្រិតនេះបានឡើយ ប៉ុន្តែព្រះយេស៊ូទ្រង់លើសពីមនុស្សទៅទៀត។

សេចក្តីស្រឡាញ់ របស់ទ្រង់ ក៏បានកំណត់ព្រះយេស៊ូឲ្យដាច់ពីមនុស្សសាមញ្ញ។ ទ្រង់បានបង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ តាមរយៈទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងមនុស្ស ពីគ្រប់ដំណើរជីវិត និងគ្រប់កម្រិតក្នុងសង្គមទាំងអស់ (គម្ពីរលូកា ១៩:១០ ព្រមទាំងប្រៀបធៀបរវាង គម្ពីរម៉ាថាយ១១:១៩ ជាមួយនឹង គម្ពីរម៉ាកុស ១០:១៧-២២)។ ទ្រង់បានអធិស្ឋានសម្រាប់អ្នកដែលដើរតាមទ្រង់ ហើយទ្រង់ក៏អធិស្ឋានសម្រាប់សត្រូវរបស់ទ្រង់ដែរ (គម្ពីរយ៉ូហាន ១៧:៩-២០ គម្ពីរលូកា ២៣:៣៤)។គុណសម្បត្តិដ៏ឥតខ្ចោះរបស់ទ្រង់មួយនេះបានបង្ហាញថា ទ្រង់គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់។

សេចក្តីស្រឡាញ់របស់ព្រះយេស៊ូ បានសំដែងទៅតាមរបៀបជាច្រើន។ ទ្រង់បង្ហាញពីការបន្ទាបខ្លួន និង ការដាក់ខ្លួនដ៏ពិត។ នៅពេលដែលទ្រង់បានចូលទៅក្នុងព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់ ទ្រង់បានទទួលការជំរុញចិត្តពីបំណងព្រះហឫទ័យនៃការបម្រើ (គម្ពីរម៉ាថាយ ២០:២៨)។ ក្នុងនាមទ្រង់ជាម្ចាស់ និង ជាគ្រូបង្រៀនម្នាក់ ទ្រង់បានបង្ហាញពីអត្ថន័យពិត នៃការបម្រើតាមរយៈការលាងជើងឲ្យពួកសិស្សរបស់ទ្រង់ (គម្ពីរយ៉ូហាន១៣:១៤) ។ ទ្រង់ទន់ភ្លន់ចំពោះពួកអ្នកមានបាប (គម្ពីរលូកា ៧:៣៧-៣៩, ៤៤-៥០) ចំពោះពួកអ្នកមានចិត្តសង្ស័យ (គម្ពីរយ៉ូហាន ២០:២៩) និង ចំពោះអស់អ្នកដែលបានបដិសេធមិនទទួលស្គាល់ទ្រង់ (គម្ពីរលូកា២២:៦១ គម្ពីរយ៉ូហាន ២១:១៥-២៣)។ ដោយក្តីស្រឡាញ់ ទ្រង់បានបង្ហាញពីគោលការណ៍ដែលទ្រង់បានបង្រៀន! គ្មានមនុស្សសាមញ្ញណាម្នាក់អាចរស់នៅក្នុងជីវិតដែលពេញដោយសេចក្តីស្រឡាញ់យ៉ាងពេញបរិបូរណ៌ដូច្នេះបានឡើយ។

សេចក្តីស្រឡាញ់របស់ទ្រង់ ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់បំផុត តាមរយៈក្តីស្រឡាញ់ដែលទ្រង់មានចំពោះព្រះជាម្ចាស់ព្រះវរបិតារបស់ទ្រង់។ ទ្រង់បានបង្ហាញ តាមរយៈឧទាហរណ៍ផ្ទាល់របស់ទ្រង់ ថាជីវិតខាងឯវិញ្ញាណដ៏មានប្រសិទ្ធិភាព គឺផ្អែកទៅលើការមានទំនាក់ទំនងយ៉ាងស្និទ ជាមួយព្រះជាម្ចាស់។ គ្មានមនុស្សសាមញ្ញណាម្នាក់អាច អធិស្ឋានដូចជាទ្រង់បានឡើយ។ ទ្រង់បានអធិស្ឋានយ៉ាងស្វិតស្វាញ (គម្ពីរលូកា២២:៣៩-៤៤) យ៉ាងទៀងទាត់ និង យ៉ាងយូរទៀតផង ។ ពេលខ្លះទ្រង់អធិស្ឋានអស់ពេញមួយយប់ ។ មានពេលខ្លះទៀត ទ្រង់តើនឡើងពីព្រលឹមដើម្បីអធិស្ឋាន (គម្ពីរម៉ាកុស ១:៣៥) ។ ទ្រង់បានបន្សល់ទុកគំរូដ៏ល្អឥតខ្ចោះ អំពីមាគ៌ាក្នុងការរក្សា និង អភិវឌ្ឍជីវិតខាងឯវិញ្ញាណរបស់យើង (គម្ពីរ១ពេត្រុស ២:២១)។

គ្មាននរណាម្នាក់ ដែលជិតស្និទជាមួយទ្រង់ អាចសង្ស័យនឹងភាពជាមនុស្សរបស់ទ្រង់បានឡើយ។ ហើយក៏គ្មាននរណាម្នាក់អាចប្រៀបធៀបភាពល្អឥតខ្ចោះរបស់ទ្រង់ ទៅជាមួយនឹងការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់មនុស្សណាម្នាក់បានដែរ។ ឧទាហរណ៍ដ៏ល្អបំផុត អំពីភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ត្រូវបានបង្ហាញឲ្យឃើញនៅក្នុងប្រសាសន៍របស់លោកពេត្រុសថា " លោកជាព្រះគ្រិស្ត(មេស្ស៊ី)* ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅ" (គម្ពីរម៉ាថាយ១៦:១៦) ។

លំហាត់អនុវត្តន៍

៥ ចូរថ្លែងពីរបៀបដែលព្រះយេស៊ូបង្ហាញពីភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ទ្រង់ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

គុណលក្ខណៈ:បែបធម្មជាតិ

លោកប៉ូលបានថ្លែងប្រកាសថា ព្រះយេស៊ូគ្រិស្តគឺជាឫទ្ធានុភាព និង ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ (គម្ពីរ១កូរិនថូស ១:២៤) ហើយថ្លែងថា ព្រះជាម្ចាស់គាប់ព្រះហឫទ័យឲ្យគ្រប់លក្ខណសម្បត្តិរបស់ព្រះអង្គស្ថិតនៅក្នុងព្រះបុត្រា (គម្ពីរកូឡូស ១:១៩; ២:៩)។ លោកម៉ាថាយបានធ្វើការបញ្ចប់កំណត់ត្រាដំណឹងល្អរបស់លោក ជាមួយនឹងព្រះបន្ទូលរបស់ព្រះយេស៊ូថា ៖ "ខ្ញុំបានទទួលគ្រប់អំណាច ឫទ្ធានុភាព ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី" (គម្ពីរម៉ាថាយ ២៨:១៨)។ បទគម្ពីរនេះបានបង្ហាញថាព្រះយេស៊ូដែលជាអង្គទីពីរនៅក្នុងព្រះត្រៃឯក ទ្រង់គឺ*សព្វានុភាព* ។ រាល់ទេវតា អំណាច និងឫទ្ធានុភាព នៅក្នុងសាកលលោកនេះ គឺស្ថិតក្រោមឥទ្ធិពលនៃឫទ្ធានុភាព និង សិទ្ធិអំណាចរបស់ទ្រង់ (គម្ពីរ១ពេត្រុស ៣:២២)។

ព្រះគម្ពីរក៏បានបង្រៀនយើងថា ព្រះយេស៊ូទ្រង់*សព្វដ្ឋភាព* (មានវត្តមាននៅគ្រប់ទីកន្លែង) ។ លោកប៉ូលនិយាយថា ព្រះជាម្ចាស់ព្រះវរបិតាបានដាក់ឲ្យអ្វីសព្វសារពើ នៅក្រោមព្រះរាជបុត្រា និង និយាយថា ព្រះរាជបុត្រា "ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ " (គម្ពីរអេភេសូ ១:២២-២៣ នៅគម្ពីរបកប្រែចាស់)។ នេះពិតជាការលើកទឹកចិត្តដ៏ប្រពៃមួយសម្រាប់យើង នៅពេលដែលយើងចាំថា ទ្រង់នឹងរក្សាព្រះបន្ទូលសន្យារបស់ទ្រង់ ថានឹងគង់នៅជាមួយយើង នៅពេលណាដែលយើងគ្រាន់តែមានគ្នាពីរបីនាក់មករួមគ្នាថ្វាយបង្គំទ្រង់យ៉ាងដូច្នេះ (គម្ពីរម៉ាថាយ ១៨:២០)។ ទោះបីជាមានពេលខ្លះ យើងប្រហែលជាមិនអាចទទួលអារម្មណ៍ដឹងពីព្រះវត្តមានរបស់ទ្រង់ ក៏យើងនៅតែអាចប្រាកដក្នុងចិត្តថា ទ្រង់គឺនៅជាមួយយើងគ្រប់ពេលវេលា!

ព្រះយេស៊ូគ្រិស្តទ្រង់*សព្វញ្ញតភាព*(សព្វញ្ញតញាណ) ទ្រង់ជ្រាបដឹងគ្រប់ការទាំងអស់ (គម្ពីរយ៉ូហាន ២:២៤-២៥;១៦:៣០; ២១:១៧)។ លោកប៉ូលនិយាយអំពីអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ដោយលោកនិយាយថា គឺជាព្រះគ្រិស្ត "ដែលមានគ្រប់ទាំងផលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្តីចេះដឹង" (គម្ពីរ

កូឡុស ២:២-៣ នៅគម្ពីរបកប្រែចាស់ ។សូមសង្កត់បញ្ជាក់លើឃ្លាអក្សរទ្រេត)។ ទ្រង់ជ្រាបដឹងអំពីជីវិតមានបាបទាំងប៉ុន្មាន របស់ស្ត្រីសាសន៍សាម៉ារី (គម្ពីរយ៉ូហានជំពូក៤) ទ្រង់ជ្រាបដឹងពីគំនិតរបស់ពួកគណៈផារិស៊ី (គម្ពីរលូកា ៦:៨) ទ្រង់ជ្រាបដឹងពីរបៀប និង ពេលណាដែលទ្រង់អាចនឹងចាកចេញពីពិភពលោក (គម្ពីរយ៉ូហាន ១២:៣៣; ១៣:១) ព្រមទាំងធម្មជាតិ និង ទីបញ្ចប់នៃជំនាន់សព្វថ្ងៃ (គម្ពីរម៉ាថាយ ២៤-២៥ គម្ពីរម៉ាកុស ១៣ គម្ពីរលូកា ២១)

បទគម្ពីរខ្លះ បានបណ្តាលឲ្យយើងពិនិត្យមើលទៅលក្ខណសម្បត្តិនៃសព្វញ្ញុតភាពរបស់ទ្រង់ ឲ្យបានកាន់តែស៊ីជម្រៅថែមទៀត ។ ឧទាហរណ៍ នៅក្នុងគម្ពីរម៉ាថាយ ២៤:៣៦ បានប្រាប់ថា ទ្រង់មិនបានជ្រាបដឹងអំពីថ្ងៃនៃការយាងត្រឡប់មកវិញនោះទេ ហើយលោកម៉ាកុសបានសរសេរថា ព្រះយេស៊ូ បានយាងទៅឯដើមឧទុម្ពរ រំពឹងថានឹងបានឃើញមានផ្លែ តែទ្រង់ទទួលបានការខកព្រះទ័យទៅវិញ (គម្ពីរម៉ាកុស ១១:១៣)។

នៅត្រង់នេះ មានសារៈសំខាន់ណាស់ដែលយើងត្រូវបញ្ជាក់ថា នៅក្នុងកាលដែលទ្រង់គង់នៅលើផែនដី ឬ កាលដែលទ្រង់ជា *មនុស្ស* ព្រះយេស៊ូបានលះបង់សិទ្ធិរបស់ទ្រង់ក្នុងការប្រើប្រាស់ដោយសេរីនូវលក្ខណសម្បត្តិជាព្រះរបស់ទ្រង់។ ទ្រង់មានបំណងព្រះហឫទ័យជ្រើសរើសមិនប្រើប្រាស់អំណាចជាព្រះជាម្ចាស់របស់ទ្រង់នៅក្នុងពេលនោះទេ។ ទ្រង់មានអំណាច ដែលទ្រង់អាចយកមកប្រើ ដើម្បីប្រោសលោះអង្គទ្រង់ផ្ទាល់បាន ប៉ុន្តែទ្រង់បដិសេធមិនប្រើប្រាស់អំណាចទាំងនោះឡើយ (គម្ពីរ ម៉ាថាយ ២៦:៥២-៥៤) ។ ទ្រង់ធ្វើយ៉ាងដូច្នេះ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ ដ្បិតទ្រង់ជ្រាបថាប្រសិនបើទ្រង់ មិនលះបង់ដើម្បីរងទុក្ខ ហើយសុគតនោះទេ ទ្រង់មិនអាចបំពេញបេសកកម្មរបស់ទ្រង់ក្នុងការសុគតជួសមនុស្សជាតិដែលពោរពេញដោយបាបនេះបានឡើយ។ ប៉ុន្តែឥឡូវនេះ ដោយសារបេសកកម្មរបស់ទ្រង់បានសម្រេចហើយ ទ្រង់បានទទួលលក្ខណសម្បត្តិជាព្រះជាម្ចាស់ទាំងអស់របស់ទ្រង់មកវិញ រួមទាំងគុណលក្ខណៈនៃការជ្រាបដឹងគ្រប់ការទាំងអស់ផងដែរ។

ព្រះគម្ពីរបង្ហាញពីព្រះយេស៊ូ ថាជាបុត្រដ៏*អស់កល្បជានិច្ច*របស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១:១ គម្ពីរ១យ៉ូហាន ១:១ គម្ពីរមីកា ៥:២) ។ ទ្រង់មានព្រះជន្មគង់នៅជាដរាបរៀងមក ហើយទ្រង់នឹងគង់នៅជារៀងរហូត (គម្ពីរហេប្រឺ ១:១១-១២;១៣:៨)។ បទគម្ពីរទាំងនេះ ក៏បានប្រកាសថា ព្រះយេស៊ូគ្រិស្ត *មិនដែលប្រួលប្រែ* ។ លក្ខណសម្បត្តិដែលយើងបានឃើញទាំងអស់នេះ គឺជាគុណលក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់។ ដូច្នេះហើយ លក្ខណសម្បត្តិទាំងនេះផ្តល់ឲ្យយើងនូវភស្តុតាងយ៉ាងច្បាស់ អំពីភាពជាព្រះរបស់ព្រះយេស៊ូគ្រិស្ត។

លំហាត់អនុវត្តន៍

៦ សរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយពីមូលហេតុដែលព្រះយេស៊ូមិនប្រើប្រាស់លក្ខណសម្បត្តិជាព្រះជាម្ចាស់របស់ទ្រង់ នៅពេលដែលទ្រង់ជាមនុស្ស ។

៧ ចូរសរសេរនៅចំណងជើង *គុណលក្ខណៈខាងឯសីលធម៌របស់ព្រះយេស៊ូ* និង *គុណលក្ខណៈខាងឯធម្មជាតិរបស់ព្រះយេស៊ូ* ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ចូរសរសេរជាចំណុចៗ អំពីគុណលក្ខណៈដែលមាននៅក្នុងចំណងជើងនីមួយៗ។ បន្ទាប់មកចូរប្រៀបធៀបចំណុចដែលអ្នកបានសរសេរ ជាមួយនឹងគុណលក្ខណៈខាងឯសីលធម៌ និង ខាងឯធម្មជាតិរបស់ព្រះជាម្ចាស់ដែលយើងបានពិភាក្សាគ្នានៅក្នុងមេរៀនទី១ និង ទី២។ តើការប្រៀបធៀបនេះបង្ហាញអ្វីខ្លះដល់អ្នក?

ការប្រកាសថាជាព្រះជាម្ចាស់

ព្រះយេស៊ូបានធ្វើការប្រកាសច្បាស់ៗមួយចំនួន ដែលថាទ្រង់ជាព្រះជាម្ចាស់។ នៅល្ងាចមុន ការសុគតរបស់ទ្រង់ ទ្រង់បានអះអាងទៅកាន់ពួកសាវ័ក ឲ្យទទួលយកការប្រកាសទាំងនេះដោយមានមូលដ្ឋានទៅលើកិច្ចការអស្ចារ្យរបស់ទ្រង់ (គម្ពីរយ៉ូហាន ១៤:១១)។ តើការប្រកាសរបស់ទ្រង់ មានអ្វីខ្លះ?

១. ទ្រង់មានព្រះបន្ទូលទៅកាន់ពួកយូដាថា ទ្រង់ និង ព្រះវរបិតាគឺតែមួយ (គម្ពីរយ៉ូហាន ១០:៣០)។

២. នៅពេលដែលព្រះយេស៊ូគង់នៅចំពោះមុខពួកព្រឹទ្ធាចារ្យទទួលការកាត់ទោស ទ្រង់បានប្រកាសម្តងទៀតថា ទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់ (គម្ពីរលូកា ២២:៧០-៧១ គម្ពីរយ៉ូហាន ១៩:៧)។

៣. ទ្រង់បានអះអាងថា មនុស្សអាចទទួលការសង្គ្រោះបាន តែតាមរយៈទ្រង់តែមួយគត់។ (គម្ពីរយ៉ូហាន១០:៩)

៤. ទ្រង់បានមានព្រះបន្ទូលថា ទ្រង់គឺជាផ្លូវតែមួយគត់ដើម្បីចូលទៅឯព្រះវរបិតា (គម្ពីរយ៉ូហាន ១៤:៦)។

៥. ទ្រង់បានមានព្រះបន្ទូលថា គ្មាននរណាម្នាក់អាចធ្វើអ្វីបានឡើយ បើគ្មានការជួយពីទ្រង់នោះ (គម្ពីរយ៉ូហាន ១៥:៥)។

៦. ក្នុងអំឡុងពេល ព័ន្ធកិច្ចនៃការបង្រៀនរបស់ទ្រង់ ទ្រង់បានបញ្ជាក់ពីបុរេអត្ថិភាពរបស់ទ្រង់ (គម្ពីរយ៉ូហាន ៨:៥៨; ១៧:៥)។

៧. ទ្រង់បានបង្គាប់ឲ្យ ពួកសាវ័ករបស់ទ្រង់ អធិស្ឋាននៅក្នុងព្រះនាមរបស់ទ្រង់ (គម្ពីរយ៉ូហាន ១៦:២៣)។

៨. នៅពេលដែលទ្រង់ចាត់បញ្ជូន សាវ័ករបស់ទ្រង់ឲ្យចេញទៅធ្វើព័ន្ធកិច្ច ទ្រង់បានប្រទានឲ្យពួកគេនូវឫទ្ធានុភាព ដើម្បីសំដែងការអស្ចារ្យ (គម្ពីរលូកា ៩:១-២)។

ព្រះបន្ទូល និង ការថ្លែងប្រកាសទាំងអស់នេះ បូករួមទាំងកិច្ចការអស្ចារ្យដែលព្រះយេស៊ូបានសំដែង បានផ្តល់ឲ្យនូវភស្តុតាងយ៉ាងជាក់ច្បាស់ ដែលបញ្ជាក់ពីការអះអាងរបស់ទ្រង់ថាជាព្រះជាម្ចាស់។

ព្រះនាមដែលបង្ហាញពីឋានៈជាព្រះ

ព្រះនាមដែលអាចប្រើប្រាស់ តែដើម្បីសំដៅទៅលើព្រះជាម្ចាស់ ត្រូវបានយកទៅហៅព្រះយេស៊ូគ្រិស្ត នៅទូទាំងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី។ អ្នកនិពន្ធដែលបានជំរុញចិត្តដោយព្រះវិញ្ញាណ តែងតែសរសេរសំដៅទៅរកទ្រង់ថា *ព្រះបុត្រារបស់ព្រះជាម្ចាស់* ។ សម្លេងដែលមកពីស្ថានបរមសុខ នៅក្នុងព្រឹត្តិការណ៍ពីរផ្សេងគ្នា បានប្រកាសថាទ្រង់គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់ (គម្ពីរម៉ាថាយ ៣:១៧;១៧:៥)។ ព្រះយេស៊ូក៏បានប្រើប្រាស់ ព្រះនាមនេះដើម្បីហៅអង្គទ្រង់ផងដែរ (គម្ពីរយ៉ូហាន ១០:៣៦)។

ព្រះនាមមួយផ្សេងទៀតដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់ គឺត្រូវបានទស្សន៍ទាយដោយលោកហោរាអេសាយ និង បន្តប្រើម្តងហើយម្តងទៀត ដោយទេវតាដែលបាននិយាយជាមួយនឹងលោកយ៉ូសែប (គម្ពីរអេសាយ ៧:១៤ គម្ពីរម៉ាថាយ ១:២២-២៣)។ បុត្រនោះត្រូវហៅព្រះនាមថា *អេម៉ាញូអែល* ដែលមានន័យថា "ព្រះជាម្ចាស់គង់ជាមួយយើង" (គម្ពីរម៉ាថាយ ១:២៣)។ ព្រះជាម្ចាស់បានយាងមកគង់នៅមួយរយៈលើផែនដីជាមួយមនុស្សប្រុស ស្រី (គម្ពីរយ៉ូហាន ១:១៤)។

លោកយ៉ូហានបានសរសេរថាព្រះយេស៊ូ គឺជា*ព្រះបន្ទូល*របស់ព្រះជាម្ចាស់។ សម្រាប់យើង វាហាក់បីដូចជា នាមមួយចម្លែកណាស់ ប៉ុន្តែនៅជំនាន់នោះ អ្នកទស្សនវិទូ មានទស្សនៈថា គេអាចបូកបញ្ចូលគ្នានូវមូលហេតុ និង ឫទ្ធានុភាព ដែលនៅពីក្រោយបង្កើតសាកលលោកទាំងមូល នៅក្នុងគំនិតអំពីពាក្យពេចន៍ (ព្រះបន្ទូល)។ ដូច្នេះ លោកយ៉ូហាននិយាយថា "ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា" (គម្ពីរយ៉ូហាន ១:១៤)។ ពាក្យសំដីរបស់មនុស្សម្នាក់បង្ហាញពីអ្វីដែលគាត់គិត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺជាព្រះតម្រិះរបស់ព្រះជាម្ចាស់ ដែលបង្ហាញតាមរបៀបដែលយើងអាចយល់បាន។ ព្រះជាម្ចាស់មិនដាច់ចេញពីស្នាព្រះហស្តរបស់ទ្រង់នោះទេ ទ្រង់បង្ហាញអង្គទ្រង់ឲ្យពួកគេបានមើលឃើញវិញ។ លោកយ៉ូហានប្រកាសថា ព្រះបន្ទូល (ព្រះយេស៊ូ) គឺជាព្រះជាម្ចាស់តាំងពីដើមរៀងមក (គម្ពីរយ៉ូហាន ១:១-២)។

ព្រះយេស៊ូក៏ត្រូវបានគេហៅថា *ព្រះជាម្ចាស់* ។ លោកប៉ូលបានសរសេរថាយើង "ទន្ទឹងរង់ចាំសុភមង្គល តាមសេចក្តីសង្ឃឹមរបស់យើង ហើយរង់ចាំព្រះយេស៊ូគ្រិស្តជាព្រះជាម្ចាស់ដ៏ឧត្តមបំផុត និងជាព្រះសង្គ្រោះនៃយើង យាងមកប្រកបដោយសិរីរុងរឿង។" (គម្ពីរទីតុស ២:១៣)។

ព្រះនាមជាភាសាហេប្រឺ *មេស្ស៊ី* តែងតែយកទៅប្រើប្រាស់ទាក់ទងទៅនឹងព្រះយេស៊ូ។ ព្រះនាមដូចគ្នានេះ ជាភាសាក្រិក គឺ *គ្រិស្ត* ។ ការបកប្រែមួយទៀត នៃព្រះនាមនេះគឺ *អ្នកដែលគេចាក់ប្រេងអភិសេក* ។ តើអ្នកដែលត្រូវគេចាក់ប្រេងអភិសេក មានន័យយ៉ាងដូចម្តេច សម្រាប់ប្រជាជនអ៊ីស្រាអែល? នៅក្នុងវប្បធម៌របស់ពួកគេ នៅពេលដែលព្រះជាម្ចាស់ ត្រាស់ហៅមនុស្សណាម្នាក់ ឲ្យធ្វើកិច្ចការពិសេសណាមួយ អ្នកនោះនឹងត្រូវបាន*ចាក់ប្រេងអភិសេក* ដោយអ្នកដឹកនាំសាសនា ដែលបានយកប្រេងទៅចាក់បង្ហូរលើក្បាលអ្នកដែលត្រូវបានត្រាស់ហៅនោះ។ នេះគឺជានិមិត្តសញ្ញានៃការផ្តាច់ខ្លួនដើម្បីការបម្រើ។ ប្រជារាស្ត្រហេប្រឺ គឺមានទម្លាប់ជាមួយនឹងព្យាការី បូជាចារ្យ និង ស្តេចដែលត្រូវបានចាក់ប្រេងអភិសេកទៅហើយ។ ដូច្នេះ នៅពេលដែលលោកពេត្រុសប្រកាសថាព្រះយេស៊ូគឺ ព្រះអម្ចាស់ និង ជាព្រះគ្រិស្ត អស់អ្នកដែលស្តាប់លោក បានយល់ពីអ្វីដែលលោកចង់និយាយហើយ (គម្ពីរកិច្ចការ ២:៣៦)។ ការឆ្លើយតបរបស់មនុស្ស

ជាច្រើនពាន់នាក់ បង្ហាញថា ពួកគេទទួលស្គាល់ព្រះយេស៊ូជាព្រះមេស្ស៊ី ឬ ជាអ្នកដែលគេចាក់ប្រេងអភិសេកនោះហើយ។

ព្រះយេស៊ូក៏ត្រូវបានគេហៅថា *ព្រះអម្ចាស់* ។ ពេលខ្លះព្រះនាមមួយនេះ ត្រូវបានប្រើប្រាស់ជានាមនៃភាពគួរសម ប៉ុន្តែជាច្រើនលើកច្រើនសា ព្រះនាមនេះត្រូវបានគេប្រើប្រាស់ ដើម្បីសម្តែងការគោរព ចំពោះភាពជាព្រះរបស់ទ្រង់។ (ចូរមើល គម្ពីរលូកា ១:៤៣; ២:១១ គម្ពីរយ៉ូហាន ២០:២៨ គម្ពីរកិច្ចការ ១៦:៣១ និង គម្ពីរ១កូរិនថូស ១២:៣)។ ព្រះនាមនេះ ដែលតែងតែប្រើនិយាយថា ព្រះអម្ចាស់នៃយើង គឺមកពីការបកប្រែពាក្យភាសាហេប្រឺថា *យេហូវ៉ា* ។ ដូច្នេះ ព្រះគ្រិស្តដែលជាព្រះមេស្ស៊ី គឺត្រូវគេហៅ ព្រះយេហូវ៉ា នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់។

លំហាត់អនុវត្តន៍

---

៨ ចូរសរសេរព្រះនាមដែលបានថ្វាយទៅកាន់ព្រះយេស៊ូ ដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់ ព្រមទាំងសរសេរខគម្ពីរដែលជាភស្តុតាងសម្រាប់ព្រះនាមនីមួយៗ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ។ ភាពជាព្រះរបស់ព្រះយេស៊ូ គឺត្រូវបានបង្ហាញតាមរយៈ

ក) ការទទួលបានការថ្វាយបង្គំពីមនុស្ស ការអត់ទោសបាប ការមានព្រះជន្មរស់ឡើងវិញ និងការទទួលបានសិទ្ធិក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់។

ខ) គុណលក្ខណៈខាងឯសីលធម៌ ដែលមានភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ទ្រង់។

គ) គុណលក្ខណៈខាងឯធម្មជាតិ ដែលមានសព្វានុភាព សព្វដ្ឋភាព សព្វញ្ញុតភាព និង ភាពអស់កល្បជានិច្ចរបស់ទ្រង់។

ឃ) តំរិយោបថដែលប្រជារាស្ត្ររបស់ទ្រង់ទទួលយកទ្រង់។

ង) ការអះអាងទាមទារភាពជាព្រះរបស់ទ្រង់ផ្ទាល់។

ច) ព្រះនាមរបស់ទ្រង់ដែលបង្ហាញពីភាពជាព្រះរបស់ទ្រង់។

គ. ការរួមមកតែមួយនៃភាពជាព្រះ និង ភាពជាមនុស្សនៅក្នុងព្រះគ្រិស្ត

គោលលទ្ធិនៃការចាប់បដិសន្ធិ (ចាប់ជាតិ) ជាបញ្ហាមួយដែលនៅតែមិនអាចដោះស្រាយបាននៅក្នុងក្រុមជំនុំជំនាន់មុន។ គោលលទ្ធិនៃព្រះត្រៃឯក បានចាក់ឫសយ៉ាងរឹងមាំនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ បទពិសេធរបស់មិត្តសម្លាញ់របស់ព្រះយេស៊ូ និង សំណេរដែលមានព្រះវិញ្ញាណជំរុញ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី។ ប៉ុន្តែសំណួរដែលនាំឲ្យមានការប៉ាន់ស្មានយ៉ាងស្រពិចស្រពិល នោះគឺ៖ តើអាចទៅរួចទេ ព្រះបុត្រដែលគង់នៅអស់កល្បជានិច្ចមានហានៈជាព្រះជាម្ចាស់ស្មើនឹងព្រះវរបិតា មានសមាសភាពដូចព្រះវរបិតា មកចាប់កំណើតជាមនុស្សបាន?

អ្នកខ្លះដែលព្យាយាមបកស្រាយការចាប់បដិសន្ធិ(ចាប់ជាតិ) តែងតែសង្កត់ន័យទៅលើភាពជាមនុស្សរបស់ព្រះយេស៊ូខ្លាំងពេក ដែលគេបែរជាមិនទទួលស្គាល់ភាពជាព្រះរបស់ទ្រង់។ មានអ្នកខ្លះទៀតធ្វើផ្ទុយពីនេះវិញ ដោយពួកគេសង្កត់ន័យតែទៅលើភាពជាព្រះរបស់ទ្រង់ រហូតដល់ចំណុចមួយដែលគេស្ទើតែបដិសេធភាពជាមនុស្សរបស់ទ្រង់ទៅវិញ។ នៅពេលមួយ អ្នកដឹកនាំក្រុមជំនុំជំនាន់នោះ បានឈានទៅរកការកំណត់អត្ថន័យមួយនៃការចាប់បដិសន្ធិ ដែលមកដល់ពេលនេះនៅតែត្រូវបានចាត់ទុកថា ជាមូលដ្ឋានគ្រឹះនៃជំនឿរបស់គ្រិស្តបរិស័ទ ទាក់ទងនឹងអង្គព្រះយេស៊ូ។

លក្ខណាសម្បត្តិនៃការចាប់បដិសន្ធិ

វត្ថុបំណងទី៤. *ពិភាក្សាអំពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងការចាប់បដិសន្ធិ។*

អត្ថន័យនៃការចាប់បដិសន្ធិ ត្រូវបានកំណត់ដោយអ្នកដឹកនាំក្រុមជំនុំដំបូង នៅក្នុងការប្រជុំមួយដែលហៅថា កិច្ចប្រជុំក្រុមកាល់សេដូន ក្នុងឆ្នាំ៤៥១ គ.ស ដូចតទៅនេះ៖

ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង គឺពិតជាព្រះជាម្ចាស់ ហើយក៏ពិតជាមនុស្ស ដែលមានសារធាតុ ដូចជាព្រះវរបិតានៅក្នុងគ្រប់អ្វីៗទាំងអស់ បើនិយាយពីភាពជាព្រះរបស់ទ្រង់ ហើយក្នុងភាពជាមនុស្សរបស់ទ្រង់ ទ្រង់ដូចជាយើងរាល់គ្នាគ្រប់ផ្នែកទាំងអស់ លើកលែងតែអំពើបាបប៉ុណ្ណោះ។ ដូច្នេះ ព្រះយេស៊ូត្រូវបានគេស្គាល់ក្នុងនិស្ស័យពីរ៖ និស្ស័យជាព្រះជាម្ចាស់ និង និស្ស័យជាមនុស្ស។ និស្ស័យទាំងពីរនេះ គឺដោយឡែកគ្នា។ ភាពដោយឡែកគ្នានេះ ក៏មិនបានលុបបំបាត់ការរួបរួមរវាងនិស្ស័យទាំងពីរនេះដែរ ប៉ុន្តែលក្ខណៈពិសេសនៃនិស្ស័យនីមួយៗគឺត្រូវរក្សាឲ្យនៅដដែល។

ពិតណាស់ អត្ថន័យនេះមិនបានដកចេញនូវអាថ៌កំបាំងនៃការបដិសន្ធិឡើយ។ ផ្ទុយទៅវិញ គ្រិស្តបរិស័ទទាំងអស់ មានអារម្មណ៍ស្ងប់ស្ងែងដូចជាលោកសាវ័កប៉ូលដែរ៖ "គំរោងការដ៏លាក់កំបាំងនៃការគោរពប្រណិប័តន៍ព្រះជាម្ចាស់នោះធំណាស់ គឺថា: ព្រះជាម្ចាស់បានបង្ហាញអោយយើងស្គាល់ព្រះគ្រិស្តក្នុងឋានៈជាមនុស្ស" (គម្ពីរ១ធីម៉ូថេ ៣:១៦)។ យើងនឹងយល់អំពីផ្នត់គំនិតដ៏ពិបាកយល់នេះ កាន់តែច្បាស់នៅពេលយើងពិចារណាអំពីការរួបរួមនៃនិស្ស័យជាមនុស្ស និងនិស្ស័យជាព្រះក្នុងព្រះយេស៊ូ និង អំពីសារៈសំខាន់នៃព្រឹត្តិការណ៍ដ៏វិសេសន៍នេះ ។

នៅពេលយើងនិយាយអំពីនិស្ស័យជាមនុស្ស និង និស្ស័យជាព្រះរបស់ព្រះគ្រិស្ត យើងនិយាយសំដៅទៅលើភាពសំខាន់ ឬ តថភាពសំខាន់អំពីទ្រង់។ នៅពេលយើងនិយាយថា ព្រះយេស៊ូមាន *និស្ស័យជាព្រះ* យើងចង់បាននិយាយថា គុណសម្បត្តិ លក្ខណៈ ឬ គុណលក្ខណៈទាំងអស់ដែលមនុស្សម្នាក់អាចនឹងយកទៅប្រើប្រាស់ដើម្បីធៀបរាប់ពីព្រះជាម្ចាស់ធៀបទៅនឹងព្រះអង្គ(ព្រះយេស៊ូ)។ ដូច្នេះ ទ្រង់គឺជាព្រះជាម្ចាស់ មិនត្រឹមដូចព្រះប៉ុណ្ណោះ តែទ្រង់គឺជាអង្គព្រះជាម្ចាស់ផ្ទាល់តែម្តង។

នៅពេលដែលយើងនិយាយថាព្រះយេស៊ូមាន*និស្ស័យជាមនុស្ស* យើងចង់បាននិយាយថា ព្រះយេស៊ូគ្រិស្ត មិនមែនជាព្រះជាម្ចាស់ដែលសម្តែងជាមនុស្សនោះទេ ទ្រង់គឺជាមនុស្សតែម្តង។ ទ្រង់មិនត្រឹមតែជាមនុស្ស ឬ ជាព្រះជាម្ចាស់*ប៉ុណ្ណោះ* នោះទេ ទ្រង់គឺជាព្រះជាម្ចាស់ដែល "កើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា" (គម្ពីរយ៉ូហាន ១:១៤)។ ទ្រង់មិនឈប់ធ្វើជាព្រះជាម្ចាស់នៅពេលដែលទ្រង់ក្លាយជាមនុស្សនោះទេ។ ទ្រង់មិនដោះដូរភាពជាព្រះរបស់ទ្រង់ ជាមួយភាពជាមនុស្សនោះដែរ។ ផ្ទុយទៅ

វិញ ទ្រង់*ចាប់យក*ភាពជាមនុស្ស។ នោះមានន័យថា ទ្រង់បន្ថែមនិស្ស័យជាមនុស្សមួយទៀតទៅលើនិស្ស័យជាព្រះរបស់ទ្រង់។ ដូច្នេះ ដោយសារតែការចាប់បដិសន្ធិនេះហើយ ទ្រង់គឺជាព្រះជាម្ចាស់ផង និង ជាមនុស្សផង យើងហៅថាមនុស្សព្រះក៏បាន។

ព្រះយេស៊ូជាព្រះគ្រិស្តមានគ្រប់ទាំងគុណសម្បត្តិដែលជារបស់មនុស្ស រួមមានខ្លួនប្រាណ និង លក្ខណសម្បត្តិខាងរូបកាយ។ ទោះជាយ៉ាងណា យើងមិនអាចនិយាយថា នៅក្នុងទីជម្រៅរបស់ទ្រង់ ទ្រង់គឺជាមនុស្សម្នាក់នោះទេ។ ទ្រង់គឺជា *ព្រះជាម្ចាស់* ដែលមាននិស្ស័យជាមនុស្ស។ នោះបានន័យថា ទ្រង់មិនដាក់បញ្ចូលបុគ្គលិកលក្ខណៈរបស់មនុស្ស ទៅក្នុងនិស្ស័យរបស់ទ្រង់ផ្ទាល់នោះឡើយ តែផ្ទុយទៅវិញ ទ្រង់បន្ថែមនិស្ស័យជាមនុស្ស ទៅក្នុងបុគ្គលិកលក្ខណៈផ្ទាល់របស់ទ្រង់។ បុគ្គលិកលក្ខណៈជាព្រះជាម្ចាស់របស់ទ្រង់ គឺជាអ្វីដែលនៅទីជម្រៅបំផុត។ ប្រសិនបើទ្រង់មិនមែនជាព្រះជាម្ចាស់នោះទេ ទ្រង់មិនអាចទទួលបានការថ្វាយបង្គំពីយើងបាននោះឡើយ សម្រាប់គ្រិស្តបរិស័ទ គឺត្រូវបានតម្រូវឲ្យថ្វាយបង្គំព្រះជាម្ចាស់តែមួយអង្គគត់។

ដូច្នេះ យើងឃើញថាការចាប់បដិសន្ធិរបស់ព្រះបុត្រា បានរួបរួមភាពជាព្រះជាម្ចាស់ពិត និង ភាពជាមនុស្សដ៏ពិតនៅក្នុងខ្លួនបុគ្គលម្នាក់។ ដូច្នេះ មានការប្រកបនៃគុណសម្បត្តិមួយនៅក្នុងអង្គទ្រង់ដែលយើងអាចនិយាយអំពីទ្រង់តាមរបៀបដែលស័ក្តិសមក្នុងការនិយាយជាមួយព្រះជាម្ចាស់ ឬ មនុស្ស។

លំហាត់អនុវត្តន៍

១០ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលបង្ហាញពីសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទាក់ទងទៅនឹងការចាប់បដិសន្ធិ។

ក) ព្រះយេស៊ូគ្រិស្តគឺជាអង្គព្រះជាម្ចាស់ដែលចាប់យកភាពជាមនុស្ស។

ខ) ព្រះគ្រិស្តគឺជាមនុស្សដែលចាប់យកភាពជាព្រះ។

គ) ដោយសារព្រះយេស៊ូគ្រិស្តជា អង្គព្រះជាម្ចាស់ ទ្រង់ជាព្រះដែលស័ក្តិសមទទួលបានការថ្វាយបង្គំរបស់យើង។

ឃ) ទាក់ទងទៅនឹងនិស្ស័យជាមនុស្សរបស់ទ្រង់ ព្រះយេស៊ូទ្រង់ចេះឃ្លាន ចេះស្រេក ចេះព្រួយបារម្ភ និង ទទួលការឈឺចាប់ ព្រមទាំងការស្លាប់ដូចគ្នា។ ទាក់ទងទៅនឹងនិស្ស័យជាព្រះរបស់ទ្រង់ ទ្រង់តែងតែសព្វព្រះហឫទ័យធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតាជានិច្ច ដ្បិតទ្រង់ពិតជាព្រះជាម្ចាស់។

មូលហេតុនៃការចាប់បដិសន្ធិ

នៅក្នុងស្ថានភាពដែលមានកម្រិតរបស់យើង យើងមិនអាចនឹងយល់ពីមូលហេតុដែលព្រះអម្ចាស់មកចាប់កំណើតជាមនុស្សនោះទេ។ តើអ្វីជាកត្តាជំរុញឲ្យព្រះបុត្រារបស់ព្រះជាម្ចាស់យាងមកលើផែនដីមកក្លាយជាផ្នែកមួយនៃអំបូរដែលបានដួលរលំ និង ត្រូវបានហុំព័ទ្ធដោយក្តីច្រណែន និង ការស្អប់ខ្ពើមយ៉ាងដូច្នេះ?

ដំបូងបំផុត ព្រះជាម្ចាស់មិនអាចសុគតបាននោះទេ។ វាគឺជារឿងចាំបាច់ណាស់ ដែលត្រូវតែមានការបូជាមួយដែលគ្មានទោសកំហុសទាល់តែសោះសម្រាប់អំពើបាប។ ដោយសារមនុស្សជាតិទាំងអស់ មានបាប ព្រះជាម្ចាស់បានយាងមកចាប់កំណើតជាមនុស្សដើម្បី ប្រទានក្នុងបូជាដ៏ឥតខ្ចោះ ដើម្បីបង់លោះសម្រាប់ទោសនៃបាប (គម្ពីរហេប្រឺ ២:៩)។ ទីពីរ តាមរយៈការចាប់បដិសន្ធិ ព្រះយេស៊ូបានបង្ហាញព្រះវរបិតាទៅកាន់មនុស្សជាតិ ឲ្យឃើញពីភាពល្អឥតខ្ចោះគ្មានអ្វីប្រៀបផ្ទឹម និង ភាពស្រស់ស្អាតរបស់ព្រះអង្គ (គម្ពីរយ៉ូហាន ១៤:៧-១១)។ ទីបី តាមរយៈការចាប់កំណើតជាមនុស្ស ព្រះអម្ចាស់នៃយើង បានផ្តល់ឲ្យយើងនូវគំរូមួយដ៏ត្រឹមត្រូវ (គម្ពីរ១ពេត្រុស ២:២១-២៥)។ នៅពេលដែលយើងសិក្សាអំពី របៀបដែលទ្រង់ឆ្លើយតបទៅនឹងស្ថានភាពរបស់មនុស្ស យើងអាចត្រូវបានគេសំគាល់ជាមួយទ្រង់ និងដឹងថាគោលដៅរបស់គ្រិស្តបរិស័ទគឺរស់នៅឲ្យបានដូចជាព្រះគ្រិស្ត (គម្ពីររ៉ូម ៨:២៩)។

ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ទ្រង់នឹងចាត់បញ្ជូនពួកគេឲ្យទៅពេញពិភពលោក តាមរបៀបដែលព្រះវរបិតាបានចាត់បញ្ជូលទ្រង់មកដែរ (គម្ពីរយ៉ូហាន ១៧:១៨; ២០:២១)។ ក្រឹត្យវិន័យនេះ មានភ្ជាប់ជាមួយនឹងការថ្លែងប្រកាសពីការប្រទានសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ ទៅកាន់មនុស្សគ្រប់រូបដែលជឿលើទ្រង់។ នេះគឺជាផ្នែកមួយនៃមហាបេសកម្ម ក្នុងការចេញទៅក្នុងពិភពលោក ហើយធ្វើការចែកចាយដំណឹងល្អទៅកាន់គ្រប់ស្នាព្រះហស្តរបស់ព្រះជាម្ចាស់ទាំងអស់ (គម្ពីរម៉ាកុស ១៦:១៥)។ ព្រះយេស៊ូ គឺជាការប្រទានរបស់ព្រះជាម្ចាស់ មកសម្រាប់សង្គ្រោះយើងរាល់គ្នា។ យើងត្រូវនាំដំណឹងល្អទៅកាន់មនុស្សគ្រប់គ្នា។

លំហាត់អនុវត្តន៍

---

១១ ចូរសរសេរលេខ១ នៅខាងមុខប្រយោគណា ដែលជាមូលហេតុពិត ឬ ត្រឹមត្រូវនៃការចាប់បដិសន្ធិ ។ សរសេរលេខ២ ប្រសិនបើប្រយោគនោះមិនពិត។

.....ក) ព្រះយេស៊ូត្រូវចាប់កំណើតក្នុងរូបកាយដែលរមែងតែស្លាប់ ដើម្បីទ្រង់អាចបង់លោះទោសស្លាប់សម្រាប់បាបរបស់របស់។

.....ខ) ការចាប់បដិសន្ធិ គឺពិតជាចាំបាច់ណាស់ ព្រោះព្រះជាម្ចាស់ត្រូវតែដឹងថា តើការក្លាយខ្លួនជាមនុស្សមានបាបនោះ យ៉ាងណា?

.....គ) តាមរយៈការចាប់បដិសន្ធិ យើងទទួលបានការបង្ហាញឲ្យឃើញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និង ការផ្គត់ផ្គង់សម្រាប់មនុស្សជាតិ។

.....ឃ) ការចាប់បដិសន្ធិ បានផ្តល់ឲ្យព្រះយេស៊ូនូវ បទពិសោធន៍ផ្ទាល់ នៃភាពមានកម្រិត និង ភាពទន់ខ្សោយរបស់មនុស្សជាតិ។ ការនេះបញ្ជាក់ថាទ្រង់មានសិទ្ធិទូលអង្វរជួសយើង ជាមួយនឹងព្រះវរបិតា។

.....ង) ជាលទ្ធផលដែលបានមកពីការចាប់បដិសន្ធិរបស់ទ្រង់ មនុស្សមិនកើតមកនៅក្នុងអំពើបាបទៀតទេ ដ្បិតការបូជានៃបុត្ររបស់ព្រះជាម្ចាស់ ក្នុងសណ្ឋានជាមនុស្សបានធ្វើឲ្យមនុស្សជាតិអស់ទោសកំហុស។

ឃ. រាជកិច្ចរបស់ព្រះគ្រិស្ត

វត្ថុបំណងទី ៥. *បកស្រាយពីមូលហេតុដែលកិច្ចការរបស់ព្រះគ្រិស្ត ជាសារៈសំខាន់សម្រាប់មនុស្សជាតិ។*

ឥឡូវនេះយើងបែរត្រឡប់ទៅមើលពីរាជកិច្ចរបស់ព្រះគ្រិស្តវិញ។ នៅពេលដែលយើងនិយាយអំពី *រាជកិច្ច*របស់ទ្រង់ យើងសំដៅទៅការសុគត ការមានព្រះជន្មរស់ឡើងវិញ ការឡើងទៅស្ថានបរមសុខ និង ការលើកតម្កើង ព្រះគ្រិស្ត។ យើងនឹងពិចារណាអំពីរាជកិច្ចទាំងនេះ ទៅតាមលំដាប់លំដោយដែលរាជកិច្ចទាំងនេះកើតមានឡើង។

ការសុគតរបស់ទ្រង់

ការសុគតរបស់ព្រះយេស៊ូ គឺមានលក្ខណៈខុសគ្នាពីការស្លាប់របស់មនុស្សផ្សេងៗទៀត។ ទីមួយ ការសុគតរបស់ទ្រង់ គឺដោយការស្ម័គ្រព្រះទ័យទាំងស្រុង។ ទ្រង់បានមានព្រះបន្ទូលអំពីការសុគតថា "គ្មាននរណាដកហូតជីវិតរបស់ខ្ញុំបានឡើយ គឺខ្ញុំស៊ូប្តូរជីវិត ដោយខ្លួនខ្ញុំផ្ទាល់តែម្តង។" (គម្ពីរយ៉ូហាន ១០:១៨)។ នៅពេលដែលទ្រង់សុគតទ្រង់បានលះបង់ព្រះវិញ្ញាណរបស់ទ្រង់ (គម្ពីរម៉ាថាយ២៧:៥០)។ ការសុគតនេះមិនធ្វើឡើងដោយមានការបង្ខិតបង្ខំ ពីសាតាំង ឬ ដោយអនុភាពដ៏លើសលប់របស់ពួកទាហានរ៉ូម៉ាំងនោះទេ។ ផ្ទុយវិញ ទ្រង់បានទទួលយកការសុគតនេះ តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីការសង្គ្រោះមនុស្សជាតិវិញ។

ការសុគតរបស់ទ្រង់គឺជារាជកិច្ចមួយ ហើយតាមរយៈការសុគតរបស់ទ្រង់នេះ ព្រះគ្រិស្តបានបង់លោះទោសបាបរបស់យើង។ ទោសនៃអំពើបាប គឺជាការដាច់ចេញពីព្រះជាម្ចាស់។ នេះគឺជាទោសដែលទ្រង់ត្រូវបង់លោះ ដើម្បីការសង្គ្រោះយើង។ នៅពេលដែលទ្រង់សុគតនៅលើឈើឆ្កាង ទ្រង់ទទួលរងការកាត់ផ្តាច់ដ៏អាក្រក់មួយនេះ។ ទ្រង់ស្រែកទូលថា៖ "ឱព្រះនៃទូលបង្គំ ព្រះនៃទូលបង្គំអើយ ហេតុអ្វីបានជាព្រះអង្គបោះបង់ទូលបង្គំចោលដូច្នេះ?" (គម្ពីរម៉ាកុស ១៥:៣៤)។ នៅក្នុងរាជកិច្ចមួយនេះ ទ្រង់រំងាប់ ឬធ្វើឲ្យស្ងប់ ព្រះពិរោធរបស់ព្រះជាម្ចាស់ ដែលបានកើតឡើងដោយសារតែអំពើបាបរបស់យើង។ ទ្រង់បានអនុញ្ញាតិកម្លាំងបោកបក់នៃភាពយុត្តិធម៌ដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ ធ្លាក់មកលើទ្រង់។ តាមរយៈការបូជារបស់ទ្រង់ ព្រះគ្រីស្ទបានធ្វើការរំដោះអំពើបាបរបស់យើង ដោយការសុគតរបស់ព្រះអង្គ ដែលជាការជំនួសការស្លាប់របស់យើង។ទ្រង់ធ្វើយ៉ាងដូច្នេះ ដើម្បីឲ្យយើងទទួលបានការលើកលែងទោស និង អាចផ្សះផ្សាឲ្យបានទៅដល់កន្លែងដែលមានភាពស៊ីចង្វាក់គ្នាជាមួយព្រះជាម្ចាស់។

ជាច្រើនសម័យកាលមកហើយ មនុស្សបានព្យាយាមបង្វែរចេញនូវកំហឹងរបស់ព្រះដែលពួកគេ បានបង្កើតឡើង។ ពួកគេពិតជាគួរឲ្យអាណិតខ្លាំងណាស់។ ពួកគេបានថ្វាយដង្វាយ និង ធ្វើការបូជាឈាម ប៉ុន្តែពួកគេបានចាកចេញទៅទាំងមិនបានដឹងថា ដង្វាយរបស់ពួកគេត្រូវបានព្រះរបស់ពួកគេទទួលបានហើយឬនៅ។ ឧទាហរណ៍ជនជាតិភាគតិច អាហ្សតិច មានការកោតខ្លាចយ៉ាងខ្លាំងចំពោះអ្វីដែលពួកគេគិតថាជាព្រះរបស់ពួកគេ។ ពួកគេថ្វាយមនុស្សជាច្រើនដើម្បីធ្វើជាយញ្ញបូជា នៅពេលដែលពួកគេគិតថាជារឿងចាំបាច់ ប៉ុន្តែអំពើល្អ ដ៏មានតម្លៃ និង ពេញដោយការគោរពនេះ គឺតែងតែឥត

ន័យ។ ការឆ្លើយតបរបស់អាចារ្យពួកគេ នៅតែឆ្លើយតបដដែលថា៖ "ព្រះរបស់យើងទាមទារ ឈាមបន្ថែមទៀត"!

ព្រះគម្ពីរបានបង្ហាញប្រាប់យើងថា ព្រះវរបិតានៃស្ថានបរមសុខរបស់យើង ទ្រង់ពិតជាក្រោធខ្លាំងណាស់ ព្រោះអំពើបាបរបស់យើង ប៉ុន្តែព្រះពិរោធរបស់ទ្រង់គឺមិនដូចជាគំនិតរបស់ជនជាតិអាហ្សតិចដែលគិតអំពីព្រះរបស់ពួកគេឡើយ។ យើងមិនមានភាពភ័យខ្លាច ឬ និស្ស័យទាក់ទងទៅនឹង អ្វីដែលយើងត្រូវធ្វើ ដើម្បីបំបាត់ព្រះពិរោធរបស់ទ្រង់ឡើយ។ ទ្រង់បានធ្វើការនោះដោយអង្គទ្រង់ហើយ។ ទ្រង់បានប្រទានការបូជារបស់ព្រះអង្គផ្ទាល់ គឺព្រះបុត្រារបស់ព្រះអង្គ។ តាមរយៈការសុគតរបស់ទ្រង់ ព្រះយេស៊ូបានបង់លោះទោសកំហុស និង ធ្វើឲ្យអ្វីបានទៅជាល្អប្រសើរវិញ។ ដោយធ្វើយ៉ាងដូច្នេះ សេចក្តីសុចរិតរបស់ព្រះជាម្ចាស់ បានរក្សាទុកនៅ។ អំពើបាបត្រូវបានដោះស្រាយ ទោសកំហុសត្រូវបានបង់លោះ មនុស្សទទួលបានការអត់ទោស ហើយមានសិទ្ធិចូលទៅកាន់ព្រះជាម្ចាស់ដ៏វិសុទ្ធ។ លោកប៉ូលបានបកស្រាយការនេះ នៅក្នុងគម្ពីររ៉ូម៣:២៥-២៦៖

> ព្រះជាម្ចាស់បានតំរូវអោយព្រះយេស៊ូធ្វើជាយញ្ញបូជា សំរាប់លោះអស់អ្នកដែលមានជំនឿ អោយរួចពីបាប ដោយសារព្រះលោហិតរបស់ព្រះអង្គ។ ធ្វើដូច្នេះ ព្រះអង្គបង្ហាញរបៀបដែលព្រះអង្គប្រោសមនុស្សអោយបានសុចរិត គឺពីដើម ព្រះអង្គពុំបានដាក់ទោសមនុស្សលោកដែលប្រព្រឹត្តអំពើបាបក្នុងគ្រាដែលព្រះអង្គមានព្រះហឫទ័យអត់ធ្មត់ដល់គេនោះទេ។ ឥឡូវនេះ ព្រះអង្គសព្វព្រះហឫទ័យបង្ហាញអំពីរបៀបដែលព្រះអង្គប្រោសមនុស្សអោយបានសុចរិត ដើម្បីសំដែងថាព្រះអង្គសុចរិត ហើយទ្រង់ប្រោសអ្នកដែលជឿលើព្រះយេស៊ូអោយបានសុចរិតផងដែរ។

ការសុគតរបស់ព្រះគ្រិស្ត ក៏មានផលប្រយោជន៍ជាក់ស្តែងនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើងដែរ។ នៅក្នុងសំបុត្រមួយរបស់លោកប៉ូល ទៅកាន់ក្រុមជំនុំក្រុងកាឡាទី លោកនិយាយថា៖ "ខ្ញុំបានជាប់ឆ្កាងរួមជាមួយព្រះគ្រិស្ត" (គម្ពីរកាឡាទី២:១៩) ។ "អស់អ្នកដែលរួមជាមួយព្រះគ្រិស្តយេស៊ូបានឆ្កាងតណ្ហា និងបំណងលោភលន់ផ្សេងៗរបស់និស្ស័យលោកីយ៍នោះចោលហើយ។" (គម្ពីរកាឡាទី៥:២៤) ។ ការនេះមានពាក់ព័ន្ធជាមួយនឹងការឆ្កាង*ខ្លួនឯង* ដែលមានន័យថាការលះបង់បំណងចិត្តផ្ទាល់ខ្លួន ដើម្បីបែរទៅធ្វើអ្វីដែលគាប់ព្រះហឫទ័យទ្រង់។ ការជាប់ឆ្កាងរបស់ព្រះគ្រិស្ត ត្រូវក្លាយទៅជាការជាប់ឆ្កាងរបស់យើង។ ការសង្គ្រោះដែលទ្រង់បានប្រទានមក ផ្តល់ឲ្យយើងនូវ ឱកាសដើម្បីរស់នៅក្នុងជីវិតដ៏វិសុទ្ធមួយ ជាជីវិតដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ពិតៗ។ ការនេះនឹងក្លាយទៅជាការពិត នៅពេលយើងថ្វាយជីវិតរបស់យើង ទៅកាន់ភាពជាម្ចាស់របស់ទ្រង់ និង ទៅកាន់ការគ្រប់គ្រងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីររ៉ូម ៨:៥-១១)។

លំហាត់អនុវត្តន៍

១២ តើអ្នកកំពុងធ្វើការដើម្បីសម្លាប់និស្ស័យមានបាបរបស់អ្នកមែនទេ? ចូររៀបរាប់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក អំពីអ្វីដែលអ្នកដទៃអាចឃើញនៅក្នុងអ្នក ដែលបង្ហាញថាអ្នកបានឆ្កាងខ្លួនឯង ហើយបែរទៅផ្តល់ការយកចិត្តទុកដាក់ទៅលើទំនួលខុសត្រូវជាគ្រិស្តបរិស័ទវិញ។

១៣ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខប្រយោគត្រឹមត្រូវ ទាក់ទងនឹងសារៈសំខាន់នៃរាជកិច្ចរបស់ព្រះគ្រិស្តសម្រាប់យើង។

ក) ការសុគតរបស់ទ្រង់បានបង់ថ្លៃជួសអំពើបាបរបស់យើង ហើយបានរំសាយព្រះពិរោធរបស់ព្រះជាម្ចាស់។

ខ) ការសុគតរបស់ព្រះគ្រិស្ត គឺជាលទ្ធផលដែលបានមកពីការបង្ខិតបង្ខំនៃអំណាចដែលលើសពីគ្រប់គ្រងរបស់ទ្រង់ ដូច្នេះហើយ ការសុគតនេះគឺគ្រាន់តែជារឿងចៃដន្យមួយប៉ុណ្ណោះ។

គ) ការសុគតរបស់ព្រះគ្រិស្តបានផ្សះផ្សាសម្ព័ន្ធភាពរវាងព្រះជាម្ចាស់ និង មនុស្សជាតិ។

ឃ) ការសុគតរបស់ទ្រង់បានបំពេញសេចក្តីយុត្តិធម៌របស់ព្រះជាម្ចាស់ ដែលត្រូវបានបែរឆ្ពោះទៅរកអំពើបាបនៃមនុស្សជាតិ។

ង) ដោយព្រោះការសុគតរបស់ព្រះគ្រិស្ត យើងនឹងមិនចាំបាច់ត្រូវឆ្លើយតបទៅនឹងអំពើបាបរបស់យើងទៀតឡើយ ទោះបីជាយើងនៅតែកំពុងបន្តប្រព្រឹត្តិអំពើបាបក៏ដោយ។

ច) ការសុគតរបស់ព្រះគ្រិស្ត គឺជាគំរូមួយនៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការផ្តន្ទាទោសយើង ចំពោះភាពទន់ខ្សោយ និង ភាពបរាជ័យជាមនុស្សរបស់យើង។

ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់

ប្រសិនបើព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៃយើងមិនមានព្រះជន្មរស់ឡើងវិញនោះទេ រាជកិច្ចរបស់ទ្រង់មិនអាចនឹងសម្រេចបាននោះទេ ហើយជំនឿរបស់យើងក៏នឹងមិនមានប្រយោជន៍អ្វីដែរ (គម្ពីរ ១កូរិនថូស ១៥:១៤)។ ព្រឹត្តិការណ៍នេះបានសំគាល់ ពីការសម្រេចនៃរាជកិច្ចរបស់ទ្រង់នៅលើផែនដីនេះ។ ដូច្នេះ ការមានព្រះជន្មរស់របស់ព្រះគ្រិស្ត បានកំណត់ឲ្យគ្រិស្តបរិស័ទដាច់ចេញទាំងស្រុងពីសាសនា និង ជំនឿទាំងឡាយផ្សេងៗទៀត។ គ្មានសាសនាណាផ្សេង អាចនិយាយបានថាផ្នូររបស់ស្ថាបនិកសាសនារបស់ពួកគេនៅទទេនោះទេ។ យើងរាល់គ្នាដែលជាគ្រិស្តបរិស័ទ មិននាំគ្នាទៅប្រមូលផ្តុំនៅកន្លែងផ្នូរសាកសពរបស់ព្រះអម្ចាស់នៃយើងឡើយ ព្រោះទ្រង់មិនគង់នៅក្នុងផ្នូរនោះទេ! យើងសរសើរតម្កើងទ្រង់ទុកជាព្រះអង្គសង្គ្រោះដ៏រស់! ទ្រង់បានឈ្នះសេចក្តីស្លាប់ហើយ! ដោយព្រោះទ្រង់មានព្រះជន្មរស់ យើងបានស្នងជីវិតដ៏អស់កល្បជានិច្ច។

ការមានព្រះជន្មរស់របស់ព្រះគ្រិស្តគឺជា ថ្មគ្រឹះនៃជំនឿរបស់គ្រិស្តបរិស័ទ។ បើគ្មានការមានព្រះជន្មរស់របស់ទ្រង់នោះទេ ការសុគតរបស់ព្រះគ្រិស្តមុខជាគ្មានអត្ថន័យអ្វីឡើយ ដ្បិតការមានព្រះជន្មរស់ បានបង្ហាញពីប្រសិទ្ធិភាពនៃការសុគតរបស់ទ្រង់ និង បានផ្តល់តម្លៃទៅឲ្យការសុគតនោះផង។ ទាក់ទង

ជាមួយនឹងរឿងនេះ លោកប៉ូលមានប្រសាសន៍ថា៖ "ព្រះជាម្ចាស់ប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ ដើម្បីអោយយើងបានសុចរិត" (គម្ពីររ៉ូម៤:២៥)។

មានមូលហេតុជាច្រើន ដែលការមានព្រះជន្មរស់មានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើង។ យើងគប្បីកត់សំគាល់ពីលទ្ធផលពិសេសៗនៃព្រឹត្តិការណ៍នេះ។

១. ការមានព្រះជន្មរស់បង្ហាញថារាជកិច្ចរបស់ព្រះគ្រិស្ត នៃការធ្វើជាអ្នកជំនួសកន្លែងមនុស្សមានបាបត្រូវបានទទួលយក។ យើងអាចទុកចិត្តបានថា ព្រះជាម្ចាស់បានទទួលយកការសុគតជំនួសរបស់ព្រះគ្រិស្ត ព្រោះ ព្រះជាម្ចាស់បានប្រោសទ្រង់ឲ្យមានព្រះជន្មរស់ឡើងវិញ (គម្ពីរកិច្ចការ ២:២៤, ៣២; ៣:១៥; ៤:១០; ៥:៣០)។

២. ការមានព្រះជន្មរស់ បញ្ជាក់ពីភាពជាព្រះរបស់ព្រះអម្ចាស់។ លោកប៉ូលបានប្រកាសនៅក្នុងគម្ពីររ៉ូម១:៤ ថា៖ "តែបើគិតតាមព្រះវិញ្ញាណ ដែលផ្តល់អោយមនុស្សបានវិសុទ្ធ*វិញ ព្រះជាម្ចាស់បានតែងតាំងព្រះអង្គ ជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព ដោយប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ។"

៣. តាមរយៈគុណសម្បត្តិនៃការមានព្រះជន្មរស់របស់ទ្រង់ ព្រះគ្រិស្តបានក្លាយទៅជា *មហាបូជាចារ្យដ៏ខ្ពង់ខ្ពស់របស់យើង* នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ (គម្ពីរហេប្រឺ ៩:២៤)។ ទ្រង់គឺជាអ្នកសម្រុះសម្រួលរបស់យើង (គម្ពីររ៉ូម ៨:៣៤) ជាអ្នកផ្លូវការរបស់យើងនៅឯស្ថានបរមសុខ (គម្ពីរអេភេសូ ១:២០-២២) ជាអ្នកសម្របសម្រួលរបស់យើង (គម្ពីរ១ធីម៉ូថេ ២:៥) និង អ្នកនិយាយជួស ឬ មេធាវីរបស់យើង (គម្ពីរ១យ៉ូហាន ២:១) ។ ដូច្នេះ បន្ថែមពីលើការប្រោសលោះ ឲ្យផុតពីចំណងទោស ដែលធ្វើឡើងតាមរយៈការសុគតរបស់ទ្រង់ ព្រះគ្រិស្តបានចូលមកទូលអង្វរជួសយើង នៅចំពោះព្រះរាជបល្ល័ង្កនៃព្រះគុណ។

៤. ការមានព្រះជន្មរស់ បង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ នៅក្នុងការប្រទានការសង្គ្រោះសម្រាប់យើង។ យើងអាចប្រាកដក្នុងចិត្តថា ទ្រង់នឹងផ្គត់ផ្គង់ឲ្យយើងមានអំណាចដែលសមស្របដើម្បីឲ្យយើងមានជីវិតរស់ និង បម្រើទ្រង់យ៉ាងមានប្រសិទ្ធិភាព (ចូរប្រៀបធៀបគម្ពីរភីលីព ៣:១០ ជាមួយនឹងគម្ពីរភីលីព ១:៦)។ ទ្រង់មានឫទ្ធានុភាពគ្រប់ទាំងអស់។

៥. ការមានព្រះជន្មរស់គឺជាការធានា ថាអស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញ(គម្ពីរយ៉ូហាន ៥:២៨; ៦:៤០គម្ពីររ៉ូម ៨:១១ គម្ពីរ១កូរិនថូស ១៥:២០-២៣ គម្ពីរ១ថេស្សាឡូនិក៤:១៤)។

ដូច្នេះ ការមានព្រះជន្មរស់ បាននាំឲ្យបេសកម្មនៃការសង្គ្រោះរបស់ព្រះជាម្ចាស់បានបញ្ចប់ទៅយ៉ាងសមស្រប។ បេសកកម្មនេះត្រូវបានរៀបចំផែនការតាំងពីដើមមកហើយ ប៉ុន្តែត្រូវបានអនុវត្តនៅពេលដែលព្រះជាម្ចាស់ពុះផ្តាច់ច្រវ៉ាក់នៃអត្ថិភាពជាមនុស្ស តាមរយៈការចាប់បដិសន្ធិ។ ព្រះគ្រិស្តបានរស់នៅក្នុងជីវិតល្អឥតខ្ចោះ ហើយទ្រង់បានសុគតជាអ្នកជំនួសដ៏ល្អឥតខ្ចោះសម្រាប់មនុស្សបាប ហើយបានបង់លោះទោសបាបរបស់ពួកគេផងដែរ។ ដោយធ្វើយ៉ាងដូច្នេះ ទ្រង់បានពន្លត់ព្រះពិរោធរបស់ព្រះជាម្ចាស់ ផ្សះផ្សាអ្នកមានបាបជាមួយព្រះជាម្ចាស់ និង ស្រោចស្រង់សមត្ថភាពរបស់ពួកគេក្នុងការឆ្លើយតបជាមួយព្រះ

វិញ្ញាណដ៏វិសុទ្ធ។ បន្ទាប់មក រាជកិច្ចរបស់ព្រះគ្រិស្តនៅលើផែនដីបានសម្រេច ហើយក៏ដល់ពេលដែលទ្រង់ត្រូវត្រឡប់ទៅឯព្រះវរបិតាវិញដែរ ។ បេសកកម្មរបស់ទ្រង់បានសម្រេចយ៉ាងជោគជ័យ!

លំហាត់អនុវត្តន៍

១៤ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខប្រយោគដែលនិយាយពីលទ្ធផលដ៏ពិតប្រាកដនៃការមានព្រះជន្មរស់ឡើងវិញ។

ក) ការមានព្រះជន្មរស់ឡើងវិញ បានធ្វើឲ្យគ្រិស្តសាសនា ជាសាសនាមួយនៅក្នុងចំណោមសាសនានានាដែលមានស្តាបនិកបានត្រឡប់មកមានជីវិតរស់ឡើងវិញ។

ខ) ការមានព្រះជន្មរស់ឡើងវិញ បង្ហាញពីការទទួលយករបស់ព្រះជាម្ចាស់ នូវការបូជារបស់ព្រះគ្រិស្តទុកជាការលុបលាងទោសសម្រាប់បាបរបស់មនុស្សជាតិ។

គ) ភាពជាព្រះរបស់ព្រះអម្ចាស់នៃយើង បានបញ្ជាក់ដោយការមានព្រះជន្មរស់របស់ទ្រង់។

ឃ) តាមរយៈការមានព្រះជន្មរស់របស់ទ្រង់ ព្រះគ្រិស្តបានក្លាយជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់ ដែលជួយទូលអង្វរជំនួសយើងនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់។

ង) ការមានព្រះជន្មរស់ធានា ថាគ្រិស្តបរិស័ទមិនអាចនឹងធ្លាក់ចេញពីព្រះទ័យមេត្តារបស់ព្រះជាម្ចាស់បានឡើយ។

ច) ការមានព្រះជន្មរស់គឺជាការធានាសម្រាប់អ្នកជឿថា អស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្ត នឹងត្រូវបានប្រោសឲ្យមានជីវិត នៅថ្ងៃទ្រង់យាងត្រឡប់មកវិញ។

ការលើកឡើងទៅ និង ការលើកតម្កើងរបស់ទ្រង់

កំណត់ត្រានៅក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី បង្ហាញថា បន្ទាប់ពីធ្វើបេសកកម្មបាន៤០ថ្ងៃ ក្រោយពេលមានព្រះជន្មរស់ឡើងវិញហើយ ព្រះគ្រិស្តត្រូវលើកឡើង ឬ ត្រឡប់ទៅឯស្ថានបរមសុខវិញ៖ "នៅពេលដែលក្រុមសាវ័កកំពុងតែមើលព្រះអង្គ នោះព្រះជាម្ចាស់ក៏លើកព្រះអង្គឡើងទៅលើមេឃ ព្រមទាំងមានពពក*មកបាំងព្រះអង្គបាត់ពីភ្នែកគេទៅ" (គម្ពីរកិច្ចការ ១:៩)។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត និង ការលើកទ្រង់ឡើង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនៅក្នុងការអធិប្បាយរបស់ពួកសាវ័ក (គម្ពីរកិច្ចការ ២:៣២-៣៥ គម្ពីរអេភេសូ ១:២០ គម្ពីរ១ពេត្រុស៣:២១-២២)។ ព្រឹត្តិការណ៍ទាំងពីរនេះ គឺជាចំណុចចាប់ផ្តើមនៃការលើកតម្កើងព្រះអម្ចាស់របស់យើងដែលត្រូវបានគេឆ្លាង ។

ពាក្យថា *ការលើកឡើងទៅ* គឺនិយាយអំពីព្រឹត្តិការណ៍ ដែលព្រះយេស៊ូបានត្រឡប់ទៅឯស្ថានបរមសុខវិញ។ ពាក្យថា *លើកតម្កើង* និយាយអំពីការ *"លើកឡើង"* "លើកឡើងដល់កម្រិតដ៏ខ្ពស់មួយ"។ ព្រះយេស៊ូត្រូវលើកឡើងដល់ឋានៈដ៏មានកិត្តិយស និង សិរីរុងរឿង នៅព្រះហស្តស្តាំរបស់ព្រះវរបិតា។នៅក្នុងការលើកឡើងទៅនគរស្ថានសួគ៌របស់ទ្រង់ ព្រះគ្រិស្តបានទទួលតំណែងស័ក្តិសមជាព្រះរាជាដែលគ្រងរាជ្យ (គម្ពីរកិច្ចការ ២:៣៣-៣៦; ៥:៣១ គម្ពីរអេភេសូ ១:១៩-២៣ គម្ពីរហេប្រឺ ២:១៤-១៨ ៤:១៤-១៦)។

ឋានៈដ៏ខ្ពង់ខ្ពស់នេះ មានក្លាយជាផលប្រយោជន៍ដ៏អស្ចារ្យសម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ដែលមានផលប្រយោជន៍ខ្លះយើងគួរតែកត់ចំណាំទុក៖

១. ឥឡូវនេះពេលដែលទ្រង់នៅឯនគរស្ថានសួគ៌ ព្រះយេស៊ូខាងឯវិញ្ញាណគង់នៅគ្រប់ទីកន្លែង នៅពេញសាកលលោកទាំងមូល (គម្ពីរអេភេសូ ៤:១០)។ ដូច្នេះទ្រង់សក្តិសមនឹងទទួលបានការថ្វាយបង្គំសម្រាប់មនុស្សគ្រប់ទាំងអស់ (គម្ពីរ១កូរិនថូស ១:២)។

២. ព្រះយេស៊ូបានយាងចូលទៅក្នុងព័ន្ធកិច្ចជាបូជាចារ្យរបស់ទ្រង់នៅស្ថានបរមសុខ ដូចដែលយើងបានបកស្រាយរួចមកហើយ (គម្ពីរហេប្រឺ ៤:១៤; ៥:៥-១០)។

៣. ទ្រង់បានប្រទានអំណោយទានមកឲ្យប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរអេភេសូ ៤:៨-១១)។ អំណោយទាននេះរាប់បញ្ចូលទាំងអំណោយទានសម្រាប់បុគ្គលម្នាក់ៗ (គម្ពីរ១កូរិនថូស ១២:៤-១១) និង អំណោយទានសម្រាប់ក្រុមជំនុំផងដែរ (គម្ពីរអេភេសូ ៤:៨ -១៣)។

៤. ទ្រង់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់មកលើប្រជារាស្ត្ររបស់ទ្រង់ (គម្ពីរកិច្ចការ ២:៣៣)

៥. ក្នុងនាមជាព្រះរាជបុត្រា និង ជាព្រះសង្គ្រោះដែលគេលើកតម្កើង ទ្រង់បានប្រទានការកែប្រែចិត្ត និងជំនឿទៅដល់មនុស្ស (គម្ពីរកិច្ចការ ៥:៣១; ១១:១៨ គម្ពីរ២ពេត្រុស ១:១)។

៦. ព្រះអម្ចាស់ដែលត្រូវបានលើកឡើងទៅនគរស្ថានសួគ៌ និង ត្រូវបានគេលើកតម្កើង ទ្រង់នឹងយាងទៅនគរស្ថានសួគ៌ក្នុងភាពជាមនុស្សរបស់ទ្រង់ (ព្រះកាយដ៏មានសិរីរុងរឿងរបស់ទ្រង់)។ គំនិតនេះបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងលិខិតទៅកាន់សាសន៍ហេប្រឺ ដែលក្នុងនោះអ្នកនិពន្ធបានប្រកាសថា ដោយសារតែព្រះយេស៊ូបានឆ្លងកាត់បទពិសោធន៍ជាមនុស្ស ទ្រង់អាចក្លាយជាបូជាចារ្យដ៏ខ្ពស់ខ្ពស់ប្រកបដោយព្រះហឫទ័យមេត្តា និង ភាពស្មោះត្រង់ (គម្ពីរហេប្រឺ ២:១៤-១៨; ៤:១៤-១៦)។ នេះគឺជាប្រភពកម្លាំង និង ការកំសាន្តចិត្តដ៏អស្ចារ្យមួយ។

លំហាត់អនុវត្តន៍

---

១៥ ចូរសរសេរនិយមន័យនៃពាក្យ *ការលើកឡើង* និង *ការលើកតម្កើង* ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

១៦ នៅក្នុងលំហាត់នេះ ចូរសរសេរលេខ ១ នៅខាងមុខប្រយោគដែលបង្ហាញពីលទ្ធផលនៃរាជកិច្ចរបស់ព្រះគ្រិស្តយ៉ាងត្រឹមត្រូវ ហើយសរសេរលេខ២ នៅខាងមុខប្រយោគណាដែលបង្ហាញមិនបានត្រឹមត្រូវ។

.....ក) ព្រះគ្រិស្តបានបំពេញសាកលលោកនេះ ដូច្នេះហើយទ្រង់គឺជាព្រះដែលសមទទួលការថ្វាយបង្គំរបស់មនុស្សទាំងអស់។

.....ខ) ព្រះគ្រិស្តបានបញ្ចប់កិច្ចការរបស់ទ្រង់សម្រាប់មនុស្សរួចហើយ ហើយទ្រង់លែងចូលទៅពាក់ព័ន្ធនឹងជីវិតខាងឯវិញ្ញាណរបស់ពួកគេទៀតហើយ។

.....គ) ព្រះគ្រិស្តបានយាងចូលទៅកាន់តំណែងជាបូជាចារ្យដ៏ខ្ពង់ខ្ពស់ សម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់។

.....ឃ) ព្រះគ្រិស្តប្រទានអំណោយទាន ទៅដល់បុគ្គលអ្នកជឿម្នាក់ៗ និងទៅដល់ក្រុមជំនុំទាំងមូល។

.....ង) ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានចាក់បង្ហូរមកលើអ្នកជឿ។

.....ច) ការសុគតរបស់ព្រះគ្រិស្ត បានបង់ថ្លៃលោះទោសបាប និង រំសាយព្រះពិរោធរបស់ព្រះជាម្ចាស់។

.....ឆ) ការសុគតរបស់ព្រះគ្រិស្ត បានស្តារទំនាក់ទំនងយ៉ាងពេញលេញរវាងព្រះជាម្ចាស់ និង មនុស្សជាតិ។

.....ជ) អ្នកជឿមិនចាំបាច់ត្រូវអភិវឌ្ឍជីវិតខាងឯវិញ្ញាណរបស់ពួកគេតទៅទៀតនោះទេ ដោយសារតែព្រះយេស៊ូបានធ្វើការទាំងនោះអស់ហើយ។

.....ឈ) ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺជាការធានាសម្រាប់អ្នកជឿ ថា អស់អ្នកដែលស្លាប់នៅក្នុងព្រះគ្រិស្ត នឹងត្រូវប្រោសឲ្យរស់ពីស្លាប់ឡើងវិញ។

យើងអាចឃើញថារាជកិច្ចទាំងអស់របស់ព្រះគ្រិស្តសុទ្ធតែមានអត្ថន័យយ៉ាងអស្ចារ្យសម្រាប់យើង។ តាមរយៈការសុគតរបស់ទ្រង់ ទ្រង់បានបង់ថ្លៃសម្រាប់ទោសបាបរបស់យើង។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ផ្តល់ឲ្យយើងនូវការធានាថាមានជីវិតអស់កល្បជានិច្ចជាមួយទ្រង់។ តាមរយៈការលើកឡើងទៅឯស្ថានបរមសុខ និង ការលើកតម្កើងទ្រង់ ទ្រង់ត្រូវបានលើកឡើងឲ្យសមនឹងឋានៈរបស់ទ្រង់ជាព្រះអធិបតីនៃព្រះអម្ចាស់របស់យើងរាល់គ្នា។ ពេលនេះទ្រង់កសាង និង ថែរក្សាក្រុមជំនុំ ហើយប្រទានអ្វីៗដែលចាំបាច់ដើម្បីនាំឲ្យយើងបានពេញវ័យខាងឯវិញ្ញាណ។

ការប្រឡងផ្ទាល់ខ្លួន

១ តើចម្លើយណាមួយនៅខាងក្រោមនេះ ជាភស្តុតាងអំពីភាពជាមនុស្សរបស់ព្រះគ្រិស្ត ដូចដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ?

ក) ដៃនកំណត់របស់មនុស្ស និង ព្រះនាមជាមនុស្សរបស់ទ្រង់

ខ) មានបុព្វបុរសជាមនុស្ស

គ) មានពេញដោយបាបដូចមនុស្ស

ឃ) សណ្ឋាន និង ការលូតលាស់ជាមនុស្ស

២ ភស្តុតាងនៅក្នុងព្រះគម្ពីរ សម្រាប់ភាពជាព្រះរបស់ព្រះយេស៊ូគ្រិស្តបង្ហាញថា

ក) ទ្រង់បានប្រើប្រាស់សិទ្ធិជាព្រះរបស់ទ្រង់ទាំងអស់ជាប្រចាំ។

ខ) អាកប្បកិរិយារបស់ទ្រង់ ការអះអាងរបស់ទ្រង់ និង គុណសម្បត្តិរបស់ទ្រង់បង្ហាញថា ទ្រង់លើសពីមនុស្សធម្មតា។

គ) ភស្តុតាងគឺស្ថិតនៅត្រឹមការអះអាងផ្ទាល់របស់ទ្រង់ និង ទីបន្ទាល់នៃមិត្តភក្តិរបស់ទ្រង់។

៣ តើប្រយោគណាមួយនៅខាងក្រោមនេះ ឆ្លុះបញ្ចាំងយ៉ាងសុក្រិតជាងគេអំពីគោលលទ្ធិគ្រិស្តបរិស័ទទាក់ទងនឹងលក្ខណៈនៃការចាប់បដិសន្ធិរបស់ព្រះយេស៊ូ? ព្រះអម្ចាស់យេស៊ូគ្រិស្ត

ក) គឺជាព្រះជាម្ចាស់ដែលក្លែងធ្វើជាមនុស្ស។

ខ) មាននិស្ស័យជាមនុស្ស។

គ) មាននិស្ស័យជាព្រះជាម្ចាស់។

ឃ) ពិតជាព្រះជាម្ចាស់ ហើយពិតជាមនុស្ស។

៤ បទគម្ពីរបង្ហាញមកកាន់យើងថាព្រះយេស៊ូគ្រិស្ត

ក) គឺជាមនុស្សម្នាក់ដែលចាប់យកភាពជាព្រះ។

ខ) គឺជាអង្គព្រះជាម្ចាស់ដែលចាប់យកភាពជាមនុស្ស។

គ) មានគុណសម្បត្តិខ្លះ ដែលជាគុណសម្បត្តិរបស់មនុស្ស។

ឃ) មានគុណសម្បត្តិខ្លះ ដែលជាគុណសម្បត្តិរបស់ព្រះជាម្ចាស់។

៥ គោលបំណងដ៏ធំបំផុតនៃការចាប់បដិសន្ធិគឺ

ក) ដើម្បីជំរុញឲ្យផែនការនៃការប្រោសលោះមនុស្សជាតិរបស់ព្រះជាម្ចាស់មានដំណើរការ។

ខ) ដើម្បីបញ្ចប់អំណាចគ្រប់គ្រងនៃច្បាប់ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់។

គ) ដើម្បីសម្រេចឲ្យបាននូវគំរូសីលធម៌មួយសម្រាប់ឲ្យមនុស្សជាតិដើរតាម។

ឃ) ដើម្បីឲ្យមនុស្សបានស្គាល់ពីព្រះជាម្ចាស់។

៦ ការសុគតរបស់ព្រះគ្រិស្តត្រូវបានចាត់ទុកថាជារាជកិច្ចមួយ ព្រោះការសុគតនោះ

ក) គឺជាកិច្ចការដែលទ្រង់សព្វព្រះទ័យទទួលយក ដើម្បីបង់លោះទោសបាបរបស់យើង។

ខ) គឺមានជាប់ទាក់ទងនឹងការលះបង់ខាងឯរូបកាយ ក៏ដូចជាការធ្វើទុក្ខបុកម្នេញ និង ការស្លាប់ផងដែរ។

គ) គឺជាការបង្ខំលើទ្រង់។

៧ ការចាប់បដិសន្ធិគឺចាំបាច់ណាស់ ព្រោះ

ក) ព្រះគ្រិស្តត្រូវចាប់យករូបកាយជាមនុស្សដែលអាចស្លាប់ ដើម្បីទ្រង់អាចបង់លះទោសបាបរបស់យើងរាល់គ្នា។

ខ) ការនេះបានបង្ហាញ ពីព្រះវរបិតានៃស្ថានបរមសុខទៅចំពោះមនុស្ស។

គ) នៅក្នុងការចាប់បដិសន្ធិនេះ ព្រះជាម្ចាស់បានជ្រាបពីជម្រៅបាប និង ជ្រាបថាជាមនុស្សមានបាបមានន័យយ៉ាងណា។

ឃ) នៅក្នុងការចាប់ដិសន្ធិនេះ ព្រះគ្រិស្តបានប្រទានឲ្យយើងនូវគំរូមួយយ៉ាងល្អ។

៨ សារៈសំខាន់ដ៏ជាក់ស្តែងមួយ នៃការសុគតរបស់ព្រះគ្រិស្ត គឺមានជាប់ទាក់ទងជាមួយនឹងការឆ្លាងភាពជាខ្លួនឯង។ នេះមានន័យថា អស់អ្នកដែលនៅជាប់ជាមួយនឹងព្រះគ្រិស្តត្រូវ

ក) ឆ្លងកាត់ការស្លាប់ដោយសារបាបរបស់ខ្លួនឯងដោយផ្ទាល់។

ខ) សម្លាប់និស្ស័យបាបរបស់ពួកគេ ព្រោះការសង្គ្រោះអនុញ្ញាតឲ្យពួកគេអាចរស់នៅក្នុងជីវិតដ៏វិសុទ្ធមួយបាន។

គ) ដឹងថា តាមរយៈការសុគតរបស់ព្រះគ្រិស្ត ទ្រង់បានដកចេញនិស្ស័យបាបរបស់ពួកគេ ដើម្បីឲ្យពួកគេបានទៅជាវិសុទ្ធពេញលេញ។

៩ រាជកិច្ចនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត គឺមានសារៈសំខាន់ណាស់ ព្រោះ

ក) រាជកិច្ចនេះបង្ហាញពីការទទួលយករបស់ព្រះវរបិតា នូវការបូជារបស់ព្រះគ្រិស្ត ថាជាការទូលអង្វរជំនួសបាបរបស់មនុស្ស។

ខ) រាជកិច្ចនេះបញ្ជាក់ពីភាពជាព្រះរបស់ព្រះអម្ចាស់នៃយើង។

គ) រាជកិច្ចនេះធានាថា គ្រិស្តបរិស័ទមិនអាចធ្លាក់ចេញពីការគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានឡើយ។

ឃ) ព្រះគ្រិស្តគឺជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់របស់យើងដែល ចាំទូលអង្វរជំនួសយើងនៅក្នុងព្រះវត្តមានរបស់ព្រះវរបិតា។

ង) រាជកិច្ចនេះជាការធានាសម្រាប់គ្រិស្តបរិស័ទ ថាពួកគេនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញនៅពេលព្រះគ្រិស្តយាងត្រឡប់មកវិញ។

១០ ការលើកឡើងទៅស្ថានបរមសុខ និង ការលើកតម្កើង ព្រះអម្ចាស់នៃយើង គឺជាការសំខាន់ ព្រោះព្រឹត្តិការណ៍ទាំងអស់នេះ បាននាំមកនូវ

ក) ផ្នែកថ្មីនៃព័ន្ធកិច្ចរបស់ព្រះគ្រិស្ត៖ ក្នុងនាមជាព្រះអធិបតី ទ្រង់ថែទាំ និង កសាងក្រុមជំនុំ ហើយព្រះវត្តមានរបស់ទ្រង់គឺមាននៅគ្រប់ទីកន្លែងទាំងអស់។

ខ) ទីបញ្ចប់នៃរាជកិច្ចរបស់ព្រះគ្រិស្តសម្រាប់មនុស្សជាតិ។

គ) ការចាប់ផ្តើមនៃការថ្វាយបង្គំដោយវិញ្ញាណដ៏ពិត។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ លើកលែងតែចម្លើយ ឃ)។

១ អ្នកត្រូវជ្រើសរើសចម្លើយ សតិបញ្ញា រូបកាយ វិញ្ញាណ និង សង្គម។ ព្រោះព្រះយេស៊ូ បានអភិវឌ្ឍទៅលើផ្លូវទាំងអស់នេះ។

១០ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

២ ក) និង ខ) ជាចម្លើយត្រឹមត្រូវ។

១១ ក) គ) និង ឃ) គឺជាមូលហេតុដ៏សំខ្លាំងសម។

៣ ក) ៤)ដែនកំណត់ជាមនុស្ស
ខ) ៥)ព្រះនាមជាមនុស្ស
គ) ១)បុព្វបុរសជាមនុស្ស
ឃ) ៣)សណ្ឋានជាមនុស្ស
ង) ២)ការអភិវឌ្ឍន៍ជាមនុស្ស

១២ ចម្លើយផ្ទាល់ខ្លួនរបស់អ្នក។ យើងត្រូវធ្វើរឿងនេះជាប្រចាំថ្ងៃ។

៤ ទ្រង់ទទួលយកការថ្វាយបង្គំរបស់មនុស្ស ទ្រង់អត់ទោសបាប ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយទ្រង់ទទួលបានសិទ្ធិក្នុងការវិនិច្ឆ័យទោស របស់គ្រប់ទាំងអស់។

១៣ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

៥ ទ្រង់បង្ហាញពីភាពវិសុទ្ធរបស់ទ្រង់ ដោយការមិនប្រព្រឹត្តិបាបសោះ។ ទ្រង់បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ដោយ ការដាក់ខ្លួន ការបម្រើ និង ភាពទន់ភ្លន់របស់ទ្រង់ និងដោយទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ព្រះវរបិតា និង តាមរបៀបច្រើនផ្សេងទៀត។

១៤ ចម្លើយទាំងអស់សុទ្ធតែជាចម្លើយត្រឹមត្រូវ លើកលែងចម្លើយ ក) និង ង)

៦ ទ្រង់បានជ្រើសរើស ដាក់អង្គទ្រង់នៅក្នុងដែនកំណត់របស់មនុស្ស ដើម្បីឲ្យទ្រង់អាចបំពេញបេសកកម្មរបស់ទ្រង់ ក្នុងការសុគតជួសមនុស្សជាតិដែលពេញដោយបាប។

១៥ *ការលើកឡើង* សំដៅទៅលើព្រឹត្តិការណ៍ដែលព្រះគ្រិស្តយាងត្រឡប់ទៅនគរឋានសួគ៌វិញ ក្នុងព្រះកាយប្រកបដោយសិរីរុងរឿងរបស់ទ្រង់។ *ការលើកតម្កើង* សំដៅទៅលើការដែលព្រះយេស៊ូត្រូវបានគេលើកតម្កើង សមនឹងឋានៈដ៏មានកិត្តិយស និង សិរីរុងរឿង នៅឯព្រះហស្តស្តាំរបស់ព្រះវរបិតា។

៧ *គុណលក្ខណៈខាងសីលធម៌របស់ព្រះយេស៊ូ* ភាពវិសុទ្ធ និង សេចក្តីស្រឡាញ់របស់ទ្រង់។ *គុណលក្ខណៈពីធម្មជាតិរបស់ព្រះយេស៊ូ* ព្រះប្រាជ្ញាញាណ សព្វានុភាព សព្វញ្ញុតញ្ញាណ សព្វដ្ឋភាព និង ភាពអស់កល្បជានិច្ចរបស់ទ្រង់។ ការប្រៀបធៀប បង្ហាញឲ្យឃើញថាទាំងនេះសុទ្ធតែជាគុណលក្ខណៈរបស់ព្រះជាម្ចាស់។

១៦ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ លើកលែងតែចម្លើយ ខ) និង ជ)

៨ ក) ព្រះបន្ទូល (គម្ពីរយ៉ូហាន ១:១៤)

ខ) បុត្រារបស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១០:៣៦)

គ) ព្រះមេស្ស៊ី ព្រះគ្រិស្ត អ្នកដែលគេចាក់ប្រេងអភិសេក (គម្ពីរកិច្ចការ ២:៣៦)

ឃ) អេម៉ាញូអែល (គម្ពីរអេសាយ ៧:១៤)

ង) ព្រះអម្ចាស់ (គម្ពីរលូកា ២:១១)

មេរៀនទី ៤ ព្រះវិញ្ញាណដ៏វិសុទ្ធ៖ អ្នកគ្រប់គ្រងដែលប្រកបដោយប្រាជ្ញាញាណ

តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ពួកអ្នកដើរតាមទ្រង់ថា "បើខ្ញុំទៅ ទើបមានប្រយោជន៍ដល់អ្នករាល់គ្នា" (គម្ពីរយ៉ូហាន ១៦:៧)? មូលហេតុគឺដោយសារតែទ្រង់ត្រូវបានស្ថិតនៅក្នុងដែនកំណត់នៃភាពជាមនុស្ស ហើយអាចគង់នៅបានតែមួយកន្លែងក្នុងពេលតែមួយប៉ុណ្ណោះ។ ទោះជាយ៉ាងណា ទ្រង់បានជ្រាបថា នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកជំនួសទ្រង់ នោះនឹងគ្មានដែនកំណត់ទៅលើពេលវេលាដែលទ្រង់អាចគង់នៅបាន ឬ ទៅលើកិច្ចការដែលទ្រង់អាចធ្វើបាននោះទេ។

ដូច្នេះ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះជាម្ចាស់មិនត្រឹមតែដាក់ការងារមួយឲ្យយើងនោះទេ ប៉ុន្តែទ្រង់ក៏គង់នៅជាមួយយើង និង អនុញ្ញាតឲ្យយើងអាចសម្រេចការងារនោះបានផងដែរ។ លើសពីនេះទៅទៀត ទ្រង់បានសង់ដំណាក់ទ្រង់នៅក្នុងយើងរាល់គ្នា និង ប្រទានការនាំផ្លូវដោយផ្ទាល់ សម្ព័ន្ធភាព ការកំសាន្តចិត្ត និងការផ្តល់អំណាចសម្រាប់តម្រូវការខាងឯវិញ្ញាណរបស់យើងផងដែរ។

នៅក្នុងមេរៀនមុនៗ យើងបានឃើញថាការខ្វល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះការប្រោសលោះមនុស្ស ។ នៅក្នុងមេរៀនរបស់យើងមុននេះ យើងបានឃើញថា ព្រះគ្រិស្តស្រឡាញ់មនុស្សគ្រប់រូបខ្លាំងណាស់ បានជាទ្រង់បន្ទាបខ្លួនយ៉ាងទាប មកក្លាយជាមនុស្សម្នាក់។ ឥឡូវនេះនៅពេលដែលយើងបង្វែរការយកចិត្តទុកដាក់របស់យើងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធវិញ យើងសង្កេតឃើញ សេចក្តីស្រឡាញ់ដូចគ្នានេះ សម្រាប់មនុស្សជាតិ និង ឃើញពីគុណសម្បត្តិ និង បុគ្គលិកលក្ខណៈដ៏អស្ចារ្យដូចគ្នាដែរ។

នៅពេលអ្នកសិក្សាមេរៀននេះ ខ្ញុំសូមអធិស្ឋានសូមឲ្យមានឥទ្ធិពលយ៉ាងពេញលេញនៃអង្គព្រះវិញ្ញាណដ៏វិសុទ្ធ និង កិច្ចការរបស់ទ្រង់បានបង្ហូរមកលើអ្នកជាមួយនឹងអត្ថន័យដ៏អស្ចារ្យជាងពេលមុនៗទៅទៀត។ នៅពេលដែលការនេះកើតឡើង ទំនាក់ទំនងផ្ទាល់របស់អ្នកជាមួយទ្រង់ នឹងបានអភិវឌ្ឍន៍ និង បានឆ្លុះបញ្ចាំងនៅក្នុងព័ន្ធកិច្ចរបស់អ្នកទៅចំពោះអ្នកដទៃ (គម្ពីរ២កូរិនថូស ៣:១៨)។

គម្រោងមេរៀន

ក. ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ
ខ. បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ
គ. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ស្គាល់ពីលក្ខណសម្បត្តិនៃភាពជាព្រះ ដែលត្រូវបាននិយាយថាជាលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
២. ស្គាល់ពីផ្នែកសំខាន់នៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
៣. ផលឧទាហរណ៍អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើចំពោះពិភពអ្នកមិនជឿ ធ្វើចំពោះបុគ្គលអ្នកជឿម្នាក់ និង ក្រុមជំនុំទាំងមូល។
៤. បកស្រាយរបៀបប្រាំមួយយ៉ាងដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ។
៥. ស្គាល់ពីពាក្យផ្សេងៗទាក់ទងនឹងការជ្រមុជនឹងព្រះវិញ្ញាណ។
៦. ប្រាប់ពីរបៀបដែលអ្នកអាចយក ផ្នត់គំនិតដែលនិមិត្តសញ្ញានីមួយនៃវិញ្ញាណតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានប្រសើរជាងមុន។
៧. រៀបរាប់ពីការផ្តល់អំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ការបម្រើ និង ការឆ្លើយតបរបស់អ្នកជឿទៅនឹងការផ្តល់អំណាចនេះ។

សកម្មភាពនៅក្នុងការសិក្សា

១. ដើរតាមនិតិវិធីមេរៀន ដែលបង្ហាញហើយនៅក្នុងមេរៀនទី១។ វាគឺជារឿងសំខាន់ណាស់ដែលអ្នកបើកព្រះគម្ពីររបស់អ្នក ហើយអានខគម្ពីរទាំងអស់ ដែលមេរៀនបានផ្តល់ជូន ដ្បិតខគម្ពីរទាំងនោះគឺមានសារៈសំខាន់ ក្នុងការស្វែងយល់អំពីមេរៀន។
២. ធ្វើការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។
៣. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូរអំពុកមេរៀនទី១ ដល់ ទី៤ (ជំពូកទីមួយ)។ បន្ទាប់មកចូរធ្វើ*ការប្រឡងជំពូកទីមួយ*។

ពាក្យសំខាន់

ស្មាក្តី	ស្មើភាពគ្នា	សក្តានុពល
លក្ខណៈរបស់	ការបំភ្លឺ	ដាក់បញ្ញត្តិ
អំពើកាមគុណ	ការជ្រមុជ	ការបង្កើតឡើងវិញ
គ្រឿងបណ្តុំ	អ្នកបកប្រែ	ឆ្អែត ផ្សើមជោក
ចូលរួម	ការលើកទឹកចិត្ត	វេទយិតភាព
ការអនុញ្ញាត	ដើមកំណើត	មិនស៊ីជម្រៅ
ការបំភ្លឺឲ្យច្បាស់	ពហុភាព	

ក. ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

នៅក្នុងការពិចារណារបស់យើងអំពីនិស្ស័យរបស់ព្រះនៅក្នុងមេរៀនទី១ យើងបានពិភាក្សាអំពីសមាសភាពរបស់ទ្រង់ និង កត់ចំណាំចំណុចខាងក្រោមនេះ៖

១. ព្រះជាម្ចាស់គឺជាវិញ្ញាណ
២. ទ្រង់គឺជាព្រះជាម្ចាស់តែមួយគត់។
៣. ទ្រង់មានបុគ្គលិកលក្ខណៈ។
៤. ទ្រង់គឺជាព្រះបីអង្គរួមមកតែមួយ។
៥. ទ្រង់គឺអស់កល្បជានិច្ច។
៦. ទ្រង់មិនផ្លាស់ប្រែ។

យើងក៏បានឃើញថា គុណសម្បត្តិទាំងនេះរបស់ព្រះជាម្ចាស់ និយាយចំពោះព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធស្មើៗគ្នា។ អង្គទាំងបី មានសិរីរុងរឿងស្មើៗគ្នា ហើយព្រះតេជៈដែលអង្គព្រះទាំងបីមាន គឺមានភាពអស់កល្បជានិច្ចរួមគ្នា។ ដោយសារតែអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ មានលក្ខណៈដូចគ្នា យើងមិនបានពិចារណាអំពីទ្រង់ម្តងទៀតនៅក្នុងការពិចារណាអំពីព្រះគ្រិស្តនោះទេ យើងក៏មិនចាំបាច់ត្រូវពិនិត្យពិច័យពីទ្រង់ម្តងទៀតនៅក្នុងការពិនិត្យពិច័យអំពីព្រះវិញ្ញាណដ៏វិសុទ្ធនោះដែរ។ ទោះជាយ៉ាងណា យើងចង់បញ្ជាក់ឡើងវិញម្តងទៀតយ៉ាងខ្លីៗអំពីការពិតដែលថាព្រះវិញ្ញាណដ៏វិសុទ្ធគឺពិតជាព្រះជាម្ចាស់ និង ដែលថាទ្រង់មានលក្ខណសម្បត្តិនៃបុគ្គលិកលក្ខណៈដោយឡែក។ ដំបូងយើងនឹងពិភាក្សាអំពីភាពជាព្រះរបស់ទ្រង់ជាមុនសិន។

ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺបង្កើតឡើងដោយលក្ខណសម្បត្តិរបស់ទ្រង់ ទំនាក់ទំនងរបស់ទ្រង់ជាមួយអង្គព្រះដទៃទៀតនៅក្នុងព្រះត្រៃឯក ព្រះនាមជាព្រះជាម្ចាស់ដែលបានថ្វាយសម្រាប់ទ្រង់ និង កិច្ចការដែលទ្រង់បានសំដែង។

លក្ខណសម្បត្តិនៃនិស្ស័យជាព្រះរបស់ទ្រង់

វត្ថុបំណងទី១. *ស្គាល់ពីលក្ខណសម្បត្តិនៃភាពជាព្រះ ដែលត្រូវបាននិយាយថាជាលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

ព្រះវិញ្ញាណដ៏វិសុទ្ធមានលក្ខណសម្បត្តិនៃនិស្ស័យជាព្រះជាម្ចាស់។ ឧទាហរណ៍ ទ្រង់គឺអស់កល្បជានិច្ច។ ពាក្យថា*អស់កល្បជានិច្ច* មានន័យថា "មានរយៈពេលគ្មានទីបញ្ចប់៖ ដែលគ្មានទីចាប់ផ្តើម ឬ ទីបញ្ចប់ ឬ ដែនកំណត់"។ ដូច្នេះ នេះគឺជាលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ អ្នកសរសេរសំបុត្រទៅកាន់សាសន៍ហេប្រឺដែលទទួលការជំរុញពីព្រះវិញ្ញាណ បានប្រាប់ថា ទ្រង់គឺជា*ព្រះវិញ្ញាណដែលគង់នៅអស់កល្បជានិច្ច* (គម្ពីរហេប្រឺ ៩:១៤) ។ ពាក្យថា *អស់កល្បជានិច្ច* ដែលមានប្រើនៅត្រង់នេះ គឺជាពាក្យដូចគ្នាដែលបានប្រើនៅកន្លែងផ្សេងទៀតដើម្បីរៀបរាប់អំពីភាពអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ព្រះវរបិតា និងរបស់ព្រះយេស៊ូគ្រិស្ត ជាបុត្រារបស់ព្រះជាម្ចាស់ដែរ។

ព្រះវិញ្ញាណដ៏វិសុទ្ធក៏មានលក្ខណសម្បត្តិដូចខាងក្រោមនេះដែរ៖

១. ទ្រង់មានព្រះវត្តមាននៅគ្រប់ទីកន្លែង (សព្វដ្ឋភាព) ។ អ្នកនិពន្ធព្រះបាទដាវីឌបានសំដែងឡើងថា៖ " តើទូលបង្គំអាចទៅណាឆ្ងាយពីព្រះអង្គបាន?តើទូលបង្គំគេចចេញអោយឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គដូចម្តេចបាន?" (គម្ពីរទំនុកតម្កើង ១៣៩:៧-១០) ។

២. ទ្រង់ជ្រាបគ្រប់ការទាំងអស់ (សព្វញ្ញុតភាព) ។ នៅក្នុងការរៀបរាប់ពីលក្ខណសម្បត្តិជាព្រះនេះទៅកាន់អ្នកជឿក្រុងកូរិនថូស លោកប៉ូលបានឃើញថា
"គ្មានអ្នកណាស្គាល់គំនិតរបស់ព្រះក្រៅពីព្រះវិញ្ញាណរបស់ព្រះនោះឡើយ" (គម្ពីរ(គកស១៦),១កូរិនថូស ២:១១)។ លើសពីនេះទៅទៀត ទ្រង់ដែលយល់ពីព្រះតម្រិះរបស់ព្រះជាម្ចាស់ ក៏យល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ ហើយទ្រង់ផ្តល់អំណាចឲ្យយើងអាចអធិស្ឋាន ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ (គម្ពីររ៉ូម៨:២៦-២៧)។

៣. ព្រះវិញ្ញាណដ៏វិសុទ្ធមានអំណាចលើគ្រប់ទាំងអស់ (សព្វានុភាព)។ នោះគឺ ទ្រង់មានអំណាច និងឫទ្ធានុភាព សម្រេចបាននូវអ្វីៗដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ដោយគ្មានដែនកំណត់សោះឡើយ (គម្ពីរលូកា ១:៣៥ គម្ពីរកិច្ចការ១:៨)។

លំហាត់អនុវត្តន៍

១ កំណត់លក្ខណសម្បត្តិនីមួយៗ នៃភាពជាព្រះដែលថ្វាយទៅព្រះវិញ្ញាណដ៏វិសុទ្ធ ដោយផ្គូផ្គងលក្ខណសម្បត្តិ (ខាងស្តាំ) ទៅជាមួយនឹងនិយមន័យនៃលក្ខណសម្បត្តិនីមួយៗ (ខាងឆ្វេង)។

.....ក) គ្មានដែនកំណត់ ឬ ព្រំដែន ចំពោះពេលវេលានោះទេ។
.....ខ) សមត្ថភាពនៅពេញសកលលោក ដែលទ្រង់មានព្រះវត្តមាននៅគ្រប់ទីកន្លែង។
.....គ) សមត្ថភាពដែលអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើអ្វីៗគ្រប់យ៉ាងតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ដោយគ្មានការរារាំងពីអ្វីឡើយ។
.....ឃ) ព្រះតម្រិះដែលឥតដែនកំណត់

១) សព្វានុភាព
២) សព្វញ្ញុតភាព,សព្វញ្ញុតញ្ញាណ
៣) សព្វដ្ឋភាព,សព្វត្ថិភាព
៤) និរន្តរភាព, អនន្តភាព

ឋានន្តរនៃនិស្ស័យជាព្រះរបស់ទ្រង់

វាពិតជាគួរឲ្យចាប់អារម្មណ៍ ដែលយើងចាំថានៅពេលដែលលោកសាវ័កពេត្រុសនិយាយទៅកាន់អាណាណាសដែលមានចិត្តគេងប្រវ័ញ្ច លោកបានមានប្រសាសន៍ថានៅពេលដែលអាណាណាសកុហកព្រះវិញ្ញាណដ៏វិសុទ្ធ លោកកុហកនឹងព្រះជាម្ចាស់ (គម្ពីរកិច្ចការ ៥:៤)។

ដូច្នេះ លោកសាវ័កពេត្រុសថ្វាយភាពជាព្រះទៅដល់ព្រះវិញ្ញាណដ៏វិសុទ្ធ។ លោកសាវ័កប៉ូលក៏បានអះអាងពីការពិតមួយនេះ ដោយមានប្រសាសន៍ថា យើងត្រូវបានផ្លាស់ប្តូរឲ្យបានដូចជាព្រះគ្រិស្ត ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះអម្ចាស់ (គម្ពីរ២កូរិនថូស ៣:១៧-១៨) ។ នៅក្នុងជំនាន់របស់លោកសាវ័កប៉ូល មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចត្រូវបានប្រសព្វនាមជាព្រះអម្ចាស់។ តាមការពិត សូម្បីតែអធិរាជរ៉ូម៉ាំង និង អេស៊ីព្ទ នៅក្នុងជំនាន់នោះ ក៏មិនអនុញ្ញាតឲ្យប្រជារាស្ត្ររបស់ពួកគេប្រើប្រាស់ពាក្យ*ព្រះអម្ចាស់*នៅពេលដែលហៅពួកគេឡើយ លុះត្រាតែពួកគេទទួលបានការតែងតាំងជាអាទិទេពជាផ្លូវការដោយខ្លួនឯង។ ការប្រើប្រាស់នេះ បញ្ជាក់ពីការពិតថា នៅពេលដែលលោកសាវ័កប៉ូលមានប្រសាសន៍អំពីព្រះវិញ្ញាណដ៏វិសុទ្ធ ថាជាព្រះអម្ចាស់ លោកបានស្គាល់ពីភាពជាព្រះរបស់ទ្រង់ទៅហើយ។

លំហាត់អនុវត្តន៍

---

២ តើបទគម្ពីរណាមួយនៅខាងក្រោមនេះ អាចយកមកប្រើជាភស្តុតាងបង្ហាញពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបាន។

ក) លោកសាវ័កប៉ូលមានប្រសាសន៍សំដៅទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធ ថាជា*ព្រះអម្ចាស់* ។

ខ) ព្រះយេស៊ូមានព្រះបន្ទូលសំដៅទៅព្រះវិញ្ញាណដ៏វិសុទ្ធថាជា *ទីប្រឹក្សា* ។

គ) លោកអេសាយបានមានប្រសាសន៍សំដៅទៅលើ*ព្រះវិញ្ញាណរបស់ព្រះអម្ចាស់* (គម្ពីរអេសាយ ១១:២)។

ឃ) លោកពេត្រុសប្រកាសថា ការកុហកព្រះវិញ្ញាណដ៏វិសុទ្ធគឺការកុហកព្រះជាម្ចាស់។

ទំនាក់ទំនងរបស់ទ្រង់ទៅនឹងនិស្សិតជាព្រះជាម្ចាស់

ខគម្ពីរជាច្រើនបង្ហាញពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈទំនាក់ទំនងរបស់ទ្រង់។ នៅក្នុងឧទាហរណ៍ពីរដំបូង ដែលមាននៅខាងក្រោមនេះ ភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺទទួលបានមកតាមរយៈទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងអង្គព្រះពីរទៀតនៅក្នុងព្រះត្រៃឯក។ យើងបានឃើញនៅត្រង់ចំណុចនេះ អំពីគុណសម្បត្តិដ៏សំខាន់មួយរបស់បុគ្គល ក៏ដូចជាភាពជាព្រះសំខាន់ៗផងដែរ។

១. គម្ពីរម៉ាថាយ ២៨:១៩ ៖ *រូបមន្តសំរាប់ការជ្រមុជ៖* "...ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។

២. គម្ពីរ២កូរិនថូស ១៣:១៣ ៖ *ប្រសិទ្ធិពររបស់ពួកសាវ័ក៖* "សូមអោយបងប្អូនបានប្រកបដោយព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងការរួមរស់ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ" ។

៣. គម្ពីរ១កូរិនថូស ១២។ នៅក្នុងជំពូកមួយនេះ យើងឃើញថាក្រុមជំនុំគឺជាព្រះកាយរបស់ព្រះជាម្ចាស់ (ខ២៧)។ នៅលើក្រុមជំនុំនេះ ព្រះជាម្ចាស់បានចាត់តាំង ឲ្យមានព័ន្ធកិច្ចដើម្បីជួយដល់ការអភិវឌ្ឍក្រុមជំនុំនោះ (ខ ២៨)។ ហើយដោយអំណាចគ្រងរាជ្យ(ឬទ្ធានុភាពខ្ពង់ខ្ពស់បំផុត)របស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលបានចែកចាយអំណោយទាននេះសម្រាប់រូបកាយមួយនេះ (ខ១១)។ ទំនាក់ទំនងទៅវិញទៅមកដែលយើងឃើញនៅចំណុចនេះ អាចបកស្រាយបានដោយផ្អែកលើមូលដ្ឋានដែលថាមានភាពស្មើគ្នារវាងអង្គព្រះត្រៃឯកតែប៉ុណ្ណោះ។ មានតែការផ្អែកលើមូលដ្ឋាននេះប៉ុណ្ណោះ ដែលអាចឲ្យព្រះវិញ្ញាណដ៏វិសុទ្ធប្រើប្រាស់សិទ្ធិនៃភាពជាព្រះ និង ចែករំលែកអំណោយទានប្រកបដោយអធិបតេយ្យភាព តាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរ១កូរិនថូស ១២:៤-៦,១១)។

៤. គម្ពីរកិច្ចការ ២៨:២៥-២៨។ លោកប៉ូលបានផ្តល់នូវចំណេះដឹងដ៏មានប្រយោជន៍ អំពីបញ្ហានេះនៅពេលលោកបានមានប្រសាសន៍ថា ព្រះវិញ្ញាណដ៏វិសុទ្ធបានមានព្រះបន្ទូលដែលមានកត់ត្រានៅក្នុងគម្ពីរអេសាយ ៦:៩-១០ ដែលយោងតាមលោកអេសាយ គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ចូរប្រៀបធៀបខគម្ពីរទាំងពីរនេះ។ ការប្រៀបធៀបនេះ បង្ហាញថាដោយសារតែព្រះវិញ្ញាណដ៏វិសុទ្ធគឺជាអ្នកតំណាង ឬ ជាភ្នាក់ងាររបស់ព្រះជាម្ចាស់ព្រះវរបិតា ដូច្នេះទ្រង់ធ្វើកិច្ចការជួសឲ្យព្រះវរបិតានៅលើផែនដីនេះ។ ការនេះបានបង្ហាញកាន់តែច្បាស់នៅក្នុងឧទាហរណ៍ទាំងនេះ៖ ទ្រង់នាំមនុស្សមករកព្រះគ្រិស្ត (គម្ពីរយ៉ូហាន ៦:៤៤) ទ្រង់បង្ហាញសេចក្តីពិត (គម្ពីរយ៉ូហាន ១៤:២៦; ១៦:១៣) ហើយទ្រង់នាំផ្លូវ (គម្ពីររ៉ូម៨:១៤) ។

៥. គម្ពីរលោកុប្បត្តិជំពូក១។ ការរួមគ្នានៃឫទ្ធានុភាពរបស់ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ គឺឃើញមាននៅក្នុងគម្ពីរលោកុប្បត្តិ ១:២៦ ដែលក្នុងនេះព្រះជាម្ចាស់មានព្រះបន្ទូលថា " យើងបង្កើតមនុស្សជាតំណាងរបស់យើង មានលក្ខណៈដូចយើង" ។ ការប្រើប្រាស់សព្វនាមពហុវចន បង្ហាញពីពហុភាពនៃអង្គព្រះត្រៃឯកភាពពេញលេញ ដូចដែលយើងបានឃើញនៅក្នុងមេរៀនទី១ ។ អត្ថន័យបង្កប់នៅត្រង់នេះ គឺថាអង្គទាំងបីនៃព្រះជាម្ចាស់គឺសុទ្ធតែមានសកម្មភាពក្នុងការបង្កើត។

ខគម្ពីរយោងទាំងអស់នេះ ដែលនិយាយអំពីទំនាក់ទំនងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធជាមួយ អង្គព្រះពីរទៀតនៅក្នុងព្រះត្រៃឯក បង្ហាញតាមបែបបទគម្ពីរថា ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះជាម្ចាស់ស្មើគ្នាជាមួយព្រះវរបិតា និង ព្រះរាជបុត្រាដែរ។

លំហាត់អនុវត្តន៍

៣ ផ្គូផ្គងខគម្ពីរនីមួយៗ (ខាងឆ្វេង) ជាមួយនឹងភស្តុតាងដែលខគម្ពីរនោះផ្តល់ឲ្យ អំពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (ខាងស្តាំ)។

.....ក) គម្ពីរកិច្ចការ ២៨:២៥-២ និងគម្ពីរអេសាយ ៦:៩-១០

.....ខ) គម្ពីរ១កូរិនថូស ១២

.....គ) គម្ពីរ២កូរិនថូស ១៣:១៤

.....ឃ) គម្ពីរលោកុប្បត្តិ ១

.....ង) គម្ពីរម៉ាថាយ ២៨:១៩

១) ពហុភាពនៃអង្គព្រះនៅក្នុង ព្រះត្រៃឯកភាពពេញលេញនៅក្នុងការបង្កើតរបស់សព្វសារពើ

២) កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅលើផែនដី។

៣) អធិបតេយ្យរបស់ព្រះជាម្ចាស់

៤) ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ

ខ. បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

វត្ថុបំណងទី២. *ស្គាល់ពីផ្នែកសំខាន់នៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។*

ផ្នែកសំខាន់ៗនៃបុគ្គលិកលក្ខណៈ

យើងបានឃើញរួចមកហើយនៅក្នុងមេរៀនទី១ ថា ផ្នែកសំខាន់ៗនៃបុគ្គលិកលក្ខណៈមានបីយ៉ាង៖ ១) *សតិបញ្ញា* (សមត្ថភាពក្នុងការគិត) ២) *វេទយិតភាព* (សមត្ថភាពក្នុងការមានអារម្មណ៍) និង ៣) *បំណងហឫទ័យ* (សមត្ថភាពធ្វើការសម្រេចចិត្ត) ។ ចូរយើងទៅសិក្សាអំពីខគម្ពីរដែលនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ហើយមើលពីរបៀបដែលលក្ខណសម្បត្តិទាំងនេះ ត្រូវបានប្រើប្រាស់ចំពោះទ្រង់។

ព្រះគម្ពីរបានថ្លែងយ៉ាងច្បាស់ៗមកយើង ស្តីពីបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងប្រសាសន៍យ៉ាងម៉ឺងម៉ាត់របស់លោកសាវ័កប៉ូល លោកបានសន្និដ្ឋានដោយនិយាយសំដៅទៅកាន់ "ព្រះបំណងរបស់ព្រះវិញ្ញាណ" (គម្ពីររ៉ូម ៨:២៧) ដែលបានបង្ហាញពីអានុភាពនៃសតិបញ្ញារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ លោកសាវ័កប៉ូលក៏បានថ្វាយ*វេទយិតភាព*ទៅកាន់ដល់ព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ (គម្ពីររ៉ូម ១៥:៣០)។ ត្រង់នោះ លោកបាននិយាយសំដៅទៅលើសមត្ថភាពរបស់ព្រះវិញ្ញាណ ក្នុងការទទួលអារម្មណ៍ ក្នុងករណីនេះ គឺការមានអារម្មណ៍*ស្រឡាញ់* និង សមត្ថភាពរបស់ទ្រង់ក្នុង*ការបង្ហាញអារម្មណ៍* ។ ចុងក្រោយ លោកសាវ័កប៉ូលបានមានប្រសាសន៍ទៅកាន់អ្នកជឿក្រុងកូរិនថូស អំពីសកម្មភាពជាព្រះអធិបតីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដូចដែលទ្រង់បានបង្ហាញពីអានុភាពនៃ*បំណងព្រះហឫទ័យ* និង អំពីការប្រទានព្រះអំណោយទានទៅដល់អ្នកជឿ តាមការទ្រង់បានកំណត់ ឬ សព្វព្រះហឫទ័យ (គម្ពីរ១កូរិនថូស ១២:១១) ។ ខគម្ពីរទាំងនេះ បង្ហាញថាព្រះវិញ្ញាណដ៏វិសុទ្ធមានលក្ខណសម្បត្តិសំខាន់ៗខាងឯបុគ្គលិកលក្ខណៈ។

លំហាត់អនុវត្តន៍

៤ នៅក្នុងលំហាត់ខាងក្រោមនេះ ចូរអ្នកផ្គូផ្គងផ្នែកសំខាន់ៗខាងឯបុគ្គលិកលក្ខណៈ (ខាងស្តាំ) ជាមួយនិយមន័យ ឬការរៀបរាប់របស់បុគ្គលិកលក្ខណៈនោះ (ខាងឆ្វេង)។

.....ក) អានុភាពដែលអនុញ្ញាតឲ្យមនុស្សម្នាក់ធ្វើការសម្រេចចិត្ត។

.....ខ) សមត្ថភាពដើម្បីរិះគិត រកហេតុផល និង ជ្រាបដឹង

.....គ) សមត្ថភាពដើម្បីទទួលបានអារម្មណ៍ ដើម្បីបង្ហាញពីអារម្មណ៍។

១) សតិបញ្ញា

២) វេទយិតភាព

៣) បំណងហឫទ័យ

ចំណុចសំខាន់ផ្សេងៗទៀតនៃបុគ្គលិកលក្ខណៈ

បន្ថែមពីលើផ្នែកចាំបាច់នៃបុគ្គលិកលក្ខណៈទាំងអស់ មានចំណុចសំខាន់ៗខ្លះទៀតដែលរួមបញ្ចូលនៅក្នុងការយល់ដឹងរបស់យើងអំពីបុគ្គលិកលក្ខណៈ។ ចំណុចទាំងនោះមានដូចជា ១) ទំនាក់ទំនងជាបុគ្គល ២) ទង្វើ ឬ សកម្មភាពជាបុគ្គល ៣) នាមជាបុគ្គល ៤) សព្វនាមជាបុគ្គល និង ៥) ការប្រព្រឹត្តជាបុគ្គល។ លក្ខណសម្បត្តិទាំងអស់នេះក៏អាចយកទៅប្រើជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធបានផងដែរ ដូចដែលយើងនឹងបានឃើញនៅខាងក្រោមនេះ ។

១. *ទំនាក់ទំនងជាបុគ្គល*

យើងបានកត់សំគាល់ឃើញថា រូបមន្តសម្រាប់ការជ្រមុជ និង ការប្រសិទ្ធពររបស់ពួកសាវ័ក ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវបានលើកយកមកថ្លែងរួមជាមួយព្រះវរបិតា និង ព្រះរាជបុត្រា។ ការទំនាក់ទំនងជាមួយបុគ្គលផ្សេងនេះ បញ្ជាក់ឲ្យឃើញពីបុគ្គលិកលក្ខណៈ។ តើវាមិនមែនជារឿងដ៏ល្ងង់ខ្លៅមួយទេឬអី ដែលបង្គាប់ឲ្យនរណាម្នាក់ជ្រមុជទឹកនៅក្នុងព្រះនាមព្រះវរបិតា និង ព្រះរាជបុត្រា និង " កម្លាំង" "ដង្ហើម" ឬ "ខ្យល់" វិញនេះ ? (គម្ពីរម៉ាថាយ ២៨:១៩)។ នោះពិតជារឿងដ៏ល្ងង់ខ្លៅណាស់ ដ្បិតមានតែបុគ្គលិកលក្ខណៈប៉ុណ្ណោះដែលអាច មានទំនាក់ទំនងជាមួយនឹងបុគ្គលិកលក្ខណៈដទៃផ្សេងទៀត។

នេះប្រាកដជាមូលដ្ឋានដែលពួកសាវ័ក និង ព្រឹទ្ធាចារ្យមានកិច្ចប្រជុំប្រឹក្សាសំខាន់នៅក្រុងយេរ៉ូសាឡឹម បានសរសេរពាក្យទាំងនេះថា៖ " ព្រះវិញ្ញាណដ៏វិសុទ្ធ* និងយើងខ្ញុំយល់ឃើញថា មិនគួរយកវិន័យ* ណាផ្សេងទៀតដែលមិនចាំបាច់ មកបង្ខំបងប្អូនអោយប្រតិបត្តិតាមឡើយ" (គម្ពីរកិច្ចការ ១៥:២៨) ។ បុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺបានបញ្ជាក់ឲ្យឃើញដោយទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងអង្គព្រះពីរផ្សេងទៀតនៅក្នុងព្រះត្រៃឯក។

២. *ទង្វើ ឬ សកម្មភាពជាបុគ្គល*

នៅពេលដែលយើងពិចារណាអំពីសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានបង្ហាញនៅក្នុងខគម្ពីរ យើងនឹងឃើញពីរបៀបដែលខគម្ពីរទាំងនោះប្រាប់ពីនិយមន័យពេញលេញ ទៅកាន់បុគ្គលិកលក្ខណៈរបស់ទ្រង់។ ចូរអ្នកអានខគម្ពីរនីមួយៗខាងក្រោមនេះ។

ខគម្ពីរ	**សកម្មភាពនៃលក្ខណៈបុគ្គល**
គម្ពីរ២ពេត្រុស ១:២១	ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញ លើកទឹកចិត្ត និង ផ្តល់អំណាច
គម្ពីរ១កូរិនថូស ២:១០	ទ្រង់ស្វែងរក
គម្ពីរកិច្ចការ ១៣:២ គម្ពីររ៉ូម៉ែ: ២:៧	ទ្រង់មានព្រះបន្ទូល ត្រាស់ហៅមនុស្សឲ្យធ្វើការបម្រើ
គម្ពីរយ៉ូហាន ១៥:២៦	ទ្រង់ធ្វើបន្ទាល់
គម្ពីរកិច្ចការ១៦:៦-៧	ទ្រង់ដឹកនាំ មនុស្សរបស់ទ្រង់នៅក្នុងការបម្រើ ជារឿយតែងតែរារាំង និង ហាមឃាត់ពួកគេមិនឲ្យធ្វើសកម្មភាពខ្លះៗ
គម្ពីររ៉ូម ៨:២៦	ទ្រង់ទូលអង្វរជំនួសយើង
គម្ពីរយ៉ូហាន ១៤:២៦	ទ្រង់បង្រៀន
គម្ពីរយ៉ូហាន ១៦:៨- ១១	ទ្រង់កាត់ទោស
គម្ពីរយ៉ូហាន ១៦:១៣	ទ្រង់នាំផ្លូវយើង
គម្ពីរយ៉ូហាន ១៦:១៤	ទ្រង់ថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត
គម្ពីរយ៉ូហាន ៣:៥	ទ្រង់បង្កើតយើងជាថ្មី

លំហាត់អនុវត្តន៍

---

៥ តើសកម្មភាពខាងលើនេះបានបង្ហាញអ្វី អំពីនិស្ស័យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ? ចូរសរសេរចម្លើយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

---

៣. *ព្រះនាមជាបុគ្គល*

នៅល្ងាចនៃថ្ងៃដែលទ្រង់ត្រូវគេឆ្កាង ព្រះយេស៊ូបានសំដែងទៅកាន់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងចាកចេញពីពួកគេ។ ដោយដឹងថាការចាកចេញរបស់ទ្រង់ ក៏មានន័យថាដកការដឹកនាំរបស់ទ្រង់ ការធានាអះអាង និង ការប្រឹក្សារបស់ទ្រង់ចេញពីពួកគេ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ខ្ញុំនឹងទូលអង្វរព្រះបិតា ហើយទ្រង់ប្រទានព្រះដ៏ជួយការពារមួយអង្គទៀត អោយគង់នៅជាមួយអ្នករាល់គ្នាជាដរាបតរៀងទៅ" (គម្ពីរយ៉ូហាន ១៤:១៦)។

ភ្លាមៗនេះព្រះយេស៊ូក៏បានបង្ហាញថា ព្រះមួយអង្គទៀតដែលនឹងជំនួសកន្លែងទ្រង់គឺជាព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:២៦) ។ ព្រះក៏បានបញ្ជាក់ថែមទៀតថា ដូចដែលទ្រង់បានយាងមកដើម្បីប្រកាសអំពីព្រះវរបិតា ព្រះវិញ្ញាណដ៏វិសុទ្ធក៏យាងមកដើម្បីពន្យល់ បង្ហាញ និង បកស្រាយ

និស្ស័យនិង បំណងព្រះហឫទ័យរបស់ព្រះយេស៊ូទៅកាន់មនុស្សជាតិដែរ។ (ចូរប្រៀបធៀបខគម្ពីរទាំងនេះ ៖ គម្ពីរយ៉ូហាន ១៤:១៥-១៨, ២៦; ១៥:២៦ និង ១៦:១៣-១៥)។ យើងឃើញហើយថា ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានគេហៅថា *ព្រះដ៏ជួយការពារ* ហើយទ្រង់យាងមកដើម្បីជំនួសកន្លែងរបស់ព្រះយេស៊ូ និង បំពេញព័ន្ធកិច្ចរបស់ព្រះគ្រិស្ត ជាអ្នកជួយការពារ *មួយអង្គទៀត* ។ ទំនួលខុសត្រូវនេះ ទាមទារឲ្យមានការវិនិច្ឆ័យបានល្អ អារម្មណ៍ បុគ្គលិកលក្ខណៈងាយទទួលដឹង ដែលអាចធ្វើការជួសឲ្យព្រះបុត្រារបស់ព្រះជាម្ចាស់បាន។

ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានចាត់បញ្ជូនមកដោយព្រះវរបិតា តាមសំណើររបស់ព្រះបុត្រា (គម្ពីរយ៉ូហាន ១៥:២៦) ដើម្បីតម្កើងសិរីរុងរឿងព្រះបុត្រា និង ព័ន្ធកិច្ចរបស់ទ្រង់ទៅកាន់តម្រូវការខាងឯវិញ្ញាណរបស់អ្នកជឿ។ ទ្រង់ត្រូវបានគេហៅថា *ព្រះវិញ្ញាណដែលសំដែងសេចក្តីពិត* (គម្ពីរយ៉ូហាន ១៤:១៧) ព្រះវិញ្ញាណដែលផ្តល់ជីវិត(គម្ពីររ៉ូម ៨:២) ព្រះវិញ្ញាណនៃព្រះគុណ (គម្ពីរហេប្រឺ១០:២៩) *ព្រះវិញ្ញាណនៃការទទួលជាបុត្រ* (គម្ពីររ៉ូម៨:១៥ គម្ពីរកាឡាទី ៤:៥-៧) *ព្រះវិញ្ញាណនៃព្រះបន្ទូលសន្យា* (គម្ពីរកិច្ចការ ១:៥) *ព្រះវិញ្ញាណនៃភាពវិសុទ្ធ* (គម្ពីររ៉ូម ១:៤) និង *អ្នកទូលអង្វរជួស* ឬ *ព្រះដ៏ជួយការពារ* (គម្ពីរ១យ៉ូហាន ២:១ គម្ពីរយ៉ូហាន ១៤:១៦,២៦)។ ព្រះដែលមានព្រះនាមទាំងអស់ខាងលើនេះ គឺជាព្រះវិញ្ញាណដ៏វិសុទ្ធតែមួយដែលបានថ្វាយសិរីរុងរឿងរបស់ព្រះយេស៊ូ ធ្វើឲ្យទ្រង់បានមានភាពជាក់ស្តែងសម្រាប់យើងរាល់គ្នា ហើយបន្តកិច្ចការរបស់ទ្រង់នៅលើផែនដី។

ព្រះដ៏ជួយការពារអង្គនេះ ក៏ត្រូវបានគេហៅថា *ព្រះវិញ្ញាណដ៏វិសុទ្ធ* (គម្ពីរអេភេសូ ៤: ៣០) ព្រះវិញ្ញាណរបស់ព្រះយេស៊ូ (គម្ពីរកិច្ចការ ១៦:៧) ព្រះវិញ្ញាណរបស់ព្រះគ្រិស្ត (គម្ពីររ៉ូម ៨:៩) ព្រះវិញ្ញាណរបស់ព្រះយេស៊ូគ្រិស្ត (គម្ពីរភីលីព ១:១៩) និង ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ (គម្ពីរ១យ៉ូហាន ៤:២) ។ ទោះបីជាព្រះនាមទាំងនេះខុសគ្នាក៏ដោយ ការហៅនេះគឺសំដៅតែទៅលើព្រះមួយអង្គគត់។ ព្រះនាមផ្សេងគ្នានេះ គឺគ្រាន់តែបង្ហាញអំពីផ្នែកផ្សេងៗគ្នានៃនិស្ស័យ និង ព្រះរាជកិច្ចរបស់ទ្រង់តែប៉ុណ្ណោះ។

៤. *សព្វនាមជាបុគ្គល*

អ្នកប្រហែលជាបានសំគាល់ឃើញពីការយកចិត្តទុកដាក់អំពីព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងគម្ពីរយ៉ូហានជំពូក១៤,១៥និង១៦ រួចមកហើយ។ វាគឺជារឿងចាំបាច់ណាស់ ដែលលោកយ៉ូហានប្រើប្រាស់សព្វនាមបុរិស: ដើម្បីទាក់យកចំណាប់អារម្មណ៍ទៅលើភាពជាបុគ្គលរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ឧទាហរណ៍ សព្វនាមជាបុរស *អេខនូស (ekeinos)* ត្រូវបានយកមកប្រើប្រាស់នៅក្នុងគម្ពីរយ៉ូហាន ១៦:១៣ ដើម្បីនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ជាប្រយោជន៍ក្នុងការសំគាល់ពីភាពជាបុគ្គលរបស់ទ្រង់។ នេះគឺជាសព្វនាមដូចគ្នាទៅនឹងសព្វនាមដែលបានប្រើប្រាស់ដើម្បីនិយាយអំពីព្រះយេស៊ូ នៅក្នុងគម្ពីរ១យ៉ូហាន ២:៦; ៣:៣,៥,៧ និង១៦។

៥. ការប្រព្រឹត្តជាបុគ្គល។

ចុងបញ្ចប់ ការពិតដែលថាព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវទទួលរងការប្រព្រឹត្តិមកចំពោះទ្រង់ដូចជាបុគ្គលក៏បានបង្ហាញទៅកាន់ភាពជាបុគ្គលរបស់ទ្រង់ផងដែរ។ បទគម្ពីរបានសំដែងថា ទ្រង់អាចត្រូវល្បងលឬល្បួង (គម្ពីរកិច្ចការ ៥:៩) ត្រូវធ្វើឲ្យព្រួយព្រះទ័យ (គម្ពីរអេភេសូ ៤:៣០) ត្រូវបានកុហក (គម្ពីរកិច្ចការ ៥:៣) ត្រូវបានប្រមាថ និង និយាយទាស់ប្រឆាំង (គម្ពីរម៉ាថាយ ១២:៣១-៣២) ត្រូវបានជំទាស់ប្រឆាំង

(គម្ពីរកិច្ចការ ៧:៥១) និង ត្រូវបានត្មះតិះដៀល (គម្ពីរហេប្រឺ១០:២៩) ។ កម្លាំងអបុគ្គល មិនត្រូវបានទទួលរងនូវការប្រព្រឹត្តិយ៉ាងដូច្នេះឡើយ ហើយក៏មិនអាចនឹងមានឥរិយាបថឆ្លើយតបដូច្នេះបានដែរ។

លំហាត់អនុវត្តន៍

---

៦ តើពាក្យណាខ្លះនៅខាងក្រោមនេះ ដែលអាចយកទៅប្រើដើម្បីរៀបរាប់អំពីព្រះវិញ្ញាណដ៏វិសុទ្ធបានយ៉ាងត្រឹមត្រូវ ? ចូរគូសរង្វង់ជុំវិញ អក្សរនៅខាងមុខចម្លើយរបស់អ្នក។

ក)	ព្រះដ៏ជួយការពារ	ជ)	ព្រះដែលត្រូវបានល្បួង
ខ)	អ្នកនាំផ្លូវ	ឈ)	បុគ្គលម្នាក់
គ)	កម្លាំងអបុគ្គល	ញ)	គ្រូ
ឃ)	ទ្រង់	ដ)	ដែលប្រកបដោយសតិបញ្ញា
ង)	ភាពជាព្រះ	ឋ)	ព្រះដែលគ្រងរាជ្យ
ច)	អ្នកទូលអង្វរជួស	ឌ)	ព្រះដែលទទួលជ្រាបអារម្មណ៍
ឆ)	វា	ឍ)	ព្រះដែលអាចនឹងត្រូវត្មះតិះដៀល

ការស្គាល់ពីភាពជាបុគ្គលរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺមានសារៈសំខាន់ណាស់។ នៅពេលដែលយើងដឹងថា ទ្រង់គឺជាភាពបុគ្គលមួយទៀតនៅក្នុងព្រះត្រៃឯកភាពពេញលេញ យើងឃើញថាទ្រង់ស័ក្តិសមទទួលបានការថ្វាយបង្គំរបស់យើង ជំនឿរបស់យើង ក្តីស្រឡាញ់ និង ការលើកតម្កើងរបស់យើង។ រឿងដែលយើងត្រូវធ្វើគឺអនុញ្ញាតឲ្យទ្រង់គង់នៅក្នុងយើង ហើយប្រើប្រាស់យើងសម្រាប់ព្រះកិត្តិនាម និង សិរីរុងរឿងរបស់ទ្រង់។

គ. ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ

យើងបានឃើញផ្នែកមួយនៃព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលទ្រង់ធ្វើសកម្មភាពជាមួយព្រះវរបិតា និង ព្រះបុត្រា ក្នុងការបង្កើតរបស់សព្វសារពើហើយ។ ដោយយោងទៅតាមការចូលរួមនេះ អ្នកនិពន្ធគម្ពីរទំនុកតំម្កើងបានថ្លែងថា៖ "ពេលណាព្រះអង្គប្រទានខ្យល់ដង្ហើម សត្វទាំងនោះនឹងកកើតឡើងហើយអ្វីៗទាំងអស់នៅលើផែនដីមានជីវិតឡើងវិញ។" (គម្ពីរទំនុកតម្កើង ១០៤:៣០)។ ខគម្ពីរយោងដែលយើងនឹងបានឃើញ ក៏មាននិយាយអំពីតួនាទីរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងការការពារ នឹងថែរក្សា ស្មាព្រះហស្តរបស់ព្រះជាម្ចាស់ផងដែរ។

នៅពេលដែលលោកហោរាអេសាយមានប្រសាសន៍អំពីភាពអស្ចារ្យគ្មានដែនកំណត់នៃឫទ្ធានុភាពរបស់ព្រះជាម្ចាស់នៅក្នុងការបង្កើតរបស់សព្វសារពើ និង ឧបការគុណ (ការនាំផ្លូវ ឬការថែរក្សាពីព្រះជាម្ចាស់) លោកបានចោតសួរថា "តើនរណាស្ទង់ព្រះវិញ្ញាណនៃព្រះអម្ចាស់ តើនរណាធ្វើជាទីប្រឹក្សា ជួយគំនិតព្រះអង្គ?" (គម្ពីរអេសាយ ៤០:១៣)។ នៅពេលពិចារណាអំពីសំណួរមួយនេះ យើងចាប់ផ្តើមឃើញពីដែនកំណត់នៃសមត្ថភាពរបស់យើងក្នុងការយល់ពីភាពអាថ៌កំបាំងរបស់ព្រះជាម្ចាស់។ ដូច្នេះ យើងអាចបានត្រឹមតែ ឆ្លើយទៅនឹងសំណួរនេះដោយនិយាយថា យើងមិនអាចយល់ច្បាស់ពីព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ ប៉ុន្តែយើងអាចទទួលបានការប៉ះពាល់ ទទួលបានព្រះពរ និង ការដឹកនាំដោយព្រះវត្តមានរបស់

ទ្រង់ ហើយទទួលបានអំណាចតាមរយៈឫទ្ធានុភាពរបស់ទ្រង់។ យើងអាចឃើញពីឥទ្ធិពលនៃព័ន្ធកិច្ច របស់ទ្រង់ ដូចដែលយើងអាចឃើញពីឥទ្ធិពលរបស់ខ្យល់ ទោះបីជាយើងមិនយល់ច្បាស់ពីអាថ៌កំបាំង របស់ខ្យល់នោះផងដែរ។ (គម្ពីរយ៉ូហាន ៣:៨)

ស្របពេលដែលយើងរាល់គ្នាដែលជាសភាវៈមានដែនកំណត់ មិនអាចយល់បានយ៉ាងពេញលេញ អំពីវិសាលភាពនៃសកម្មភាពដែលឥតដែនកំណត់របស់ព្រះវិញ្ញាណបាន យើងនៅតែអាចសិក្សាអំពីផ្នែក ខ្លះៗនៃសកម្មភាពរបស់ទ្រង់ដែលបានបង្ហាញនៅក្នុងបទគម្ពីរ។ ការបើកបង្ហាញរបស់ បទគម្ពីរទាំងនេះ ផ្តល់ឲ្យយើងនូវរូបភាពស្ទើរតែគ្រប់ជ្រុងជ្រោយនៃអង្គព្រះវិញ្ញាណដ៏វិសុទ្ធ និង វិសាលភាពដ៏ធំធេងនៃព័ន្ធកិច្ច របស់ទ្រង់។ យើងគួរតែពិចារណាអំពី ព័ន្ធកិច្ចរបស់ទ្រង់ដែលទាក់ទងនឹង ១)ពិភពលោករបស់អ្នកមិនជឿ ២) អ្នកជឿម្នាក់ៗ និង ៣) ក្រុមជំនុំទាំងមូល។

ទាក់ទងនឹងពិភពលោករបស់អ្នកមិនជឿ

វត្ថុបំណងទី៣. *ផលឧទាហរណ៍អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើចំពោះពិភពអ្នកមិនជឿ ធ្វើចំពោះ បុគ្គលអ្នកជឿម្នាក់ និង ក្រុមជំនុំទាំងមូល។*

លើសពីការចូលរួមរបស់ទ្រង់នៅក្នុងការបង្កើតរបស់សព្វសារពើ និង ឧបការគុណរបស់ទ្រង់ ព្រះ វិញ្ញាណដ៏វិសុទ្ធក៏បានចូលរួមនៅក្នុងពិភពលោករបស់អ្នកមិនជឿផងដែរ។ យោងទៅតាមគម្ពីរយ៉ូហាន ១៦:៨-១១ ទ្រង់ប្រកាសប្រាប់មនុស្សអំពីអំពើបាប ភាពសុចរិត និង ការកាត់ទោស។

១. *ប្រកាស(បញ្ជាក់)ប្រាប់ពីអំពើបាប។*

ព្រះយេស៊ូបានមានព្រះបន្ទូលថា នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដល់ "ព្រះអង្គនឹង បញ្ជាក់អោយមនុស្សលោកដឹងថា គេយល់ខុសអំពីបាប* អំពីសេចក្តីសុចរិត* និងអំពីការកាត់ទោស។ គេ យល់ខុសអំពីបាប ព្រោះគេមិនជឿលើខ្ញុំ" (គម្ពីរយ៉ូហាន១៦:៨-៩)។ ព្រះវិញ្ញាណដ៏វិសុទ្ធ បញ្ជាក់ឲ្យមនុស្ស ដឹងអំពីភាពមានបាបដែលមកពីការមិនទទួលជឿលើព្រះយេស៊ូគ្រិស្ត។

២. *ប្រកាស(បញ្ជាក់)ប្រាប់អំពីភាពសុចរិត។*

"....អំពីសេចក្តីសុចរិតព្រោះខ្ញុំទៅឯព្រះបិតា ហើយអ្នករាល់គ្នានឹងមិនឃើញខ្ញុំទៀត" (គម្ពីរយ៉ូហាន ១៦:១០)។ នោះមានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញទៅកាន់មនុស្សលោកអំពីភាពសុចរិតរបស់ព្រះអ ម្ចាស់យេស៊ូគ្រិស្ត និង ភាពទុច្ចរិតរបស់អ្នកដទៃផ្សេងទៀត។ ទ្រង់ក្រើនរំឭកពួកគេថា ដោយសារតែជ័យជំ នះរបស់ព្រះយេស៊ូលើអំពើបាប ទើបពេលនេះព្រះជាម្ចាស់ប្រកាសថាមនុស្សបាបបានទៅជាសុចរិត និង អនុញ្ញាតឲ្យពួកគេធ្វើខ្លួនឲ្យបានសុចរិត តាមរយៈជំនឿរបស់ពួកគេលើទ្រង់។

៣. *ប្រកាស(បញ្ជាក់)ប្រាប់អំពីការកាត់ទោស។*

"....អំពីការកាត់ទោស ព្រោះចៅហ្វាយរបស់មនុស្សលោកនេះបានទទួលទោសរួចហើយ។" (គម្ពីរយ៉ូ ហាន ១៦:១១) ។ ព្រះវិញ្ញាណដ៏វិសុទ្ធប្រកាស(បញ្ជាក់)ប្រាប់អ្នកមិនជឿអំពីការកាត់ទោស តាមរយៈការ បង្ហាញទំនាក់ទំនងរវាងការសុគតរបស់ព្រះគ្រិស្ត និង ការមានព្រះជន្មរស់ឡើងវិញ និង ការវិនិច្ឆ័យទោស បាបពិភពលោកនេះ។ តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ទ្រង់បានក្លាយជា អ្នកមានជ័យជំនះលើខ្មាំងសត្រូវគឺសាតាំង ដែលជាត្រូវបានកាត់ទោសឲ្យស្លាប់ជារៀងរហូត។ ដូច្នេះ ឈើ

ឆ្កាងសំគាល់ពីការបង់ថ្លៃបំណុលមួយ ដែលជាបំណុលទោសបាបរបស់យើង។ ឈើឆ្កាងក៏សំគាល់ពីការប្រទានការរំដោះបាប,សសម្រាស់អស់អ្នកដែលនឹងទទួលឈើឆ្កាង ហើយច្រានចោលអំណាចរបស់អំពើបាប និង សាតាំង។

សេចក្តីបង្រៀនរបស់ព្រះយេស៊ូ អំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១៤:១៦-១៧, ២៦; ១៥:២៦; ១៦:៥-១៥) បាននាំយើងឲ្យចូលទៅរកការសន្និដ្ឋានដែលថានៅក្នុងពេលគ្មានព្រះវត្តមានព្រះអម្ចាស់យេស៊ូនៅលើផែនដីនេះ ហើយដើម្បីជំនួសឲ្យព្រះវរបិតា ព្រះវិញ្ញាណដ៏សុទ្ធគឺជាព្រះដែលជាសក្ខីភាពទៅដល់អ្នកមិនជឿ។ ព្រះវិញ្ញាណបានបញ្ជាក់ប្រាប់ ពួកគេអំពីអំពើបាប និង នាំពួកគេឲ្យបានចូលទៅឯព្រះគ្រិស្ត (គម្ពីរយ៉ូហាន ៦:៤៤) ។ បន្ទាប់មកទ្រង់បានបំភ្លឺផ្លូវសម្រាប់អ្នកជឿអំពីទំនួលខុសត្រូវខាងឯវិញ្ញាណរបស់ពួកគេ (គម្ពីរ១យ៉ូហាន ១:៩) ។

លំហាត់អនុវត្តន៍

---

៧ តើចម្លើយមួយណានៅខាងក្រោមនេះ ជាឧទាហរណ៍ត្រឹមត្រូវអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើព័ន្ធកិច្ចជាមួយនឹងពិភពលោករបស់អ្នកមិនជឿ? ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយរបស់អ្នក។

ក) ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញមនុស្សទុច្ចរិតថា មធ្យោបាយតែមួយគត់ដើម្បីឲ្យពួកគេក្លាយទៅជាសុចរិត គឺតាមរយៈជំនឿទៅលើការរំដោះបាបរបស់ព្រះគ្រិស្ត។

ខ) តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះវត្តមាននៅលើផែនដីនេះ ទ្រង់បានយកឈ្នះលើកចុងក្រោយលើសាតាំង។

គ) យើងបានឃើញថា ព្រះគ្រិស្តបានបង់លោះទោសនៃអំពើបាបម្តងរួចហើយ ហើយដោយព្រោះការទាំងនេះ ព្រះវិញ្ញាណដ៏វិសុទ្ធអាចបញ្ចុះបញ្ចូលអ្នកមិនជឿអំពីការនិច្ឆ័យទោសរបស់ព្រះជាម្ចាស់។

ឃ) ព្រះវិញ្ញាណដ៏វិសុទ្ធប្រកាសប្រាប់ក្នុងចិត្តអ្នកមិនជឿអំពីអំពើបាប។

ទាក់ទងជាមួយនឹងអ្នកជឿម្នាក់ៗ

ជំនួយរបស់ទ្រង់

វគ្គបំណងទី៤. *បកស្រាយរបៀបប្រាំមួយយ៉ាងដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ។*

ចូរយើងពិចារណាអំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅចំពោះអ្នកជឿ ទៅតាមប្រភេទពីរយ៉ាង៖ ១) ជំនួយរបស់ទ្រង់ និង ការជ្រមុជរបស់ទ្រង់។ ព្រះយេស៊ូបានប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ការចាកចេញរបស់ទ្រង់ពីពួកគេទៅគឺប្រសើរជាង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកជួយពួកគេបន្ទាប់ពីទ្រង់ (គម្ពីរយ៉ូហាន ១៦:៧) ។ ខ្ញុំពិតជាស្ងប់ស្ងែងណាស់ដែលបានឃើញពីជំនួយជាច្រើនប្រភេទដែលអ្នកជឿអាចទទួលបានពីទ្រង់។

១. *យើងក្លាយខ្លួនជាអ្នកជឿ តាមរយៈកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ*

ពេលដែលយើងនៅជាអ្នកមិនជឿ យើងបានស្លាប់ខាងឯវិញ្ញាណទៅហើយ ប៉ុន្តែនៅពេលដែលយើងចូលមកឯព្រះជាម្ចាស់ ជាមួយនឹងការលន់តួ និង ជំនឿ យើងបានកើតជាថ្មីខាងឯជំនឿ។ យើងបានក្លាយជាការបង្កើតថ្មីមួយ (គម្ពីរ២កូរិនថូស ៥:១៧)។ យើងក៏បានកើតជាថ្មីម្តងទៀត ដោយសារព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ហើយយើងបានទទួលនិស្ស័យថ្មីមួយ។ បទពិសោធន៍មួយនេះ ត្រូវបានអ្នកទេវវិទូហៅថា *កំណើតថ្មី*។ (ចូរមើលគម្ពីរយ៉ូហាន ៣:៥-៧ គម្ពីរអេភេសូ ២:៥ និង គម្ពីរទីតុស ៣:៥) ។

២. *យើងទទួលបានឫទ្ធានុភាពពីព្រះវិញ្ញាណ សម្រាប់ធ្វើសក្ខីភាព។*

(គម្ពីរកិច្ចការ១:៨) ។ បញ្ហាកើតឡើងនៅពេលដែលយើងធ្វើការសម្រេចចិត្តដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ។ កាលៈទេសៈ មនុស្ស និង វិញ្ញាណអាក្រក់ព្យាយាមរារាំងយើង។ យើងត្រូវតែមានឫទ្ធានុភាពពិសេសដើម្បីយកឈ្នះលើឧបសគ្គទាំងអស់នេះ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គឺជាប្រភពនៃឫទ្ធានុភាពដែលយើងត្រូវការទាញយកមកដាក់ក្នុងខ្លួនដើម្បីឲ្យធ្វើសក្ខីភាពប្រកបដោយប្រសិទ្ធិភាព។

៣. *ព្រះវិញ្ញាណដ៏វិសុទ្ធ ជួយដឹកនាំយើងក្នុងនាមជាគ្រូម្នាក់* (គម្ពីរយ៉ូហាន ១៤:២៦; ១៥:២៦; ១៦:១៣)។

ខ្ញុំប្រហែលជាមិនបានរៀននៅក្នុងថ្នាក់របស់អភិជនអ្វីនោះទេ ប៉ុន្តែនៅពេលខ្ញុំចូលទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីរកជំនួយ ទ្រង់នឹងបង្រៀនខ្ញុំ។ ទ្រង់សព្វព្រះហឫទ័យបង្ហាញមកកាន់ខ្ញុំ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ ដូចទ្រង់សព្វព្រះហឫទ័យបង្ហាញទៅកាន់អ្នកដទៃទៀតដែរ (គម្ពីរ១កូរិនថូស ២:១២-១៤)។

៤. *យើងក៏បានទទួលជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈការទូលអង្វរជំនួសយើងផងដែរ។*

នេះមានន័យថា ទ្រង់ជាតំណាងនៃតម្រូវការរបស់យើងនៅចំពោះព្រះភ័ក្ត្រព្រះវរបិតានៃស្ថានបរមសុខ។ តើអ្នកធ្លាប់មានអារម្មណ៍ដូចខ្ញុំទេ ថានៅក្នុងស្ថានភាពមួយចំនួន អ្នកមិនដឹងអធិស្ឋានយ៉ាងដូចម្តេចនោះទេ? ពេលខ្លះយើងមានអារម្មណ៍ថា មិនចង់អធិស្ឋានសោះតែម្តង។ នៅក្នុងគ្រាបែបនេះ យើងអាចពឹងលើសេចក្តីអធិស្ឋានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបាន (គម្ពីររ៉ូម ៨:២៦)។

៥. *ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំយើង ពីមួយថ្ងៃទៅមួយថ្ងៃ ឆ្ពោះទៅរកជីវិតប្រកបដោយភាពជោគជ័យដូចជាព្រះគ្រិស្ត។*

នៅពេលយើងកើតជាថ្មី ហើយព្រះវិញ្ញាណដ៏វិសុទ្ធសង់ដំណាក់ទ្រង់នៅក្នុងជីវិតរបស់យើង យើងឃើញថា យើងមាននិស្ស័យពីរយ៉ាង ៖ និស្ស័យមួយទាក់ទងជាមួយនឹងនិស្ស័យខាងឯធម្មជាតិ ឬ រូបកាយ ហើយមួយទៀតទាក់ទងជាមួយនឹងនិស្ស័យខាងឯវិញ្ញាណ។ យើងឃើញថា ខ្លួនប្រាណរបស់យើងនៅតែទទួលរងសេចក្តីល្បួងខាងឯសាច់ឈាម។ នៅលំបាកដែលយើងឆ្លងកាត់ រវាងការល្អ និងការអាក្រក់ដែលមាននៅក្នុងយើង គឺត្រូវបានរៀបរាប់យ៉ាងលំអិតនៅក្នុងគម្ពីររ៉ូមជំពូកទី៧ ។ លោកប៉ូលបានមានប្រសាសន៍ថា៖ " ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមាននិស្ស័យលោកីយ៍ទេ(និស្ស័យសាច់ឈាម)។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ" (គម្ពីររ៉ូម ៧:១៨) ។ នៅត្រង់នេះលោកសាវ័កប៉ូលមិនបាននិយាយទាក់ទងនឹងជំនួយរបស់ព្រះវិញ្ញាណនោះទេ ប៉ុន្តែនៅក្នុងជំពូកទី៨ លោកបាននិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធចំនួន១៩ ដង ភ្ជាប់

ជាមួយនឹងជីវិតដែលប្រកបដោយភាពជោគជ័យ។ ច្បាប់របស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតគ្រិស្ត បរិស័ទគឺជាអាថ៌កំបាំងក្នុងការយកឈ្នះលើអំពើបាបបាន។ ព្រះវិញ្ញាណបានលះបង់ខ្លាំងណាស់ ចំពោះការអភិវឌ្ឍខាងឯវិញ្ញាណរបស់យើង ទ្រង់សព្វព្រះហឫទ័យបង្ហាញយើងពីរបៀបជំនះលើនិស្ស័យដ៏អាត្មានិយមរបស់យើង (គម្ពីររ៉ូម ៨:១-១៤)។

ទីកន្លែង និង ភាពសំខាន់នៅក្នុងជីវិតរបស់យើង ដែលយើងថ្វាយទៅកាន់ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជាកត្តាកំណត់លក្ខណសម្បត្តិរបស់យើង។ មនុស្សមិនកើតមកជាមួយនឹងទម្លាប់មួយជាក់លាក់នោះទេ។ លក្ខណសម្បត្តិ គឺជាលទ្ធផលដែលបានមកពីទម្លាប់ដែលយើងបង្កើតឡើងដោយទង្វើដែលធ្វើម្តងហើយម្តងទៀត។ លក្ខណសម្បត្តិនៃបុគ្គលនៃរូបកាយ ដែលរស់នៅដើម្បីតែបំពេញចំណង់ខាងឯរូបកាយរបស់ខ្លួនឯង គឺជារូបភាពមួយដែលគួរឲ្យខ្ពើមរអើម និង គួរឲ្យអាណិតខ្លាំងណាស់។ លក្ខណសម្បត្តិនៃបុគ្គលខាងវិញ្ញាណ ដែលអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំជីវិតរបស់គាត់ គឺខុសគ្នាស្រឡះ ដូចដែលយើងនឹងឃើញ។ ដំណោះស្រាយដែលលោកប៉ូលបានផ្តល់ឲ្យគឺថា ៖ "ចូររស់នៅអោយស្របតាមព្រះវិញ្ញាណ នោះបងប្អូននឹងមិនបំពេញតាមបំណងចិត្តលោភលន់របស់និស្ស័យលោកីយ៍ទៀតឡើយ" (គម្ពីរកាឡាទី ៥:១៦)។

៦. *ព្រះវិញ្ញាណដ៏វិសុទ្ធបង្កើតផលផ្លែពេញដោយព្រះពរ នៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ។*

មិត្តម្នាក់បានសួរមកខ្ញុំថា ហេតុអ្វីបានជាក្រុមអ្នកដែលថ្លែងថាខ្លួនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ បានអួតប្រាប់អ្នកដទៃអំពីរឿងខាងវិញ្ញាណរបស់ពួកគេទៅវិញ។ គាត់បាននិយាយថា គាត់មិនអាចនឹកស្រមៃថាព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការអួតបំប៉ោងយ៉ាងនេះអំពីទ្រង់យ៉ាងដូច្នេះទេ។ ខ្ញុំបានយល់ស្របជាមួយគាត់ទាំងស្រុង ។ ដើម្បីជៀសផុតពីបំណងខាងឯសាច់ឈាម (ការចុះចូលជាមួយនឹងចំណង់ខាងសាច់ឈាម) ឬ ជីវិតខាងវិញ្ញាណមិនត្រឹមត្រូវ យើងត្រូវតែដើរជាមួយព្រះវិញ្ញាណ។

ការដើរជាមួយនឹងព្រះវិញ្ញាណ បង្ហាញថាបុគ្គលម្នាក់នោះពឹងផ្អែកលើទ្រង់គ្រប់ពេល និង ជឿលើសមត្ថភាពរបស់ទ្រង់ ក្នុងការប្រទានឲ្យមានការប្រោសលោះនៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់បុគ្គលនោះ។ ខណៈពេលដែលយើងមិនបានទទួលការសន្យាថានឹងមានជីវិតដែលមានភាពឥតខ្ចោះគ្មានបាប យើងនឹងទទួលបានការកែប្រែយ៉ាងអស្ចារ្យ នៅពេលណាដែលយើងមានពេញដោយព្រះវិញ្ញាណ និង ត្រូវបានគ្រប់គ្រងដោយព្រះវិញ្ញាណ។ ជំនួសឲ្យការសម្តែងបង្ហាញពីកិច្ចការខាងឯសាច់ឈាម (គម្ពីរកាឡាទី ៥:១៩-២១) យើងបង្កើតបានជាផលផ្លែរបស់ព្រះវិញ្ញាណវិញ "សេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោស មេត្តា ជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង" (គម្ពីរកាឡាទី ៥:២២-២៣) ។ គុណសម្បត្តិ ឬ ផលផ្លែទាំងនេះ គឺជាលក្ខណសម្បត្តិរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងគឺពិនិត្យឲ្យបានជាក់ច្បាស់ទៅលើឥរិយាបថ ទំនាក់ទំនង និង សកម្មភាពរបស់យើង ដើម្បីឲ្យឃើញថា ចំណុចទាំងនោះរបស់យើងបានព័ណនាពីលក្ខណសម្បត្តិទាំងនេះ ឬ បង្ហាញពីកង្វះខាតផលផ្លែទាំងនេះ ។ (សម្រាប់ការសិក្សាបន្ថែមអំពីផលផ្លែនៃព្រះវិញ្ញាណទាំងនេះ សូមមើលនៅក្នុងវគ្គសិក្សាការបម្រើរបស់គ្រិស្តបរិស័ទរបស់សាកលវិទ្យាល័យគ្លូបល ដែលមានចំណងជើងថា៖ *ការរស់នៅដ៏ពេញបរិបូរណ៌ - ការសិក្សាអំពីលក្ខណសម្បត្តិរបស់គ្រិស្តបរិស័ទ។)*

លំហាត់អនុវត្តន៍

៨ ចូរបកស្រាយរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកជឿ ដោយផ្គែកទៅលើពាក្យទាំងប្រាំមួយនៅខាងក្រោមនេះ។

ក) កំណើតថ្មី

ខ) សក្ខីភាព

គ) ការបង្រៀន

ឃ) ការទូលអង្វរជំនួស

ង) ការនាំផ្លូវ

ច) ផលផ្លែ

ការជ្រមុជរបស់ទ្រង់

វត្ថុបំណងទី៥. *ស្គាល់ពីពាក្យផ្សេងៗទាក់ទងនឹងការជ្រមុជនឹងព្រះវិញ្ញាណ។*

ទំនាក់ទំនងដ៏ស្និតរមួតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ជាមួយនឹងអ្នកជឿត្រូវបង្ហាញឲ្យឃើញនៅក្នុងព្រះគម្ពីររួមជាមួយនឹងពាក្យរៀបរាប់ជាច្រើន។ ក្នុងនោះមានពាក្យមួយដែលគេហៅថា *ការជ្រមុជ* ដូចយើងបានឃើញពីខាងលើមក ដែលមានន័យថា"ការមុជចុះ"(គម្ពីរម៉ាថាយ ៣:១១ គម្ពីរកិច្ចការ ១:៥)។ តើមានរឿងអ្វីកើតឡើងនៅពេលដែលមនុស្សមុជចុះទៅក្នុងទឹក? ពួកគេនឹងទទឹកសព្វទាំងអស់! ទឹកគឺនៅពេញលើខ្លួនរបស់គេ។ នេះគឺពិតជារឿងមួយដែលអស្ចារ្យណាស់ ដែលយើងដឹងថា មនុស្សធម្មតាដូចយើងអាចត្រូវបានព្រះជាម្ចាស់ចាក់បង្ហូរអង្គទ្រង់យ៉ាងជោកជាំមកលើយើងរាល់គ្នា (បំពេញយើងយ៉ាងពេញលេញ)!

ពាក្យមួយទៀតដែលត្រូវបានប្រើដើម្បីរៀបរាប់អំពីទំនាក់ទំនងមនុស្សជាមួយនឹងព្រះវិញ្ញាណ គឺពាក្យថា *បំពេញ* (គម្ពីរកិច្ចការ ២:៤; ៤:៣១)។ នៅពេលដែលចានពេញ វាគ្មានលទ្ធភាពទទួលអ្វីបានទៀតនោះទេ។ តាមរបៀបដូចគ្នានេះដែរ ព្រះវិញ្ញាណដ៏វិសុទ្ធ សព្វព្រះហឫទ័យប្រទានឫទ្ធានុភាព និង សិរីរុងរឿងរបស់ទ្រង់មកឲ្យយើងយ៉ាងច្រើន ដល់យើងមិនអាចទទួលអ្វីទៀតបាន។ បន្ទាប់មកយើងនឹងមានឫទ្ធានុភាព ប្រាជ្ញាញាណ និង ការចាត់តាំងដែលចាំបាច់សម្រាប់ផ្គាប់ព្រះទ័យព្រះជាម្ចាស់ និង បម្រើទ្រង់យ៉ាងមានប្រសិទ្ធិភាពនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ យើងអាចពោរពេញដោយព្រះវិញ្ញាណ ម្តងហើយម្តងទៀតទៅតាមពេលវេលា ដូចដែលគ្រិស្តបរិសុទ្ធនៅជំនាន់មុខទទួលដែរ។ នៅពេលដែលសមត្ថភាពរបស់យើងកាន់តែរីកចម្រើនឡើង ទ្រង់នឹងបន្តបំពេញយើងឲ្យកើនទៅកម្រិតថ្មីមួយ ជាមួយនឹងភាពពេញបរិបូរណ៍របស់ទ្រង់។ អ្នកជឿបានទទួលការដាស់តឿនយ៉ាងដូច្នេះថា៖ "ត្រូវអោយបានពោរពេញដោយព្រះវិញ្ញាណ។" (គម្ពីរអេភេសូ ៥:១៨) ។ សូមឲ្យយើងប៉ងប្រាថ្នា ថានឹងបាននៅតែពេញដោយព្រះវិញ្ញាណ!

របៀបទីបីដែលយើងអាចមើលទៅលើទំនាក់ទំនងនេះ គឺការនិយាយថា ព្រះវិញ្ញាណបាន*ចាក់បង្ហូរ*មកលើយើងរាល់គ្នា (គម្ពីរយ៉ូអែល ២:២៨-២៩) ។ លោកយ៉ូអែលបាននិយាយអំពីភ្លៀងធ្លាក់នៅសរទរដូវដែលកសិករសាសន៍អ៊ីស្រាអែលទន្ទឹងរង់ចាំយ៉ាងព្រួយចិត្ត ជាភ្លៀងដែលអាចនឹងជួយដំណាំរបស់ពួកគេ

ឲ្យរីកលូតលាស់បានពេញលេញដល់ពេលច្រូតកាត់។ សូមឲ្យយើងមានបំណងចិត្តយ៉ាងឆេះឈួលដូចគ្នានេះ ទៅលើការចាក់បង្ហូរនៃព្រះវិញ្ញាណដ៏វិសុទ្ធមកលើក្រុមជំនុំរបស់យើង និង ជីវិតរបស់យើង ដើម្បីឲ្យយើងអាចបង្កើននូវលទ្ធភាពទាំងអស់ដែលយើងមាន ដើម្បីចែកចាយសិរីរុងរឿងរបស់ព្រះជាម្ចាស់។

គម្ពីរសម្ព័ន្ធមេត្រីថ្មី បង្ហាញថាដើម្បីឲ្យកិច្ចការពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធអាចចាប់ផ្តើមនៅក្នុងជីវិតរបស់យើង ដូចដែលបានបង្ហាញដោយពាក្យដែលខ្ញុំទើបតែបានបង្ហាញខាងលើនេះ យើងត្រូវមានពិសោធដំបូងមួយជាមុនសិន។ គម្ពីរកិច្ចការ ជំពូក២ប្រាប់យើងអំពីការចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធជាលើកដំបូង ដូចនៅការបំពេញសេចក្តីទំនាយរបស់លោកយ៉ូអែល (២:២៨-៣២)។ បទគម្ពីរបានកត់ត្រាអំពីវត្តមានអស់អ្នកដែលបានស្តាប់យល់ពួកសាវ័កនៅពេលដែលពួកគាត់បាននិយាយភាសាផ្សេងៗខុសគ្នា។ ព្រះវិញ្ញាណបានផ្តល់អំណាចឲ្យពួកសាវ័ក និងអ្នកដទៃទៀតបង្ហាញឲ្យឃើញថាពួកគេនិយាយភាសាទាំងនោះ ទោះបីជាពួកគេមិនមែនជាជនជាតិដូចគ្នាក៏ដោយ។ ជាលទ្ធផល អ្នកជឿលើបុណ្យថ្ងៃទីហាសិបជាច្រើននាក់ ជឿថាភស្តុតាងជាក់ស្តែងនៃការជ្រមុជនៅក្នុងព្រះវិញ្ញាណលើកដំបូង គឺជាការនិយាយភាសាដទៃ (ឧទាហរណ៍៖ ភាសាដែលមិនបានមកពីការរៀននេះទេ ប៉ុន្តែបានមកពីការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធវិញ)។ ការឆ្លងកាត់របស់បុគ្គលនៅក្នុងការជ្រមុជនៅក្នុងព្រះវិញ្ញាណជាលើកដំបូងនេះ មិនគួរត្រូវបានចាត់ទុកជាចំណុចកំពូលបំផុត(នៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែជាការចាប់ផ្តើមនៃដំណើររួមជាមួយព្រះវិញ្ញាណវិញ។

ចាប់ផ្តើមពីបទពិសោធន៍ដែលអ្នកជឿបានឆ្លងកាត់នៅក្នុងកំណត់ត្រាគម្ពីរកិច្ចការ យើងដឹងថាបន្ទាប់ពីការជ្រមុជជាលើកដំបូងនោះ (គម្ពីរកិច្ចការ ២) ពួកគេបានទទួលការបំពេញបន្ថែមទៀត (គម្ពីរកិច្ចការ ៤:៣១)។ បន្ទាប់ពីបានចាប់ផ្តើមជីវិតនៅក្នុងព្រះវិញ្ញាណ ពួកគេបានដើរជាមួយទ្រង់ នឹងលូតលាស់ខាងឯវិញ្ញាណ។ ឧទាហរណ៍ ចូរប្រៀបធៀប គម្ពីរ២កូរិនថូស ៣:១៨ គម្ពីររ៉ូម ៨:២៩ និង គម្ពីរ២ពេត្រុស ៣:១៨)។ ទំនាក់ទំនងនេះ គួរតែកាន់តែស្រស់ត្រកាលជារៀងរាល់ថ្ងៃ។ យើងគួរឃើញពីការលូតលាស់ខាងឯវិញ្ញាណដ៏ជាក់ស្តែង កាលដែលពេលវេលាកាន់តែរំកិលទៅមុខ។ បន្ទាប់ពីបានចាប់ផ្តើមកិច្ចការដ៏ល្អជាមួយយើង ព្រះវិញ្ញាណដ៏វិសុទ្ធនឹងបន្តកិច្ចការនេះរហូតដល់ទីបញ្ចប់ ស្របពេលដែលយើងដើរជាមួយទ្រង់ (គម្ពីរភីលីព ១:៦)។

លំហាត់អនុវត្តន៍

៩ ចូរបំពេញប្រយោគខាងក្រោម ដោយបំពេញពាក្យសំគ្តិសមនឹងការរៀបរាប់ ដែលបានផ្តល់ជូននៅខាងក្រោមនេះនៅក្នុងចន្លោះបន្ទាត់ ៖ *ការជ្រមុជ ការបំពេញ ការចាក់បង្ហូរ*

ក) តាមការទតឃើញរបស់ព្រះជាម្ចាស់ ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺចាត់ទុកជា.....។

ខ) អ្នកជឿដែលមិនបានជ្រមុជ ដែលស្វែងរកជំហានដំបូងទៅក្នុងជីវិតជាមួយព្រះវិញ្ញាណ ត្រូវការ.....នៃព្រះវិញ្ញាណ។

គ) កត្តាមួយដែលសំដៅទៅលើសមត្ថភាពរបស់អ្នកសម្រាប់ទទួលព្រះវិញ្ញាណ គឺ..... .....។

និមិត្តសញ្ញារបស់ទ្រង់

វត្ថុបំណងទី៦. *ប្រាប់ពីរបៀបដែលអ្នកអាចយក ផ្នត់គំនិតដែលនិមិត្តសញ្ញានីមួយនៃវិញ្ញាណតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់យើង ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានប្រសើរជាងមុន។*

យើងមិនអាចធ្វើការសន្និដ្ឋានការសិក្សានេះនៅលើគោលលទ្ធិអំពីព្រះវិញ្ញាណដ៏វិសុទ្ធទៅចំពោះអ្នកជឿដោយមិនបាននិយាយអំពីនិមិត្តសញ្ញានៅក្នុងព្រះគម្ពីរដែលរៀបរាប់ពីផ្នែកខ្លះៗនៃកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ។ ចូរបើកមើលខគម្ពីរខាងក្រោមនេះ ដើម្បីឃើញពីរបៀបដែលនិមិត្តសញ្ញាទាំងនេះត្រូវបានគេយកទៅប្រើប្រាស់។

ខគម្ពីរ	**និមិត្តសញ្ញា**	**ការរៀបរាប់**
១. គម្ពីរម៉ាថាយ ៣:១១	ភ្លើង	ភ្លើងដុតកំទេចអ្វីដែលមិនបរិសុទ្ធ
២. គម្ពីរម៉ាថាយ ៣:១៦	សត្វព្រាប	សត្វព្រាបតំណាងឲ្យភាពទន់ភ្លន់
៣. គម្ពីរ១ពង្សាវតារក្សត្រ១៩:១៦ គម្ពីរ១យ៉ូហាន ២:២០	ប្រេងតាំង ការចាក់ប្រេងតាំងដោយព្រះវិញ្ញាណដ៏វិសុទ្ធ	ស្តេច និង ព្យាការីនៅក្នុងសម័ន្ធមេត្រីចាស់តែងតែត្រូវបានចាក់ប្រេងប្រសិទ្ធិពរឲ្យ ជាសញ្ញាសំគាល់អំពីការអនុញ្ញាតរបស់ព្រះអម្ចាស់ក្នុងកិច្ចការរបស់ពួកគេ។
៤. គម្ពីរលូកា ១១:១៣	ព្រះអំណាយទាន	ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះអំណាយទានរបស់ព្រះវរបិតាមកកាន់យើង។
៥. គម្ពីរយ៉ូហាន ៧:៣៧-៣៩	ទន្លេដែលមានទឹកផ្តល់ជីវិត	ព្រះវិញ្ញាណដ៏វិសុទ្ធបំពេញយើងឲ្យបានហូរហៀរជាមួយនឹងជីវិតថ្មី។
៦. គម្ពីរ២កូរិនថូស ១:២២ គម្ពីរអេភេសូ ១:១៣-១៤	ត្រា ឬ ការបញ្ចាំចិត្ត	ព្រះវិញ្ញាណដ៏វិសុទ្ធត្រូវប្រទានមកដើម្បីធានាអំពីជីវិតអស់កល្បជានិច្ចរបស់យើងជាមួយព្រះវរបិតា។
៧. គម្ពីរយ៉ូហាន២០:២២ គម្ពីរអេសេគាល ៣៧:៩, ១៤	ខ្យល់ដង្ហើម ខ្យល់	ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់ដែលប្រទានជីវិតមកឲ្យយើង។

លំហាត់អនុវត្តន៍

១០ ចូរសរសេររៀបរាប់និមិត្តសញ្ញាទាំងអស់ជាចំណុចៗ នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ថ្លែងពីរបៀបដែលអ្នកអាចយកគំនិតសំខាន់ដែលនិមិត្តសញ្ញានីមួយៗតំណាងឲ្យ ទៅប្រើប្រាស់នៅក្នុងជីវិតរបស់អ្នក ដើម្បីឲ្យអ្នកអាចបម្រើព្រះអម្ចាស់បានកាន់តែប្រសើរឡើង។ លំហាត់នេះនឹងជួយអ្នកឲ្យរកឃើញពីសេចក្តីពិតខ្លះ អំពីកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់អ្នក និង អំណរដែលបានមកតាមរយៈទ្រង់។

ទាក់ទងនឹងក្រុមជំនុំ

វត្ថុបំណងទី៧. *រៀបរាប់ពីការផ្តល់អំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ការបម្រើ និង ការឆ្លើយតបរបស់អ្នកជឿទៅនឹងការផ្តល់អំណាចនេះ។*

ការពិភាក្សារបស់យើងអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធ ដឹកនាំពិភពលោកនៃអ្នកមិនជឿ និង អ្នកជឿ ផ្តល់ឲ្យយើងនូវមូលដ្ឋានសម្រាប់ការមើលទៅកាន់ព័ន្ធកិច្ចរបស់ទ្រង់ចំពោះព្រះកាយរបស់ព្រះគ្រិស្ត ទុកជាសមាគម និង ក្រុមមួយ។

នៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ មនុស្សរបស់ព្រះជាម្ចាស់ទទួលបានផលប្រយោជន៍យ៉ាងច្រើន ពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលដែលទ្រង់បានចាត់តាំងមនុស្សដែលត្រូវបានជ្រើសរើសសម្រាប់ការបម្រើជាពិសេស។ ទោះជាយ៉ាងណា នៅក្នុងសម័យសម្ព័ន្ធមេត្រីថ្មី ព័ន្ធកិច្ចនេះគឺកាន់តែបង្ហាញឲ្យឃើញច្បាស់ ដ្បិតព័ន្ធកិច្ចនៅតែបន្តទៅមុខ និង គ្មានការកំណត់សម្រាប់ក្រុមអ្នកជឿពិសេសណាមួយទេ។ សូមមើលពីរបៀប និង មូលហេតុដែលព័ន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជំនាន់សម្ព័ន្ធមេត្រីថ្មី មានភាពខុសគ្នាពីកិច្ចការរបស់ទ្រង់នៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់។

នៅក្នុងព្រឹត្តិការណ៍នៃការជ្រមុជទឹករបស់ព្រះយេស៊ូ លោកយ៉ូហានបាទីស្តបានប្រកាសថាព្រះយេស៊ូជាព្រះដែលនឹងជ្រមុជពួកគេនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរយ៉ូហាន ១:៣៣) ។ ជាលទ្ធផលដែលបានមកពីកិច្ចការប្រោសលោះរបស់ទ្រង់ ព្រះយេស៊ូបានបើកផ្លូវដើម្បីឲ្យអ្នកជឿបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និង ទទួលបានព្រះដ៏ជួយការពារ។ ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាអ្នកតំណាងផ្ទាល់របស់ព្រះយេស៊ូដែលនឹងមកគង់ជាមួយពួកគេជារៀងរហូត (គម្ពីរយ៉ូហា១៤:១៦)។ បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់ទៅពួកសាវ័ករបស់ទ្រង់ថា ពួកគេនឹងត្រូវបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ នៅប៉ុន្មានថ្ងៃទៀត ហើយជាលទ្ធផលពួកគេក៏បានទទួលឫទ្ធានុភាព(គម្ពីរកិច្ចការ១:៥,៨)។

ផ្ទុយពីការចាត់តាំងពិសេសសម្រាប់ការងារជាក់លាស់ណាមួយ ដូចនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ បទពិសោធន៍ថ្មីនៃការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះ គឺជាការផ្តល់អំណាចជាមូលដ្ឋានសម្រាប់អ្នកជឿ ដើម្បីឲ្យមានជីវិត និង ការបម្រើ ដ៏ជាប់លាប់ និង មានប្រសិទ្ធិភាព។ ព្រះវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមិនមែនកម្រិតត្រឹមការសម្រេចកិច្ចការជាក់លាក់ណាមួយ ឬ ឱកាស (ពេលវេលា) ជាក់លាក់ណាមួយ ដូចនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់នោះទេ។ ផ្ទុយទៅវិញ ទ្រង់នឹងគង់នៅជារៀងរហូតនៅ

ក្នុងអស់អ្នកដែលទទួលព្រះគ្រិស្ត (គម្ពីរយ៉ូហាន ៧:៣៨-៣៩; ១៤:១៧)។ លទ្ធផលនៃព្រះវត្តមានដែលគង់នៅក្នុងយើង និង ប្រកបដោយឫទ្ធានុភាពថ្មីនេះ គឺជាការរីកចម្រើនដែលគួរឲ្យគាប់ចិត្តមួយ នៅពេលដែលអ្នកដើរតាមព្រះយេស៊ូ ចែករំលែកជំនឿ និង បទពិសោធន៍របស់គេ ជាមួយអ្នកដទៃ។

ដូច្នេះ ក្នុងបទពិសោធន៍ជាមួយនឹងគម្ពីរសម្ព័ន្ធមេត្រីថ្មី អ្នកជឿអាចទទួលបានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងពួកគេ ផ្តល់អំណាចឲ្យពួកគេដើម្បីរស់នៅក្នុងជីវិតដ៏វិសុទ្ធ និង បម្រើព្រះជាម្ចាស់ដោយស្មគ្រចិត្ត។ ពួកគេលែងចាំបាច់ត្រូវរស់នៅតាមក្រឹត្យវិន័យ (ច្បាប់) ណាមួយដូចនៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ដោយគ្មានការផ្តល់អំណាចដើម្បីបំពេញតាមការកំណត់របស់ច្បាប់នោះទេ មានតែបំណងល្អរបស់ពួកគេតែប៉ុណ្ណោះ។ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងសមជិកក្រុមជំនុំ និង ដឹកនាំសកម្មភាពរួមគ្នារបស់ពួកគេ នោះពួកគេមានសមត្ថភាពក្នុងការធ្វើកិច្ចការ និង ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅលើផែនដី។

លំហាត់អនុវត្តន៍

---

១១ ចូរផ្គូផ្គងកាលបរិច្ឆេទ (ខាងស្តាំ) ទៅជាមួយនឹងការរៀបរាប់អំពីសកម្មភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់មនុស្ស (ខាងឆ្វេង)។ លំហាត់នេះនឹងជួយឲ្យអ្នកបានឃើញពីភាពខុសគ្នារវាងសកម្មភាពរបស់ព្រះវិញ្ញាណនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី។

.....ក) ការគង់នៅសម្រាប់ព័ន្ធកិច្ចណាមួយ បន្ទាប់មកក៏ត្រូវបានដកចេញ។

.....ខ) ការគង់នៅក្នុងអស់អ្នកណាដែលទទួលព្រះគ្រិស្ត។

.....គ) ព្រះវត្តមានរបស់ទ្រង់គឺស្ថិតនៅខាងក្នុង និង មានលក្ខណៈបុគ្គល

.....ឃ) ព្រះវត្តមានរបស់ទ្រង់ស្ថិតនៅខាងក្រៅ និង គ្មានលក្ខណៈជាបុគ្គល

.....ង) មនុស្សដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណតាមរយៈការទទួលទ្រង់។

.....ច) ការចាក់ប្រេងតាំងមនុស្សណាម្នាក់ទៅតាមពេលវេលាណាមួយ និងសម្រាប់មូលហេតុពិសេស

១) គម្ពីរសម្ព័ន្ធមេត្រីចាស់

២) គម្ពីរសម្ព័ន្ធមេត្រីថ្មី។

អ្នកដើរតាមព្រះយេស៊ូមិនត្រឹមតែទទួលបានអំណាច ឲ្យធ្វើ*សក្ខីភាព* យ៉ាងមានប្រសិទ្ធិភាពប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ទទួលបានកម្លាំងប្រកបដោយភាពជោគជ័យ ដើម្បី*ការពារ* ដំណឹងល្អ។ នេះគឺជាការសម្រេចបានដោយផ្ទាល់នៃគម្ពីរម៉ាកុស១៣:៩-១១។ ដំបូងឡើយ លោកពេត្រុសគ្មានកម្លាំងដើម្បីការពារទំនាក់ទំនងរបស់លោកជាមួយព្រះយេស៊ូនោះទេ (គម្ពីរម៉ាថាយ ២៦:៦៩-៧៥)។ ទោះជាយ៉ាងណា

បន្ទាប់ពីមានបទពិសោធន៍ពិសេសៗជាច្រើនលើក រួមបញ្ចូលទាំងបានឃើញការមានព្រះជន្មរស់របស់ព្រះយេស៊ូ និង ការបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងបុណ្យថ្ងៃទីហាសិប លោកបានទទួលភាពក្លាហានក្នុងការចែកចាយ (គម្ពីរកិច្ចការ ២) និង ភាពក្លាហានក្នុងការផ្តល់ហេតុផលការពារជំនឿរបស់លោក (គម្ពីរកិច្ចការ ៤:៨-២០)។

លើសពីនេះទៅទៀត ព្រះវិញ្ញាណដ៏វិសុទ្ធបានគ្រប់គ្រងបេសកម្មនៃការផ្សាយដំណឹងល្អ របស់ក្រុមជំនុំ ប្រាប់អ្នកបម្រើរបស់ទ្រង់ថា កន្លែងដែលត្រូវទៅ និង កន្លែងណាមិនត្រូវទៅ (គម្ពីរកិច្ចការ ១៣:២; ១៦:៦-៧)។ តាមរយៈការដឹកនាំរបស់ទ្រង់ គ្រិស្តបរិស័ទដំបូង បានទៅដល់តំបន់សំខាន់ៗ ដែលបានក្លាយជាកន្លែងមិនអាចខ្វះបាននៅក្នុងការបន្តបេសកម្មរបស់ក្រុមជំនុំ គឺការចែកចាយដំណឹងល្អទៅដល់ "មនុស្សលោកទាំងអស់" (គម្ពីរម៉ាកុស ១៦:១៥)។ នៅក្នុងបេសកម្មផ្សាយដំណឹងល្អលើកទីមួយ របស់ក្រុមជំនុំ ព្រះវិញ្ញាណដ៏វិសុទ្ធបានញែកលោកប៉ូល និង លោកបារណាបាស សម្រាប់ការបម្រើ និង ចាត់តាំងពួកលោកសម្រាប់ព័ន្ធកិច្ច (គម្ពីរកិច្ចការ ១៣:២)។

ព្រះវិញ្ញាណដ៏វិសុទ្ធ ក៏បានដឹកនាំនៅក្នុងកិច្ចការគ្រប់គ្រងពិតជាក់ស្តែងរបស់ក្រុមជំនុំដែរ។ នៅពេលដែលក្រុមជំនុំបានលូតលាស់ និង បានឆ្លងកាត់ដែនកំណត់របស់ជាតិសាសន៍ វប្បធម៌ និង សាសន៍ សំណួរជាច្រើនត្រូវបានលើកឡើងដែលទាមទារចម្លើយដែលស្របទៅតាមបទគម្ពីរ និង សេចក្តីស្រឡាញ់របស់គ្រិស្តបរិស័ទ។ ការប្រកាន់ពូជសាសន៍របស់មនុស្សលោក បានគំរាមកំហែងបែងចែកព្រះកាយរបស់ព្រះគ្រិស្ត ប៉ុន្តែដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្តល់អំណាចឲ្យលោកយ៉ាកុប និង ពួកសាវ័កដើម្បីដោះស្រាយបញ្ហាលំបាក និង ដើម្បីផ្តល់ការប្រឹក្សាដ៏ឈ្លាសវៃ (គម្ពីរកិច្ចការ ១៥:២៨-២៩)។ ការនេះបានអនុញ្ញាតឲ្យក្រុមជំនុំលូតលាស់ កាន់តែលឿន និង បង្កើតបានជាការរួបរួមខាងឯវិញ្ញាណមួយ។

តាមរយៈការដឹកនាំបន្តបន្ទាប់របស់ទ្រង់ ព្រះវិញ្ញាណដ៏វិសុទ្ធបាននាំលោកប៉ូល និង អ្នកដទៃទៀតឲ្យផ្តល់ការលើកទឹកចិត្ត ការកំសាន្តចិត្ត សេចក្តីបង្រៀនពីគោលលទ្ធិ ការព្រមាន និង ការដាក់បញ្ញត្តិទៅដល់ក្រុមជំនុំតាមរយៈសំបុត្រដែលមានការជំរុញពីព្រះវិញ្ញាណ។ ឧទាហរណ៍ លោកប៉ូលបានដោះស្រាយជាមួយនឹងសំណួរពិសេសអំពីតរិយាបថនៅក្នុងក្រុមជំនុំក្រុងកូរិនថូស ទាក់ទងនឹងទំនួលខុសត្រូវនៅក្នុងសង្គម (គម្ពីរ១កូរិនថូស ៧:៤០)។ អ្នកសរសេរសំបុត្រទៅកាន់សាសន៍ហេប្រឺបានបកស្រាយពីវិន័យ ថាជាដំណើរការនៅការលូតលាស់ ដែលតាមរយៈការលូតលាស់នេះព្រះជាម្ចាស់ដឹកនាំអ្នកជឿឆ្ពោះទៅភាពពេញវ័យខាងឯវិញ្ញាណរបស់ពួកគេ (គម្ពីរហេប្រឺ ១២:៤-១១)។

នៅក្នុងដំណើរការធំពេញវ័យ ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអ្នកគ្រប់គ្រងប្រកបដោយប្រាជ្ញាញាណ ទ្រង់បានបំពាក់បំប៉នអ្នកជឿជាមួយនឹងព្រះអំណោយទានដែលចាំបាច់នៅក្នុងការធ្វើតាមតួនាទីរបស់ពួកគេ នៅក្នុងពិភពលោក និងនៅក្នុងក្រុមជំនុំដែលជាព្រះកាយរបស់ព្រះគ្រិស្ត។ (ចូរប្រៀបធៀប គម្ពីរ៉ូម ១២:៤-៨ គម្ពីរ១កូរិនថូស១២:១-២៨ និង គម្ពីរអេភេសូ ៤:១១-១៦)។ លោកប៉ូលមានប្រសាសន៍ថា៖ "មានសកម្មភាពផ្សេងៗពីគ្នា តែមានព្រះជាម្ចាស់តែមួយព្រះអង្គទេ ដែលបំពេញសកម្មភាពទាំងនោះ នៅក្នុងមនុស្សទាំងអស់។ ព្រះវិញ្ញាណប្រោសប្រទានអោយម្នាក់ៗសំដែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម" (គម្ពីរ១កូរិនថូស ១២:៦-៧)។

ដូច្នេះព្រះវិញ្ញាណដ៏វិសុទ្ធប្រទានកម្លាំងទាំងនេះទៅកាន់អ្នកជឿ៖

១. ឫទ្ធានុភាពដើម្បីផ្សព្វផ្សាយដំណឹងល្អ។
២. ប្រាជ្ញាញាណ និង កម្លាំងចិត្តដែលចាំបាច់ក្នុងការការពារជំនឿ
៣. ព្រះអំណាយទានសមរម្យដើម្បីបម្រើព្រះកាយរបស់ព្រះគ្រិស្តទាំងមូល និង សម្រាប់សមាជិកម្នាក់ៗផងដែរ។
៤. ការដឹកនាំរបស់មនុស្ស ដើម្បីដឹកនាំកិច្ចការបម្រើ
៥. និមិត្ត និង ការជំរុញចិត្តដែលចាំបាច់ក្នុងការបំពេញតាមមហាបេសកកម្ម។

លំហាត់អនុវត្តន៍

១២ ចូរផ្គូផ្គងសេចក្តីរៀបរាប់អំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណ (ខាងស្តាំ) ទៅជាមួយនឹងការឆ្លើយតបដែលស័ក្តិសមនឹងសេចក្តីរៀបរាប់នោះ (ខាងឆ្វេង)។

.....ក) អ្នកជឿបានដឹង និង មានបំណងចិត្ត សម្រាប់ឱកាសដើម្បីឈោងចាប់អ្នកមិនទាន់ជឿ។

.....ខ) អ្នកជឿនៅក្នុងក្រុមជំនុំបំពេញតួនាទីដូចជាខ្លួនមួយ ដែលម្នាក់បំពេញព័ន្ធកិច្ចបម្រើពិសេសរៀងៗខ្លួន។

.....គ) អ្នកជឿទទួលបានអំណាចដើម្បីការពារដំណឹងល្អ។

.....ឃ) អ្នកជឿពឹងផ្អែកលើខគម្ពីរ និង ការអធិស្ឋាននៅពេលពួកគេប្រឈមមុខជាមួយនឹងការលំបាក និង ការសម្រេចចិត្ត។

១) ជះឥទ្ធិពលទៅលើឫទ្ធានុភាពចម្បងសម្រាប់ជីវិត និងការបម្រើ។
២) ការប្រទានព្រះអំណោយទាន
៣) ការប្រទាននិមិត្ត និង ការដឹកនាំ
៤) ការដោះស្រាយបញ្ហា
៥) ការប្រទានប្រាជ្ញា និងសេចក្តីក្លាហាន

តើអ្នកឃើញដែរឬទេថា យើងត្រូវពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធខ្លាំងប៉ុនណា នៅលើជីវិតខាងឯវិញ្ញាណ កម្លាំង និមិត្ត ប្រសិទ្ធិភាពនៅក្នុងការបម្រើ ជំនួយនៅពេលជួយការល្បួងល និង ការធ្វើការសម្រាប់ជ័យជំនះ និង ភាពពេញវ័យផ្ទាល់ខ្លួនរបស់យើង? ចូរថ្វាយបង្គំព្រះវិញ្ញាណដ៏វិសុទ្ធ ។ ចូរស្រឡាញ់ព្រះវត្តមានរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។ ចូរមានបំណងចិត្តដើម្បីលូតលាស់ និង អភិវឌ្ឍខ្លួនឲ្យទៅជាមនុស្សខាងឯវិញ្ញាណ ដូចដែលទ្រង់សព្វព្រះហឫទ័យសម្រាប់អ្នក។ សូមឲ្យអ្នកតែងតែដឹងជានិច្ចអំពីវត្តមាននៃបុគ្គលខាងឯវិញ្ញាណដែលបានកើតឡើងនៅក្នុងអ្នក ។ សូមឆាប់ទទួលអារម្មណ៍ដឹងពីសម្លេងនៃអង្គបុគ្គលនេះ ឮពីការអង្វររបស់ទ្រង់ ការកែតម្រូវរបស់ទ្រង់ និង ការក្រើនរំលឹកពីទ្រង់។ សូមឲ្យគ្រប់គំនិត ការសន្ទាន និង ទង្វើទាំងអស់របស់អ្នកបានឆ្លុះបញ្ចាំងពីការដឹងនៅក្នុងចិត្តរបស់អ្នក អំពីហានៈនៃការដឹកនាំរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក។ បន្ទាប់មកមាគ៌ារបស់អ្នក នឹងក្លាយជាការរីកចម្រើនខាងឯវិញ្ញាណ ហើយជីវិតរបស់អ្នកនឹងបានជោគជ័យពិតៗ។

ការប្រឡងផ្ទាល់ខ្លួន

ត្រូវ/ខុស។ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគណាត្រឹមត្រូវ។ ប្រសិនបើប្រយោគមិនត្រឹមត្រូវ ចូរសរសេរអក្សរ ខ។

.....១ លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ មានដូចជា ភាពអស់កល្បជានិច្ច សព្វានុភាព សព្វដ្ឋភាព(សព្វត្ថិភាព) និង សព្វញ្ញុតភាព ក៏អាចយកទៅប្រើប្រាស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធបានដែរ។

.....២ ដូចដែលបានប្រើនៅក្នុងសំណេររបស់លោកប៉ុល ពាក្យថា*ព្រះអម្ចាស់*ដែលនិយាយសំដៅទៅលើព្រះជាម្ចាស់តែមួយគត់ គឺត្រូវបានប្រើប្រាស់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។

.....៣ ការប្រសិទ្ធិពររបស់ពួកសាវ័ក និង រូបមន្តសម្រាប់ការជ្រមុជ បង្ហាញពីគុណសម្បត្តិដ៏សំខាន់របស់អង្គព្រះនៅក្នុងព្រះត្រៃឯក។

.....៤ យោងតាមនិស្ស័យ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះ គ្មានភាពជាបុគ្គល ដែលមានលក្ខណៈសម្បត្តិដូចជាខ្យល់។

.....៥ ទង្វើជាបុគ្គល ព្រះនាមជាបុគ្គល ការទាក់ទងជាបុគ្គល សព្វនាមជាបុគ្គល និង ការទទួលទង្វើបែបបុគ្គល គឺជាសមាសភាគ ដែលបញ្ជាក់ប្រាប់យ៉ាងច្បាស់ថា ព្រះវិញ្ញាណដ៏វិសុទ្ធមានបុគ្គលិកលក្ខណៈ។

.....៦ ដោយយើងរាល់គ្នាមានកំណត់ ហើយព្រះវិញ្ញាណដ៏វិសុទ្ធគ្មានដែនកំណត់ យើងមិនអាចយល់អ្វីសោះអំពីបុគ្គលិកលក្ខណៈ និង កិច្ចការរបស់ទ្រង់។

.....៧ ព្រះវិញ្ញាណដ៏វិសុទ្ធមិនទាក់ទងជាមួយភាពមិនវិសុទ្ធ និង មនុស្សមានបាបនោះទេ។

.....៨ អ្នកជឿទទួលបានជំនួយពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈការទូលអង្វរជំនួសរបស់ទ្រង់សម្រាប់ពួកគេ។

.....៩ លោកពេត្រុសបានបង្រៀនថា បទពិសោធន៍ផ្ទាល់ខ្លួនរបស់នរណាម្នាក់គឺ អាចទុកចិត្តនៅក្នុងការដឹកនាំជំនឿ និង ការអនុវត្ត ជាជាងព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅទៀត។

.....១០ ភាពខុសគ្នាធំបំផុតរវាង ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណនៅក្នុងជំនាន់អ៊ីស្រាអែលសម័ន្ធមេត្រីចាស់ និង នៅក្នុងក្រុមជំនុំសម័ន្ធមេត្រីថ្មី គឺថា ទ្រង់បានគង់នៅក្នុងអ្នកជឿនៃសម័ន្ធមេត្រីថ្មី។

.....១១ ព័ន្ធកិច្ចរបស់ព្រះវិញ្ញាណគឺ កំណត់នៅត្រឹមការនាំយកដំណឹងល្អទៅកាន់មនុស្ស និង ការពារដំណឹងល្អនៅចំពោះមុខរាជរដ្ឋាភិបាល។

.....១២ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាអ្នកគ្រប់គ្រងដ៏គួរឲ្យទុកចិត្តនៅក្នុងស្ថានភាពដែលមានបញ្ហា។

.....១៣ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធ អាចដឹកនាំអ្នកជឿឆ្ពោះទៅ ជ័យជំនះលើនិស្ស័យបាបរបស់ពួកគេ អ្នកជឿទាំងនោះបានកាន់តែដូចព្រះអម្ចាស់របស់ពួកគេ។

.....១៤ ជីវិតនៅក្នុងព្រះវិញ្ញាណចាប់ផ្តើមនៅពេលដែលយើងបានពេញដោយព្រះវិញ្ញាណ។

.....១៥ នៅពេលដែលអ្នកជឿទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណ ពួកគេបានចូលទៅដល់ភាពពេញវ័យបរិបូរណ៌ខាងឯវិញ្ញាណ។

.....១៦ ការជ្រមុជនៅក្នុងព្រះវិញ្ញាណ គឺជាគ្រិះមូលដ្ឋាននៃជីវិត និង ការលូតលាស់ផ្លែងឆ្ងាយទៅមុខនៅក្នុងព្រះវិញ្ញាណ។

.....១៧ ព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវបានប្រទានមកកាន់ពួកយើង ទុកជាការធានានៃជីវិតអស់កល្បជានិច្ចជាមួយព្រះវរបិតា។

.....១៨ ការអភិសេកដោយប្រេង ជាការតំណាងឲ្យភាពបរិសុទ្ធរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

.....១៩ ការជ្រមុជនៅក្នុងព្រះវិញ្ញាណគឺប្រៀបបានទៅនឹងទន្លេនៃទឹកដែលផ្តល់ជីវិត នៅក្នុងបទគម្ពីរ។

.....២០ ការគង់នៅរបស់ព្រះវិញ្ញាណ គឺការធានាថា អ្នកជឿនឹងបានវិសុទ្ធ និង មានប្រសិទ្ធិភាពជានិច្ច។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ក) ៤) ភាពអស់កល្បជានិច្ច

ខ) ៣) សព្វដ្ឋភាព(សព្វត្ថិភាព)

គ) ១) សព្វានុភាព

ឃ) ២) សព្វញ្ញុតភាព

៧ ចម្លើយ ក) គ) និង ឃ) ជាចម្លើយត្រឹមត្រូវ។ ចម្លើយខ) គឺចម្លើយខុស។ (តាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់គ្រិស្ត ទ្រង់បានយកឈ្នះលើសាតាំង។)

២ ចម្លើយ ក) គ) និង ឃ) គឺជាភស្តុតាងអំពីភាពជាព្រះរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
ចម្លើយ ខ) មិនមែនជាភស្តុតាងបញ្ជាក់ភាពជាព្រះរបស់ទ្រង់នោះទេ ។ ពាក្យថា *ព្រះដ៏ជួយការពារ* គឺជាការរៀបរាប់អំពីតួនាទីមួយនៅក្នុងចំណោមតួនាទីជាច្រើនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

៨ ចម្លើយរបស់អ្នក គួរតែស្រដៀងចម្លើយខាងក្រោមនេះ៖

ក) តាមរយៈការកើតជាថ្មី ព្រះវិញ្ញាណដ៏វិសុទ្ធ នាំយើងចូលទៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់។

ខ) ទ្រង់ប្រទានឫទ្ធានុភាពឲ្យយើងដើម្បីធ្វើសក្ខីភាព។

គ) ទ្រង់បង្រៀនយើង។

ឃ) ទ្រង់អធិស្ឋានទៅកាន់ព្រះវរបិតាជំនួសយើង (ទូលអង្វរសម្រាប់យើង)។

ង) នៅពេលយើងអនុញ្ញាត ទ្រង់នឹងដឹកនាំយើងឆ្ពោះទៅកាន់ភាពជោគជ័យ និង ជីវិតដូចជាព្រះគ្រិស្ត។

ច) ទ្រង់បង្កើតផលផ្លែនៃព្រះវិញ្ញាណ (លក្ខណសម្បត្តិដូចជាព្រះគ្រិស្ត) នៅក្នុងយើង នៅពេលដែលយើងថ្វាយការគ្រប់គ្រងលើជីវិតរបស់យើងទៅដល់ទ្រង់។

៣ ក) ២) កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅលើផែនដី។

ខ) ៣) អធិបតេយ្យរបស់ព្រះជាម្ចាស់

គ) ៤) ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ

ឃ) ១) ពហុភាពនៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញនៅក្នុងការបង្កើតរបស់សព្វសារពើ

ង) ៤) ភាពស្មើគ្នានៃអង្គព្រះនៅក្នុងព្រះត្រៃឯកភាពពេញលេញ

៩ ក) ការចាក់បង្ហូរ

ខ) ការជ្រមុជ

គ) ការបំពេញ

៤ ក) ៣) បំណងព្រះហឫទ័យ

ខ) ១) សតិបញ្ញា

គ) ២) វេទយិតភាព

១០ ចម្លើយរបស់អ្នកអាចស្រដៀងនឹងចម្លើយរបស់ខ្ញុំ៖

ភ្លើង៖ ព្រះវិញ្ញាណដ៏វិសុទ្ធបន្សុទ្ធខ្ញុំ

សត្វព្រាប៖ ទ្រង់ដឹកនាំខ្ញុំដោយក្តីទន់ភ្លន់

ប្រេងតាំង៖ ព្រះវិញ្ញាណចាត់តាំងខ្ញុំសម្រាប់ការបម្រើដោយមានប្រសិទ្ធិភាព។

ព្រះអំណោយទាន៖ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះអំណោយទានរបស់ព្រះវរបិតាសម្រាប់ខ្ញុំ។

ទឹកដែលផ្តល់ជីវិត៖ ទ្រង់បំពេញខ្ញុំឲ្យបានពេញហូរហៀរ ទ្រង់ផ្តល់ជីវិតឲ្យខ្ញុំ។

ក្រា ឬ ការបញ្ចាំចិត្ត៖ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាការធានារបស់ព្រះជាម្ចាស់មកកាន់ខ្ញុំថា ខ្ញុំនឹងទទួលព្រះរាជ្យដ៏អស់កល្បរួមជាមួយទ្រង់។

ខ្យល់ដង្ហើម និង ខ្យល់៖ ព្រះវិញ្ញាណដ៏វិសុទ្ធប្រទាន (ដង្ហើមនៅក្នុងខ្ញុំ) ជីវិតអស់កល្បជានិច្ច។

៥ សកម្មភាពទាំងនេះបង្ហាញថាទ្រង់បានធ្វើសកម្មភាព ដែលមានតែភាវៈមានភាពជាបុគ្គលតែប៉ុណ្ណោះអាចធ្វើបាន ហើយមិនអាចធ្វើឡើងដោយកម្លាំងអបុគ្គលនោះទេ។ ដូច្នេះហើយ សកម្មភាពទាំងនេះចង្អុលបង្ហាញពី*ភាពជាបុគ្គល*របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

១១ ក) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

ខ) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

គ) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

ឃ) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

ង) ២) គម្ពីរសម្ព័ន្ធមេត្រីថ្មី

ច) ១) គម្ពីរសម្ព័ន្ធមេត្រីចាស់

៦ អ្នកគួរតែបានគូសរង្វង់ជុំវិញចម្លើយទាំងអស់លើកលែងតែចម្លើយ គ) កម្លាំងអបុគ្គល និង ឆ) វា, ចម្លើយទាំងពីរនេះមិនអាចប្រើជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធបានឡើយ។

១២ ក) ៣) ការប្រទាននិមិត្ត និង ការដឹកនាំ

ខ) ២) ការប្រទានព្រះអំណោយទាន

គ) ១) ជះឥទ្ធិពលទៅលើឫទ្ធានុភាពចម្បងសម្រាប់ជីវិត និង ការបម្រើ។

ឃ) ៥) ការប្រទានប្រាជ្ញា និង សេចក្តីក្លាហាន

ង) ៤) ការដោះស្រាយបញ្ហា

ការប្រឡងជំពូកទីមួយ

ពេលនេះ ដោយអ្នកបានបញ្ចប់ជំពូកទីមួយ ជាស្តាពរ អ្នកអាចឆ្លើយសំណួរ*ការប្រឡងតាមជំពូក*បានហើយ។ សូមរំឭកមេរៀនកន្លងមកឡើងវិញ មុនពេលដែលអ្នកចាប់ផ្តើម។ សូមធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ ដើម្បីសម្រេចការប្រឡងនេះ ហើយសូមបន្តទៅជំពូកទីពីរទៀត។

ជំពូកទី ពីរ :
ប្រធានបទអំពីព្រះជាម្ចាស់

<u>មេរៀន</u>

៥. ទេវតា៖ កងទ័ពនៃភាពងងឹត និង កងទ័ពនៃពន្លឺ

៦. មនុស្សជាតិ ៖ អនុរាស្ត្រនៃព្រះអាទិករ

៧. អំពើបាប និង សេចក្តីសង្គ្រោះ៖ បញ្ហា និង ដំណោះស្រាយ

មេរៀនទី ៥ ទេវតា៖ កងទ័ពនៃភាពងងឹត និង កងទ័ពនៃពន្លឺ

ថ្ងៃមួយខ្ញុំបានភ្ញាក់ឡើងដោយសូរសម្លេងគ្រាប់កាំភ្លើង នៅពេលដែលកងទ័ពសត្រូវធ្វើការវាយប្រហារនៅក្បែរផ្ទះរបស់ខ្ញុំ។ ប្រពន្ធរបស់ខ្ញុំ និង គ្រួសារបានស្វែងរកកន្លែងជ្រក នៅពេលមានយន្តហោះទំលាក់គ្រាប់បែកបានហោះនៅពីលើយើង។ ខ្ញុំបានឃើញទាហានដណ្តើមអាហារពីប្រជាជនស្លូតត្រង់ ។ ខ្ញុំស្អប់សង្គ្រាមណាស់!

តើអ្នកគ្រប់គ្រងដ៏ល្អ និង ឈ្លាសវៃម្នាក់គួរធ្វើអ្វី នៅពេលមានការវាយប្រហារ ពីសំណាក់ខ្មាំងសត្រូវ? ប្រសិនបើពួកគេ ពិតជាខ្វល់ខ្វាយចំពោះប្រជាជនរបស់ពួកគេ និង មាគ៌ាជីវិតដែលពួកគេបានថែរក្សា ពួកគេ*ត្រូវតែ* តតាំងជាមួយនឹងខ្មាំងសត្រូវ។ ពួកគេដឹងពីអ្វីដែលនឹងកើតឡើង ប្រសិនបើខ្មាំងសត្រូវយកឈ្នះលើពួកគេ!

បើគំនិតមួយ នេះគឺជាស្ថានភាពនៅក្នុងពិភពខាងឯវិញ្ញាណ។ កម្លាំងខាងឯវិញ្ញាណដ៏កំណាចរបស់សាតាំង តែងតែរកមធ្យោបាយបំផ្លាញ រនាំងការពាររបស់យើង ហើយសម្លាប់យើងផ្នែកខាងឯវិញ្ញាណ។ យើងនៅមានសុវត្ថិភាព ដរាបណាយើងនៅតែទុកចិត្តលើព្រះជាម្ចាស់។ កម្លាំងខាងឯវិញ្ញាណដ៏អស្ចារ្យរបស់ទ្រង់ ផ្តល់ឲ្យយើងនូវការជំនួយ នៅក្នុងការតតាំងជាមួយអារក្ស ដែលជាខ្មាំងសត្រូវរបស់យើងនោះ។ ដូច្នេះសង្គ្រាមខាងឯវិញ្ញាណ បង្កើតបានជាមូលដ្ឋានគ្រឹះផ្ទុយនឹងអ្វីដែលយើងសិក្សាអំពីទេវតា។

នៅក្នុងជំពូកទី១ យើងបានរៀនអំពីព្រះជាម្ចាស់ និង ការគ្រប់គ្រងជាអធិបតី របស់ទ្រង់នៅក្នុងសាកលលោកនេះហើយ។ ឥឡូវនេះយើង ងាកទៅរកអនុរាស្ត្រដែលស្ថិតក្រោមការគ្រប់គ្រងដ៏ខ្ពស់បំផុតរបស់ទ្រង់ គឺទេវតា មនុស្ស និង បញ្ហានៃអំពើបាបវិញម្តង។ នៅក្នុងមេរៀនទាំងបីបន្ទាប់នេះ យើងនឹងមិនត្រឹមតែបានឃើញពីមូលហេតុនៃអំពើបាបនោះទេ ប៉ុន្តែយើងក៏បានឃើញពីផលវិបាកដ៏ធំធេងរបស់អំពើបាបទៅលើអនុរាស្ត្រទាំងអស់របស់ព្រះជាម្ចាស់ផងដែរ។

ក្នុងពេលដែលយើងសិក្សាមេរៀននេះ អំពីព្រះមហាក្សត្រ និង កម្លាំងនៃទេវតា ដែលទ្រង់អាចប្រើតាមបំណងព្រះទ័យរបស់ទ្រង់ ខ្ញុំសូមអធិស្ឋានឲ្យអ្នកបាន យល់ដឹកកាន់តែច្បាស់ថែមទៀតនៅពេលដែលអ្នកដឹងថា ទ្រង់កំពុងតែដឹកនាំមនុស្សដែលទទួលបានការជ្រោសលោះជាច្រើននាក់ ឆ្ពោះទៅកាន់ជ័យជម្នះចុងក្រោយបំផុត។

គោលបំណងមេរៀន

ក. និស្ស័យរបស់ទេវតា

ខ. លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា

គ. ចំនួនរបស់ទេវតា

ឃ. ការរៀបចំនិងសកម្មភាពរបស់ទេវតា

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់ពីដើមកំណើត និង លក្ខណសម្បត្តិរបស់ទេវតា។

២. រៀបរាប់ពី លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា ដោយប្រើប្រាស់ខគម្ពីរធ្វើជាមូលដ្ឋាន។

៣. សង្ខេបសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងចំនួនរបស់ទេវតា។

៤. បង្ហាញភស្តុតាងនៃ សកម្មភាពដែលបានរៀបរបស់ចំពូកទេវតាដ៏វិសុទ្ធ។

៥. រៀបរាប់អំពីសកម្មភាព និង វាសនាពួកទេវតាមិនវិសុទ្ធ និង អ្នកដឹកនាំរបស់ពួកគេ។

សកម្មភាពនៅក្នុងការសិក្សា

១. សម្រាប់គ្រឹះមូលដ្ឋាននៃមេរៀននេះ ចូរអានគម្ពីរអេភេសូ ៦:១០-១៨ គម្ពីរ២ពេត្រុស ២:១-២២ និង គម្ពីរយូដាស។

២. ការសិក្សាមេរៀនដោយផ្អែកទៅលើក្បួនដែលបានផ្តល់ជូននៅក្នុងមេរៀនទី១។ មានខគម្ពីរយោងច្រើន ដែលមានសារៈសំខាន់ដើម្បីស្វែងយល់អំពីមេរៀននេះ ។ ត្រូវតែធ្វើឲ្យប្រាកដថា អ្នកបានអានខគម្ពីរយោងទាំងអស់នោះ ហើយឆ្លើយនឹងសំណួរនៅក្នុងមេរៀនទាំងអស់។ បន្ទាប់មកធ្វើការប្រឡងផ្ទាល់ខ្លួនដូចធម្មតា។

ពាក្យសំខាន់ៗ

បច្ចាមិត្ត	កំណាច	សមហេតុផល
ភ្នាក់ងារ	មហន្តរាយ	អាណាចក្រ
ទទួលយក	ការសរសើរតម្កើង	ការបះបោរ
ឋានអាទិទេព	ក្លែងខ្លួន	អនុរាស្ត្រ
អះអាងបញ្ជាក់	ការអន្តរាគមន៍	កំពូលមនុស្ស
ជោគវាសនា	ការពិសោធន៍មើល	

ក. និស្ស័យរបស់ទេវតា

អ្នកនិពន្ធគម្ពីរហេប្រឺបានណែនាំយ៉ាងដូច្នេះថា៖ "សូមកុំភ្លេចទទួលអ្នកដទៃយ៉ាងរាក់ទាក់។ ដោយទទួលអ្នកដទៃដូច្នេះ អ្នកខ្លះបានទទួលទេវតា*ទាំងមិនដឹងខ្លួន។" (គម្ពីរហេប្រឺ ១៣:២)។

នៅក្នុងការនិយាយអំពីទេវតាត្រង់នេះ យើងឃើញអ្វីម្យ៉ាងអំពីនិស្ស័យរបស់ពួកគេ ដ្បិតពួកគេគឺអស្ចារ្យណាស់។ ដោយសារតែភាពមិនធម្មតារបស់ពួកគេនេះហើយ ទើបធ្វើឲ្យមានអាថ៌កំបាំងជាច្រើនដែលទាក់ទងនឹងពួកគេ។ ការពិតមួយនេះត្រូវបានបង្ហាញម្តងហើយម្តងទៀតទាំងនៅក្នុងបទគម្ពីរសម្ព័ន្ធមេត្រីចាស់ និង គម្ពីរសម្ព័ន្ធមេត្រីថ្មី។

យើងមិនអាចអានបទគម្ពីរដោយគ្មានការសង្កេតឃើញថា ខគម្ពីរទាំងនោះបានគាំទ្រអត្ថិភាពរបស់ពួកទេវតា។ តើយើងអាចដឹងអ្វីខ្លះពីព្រះគម្ពីរទាក់ទងនឹងពួកទេវតា? តើពួកគេមានដើមកំណើតមកពីណា? តើពួកគេមានលក្ខណសម្បត្តិយ៉ាងដូច្នេះ? ការស្វែងរកចម្លើយសម្រាប់សំណួរទាំងនេះ នឹងជួយឲ្យយើងបានយល់បន្ថែមទៀតអំពីគោលបំណងសម្រាប់ពួកទេវតា និង សារៈសំខាន់របស់ពួកគេនៅក្នុងជីវិតរបស់យើង។ ចូរសិក្សាអំពីការពិតខ្លះៗដែលព្រះគម្ពីរបានលើកឡើង ទាក់ទងនឹងដើមកំណើត (ការចាប់ផ្តើម) និង លក្ខណសម្បត្តិរបស់ពួកទេវតា។

ដើមកំណើតរបស់ពួកគេ

វត្ថុបំណងទី១. *ប្រាប់ពីដើមកំណើត និង លក្ខណសម្បត្តិរបស់ទេវតា។*

តើទេវតាគឺជាអ្វី? ពួកទេវតាគឺជាចំណែកមួយ ឬ ក្រុមមានដែនកំណត់មួយ នៃភាវៈដែលត្រូវបានបង្កើតឡើងឲ្យធ្វើជាអ្នកនាំសារ ឬ អ្នកបម្រើរបស់ព្រះជាម្ចាស់។ ពួកគេមានសតិបញ្ញា និង ឫទ្ធានុភាពអស្ចារ្យជាងមនុស្ស។ មានទេវតាខ្លះបម្រើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងរបៀបវិជ្ជមានមួយតាមរយៈពួកវិសុទ្ធរបស់ពួកគេ និង ដោយស្ម័គ្រចិត្តធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ចំណែកឯពួកទេវតាខ្លះទៀត ដែលបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ជាលទ្ធផលពួកគេបានដាច់ចេញពីព្រះជាម្ចាស់ជារៀងរហូត។ ការដាច់ចេញអស់កល្បជានិច្ចពីព្រះជាម្ចាស់ បង្ហាញយ៉ាងច្បាស់ពីព្រះគុណរបស់ព្រះជាម្ចាស់ចំពោះមនុស្សជាតិមានបាប ដែលទទួលបានការសង្គ្រោះតាមរយៈព្រះគ្រិស្ត។

ពាក្យថា*ទេវតា* តាមភាសាព្រះគម្ពីរដើមដំបូងបង្អស់ គឺមានន័យថា *អ្នកនាំសារ* ។ ពេលខ្លះពាក្យថា *អ្នកនាំសារ* ត្រូវបានគេប្រើប្រាស់ដើម្បីនិយាយសំដៅទៅលើ មនុស្ស (បូជាចារ្យម្នាក់នៅក្នុងគម្ពីរម៉ាឡាគី ២:៧) ឬ ត្រូវបានប្រើប្រាស់ដើម្បី ធ្វើជាតំណាងឲ្យរបស់ដែលអរូប (ខ្យល់នៅក្នុងគម្ពីទំនុកតម្កើង ១០៤:៤) ។ ដោយសារតែពាក្យនេះត្រូវបានគេប្រើប្រាស់តាមរបៀបខុសៗគ្នា យើងត្រូវគិតពិចារណាទៅលើបរិបទនៅក្នុងករណីនីមួយៗដើម្បីកំណត់ថាតើមួយណាជាអត្ថន័យត្រឹមត្រូវ។ ជាទូទៅ ទោះជាយ៉ាងណាក្តី នៅពេលដែលព្រះគម្ពីរចែងអំពីពួកទេវតា គឺតែងតែសំដៅទៅលើភាវៈខាងឯវិញ្ញាណ និង និង អធិធម្មជាតិដែលត្រូវបានបង្ហាញថាជាអ្នកនាំសារពិសេសរបស់ព្រះជាម្ចាស់។

តើពួកទេវតាទាំងនោះមកពីកន្លែងណា? អ្នកនិពន្ធគម្ពីរទំនុកតម្កើង ពោលថា ទេវតា និង អ្វីៗដែលស្ថិតនៅឋានអាទិទេព រួមជាមួយនឹងព្រះអាទិត្យ ព្រះច័ន្ទ និង ផ្កាយគឺសុទ្ធតែត្រូវបានបង្កើតដោយព្រះជាម្ចាស់ (គម្ពីរទំនុកតម្កើង ១៤៨:២-៥)។ លោកយ៉ូហាន បានបន្ថែមឃ្លាមួយកាន់តែពេញលេញ អំពីកិច្ចការ

បង្កើតរបស់ព្រះគ្រិស្ត ៖ "សព្វសារពើសុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្តាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពីព្រះអង្គបង្កើតនោះឡើយ។" (គម្ពីរយ៉ូហាន ១:៣)។ ដោយសារតែបទគម្ពីរបានសន្មតយ៉ាងជាក់លាក់ថា អត្ថិភាពនៃអ្វីៗគ្រប់បែបយ៉ាងគឺជារបស់ព្រះជាម្ចាស់ នោះយើងដឹងថាពួកទេវតាក៏ជាភាវៈដែលត្រូវបានព្រះជាម្ចាស់បង្កើតឡើងផងដែរ។ បទគម្ពីរខាងក្រោម បង្ហាញឲ្យយើងឃើញកាន់តែច្បាស់ថែមទៀត។

លំហាត់អនុវត្តន៍

១ ចូរបំពេញប្រយោគខាងក្រោមនេះ។

ក) គម្ពីរកូឡុស១:១៦ ថ្លែងថា ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង បានបង្កើត.....
.....(បូករួមទាំងពួកទេវតាផងដែរ)។

ខ) នៅក្នុងគម្ពីរ១ធីម៉ូថេ ៦:១៣-១៦ យើងបានដឹងថា ព្រះជាម្ចាស់តែមួយគត់ដែលបានប្រទាន
.....ឲ្យអ្វីគ្រប់យ៉ាង។ (បូករួមទាំងពួកទេវតាផងដែរ)។

យើងមិនបានដឹងថាពួកទេវតាត្រូវបានបង្កើតឡើង នៅពេលណាឲ្យជាក់លាក់នោះទេ ព្រោះព្រះគម្ពីរមិនបានបង្ហាញពីពេលវេលានោះទេ។ យើងបានត្រឹមតែដឹងថា ការបង្កើតពួកទេវតាគឺមុនព្រឹត្តិការណ៍ដែលមានកត់ត្រានៅក្នុងគម្ពីរលោកុប្បត្តិជំពូក៣ទៅទៀត ព្រោះត្រង់ចំណុចនោះ គឺជាពេលសាតាំងដែលជាទេវតាមួយរូប បានមកមានទំនាក់ទំនងជាមួយមនុស្សជាតិ។ ក្នុងពេលជាមួយភាវៈប្រកបដោយពិចារណញ្ញាណ (ការគិត) ដែលព្រះជាម្ចាស់បង្កើត ពួកទេវតាទទួលបានភាពអមតៈ នោះមានន័យថាពួកគេនឹងមិនបាត់ទៅណាឡើយ (គម្ពីរលូកា ២០:៣៦)។

លំហាត់អនុវត្តន៍

២ យោងតាមភស្តុតាងនៅក្នុងព្រះគម្ពីរ ទាក់ទងនឹងដើមកំណើតរបស់ពួកទេវតា យើងអាចសន្និដ្ឋានបានថា ពួកគេគឺជា

ក) ភាវៈមានជីវិតអមតៈ ដែលមានអត្ថិភាពតាំងពីដើមរៀងមក។

ខ) ភាវៈមានជីវិតអមតៈ ដែលនឹងមិនបាត់ទៅណានោះទេ។

គ) ភាវៈមានជីវិតអាចស្លាប់ដូចជាមនុស្ស ប៉ុន្តែមានឫទ្ធានុភាព និង ប្រាជ្ញាខ្ពង់ខ្ពស់ជាង។

ឃ) ជាអំបូរនៃភាវៈមួយដែលស្រដៀងនឹងព្រះជាម្ចាស់ដែរ។

លក្ខណាសម្បត្តិរបស់ពួកគេ

នៅក្នុងការពិភាក្សាអំពីដើមកំណើតរបស់ពួកទេវតា យើងបានសំគាល់ឃើញពីលក្ខណសម្បត្តិមួយរបស់ពួកគេ៖ ពួកគេគឺ*ត្រូវបានបង្កើត* ។ លក្ខណសម្បត្តិមួយចំនួនទៀតក៏ លេចមកឲ្យយើងឃើញ នៅពេលដែលយើងសិក្សាអំពីបទគម្ពីរ។

ពួកទេវតាគឺជា*ភាវៈខាងវិញ្ញាណ* ។ គម្ពីរហេប្រឺ ១:១៤ បានថ្លែងថា៖ "ទេវតាទាំងនោះសុទ្ធតែជាវិញ្ញាណ ដែលនៅបំរើព្រះជាម្ចាស់ ព្រះអង្គចាត់ពួកលោកអោយមកបំពេញមុខងារ ជាប្រយោជន៍ដល់អស់អ្នកដែលត្រូវទទួលការសង្គ្រោះទុកជាមត៌ក!" ពួកមនុស្សមិនត្រូវបានរៀបរាប់ថា ជា*វិញ្ញាណ*នោះទេ ដ្បិតពួកគេមាននិស្ស័យពីរយ៉ាង៖ ខាងរូបី(សាច់ឈាម) និង ខាងអរូបី (វិញ្ញាណ)។ ដោយសារតែពួកទេវតាគឺជា*វិញ្ញាណ* យើងមិនអាចចាត់ទុកពួកគេថាមានរូបកាយបាននោះទេ។ រឿងនេះគឺជារឿងដែលជាប់ពាក់ព័ន្ធនឹងគម្ពីរអេភេសូ ៦:១២៖ "ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹង.....ឥទ្ធិពលអរូបដ៏អាក្រក់ទាំងឡាយដែលនៅស្ថានលើដែរ។" ខគម្ពីរនេះនិយាយសំដៅទៅលើពួកទេវតាអាក្រក់ដែលធ្វើការឲ្យសាតាំង។

ខគម្ពីរបានបង្ហាញថា ពួកទេវតាតែងតែបានបង្ហាញខ្លួន ក្នុងទម្រង់ជាមនុស្ស (គម្ពីរចៅហ្វាយ ៦:១១-២៤ គម្ពីរយ៉ូហាន ២០:១២) ប៉ុន្តែការលេចឡើងមិនធម្មតានេះ មិនមានន័យថាពួកគេមានខ្លួនប្រាណជាផ្នែកសំខាន់ចាំបាច់នៅក្នុងអត្ថិភាពរបស់ពួកគេនោះទេ។ ផ្ទុយទៅវិញ ពួកគេ*ទទួលយក*សណ្ឋានដែលមានខ្លួនប្រាណ នៅក្នុងពេលខ្លះ ដើម្បីជាប្រយោជន៍សម្រាប់ពួកគេធ្វើទំនាក់ទំនងជាមួយមនុស្ស។ ដោយពួកគេគ្មានខ្លួនប្រាណខាងឯសាច់ឈាម ជាផ្នែកចាំបាច់នៃអត្ថិភាពរបស់ពួកគេ នោះពួកទេវតាមិនស្គាល់សោះឡើយ ថាអ្វីជាការលូតលាស់ ភាពចាស់ និង សេចក្តីស្លាប់។

ពួកទេវតាគឺជា*ភាវៈដែលមានលក្ខណៈជាបុគ្គល* ។ ពួកគេបង្ហាញឲ្យឃើញពីផ្នែកមូលដ្ឋានចម្បង នៃបុគ្គលិកលក្ខណៈ៖ សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ។ ចំណេះដឹងខ្លះៗអំពីសមត្ថភាពខាង*សតិបញ្ញា*របស់ពួកទេវតា ដែលមនុស្សជំនាន់សម័្ពន្ធមេត្រីចាស់សង្កេតឃើញ ត្រូវបានលើកនៅក្នុងគម្ពីរ២សាំយូអែល ១៤:២០។ គម្ពីរលូកា៤:៣៤ បង្ហាញថាសូម្បីតែពួកទេវតាអាក្រក់ក៏មានវិសាលភាពនៃចំណេះដឹងខ្ពង់ខ្ពស់ជាងមួយមនុស្សទៅទៀត។ គម្ពីរវិវរណៈ ១២:១២ បង្ហាញយើងអំពីសមត្ថភាពរបស់ពួកទេវតាអាក្រក់ ក្នុងការបង្ហាញ*អារម្មណ៍* (ភាពឃោរឃៅ ឬកំហឹង) ។ ព្រះយេស៊ូមានព្រះបន្ទូលអំពីការបង្ហាញអារម្មណ៍ដ៏វិជ្ជមានរបស់ពួកទេវតាដ៏វិសុទ្ធ (អំណរ) នៅក្នុងគម្ពីរលូកា ១៥:១០។ លោកប៉ូលបាននិយាយអំពីសមត្ថភាពរបស់អារក្សក្នុងការ ដាក់អន្ទាក់មនុស្ស ដើម្បីឲ្យពួកគេធ្វើតាម *ចិត្ត*របស់វា (គម្ពីរ២ធីម៉ូថេ ២:២៦)។ ទាំងនេះគ្រាន់តែជាឧទាហរណ៍បន្តិចបន្តួចនៃខគម្ពីរដែលនិយាយអំពីនិស្ស័យជាបុគ្គលរបស់ពួកទេវតា។

ពួកទេវតា *គ្មានភេទ* នោះទេ។ ពួកគេមិនត្រូវបានបែងចែក ដោយយោងទៅតាមភេទរបស់ពួកគេនោះទេ ទោះបីជាមានទេវតាខ្លះទទួលបានឈ្មោះបែបមនុស្សប្រុស (កាព្រីយ៉ែល និង មីកែល)។ ព្រះគម្ពីរបានថ្លែងថា ពួកទេវតាមិនរៀបការប្តីប្រពន្ធនោះទេ (គម្ពីរម៉ាថាយ ២២:៣០) ។ ដោយសារតែពួកទេវតាមិនអាចបន្តពូជដោយខ្លួនឯងបាន យើងអាចនិយាយយ៉ាងត្រឹមត្រូវថា ពួកគេគឺជាក្រុមមួយ ហើយមិនមែនជាពូជអំបូរមួយនោះទេ។ អ្នកប្រហែលជាបានសំគាល់ឃើញថា ស្របពេលដែលបទគម្ពីរបាននិយាយនៅ

ក្នុងគម្ពីរសម័ន្ធមេត្រីចាស់ថា ពួកទេវតាគឺជា *បុត្ររបស់ព្រះជាម្ចាស់* តែមិនដែលនិយាយអំពី *កូនរបស់ពួកទេវតានោះទេ* (សូមមើលគម្ពីរយ៉ូប ១:៦; ២:១; ៣៨:៧)។

ដូចដែលយើងបានសំគាល់ឃើញហើយថា ពួកទេវតាមានសតិបញ្ញាលើសពីមនុស្ស ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា ប្រាជ្ញាញាណរបស់ពួកគេគឺធំធេងណាស់៖ "រីឯថ្ងៃកំណត់ និងពេលវេលា គ្មាននរណាដឹងឡើយ *ទោះបី*ទេវតា*នៅស្ថានបរមសុខ* ឬព្រះបុត្រាក៏ពុំជ្រាបដែរ មានតែព្រះបិតាមួយព្រះអង្គប៉ុណ្ណោះដែលជ្រាប។" (គម្ពីរម៉ាថាយ ២៤:៣៦)។ ប៉ុន្តែទោះបីជាចំណេះដឹងរបស់ពួកគេលើសពីមនុស្សយ៉ាងណាក្តី ក៏នៅតែមានកំណត់។ លោកពេត្រុស បានមានប្រសាសន៍ នៅក្នុងការរៀបរាប់ពីសិរីរុងរឿងដែលនឹងមកតាមក្រោយ ថា៖ "សូម្បីតែពួកទេវតា* ក៏ប្រាថ្នាចង់យល់ជំពៅនៃសេចក្តីទាំងនោះដែរ"។ (គម្ពីរ១ពេត្រុស ១:១២)។

ការសិក្សាស៊ីជម្រៅអំពីលក្ខណសម្បត្តិរបស់ពួកទេវតា នាំឲ្យយើងសន្និដ្ឋានបានថា *ឫទ្ធានុភាព* របស់ពួកគេគឺ ត្រូវបានបញ្ជាក់ច្បាស់ជាងលក្ខណសម្បត្តិដទៃផ្សេងទៀត។ លោកពេត្រុសសង្កេតឃើញថា ពួកទេវតាគឺមានឫទ្ធានុភាពខ្លាំងក្លាជាងមនុស្ស (គម្ពីរ២ពេត្រុស ២:១១) ។ អ្នកនិពន្ធទំនុកតម្កើងបានចាត់ទុកទេវតាជា "អ្នកដែលមានឥទ្ធិឫទ្ធិខ្លាំង ហើយក៏ប្រតិបត្តិតាមបង្គាប់ទ្រង់ ដោយស្តាប់តាមព្រះសូរសៀងនៃព្រះបន្ទូលទ្រង់" (គម្ពីរទំនុកតម្កើង ១០៣:២០, ពគប១៩៥៤)។ លោកប៉ូលបានចាត់ទុកពួកគេថា ជា " ពួកទេវតានៃព្រះចេស្តាទ្រង់" (គម្ពីរ២ថែស្សាឡូនិក ១:៧,ពគប១៩៥៤) ។

នៅក្នុងករណីទេវតាអាក្រក់ (ដែលយើងនឹងវិភាគនៅពេលក្រោយ) ក៏ដូចគ្នាដែរ ។ ឫទ្ធានុភាព គឺនៅតែជាលក្ខណសម្បត្តិដែល ត្រូវបានបញ្ជាក់ច្បាស់ៗ៖ "ចៅហ្វាយរបស់លោកីយ៍នេះ" (គម្ពីរយ៉ូហាន ១២:៣១,ពគប ១៩៥៤) "មនុស្សខ្លាំងពូកែ" (គម្ពីរលូកា១១:២១,ពគប ១៩៥៤) "អំណាចនៃសេចក្តីងងឹត" (គម្ពីរលូកា២២:៥៣,ពគប ១៩៥៤) "ពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះ" (គម្ពីរអេភេសូ៦:១២, ពគប ១៩៥៤ "ឫទ្ធិអំណាចគ្រប់យ៉ាងរបស់មារសត្រូវ" (គម្ពីរលូកា ១០:១៩) ។ នៅពេលដែលសាតាំងល្បួងព្រះយេស៊ូ វាបានបង្ហាញព្រះយេស៊ូគ្រប់នគរទាំងអស់នៅក្នុងលោកីយ៍ ហើយបាននិយាយថា៖ "ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះអោយលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់អោយអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។" (គម្ពីរលូកា ៤:៦)។

ប៉ុន្តែទោះបីជាប្រាជ្ញានិង ឫទ្ធានុភាពរបស់ពួកគេលើសពីមនុស្សយ៉ាងណាក្តី *លក្ខណសម្បត្តិទាំងនេះរបស់ពួកទេវតានៅតែមានដែនកំណត់។* គ្រាន់តែទេវតាតែម្នាក់ប៉ុណ្ណោះ ក៏អាចចាប់សាតាំងចង ហើយបោះវាទៅក្នុង រណ្តៅគ្មានបាត នៅគ្រាចុងក្រោយបានដែរ (គម្ពីរវិវរណៈ ២០:២-៣) ។
ប៉ុន្តែមុននឹងគ្រានៃការឃុំឃាំងនោះមកដល់ សាតាំង និង ទេវតារបស់វា នឹងត្រូវតយុទ្ធជាមួយទេវតាមីកែលដែលជាមហាទេវតាម្នាក់ និង ពួកទេវតារបស់លោក។ សាតាំងនឹងចាញ់សង្គ្រាមនៅស្ថានលើ ហើយនឹងត្រូវបណ្តេញចេញ (គម្ពីរវិវរណៈ ១២:៧-៩) ។ យោងតាមគម្ពីរដានីយ៉ែលជំពូក១០ ទេវតាល្អ និង ទេវតាអាក្រក់មានជម្លោះជាមួយគ្នាដោយសារតែរឿងមនុស្ស និង ប្រជាជាតិ។ ទាំងទេវតាមីកែលដែលជាមហាទេវតា (គម្ពីរយូដាស ៩) ឬ សាតាំង (យ៉ូប ១-២) អំណាចរបស់ពួកគេសុទ្ធតែមានកម្រិត។

ភស្តុតាងមួយអំពីភាពមានកម្រិតរបស់ពួកទេវតា គឺយើញមាននៅក្នុងការពិតដែលថា *ពួកគេមិនមានសព្វដ្ឋភាព(សព្វវត្តមាន,សព្វត្ថិភាព)នោះទេ។* សាតាំងបានទូលតបទៅនឹងសំណួររបស់ព្រះជាម្ចាស់ទាក់ទងនឹងសកម្មភាពរបស់វា ថា៖ "មកពីដើរចុះឡើងទៅមកនៅផែនដី" (គម្ពីរយ៉ូប១:៧ពគប១៩៥៤ ហើយសូមមើលគម្ពីរ១ពេត្រុស៥:៨)។ ពួកទេវតារបស់ព្រះអម្ចាស់ទូលទ្រង់ថាពួក "យើងខ្ញុំបានធ្វើដំណើរឆ្លងកាត់ផែនដី" (គម្ពីរសាការី១:១១) ។ ចលនាទាំងពីកន្លែងមួយទៅកន្លែងមួយទាំងអស់នេះ គឺត្រូវការពេលវេលា ហើយមានពេលខ្លះ ត្រូវបានពន្យារពេលផងដែរ (គម្ពីរដានីយ៉ែល ១០:៥,១២-១៤) ។ ភាពមានដែនកំណត់នេះ ក៏ជាមូលហេតុធ្វើឲ្យ ចម្បាំងខាងឯវិញ្ញាណដែលមនុស្សរបស់ព្រះជាម្ចាស់ច្បាំង តែងតែបន្តអស់រយៈជាយូរ។

ចុងក្រោយយើងត្រូវយល់ថា *ទេវតាមិនមែនជាមនុស្សបានសិរីល្អនោះទេ ។* ព្រះគម្ពីរបានធ្វើការបែងចែករវាង "ពួកទេវតាទាំងសល់សែន" និង "វិញ្ញាណនៃពួកសុចរិត ដែលបានគ្រប់លក្ខណ៍" នៅក្នុងក្រុងយេរូសាឡឹមនៃស្ថានបរមសុខ (គម្ពីរហេប្រឺ ១២:២២-២៣ *ពគប១៩៥៤*) ភាពដោយឡែកគ្នានេះ ត្រូវបានគេឃើញមាននៅក្នុងគម្ពីរហេប្រឺ ២:១៦៖ "ព្រះយេស៊ូពិតជាពុំបានយាងមកជួយពួកទេវតា*ទេ គឺព្រះអង្គមកជួយពូជពង្សរបស់លោកអប្រាហាំវិញ។"

តាមពិតទៅ យើងមាន "ឋានៈទាបជាងទេវតាតែបន្តិច" ក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ(គម្ពីរទំនុកតម្កើង៨:៤-៥) ប៉ុន្តែនៅក្នុងថ្ងៃអនាគត យើងនឹងបានខ្ពស់ជាង (គម្ពីរហេប្រឺ ២:៧) ។ លោកប៉ូលមានប្រសាសន៍ថា៖ "សូម្បីតែពួកទេវតា* ក៏យើងវិនិច្ឆ័យទោសទៅហើយ"។ នៅក្នុងការវិនិច្ឆ័យទោសនេះ យើងដឹងថាអ្នកដែលតូចទាប ឬ មានឋានៈក្រោម មិនអាចវិនិច្ឆ័យទោសអ្នកដែលមានឋានៈខ្ពស់ជាងបានឡើយ។

លំហាត់អនុវត្តន៍

---

៣ ចូរប្រាប់របៀបបីយ៉ាង ដែលថាលក្ខណសម្បត្តិរបស់ទេវតាមានដែនកំណត់

.....

.....

.....

៤ ចូរផ្គូផ្គងលក្ខណសម្បត្តិរបស់ពួកទេវតា (ខាងស្តាំ) ទៅជាមួយនឹងការរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

.....ក) មិនអាចបន្តពូជ ឬបង្កើនចំនួនដោយខ្លួនឯងបាន	១) ត្រូវបានបង្កើតឡើង
	២) ជាវិញ្ញាណ
.....ខ) អាចនៅកន្លែងតែមួយក្នុងពេលតែមួយ	៣) មានភាពជាបុគ្គល
.....គ) អាចបំពេញតាមបំណងព្រះហឫទ័យ និង ការសម្រេចព្រះទ័យអ្នកដឹកនាំរបស់ពួកគេ។	៤) គ្មានភេទ
	៥) មានសតិបញ្ញា
	៦) មានឫទ្ធានុភាពខ្ពស់
.....ឃ) មានចំណេះដឹងអំពីរឿងរ៉ាវរបស់មនុស្ស។	៧) គ្មានសព្វដ្ឋភាព(សព្វត្ថិភាព)

.....ង) គ្មានរូបរាងសាច់ឈាមនោះទេ។

.....ច) បានកើតឡើងនៅក្នុងពេលវេលាជាក់លាក់មួយ សិរីល្អនោះទេ។

.....ឆ) ត្រូវបានបែងចែកយ៉ាងច្បាស់នៅក្នុង បទគម្ពីរឲ្យដាច់ពីមនុស្ស។

.....ជ) មានសតិបញ្ញា អារម្មណ៍ និង ឆន្ទៈ

ឈ) មិនមែនជាមនុស្សដែលបានណាមួយ។

ខ. លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា

ទេវតាត្រូវបានបង្កើតមកឲ្យមានតាពវិសុទ្ធ

វត្ថុបំណងទី២. *រៀបរាប់ពី លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា ដោយប្រើប្រាស់ខគម្ពីរធ្វើជាមូលដ្ឋាន។*

យើងបាននិយាយអំពីទេវតាដ៏វិសុទ្ធ ព្រមទាំងទេវតាអាក្រក់ផងដែរ។ ការសិក្សារបស់យើងនៅក្នុងផ្នែកនេះ នឹងបង្ហាញថា ទេវតាទាំងអស់ត្រូវបានមកឲ្យមានភាពវិសុទ្ធ ប៉ុន្តែមានទេវតាខ្លះបានធ្លាក់ចេញពីភាពវិសុទ្ធរបស់ពួកគេ ហើយដោយសារតែការមានកំហុសរបស់ពួកគេនេះហើយ ក៏បណ្តាលឲ្យមានផលលំបាកយ៉ាងធ្ងន់ធ្ងរចំពោះសាកលលោកទាំងមូល។

ព្រះគម្ពីរបាននិយាយតែបន្តិចបន្តួចតែប៉ុណ្ណោះអំពីសភាពដើមរបស់ពួកទេវតា ប៉ុន្តែយើងបានដឹងហើយថា នៅចុងបញ្ចប់នៃសកម្មភាពនៃការបង្កើតរបស់សព្វសារពើ "ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ព្រះអង្គឈ្វេងយល់ថាល្អប្រសើរបំផុតហើយ"។ (គម្ពីរលោកុប្បត្តិ ១:៣១)។ ពិតណាស់ ការនេះបូករួមទាំងការល្អប្រសើរបំផុតភាពវិសុទ្ធរបស់ពួកទេវតា នៅពេលដែលពួកគេត្រូវបានបង្កើតឡើងនោះ។ យ៉ាងណាមិញ បទគម្ពីរបានរៀបរាប់អំពីការធ្លាក់ចុះដ៏សោកសៅរបស់ពួកគេ។ សូមយើងពិចារណាអំពីសមត្ថភាពរបស់ពួកទេវតា ទាំងក្នុងការធ្វើសកម្មភាពត្រឹមត្រូវ និង សកម្មភាពខុសឆ្គង ព្រមទាំងពិចារណាអំពីសមត្ថភាពរបស់ពួកគេនៅក្នុងការស្គាល់ និង គោរពទៅតាមក្បួនខ្នាតនៃឥរិយាបថត្រឹមត្រូវ។

លំហាត់អនុវត្តន៍

៥ សូមអានខគម្ពីរយោង ហើយបំពេញប្រយោគខាងក្រោម។

ក) គម្ពីរយ៉ូហាន៨:៤៤។ អំពើបាបមួយដែលបណ្តាលឲ្យមានការធ្លាក់ចុះរបស់អារក្សគឺ .....

ខ) គម្ពីរ២ពេត្រុស២:៤ ។ ព្រះជាម្ចាស់មិនយោគយល់ដល់ពួកទេវតាឡើយនៅពេលដែល .....

គ) គម្ពីរយូដាស៦ ។ ទេវតាខ្លះមិនបានរក្សា.....របស់ពួកគេ ប៉ុន្តែពួកគេបែរជា.....

ឃ) គម្ពីរ១ធីម៉ូថេ ៣:៦ ។ មូលហេតុសំខាន់មួយនៃការធ្លាក់ចុះរបស់អារក្សគឺអំពើបាបនៃការ

.....

ពួកទេវតាបានធ្វើការជ្រើសរើស

ដូចដែលយើងបានឃើញហើយថា ទេវតាទាំងអស់ត្រូវបង្កើតមកដំបូងឲ្យមានភាពល្អឥតខ្ចោះ។ ដំបូងមេត្រីភាព ឬ សេចក្តីស្រឡាញ់របស់ពួកគេគឺត្រូវថ្វាយទៅព្រះអាទិករដែលបង្កើតពួកគេ ហើយពួកគេមានទំនោរចង់ធ្វើអ្វីទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ទោះបីជាព្រះគម្ពីរមិនបានផ្តល់សេចក្តីលំអិតមកឲ្យយើង យើងក៏ជឿថា នៅក្នុងដំណាក់កាលនេះពួកគេមានសមត្ថភាពទាំងក្នុង*ការប្រព្រឹត្តិអំពើបាប ឬ មិនប្រព្រឹត្តិពើបាប។* ច្បាស់ណាស់ ពួកគេដឹងខ្លួនច្បាស់អំពីឋានៈរបស់ពួកគេ និង អំពីទំនាក់ទំនងរបស់ពួកគេទៅនឹងអ្នកដែលបានបង្កើតពួកគេមក។ ពួកគេក៏ប្រាកដជាបានដឹងហើយ ថាការស្តាប់បង្គាប់ ឬ ការមិនស្តាប់បង្គាប់របស់ពួកគេ នឹងជាកំណត់វាសនាទៅថ្ងៃអនាគតរបស់ពួកគេ។

នៅពេលដែលពួកទេវតាមានសិទ្ធិក្នុងការជ្រើសរើស ក្នុង*ការប្រព្រឹត្តិអំ*ពើបាប ឬ មិន*ប្រព្រឹត្តិ* អំពើបាប ពួកគេក៏មិនត្រូវបាន*បង្ខិតបង្ខំ* ឲ្យស្តាប់បង្គាប់តាមព្រះជាម្ចាស់ ហើយរក្សាឋានៈរបស់ពួកគេឡើយ។ ជម្រើសរបស់ពួកគេ គឺធ្វើឡើងដោយការស្ម័គ្រចិត្តទាំងស្រុង។ ជាអកុសល ពួកគេមិនបានដឹងពីរឿងដែលកើតឡើងនៅជុំវិញសោកនាដកម្ម នៅពេលដែលមួយផ្នែកនៃពួកទេវតាធ្លាក់ចុះនោះឡើយ។ យ៉ាងណាមិញ ដោយមានការជំរុញពីព្រះជាម្ចាស់ លោកប៉ូលបានបញ្ជាក់ថា ការធ្លាក់ចុះរបស់ពួកមារ កើតមានឡើង ដោយសារអំណួតរបស់គេ (មោទនភាពជ្រុល) (គម្ពីរ១ធីម៉ូថេ ៣:៦)។

មានផ្នែកជាច្រើននៅក្នុងបទគម្ពីរ ដែលនិយាយជាអាទិ៍អំពីស្តេចរបស់លោកីយ៍ ក៏ហាក់បីដូចជានិមិត្តសញ្ញាតំណាងឲ្យសាតាំងផងដែរ។ ឧទាហរណ៍ នៅក្នុងគម្ពីរអេសេគាល ២៨:១២-១៩ បានប្រាប់ថា ស្តេចនៃក្រុងទីរ៉ុស បានធ្លាក់ចុះ ដោយសារតែមោទនភាពជ្រុលទៅលើភាពស្រស់ស្អាតរបស់ខ្លួន។ អំណួតនេះ បានបំផ្លាញសមត្ថភាពរបស់គេក្នុងការប្រព្រឹត្តិរឿងត្រឹមត្រូវ ឬ ធ្វើការវិនិច្ឆ័យត្រឹមត្រូវ។

ស្តេចស្រុកបាប៊ីឡូន ក៏ត្រូវបានដាក់ទោសឲ្យវិនាសហិនហោចដោយសារតែអំណួតជ្រុល និងមហិចតាផងដែរ បើយោងទៅតាមគម្ពីរអេសាយ ១៤: ១២-១៥។ មិនថាឧទាហរណ៍ទាំងនេះនិយាយគ្រាន់តែជាតំណាងឲ្យការធ្លាក់ចុះរបស់សាតាំង ឬអត់ ក៏យើងដឹងថាមានទេវតាខ្លះ ធ្វើតាមបំណងចិត្តរបស់ពួកគេ ដោយបានជ្រើសរើសយកការចាកចេញពីតំណែងនៃសិទ្ធិអំណាច និង ផ្ទះរបស់ពួកគេ (គម្ពីរយូដាស ៦)។

ឥរិយាបថដែលបានធ្វើឲ្យអារក្សមានបាប ហាក់បីដូចជាបានចម្លងទៅលើពួកទេវតាមួយចំនួនធំដែរ។ គម្ពីរវិវរណៈ ១២:៤ ប្រហែលជាបាននិយាយអំពីហេតុការណ៍ នៅពេលដែលទេវតាមួយភាគបី បានដើរតាមសាតាំងក្នុងការប្រឆាំងទាស់ជាមួយព្រះជាម្ចាស់។ ទោះជាយ៉ាងណា យើងដឹងថាសាតាំងគឺជាមេបោកបញ្ឆោតខាងឯវិញ្ញាណ (គម្ពីរយ៉ូហាន ៨:៤៤) ។ ដោយសាតាំង និង ទេវតាឯទៀតដែលបានបះបោរដែលនេះជាជម្រើសធ្វើឡើងសម្រាប់ខ្លួនឯង និង ប្រយោជន៍ផ្ទាល់ខ្លួន មិនមែនជាជម្រើសសម្រាប់ព្រះជាម្ចាស់ និង ប្រយោជន៍របស់ទ្រង់នោះទេ។ លទ្ធផលដែលបានមកពីការនេះ គឺភាពមហន្តរាយ និង ការកាត់

ទោសដែលមកតាមក្រោយ៖ "ដ្បិតព្រះជាម្ចាស់ពុំបានយោគយល់ដល់ពួកទេវតា*ដែលប្រព្រឹត្តអំពើបាប"។ (គម្ពីរ២ពេត្រុស ២:៤)។

ការសង្គ្រោះ ដែលបានកំណត់ទុកជាមុនដើម្បីបំពេញតម្រូវការខាងឯវិញ្ញាណរបស់មនុស្ស គឺមិនមានសម្រាប់ពួកទេវតាដែលបានធ្លាក់ចុះនោះទេ។ ទេវតាមិនវិសុទ្ធ នៅតែមានវត្តមាននៅក្នុងស្ថានរបស់ "មារកំណាច" (គម្ពីរម៉ាថាយ ៦:១៣, ១៣:៩ គម្ពីរ១យ៉ូហាន ៥:១៨-១៩)។ ការបន្តមានវត្តមានរបស់ពួកគេ ដែលយើងនឹងពិភាក្សានៅក្នុងផ្នែកបន្ទាប់ទៀត គឺជាការព្រមានដដែលសម្រាប់យើង អំពីគ្រោះថ្នាក់ដែលបានមកពីការបដិសេធព្រះជាម្ចាស់ ឬ ការឆ្វេសប្រហែសចំពោះព្រះគុណដែលទ្រង់ប្រទានមកឲ្យយើង។

ទេវតាខ្លះដែលប្រព្រឹត្តិអំពើបាប ត្រូវបានវិនិច្ឆ័យទោស ហើយក៏បានក្លាយជាផ្នែកនៃទេវតារបស់មារកំណាច (គម្ពីរម៉ាថាយ ២៥:៤១) ។ ទេវតាឯទៀតដែលមិនបានប្រព្រឹត្តិបាប ពួកគេនៅជាប់ជាមួយព្រះវរបិតា និង "ទេវតាដ៏វិសុទ្ធ" របស់ទ្រង់ (គម្ពីរម៉ាកុស ៨:៣៨)។ បទគម្ពីរ មិនបានប្រាប់ច្រើនទៀតទេ អំពីការបះបោរ និង ការវិនិច្ឆ័យទោសពួកទេវតា។ ដូច្នេះ ពួកទេវតាហាក់បីមានភាពច្បាស់លាស់នៅក្នុងការសម្រេចចិត្តរបស់ពួកគេ ថាអ្នកណាជ្រើសរើសធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតានឹងបានវិសុទ្ធជារៀងរហូត ហើយអ្នកណាជ្រើសរើសផលប្រយោជន៍របស់ខ្លួន គឺក្លាយជាអាក្រក់ជារៀងរហូត។

ពួកទេវតាដ៏វិសុទ្ធគឺជាពួកទេវតាដែលបានជ្រើសរើស ការបន្តទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់ សម្លឹងមើលទៅឯព្រះវរបិតាគង់នៅស្ថានបរមសុខ (គម្ពីរម៉ាថាយ ១៨:១០) និង ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរម៉ាថាយ ៦:១០)។ ពួកគេត្រូវបានចាត់ទុកជាទេវតានៃពន្លឺ (ជាអ្នកដែលសាតាំងព្យាយាមក្លែងខ្លួនធ្វើតាម ឬ ធ្វើជាតំណាង - គម្ពីរ២កូរិនថូស ១១:១៤)។

លំហាត់អនុវត្តន៍

---

៦ ចូរជ្រើសរើសថាតើប្រយោគណា ត្រូវបាន ព្រះគម្ពីរ*គាំទ្រច្បាស់ៗ* អត្ថបទ*បញ្ជាក់* ឬ ដោយភាសានិមិត្តរូប ឬ *មិនគាំទ្រដោយគម្ពីរសោះ* ។

.....ក) សាតាំងធ្លាក់ចុះ ដោយសារអំណួត ឬ មោទនភាពជ្រុលលើខ្លួនឯង។

.....ខ) ទេវតាត្រូវបានបង្កើតមកឲ្យល្អឥតខ្ចោះ។

.....គ) ទេវតាមួយភាគបី បានជ្រើសរើសដើរតាមសាតាំង។

.....ឃ) ទេវតាដែលបានធ្លាក់ចុះទាំងអស់នឹងមានឱកាសលន់តួបាបរបស់គេ។

.....ង) ទេវតាទាំងអស់បានធ្វើការជ្រើសរើសដោយស្មគ្រ មិនថាក្នុងការប្រព្រឹត្តិបាប និង ការមិនប្រព្រឹត្តិធ្វើបាបទេ។

.....ច) ព្រះជាម្ចាស់បានប្រកាសការវិនិច្ឆ័យភ្លាមៗចំពោះទេវតាដែលបានប្រព្រឹត្តិបាប។

១) គម្ពីរគាំទ្រច្បាស់ៗ
២) អត្ថបទបញ្ជាក់
៣) មិនគាំទ្រដោយគម្ពីរសោះ

.....ឆ) ទេវតាទាំងអស់មានភាពច្បាស់នៅក្នុងការសម្រេចចិត្ត
របស់ពួកគេ មិនថាការប្រព្រឹត្តិបាប ឬ មិនប្រព្រឹត្តិបាប។

.....ជ) សាតាំងត្រូវបានចាត់ទុកជាទេវតានៃពន្លឺ។

.....ឈ) មានតែទេវតាដ៏វិសុទ្ធប៉ុណ្ណោះដែល ធ្វើការតាមបំណង
ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឯទេវតាអាក្រក់វិញ
ធ្វើការតាមបំណងរបស់សាតាំង។

.....ញ) ចាប់តាំងពីត្រូវបានបង្កើតឡើងដំបូង សាតាំងគឺអាក្រក់
ទៅហើយ។

គ. ចំនួនរបស់ទេវតា

វត្ថុបំណងទី៣. *សង្ខេបសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងចំនួនរបស់ទេវតា។*

មុនពេលយើងចូលទៅមើលឲ្យកាន់តែស៊ីជម្រៅអំពីការរៀបចំ និង សកម្មភាពរបស់ទេវតាដ៏វិសុទ្ធ និងទេវតាមិនវិសុទ្ធ ចូរយើងក្រឡេកទៅមើលពីអ្វីដែលព្រះគម្ពីរចែងពីចំនួនរបស់ទេវតាជាមុនសិន។ នៅពេលដែល បទគម្ពីរមិនបានប្រាប់ពីចំនួនជាក់លាក់របស់ពួកទេវតា យើងនៅតែដឹងថាពួកគេមានបរិមាណ និង ចំនួនច្រើនសន្ធឹកសន្ធាប់។ យើងរកឃើញបទគម្ពីរទាំងប៉ុន្មានខាងក្រោមនេះ អំពីចំនួនយ៉ាងច្រើនសន្ធឹករបស់ពួកទេវតា៖

១. នៅពេលដែលលោកហោរាអេលីសេ និង អ្នកបម្រើរបស់លោកត្រូវបានលោមព័ទ្ធនៅក្នុងក្រុងដូថាន់ ដោយកងទ័ពស៊ីរីដ៏មានអំណាចខ្លាំងក្លា ព្រះជាម្ចាស់បានចាត់បញ្ជូនទ័ពទេវតាដ៏ធំជាងនេះទៅទៀត មកដើម្បីការពារអ្នកបម្រើរបស់លោក។(គម្ពីរ១ពង្សាវតារក្សត្រ ៦:១៤-១៧)

២. ដោយយោងទៅតាមអ្នកនិពន្ធទំនុកតម្កើង "ទ័ពសេះរបស់ព្រះជាម្ចាស់ មានចំនួនរាប់លានរាប់កោដិ ព្រះអង្គគង់ជាមួយពួកគេនៅភ្នំស៊ីណៃជាទីសក្ការៈរបស់ព្រះអង្គ។" (គម្ពីរទំនុកតម្កើង ៦៨:១៧)

៣. នៅក្នុងការឲ្យពរទៅជនជាតិអ៊ីស្រាអែលលោកម៉ូសេបាននិយាយអំពីព្រះអម្ចាស់ដែលបានយាងមកជាមួយនឹង "ទេវតា*យ៉ាងច្រើនអនេកអនន្ត (ច្រើនមិនអាចរាប់បាន)" (គម្ពីរទុតិយកថា ៣៣:២)

៤. នៅក្នុងបទទំនាយទុកជាមុន លោកដានីយ៉ែលបានឃើញព្រះជាម្ចាស់នៃពេលវេលាដែលមានព្រះជន្មាយុយឺនយូរ គង់នៅលើបល្ល័ង្ក នៃការវិនិច្ឆ័យ។ លោកដានីយ៉ែលរៀបរាប់អំពីព្រឹត្តិការណ៍នោះថា៖ "មានមនុស្សរាប់ម៉ឺនរាប់សែននាក់គោរពបំរើព្រះអង្គ និងរាប់លានរាប់កោដិនាក់ទៀតឈរនៅចំពោះព្រះភក្ត្រព្រះអង្គ។" (គម្ពីរដានីយ៉ែល ៧:១០)។

៥. អ្នកនិពន្ធគម្ពីរហេប្រឺបានក្រើនរំឭកអ្នកអានរបស់លោកអំពីអភ័យឯកសិទ្ធិដ៏រុងរឿង នៃការចូលទៅឯព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ដែលនៅក្នុងព្រះវត្តមានរបស់ទ្រង់មានការប្រមូលផ្តុំដ៏ពេញដោយអំណរនៃ "ទេវតា*រាប់លានរាប់កោដិ" (គម្ពីរហេប្រឺ ១២:២២)

៦. ចុងក្រោយ នៅពេលដែលព្រះជាម្ចាស់បានប្រទានឲ្យលោកយ៉ូហានដែលជាសាវ័កសំណព្វ បានឃើញពីទិដ្ឋភាពដ៏ពេញដោយព្រះចេស្តានៃទីកាត់ក្តីនៅស្ថានបរមសុខរបស់ទ្រង់ លោកយ៉ូហាន

ថាសរសេរថា៖ "ពេលនោះ ខ្ញុំមើលទៅ ហើយឮសូរសំឡេងទេវតា*យ៉ាងច្រើននៅជុំវិញបល្ល័ង្ក ជុំវិញសត្វមានជីវិត និងជុំវិញពួកព្រឹទ្ធាចារ្យ។ ទេវតាទាំងនោះមានចំនួនរាប់ម៉ឺនរាប់សែន ច្រើនអនេកអនន្ត" (គម្ពីរវិវរណៈ ៥:១១)

តាមភស្តុតាងនេះ យើងឃើញថាចំនួនទ័ពទេវតា ឬ ទេវតាដ៏វិសុទ្ធ គឺពិតជាច្រើនណាស់។ លើសពីនេះទៅទៀត យើងដឹងថាកងទ័ពទេវតាកំណាចរបស់សាតាំង ក៏មានវត្តមាន ហើយដឹងថាចំនួនរបស់ពួកគេក៏ច្រើនសន្ធឹកដែរ (គម្ពីរវិវរណៈ ១២:៧-១២)។

លំហាត់អនុវត្តន៍

---

៧ ព្រះគម្ពីរបង្រៀនអ្វីអំពីចំនួនពួកទេវតា?

ក) មានទេវតាធ្លាក់ចុះច្រើនជាងទេវតាដែលនៅស្មោះត្រង់ជាមួយព្រះជាម្ចាស់។

ខ) មានទេវតាជាច្រើនរាប់មិនអស់ ទាំងល្អនិងអាក្រក់ ។

គ) ទេវតាច្រើននៅបម្រើព្រះជាម្ចាស់ ហើយមានទេវតាមួយចំនួនតូចទៅបម្រើសាតាំង។

ឃ) ចំនួនទេវតា កំពុងថយចុះ។

ឃ. ការរៀបចំនិងសកម្មភាពរបស់ពួកទេវតា

ភស្តុតាងអំពីការរៀបចំ

វគ្គបំណងទី៤. *បង្ហាញភស្តុតាងនៃសកម្មភាពដែលបានរៀបចំរបស់ពួកទេវតាដ៏វិសុទ្ធ។*

មានភស្តុតាងក្នុងបទគម្ពីរជាច្រើនដែល បង្ហាញពីការរៀបចំកម្លាំងដែលមានប្រសិទ្ធិភាពខាងឯវិញ្ញាណ ដើម្បីធ្វើកិច្ចការដែលបានប្រទានឲ្យពួកគេ។ បទគម្ពីរខ្លះនៅក្នុងបទគម្ពីរទាំងនេះ គឺមានដូចខាងក្រោម៖

១. គម្ពីរ១ពង្សាវតារក្សត្រ២២:១៩ ។ លោកព្យាការីមីកាបង្ហាញអ្វីម្យ៉ាងអំពីការរៀបចំរបស់ពួកទេវតា៖ "ទូលបង្គំបានឃើញព្រះអម្ចាស់គង់លើរាជបល្ល័ង្ក ហើយមានកងពលនៃស្ថានបរមសុខទាំងមូលឈរគាល់ព្រះអង្គ ទាំងឆ្វេង ទាំងស្តាំផង។" ព្រះជាម្ចាស់គង់នៅលើរាជបល្ល័ង្ក កងពល (ពួកទេវតា) នៃស្ថានបរមសុខទាំងមូល នៅជុំវិញទ្រង់។

២. គម្ពីរម៉ាថាយ ២៦:៥៣។ព្រះយេស៊ូបានមានព្រះបន្ទូលទាំងនេះទៅកាន់លោកពេត្រុស៖ "អ្នកស្មានថា ខ្ញុំមិនអាចអង្វរករព្រះបិតាខ្ញុំអោយចាត់ទេវតាជាងដប់ពីរកងពល មកជួយខ្ញុំបានភ្លាមៗទេឬ?" នេះបង្ហាញឲ្យឃើញអំពីអ្វីដែលស្រដៀងនៅនឹងការរៀបចំកងទ័ពរ៉ូម៉ាំងដែរ។ ព្រះបន្ទូលត្រង់នេះក៏ប្រាប់ថា ពួកទេវតាតែងតែប្រុងប្រៀប និងត្រៀមខ្លួនដើម្បីធ្វើតាមការបញ្ជារបស់ព្រះវរបិតានៃស្ថានបរមសុខ។

៣. គម្ពីរលូកា ២:៨-១៤ ។ ទេវតានាំសារដែលបានលេចមកឯអ្នកគង្វាល ហើយបានធ្វើការប្រកាសអំពីកំណើតរបស់ព្រះយេស៊ូ ក៏ត្រូវបានចូលរួមដោយ "ទេវតាច្រើនកុះករ ចុះពីស្ថានបរមសុខ" ។ ទេវតានាំសារ និង ក្រុមទេវតាខាងចម្រៀងបានបន្លឺសម្លេងចម្រៀងនៃការសរសើរតម្កើងថ្វាយទៅដល់

ព្រះជាម្ចាស់។ ទេវតាដែលមានលក្ខណៈបុគ្គល និង ក្រុមទេវតាខាងចម្រៀង ច្បាស់ជាបានឆ្លើយតប ទៅតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា និង ធ្វើការទៅតាមការងាររៀងៗខ្លួន។

៤. គម្ពីរវិវរណៈ ១៩:១០-១៤ ។ និមិត្តរបស់លោកយ៉ូហាន អំពីកងទ័ពទេវតាដែលមានជោគជ័យ នៅក្នុងពេលនៃការយាងមកដល់របស់ព្រះអម្ចាស់ ក៏បានបង្ហាញពី ភាពសុក្រឹត សណ្តាប់ធ្នាប់ ការរៀបចំ សិទ្ធិអំណាច និង គោលបំណងផងដែរ៖ "កងទ័ពនៅស្ថានសួគ៌នាំគ្នាជិះសេះ ស មកតាមព្រះអង្គ ទាំងស្លៀកពាក់សំពត់ទេសឯកពណ៌ស និងបរិសុទ្ធ*។" អ្នកប្រហែលជាបានសំគាល់ឃើញថា បទគម្ពីរបានចែងពីការរៀបចំរបស់ពួកទេវតា។ នៅក្នុងផ្នែកក្រោយៗទៀតនៃមេរៀននេះ យើងនឹងឃើញថា កម្លាំងនៃសេចក្តីអាក្រក់ ក៏ត្រូវមានការរៀបចំដែរ។ ជាពិសេស ពួកគេត្រូវបានរៀបចំ ដើម្បីទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។

សកម្មភាពដែលមានការរៀបចំរបស់ទេវតាដ៏វិសុទ្ធ

ដោយសារយើង ត្រូវប្រឈមមុខជាមួយនឹងទេវតាពីរក្រុមដោយឡែកគ្នា មានទេវតាវិសុទ្ធ និង ទេវតាមិនវិសុទ្ធ ឬ ទេវតាអាក្រក់ យើងត្រូវពិនិត្យមើលកិច្ចការដែលទេវតាដ៏វិសុទ្ធធ្វើជាមុនសិន។ នៅពេលដែលយើងស្វែងយល់ពីកិច្ចការដែលពួកគេធ្វើហើយ យើងត្រូវយល់បន្ថែមទៀតអំពីរបៀបដែលពួកគេរៀបចំដើម្បីធ្វើកិច្ចការនេះ។

ពួកទេវតាថ្វាយបង្គំព្រះជាម្ចាស់។ នៅក្នុងចំណោមរូបភាពទាំងប៉ុន្មាននៃទេវតាដ៏វិសុទ្ធដែលត្រូវបានបង្ហាញនៅក្នុងបទគម្ពីរ ក៏មានរូបភាពស្តីពីពួកទេវតាដែលកំពុងឈរនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និងកំពុងតែថ្វាយបង្គំទ្រង់ផង (គម្ពីរទំនុកតម្កើង ១០៣:២០; ១៤៨:២ គម្ពីរអេសាយ ៦:១-៧) ។ ពួកគេលើកសម្លេងរបស់ពួកគេឡើង ច្រៀងជាចម្រៀងនៃការសរសើរដ៏មានចេស្តា ដ្បិតទ្រង់ស័ក្តិសមទទួលការសរសើរពីស្នាព្រះហស្តរបស់ទ្រង់។ ពួកគេថ្វាយបង្គំព្រះជាម្ចាស់ ដោយទ្រង់គឺជាព្រះ និង សម្រាប់អ្វីដែលទ្រង់បានប្រទាន និងសម្រាប់អ្វីដែលទ្រង់បានប្រើប្រាស់ដើម្បីសម្រេចបាននូវការប្រោសលោះ (ប្រៀបធៀបទៅគម្ពីរវិវរណៈ ៥:៩-១២ជាមួយ ៥:១៣-១៤)។

ពួកទេវតាដ៏វិសុទ្ធ សាទរនឹងកិច្ចការនៃការបង្កើតរបស់ព្រះជាម្ចាស់ នៅក្នុងធម្មជាតិ (គម្ពីរយ៉ូប ៣៨:៧) និង ចំពោះការអស្ចារ្យដ៏ស្រស់បំព្រងដែលទ្រងធ្វើ ដើម្បីផ្លាស់ប្រែមនុស្សបាប និង នាំពួកគេឲ្យចូលមកក្នុងគ្រួសាររបស់ទ្រង់ (គម្ពីរលូកា ១៥:១០)។ ស្ថានសួគ៌ត្រូវបានបើកចំហ ជាព្រះវិហារដ៏រុងរឿងមួយ ដែលមានពួកទេវតាលេចមក ជា*ក្រុមជំនុំនៃស្ថានបរមសុខ* ។ នៅក្នុងព្រះវិហារនោះ ពួកគេថ្វាយបង្គំ និងសរសើរតម្កើងព្រះជាម្ចាស់ ដែលពួកគេស្ថិតនៅក្នុងព្រះវត្តមានរបស់ទ្រង់គ្រប់ពេល។ (គម្ពីរម៉ាថាយ ១៨:១០)។

ទេវតា គឺជាវិញ្ញាណដែលចាំដឹកនាំបម្រើ ។ ទេវតាមិនត្រឹមតែថ្វាយបង្គំ ព្រះជាម្ចាស់ និង សាទរនៅក្នុងព្រះវត្តមានរបស់ទ្រង់ និង កិច្ចការរបស់ទ្រង់នោះទេ ពួកគេក៏ធ្វើកិច្ចការទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ផងដែរ (គម្ពីរទំនុកដំកើង១០៣:២០) ។ ក្នុងនាមជាទេវតាដឹកនាំបម្រើ ពួកទេវតាត្រូវបានចាត់បញ្ជូនមកដើម្បីបម្រើអស់អ្នកដែលនឹងទទួលមរតកនៃការសង្គ្រោះ (គម្ពីរហេប្រឺ ១:១៤) ។ ចូរសំគាល់

មើលពីរបៀបដែលព្រះជាម្ចាស់ប្រទានការបម្រើរបស់ពួកទេវតានេះ ទាំងនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធថ្មី៖

១. លោកប៉ូលកាលនៅជាអ្នកទោសម្នាក់ ដែលកំពុងស្ថិតនៅក្នុងកាល:ទេស:ដ៏គ្រោះថ្នាក់មួយ បានទទួល*ការលើកទឹកចិត្តពីទេវតា* (គម្ពីរកិច្ចការ ២៧:២៣-២៤)។

២. លោកភីលីព*ទទួលបានការដឹកនាំនៅក្នុងព័ន្ធកិច្ច* ពីទេវតា (គម្ពីរកិច្ចការ ៨:២៦) ។

៣. លោកកូនេលាស ទទួលបាន*ជំនួយ* ពីទេវតា នៅក្នុងការស្វែងរកភាពស្គប់ស្គាល់នៅក្នុងព្រះជាម្ចាស់បន្ថែមទៀត (គម្ពីរកិច្ចការ ១០:៣-៧)។

៤. លោកពេត្រុស ត្រូវបាន*រំដោះ* ដោយទេវតាយ៉ាងអស្ចារ្យ (គម្ពីរកិច្ចការ ១២:៧-១០)។

៥. នៅក្នុងព្រឹត្តិការណ៍ដែលត្រូវបានកត់ត្រាទុក ព្រះយេស៊ូបាន*ទទួលកម្លាំងបន្ថែម* ដោយពួកទេវតា (គម្ពីរម៉ាថាយ ៤:១១ លូកា ២២:៤៣)។

៦. លោកអេលីសេ *ត្រូវបានការពារ* ផុតពីកងទ័ពសាសន៍ស៊ីរី ដោយទេវតាដ៏វិសុទ្ធមួយក្រុម (គម្ពីរ ២ពង្សាវតារក្សត្រ ៦:៨-២៣)។

៧. លោកដាវីឌ ត្រូវបានគេទទួលស្គាល់ បន្ទាប់ពីការភៀសខ្លួនរបស់លោក ពីស្តេចអប៊ីម៉ាឡេក (គម្ពីរ១សាំយូអែល ២១:១០-២២:១) ដែលពេលនោះលោកបានទទួល*ការការពារ និង រំដោះ* ដោយពួកទេវតា (សូមមើលគម្ពីរ ទំនុកតម្កើង ៣៤:៧)។

ពួកទេវតាគឺជាភ្នាក់ងារនៃការវិនិច្ឆ័យទោស ។ នៅក្នុងការធ្វើកិច្ចការតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ពួកទេវតាក៏ជាភ្នាក់ងារនៅក្នុងការវិនិច្ឆ័យទោស ការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់ផងដែរ។ ឧទាហរណ៍មួយនៃការនេះ គឺឃើញមាននៅក្នុងគម្ពីរ២ពង្សាវតារក្សត្រ ១៩:៣៥៖ " នៅយប់នោះទេវតា*របស់ព្រះអម្ចាស់បានចេញមកវាយទីតាំងទ័ពរបស់ពួកអាស្សីរី ហើយប្រហារជីវិតពួកគេអស់មួយសែនប្រាំបីម៉ឺនប្រាំពាន់នាក់" ។ នៅក្នុងគម្ពីរកិច្ចការ១២:២៣ ក៏មានចែងថា៖ "រំពេចនោះ ស្រាប់ តែមានទេវតារបស់ព្រះជាម្ចាស់មកប្រហារស្តេចហេរ៉ូដ ព្រោះទ្រង់ពុំបានថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់។ ស្តេចត្រូវដង្កូវចោះ ហើយក៏ផុតដង្ហើមទៅ។"

មានបទគម្ពីរជាច្រើនទៀត ដែលនិយាយអំពីកិច្ចការរបស់ពួកទេវតា ជាភ្នាក់ងារដែលធ្វើការតាមគម្រោងការរបស់ព្រះជាម្ចាស់ ជាភ្នាក់ងារក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់ ទាំងនៅអតីតកាល និង នៅអនាគត ហើយក៏ជាកម្លាំងពិសេសដែលរួមដំណើរជាមួយព្រះអម្ចាស់ នៅក្នុងពេលដែលទ្រង់យាងត្រឡប់មកវិញផងដែរ។

លំហាត់អនុវត្តន៍

៨ តើទេវតាដ៏វិសុទ្ធមានចូលរួមនៅក្នុងសកម្មភាពណាខ្លះ នៅខាងក្រោមនេះ ? ពួកលោក

ក) ថ្វាយបង្គំ និង សរសើរតម្កើងព្រះជាម្ចាស់ ហើយធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ខ) បម្រើអ្នកដែលត្រូវប្រោសលោះ នៅលើផែនដី ក្នុងនាមជាវិញ្ញាណដែលបម្រើ។

គ) ថ្កោលទោសមនុស្សបាប ហើយនាំពួកគេឲ្យលន់តួ។

ឃ) ការពារ រំដោះ ដឹកនាំ លើកទឹកចិត្ត និង ផ្តល់កម្លាំងឲ្យមនុស្សរបស់ព្រះជាម្ចាស់។

ង) ដើរតួជាភ្នាក់ងារនៃការវិនិច្ឆ័យទោស និងការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់។

ទេវតាហាក់បីដូចជាមានឥទ្ធិពល នៅក្នុងកិច្ចការរបស់ប្រទេសជាតិផងដែរ ។ គម្ពីរដានីយ៉ែល ១០:១៣,២០ បង្ហាញថាមានក្សត្រអាក្រក់នៅក្នុងប្រជាជាតិជាច្រើន ហើយពួកគេត្រូវបានរារាំងដោយទេវតាដ៏វិសុទ្ធ។ តាមខគម្ពីរយោងនេះ និង គម្ពីរដានីយ៉ែល ១០:២១-១១:១ យើងសន្និដ្ឋានបានថា ពួកទេវតា ពិតជាត្រូវបានចាត់ឲ្យទទួលខុសត្រូវ កិច្ចការរបស់ប្រទេសជាតិមែន ។ តាមរយៈការប្រៀបធៀបខគម្ពីរយោងទាំងនេះនៅក្នុងគម្ពីរដានីយ៉ែល ជាមួយនឹងគម្ពីរអេភេសូ ១:២១; ៦:១២ និង គម្ពីរកូឡូស ១:១៦; ២:១៥ យើងឃើញថាសង្គ្រាមខាងវិញ្ញាណ កំពុងកើតឡើងគ្រប់ពេលវេលានៅឯស្ថានបរមសុខ។ សង្គ្រាមនេះស្តែងឡើងដោយ កម្លាំងនៃវិញ្ញាណអាក្រក់ បញ្ឆោតគំនិត និង សុច្ឆន្ទៈ របស់មនុស្សប្រុសស្រី ហើយជាលទ្ធផល ព្រលឹងរបស់គេទាំងមូលក៏ត្រូវបានបោកបញ្ឆោត។

នៅពេលខ្លះ សង្គ្រាមនេះហាក់បីដូចជាមានស្វិតស្វាញ ខ្លាំងណាស់ ដែលសូម្បីតែ*មហាទេវតា* ក៏បានចូលរួមច្បាំងដោយផ្ទាល់ផងដែរ។ *ទេវតាមីកែល* ដែលត្រូវបានគេហៅថា មហាទេវតា នៅក្នុងគម្ពីរយូដាស ៩ គឺជា*អ្នកដឹកនាំ* ទ័ពទេវតាដ៏វិសុទ្ធ។ លោកក៏ត្រូវបានគេហៅថា ក្សត្រានៃប្រជាជាតិអ៊ីស្រាអែល ហើយកិច្ចការរបស់លោកគឺបូករួមទាំងការការពារ និង ធ្វើឲ្យប្រជាជាតិនេះបានរីកចម្រើន (គម្ពីរដានីយ៉ែល ១០:១៣, ២១; ១២:១)។ លោកនឹងលើកសម្លេងរបស់លោកឡើងដោយការសរសើរតម្កើង នៅពេលព្រឹត្តិការណ៍នៃការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ចាប់ផ្តើម (គម្ពីរ១ថែស្សាឡូនិក ៤:១៦)។

មានតែទេវតាពីរអង្គតែប៉ុណ្ណោះ ដែលត្រូវបានលើកយកមកនិយាយចំឈ្មោះនៅក្នុងបទគម្ពីរ៖ ទេវតាមីកែល ជាមហាទេវតា និង ទេវតាកាព្រីយ៉ែលដែលត្រូវបានបង្ហាញថាជាអ្នកនាំសារពិសេស (គម្ពីរដានីយ៉ែល ៨:១៦; ៩:២១ គម្ពីរលូកា១:១៩,២៦)។ មានទេវតានាំសារដែលមិនបានរៀបរាប់ឈ្មោះជាច្រើនអង្គផ្សេងទៀត ក៏បានបម្រើព្រះអម្ចាស់ដែលមានសមត្ថភាពដូចនេះដែរ។

ព្រះគម្ពីរបានប្រទានភស្តុតាងតែបន្តិចបន្តួចប៉ុណ្ណោះ ទាក់ទងនឹងឋានៈផ្សេងទៀតរបស់ពួកទេវតាដ៏វិសុទ្ធ៖

១. ចេរូប៊ីន (គម្ពីរលោកុប្បត្តិ ៣:២៤ គម្ពីរ២ពង្សាវតារក្សត្រ ១៩:១៥ គម្ពីរអេសេគាល ១០:១-២២; ២៨:១៤-១៦) ។ ចេរូប៊ីន គឺជាអ្នកថែរក្សារាជបល្ល័ង្ករបស់ព្រះជាម្ចាស់។ ពួកគេក៏បានយាមឃ្លាំងទ្វារចូលទៅក្នុងសួនច្បារអេដែនផងដែរ។

២. សេរ៉ាភីម (គម្ពីរអេសាយ ៦:២,៦) ។ សេរ៉ាភីមប្រហែលជាអ្នកដឹកនាំនៅក្នុងការថ្វាយបង្គំព្រះជាម្ចាស់។ កិច្ចការចម្បងរបស់ពួកគេ គឺភាពវិសុទ្ធ និង ការបន្សុទ្ធ របស់ពួកអ្នកដែលបានប្រោសលោះ សម្រាប់ការថ្វាយបង្គំ និង ការបម្រើ ដ៏សមគួរមួយ។

៣. ពួកពិនិត្យត្រួតមើល [ពគប១៩៥៤] (គម្ពីរដានីយ៉ែល ៤:១៣,១៧) ។ ពិតណាស់ ពួកគេត្រូវបានចាត់ឲ្យឃ្លាំមើលសកម្មភាពជាក់លាក់ណាមួយ។ ពួកគេស្មោះត្រង់ជាមួយភារកិច្ចរបស់ពួកគេ ហើយដូចដែលបានឃើញនៅក្នុងអត្ថបទគម្ពីរនេះ ពួកគេក៏នាំសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្សជាតិផងដែរ។

៤. សត្វមានជីវិត (គម្ពីរវិវរណៈ ៤:៦-៩; ៦:១-៧; ១៥:៧)។ សត្វទេពទាំងនេះ ដូចជាមានភាពខុសគ្នានឹងសេរ៉ាភីម ចេរូប៊ីន និង ទេវតាធម្មតាផ្សេងទៀត។ ពួកគេហាក់ដូចជាថ្វាយបង្គំព្រះជាម្ចាស់ រៀបចំការវិនិច្ឆ័យរបស់ទ្រង់ និង មានសកម្មភាពចំពោះរាជបល្ល័ង្ករបស់ព្រះជាម្ចាស់។

សរុបមក ពពួកទេវតាដ៏វិសុទ្ធទាំងអស់នេះ បម្រើព្រះជាម្ចាស់យ៉ាងមានប្រសិទ្ធិភាព ហើយត្រៀមខ្លួនរួចរាល់ជានិច្ចដើម្បីបំពេញកិច្ចការតាមបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់។

លំហាត់អនុវត្តន៍

៩ ចូរផ្គូផ្គងឈ្មោះ ឬ ចំណែកថ្នាក់ (ខាងស្តាំ) ទៅជាមួយនឹងការរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

.....ក) ពួកពិនិត្យត្រួតមើលដែល ត្រូវបានចាត់ឲ្យឃ្លាំមើលសកម្មភាពអ្វីមួយ។	១) មីកែល
	២) កាព្រីយ៉ែល
.....ខ) ទេវតានាំសារពិសេសមួយរូប។	៣) ពួកទេវតាដ៏វិសុទ្ធ
.....គ) ទេវតាដែលការពាររាជបល្ល័ង្ករបស់ព្រះជាម្ចាស់	៤) ចេរូប៊ីន
.....ឃ) អ្នកដែលមមាញឹកអំពីរាជបល្ល័ង្ករបស់ព្រះជាម្ចាស់ ហើយជាអ្នកដឹកនាំការវិនិច្ឆ័យខ្លះៗ។	៥) សេរ៉ាភីម
	៦) ពួកពិនិត្យត្រួតមើល
.....ង) ក្រុមទេវតាទូទៅដែលចាំលើកព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ថ្វាយបង្គំទ្រង់ និង ឈរប្រុងប្រៀបធ្វើតាមព្រះរាជបញ្ជារបស់ទ្រង់។	៧) សត្វមានជីវិត
.....ច) ពួកទេវតាដែលទាក់ទងជាពិសេសទៅនឹងភាពវិសុទ្ធនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និងការថ្វាយបង្គំដ៏សមស្រប។	
.....ឆ) ក្បាត្រាដ៏ពិសេសរបស់សាសន៍អ៊ីស្រាអែល។	

ទំហំនៃសកម្មភាពរបស់ទេវតាដ៏វិសុទ្ធ

មុនពេលបញ្ចប់មេរៀននៃសកម្មភាពរបស់ពួកទេវតាដ៏វិសុទ្ធ យើងគប្បីនិយាយអំពីសេចក្តីសន្និដ្ឋានជាច្រើនដែលយើងបានដាក់ចេញពីបទគម្ពីរ ទាក់ទងនឹង *ទំហំ* ឬ *វិសាលភាព*នៃសកម្មភាពរបស់ពួកលោក។

ទីមួយ ទេវតាដ៏វិសុទ្ធគឺជាអ្នកបម្រើនៃឧបការគុណពិសេសរបស់ព្រះជាម្ចាស់ នៅក្នុងកិច្ចការមនុស្ស និង ក្រុមជំនុំរបស់ទ្រង់ ។ គម្ពីរហេប្រឺ១:៧ ថ្លែងថា៖ "ព្រះអង្គបានយកពួកទេវតាធ្វើជាខ្យល់និងយកពួកអ្នកបំរើរបស់ព្រះអង្គធ្វើជាអណ្តាតភ្លើង" (សូមមើលផងដែរនៅក្នុងគម្ពីរទំនុកតម្កើង១០៤:៤)។ យើងអាចនិយាយបានថា ព្រះជាម្ចាស់ប្រើប្រាស់ទេវតា ជាអ្នកនាំសាររបស់ទ្រង់ មិនមែននៅក្នុងកិច្ចការធម្មតារបស់ទ្រង់នោះទេ ប៉ុន្តែនៅក្នុងការបង្ហាញជាពិសេសនៃឫទ្ធានុភាពដែលទាក់ទងទៅនឹងច្បាប់របស់ទ្រង់ (គម្ពីរទុតិយកថា ៣៣:២ គម្ពីរកិច្ចការ ៧:៥៣ គម្ពីរកាឡាទី ៣:១៩ និងគម្ពីរហេប្រឺ២:២)។ ការអន្តរាគមន៍ ឬការចូលរួមពាក់ព័ន្ធ របស់ពួកទេវតានៅក្នុងដំណើរធម្មតានៃកិច្ចការរបស់មនុស្ស ហាក់បីដូចជា កើតមានឡើងទៅតាមពេលវេលា ហើយពិសេសខុសធម្មតាទៀតផង។ ពួកទេវតាមិនធ្វើអន្តរាគមន៍ទៅតាមការសម្រេចចិត្តរបស់ពួកគេឡើយ ប៉ុន្តែគេធ្វើតាមតែការបញ្ជារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ពួកគេមិនចូលមកចន្លោះកណ្តាលរវាងព្រះជាម្ចាស់នឹងប្រជារាស្ត្ររបស់ទ្រង់នោះ។

ទីពីរ ឫទ្ធានុភាពរបស់ពួកទេវតា ដែលផ្អែកទៅលើព្រះជាម្ចាស់ និង បានមកពីទ្រង់ផងនោះ ហាក់បីដូចជាត្រូវបានដាក់ឲ្យប្រើប្រាស់ដោយយោងទៅតាមច្បាប់ខាងវិញ្ញាណផង និង ខាងឯធម្មជាតិផង។ ខុសគ្នាពីព្រះជាម្ចាស់ ទេវតាមិនអាចបង្កើត ឬធ្វើសកម្មភាពដោយគ្មានការអនុញ្ញាតរបស់ព្រះជាម្ចាស់បាន ពួកគេមិនអាចស្ទង់ជម្រៅចិត្ត ឬ ផ្លាស់ប្តូរច្បាស់ធម្មជាតិបាននោះទេ។ ពួកគេមិនអាចមានឥទ្ធិពលមកលើគំនិតរបស់មនុស្សបាននោះទេ ដ្បិតការងារនេះជាការងាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ទេវតា ធ្វើការយ៉ាងជាក់ច្បាស់ ដែលស្ថិតនៅក្នុងដែនកំណត់។

ទីបី បទគម្ពីរបង្ហាញថា ជាទូទៅ ការបានបង្ហាញខ្លួនរបស់ពួកទេវតាគឺកើតឡើងនៅមុនពេល និង នាំមកជាមួយគ្នានូវចំណុចផ្លាស់ប្តូរយ៉ាងសំខាន់ថ្មីមួយនៅក្នុងផែនការរបស់ព្រះជាម្ចាស់ដែលកំពុងតែបើកសំដែង។ ឧទាហរណ៍ យើងឃើញសកម្មភាពរបស់ពួកទេវតានៅក្នុងពេលមួយនៃព្រឹត្តិការណ៍ទាំងនេះ។

- ការបង្កើតពិភពលោក (គម្ពីរយ៉ូប ៣៨:៧)
- នៅពេលផ្តល់ក្រឹត្យវិន័យ(គម្ពីរកាឡាទី ៣:១៩)
- នៅមុនពេល និងនៅក្នុងពេលព្រះគ្រិស្តប្រសូត (គម្ពីរលូកា១:១១, ២៦;២:១៣)
- នៅក្នុងអំឡុងពេល ព្រះយេស៊ូត្រូវបានល្បួងនៅក្នុងវាលរហោស្ថាន និង នៅក្នុងសួនកេតសេម៉ានី។ (គម្ពីរម៉ាថាយ ៤:១១ ឬគម្ពីរលូកា២២:៤៣)
- នៅក្នុងពេលប្រាសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (គម្ពីរម៉ាថាយ ២៨:២)
- នៅពេលព្រះយេស៊ូយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ (គម្ពីរកិច្ចការ ១:១០-១១)

- នៅក្នុងអំឡុងពេលកិច្ចការនៃគ្រាចុងក្រោយ មុនពេលដែលព្រះគ្រិស្តយាងត្រឡប់មកជាលើកទីពីរ (សូមមើលខគម្ពីរយោងជាច្រើន អំពីសកម្មភាពឬ កិច្ចការរបស់ទេវតានៅក្នុងកណ្ឌគម្ពីរវិវរណៈ និង គម្ពីរម៉ាថាយ ២៥:៣១)។

លំហាត់អនុវត្តន៍

១០ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងក្នុងឃ្លាបំពេញត្រឹមត្រូវ ដែលរៀបរាប់អំពីសកម្មភាពរបស់ពួកទេវតាដ៏វិសុទ្ធ។ ពួកគេ...

ក) ធ្វើអន្តរាគមរវាងព្រះជាម្ចាស់ និង ប្រជារាស្ត្ររបស់ទ្រង់។
ខ) គឺជាអ្នកបម្រើពិសេសនៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់។
គ) បានបង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យ នៅពេលផ្តល់ក្រឹត្យវិន័យ។
ឃ) មានវត្តមាននៅពេលព្រះជាម្ចាស់បង្កើតពិភពលោក។
ង) ឧបករណ៍នៅក្នុងការជះឥទ្ធិពលទៅលើគំនិតរបស់មនុស្សម្នាក់។
ច) ទទួលខុសត្រូវនៅក្នុងការល្បួងមនុស្សដោយផ្ទាល់។
ឆ) ចូលរួមជាពិសេសនៅក្នុងការការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់។
ជ) គ្រប់គ្រងលើក្រឹត្យវិន័យនៅក្នុងស្ថានវិញ្ញាណ និង នៅក្នុងធម្មជាតិ។

សកម្មភាពដែលមានការរៀបចំរបស់ទេវតាមិនវិសុទ្ធ

វគ្គបំណែងទី៥. *រៀបរាប់អំពីសកម្មភាព និង វាសនាពួកទេវតាមិនវិសុទ្ធ និង អ្នកដឹកនាំរបស់ពួកគេ។*

ដូចដែលបានបង្ហាញថា ព្រះជាម្ចាស់មានរាជបល្ល័ង្ករបស់ទ្រង់ និង បរិវាររបស់ទ្រង់ ព្រះគម្ពីរក៏បានបង្ហាញថា នៅក្នុងស្ថាននៃវិញ្ញាណខ្មៅងងឹត អារក្សក៏មានការរៀបចំរបស់វាផងដែរ។ មានអ្នកខ្លះបានកត់សំគាល់យ៉ាងមោះមុតថា សាតាំងគឺជា "ស្វា" (ឬ "អ្នកធ្វើត្រាប់") តាមព្រះជាម្ចាស់។ សាតាំងមានបល្ល័ង្ក (គម្ពីរវិវរណៈ២:១៣)។ នៅក្នុងព្រះគម្ពីរ សាតាំងត្រូវបានគេហៅថា " ចៅហ្វាយរបស់លោកីយ៍" (គម្ពីរយ៉ូហាន១៤:៣០; ១៦:១១) និង " មេគ្រប់គ្រងរាជ្យលើអាកាស" (គម្ពីរអេភេសូ ២:២) ។ សាតាំងគឺជាមេគ្រប់គ្រងលើស្ថាប័នដ៏កំណាចមួយ។ ព្រះគម្ពីរបានថ្លែងថា សាតាំងមានទេវតារបស់វា (គម្ពីរម៉ាថាយ ២៥:៤១) ហើយទេវតាទាំងនេះប្រឆាំងជាមួយព្រះជាម្ចាស់ (គម្ពីរវិវរណៈ ១២:៧-៩) ។

ភស្តុតាងបន្ថែមទៀតអំពីស្ថាប័នដ៏កំណាចមួយនេះ ត្រូវបានលើកមកនិយាយនៅក្នុងលិខិតរបស់លោកប៉ូល ។ នៅក្នុងគម្ពីរកូឡូស ១:១៦ លោកនិយាយអំពី "រាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាច" ឯគម្ពីរអេភេសូ ៦:១២ ប្រាប់អំពី "ពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះ.....អំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ" ។ ទាំងអស់នេះ គឺដូចគ្នាជាមួយនឹង " ពួកគ្រប់គ្រង និងពួកមានអំណាច" ដែលព្រះគ្រិស្តបានយកឈ្នះដោយសារឈើឆ្កាង (គម្ពីរកូឡូស ២:១៥)។ នៅក្នុងបទគម្ពីរយោងទាំងនេះ យើងឃើញពីភស្តុតាងពីការរៀបចំទៅតាមហាន:

ដោយផ្អែកលើកម្រិតនៃអំណាច។ ការរៀបចំដ៏កំណាចនេះ ត្រូវបានរៀបចំឡើងដើម្បីប្រឆាំងទាស់ជាមួយព្រះអម្ចាស់យេស៊ូគ្រិស្ត ហើយធាតុផ្សំផ្សេងៗនៃអំណាចរបស់សាតាំងទាំងអស់នេះ ប្រកាន់គោលជំហរផ្ទុយពីព្រះជាម្ចាស់ និង ប្រជារាស្ត្ររបស់ទ្រង់។ យើងដឹងរឿងជាច្រើនអំពី ទេវតាមិនវិសុទ្ធ តាមរយៈការពិនិត្យទៅលើអ្នកដឹកនាំរបស់ពួកគេ។

មេដឹកនាំរបស់ពួកគេ

ទេវតាមិនវិសុទ្ធ តែងតែទាស់ជាមួយព្រះជាម្ចាស់ ហើយព្យាយាមបំផ្លាញបំណងព្រះហឫទ័យរបស់ទ្រង់។ យើងឃើញពីភស្តុតាងនៃការនេះនៅក្នុងឈ្មោះដែលគេបានដាក់ឲ្យមេដឹកនាំរបស់ពួកគេ៖

១. មេដឹកនាំនោះត្រូវបានគេហៅថា *សាតាំង* ដែលមានន័យថា *បច្ចាមិត្រ* ឬ *គូរបដិបក្ស* ។ សាតាំងគឺជាបច្ចាមិត្រជាចំបងរបស់*ព្រះជាម្ចាស់* ។ គេក៏ជាបច្ចាមិត្ររបស់*មនុស្សជាតិ* ផងដែរ (គម្ពីរសាការី ៣:១ គម្ពីរម៉ាថាយ ១៣:៣៩ គម្ពីរ១ពេត្រុស ៥:៨)។

២. គេត្រូវបានហៅថា *អារក្ស ឬ មារ* ដែលមានន័យថា *អ្នកមូលបង្កាច់គេ* (អ្នកដែលធ្វើការចោទប្រកាន់មិនពិតត្រឹមត្រូវ ទាស់ជាមួយនឹងនរណាម្នាក់) ។ គេមូលបង្កាច់ព្រះជាម្ចាស់ទៅកាន់មនុស្ស (គម្ពីរលោកុប្បត្តិ ៣:១-៤) និង មូលបង្កាច់មនុស្សទៅកាន់ព្រះជាម្ចាស់ (គម្ពីរយ៉ូប ១:៩ ,១៦ គម្ពីរវិវរណៈ ១២:១០) ។

៣. ដោយសារតែ គេបញ្ឆោតចិត្ត (ល្បួង)មនុស្សឲ្យធ្វើអំពើបាប គេត្រូវបានហៅថា *អ្នកល្បួង* ។ វិធីសាស្ត្ររបស់គេគឺ ការបង្ហាញឲ្យឃើញពីការដោះសារដ៏សមហេតុសមផលបំផុតសម្រាប់អំពើបាប ក៏ដូចជាផលប្រយោជន៍ដ៏អស្ចារ្យដែលសង្ឃឹមថានឹងទទួលបានការធ្វើអំពើបាបនោះ (គម្ពីរម៉ាថាយ ៤:៣ គម្ពីរ១ថែក្សាឡូនិក ៣:៥)។

ដោយសារតែសាតាំងមានដែនកំណត់ ហើយគ្មានឫទ្ធានុភាពគ្រប់ទាំងអស់ ដឹងគ្រប់យ៉ាង ឬមានវត្តមាននៅគ្រប់ទីកន្លែងបាន វាប្រើប្រាស់មធ្យោបាយផ្សេង ដើម្បីទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។ ប្រាកដណាស់ វាមិនអាចវាយប្រហារព្រះជាម្ចាស់បានដោយផ្ទាល់នោះទេ ដូច្នេះហើយវាក៏វាយប្រហារមនុស្សដែលជាស្នាព្រះហស្តដ៏ល្អក្រៃលែងរបស់ព្រះជាម្ចាស់ តាមរបៀបជាច្រើន៖

- វាកុហក (គម្ពីរយ៉ូហាន ៨:៤៤ គម្ពីរ២កូរិនថូស ១១:៣)
- វាល្បួង (គម្ពីរម៉ាថាយ ៤:១)
- វាលួច (គម្ពីរម៉ាថាយ ១៣:១៩)
- វាធ្វើទារុណកម្ម (គម្ពីរ២កូរិនថូស ១២:៧)
- វារារាំង (គម្ពីរ១ថេស្សាឡូនិក ២:១៨)
- វាវែង (បែកចែក ច្រោះ) (គម្ពីរលូកា ២២:៣១)
- វាក្លែងបន្លំ ដើម្បីធ្វើការបំភាន់ (គម្ពីរ២កូរិនថូស ១១:១៤)
- វាចោទប្រកាន់ (គម្ពីរវិវរណៈ ១២:១០)
- វាធ្វើទុក្ខបុកម្នេញជាមួយជំងឺ (គម្ពីរលូកា១៣:១៦)
- វាចូលសណ្ឋិត (គម្ពីរយ៉ូហាន១៣:២៧)

- វាសម្លាប់ រួចលេបត្រាប់ (គម្ពីរយ៉ូហាន៨:៤៤ គម្ពីរ១ពេត្រុស ៥:៨)

ដូចដែលយើងបានឃើញហើយថា សាតាំងគ្រប់គ្រងទេវតាអាក្រក់ជាច្រើន ដែលបានចូលរួមជាមួយវានៅពេលដែលវាបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ បើមើលទៅហាក់បីដូចជា ព្រះជាម្ចាស់បានអនុញ្ញាតឲ្យវារក្សាអំណាចដែលវាទទួលបាននៅក្នុងពេលដែលទ្រង់បង្កើតវាឡើងមក។ ពួកទេវតាមិនវិសុទ្ធដែលបានជ្រើសរើសដើរតាមវា ដោយមិនរក្សាសិទ្ធិអំណាចរបស់ពួកគេ និង ជម្រកដែលព្រះជាម្ចាស់បានប្រទានឲ្យ(គម្ពីរយូដាស៦) និង មិនបន្តស្មោះត្រង់ជាមួយនឹងព្រះអាទិកររបស់ពួកគេ គឺត្រូវបានបង្ហាញឲ្យឃើញច្បាស់តាមរយៈការបះបោររបស់ពួកគេ។ ពួកគេបានផ្តល់ភក្តីភាពរបស់ពួកគេទាំងស្រុងទៅដល់មេដឹកនាំរបស់ពួកគេ ហើយពួកគេសុខចិត្តផ្តល់ការបម្រើរបស់ពួកគេ ដើម្បីជួយវាឲ្យសម្រេចបាននូវបំណងដ៏អាក្រក់របស់វា។

លំហាត់អនុវត្តន៍

---

១១ ចូរផ្គូផ្គងពាក្យ ឬ ឈ្មោះ (ខាងស្តាំ) ទៅជាមួយនឹងសេចក្តីរៀបរាប់របស់ពាក្យនោះ (ខាងឆ្វេង)។

.....ក)	ជាគោលដៅនៅក្នុងការវាយប្រហាររបស់អារក្ស ឬ ជាមធ្យោបាយដែលវាអាចសងសឹកព្រះជាម្ចាស់។	១)	សាតាំង
		២)	មារ ឬ អារក្ស
		៣)	អ្នកល្បួង
.....ខ)	ជាអ្នករួមចំណែកជាមួយអារក្ស នៅក្នុងការប្រយុទ្ធទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។	៤)	មនុស្សជាតិ
		៥)	ទេវតាអាក្រក់
.....គ)	ផ្តល់ឲ្យឃើញពីគំនិតអំពីបច្ចាមិត្ត ឬ អ្នកទាស់ប្រឆាំង។		
.....ឃ)	ឈ្មោះដែលបានដាក់ឲ្យអ្នកដែលបញ្ឆោតចិត្តអ្នកផ្សេងមួយទៀតឲ្យធ្វើអំពើបាប។		
.....ង)	ឈ្មោះដែលត្រូវបានដាក់ឲ្យអ្នកដែលមូលបង្កាច់អ្នកដទៃ។		

សកម្មភាពរបស់ពួកគេ

ទេវតាមិនវិសុទ្ធទាស់ប្រឆាំងនឹងព្រះជាម្ចាស់ មនុស្សរបស់ទ្រង់ ព្រមទាំងកិច្ចការរបស់ទ្រង់ ដោយដើរតួជាផ្នែកយោធា (ប្រយុទ្ធ) នៃអាណាចក្រដ៏ខ្មៅងងឹតរបស់សាតាំង (គម្ពីរម៉ាថាយ ២៥:៤១ គម្ពីរអេភេសូ ៦:១២ គម្ពីរវិវរណៈ១២:៧-១២)។ មានមនុស្សខ្លះព្យាយាមបែងចែកឲ្យដាច់ពីគ្នា រវាងវិញ្ញាណទេវតាមិនវិសុទ្ធ នឹង អារក្ស ឬ មារ ប៉ុន្តែគ្មានភស្តុតាងណាមួយដែលបង្ហាញថា ភាវៈទាំងពីរនេះមិនមែនជាភាវៈតែមួយ និង ជារបស់តែមួយនោះទេ។

ទេវតាទាំងនេះព្យាយាមបំបែកប្រជារាស្ត្ររបស់ទ្រង់ចេញពីទ្រង់ (គម្ពីរ៉ូម ៨:៣៨) ។ ពួកគេទាស់ប្រឆាំងជាមួយនឹងទេវតាដ៏វិសុទ្ធ (គម្ពីរដានីយ៉ែល ១០:១២-១១:១) ធ្វើទុក្ខមនុស្សដោយជំងឺខាងផ្លូវកាយ និងផ្លូវចិត្ត (គម្ពីរម៉ាថាយ ៩:៣៣;១២:២២ គម្ពីរម៉ាកុស៥:១-១៦ គម្ពីរលូកា ៩:៣៧-៤២) ផ្សព្វផ្សាយសេចក្តីបង្រៀនមិនពិត (គម្ពីរ២ថេស្សាឡូនិក ២:១-១២ គម្ពីរ១ធីម៉ូថេ៤:១) និង សណ្ឋិតក្នុងមនុស្ស ហើយសូម្បីតែសត្វទៀតផង (គម្ពីរម៉ាថាយ ៤:២៤ គម្ពីរម៉ាកុស៥:៨-១៤ គម្ពីរលូកា ៨:២ គម្ពីរកិច្ចការ ៨:៧; ១៦:១៦)។

ទោះបីជាពួកទេវតាមិនវិសុទ្ធមិនចង់ក៏ដោយ ពេលខ្លះព្រះជាម្ចាស់ប្រើប្រាស់ពួកគេ ដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់ក្នុងការដាក់ទោសអ្នកមិនគោរពកោតខ្លាចព្រះជាម្ចាស់ (គម្ពីរទំនុកតម្កើង ៧៨:៤៩ គម្ពីរ១ពង្សាវតារក្សត្រ ២២:២៣) និង នៅអប់រំ និង ណែនាំមនុស្សល្អ (គម្ពីរយ៉ូប ១-២ គម្ពីរ១កូរិនថូស ៥:៥)។

វាសនារបស់ពួកគេ

ពួកទេវតាមិនវិសុទ្ធ ជួយនៅក្នុងការបង្ហាញពីអ្វីដែលនឹងកើតឡើងទៅលើអស់អ្នកអសីលធម៌។ ភស្តុតាងបទគម្ពីរខាងក្រោមនេះ រៀបរាប់អំពីវាសនារបស់ពួកគេ ៖

- អារក្សដែលសណ្ឋិតនៅក្នុងបុរសពីរនាក់ បានស្រែកទៅកាន់ព្រះយេស៊ូថា៖ "ព្រះបុត្រារបស់ព្រះជាម្ចាស់អើយ! តើព្រះអង្គចង់ធ្វើអ្វីយើងខ្ញុំ? ព្រះអង្គយាងមកទីនេះ ដើម្បីធ្វើទុក្ខទោសយើងខ្ញុំ មុនពេលកំណត់ឬ?" (គម្ពីរម៉ាថាយ ៨:២៩)។
- ព្រះយេស៊ូបានមានព្រះបន្ទូលអំពី " ភ្លើងដែលឆេះអស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសំរាប់ផ្តន្ទាទោសមារ*សាតាំង និងបរិវារ(ទេវតា)របស់វា" (គម្ពីរម៉ាថាយ ២៥:៤១)។
- លោកប៉ូលបានប្រាប់យើងថា៖ " វានឹងចេញមុខមក ហើយព្រះអម្ចាស់យេស៊ូនឹងបំផ្លាញវាដោយខ្យល់ដែលចេញពីព្រះឱស្ឋរបស់ព្រះអង្គរួចហើយ នៅពេលព្រះអង្គយាងមក ព្រះអង្គនឹងជាន់កំទេចវា ដោយរស្មីរុងរឿងរបស់ព្រះអង្គ។" (គម្ពីរ២ថេស្សាឡូនិក ២:៨)។
- លោកយ៉ាកុបបានមានប្រសាសន៍ថា៖ "ពួកអារក្សក៏ជឿដូច្នេះដែរ ហើយថែមទាំងភ័យញាប់ញ័រទៀតផង" (គម្ពីរយ៉ាកុប ២:១៩)។
- លោកយ៉ូហានបានមានប្រសាសន៍៖ "ដ្បិតមារ*បានចុះទៅរកអ្នករាល់គ្នាទាំងមានកំហោលចូលយ៉ាងខ្លាំងផង ព្រោះវាដឹងថា វានៅសល់ពេលតែបន្តិចប៉ុណ្ណោះ"។ (គម្ពីរវិវរណៈ ១២:១២)
- លោកយ៉ូហាន មានប្រសាសន៍ថា៖ "គេនឹងរងទុក្ខវេទនាទាំងថ្ងៃ ទាំងយប់ អស់កល្បជាអង្វែងតរៀងទៅ។" (គម្ពីរវិវរណៈ ២០:១០)។

លំហាត់អនុវត្តន៍

១២ ចូរអានបទគម្ពីរខាងក្រោម ហើយបំពេញប្រយោគខាងក្រោម។

ក) គម្ពីរ២ពេត្រុស ២:៤ ។ ដ្បិតព្រះជាម្ចាស់ពុំបានយោគយល់ដល់ពួកទេវតា*ដែលប្រព្រឹត្តអំពើបាបទេ ទ្រង់បានរុញពួកគេទម្លាក់ទៅក្នុង..... ដែល..... ហើយគេជាប់ឃុំឃាំងនៅទីនោះ រង់ចាំពេលព្រះអង្គ.....។

ខ) យូដាស ៦ ។ រីឯពួកទេវតា* ដែលពុំបានរក្សាឋានៈរបស់ខ្លួន តែបែរជាបោះបង់ចោលលំនៅរបស់ខ្លួន ផ្ទាល់ទៅវិញនោះ ព្រះជាម្ចាស់បានឃុំគេ.....ហើយគេនៅជាប់ចំណងអស់កល្បជានិច្ច រង់ចាំថ្ងៃដ៏អស្ចារ្យដែលព្រះជាម្ចាស់នឹង.....។

គ) ទំនុកតម្កើង ៧៨:៤៩។ ព្រះអង្គដាក់ទោសពួកគេ អោយរងទុក្ខលំបាកយ៉ាងសែនវេទនា ដោយចាត់ពួក.....ពួកគេ។

ឃ) គម្ពីរម៉ាថាយ៨:១៦ គម្ពីរម៉ាកុស ៩:២៥-២៦ ។ វិញ្ញាណអាក្រក់.....ក្នុងមនុស្ស។

ង) គម្ពីរលូកា ១៣:១០-១៦ ។ វិញ្ញាណអាក្រក់អាច.....។

ច) គម្ពីរវិវរណៈ ១២:៧-១២ គម្ពីរអេភេសូ ៦:១២។ កន្លែងដែលសាតាំង និង ទេវតាមិនវិសុទ្ធធ្វើសកម្មភាពគឺនៅ.....។

ចេញពីការសិក្សារបស់យើងទៅលើសកម្មភាព និង វាសនារបស់ពួកទេវតា យើងអាចទាញយកសេចក្តីសន្និដ្ឋានសំខាន់ខ្លះៗដូចជា៖

១. យើងមិនត្រូវភាន់ច្រលំទាក់ទងនឹងវិធីសាស្ត្ររបស់អារក្ស ហើយអនុញ្ញាតឲ្យវាបោកប្រាស់យើងបាននោះឡើយ (គម្ពីរ២កូរិនថូស ២:១១)។ យើងមិនត្រូវអនុញ្ញាតឲ្យវា មានកន្លែងឈរជើងនៅក្នុងជីវិតរបស់យើងឡើយ (គម្ពីរអេភេសូ ៤:២៧)។ ផ្ទុយទៅវិញ យើងត្រូវត្រៀមខ្លួនដើម្បីជំទាស់នឹងវា ដោយប្រើប្រាស់អាវក្រោះរបស់ព្រះជាម្ចាស់ (គម្ពីរយ៉ាកុប ៤:៧ គម្ពីរអេភេសូ ៦:១០-១៨)

២. យើងមិនត្រូវមើលស្រាលអំពីអារក្សឡើយ (គម្ពីរយូដាស៨-៩) ហើយក៏មិនត្រូវមើលងាយកម្រិតដែលវាហ៊ានបំផ្លាញជីវិតខាងឯវិញ្ញាណរបស់អ្នកជឿនោះដែរ។ ម្យ៉ាងវិញទៀត យើងមិនគួរភ្លេចសោះឡើយថា ព្រះយេស៊ូបានយកឈ្នះលើសាតាំងនៅលើឈើឆ្កាងរួចទៅហើយ (គម្ពីរហេប្រឺ ២:១៤) និងមិនត្រូវភ្លេចថា យើងរស់នៅដោយជំនឿ ដែលផ្អែកទៅលើជ័យជំនះមួយនោះ។

៣. អំណាចរបស់សាតាំង និង ទេវតាមិនវិសុទ្ធរបស់វា គឺមានដែនកំណត់នៅក្នុងពេលវេលា និង មានកម្រិតទៅតាមបំណងព្រះហឫទ័យដែលព្រះជាម្ចាស់អនុញ្ញាត្ត។ ពួកទេវតាទាំងនោះ មិនមានអំណាចគ្រប់ទាំងអស់ មិនដឹងគ្រប់យ៉ាង និង មិនមានវត្តមាននៅគ្រប់ទីកន្លែងឡើយ។

៤. យើងមិនត្រូវកំណត់ថាជំងឺ និង គ្រោះធម្មជាតិ ជាអំពើរបស់អារក្ស និង ទេវតារបស់វាឡើយ លុះត្រាតែនេះត្រូវបានបើកបង្ហាញជាក់លាក់។ អំណាចរបស់ពួកគេចំពោះការអាក្រក់គឺមានពិតប្រាកដតែនៅមានកម្រិត។

៥. ទោះបីជាពួកគេប្រឆាំងជាមួយព្រះជាម្ចាស់ ទ្រង់នៅតែបង្ខិតបង្ខំពួកគេឲ្យបម្រើតាមបំណងព្រះហឫទ័យរបស់ទ្រង់បាន។ នៅពេលដែលព្រះជាម្ចាស់ប្រើប្រាស់ទំនោរនៃការអាក្រក់របស់ពួកគេ ដើម្បីសម្រេចបាននូវបំណងព្រះហឫទ័យរបស់ទ្រង់ ទ្រង់*នឹង* ធ្វើការវិនិច្ឆ័យ និង ដាក់ទោសពួកគេនៅក្នុងពេលដែលបានកំណត់ណាមួយ។

៦. អំណាចនៃវិញ្ញាណអាក្រក់មកលើមនុស្សជាតិ គឺមិនឯករាជ្យលើឆន្ទៈរបស់មនុស្សនោះទេ។ វិញ្ញាណអាក្រក់មិនអាចប្រើប្រាស់អំណាចរបស់ពួកវាបាន ដោយគ្មានការអនុញ្ញាតពីមនុស្សបានឡើយ។ នេះមានន័យថា អ្នកជឿអាចជំទាស់នឹងអំណាចរបស់ពួកវា តាមរយៈការអធិស្ឋាន និង ជំនឿលើព្រះជាម្ចាស់! យើងមានសេចក្តីសន្យាដ៏ប្រាកដនេះ ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់មក៖ "កូនចៅអើយ អ្នករាល់គ្នាកើតមកពីព្រះជាម្ចាស់ ហើយអ្នករាល់គ្នាបានឈ្នះព្យាការី*ក្លែងក្លាយទាំងនោះ ដ្បិតព្រះអង្គដែលគង់នៅក្នុងអ្នករាល់គ្នា ទ្រង់មានអំណាចធំជាងម្ចាស់លោកីយ៍នេះទៅទៀត។" (គម្ពីរ១យ៉ូហាន៤:៤)។

លំហាត់អនុវត្តន៍

---

១៣ ចូរគូសរង្វង់នៅជុំវិញអក្សរដែលនៅខាងមុខប្រយោគនីមួយៗដែលត្រឹមត្រូវ។

ក) យើងឃើញពីភស្តុតាងនៃបំណងរបស់សាតាំងនៅក្នុងឈ្មោះដែលត្រូវបានដាក់ឲ្យវា។

ខ) ដោយសារតែសាតាំងមិនអាចវាយប្រហារព្រះជាម្ចាស់ដោយផ្ទាល់បាន វាប្រហារមនុស្ស ដើម្បីជាការសងសឹកព្រះជាម្ចាស់។

គ) អារក្សត្រូវបានបង្កើតឡើងដើម្បីឲ្យធ្វើជាអ្នកដឹកនាំទេវតាអាក្រក់ដែលបះបោរជាមួយនឹងព្រះជាម្ចាស់។

ឃ) ទេវតាមិនវិសុទ្ធត្រូវបានបង្កើនមកឲ្យមានអាក្រក់ ដោយស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

ង) ទេវតាអាក្រក់ គឺគ្មានដែនកំណត់នោះទេ ហើយអាចធ្វើរឿងទាស់ប្រឆាំងនឹងនរណាក៏បានគ្រប់ពេលទាំងអស់។

ច) ព្រះជាម្ចាស់ អាចប្រើពួកទេវតាអាក្រក់ ដោយមិនចាំបាច់មានការយល់ព្រមពីពួកគេ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ ដើម្បីដាក់ទោសមនុស្សដែលមិនគោរពកោតខ្លាចព្រះជាម្ចាស់ ឬ អប់រំមនុស្សល្អ។

ឆ) មានទេវតាអាក្រក់ខ្លះ ត្រូវនៅជាប់ឃុំ រហូតដល់ថ្ងៃវិនិច្ឆ័យទោសរបស់ពួកគេ ហើយមានខ្លះទៀតនៅមានសេរីភាពដើម្បីធ្វើកិច្ចការតាមបំណងរបស់អារក្ស។

ជ) សាតាំង និង ទេវតារបស់វា ស្ថិតនៅជាប់ក្នុងដែនកំណត់ក្នុងពេលវេលា ហើយអាចលាតសន្ធឹងបានតែទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អនុញ្ញាតឲ្យតែប៉ុណ្ណោះ។

ឈ) យោងទៅតាមបទគម្ពីរ អ្នកជឿគឺត្រូវបានបំពាក់បំប៉នយ៉ាងគ្រប់គ្រាន់ដើម្បីប្រឆាំងជាមួយនឹងអារក្ស និង កម្លាំងរបស់វា ហើយក៏ត្រូវបានបង្គាប់ឲ្យធ្វើយ៉ាងដូច្នោះដែរ ។

ញ) អារក្សមិនអាចចូល អ្នកជឿបាន ដោយផ្ទុយពីចិត្តរបស់គេបានឡើយ។

ការប្រឡងផ្ទាល់ខ្លួនឯង

ត្រូវ/ខុស ៗ ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគត្រឹមត្រូវ និង អក្សរ ខ នៅខាងមុខប្រយោគមិនត្រឹមត្រូវ។

.....១ ទេវតា ត្រូវបានបង្កើតឡើង ជាភាវៈខាងឯវិញ្ញាណ។

.....២ ទេវតាគ្រប់រូបគឺ ត្រូវបានបង្កើតមកឲ្យមានភាពវិសុទ្ធ។

.....៣ ពួកទេវតា អាចត្រូវបានគេហៅថា ក្រុមមួយ ឬ ពូជអម្បូរមួយ។

.....៤ ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃពួកទេវតា បង្ហាញឲ្យឃើញពីភស្តុតាងនៃការរៀបចំ ដែលហាក់បីដូចជា ផ្អែកទៅលើការងារ ឬ កិច្ចការនៃក្រុមនីមួយៗ។

.....៥ ទេវតាដែលចុះចោលឋានៈរបស់គេ និង ចាកចេញពីទីលំនៅរបស់គេ បានធ្វើដូច្នេះដោយជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ។

.....៦ ទេវតាមានភាពជាបុគ្គល មានសតិបញ្ញានិងអំណាចលើសពីមនុស្ស។

.....៧ ទេវតាភាគច្រើនគឺមានសព្វញ្ញុតភាព សព្វដ្ឋភាព និង សព្វានុភាព។

.....៨ ព្រះគម្ពីរបានបញ្ជាក់ថា ការធ្លាក់ចុះរបស់សាតាំងគឺជាលទ្ធផលនៃភាពក្រអឺតក្រទម ឬ អំនួតរបស់គេ។

.....៩ មានភស្តុតាងត្រូវបានលើកឡើង ដើម្បីគាំទ្រវត្តមានរបស់មហាទេវតា ចេរូប៊ីន សេរាភីម និង ទេវតាជាច្រើនផ្សេងទៀតដែលគ្មានតំណាងសំខាន់។

.....១០ អំណាចរបស់សាតាំងគឺមានដែនកំណត់នៅក្នុងពេលវេលា ហើយអាចលាតសន្ធឹងបានទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អនុញ្ញាត។

.....១១ ព្រះគម្ពីរបានថ្លែងថា យ៉ាងហោចណាស់មានទេវតា ពាក់កណ្តាល បានសម្រេចចិត្តដើរតាមសាតាំង ដូច្នេះក៏ត្រូវបានធ្លាក់ចុះជាមួយវា។

.....១២ អារក្សអាចធ្វើការល្បួងយើងដើម្បីឲ្យយើងធ្លាក់ចុះបាន ប៉ុន្តែវាមិនអាចធ្វើឲ្យយើងឲ្យធ្លាក់ចុះបានឡើយ។

.....១៣ មនុស្សអាចត្រូវអារក្សចូល ទាស់នឹងឆន្ទៈរបស់គេបាន ទោះបីជាពួកគេប្រឆាំងនឹងវាក៏ដោយ។

.....១៤ ព្រះគម្ពីរបានបង្ហាញថា មានទេវតាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលពួកគេបង្កើតបានជាកងពលមួយដែលមិនអាចកំណត់ចំនួនបាន។

.....១៥ ពាក្យថា ទេវតា មានន័យថា "អ្នកនាំសារ" និង រៀបរាប់ពីកិច្ចការដ៏ចម្បងមួយរបស់ពួកទេវតា។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៧ ខ) មានទេវតាជាច្រើនរាប់មិនអស់ ទាំងល្អនិងអាក្រក់ ។

១ ក) អ្វីៗសព្វសារពើ , ទាំងអ្វីៗដែលមើលឃើញ ទាំងអ្វីៗដែលមើលមិនឃើញ។

ខ) ជីវិត

៨ ក) ថ្វាយបង្គំ និង សរសើរតម្កើងព្រះជាម្ចាស់ ហើយធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ខ) បម្រើអ្នកដែលត្រូវប្រោសលោះ នៅលើផែនដី ក្នុងនាមជាវិញ្ញាណដែលចាំបម្រើ។

ឃ) ការពារ រំដោះ ដឹកនាំ លើកទឹកចិត្ត និង ផ្តល់កម្លាំងឲ្យមនុស្សរបស់ព្រះជាម្ចាស់។

ង) ដើរតួជាភ្នាក់ងារនៃការវិនិច្ឆ័យទោស និងការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់។

២ ខ) ភាវៈមានជីវិតអមតៈ ដែលនឹងមិនបាត់ទៅណានោះទេ។

៩ ក) ៦) ពួកពិនិត្យត្រួតមើល

ខ) ២) កាព្រីយ៉ែល

គ) ៤) ចេរូប៊ីន

ឃ) ៧) សត្វមានជីវិត

ង) ៣) ពួកទេវតាដ៏វិសុទ្ធ

ច) ៥) សេរ៉ាភីម

ឆ) ១) មីកែល

៣ ពួកលោកមិនដឹងគ្រប់យ៉ាង មិនមានឫទ្ធានុភាពគ្រប់ទាំងអស់ និង មិនមានវត្តមាននៅគ្រប់ទីកន្លែងនោះទេ។

១០ ខ) គឺជាអ្នកបម្រើពិសេសនៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់។

គ) បានបង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យ នៅពេលផ្តល់ក្រឹត្យវិន័យ។

ឃ) មានវត្តមាននៅពេលព្រះជាម្ចាស់បង្កើតពិភពលោក។

ឆ) ចូលរួមជាពិសេសនៅក្នុងការការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់។

៤ ក) ៤) គ្មានភេទ

ខ) ៧) គ្មានសព្វដ្ឋភាព

គ) ៦) មានឫទ្ធានុភាពខ្ពស់

ឃ) ៥) មានសតិបញ្ញា

ង) ២) ជាវិញ្ញាណ

ច) ១) ត្រូវបានបង្កើតឡើង

ឆ) ៨) មិនមែនជាមនុស្សដែលមានសិរីល្អនោះទេ។

ជ) ៣) មានភាពជាបុគ្គល

១១ ក) ៤) មនុស្សជាតិ
ខ) ៥) ទេវតាអាក្រក់
គ) ១) សាតាំង
ឃ) ៣) អ្នកល្បួង
ង) ២) មារ ឬ អារក្ស

៥ ក) មិនកាន់តាមសេចក្តីពិត
ខ) ប្រព្រឹត្តិអំពើបាប
គ) ហានៈរបស់ខ្លួន, បោះបង់ចោលលំនៅរបស់ខ្លួនផ្ទាល់ទៅវិញ
ឃ) ការអួតបំប៉ោង (ដែលមានន័យថា មោទនភាពជ្រុល)

១២ ក) នរកអវិចី , ងងឹតសូន្យ, វិនិច្ឆ័យទោស
ខ) ទុកក្នុងទីងងឹត, វិនិច្ឆ័យទោស
គ) ទេវតាអោយមកប្រហារ
ឃ) ចូលសណ្ឋិត
ង) ធ្វើឲ្យមនុស្សពិការ
ច) ស្ថានលើ និង ផែនដី

៦ ក) ២) អត្ថបទបញ្ជាក់
ខ) ១) គាំទ្រច្បាស់ៗ
គ) ២) អត្ថបទបញ្ជាក់
ឃ) ៣) មិនគាំទ្រសោះ
ង) ២) អត្ថបទបញ្ជាក់
ច) ១) គាំទ្រច្បាស់ៗ
ឆ) ១) គាំទ្រច្បាស់ៗ
ជ) ៣) មិនគាំទ្រសោះ
ឈ) ១) គាំទ្រច្បាស់ៗ
ញ) ៣) មិនគាំទ្រសោះ

១៣ គ), ឃ), និង ង) គឺមិនត្រឹមត្រូវទេ។ ឯចម្លើយផ្សេងទៀតដែលនៅសល់គឺសុទ្ធតែជាចម្លើយត្រឹមត្រូវ។

មេរៀនទី ៦ មនុស្សជាតិ៖ ប្រជារាស្ត្រនៃព្រះអាទិករ

មនុស្សមានចម្លើយជាច្រើនប្រភេទ ដើម្បីបកស្រាយពីប្រភពដើមរបស់មនុស្សជាតិ។ ទស្សនវិទូខំលើកហេតុផល អ្នកវិវត្តន៍និយមខំបង្ហាញសំណុំរឿងរបស់ពួកគេ អ្នកវិទ្យាសាស្ត្រធ្វើការប៉ាន់ស្មាន។ ការព្យាយាមរបស់អ្នកមិនជឿ ក្នុងការបកស្រាយអំពីប្រភពដើម និង ការអភិវឌ្ឍន៍របស់ពួកគេ បែរជាបន្សល់ត្រឹមតែភាពឥតន័យ ដ្បិតពួកគេជឿថា យើងគឺគ្រាន់តែជារឿងចៃដន្យមួយតែប៉ុណ្ណោះ ហើយគ្មានអត្ថន័យ និង គោលបំណងអ្វីនោះទេ។ ផ្ទុយទៅវិញ អ្នកនិពន្ធទំនុកតម្កើង បានធ្វើការឆ្លុះបញ្ចាំងទៅលើដើមកំណើតរបស់គាត់ ហើយមានប្រសាសន៍ទូលទៅកាន់ព្រះជាម្ចាស់ថា "ទូលបង្គំសូមលើកតម្កើងព្រះអង្គ ដ្បិតទូលបង្គំជាស្នាព្រះហស្តដ៏ល្អអស្ចារ្យ ទូលបង្គំដឹងច្បាស់ថាអ្វីៗដែលព្រះអង្គធ្វើ សុទ្ធតែល្អអស្ចារ្យទាំងអស់...ព្រះអង្គក៏បានកំណត់ចំនួនថ្ងៃនៃអាយុជីវិតរបស់ទូលបង្គំទុកក្នុងបញ្ជីរបស់ព្រះអង្គមុននឹងថ្ងៃទាំងនោះមកដល់ទៅទៀត។ (គម្ពីរទំនុកតម្កើង ១៣៩:១៤,១៦) ។

យើងត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់។ យើងត្រូវបានបង្កើតឡើង ដោយព្រះអាទិករនៃយើងដើម្បីគ្រប់គ្រងលើផែនដីនេះ ដោយភាពយុត្តិធម៌ ភាពច្នៃប្រឌិត និង ដោយភាពទទួលខុសត្រូវ។ ទ្រង់បានប្រទានបញ្ញាញាណ អារម្មណ៍ និង សមត្ថភាពក្នុងការធ្វើការសម្រេចចិត្តប្រកបទំនួលខុសត្រូវខាងឯសីលធម៌។ យើងមានសមត្ថភាព សម្រេចកិច្ចការបានជាច្រើន ប៉ុន្តែយើងក៏មានឱកាសនឹងបំផ្លាញព្រះអំណោយទានពីធម្មជាតិរបស់យើង និង បដិសេធមិនទទួលស្គាល់អ្នកដែលបានប្រទានអំណោយទានទាំងអស់នោះមក ផងដែរ។ មធ្យោបាយតែមួយគត់ ដែលយើងអាចដឹងពីសក្តានុពល ដែលព្រះជាម្ចាស់បានប្រទានមក គឺតាមរយៈការស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ទ្រង់។ ប៉ុន្តែ ការមិនស្តាប់បង្គាប់របស់យើងបាន ទាញយើងចុះមិនឲ្យឈានទៅដល់សក្តានុពលរបស់យើងទាំងនៅក្នុងពេលបច្ចុប្បន្ន និង ដរាបអស់កល្បជានិច្ច។

នៅក្នុងមេរៀនមុន យើងបានសិក្សាអំពីស្ថានខាងឯវិញ្ញាណ។ ឥឡូវនេះយើងនឹងមើលទៅលើប្រជានុរាស្ត្រមួយប្រភេទទៀតរបស់ព្រះជាម្ចាស់៖ អម្បូរមនុស្ស។ នៅពេលដែលអ្នកសិក្សាមេរៀននេះ អ្នកអាចនឹងយល់អំពីខ្លួនអ្នកប្រសើរជាងមុន ហើយយល់កាន់តែច្បាស់ថែមទៀតពីអ្វីដែលជាតួនាទី ក៏ដូចជាសិទ្ធិរបស់អស់អ្នកទាំងឡាយណាដែលទទួលស្គាល់អធិបតីភាពរបស់ព្រះជាម្ចាស់។

គម្រោងមេរៀន

ក. ដើមកំណើតរបស់មនុស្សជាតិ
ខ. និស្ស័យរបស់មនុស្សជាតិ
គ. ភាពអមត:របស់មនុស្សជាតិ

វត្ថុបំណងមេរៀន

នៅពេលដែលយើងបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ផ្តល់នូវភស្តុតាងដែលថាមនុស្ស គឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។
២. រកឃើញបទគម្ពីរណាដែលបញ្ជាក់ ឬ បង្ហាញអំពីភាពដូចគ្នារបស់មនុស្ស ទៅនឹងព្រះជាម្ចាស់ នៅក្នុងបទគម្ពីរដែលយើងបានផ្តល់ជូន។
៣. ប្រើប្រាស់បទគម្ពីរ ដើម្បីធ្វើការពិភាក្សាអំពីទិដ្ឋភាពរូបី និង ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ។
៤. បកស្រាយអំពីតួនាទីនៃមនសិការ និង ឆន្ទៈ ក្នុងការធ្វើការសម្រេចចិត្តយ៉ាងមានសីលធម៌។
៥. បកស្រាយគំនិតអំពីភាពអមត: និង អ្វីដែលកើតឡើងចំពោះមនុស្ស បន្ទាប់ពីគេបានស្លាប់ខាងឯរូបកាយហើយ។

សកម្មភាពក្នុងការសិក្សា

១. ចូរអានគម្ពីរលោកុប្បត្តិ ១-៣ ទុកជាសេចក្តីផ្តើមសម្រាប់មេរៀននេះ។ លើសពីនេះទៅទៀត អ្នកត្រូវតែស្វែងរក និង អានបទគម្ពីរយោងនីមួយៗដែលបានផ្តល់ជូននៅក្នុងមេរៀន ពេលណាអ្នករៀនដល់បទគម្ពីរទាំងនោះ។
២. ចូរសិក្សាមេរៀនតាមធម្មតា។ នៅពេលដែលអ្នកបញ្ចប់មេរៀននេះ ចូរធ្វើការប្រឡងផ្ទាល់ខ្លួនឯង និងផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

មនសិការ	វិវត្តន៍	អ្នកត្រួតពិនិត្យ
ដែលមានមនសិការ	ភាពអមត:	ភាពប្រហាក់ប្រហែលគ្នា
ផលវិបាក	ដែលមិនចេះខុស	មនុស្សក្រោមបង្គាប់

ក. ដើមកំណើតរបស់មនុស្សជាតិ

ស្នាព្រះហស្តដ៏ពិសេស

វត្ថុបំណងទី១. *ផ្តល់នូវភស្តុតាងដែលថាមនុស្ស គឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។*

ព្រះគម្ពីរបានថ្លែងយ៉ាងសមហេតុផល និង ត្រង់ៗទៅនឹងសំណួរដែលសួរថា៖ "តើមនុស្សជាតិកើតឡើងមកដោយរបៀបណា?" ព្រះគម្ពីរក៏បានផ្តល់នូវភស្តុតាងដែលស្តីអំពីដើមកំណើត គោលបំណង និងជោគវាសនារបស់យើងផងដែរ។ ព្រះគម្ពីរបានបង្ហាញមកកាន់យើងថា យើងគឺជាស្នាព្រះហស្តដ៏ពិសេសរបស់ព្រះជាម្ចាស់។

មនុស្សមានឯកលក្ខណៈ(តែមួយ)។ ព្រះគម្ពីរបានថ្លែងថា ពូជមនុស្សគឺជាលទ្ធផលដែលបានមកពីកិច្ចការពិសេសរបស់ព្រះជាម្ចាស់៖ "រីឯព្រះអម្ចាស់ ជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល ជាព្រះដែលបានបង្កើតជនជាតិនេះមកទ្រង់មានព្រះបន្ទូលថា……យើងនេះហើយដែលបានបង្កើតផែនដី ព្រមទាំងបានបង្កើតមនុស្សអោយរស់នៅលើផែនដីនេះផង។" (គម្ពីរអេសាយ ៤៥:១១-១២) ។ បទគម្ពីរផ្សេងៗទៀតបានផ្តល់ឲ្យនូវទីបន្ទាល់ដូចគ្នានេះដែរ។

លំហាត់អនុវត្តន៍

---

១ ចូរអានបទគម្ពីរ ហើយប្រាប់ពីអ្វីដែលបទគម្ពីរនីមួយៗប្រាប់យើងអំពីដើមកំណើតរបស់ពូជមនុស្សជាតិ។

ក) គម្ពីរលោកុប្បត្តិ ១:២៧

ខ) គម្ពីរលោកុប្បត្តិ ៥:១-២

គ) គម្ពីរលោកុប្បត្តិ ៦:៧

ឃ) គម្ពីរលោកុប្បត្តិ៩:៦

ង) គម្ពីរទុតិយកថា ៤:៣២

ច) គម្ពីរទំនុកតម្កើង ១០០:៣

ឆ) គម្ពីរយ៉ាកុប ៣:៩

ការបង្កើតភាវៈទាំងប៉ុន្មានដទៃទៀត គឺគ្រាន់តែបានមកពីការបញ្ជារបស់ព្រះជាម្ចាស់ ដែលបានកើតឡើងភ្លាមៗប៉ុណ្ណោះ (សូមមើលនៅក្នុងគម្ពីរលោកុប្បត្តិ ១:២០,២៤) ប៉ុន្តែសម្រាប់ការបង្កើតមនុស្សវិញ ព្រះជាម្ចាស់បានធ្វើកិច្ចការពិសេសមួយ។ ដំបូងទ្រង់បានសូន្យ រូបបុរសម្នាក់ចេញពីសារធាតុដែលមាននៅក្នុងផែនដី បន្ទាប់មកទ្រង់បានផ្លុំបញ្ចូលខ្យល់ដង្ហើមនៃជីវិតចូលទៅក្នុងច្រមុះរបស់បុរសម្នាក់នោះ (គម្ពីរលោកុប្បត្តិ ២:៧) ហើយបុរសម្នាក់នោះក៏ក្លាយទៅជាភាវៈមានជីវិត។ *ការបញ្ចូលខ្យល់ដង្ហើមនៃព្រះជាម្ចាស់*នេះបានធ្វើឲ្យនិស្ស័យខាងឯវិញ្ញាណមួយ បានមកពីព្រះជាម្ចាស់ ក្លាយជាផ្នែកមួយនៃមនុស្ស ដែលបានផ្តល់ឲ្យគាត់នូវឋានៈមួយដែលខ្ពង់ខ្ពស់លើសភាវៈទាំងប៉ុន្មានផ្សេងទៀត ដែលមានរៀបរាប់នៅក្នុងគម្ពីរលោកុប្បត្តិ ជំពូក១។ លើសពីនេះទៅទៀត ការបញ្ជារបស់ព្រះជាម្ចាស់ ដែលឲ្យមនុស្សគ្រប់គ្រង និង

ត្រួតត្រាលើផែនដី បញ្ជាក់ពីគម្លាតដ៏ធំមួយរវាងមនុស្សពីរនាក់ដំបូង និង ភាវៈនៅលើផែនដីផ្សេងទៀត នៅក្នុងលំដាប់លំដោយនៃការបង្កើត។ (១:២៨)។

យើងក៏អាចឃើញពីការគាប់ព្រះហឫទ័យលើមនុស្សជាពិសេសមួយ នៅពេលដែលព្រះជាម្ចាស់ *ប្រទានពរ* ពួកគេ ឲ្យបានពោរពេញដោយផលផ្លែ (គម្ពីរលោកុប្បត្តិ១:២៨;៥:២) ដើម្បីឲ្យពួកគេអាចបង្កើតមនុស្ស ពាសពេញផែនដី និង *ផ្តល់ឲ្យពួកគេនូវ អំណាចគ្រប់គ្រង* (ភាពជាអ្នកគ្រប់គ្រង) នៅលើភាវៈទាំងអស់ដែលមាននៅលើផែនដី និង គ្រប់ទាំងរុក្ខជាតិដែលមានគ្រប់ពូជទាំងអស់។

ភាពខុសគ្នាសំខាន់បំផុត រវាងមនុស្សមនុស្ស និង ភាវៈទាំងប៉ុន្មានផ្សេងទៀត គឺថា *មនុស្សគឺត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់* (គម្ពីរលោកុប្បត្តិ ១:២៦) ។ គ្មានភាវៈណាផ្សេងទៀតដែលត្រូវបានបង្កើតឡើងឲ្យដូចជាព្រះជាម្ចាស់នោះទេ គឺមានតែមនុស្សប៉ុណ្ណោះដែលទទួលបានសណ្ឋានរបស់ព្រះអាទិករ។ យើងនឹងបានឃើញនៅក្នុងមេរៀនបន្ទាប់ ថាភាពដូចគ្នារបស់យើងទៅជាមួយព្រះជាម្ចាស់ គឺមិនមែនខាងឯរូបកាយនោះទេ ប៉ុន្តែគឺជាការដូចគ្នាខាងឯ *សីលធម៌* និង *វិញ្ញាណ* វិញ។

យើងបានរកឃើញភស្តុតាងបន្ថែមទៀតអំពីនិស្ស័យពិសេសរបស់មនុស្ស នៅក្នុងភាពខុសគ្នាដែលយើងឃើញរវាងមនុស្ស និងសត្វ។ ចូរពិចារណាអំពីភាពខុសគ្នាខ្លះៗនៅក្នុងចំណោមភាពខុសគ្នាទាំងនេះ ៖

១. យើងមានអំណាចនៃការនិយាយ ដែលនោះគឺជាសមត្ថភាពដ៏អស្ចារ្យ ក្នុងការទំនាក់ទំនងគ្នា ទាំងនៅក្នុងគំនិតរូបី (ពិតជាក់ស្តែង) និង គំនិតអរូបី (ទ្រឹស្តី) តាមរបៀបប្រកបដោយភាពស្ទាត់ជំនាញ និង ភាពច្នៃប្រឌិត។ ឧទាហរណ៍មួយអំពីគំនិត*រូបី* (ពិតជាក់ស្តែង) គឺ៖ "ខ្ញុំរស់នៅក្នុងផ្ទះពណ៌សមួយ ដែលមានប្រាំបន្ទប់។ ឧទាហរណ៍អំពីគំនិត*អរូបី* (ទ្រឹស្តី) គឺ៖ "ការស្រឡាញ់គឺប្រសើរជាងការស្អប់"។ គំនិតទាំងពីរនេះ អាចយកទៅធ្វើទំនាក់ទំនងជាមួយនឹងមនុស្សដទៃទៀតបាន ព្រោះតែយើងមានសមត្ថភាពក្នុងការគិត យល់ និង បង្ហាញគំនិតរបស់យើងតាមរយៈពាក្យសំដី។ គ្មានសត្វណាផ្សេងទៀតអាចធ្វើយ៉ាងដូច្នេះបានឡើយ។

២. យើងមានសមត្ថភាពដើម្បីរីករាយជាមួយភាពស្រស់ស្អាត។ ប៉ុន្តែសត្វវិញ ហាក់បីដូចជាមិនដឹងពីតម្លៃនៃសួនច្បារដ៏ស្រស់ស្អាត លើសគំនរស្មៅដ៏អាក្រក់មួយនោះទេ។

៣. យើងមានសមត្ថភាពក្នុងការបែងចែករវាង ត្រូវ និង ខុស។ សត្វមិនមានសមត្ថភាពមួយនេះឡើយ។ ឧទាហរណ៍ សត្វឆ្កែមួយក្បាលអាចបង្ហាញឲ្យឃើញពីការមិនពេញចិត្ត នឹងការដាក់ទោសដោយសារតែវាបានមិនស្តាប់បង្គាប់ ហើយវាអាចនឹងត្រូវបានម្ចាស់ដាក់កំហិត ឬ បង្ខឹកឲ្យស្តាប់បង្គាប់ តាមរយៈការដាក់ទោសម្តងហើយម្តងទៀត ប៉ុន្តែវានៅតែមិនអាចដឹងថា ការដែលវាទៅលួចពងមាន់ ឬ ស៊ីកូនមាន់គឺជារឿងខុសឆ្គងខាងឯសីលធម៌នោះទេ។

៤. យើងដឹងច្បាស់ពីភាពចាំបាច់ ត្រូវថ្វាយបង្គំភាវៈដែលមានឋានៈខ្ពស់ជាងខ្លួន ប៉ុន្តែសត្វគ្មានទាំងសមត្ថភាពដើម្បីថ្វាយបង្គំ និងមធ្យោបាយក្នុងការសម្តែងភាពគោរពយ៉ាងជ្រាលជ្រៅនេះទេ។

៥. យើងអាចដាក់ផែនការទុកមុន រៀបចំសម្រាប់ពេលអនាគត និង ធ្វើការផ្លាស់ប្តូររឿងរ៉ាវផ្សេងៗ។ យើងរីករាយក្នុងការបង្កើតរចនាបទទីលំនៅថ្មី និង បែបបទសិល្បៈថ្មីៗ។ យើងរស់រានមានជីវិតជាបន្តបន្ទាប់ ដើម្បីកែច្នៃមជ្ឈដ្ឋានជុំវិញខ្លួនយើង ធ្វើឲ្យជីវិតកាន់តែមានភាពងាយស្រួល និង កាន់តែល្អប្រសើរឡើង។ ចំណែកសត្វវិញ គ្មានសមត្ថភាពក្នុងការច្នៃប្រឌិត និង មើលទៅថ្ងៃអនាគតបែបនេះបានឡើយ។ អ្វីៗដែលពួកវាធ្វើដើម្បីត្រៀមសម្រាប់ពេលមុខ គឺគ្រាន់តែជាការឆ្លើយតបទៅនឹងសភាវៈគតិរបស់វាប៉ុណ្ណោះ។ ឧទាហរណ៍ សត្វបក្សីមានសភាវៈគតិក្នុងការសាងសង់សំបុកសម្រាប់កូនៗរបស់ពួកវា ប៉ុន្តែជាច្រើនសតវត្សរ៍មកហើយ ពួកវានៅតែបន្តសាងសង់សំបុកដូចគ្នាទៅនឹងសំបុកដែលដូនតារបស់ពួកវាសាងសង់ដែរ។

ដូច្នេះហើយ វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ហើយថា មនុស្សគឺជាស្នាព្រះហស្តដ៏ពិសេសមួយរបស់ព្រះជាម្ចាស់។ យើងមិនមែនជារបស់ដែលកើតឡើងដោយចៃដន្យនោះទេ យើងមិនបាន "វិវត្តន៍" មកពីសត្វដែលតូចទាបនោះទេ។ យើងបានឃើញនៅក្នុងមេរៀនមុននេះ ថាព្រះជាម្ចាស់ដែលបានបង្កើតសាកលលោកមក ទ្រង់ក៏បានផ្គត់ផ្គង់ស្នាព្រះហស្តរបស់ទ្រង់ផងដែរ។ ធម្មជាតិដែលបណ្តោយឲ្យនៅតែឯង មិនអាចអភិវឌ្ឍន៍ទៅមុខបានទេ មានតែបាត់បង់គុណភាពវិញ។ អ្វីគ្រប់យ៉ាងនឹងសឹករឹចរឹល។ ភាពមានសណ្តាប់ធ្នាប់ ក៏ចាប់ផ្តើមក្លាយទៅជាគ្មានសណ្តាប់ធ្នាប់។ ដើម្បីរក្សារបស់ទាំងនេះ និង ធ្វើឲ្យវាបានកាន់តែល្អប្រសើរឡើង គឺចាំបាច់ត្រូវមានព្រះប្រាជ្ញាញាណ និង ថាមពលមកពីខាងក្រៅ ហើយខ្ពង់ខ្ពស់ជាអ្វីដែលមាននៅក្នុងប្រព័ន្ធមួយនោះ។ ដោយតាមរយៈកិច្ចការពិសេសនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ទើបធ្វើឲ្យមនុស្សដែលជាភាវៈដ៏អស្ចារ្យជាងគេនេះបានចាប់កំណើតឡើង។
(គម្ពីរកូឡុស ១:១៦-១៧)។

លំហាត់អនុវត្តន៍

---

២ តើប្រយោគណាខ្លះនៅខាងក្រោមនេះ ផ្តល់ភស្តុតាងដែលថាមនុស្សគឺជាស្នាព្រះហស្តដ៏ពិសេសមួយរបស់ព្រះជាម្ចាស់។

ក) ការបង្កើតមនុស្សគឺធ្វើទៅតាមរបៀបដូចគ្នា នឹងការបង្កើតរុក្ខជាតិ និង ជីវិតសត្វដែរ។

ខ) មានតែមនុស្សប៉ុណ្ណោះដែលបានទទួលជីវិត មកពីការផ្លុំខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់។

គ) មនុស្សទទួលបានអំណាចគ្រប់គ្រងលើជីវិតរុក្ខជាតិ និង សត្វ។

ឃ) មនុស្សត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចជាព្រះអាទិកររបស់ពួកគេ។

ង) មនុស្សគឺខុសពី ភាវៈផ្សេងទៀតនៅលើផែនដី ហើយថែមទាំងខ្ពង់ខ្ពស់ជាងភាវៈទាំងនេះផង។

ច) មានតែមនុស្សទេ ដែលមិនស្ថិតនៅក្រោមឫទ្ធានុភាពដែលខ្ពស់ជាងខ្លួន។

បង្កើតមកឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់

វត្ថុបំណងទី២. *រកឃើញបទគម្ពីរណាដែលបញ្ជាក់ ឬ បង្ហាញអំពីភាពដូចគ្នារបស់មនុស្ស ទៅនឹងព្រះជាម្ចាស់ នៅក្នុងបទគម្ពីរដែលយើងបានផ្តល់ជូន។*

ព្រះគម្ពីរបង្រៀនយើងថាមនុស្ស គឺត្រូវបានបង្កើតឡើងឲ្យមានសណ្ឋាន ឬ ភាពដូចគ្នាទៅនឹងព្រះជាម្ចាស់ (គម្ពីរលោកុប្បត្តិ ១:២៦-២៧; ៥:១; ៩:៦ គម្ពីរ១កូរិនថូស ១១:៧ គម្ពីរយ៉ាកុប ៣:៩)។ យើងអាចគិតគូរ ដូចជាព្រះជាម្ចាស់ដែរ ទាក់ទងនឹងការរចនា និង គោលបំណងនៃរបស់អ្វីមួយ។ យើងរាល់គ្នា អាចបង្កើតរបស់ដែលមានប្រយោជន៍ និង ស្រស់ស្អាត ទៅតាមរបៀបរៀងៗខ្លួន។ យើងក៏អាចស្វែងរក គោលការណ៍នៅក្នុងការបង្កើតរបស់សព្វសារពើ ដែលបានផ្តល់ភស្តុតាងបន្ថែមទៅឲ្យកិច្ចការដ៏ធ្ងៃតផ្ទង់របស់ព្រះជាម្ចាស់ នៅក្នុងការសិក្សារបស់យើងផងដែរ។ តើនៅមានអ្វីទៀតដែលរាប់បញ្ចូលនៅក្នុង "លក្ខណៈដូចជាព្រះជាម្ចាស់" នេះ? តើលក្ខណៈមួយនេះ*មិនរាប់បញ្ចូល*អ្វីខ្លះ?

ពាក្យថា "នៅក្នុងសណ្ឋានដូចជាព្រះជាម្ចាស់" មិនមែនមានន័យថាមនុស្សគឺជាការចម្លងដូចបេះដាក់របស់ព្រះជាម្ចាស់នោះទេ។ ន័យរបស់ពាក្យនេះគឺថា មនុស្សយើងស្រដៀងទៅនឹងព្រះជាម្ចាស់ក្នុងរឿងខ្លះ។ យើងបានឃើញនៅក្នុងមេរៀនទី១រួចមកហើយ ថាព្រះជាម្ចាស់មិនអាចត្រូវបាននរណាមើលឃើញឡើយ ហើយទ្រង់គឺជាវិញ្ញាណ។ ដូច្នេះយើងដឹងថាសណ្ឋានរបស់ព្រះជាម្ចាស់នៅក្នុងយើងនោះ គឺ*មិនមែន*ជា*លក្ខណៈដូចខាងឯសាច់ឈាម*នោះទេ។ ប្រសិនបើលក្ខណៈដូចជាព្រះជាម្ចាស់របស់យើងនោះមិនមែនខាងឯសាច់ឈាម តើជាអ្វីទៅ?

១. *បុគ្គលិកលក្ខណៈ។* ទោះបីជាព្រះជាម្ចាស់ជាវិញ្ញាណ វិញ្ញាណរបស់យើងរាល់គ្នាដែលជាមនុស្សអាចទាក់ទងជាមួយព្រះវិញ្ញាណរបស់ទ្រង់បាន ព្រោះយើងក៏ជាភាវៈដែលមានលក្ខណៈភាពជាបុគ្គលដូចជាព្រះជាម្ចាស់ផងដែរ។ យើងអាចនឹងមានឱកាស ដើម្បីធ្វើទំនាក់ទំនងជាមួយទ្រង់បាននៅក្នុងទំនាក់ទំនងជាបុគ្គលមួយ ហើយយើងក៏មានសមត្ថភាពក្នុងការមានទំនាក់ទំនងជាមួយភាវៈដទៃផ្សេងទៀតដូចជាព្រះជាម្ចាស់ដែរ។

២. *លក្ខណៈដូចខាងឯសីលធម៌។* យើងក៏មានសមត្ថភាពដើម្បីធ្វើការបែងចែករវាងល្អ និង អាក្រក់ដូចជាព្រះជាម្ចាស់ដែរ។ ដើមឡើយ បុគ្គលិកលក្ខណៈទាំងស្រុងរបស់មនុស្ស មានដូចជា សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ គឺចង្អុលទៅកាន់ព្រះជាម្ចាស់ដោយផ្ទាល់។ និស្ស័យខាងឯសីលធម៌របស់មនុស្ស គឺជាការចម្លងមួយដែលមានដែនកំណត់ ចេញពីនិស្ស័យខាងឯសីលធម៌ដ៏គ្មានដែនកំណត់របស់ព្រះជាម្ចាស់។ មនុស្សមានសេរីភាពក្នុងការធ្វើការជ្រើសរើស និង ធ្វើអ្វីៗប្រកបដោយការទទួលខុសត្រូវ។ មនុស្សអាចសាកល្បង ប្រើប្រាស់ វិនិច្ឆ័យ អភិវឌ្ឍន៍ និង រីកចម្រើន នៅពេលដែលគេប្រើប្រាស់សេរីភាពរបស់ពួកគេដើម្បីជ្រើសរើសរវាង ល្អ និង អាក្រក់។ ការពិត គឺថាមនុស្សក៏ដឹងខ្លួនច្បាស់ អំពីការចាំបាច់ត្រូវជ្រើសរើសរវាងត្រូវ និង ខុស។

៣. *និស្ស័យដែលប្រកបដោយវិចារណញ្ញាណ* យើងមានលក្ខណៈដូចទៅនឹងវិចារណញ្ញាណរបស់ព្រះជាម្ចាស់ ព្រោះតែនិស្ស័យដែលប្រកបដោយវិចារណញ្ញាណ ឬ សតិបញ្ញារបស់យើង សមត្ថភាពរបស់យើងក្នុងការញែកហេតុផល និង ការស្គាល់ព្រះជាម្ចាស់ ព្រមទាំងរឿងជាច្រើនផ្សេងទៀត។ សមត្ថភាពនេះក៏ អាចត្រូវបានចាត់ទុកថា ជាលក្ខណៈដូចខាងឯគំនិតរបស់យើង នឹងព្រះដែលបានបង្កើតយើងផងដែរ។

៤. *សមត្ថភាពគ្រប់គ្រង* ។ យើងរាល់គ្នាដូចជាព្រះជាម្ចាស់ ត្រង់សមត្ថភាពប្រើប្រាស់ក្នុងការប្រើប្រាស់អំណាចត្រួតត្រា និងការគ្រប់គ្រងលើអ្វីមួយ។ យើងអាចផ្សាំងសត្វដែលមានកម្លាំងខ្លាំងជាងយើង ។ យើងអាចគ្រប់គ្រងទន្លេដោយសាងសង់ទំនប់ ដើម្បីផលិតបានជាអគ្គីសនី។ យើងធ្វើឲ្យវាលខ្សាច់ មានផ្ការីកលូតលាស់ដូចនៅក្នុងតំបន់មានជីវជាតិដូចធម្មជាតិ។ សមត្ថភាពដែលព្រះជាម្ចាស់បានប្រទានមកនេះ គឺជាការឆ្លុះបញ្ចាំងតាមរបៀបតូចតាចមួយ អំពីអំណាចត្រួតត្រារបស់ព្រះជាម្ចាស់ នៅលើសាកលលោកទាំងមូល។

៥. ភាពយល់ច្បាស់ពីខ្លួនឯង។ ក្នុងនាមជាភាវៈមានភាពជាបុគ្គល ដែលត្រូវបានបង្កើតឡើងឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់ យើងទាំងអស់គ្នាមានការដឹងអំពីខ្លួនឯង។ តាំងពីពេលដំបូងនៅក្នុងជីវិត កុមារចាប់ផ្តើមទទួលអារម្មណ៍ថា ពួកគេគឺផ្សេងពី មនុស្សគ្រប់គ្នានៅក្នុងក្រុមគ្រួសាររបស់គេ។ ពួកគេគឺមានតែខ្លួនឯង។ មិនថាគ្រួសាររបស់គេតម្រូវឲ្យធ្វើអ្វី មិនថាវប្បធម៌នៅជុំវិញក៏ពួកគេដឹងថាពួកគេគឺដាច់ដោយឡែក។ ពួកគេមានក្តីសុបិន្ត មហិចតា ក្តីសង្ឃឹម ភាពភ័យខ្លាច និង បំណងចិត្តផ្ទាល់ខ្លួន។ ពួកគេមិនដូចភាវៈដទៃផ្សេងទៀតទេ។ សត្វទាំងឡាយផ្សេងទៀត មិនមានភាពយល់ច្បាស់ពីខ្លួនឯងនេះទេ។

៦. *និស្ស័យខាងឯសង្គម។* មូលដ្ឋានគ្រឹះនៃនិស្ស័យខាងឯសង្គមរបស់ព្រះជាម្ចាស់ គឺមេត្រីភាពរបស់ព្រះជាម្ចាស់ ឬ សេចក្តីស្រឡាញ់របស់ទ្រង់។ នៅក្នុងភាពអស់កល្បជានិច្ច ព្រះជាម្ចាស់បានរកឃើញគោលបំណងនៃសេចក្តីស្រឡាញ់របស់ទ្រង់នៅក្នុងព្រះត្រៃឯក។ ព្រះយេស៊ូបានមានព្រះបន្ទូលថា៖ "ខ្ញុំបានស្រឡាញ់អ្នករាល់គ្នា ដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។ ចូរទុកសេចក្តីស្រឡាញ់របស់ខ្ញុំអោយស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ... ចូរអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។" (គម្ពីរយ៉ូហាន១៥:៩,១២)។ ដោយយើងបានទទួលនិស្ស័យខាងឯសង្គមមួយនេះ យើងស្វែងរកទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង អ្នកដទៃផ្សេងទៀត ព្រមទាំងបានរៀបចំជីវិតដោយយោងទៅតាម ក្រុមសង្គមដំបូងគេបង្អស់មួយ៖ គ្រួសាររបស់យើង។ សេចក្តីស្រឡាញ់ និង ចំណាប់អារម្មណ៍របស់យើងលើអ្នកដទៃ បានមកផ្ទាល់ពីផ្នែកសង្គមនៃនិស្ស័យរបស់យើងនេះហើយ។

លំហាត់អនុវត្តន៍

៣ ចូរស្វែងរកខគម្ពីរខាងក្រោមនេះ ហើយប្រាប់ពីភាពដូចគ្នារបស់មនុស្សទៅជាមួយនឹង ព្រះជាម្ចាស់ ដែលមាននៅក្នុងខគម្ពីរនីមួយៗ។

ក) គម្ពីរលោកុប្បត្តិ ២:១៨

ខ) គម្ពីរអេភេសូ ៤:២៤

គ) គម្ពីរកូឡូស ៣:១០

ឃ) គម្ពីរទំនុកតម្កើង ១៣៩:១៣-១៦

ង) គម្ពីររ៉ូម ១០:៨-១១

ច) គម្ពីរលោកុប្បត្តិ ១:២៦,២៨

ឆ) គម្ពីរ១ពេត្រុស ១:១៥

ព្រះគម្ពីរបានផ្តល់យើងឲ្យនូវដំណើររឿងដ៏សមហេតុផលមួយ អំពីដើមកំណើតរបស់មនុស្ស។ ដំណើររឿងទាំងនេះ និយាយអំពីនិស្ស័យ និង សក្តានុភាពដែលព្រះបង្កើតមកជាមួយពួកមនុស្ស។ រឿងទាំងនេះក៏បានបង្ហាញការពិតអំពីភាពដូចគ្នារបស់យើងទៅនឹងព្រះអាទិការរបស់យើង ។ រឿងនេះជួយយើងឲ្យបានឃើញថាតើ យើងពិសេស និង ខ្ពង់ខ្ពស់កម្រិតណា បើធៀបជាមួយសត្វផ្សេងៗ ទៀត។ព្រះគម្ពីរក៏បានបង្រៀនយើងថា រួមជាមួយនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់យើងដែលជាភាវៈដែលមានសីលធម៌ យើងមានទំនួលខុសត្រូវ យ៉ាងសំខាន់ខ្លះៗ ជាទំនួលខុសត្រូវដែលជះឥទ្ធិពលលើជោគវាសនាអស់កល្បជានិច្ចរបស់យើង ដែលយើងនឹងធ្វើការសិក្សានៅក្នុងមេរៀនបន្ទាប់ទៀតនេះ។

ខ. និស្ស័យរបស់មនុស្សជាតិ

វត្ថុបំណងទី៣. *ប្រើប្រាស់បទគម្ពីរ ដើម្បីធ្វើការពិភាក្សាអំពីទិដ្ឋភាពរូបី និង ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ។*

ប្រសិនបើយើងមានការយល់ដឹងបានពេញលេញជាងនេះ អំពីនិស្ស័យរបស់មនុស្ស នោះនឹងមានភាពងាយស្រួលសម្រាប់យើងដោះស្រាយបញ្ហា និង យល់ពីរបៀប និង មូលហេតុដែលយើងប្រព្រឹត្តិអំពើដូចដែលយើងបានធ្វើ ។ ជារឿងពិតណាស់ ដែលថាមនុស្សគឺជាស្នាព្រះហស្តដ៏ស្មុគស្មាញមួយ មនុស្សមានរូបកាយមួយដ៏គួរឲ្យស្ងប់ស្ងែង មានគំនិតដែលចេះគិតច្រើន និង សមត្ថភាពក្នុងបែងចែករវាងត្រូវ និង ខុស។ ទាំងនេះគឺគ្រាន់តែជាលក្ខណសម្បត្តិ ដ៏លេចធ្លោមួយចំនួនតូចរបស់យើងតែប៉ុណ្ណោះ។ ការរៀបរាប់នេះ បង្ហាញមកកាន់យើងថាយើងមានទិដ្ឋភាព*រូបី* ឬ *រូបកាយ* ដែលអាចមើលឃើញ និង *ទិដ្ឋភាពអរូបី* ឬ គ្មានរូបកាយ ដែលមិនអាចមើលឃើញ មិនអាចវាស់វែង ឬ រិះគនៅក្នុងមន្ទីរពិសោធន៍បានឡើយ។ ឥឡូវនេះសូមពិចារណាអំពីទិដ្ឋភាព ឬ លក្ខណសម្បត្តិផ្សេងៗទាំងនេះនៃនិស្ស័យរបស់មនុស្ស។

ទិដ្ឋភាពរូបី

វាគឺជារឿងងាយស្រួលសម្រាប់យើង ក្នុងការសំគាល់ពីទិដ្ឋភាពរូបី ឬ រូបកាយ របស់មនុស្សជាតិ។ វាគឺជាអ្វីដែលយើងមើលឃើញនៅក្នុងបុគ្គលម្នាក់ទៀត។ វាគឺជាអ្វីដែល គ្រូពេទ្យអាចធ្វើការពិនិត្យ និង ធ្វើការវះកាត់បាន។ វាជាអ្វីដែលអាចថ្លឹង វាស់វែង និង វិភាគនៅក្នុងមន្ទីរពិសោធន៍បាន។ វានោះហើយគឺជាខ្លួនប្រាណរបស់មនុស្ស។

បទគម្ពីរបាននិយាយអំពីខ្លួនប្រាណជាញឹកញាប់ ហើយបានរួមបញ្ចូលនៅក្នុងការប្រោសលោះរបស់យើងផងដែរ (គម្ពីររ៉ូម ៨:២៣ គម្ពីរ១កូរិនថូស ៦:១២-២០)។ តើព្រះគម្ពីរបានផ្តល់តម្លៃអ្វី ទៅឲ្យខ្លួនប្រាណរបស់មនុស្ស? ស្របពេលដែលយើងទទួលបានការបង្រៀនថា ទិដ្ឋភាពដែលគ្មានរូបរបស់មនុស្ស គឺសំខាន់ខ្លាំងជាងខាងរូបកាយ (គម្ពីរម៉ាថាយ ១០:២៨) យើងក៏មិនត្រូវគិតថាខ្លួនប្រាណរបស់យើង គឺជាអ្វីដែលគួរឲ្យស្អប់ខ្ពើម និង អាក្រក់ជាប់នៅជាមួយយើងនោះដែរ។ ផ្ទុយទៅវិញ លោកសាវ័កប៉ុលបានបង្រៀនថា ទោះបីជាខ្លួនប្រាណរបស់យើងត្រូវផុយរលួយបន្ទាប់ការស្លាប់ហើយក៏ដោយ រូបកាយរបស់យើងនឹងត្រូវប្រោសឲ្យមានរស់ឡើងវិញយ៉ាងអស្ចារ្យនៅថ្ងៃណាមួយជាក់ជាមិនខាន ៖ "ព្រះអម្ចាស់យេស៊ូគ្រិស្ត..... ព្រះអង្គនឹងបំផ្លាស់បំប្រែរូបកាយដ៏ថោកទាបរបស់យើងនេះ អោយបានដូចព្រះកាយ ប្រកបដោយសិរីរុងរឿងរបស់ព្រះអង្គ" (គម្ពីរភីលីព ៣:២០-២១)។

នៅក្នុងសំណេរទៅកាន់ក្រុមជំនុំក្រុងកូរិនថូស លោកប៉ូលប្រាប់ថា រូបកាយរបស់អ្នកជឿ គឺជាសមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ លោកបានមានប្រសាសន៍ថា៖ រូបកាយរបស់ពួកគេគឺដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ដោយសារមូលហេតុនេះហើយ បានដាក់ទំនួលខុសត្រូវឲ្យគ្រិស្តបរិស័ទ ដើម្បីសរសើរតម្កើងព្រះជាម្ចាស់ជាមួយនឹងរូបកាយរបស់គេ (គម្ពីរ១កូរិនថូស ៦:១៥, ១៩-២០)។

ព្រះអម្ចាស់យេស៊ូបានលើកតម្កើងតម្លៃរូបកាយមនុស្ស យ៉ាងខ្ពស់បំផុត នៅពេលដែលទ្រង់បានចាប់កំណើតយករូបកាយជាមនុស្សដោយផ្ទាល់ព្រះអង្គ។ លោកលូកាបានកត់ត្រាថា ព្រះយេស៊ូបានរីកលូតលាស់មាឌ នៅពេលដែលទ្រង់មានវ័យចម្រើនឡើង (គម្ពីរលូកា ២:៤០) ។ ជាការពិត អ្នកសរសេរសំបុត្រផ្ញើទៅសាសន៍ហេប្រឺ បានប្រកាសថា វាគឺជារឿង*ចាំបាច់*មួយ ដែលព្រះអម្ចាស់នៃយើងត្រូវមានរូបកាយមួយ ដើម្បីឲ្យទ្រង់អាចជាបូជាចារ្យជាន់ខ្ពស់ដែលប្រកបដោយចិត្តអាណិតអាសូរដល់យើង និង ជាព្រះសង្គ្រោះដែលបានរំដោះបាបយើង (គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨)។

លំហាត់អនុវត្តន៍

៤ ចូរផ្គូផ្គងបទគម្ពីរយោង (ខាងស្តាំ) ទៅជាមួយនឹងសេចក្តីរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

.....ក) រូបកាយរបស់មនុស្សគឺជាស្នាព្រះហស្ត ដ៏អស្ចារ្យមួយរបស់ព្រះជាម្ចាស់ ដែលទ្រង់បានមានព្រះបន្ទូលប្រកាសថា ល្អប្រសើរណាស់។

.....ខ) ដោយសារតែព្រះយេស៊ូមានរូបកាយជាមនុស្ស ទ្រង់អាចធ្វើជាបូជាចារ្យជាន់ខ្ពស់ដែលប្រកបដោយចិត្តអាណិតអាសូររបស់យើងបាន។

.....គ) រូបកាយជាមនុស្សរបស់យើង និង ទិដ្ឋភាពផ្សេងក្នុងរូបកាយនោះ គឺត្រូវបានប្រើប្រាស់ជាគំរូមួយសម្រាប់តំណាងឲ្យព្រះកាយរបស់ព្រះគ្រិស្ត។

.....ឃ) រូបកាយត្រូវតែទទួលបានការលើកតម្កើងជាដំណាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

.....ង) រូបកាយជាមនុស្សរបស់យើងរាល់គ្នាក៏ត្រូវបានរួមបញ្ចូលទៅក្នុងការប្រោសលោះរបស់យើងផងដែរ។

.....ច) រូបកាយរបស់យើង ត្រូវយកទៅប្រើប្រាស់នៅក្នុងការបម្រើដ៏វិសុទ្ធ និង សមរម្យដល់ព្រះជាម្ចាស់។

.....ឆ) រូបកាយជាមនុស្សរបស់យើង នឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ និង កែប្រែឲ្យក្លាយជាដូចព្រះកាយដែលប្រកបដោយសិរីរុងរឿងរបស់ព្រះយេស៊ូ។

១) គម្ពីរលោកុប្បត្តិ ១:២៧,៣១
២) គម្ពីររ៉ូម១២:១
៣) គម្ពីរ១កូរិនថូស៦:១៥,១៩-២០
៤) គម្ពីរទំនុកតម្កើង១៣៩:១៣-១៦
៥) គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨
៦) គម្ពីរ១កូរិនថូស ៦:១៤
៧) គម្ពីរភីលីព ៣:២០-២១
៨) គម្ពីររ៉ូម៨:២៣
៩) គម្ពីរ១កូរិនថូស ១២:១២-២៧

ទដ្ឋិនាពអរូបី (គ្មានរូប)

ការស្គាល់ពីទដ្ឋិភាពរូបីរបស់យើងគឺមានភាពងាយស្រួលណាស់ តែវាគឺជារឿងពិបាកមួយក្នុងការរៀបរាប់អំពីអ្វីដែលបង្កើតបានជាខ្នាតនៃទដ្ឋិភាពអរូបី (គ្មានរូប)។ ឧទាហរណ៍ ព្រះគម្ពីរបានថ្លែងអំពី *ព្រលឹង* និង *វិញ្ញាណ* នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៥:២៣ ដែលរួមជាមួយរូបកាយ បង្កើតបានទៅជាបុគ្គលពេញលក្ខណៈមួយរូប។ ទោះជាយ៉ាងណាក្តី នៅក្នុងគម្ពីរម៉ាថាយ ១០:២៨ ព្រលឹងហាក់បីដូចជា តំណាងឲ្យទដ្ឋិភាពអរូបីទាំងមូលរបស់យើងតែម្តង។ តើយើងគឺជាភាវៈដែលជាទិដ្ឋភាពពីរ ឬ ជាភាវៈដែលជាទិដ្ឋភាពបី? តើព្រលឹង និង វិញ្ញាណគឺជារបស់តែមួយឬ ខុសពីគ្នា?

ជារឿងដ៏ពិបាកខ្លាំងណាស់ ក្នុងការកំណត់ថាតើ *ព្រលឹង* ឬ *វិញ្ញាណ* គឺជាទដ្ឋិភាពពីរផ្សេងគ្នានៃភាវៈទាំងមូលរបស់យើង ឬ តែមួយ និង ជារបស់ដូចគ្នា។ សូមចំណាំការនេះការយកចិត្តរបស់យើង នៅពេលដែលយើងសិក្សាឲ្យបានកាន់តែលំអិតជាងនេះទៀត អំពីធាតុផ្សំដែលគ្មានរូបរបស់យើង។

អ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះ ជឿថានៅពេលដែលព្រះជាម្ចាស់ បានបង្កើតមនុស្សដំបូង ទ្រង់បានផ្លុំខ្យល់ដង្ហើមតែមួយគត់ទៅក្នុងគាត់គឺ៖ ព្រលឹងដ៏រស់។ អ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះទៀត ជឿថាទិដ្ឋភាពអរូបីនៃខ្លួនរបស់យើង មានធាតុផ្សំពីរប្រភេទ។ ធាតុផ្សំមួយគឺ *ព្រលឹង* ដែលជាគោលការណ៍នៃជីវិត*ជីវសាស្ត្រ* ឬ ដែលផ្តល់ឲ្យយើងនូវដង្ហើម និង ធ្វើឲ្យយើងក្លាយជាភាវៈមានជីវិត។ ចំណែកធាតុផ្សំមួយទៀតគឺ *វិញ្ញាណ* ដែលជាមូលដ្ឋានគ្រឹះនៃជីវិត ប្រកបដោយ*សនិទានភាព* (ការរិះគិតពិចារណា) ឬ ជាអ្វីដែលទាក់ទងនឹងការពិចារណា ឬ ការយល់ដឹង។

លំហាត់អនុវត្តន៍

---

៥ ចូរអានខគម្ពីរខាងក្រោម ហើយប្រាប់ថាតើខគម្ពីរទាំងនេះ បានបញ្ជាក់អំពីទិដ្ឋភាពអរូបីមួយ ឬ ពីររបស់ផងមនុស្ស៖

ក) គម្ពីរលោកុប្បត្តិ ២:៧

ខ) គម្ពីរទំនុកតម្កើង ៨២:៦

គ) គម្ពីរ១កូរិនថូស ៥:៣

ឃ) គម្ពីរហេប្រឺ ៤:១២

ង) គម្ពីរ១ថេស្សាឡូនិក ៥:២៣

ជីវិតប្រកបដោយសនិទានភាព មានធាតុផ្សំជាច្រើន។ យើងនឹងបានឃើញថា ធាតុផ្សំបីយ៉ាងដំបូងក៏ជាទដ្ឋិភាពនៃបុគ្គលិកលក្ខណៈផងដែរ។ ធាតុផ្សំទាំងបីយ៉ាងនោះមានដូចខាងក្រោម៖

១. *ធាតុផ្សំខាងឯសតិបញ្ញា ៖* សមត្ថភាពដើម្បីយល់ដឹង ដើម្បីពិចារណា និង ដើម្បីចងចាំ។

២. *ធាតុផ្សំខាងឯអារម្មណ៍ ៖* សមត្ថភាពដើម្បីទទួលអារម្មណ៍ ក្នុងការទទួលរងនូវឥទ្ធិពលពីអ្វីដែលអ្នកនោះស្គាល់ ឬ ឆ្លងកាត់។

៣. *ឆន្ទៈ* ៖ សមត្ថភាពដើម្បីជ្រើសរើស ដើម្បីសម្រេចចិត្ត និង ធ្វើសកម្មភាព។

៤. *មនសិការ* ៖ ចំណេះដឹងអំពីខ្លួនឯង ទាក់ទងទៅនឹងខ្នាតគំរូអំពីរឿងត្រឹមត្រូវ និង រឿងខុស ដែលគេបានស្គាល់រួចមកហើយ។

នៅក្នុងការសិក្សារបស់យើង អំពីនិស្ស័យរបស់ព្រះជាម្ចាស់ (មេរៀនទី១) យើងបានដឹងថា យើងត្រូវបានបង្កើតមកជាមួយនឹងគ្រឿងផ្សំជាមូលដ្ឋាននៃបុគ្គលិកលក្ខណៈដែលមានដូចជា៖ សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ។ លក្ខណៈទាំងនេះ ជួយឲ្យយើងអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង ជាមួយមនុស្សដទៃទៀតតាមរបៀបប្រកបដោយទំនួលខុសត្រូវ និង មានអត្ថន័យ។ ធាតុផ្សំដែលគ្មានរូបទាំងនេះ រួមជាមួយនឹងជីវិតខាងឯសាច់ឈាមរបស់យើង ជួយឲ្យយើងអាចរស់នៅជាជីវិតពេញលេញ និង គ្រប់គ្រាន់។ យើងបានបង្គ្រាបបរិស្ថាននៅជុំវិញយើង ហើយដាក់យកអ្វីដែលចាំបាច់សម្រាប់មានជីវិតរស់ពីក្នុងបរិស្ថាននោះ។ យើងរៀនធ្វើការជាមួយអ្នកដទៃនៅក្នុងបរិយាកាសសង្គមមួយដ៏ស៊ីសង្វាក់គ្នា។ យើងព្យាយាមយ៉ាងខ្លាំងបំផុត ដើម្បីផ្គាប់ព្រះហឫទ័យព្រះអាទិករបស់យើង ដែលបានប្រទានអ្វីៗគ្រប់យ៉ាងដែលចាំបាច់សម្រាប់ជីវិតដ៏មានន័យ និង ការសង្គ្រោះដ៏អស់កល្បជានិច្ច។

ឆន្ទៈ របស់យើង និង *មនសិការ* របស់យើងគឺជាធាតុផ្សំដ៏មានសារៈសំខាន់នៃទដ្ឋិភាពខាងឯសីលធម៌នៃជីវិតអរូបីរបស់យើង ដែលយើងនឹងបានឃើញនៅក្នុងចំណុចបន្ទាប់ទៀតនៅក្នុងការសិក្សារបស់យើងនេះ។

លំហាត់អនុវត្តន៍

---

៦ ដោយយោងទៅតាមការពិភាក្សាខាងលើ យើងអាចដឹងយ៉ាងច្បាស់ថា

ក) យើងទាំងអស់គ្នា ផ្សំឡើងចេញពីធាតុផ្សំបីយ៉ាង៖ ខ្លួនប្រាណ ព្រលឹង និង វិញ្ញាណ។

ខ) ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗ ថាមនុស្សគឺជាភាវៈដែលមានបីចំណែក។

គ) យើងត្រូវបានបង្កើតឡើងដោយធាតុផ្សំពីរយ៉ាង៖ ខ្លួនប្រាណ និង ព្រលឹង។

ឃ) ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ៗថា មនុស្សគឺជាភាវៈដែលមានពីរចំណែក

ង) បទគម្ពីរបានថ្លែងអំពី ខ្លួនប្រាណ ព្រលឹង វិញ្ញាណ ដងដ្ហើមនៃជីវិត និង ពាក្យជាច្រើនផ្សេងទៀត ដើម្បីធ្វើការរៀបរាប់អំពីនិស្ស័យរបស់យើង ប៉ុន្តែមិនបានបង្ហាញឲ្យបានច្បាស់ៗ ថាតើយើងមាននិស្ស័យពីរចំណែក ឬក៏បីចំណែក។

៧ ធាតុផ្សំទាំងបួនយ៉ាងនៃជីវិតប្រកបដោយសនិទានភាព របស់មនុស្សលោកគឺមាន

....

....

ទដ្ឋានាពខាងឯសីលធម៌

វត្ថុបំណងទី៤. *បកស្រាយអំពីតួនាទីនៃមនសិការ និង ឆន្ទៈ ក្នុងការធ្វើការសម្រេចចិត្តយ៉ាងមានសីលធម៌។*

លក្ខណៈប្រកបដោយសនិទានភាព នៃជីវិតអរូបីរបស់យើង ដែលយើងទើបតែនឹងបានសិក្សារួចមកហើយ បានត្រៀមដើម្បីសម្រាប់សកម្មភាពត្រឹមត្រូវ ឬ ខុស។ សតិបញ្ញារបស់យើង ជួយឲ្យយើងដឹងពីបញ្ហាត្រូវ និង ខុស។ អារម្មណ៍របស់យើង បានជំរុញឲ្យយើងធ្វើដំណើរទៅតាមទិសដៅមួយ ឬ មួយផ្សេងទៀត ហើយឆន្ទៈរបស់យើងជាអ្នកសម្រេចរឿងនោះ។ ប៉ុន្តែបើគ្មានមនសិការរបស់យើងដែលជាធាតុផ្សំទីបួនទេ នោះនឹងមិនអាចមានសកម្មភាពដែលប្រកបដោយសីលធម៌បានឡើយ។

មនសិការរបស់យើងអាច ត្រូវបានគេហៅថា "សម្លេងមកពីខាងក្នុង" ដែលដាក់ក្រឹត្យវិន័យខាងឯសីលធម៌របស់ព្រះជាម្ចាស់ មកក្នុងយើងទៅតាមសកម្មភាពជាក់លាក់ណាមួយ ហើយជំរុញឲ្យយើងស្តាប់បង្គាប់ក្រឹត្យវិន័យនោះ។ ដើម្បីស្វែងយល់ឲ្យបានកាន់តែច្បាស់អំពី លក្ខណៈនៃអំណាចខាងឯសីលធម៌មួយនេះ យើងត្រូវពិចារណាអំពី*មនសិការ* និង *ឆន្ទៈ* ដ្បិតទាំងនេះគឺមានទាក់ទងនឹងទង្វើរបស់យើង។

មនសិការ

យើងឃើញយ៉ាងខ្លីៗរួចមកហើយថា មនសិការរបស់យើងគឺទាក់ទងជាមួយនឹង ឥរិយាបថ និង សកម្មភាពរបស់យើង។ មនសិការគឺជាញាណសតិដែលជួយឲ្យយើងធ្វើការវិនិច្ឆ័យបានយ៉ាងសមរម្យរវាងការធ្វើសកម្មភាព ឬ ការបង្កើតបានឥរិយាបថដែលនាំឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យ ឬ មិនគាប់ព្រះហឫទ័យ។ ព្រះជាម្ចាស់បានបើកបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ អំពីខ្នាតគំរូនៃការនៅរស់នៅដ៏សមស្របមួយ។ សេចក្តីបង្រៀន និង ការអនុវត្តន៍ជាក់ស្តែងនៃសេចក្តីពិតដ៏វិសុទ្ធ ដែលយើងទទួលបាន ជួយឲ្យយល់ពីរបៀបដែលយើងគួរតែរស់នៅ។ ដូច្នេះ អ្វីដែលយើងដឹងអំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដូចដែលបានបើកបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ និង អ្វីដែលបានដឹងនៅក្នុងការអនុវត្តន៍តាមសេចក្តីពិតមួយនេះ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង បង្កើតបានជាមូលដ្ឋានគ្រឹះដែលមនសិការអាចធ្វើសកម្មភាពបាន។

មនសិការត្រួតពិនិត្យ (ព្រមានអំពី ឬ ណែនាំអំពី) ភាពត្រឹមត្រូវ និង ភាពមិនត្រឹមត្រូវ នៅក្នុងឥរិយាបថដែលយើងរៀបនឹងស្តែងចេញមក ឬ ធ្វើសកម្មភាពចេញមក។ លោកសាវ័កប៉ូលបានផ្តល់នូវឧទាហរណ៍មួយអំពីរឿងនេះ នៅពេលដែលលោកមានប្រសាសន៍ទៅកាន់អស់អ្នកដែល "បង្ហាញអោយឃើញថា កិច្ចការដែលគម្ពីរវិន័យចែងទុកអោយធ្វើនោះ មានចារឹកនៅក្នុងដួងចិត្តរបស់គេស្រាប់ហើយ។ មនសិការរបស់គេ ព្រមទាំងការិះគិតរបស់គេ ដែលនាំអោយមានការចោទប្រកាន់ខ្លួន ឬដោះសាខ្លួន ក៏ផ្តល់សក្ខីភាពអំពីការនេះដែរ។" (គម្ពីររ៉ូម២:១៥)

ឧទាហរណ៍ សូមគិតពីអ្នកជំនួញគ្រិស្តបរិស័ទម្នាក់ ឈ្មោះចីរ៉ូម ដែលគាត់បានប្រឈមមុខជាមួយនឹងការសម្រេចចិត្តយ៉ាងដូច្នេះថា៖ "តើខ្ញុំគួរតែទៅញ៉ាំអាហារពេលល្ងាចនៅជាមួយដៃគូជំនួញដ៏សំខាន់ម្នាក់ នៅកន្លែងមួយដែលមានការកំសាន្តអាក្រក់ៗដែរឬទេ? ឬមួយខ្ញុំគួរប្រកាន់ភ្ជាប់លើគោលជំហររបស់ខ្ញុំ

ដែលថានេះគឺជារឿងមិនត្រឹមត្រូវ ទោះបីជាខ្ញុំអាចនឹងបាត់បង់កិច្ចសហប្រតិបត្តិការណ៍ជំនួញមួយនេះ ប្រសិនបើខ្ញុំមិនទទួលការអញ្ជើញមួយនេះ?

ខ្នាតគំរូរបស់ចឺរ៉ូមគឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គាត់ដឹងថា ព្រះជាម្ចាស់បានមានព្រះបន្ទូលអំពីការសេពគប់មិនត្រឹមត្រូវ (គម្ពីរ២កូរិនថូស ៧:១ គម្ពីរ១កូរិនថូស ១៥:៣៣)។ មនសិការរបស់គាត់*បញ្ជាក់* ថាការទទួលយកការអញ្ជើញនោះគឺជារឿងមិនត្រឹមត្រូវនោះទេ ព្រោះវាផ្ទុយពីខ្នាតគំរូរបស់ព្រះជាម្ចាស់។ មនសិការរបស់គាត់ក៏ *រំឭក* គាត់ពីកាតព្វកិច្ចរបស់ដែលត្រូវសម្តែងអាកប្បកិរិយាតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ ដូច្នេះ មនសិការរបស់ចឺរ៉ូមប្រកាន់ (សំគាល់ពីភាពខុស) រវាងសកម្មភាពត្រឹមត្រូវ និង សកម្មភាពមិនត្រឹមត្រូវដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដោយសារតែចឺរ៉ូមគឺជាគ្រិស្តបរិស័ទម្នាក់ មនសិការរបស់គាត់និយាយទៅកាន់គាត់ ដោយមានការចូលរួមពីព្រះវិញ្ញាណដ៏វិសុទ្ធ។

ប្រសិនបើចឺរ៉ូមមិនយកចិត្តទុកដាក់អំពីសក្តីភាពនៃមនសិការ និង ទំនួសខុសត្រូវខាងឯសីលធម៌របស់គាត់នោះទេ គាត់នឹងមានអារម្មណ៍ថា អាម៉ាស់ និង ស្តាយក្រោយ ហើយនឹងមានភាពភ័យខ្លាចចំពោះផលពិបាកនៃសកម្មភាពរបស់គេ។ ការចុះញ៉ែមជាមួយសេចក្តីល្បួង នាំមកនូវអារម្មណ៍បរាជ័យ ភាពបរាជ័យក្នុងការរស់នៅតាមខ្នាតគំរូរបស់ព្រះជាម្ចាស់។ អារម្មណ៍ដែលមានទាក់ទងនឹងភាពបរាជ័យគឺភាពអាម៉ាស់ ភាពស្តាយក្រោយ និង ភាពភ័យខ្លាច មិនមែនជាធាតុផ្សំនៃមនសិការនោះទេ ប៉ុន្តែជាអារម្មណ៍តែប៉ុណ្ណោះ។ ដូច្នេះ មនសិការដើរតួជាអ្នកវិនិច្ឆ័យតរិយាបថខាងឯគំនិត និង អាកប្បកិរិយារបស់យើង។

លំហាត់អនុវត្តន៍

---

៨ ចំពោះគ្រិស្តបរិស័ទម្នាក់ ការមិនស្តាប់បង្គាប់តាមមនសិការ នាំឲ្យមានអារម្មណ៍បីយ៉ាងកើតឡើងរួមមាន.....

ដោយព្រះជាម្ចាស់បានបង្កើតយើងមកជាមួយនឹងអ្នកត្រួតពិនិត្យ ឬ "សម្លេង" នៅខាងក្នុងនេះ យើងគួរតែស្វែងយល់បន្ថែមទៀតអំពីអ្វីដែលធ្វើបានចំពោះមនសិការរបស់យើង និង អ្វីដែលជាដែនកំណត់នៃមនសិការ។ ទីមួយ មនសិការក៏អភិវឌ្ឍន៍នៅពេលយើងលូតលាស់ និង ពេញវ័យ ដូចជាសតិបញ្ញាដែរ។ នៅពេលដែលបានយល់ពីទំនួលខុសត្រូវរបស់យើង យើងក៏ចាប់ផ្តើមយល់ពីផលពិបាកនៃសកម្មភាពរបស់យើងផងដែរ។ ទីពីរ ព្រះគម្ពីរបង្រៀនថា មនសិការក៏អាចសៅហ្មង ពុករលួយ និង ធ្វើឲ្យអស់ខ្លឹមសារបានដែរ៖

> អ្នកខ្លះនៅតែជំពាក់ចិត្តនឹងព្រះក្លែងក្លាយនៅឡើយ គេបរិភោគសាច់ទាំងនោះទុកដូចជាសំណែន ហើយដោយគោរិះគិតមិនបានដិតដល់ ក៏នឹកស្មានថា ខ្លួនត្រូវសៅហ្មង។
> (គម្ពីរ១កូរិនថូស៨:៧)
>
> ចំពោះអ្នកដែលមានចិត្តបរិសុទ្ធ អ្វីៗទាំងអស់សុទ្ធតែបរិសុទ្ធ រីឯអ្នកដែលមានចិត្តសៅហ្មង និងមិនជឿអ្វីៗទាំងអស់សុទ្ធតែមិនបរិសុទ្ធ ព្រោះ*ប្រាជ្ញា និងមនសិការរបស់គេសុទ្ធតែសៅហ្មង* ។
> (គម្ពីរទីតុស១:១៥)។

គេចាញ់បោកពុតត្បុតរបស់មេបោកប្រាស់។ *មនសិការរបស់អ្នកទាំងនោះជាប់ជាខ្ចុំបំរើរបស់អារក្ស* ។ (គម្ពីរ១ធីម៉ូថេ ៤:២) ។

បទគម្ពីរទាំងនេះបានបញ្ជាក់ថា ភាពឆ្វេសប្រហែសនៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ ការប្រើយកន្តើយនឹងសម្លេងរបស់មនសិការ និង ការបោះបង់ជំនឿ អាចធ្វើឲ្យបាត់បង់ប្រសិទ្ធិភាពរបស់ឆន្ទៈដែលជាមុខងារព្រះជាម្ចាស់ប្រទានឲ្យ។ ទោះជាយ៉ាងណាក្តី ព្រះគម្ពីរមិនបង្ហាញថា មនសិការអាចនឹងបំផ្លាញបាននោះទេ។

ទីបី មនសិការគឺមិនមែន*មិនចេះខុស* (គ្មានកំហុស មានតែភាពឥតខ្ចោះ) នោះទេ ។ នោះមានន័យថា មនសិការអាចនាំមនុស្សម្នាក់ឲ្យដើរខុសផ្លូវ ប្រសិនបើយកខ្នាតគំរូមិនត្រឹមត្រូវមកប្រើ។ មុនពេលមានហេតុការណ៍អាក្រក់កើតឡើងចំពោះលោកសាវ័កប៉ូលនៅតាមផ្លូវទៅក្រុងដាម៉ាស់ លោកសាវ័កប៉ូល ពិតជាមានភាពប្រាកដប្រជាចំពោះឥរិយាបថខុសឆ្គងរបស់គាត់ខ្លាំងណាស់។ លោកបាន*គិតថាលោកកំពុងតែធ្វើរឿងដែលត្រឹមត្រូវហើយ។* ចិត្តខ្នះខ្នែង និង ឥរិយាបថដ៏សុក្រិតរបស់លោក គឺសុទ្ធតែអាចបញ្ជាបាន ប៉ុន្តែសកម្មភាពរបស់លោក គឺពិតជាគួរឲ្យគម្រក់ខ្លាំងណាស់! ព្រោះតែការពិចារណារបស់លោក ទទួលយកការបកស្រាយមួយដែលមិនត្រឹមត្រូវចេញពីគម្ពីរសម័្ពន្ធមេត្រីចាស់ មនសិការបានមើលឃើញតែពីការបកស្រាយនោះ ហើយវាក៏នាំលោកឲ្យវង្វេង ។ (គម្ពីរកិច្ចការ ៩)។

ដូច្នេះ មនសិការរបស់យើង វិនិច្ឆ័យសកម្មភាព និង ឥរិយាបថរបស់យើងដោយផ្អែកលើមូលដ្ឋាននៃ៖

១. ចំណេះដឹងរបស់យើងអំពីអត្ថិភាពរបស់ព្រះជាម្ចាស់។
២. បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលបានបើកបង្ហាញ។
៣. ការយល់ដឹងខាងឯសីលធម៌ ដែលព្រះជាម្ចាស់បានប្រទានមក។
៤. អ្វីដែលយើងទទួលបានពីការបង្រៀន (អ្វីដែលដាក់ចូលទៅក្នុងមនសិការ)
៥. ខ្នាតគំរូសង្គម ដែលយើងបានទទួលយក។

យើងដឹងថា ចំពោះព្រះជាម្ចាស់យើងប្រកបដោយទំនួលខុសត្រូវ។ ទោះជាយ៉ាងណា ខ្នាតគំរូសង្គមមិននៅដដែលរហូតនោះទេ ដោយព្រោះតែអំពើបាប និង ការបដិសេធ ខ្នាតគំររបស់ព្រះជាម្ចាស់។ ដូច្នេះ ខ្នាតគំរូតែមួយគត់នៃមនសិការ ដែលព្រះជាម្ចាស់សព្វព្រះទ័យគឺជាខ្នាតគំរូផ្អែកលើព្រះបន្ទូលរបស់ទ្រង់ ដែលត្រូវបកស្រាយដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

លំហាត់អនុវត្តន៍

---

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) មនសិការប្រាប់យើង ថាតើយើងកំពុងរស់យ៉ាងមានទំនួលខុសត្រូវស្របទៅតាម ខ្នាតគំរូដ៏សមរម្យមួយដែរឬទេ។

ខ) គ្រិស្តបរិស័ទ តែងតែត្រូវបានដឹកនាំដោយខ្នាតគំរូសង្គម នៅក្នុងការកំណត់ថាអ្វីត្រូវ ឬអ្វីដែលខុស។

គ) មនសិការគឺតែងតែស្របតាមខ្នាតគំរូដែលវាផ្អែកលើ។

ឃ) ប្រសិនបើមនសិការផ្អែកលើខ្នាតគំរូនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះវាមិនអាចសៅហ្មង ពុករលួយ និង ធ្វើឲ្យអស់ខ្លឹមសារនោះទេ។

ង) មនសិការរបស់គ្រិស្តបរិស័ទម្នាក់គឺ កំណត់ដោយការបកស្រាយរបស់គាត់អំពីសកម្មភាពត្រូវ និង ខុស។

ច) មនសិការអាចទៅជាសៅហ្មង ខូចបង់ និង បាត់បង់ខ្លឹមសារ ប្រសិនបើវានៅតែត្រូវបានគេប្រើយកន្តើយ។

ឆ) មនសិការរបស់មនុស្សម្នាក់អាចនឹងត្រូវបំផ្លាញ ប្រសិនបើអ្នកនោះ នៅតែបន្តធ្វើសកម្មភាពតាមរបៀបដែលផ្ទុយពីមនសិការរបស់គាត់បានប្រាប់។

ឆន្ទៈ

ឆន្ទៈគឺជាញាណសតិរបស់យើងក្នុងការជ្រើសរើស ឬ ធ្វើការសម្រេចចិត្ត រវាងសកម្មភាពទាំងឡាយណាដែលអាចកើតមានឡើង។ និយាយអំពីសកម្មភាពដែលអាចកើតមានឡើង យើងត្រូវស្គាល់វាឲ្យច្បាស់មុនពេលដែលយើងបង្ហាញអារម្មណ៍របស់យើងទៅចំពោះសកម្មភាពទាំងអស់នោះ។ បន្ទាប់មក ដោយផ្អែកលើចំណេះដឹង និង អារម្មណ៍ យើងអាចជ្រើសរើសសកម្មភាពជាក់លាក់ណាមួយតាមរយៈសកម្មភាពនៃឆន្ទៈរបស់យើង។ យើងអាចជ្រើសរើសបានដោយសេរី ដើម្បីធ្វើអ្វីដែលស្របទៅជាមួយនឹងនិស្ស័យរបស់យើង ។ យើងអាចមានឆន្ទៈក្នុងការរត់បាន ប៉ុន្តែយើងមិនអាចមានឆន្ទៈក្នុងការរស់នៅក្នុងទឹកដូចជាត្រីបាននោះទេ។ ការរត់នោះគឺ ស្របទៅតាមនិស្ស័យរបស់យើង ឯការរស់នៅក្នុងទឹកគឺមិនស្របនឹងនិស្ស័យរបស់យើងនោះទេ។ ដូចដែលយើងនឹងបានឃើញនៅក្នុងមេរៀនបន្ទាប់របស់យើងថា យើងត្រូវឃាត់ឃាំងឲ្យមានកំណត់ដោយសារតែអំពើបាប ដូច្នេះហើយ យើងមិនអាចផ្លាស់ប្តូរ ស្ថានភាពខាងឯសីលធម៌របស់យើងបានដោយគ្រាន់តែ *មានឆន្ទៈ* ដើម្បីក្លាយជាសុចរិតនោះទេ។

ចុះតើអ្វីទៅដែលមានឥទ្ធិពលនៅលើឆន្ទៈ? តើឆន្ទៈស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើងទាំងស្រុង ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់។ តើមានដំណើរការអ្វីខ្លះ ដែលចូលរួមនៅក្នុងការធ្វើការសម្រេចចិត្តរបស់យើង? ចូរយើងពិនិត្យទៅលើបញ្ហាទាំងនេះ ស្របពេលដែលយើងសិក្សាអំពីនិស្ស័យបានកាន់តែច្បាស់ថែមទៀត។

នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្សមក ទ្រង់បានប្រទានអំណាចនៃការជ្រើសរើស៖ ជាអំណាចក្នុងការជ្រើសរើសប្រព្រឹត្តិបាប ឬ មិនប្រព្រឹត្តិបាប។ ព្រះជាម្ចាស់បានដាក់មនុស្សនៅក្នុងសួនអេដែន ហើយដាក់លក្ខខ័ណ្ឌដើម្បីឲ្យលោកអាចនឹងបន្តប្រកបជាមួយទ្រង់បន្តទៅទៀត៖ "ព្រះជាអម្ចាស់បានបញ្ជាមនុស្សដូចតទៅ៖ «អ្នកអាចបរិភោគផ្លែឈើទាំងប៉ុន្មាន នៅក្នុងសួនឧទ្យាននេះបាន តែមិនត្រូវបរិភោគផ្លែឈើពីដើម ដែលនាំអោយស្គាល់ល្អស្គាល់អាក្រក់ឡើយ ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន»។" (គម្ពីរលោកុប្បត្តិ ២:១៦-១៧)

តើលោកអដាំ បានឆ្លើយតបទៅនឹងការណែនាំមកពីព្រះជាអម្ចាស់នេះយ៉ាងដូចម្តេច? ដំណើរការនៃការធ្វើការសម្រេចចិត្តប្រហែលជាដើរទៅតាមលំនាំដូចខាងក្រោមនេះ៖

១. *បញ្ញាញាណ* របស់លោកអដាំស្របទៅតាមខ្នាតគំរូរបស់ព្រះជាម្ចាស់។ លោកបានយល់ពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់មកលោក។

២. *អារម្មណ៍* របស់គាត់ស្របទៅតាមភាពសុចរិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់មានសិទ្ធិក្នុងការបង្កើតខ្នាតគំរូនេះឡើង ព្រោះទ្រង់គឺជាព្រះអាទិករ និង ព្រះអម្ចាស់ជាព្រះអធិបតីរបស់លោក។

៣. *ឆន្ទៈ* របស់លោកបានរៀបចំដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសរវាង ការទទួលយក និង ការច្រានចោលការល្បួងដែលសត្វពស់បានបង្ហាញលោក។ (គម្ពីរលោកុប្បត្តិ ៣:៤-៦)។

៤. នៅក្នុងពេលវេលាដ៏សំខាន់នេះ មនសិការរបស់លោកអដាំបានលំអៀងទៅរកផលវិបាកនៃការធ្វើផ្ទុយពីខ្នាតគំរូរបស់ព្រះជាម្ចាស់។

៥. លោកអដាំ បានចុះញ៉ែមនឹងសេចក្តីល្បួង ដោយ*សកម្មភាពនៃឆន្ទៈរបស់លោក* ។

ដូច្នេះ លោកអដាំមានចេតនា មិនស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង ទទួលរងទុក្ខពីផលវិបាកនោះភ្លាមៗតែម្តង។ មនសិការរបស់លោកផ្តន្ទាទោសលោក ធ្វើឲ្យលោកដឹងថា លោកបានបរាជ័យក្នុងការគោរពតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ លោកបានមានអារម្មណ៍អាម៉ាស់ ស្តាយក្រោយ និង ភ័យខ្លាច ព្រោះទង្វើមិនស្តាប់បង្គាប់របស់លោកបានបំផ្លាញភាពត្រឹមត្រូវរបស់លោក (គម្ពីរលោកុប្បត្តិ ៣:៧-១០) ។ ពេលនេះនិស្ស័យរបស់លោកក៏ត្រូវសៅហ្មង។ លោកបានធ្លាក់ចុះពីភាពត្រឹមត្រូវគ្មានទោសអ្វី ទៅក្នុងភាពសៅហ្មង។ តាំងពីការធ្លាក់ចុះរបស់លោកអដាំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់មក យើងក៏ត្រូវបានកំណត់ដោយនិស្ស័យបាបរបស់យើង។ យើងមិនអាច *មានឆន្ទៈ* ស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយគ្មានការជួយពីព្រះជាម្ចាស់បាននោះឡើយ។ លោកប៉ូលមានប្រសាសន៍ថា៖ "ដ្បិតខ្ញុំដឹងថា អ្វីៗដែលល្អមិនស្ថិតនៅក្នុងខ្ញុំទេ ពោលគឺមិនស្ថិតនៅក្នុងខ្ញុំដែលមាននិស្ស័យលោកីយ៍ទេ។ ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។" (គម្ពីររ៉ូម ៧:១៨)។

ទោះជាយ៉ាងណាព្រះជាម្ចាស់ មិនគាប់ព្រះហឫទ័យនឹងទុកមនុស្សឲ្យស្ថិតនៅក្នុងភាពសៅហ្មងរបស់គេនោះដែរ។ ទ្រង់បានលាតសន្ធឹងព្រះគុណរបស់ទ្រង់ ទៅកាន់មនុស្សនៅក្នុងស្ថានភាពបាត់បង់របស់ពួកគេ ទ្រង់អំពាវនាវទៅកាន់ពួកគេដើម្បីឲ្យពួកគេលន់តួបាបរបស់ពួកគេ ហើយទទួលយកសេចក្តីសង្គ្រោះដែលទ្រង់ប្រទានឲ្យ (គម្ពីរទីតុស ២:១១) ។ នៅត្រង់នេះហើយ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានចាប់ផ្តើមធ្វើការ និង ជះឥទ្ធិពលទៅលើឆន្ទៈរបស់មនុស្សឲ្យបែរទៅរកព្រះជាម្ចាស់ (គម្ពីរភីលីព ២:១៣) ។ អស់អ្នកណាដែលបែរត្រឡប់ទៅរកទ្រង់វិញ នឹងមានសិទ្ធិក្លាយទៅជាបុត្ររបស់ព្រះជាម្ចាស់ (គម្ពីរយ៉ូហាន ១:១២)។

ក្នុងពេលដែលព្រះជាម្ចាស់ លាតសន្ធឹងព្រះគុណរបស់ទ្រង់ទៅដល់ពួកមនុស្សដែលបានធ្លាក់ចុះ និង ជួយឲ្យពួកគេទទួលព្រះគ្រិស្តជាព្រះសង្គ្រោះរបស់ពួកគេ ទ្រង់មិនបានបង្ខិតបង្ខំពួកគេឲ្យធ្វើយ៉ាងដូច្នោះឡើយ។ តាមរយៈសកម្មភាពនៃឆន្ទៈ មនុស្សអាចនឹងទទួលព្រះអំណោយទាន ហើយ អាចនឹងក្លាយជាបុត្ររបស់ព្រះជាម្ចាស់ ឬ ពួកគេអាចនឹងច្រានចោលព្រះអំណោយទាននោះ ហើយស្ថិតនៅក្នុង

ការថ្កោលទោស (វិនិច្ឆ័យទោស) របស់ព្រះជាម្ចាស់ដដែល។ ឆន្ទៈរបស់ពួកគេ គឺមានសេរីភាពក្នុងសម្រេចទៅលើបញ្ហាមួយនេះ។ នៅក្នុងដំណើរការនៃការសម្រេចនោះ មានការចូលរួមទាំងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ឆន្ទៈរបស់មនុស្ស (គម្ពីរទីតុស ២:១១-១២ គម្ពីរយ៉ូហាន ៧:១៧)។

លំហាត់អនុវត្តន៍

១០ ចូរផ្គូផ្គង ខគម្ពីរ (ខាងស្តាំ) ទៅជាមួយនឹងប្រយោគ (ខាងឆ្វេង)។

.....ក) ព្រះគុណព្រះអង្គ ...អប់រំយើងអោយលះបង់ចិត្តដែលមិនចេះគោរពប្រណិប័តន៍ព្រះជាម្ចាស់ចោល អោយលះបង់សេចក្តីប៉ងប្រាថ្នាខាងលោកីយ៍	១) គម្ពីរយ៉ូហាន ៧:១៧ ២) គម្ពីរភីលីព ២:១៣ ៣) គម្ពីរទីតុស២:១១-១២
.....ខ) ដ្បិតព្រះជាម្ចាស់ទេតើ ដែលធ្វើអោយបងប្អូនមានទាំងបំណង មានទាំងសមត្ថភាពអាចនឹងប្រព្រឹត្ត..។	៤) គម្ពីររ៉ូម៧:១៨
.....គ) អ្នកដែលចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មុខជាដឹងថា សេចក្តីដែលខ្ញុំបង្រៀននេះ មកពីព្រះអង្គ ឬមកពីខ្ញុំផ្ទាល់មិនខាន។	
.....ឃ) ខ្ញុំមានឆន្ទៈនឹងធ្វើអំពើល្អ តែខ្ញុំគ្មានសមត្ថភាពនឹងប្រព្រឹត្តអំពើល្អបានឡើយ។	

១១ នៅក្នុងដំណើរការដែលនាំទៅរកការធ្វើសកម្មភាព ឬ ការសម្រេចចិត្ត យើងឃើញថា ញាណសតិ ឬ ឫទ្ធានុភាពខាងឯវិចារណាញាណរបស់មនុស្សជាតិទាំងអស់ចូលរួមក្នុងការនោះ។ ចូរបំពេញបង្គ្រប់ប្រយោគខាងក្រោម ដើម្បីធ្វើការបកស្រាយអំពីដំណើរការនោះ។

ក) សតិបញ្ញា

ខ) អារម្មណ៍

គ) មនសិការ

ឃ) ឆន្ទៈ

ស្របពេលដែលញាណសតិខាងឯវិចារណាញ្ញាណរបស់យើង បានចូលរួមនៅក្នុងការធ្វើការសម្រេចចិត្ត ព្រះវិញ្ញាណដ៏វិសុទ្ធបញ្ជូនឥទ្ធិពលវិជ្ជាមានដើម្បីជាប្រយោជន៍ ដរាបណាយើងនៅរក្សាផ្តត់គំនិតរបស់យើងលើអ្វីដែលព្រះវិញ្ញាណសព្វព្រះហឫទ័យ (សូមមើលគម្ពីររ៉ូម ៨:៥-៩,១២-១៤) ហើយទ្រង់ធ្វើការនៅក្នុងយើងដើម្បីនាំមកឲ្យយើងនូវបំណងចិត្តមួយសម្រាប់បំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរភីលីព ២:១៣) ។ ការរៀនរស់នៅក្នុងព្រះវិញ្ញាណ និង រក្សាជំហានរបស់យើងនៅក្នុងព្រះវិញ្ញាណ ជាការតំណាងឲ្យការរីកលូតលាស់ខាងឯបទពិសោធន៍ នៅក្នុងជីវិតរបស់យើងម្នាក់ៗ នៅពេលដែលយើងធ្វើដំណើរឡើងម្តងបន្តិចៗ ឆ្ពោះទៅភាពពេញវ័យរបស់គ្រិស្តបរិស័ទ (គម្ពីរកាឡាទី ៥:១៦-១៨, ២៥)។

គ. ភាពអមតៈរបស់មនុស្សជាតិ

វគ្គបំណងទី៥. *បកស្រាយគំនិតអំពីភាពអមតៈ និង អ្វីដែលកើតឡើងចំពោះមនុស្ស បន្ទាប់ពីគេបានស្លាប់ខាងឯរូបកាយហើយ។*

តើមានរឿងអ្វីកើតឡើងទៅលើមនុស្សក្រោយពេលស្លាប់ទៅ? មានរឿងជាច្រើនដែលយើងមិនដឹងអំពីជីវិតបន្ទាប់ស្លាប់ហើយ ប៉ុន្តែព្រះគម្ពីរបានបង្រៀនយើង រឿងមួយចំនួនដែលបង្ហាញថាមានជីវិតបន្ទាប់ពីការស្លាប់ទៅ។

ការស្លាប់ខាងឯរូបកាយ គឺជាអ្វីដែលកើតឡើងនៅពេលណាដែលរូបកាយឈប់បំពេញតួនាទីបន្តទៅទៀត។ រូបកាយក៏ត្រូវរលួយ និង ត្រឡប់ទៅជាធូលីដីវិញ (សូមមើលគម្ពីរលោកុប្បត្តិ ៣:១៩) ប៉ុន្តែទិដ្ឋភាពអរូបីរបស់មនុស្សជាតិ ដែលព្រះគម្ពីរហៅថា ព្រលឹង ឬ វិញ្ញាណនោះ នៅបន្តមានវត្តមានតទៅទៀត។ បទគម្ពីរជាច្រើនបានបញ្ជាក់អំពីការនេះ៖

> ព្រះយេស៊ូមានព្រះបន្ទូលថា៖ «ខ្ញុំសុំប្រាប់អោយអ្នកដឹងច្បាស់ថា ថ្ងៃនេះអ្នកបានទៅនៅស្ថានបរមសុខ*ជាមួយខ្ញុំ»។ (គម្ពីរលូកា ២៣:៤៣)។
>
> យើងចូលចិត្តឃ្លាតឆ្ងាយពីរូបកាយនេះ ហើយទៅនៅជិតព្រះអម្ចាស់ប្រសើរជាង។ (គម្ពីរ២កូរិនថូស ៥:៨)។
>
> បើខ្ញុំរស់ក្នុងលោកនេះតទៅទៀត ធ្វើអោយកិច្ចការរបស់ខ្ញុំបានផល ខ្ញុំមិនដឹងជាជ្រើសរើសយកផ្លូវណាឡើយ!។ ចិត្តខ្ញុំរាវរែកទាំងសងខាង គឺម្យ៉ាងខ្ញុំប៉ងប្រាថ្នាចង់លាចាកលោកនេះ ទៅនៅជាមួយព្រះគ្រិស្តនោះប្រសើរជាងឆ្ងាយណាស់។ (គម្ពីរភីលីព ១:២២-២៣)។
>
> អ្នកណាស្តាប់សេចក្តីដែលខ្ញុំនិយាយហើយជឿលើព្រះអង្គដែលបានចាត់ខ្ញុំអោយមក អ្នកនោះមានជីវិតអស់កល្បជានិច្ច គេមិនត្រូវទទួលទោសឡើយ គឺបានឆ្លងផុតពីសេចក្តីស្លាប់ទៅរកជីវិត។ (គម្ពីរយ៉ូហាន ៥:២៤)។

សេចក្តីស្លាប់ខាងឯរូបកាយរបស់មនុស្សជាតិ គឺជាទិដ្ឋភាពមួយនៃបណ្តាសា ដែលបានមកពីនៅពេលដែលលោកអដាំប្រព្រឹត្តិអំពើបាប៖ "អ្នកកើតពីធូលីដី អ្នកត្រូវតែត្រឡប់ទៅជាធូលីដីវិញ" (គម្ពីរលោកុប្បត្តិ ៣:១៩)។ នៅពេលស្លាប់ គ្រិស្តបរិស័ទលែងមានវត្តមានជាភាវៈរូបី ឬ អរូបីពេញលេញទៀតហើយ ពួកគេមានព្រះពរនៃសេចក្តីសង្ឃឹមអំពីការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត នៅពេលនោះពួកគេនឹងទទួលបានរូបកាយដែលពេញដោយសិរីរុងរឿង។ តាមរយៈការសុគត និង តាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ទ្រង់បានធានានូវការប្រោសឲ្យរស់ពីស្លាប់សម្រាប់ពួកយើងដែរ។ រឿងនេះមានបកស្រាយនៅក្នុងគម្ពីរ ១កូរិនថូស ១៥:៤២-៤៩៖

> ចំណែកមនុស្សស្លាប់ ដែលរស់ឡើងវិញ ក៏ដូច្នោះដែរ រូបកាយដែលគេកប់ក្នុងដីតែងតែរលួយ រីឯរូបកាយដែលរស់ឡើងវិញ មិនចេះរលួយទេ។ រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ថោកទាប រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយសិរីរុងរឿង រូបកាយដែលគេកប់ក្នុងដី ជារូបកាយដ៏ទន់ខ្សោយ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយឫទ្ធានុភាព។ រូបកាយដែលគេកប់ក្នុងដីជារូបកាយធម្មជាតិ រីឯរូបកាយដែលរស់ឡើងវិញ ជារូបកាយប្រកបដោយព្រះវិញ្ញាណ។

ប្រសិនបើមានរូបកាយធម្មជាតិមែន រូបកាយប្រកបដោយវិញ្ញាណក៏មានដែរ។ ហេតុនេះហើយបានជាមានចែងទុកមកថា «មនុស្សទីមួយ គឺលោកអដាំបានទទួលជីវិត»។ រីឯលោកអដាំចុងក្រោយបង្អស់ បានទៅជាព្រះវិញ្ញាណដែលផ្តល់ជីវិត។ .....យើងមានទ្រង់ទ្រាយដូចមនុស្សដែលមានលក្ខណៈជាដីយ៉ាងណា យើងក៏នឹងមានទ្រង់ទ្រាយ ដូចព្រះអង្គដែលគង់នៅស្ថានបរមសុខយ៉ាងនោះដែរ។

ផ្ទុយពីនេះ នៅពេលមនុស្សបាបដែលមិនបានលន់តួស្លាប់ទៅ ព្រលឹងរបស់ពួកគេនឹងបន្តស្ថិតនៅក្នុងស្ថានភាពមួយដែលមានស្មារតីដឹងខ្លួន នៅក្នុងកន្លែងដែលប្រកបដោយទុក្ខវេទនា ហៅថាឋាននរក ឬ រណ្តៅនរកវិញ។ យើងបានឃើញខ្លះៗអំពីការនេះ នៅក្នុងរឿងនិទានមួយរបស់ព្រះយេស៊ូ និយាយអំពីបុរសអ្នកមាន និង លោកឡាសារ (គម្ពីរលូកា ១៦:១៩-២៤) ។ នៅក្នុងឋាននរក បុរសអ្នកមានដែលព្រះយេស៊ូរៀបរាប់នោះ អាចគិត អាចចងចាំ និយាយ និង ទទួលអារម្មណ៍។ គាត់ក៏នៅរក្សាការដឹងខ្លួនរបស់គាត់ផងដែរ។

ដូច្នេះហើយ យើងឃើញថាមនុស្សគឺត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ ឲ្យជាភាវៈអមតៈ។ នេះគឺជាសេចក្តីសង្ឃឹមដែលប្រទានទៅឲ្យអស់អ្នកដែលបានទទួលយក កិច្ចការរំដោះបាបអំពីព្រះគ្រិស្ត និងអ្នកដែលបម្រើ និងស្តាប់បង្គាប់តាមទ្រង់។ នៅពេលដែលអ្នកជឿស្លាប់ទៅ ព្រលឹងរបស់ពួកគេ នឹងស្ថិតនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ភ្លាមៗតែម្តង។ នៅក្នុងការយាងមកជាលើកទីពីររបស់ទ្រង់ រូបកាយដែលអាចស្លាប់របស់ពួកគេ នឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ ហើយត្រូវបានផ្លាស់ប្រែទៅជារូបកាយដែលប្រកបដោយសិរីរុងរឿង (គម្ពីរ១កូរិនថូស ១៥:៥០-៥៧) ។ ថ្ងៃនោះនឹងពិតជាថ្ងៃដែលពេញដោយសិរីរុងរឿងមួយ! ទោះជាយ៉ាងណា អ្នកមិនជឿនឹងប្រឈមមុខនឹងការវិនិច្ឆ័យទោសអស់កល្បជានិច្ច និងទារុណកម្មដែលមកពីព្រះវត្តមានរបស់ព្រះអម្ចាស់ (សូមមើលគម្ពីរវិវរណៈ ២០:៧-១០)។

លំហាត់អនុវត្តន៍

១២ ចូរឆ្លើយសំណួរខាងក្រោម ដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក ដោយផ្អែកលើការពិភាក្សាខាងលើ

ក) តើនឹងមានរឿងអ្វីកើតឡើង ចំពោះរូបកាយនៅពេលមនុស្សស្លាប់ទៅ?

ខ) តើមានរឿងអ្វីកើតឡើង ចំពោះព្រលឹង ឬ វិញ្ញាណនៅពេលមនុស្សស្លាប់ទៅ?

គ) តើនឹងមានរឿងអ្វីកើតឡើង សម្រាប់គ្រិស្តបរិស័ទ នៅក្នុងការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត?

ឃ) តើវាសនាអស់កល្បជានិច្ចរបស់អ្នកដែលមិនទទួលស្គាល់ព្រះគ្រិស្ត នឹងទៅជាយ៉ាងណា?

ង) ចូរបកស្រាយការលើកឡើងមួយនេះ៖ "មនុស្សគឺជាភាវៈអមតៈ"។

ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើសៗ ចូរគូសរង្វង់ជុំវិញអក្សរខាងមុខចម្លើយត្រឹមត្រូវ។

១ ទស្សនវិស័យរបស់ព្រះគម្ពីរអំពីការបង្កើតលោកអដាំ គឺថា

ក) លោកគ្រាន់តែជាភាវៈរស់មួយនៅក្នុងក្នុងចំណោមភាវៈរស់ជាច្រើនដែលព្រះជាម្ចាស់បានបង្កើត នៅក្នុងពេលជាក់លាក់ណាមួយប៉ុណ្ណោះ។

ខ) លោកគឺជាស្នាព្រះហស្តពិសេសមានតែមួយ របស់ព្រះជាម្ចាស់ ដែលបានលើកឲ្យខ្ពស់លើសភាវៈដទៃផ្សេងទៀត និង ទទួលបានព្រះពរពីព្រះជាម្ចាស់។

គ) លោកបានវិវត្តន៍ ក្នុងរយៈពេលមួយយ៉ាងយូរ ចាប់ផ្តើមពីទិដ្ឋភាពដែលទាបជាងគេនៅក្នុងស្នាព្រះហស្ត រហូតដល់គាត់អាចគ្រប់គ្រងលើស្នាព្រះហស្តទាំងនោះម្តងបន្តិចៗ។

២ នៅពេលដែលយើងនិយាយថា យើងត្រូវបានបង្កើតឡើងមកឲ្យមានសណ្ឋានដូចជាព្រះជាម្ចាស់ យើងចង់បាននិយាយថា យើង

ក) ដូចជាព្រះជាម្ចាស់បះបិទ គ្រប់ជ្រុងទាំងអស់។

ខ) ពេលនេះ គឺជាការចម្លងតាមព្រះជាម្ចាស់ដែលមានកម្រិត ហើយយើងនឹងក្លាយដូចជាព្រះជាម្ចាស់គ្រប់យ៉ាង រួមជាមួយនឹងឫទ្ធានុភាព និង សិទ្ធិអំណាចគ្មានដែនកំណត់។

គ) ដូចនឹងព្រះជាម្ចាស់ត្រង់ បុគ្គលិកលក្ខណៈ សីលធម៌ និង ការដឹងពីសង្គម និង សមត្ថភាពក្នុងការគ្រប់គ្រង។

៣ មនុស្សគឺត្រូវបានបង្កើតឡើងពី

ក) ទិដ្ឋភាពខាងរូបី និង អរូបី។

ខ) រូបកាយមួយដែលសឹករិចរឹល និង រលួយស្អុយបន្ទាប់ពីស្លាប់ទៅ និង ព្រលឹងដែលស្លាប់ទៅ រហូតដល់ពេលមួយដែលវានឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ នៅគ្រានៃការវិនិច្ឆ័យចុងក្រោយបំផុត។

គ) រូបកាយមួយដែលអាក្រក់ ហើយមានទិដ្ឋភាពអរូបីដែលល្អ។

៤. ទិដ្ឋភាពអរូបីរបស់មនុស្សជាតិ ជាគោលការណ៍សំខាន់នៃជីវិតជីវសាស្ត្រ ត្រូវបានអ្នកប្រាជ្ញខ្លះចាត់ទុកជា

ក) រូបកាយ

ខ) ព្រលឹង

គ) វិញ្ញាណ

ឃ) ដង្ហើមនៃជីវិត

៥ *ព្រលឹង វិញ្ញាណ ដង្ហើមនៃជីវិត* និង *មនសិការ* គឺជាពាក្យដែលបានប្រើនៅក្នុងព្រះគម្ពីរ ដើម្បីនិយាយសំដៅទៅលើ.....របស់មនុស្សជាតិ។

ក) ជីវិតរូបី

ខ) ជីវិតអរូបី

គ) បុគ្គលិកលក្ខណៈ

ឃ) រូបកាយ។

៦ តើប្រយោគណាមួយនៅខាងក្រោមនេះ ត្រឹមត្រូវទាក់ទងនឹងធាតុផ្សំរបស់មនុស្សក្នុងនាមជាភាវៈដែលមានគំនិត?

ក) សតិបញ្ញាដែលជួយឲ្យបុគ្គលមួយរូបអាចយល់ដឹង និង មានហេតុផល។

ខ) អារម្មណ៍ ដែលជួយឲ្យបុគ្គលមួយរូបអាច ទទួលអារម្មណ៍ដឹង និង ទទួលឥទ្ធិពលពីអ្វីដែលអ្នកនោះដឹង។

គ) សកម្មភាព ឬ ឥរិយាបថដែលថ្លឹងថ្លែងដោយមនសិការ ដែលផ្អែកលើខ្នាតគំរូត្រូវ ឬខុស។

ឃ) ឆន្ទៈគឺជាញាណសតិដែលជួយឲ្យមនុស្សម្នាក់ ជ្រើសរើស និង ធ្វើសកម្មភាព។

៧ នៅពេលដែលគេយល់ពីបញ្ហាមួយបានច្បាស់ ជំហានទីមួយ

ក) ឆន្ទៈជាអ្នកសម្រេចលើបញ្ហានោះភ្លាមៗ។

ខ) សតិបញ្ញាចង្អុលបង្ហាញពីការល្អ និង អាក្រក់ដូចបានប្រៀបធៀបទៅនឹងខ្នាតគំរូមួយ។

គ) អារម្មណ៍ប្រាប់ទៅកាន់មនុស្សម្នាក់ឲ្យធ្វើសកម្មភាព តាមរបៀបណាមួយ ឬ តាមរបៀបផ្សេងទៀត។

ឃ) មនសិការធ្វើឲ្យមានការអាម៉ាស់ និង ការស្តាយក្រោយ។

៨ នៅក្នុងដំណើរការនៃការធ្វើការសម្រេចចិត្ត ដំបូងបំផុតបុគ្គលម្នាក់ត្រូវ

ក) មានការយល់ដឹងអំពីការពិតនៃបញ្ហាដែលចោទឡើង។

ខ) សម្រេចចិត្ត ថាគួរធ្វើអ្វីមួយ ដោយយោងទៅតាមខ្នាតគំរូនៃសង្គមរបស់គេ។

គ) ពិចារណាអំពីអារម្មណ៍របស់ខ្លួន និង ផលវិបាកនៃការសម្រេចចិត្តរបស់គេ។

៩ មនសិការគឺជាធាតុផ្សំដែល

ក) សុំឲ្យមានការសម្រេចចិត្ត ដោយផ្អែកលើបំណងចិត្តរបស់បុគ្គលម្នាក់។

ខ) ថ្លឹងថ្លែងសកម្មភាព ផ្ទុយនឹងខ្នាតគំរូនៃចរិយាមារយាទរបស់បុគ្គលម្នាក់។

គ) ធ្វើការសម្រេចចិត្ត ដើម្បីបញ្ចេញសកម្មភាព

ឃ) ជ្រើសរើសរបៀបធ្វើសកម្មភាព។

១០ ឆន្ទៈរបស់យើងបំពេញតួនាទី ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រោះ

ក) បំណងចិត្តចង់ធ្វើការល្អ។

ខ) មនសិការរបស់យើង ដែលបង្ហាញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់មកកាន់យើង។

គ) ព្រះគុណរបស់ព្រះជាម្ចាស់ដែលនាំមកនូវការសង្គ្រោះ និង ការជួយឲ្យស្តាប់បង្គាប់ទ្រង់។

ឃ) សេចក្តីកោតខ្លាចការថ្កោលទោស ឬ ការវិនិច្ឆ័យទោស របស់ព្រះជាម្ចាស់។

១១ តើចម្លើយណាមួយខាងក្រោមនេះ ជាចម្លើយត្រឹមត្រូវទាក់ទងនឹងភាពអមតៈរបស់យើង?

ក) រូបកាយ និង ព្រលឹងរបស់យើង គឺអមតៈ នៅក្នុងស្ថានភាពដូចបច្ចុប្បន្ននេះ។

ខ) ខ្លួនប្រាណដែលមានរូបរបស់យើង នឹង រលួយស្អុយ និង ស្លាប់ទៅ ប៉ុន្តែព្រលឹងរបស់យើងនឹងរស់នៅជាដរាប នៅក្នុងសភាពដែលមានសុខសន្តិភាពដ៏ល្អឥតខ្ចោះ។

គ) ខ្លួនប្រាណរបស់យើងនឹងស្លាប់ ព្រលឹង ឬ វិញ្ញាណរបស់អ្នកជឿនឹងបាននៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ភ្លាមៗ ហើយនៅក្នុងពេលដែលព្រះយេស៊ូយាងមកជាលើកទីពីរ ពួកគេនឹងទទួលបាននូវរូបកាយការប្រោសឲ្យមានជីវិត ប្រកបដោយសិរីរុងរឿង ចំណែកអ្នកមិនជឿ នឹងត្រូវឆ្លងកាត់ការកាត់ទោស នៅក្នុងនរគអស់កល្បជានិច្ច។

ចម្លើយលំហាត់អនុវត្តន៍

១ ក) ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ។
ខ) ព្រះជាម្ចាស់បានបង្កើតមនុស្សប្រុស និង មនុស្សស្រី ឲ្យមានលក្ខណៈដូចជាទ្រង់។
គ) ព្រះជាម្ចាស់បានបង្កើតមនុស្សឡើងមក។
ឃ) ព្រះជាម្ចាស់បានបង្កើតមនុស្សលោកមកជាតំណាងរបស់ព្រះអង្គ។
ង) ព្រះជាម្ចាស់បង្កើតមនុស្សនៅលើផែនដីនេះ។
ច) ព្រះអង្គបានបង្កើតយើងមក។
ឆ) មនុស្សដែលព្រះអង្គបានបង្កើតមក អោយមានលក្ខណៈដូចព្រះអង្គ។

៧ ធាតុផ្សំខាងឯសតិបញ្ញា ឆន្ទៈ ធាតុផ្សំខាងឯអារម្មណ៍ និង មនសិការ។

២ ខ) មានតែមនុស្សប៉ុណ្ណោះដែលបានទទួលជីវិត មកពីការផ្លុំខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់។
គ) មនុស្សទទួលបានអំណាចគ្រប់គ្រងលើជីវិតរុក្ខជាតិ និង សត្វ។
ឃ) មនុស្សត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចជាព្រះអាទិករបស់ពួកគេ។
ង) មនុស្សគឺខុសពី ភាវៈផ្សេងទៀតនៅលើផែនដី ហើយថែមទាំងខ្ពង់ខ្ពស់ជាងភាវៈទាំងនេះផង។

៨ ភាពអាម៉ាស់ ភាពស្តាយក្រោយ និង ភាពភ័យខ្លាច

៣ ក) និស្ស័យខាងឯសង្គម
ខ) លក្ខណៈដូចខាងឯសីលធម៌
គ) និស្ស័យដែលប្រកបដោយវិចារណញ្ញាណ
ឃ) ភាពយល់ច្បាស់ពីខ្លួនឯង
ង) បុគ្គលិកលក្ខណៈ
ច) សមត្ថភាពគ្រប់គ្រង
ឆ) លក្ខណៈដូចគ្នាខាងឯសីលធម៌

៩ ក) ត្រូវ
ខ) ខុស
គ) ត្រូវ
ឃ) ខុស
ង) ខុស (ផ្ទុយទៅវិញ មនសិការរបស់មនុស្សគឺសាងឡើងដោយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចដែលត្រូវបានបកស្រាយដោយព្រះវិញ្ញាណដ៏វិសុទ្ធផងដែរ។
ច) ត្រូវ
ឆ) ខុស

៤ ក) ១) គម្ពីរលោកុប្បត្តិ ១:២៧,៣១ និង
៤) គម្ពីរទំនុកតម្កើង ១៣៩:១៣-១៦
ខ) ៥) គម្ពីរហេប្រឺ ២:១៤-១៥,១៧-១៨
គ) ៩) គម្ពីរ១កូរិនថូស ១២:១២-២៧
ឃ) ៣) គម្ពីរ១កូរិនថូស ៦:១៥,១៩-២០
ង) ៨) គម្ពីររ៉ូម ៨:២៣ និង ៦) គម្ពីរ១កូរិនថូស ៦:១៤
ច) ២) គម្ពីររ៉ូម ១២:១
ឆ) ៧) គម្ពីរភីលីព ៣:២០-២១

១០ ក) ៣) គម្ពីរទីតុស ២:១១-១២
ខ) ២) គម្ពីរភីលីព ២:១៣
គ) ១) គម្ពីរយ៉ូហាន ៧:១៧
ឃ) ៤) គម្ពីររ៉ូម ៧:១៨

៥ នៅក្នុងព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន(២០០៥) បានប្រើពាក្យខាងក្រោមនេះ៖
ក) ខ្យល់ដង្ហើមជីវិត (ទិដ្ឋភាពមួយ)(ពគប១៩៥៤)
ខ) ព្រលឹង (ទិដ្ឋភាពមួយ) (ពគប១៩៥៤)
គ) វិញ្ញាណ (ទិដ្ឋភាពមួយ) (គខប២០០៥)
ឃ) ព្រលឹង និងវិញ្ញាណ (ទិដ្ឋភាពពីរ) (គខប២០០៥)
ង) ព្រលឹងនិងវិញ្ញាណ (ទិដ្ឋភាពពីរ) (គខប២០០៥)

១១ ចម្លើយអ្នករបស់គួរតែស្រដៀងនឹងចម្លើយខាងក្រោមនេះ៖
ក) យល់ដឹងពីអ្វីដែលទាក់ទង ឬ អ្វីដែលត្រូវតែធ្វើការសម្រេចចិត្ត។
ខ) ជំរុញឲ្យមានសកម្មភាពមួយ ឬ សកម្មភាពមួយផ្សេងទៀតកើតឡើង។
គ) ថ្លឹងថ្លែងសកម្មភាពដែលបានគិតទុក ទាស់នឹងខ្នាតគំរូសីលធម៌របស់មនុស្សម្នាក់។
ឃ) សម្រេចបញ្ហា។

៦ ង) បទគម្ពីរបានថ្លែងអំពី ខ្លួនប្រាណ ព្រលឹង វិញ្ញាណ ដង្ហើមនៃជីវិត និង ពាក្យជាច្រើនផ្សេងទៀត ដើម្បីធ្វើការរៀបរាប់អំពីនិស្ស័យរបស់យើង ប៉ុន្តែមិនបានបង្ហាញឲ្យបានច្បាស់ៗ ថាតើយើងមាននិស្ស័យនូវទិដ្ឋភាពពីរ ឬក៏ទិដ្ឋភាពបី។

១២ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយខាងក្រោមនេះ៖

ក) វានឹងត្រូវស្អុយរលួយ និង ត្រឡប់ទៅជាធូលីដីវិញ។

ខ) គ្រិស្តបរិស័ទ នឹងបានទៅនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ភ្លាមៗ នាស្ថានបរមសុខ។ ចំណែកឯអ្នកមិនជឿវិញ ត្រូវរងទុក្ខវេទនាក្នុងឋាននរគ។

គ) រូបកាយដែលអាចស្លាប់របស់ពួកគេ នឹងត្រូវបានប្រោសឲ្យមានជីវិតរស់ឡើងវិញ ហើយត្រូវបានផ្លាស់ប្តូរទៅជារូបកាយដែលដែលប្រកបដោយសិរីរុងរឿង។

ឃ) ការវិនិច្ឆ័យទោសដ៏អស់កល្បជានិច្ច និង ការថ្កោលទោស ឲ្យនៅដាច់ឆ្ងាយពីព្រះវត្តមានរបស់ព្រះជាម្ចាស់។

ង) មនុស្សត្រូវបានព្រះជាម្ចាស់បង្កើតឡើងមក ឲ្យមានជីវិតរូបី និង អរូបី ដែលព្រលឹង និងវិញ្ញាណរបស់ពួកគេ នឹងមិនអាចស្លាប់ឡើយ។ ពួកគេនឹងមានវត្តមានជារៀងរហូត ទាំងនៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់ ឬ នៅក្នុងឋាននរគជាកន្លែងដែលមានការថ្កោលទោសអស់កល្បជានិច្ច។

ជំពូក ៧ អំពើបាប និង សេចក្តីសង្គ្រោះ បញ្ញា និង ដំណោះស្រាយ

"ប៊ិប! ថ្ងៃនេះ ពួកអ្នកធ្វើសំណង់ដែលកំពុងសង់ផ្ទះនៅក្បែរផ្ទះយើង ពួកគេកំពុងលាយបេតុង ដូច្នេះ ហើយ កុំទៅលេងជិតពួកគេណា ។ កូនឯងកំពុងពាក់អាវថ្មីផង"។

ប្រពន្ធរបស់ខ្ញុំចូលចិត្ត និយាយប្រាប់ខ្ញុំអំពីរឿងកាលដែលថាប្អូនប្រុសរបស់គាត់ ធុញនឹងការរំឭក របស់ម្តាយគាត់ខ្លាំងណាស់។ ក្រោយពីព្រមានមិនទាន់បានប៉ុន្មាន ប្អូនប្រុសរបស់ប្រពន្ធខ្ញុំ កាលដែលគេ មានអាយុទើបតែប្រាំមួយឆ្នាំនោះ បានក្រោកឈរឡើង ហើយដើរចេញទៅយ៉ាងរឹងចចេស ឆ្ពោះទៅរក កន្លែងគេធ្វើសំណង់នោះ។ ពេលដែលគាត់ដើរទៅដល់ មានសត្វមេអំបៅមួយក្បាលបានទុំលើស្នូក សម្រាប់លាយបេតុងនោះ។ ប៊ិប បានអោនទៅរំដោះសត្វមេអំបៅដែលកំពុងជាប់គាំងនោះ ប៉ុន្តែគាត់បាន បាត់បង់លំនឹងរបស់គាត់ ហើយក៏ធ្លាក់ចូលនៅក្នុងបេតុងនោះតែម្តងទៅ! បេតុងបានប្រឡាក់ចាប់តាំងពី ក្បាល ហើយហូរដល់លើមុខរបស់គាត់។ អាវថ្មីរបស់គាត់បានប្រឡាក់អស់! ការចចេសរឹងរូសរបស់ប៊ិប ក៏ បានផ្លាស់ប្តូរទៅជា ការឈឺចាប់ភ័យខ្លាចវិញ។ តើគាត់នឹងអាចប្រឈមមុខជាមួយនឹងម្តាយរបស់គាត់ បានយ៉ាងដូចម្តេច? តើការមិនស្តាប់បង្គាប់របស់គាត់នឹង ផ្តល់ផលវិបាកអ្វីខ្លះ?

មនុស្សជាតិក៏ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានេះដែរ។ ស្នាព្រះហស្តដ៏ពេញដោយសិរីរុងរឿង របស់ព្រះជាម្ចាស់ ដែលជាប្រធានបទនៅក្នុងមេរៀនទី៦ ក៏ត្រូវបានសៅហ្មង និង ត្រូវបានពង្វក់ដោយអំពើ បាប។ នៅក្នុងមេរៀននេះ យើងនឹងរៀននូវអ្វីដែលព្រះគម្ពីរបានថ្លែង អំពីដើមកំណើត និង ផលវិបាកនៃ អំពើបាប។ អរព្រះគុណព្រះជាម្ចាស់ យើងមិនចាំបាច់ត្រូវបញ្ឈប់ការសិក្សារបស់យើងនៅក្នុងពេលដែល យើងអស់សង្ឃឹមឡើយ។ យើងក៏ត្រូវរៀនអំពីដំណោះស្រាយដែលព្រះគ្រិស្ត បានប្រទានឲ្យផងដែរ។ ចូរ យើងទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ជួយយើងនៅក្នុងពេលដែលយើងសិក្សាអំពីប្រធានបទសំខាន់ៗទាំង នេះ។

គម្រោងមេរៀន

ក. ធាតុពិតនៃអំពើបាប
ខ. ដើមកំណើតនៃអំពើបាប
គ. និស្ស័យរបស់អំពើបាប
ឃ. ផលវិបាកនៃអំពើបាប
ង. ការស្រោចស្រង់មនុស្សមានបាប

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់ពីនិយមន័យ និង ភស្តុតាងនៃធាតុពិតរបស់អំពើបាប។
២. រៀបរាប់យ៉ាងត្រឹមត្រូវអំពីដើមកំណើតនៃអំពើបាប។
៣. ស្គាល់ពីទិដ្ឋភាពនៃអំពើបាប។
៤. រៀបរាប់អំពីផលវិបាកនៃអំពើបាប។
៥. បកស្រាយពីរបៀបដែលមនុស្សមានបាប ត្រូវបានស្រោចស្រង់ និង បកស្រាយពីលទ្ធផលនៃការស្រោចស្រង់។

សកម្មភាពក្នុងការសិក្សា

១. ចូរអានគម្ពីរលោកុប្បត្តិ ២ - ៣ និង គម្ពីររ៉ូម ៥ - ៦ ដែលជាសេចក្តីយោងសម្រាប់មេរៀននេះ ដែលមានទាក់ទងនឹងបញ្ហានៃអំពើបាប។ ចូរអានគម្ពីរអេសាយ ៥៣ ដើម្បីទទួលបានចំណេះដឹងអំពីដំណោះស្រាយដែលព្រះជាម្ចាស់បានប្រទានមកសម្រាប់អំពើបាប។ បន្ទាប់មក ចូរសិក្សាតាមដំណើររបស់មេរៀនដូចធម្មតា។
២. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី៥ ដល់ទី ៧ (ជំពូកទី២) បន្ទាប់មក ធ្វើការប្រឡងសម្រាប់ជំពូកទីពីរ។

ពាក្យសំខាន់ៗ

ការរំដោះបាប	ពិគ្រោះ	ទំនោរចិត្ត
ពុករលួយ	ការរសាយចិត្ត	ការបំពុល
ក្លែងបន្លំ	ដែលជាសត្រូវ	ភាពបះបោរ
ដែលឆបោក	ត្រាប់	ការស្តារឡើងវិញ

ក. ធាតុពិតនៃអំពើបាប

វគ្គបំណងទី ១. *ប្រាប់ពីនិយមន័យ និង ភស្តុតាងនៃធាតុពិតរបស់អំពើបាប។*

អំពើបាបអាចត្រូវបានគេឲ្យនិយមន័យថា ការមិនស្តាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមច្បាប់ដែលព្រះជាម្ចាស់បានប្រទានមកដើម្បីដឹកនាំ សភាវៈដែលមានវិចារណញ្ញាណរបស់ទ្រង់។ ដោយច្បាប់របស់ព្រះជាម្ចាស់ គឺជាការសំដៅពីនិស្ស័យខាងឯសីលធម៌ របស់ទ្រង់ យើងត្រូវប្រតិបត្តិតាមច្បាប់នោះ ដើម្បីស្របទៅតាមនិស្ស័យដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ៗ មកកាន់យើងរាល់គ្នា អំពីធាតុពិតនៃអំពើបាប ក៏ដូចជាដើមកំណើត និស្ស័យ ផលវិបាក និង ការព្យាបាលឲ្យផុតពីបាបនោះផងដែរ។ ទដ្ឋិភាពនៃអំពើបាបទាំងអស់នេះ នឹងត្រូវបានលើកយកទៅរៀងញែកស្របពេលដែលយើងសិក្សាមេរៀននេះទៅមុខ។

ដូចដែលយើងបានឃើញនៅក្នុងមេរៀនមុនរួចមកហើយថា មនុស្សគឺជាសភាវៈដែលមានវិចារណញ្ញាណ ។ ដូច្នេះហើយ ពួកគេក៏ដឹងថាពួកគេមានទោសបាបដែរ ប្រសិនបើពួកគេ ១) ធ្វើអ្វីដែលពួកគេមិនគួរនឹងធ្វើ ២) មិនធ្វើអ្វីដែលពួកគេគួរធ្វើ ៣) ធ្វើខ្លួនជាអ្វីដែលមិនមែនជាពួកគេ ឬ ៤) មិនព្រមធ្វើខ្លួនឲ្យសមជាអ្វីដែលជាពួកគេ ។ មានភស្តុតាងជាច្រើន អំពីធាតុពិតនៃអំពើបាប។ ភស្តុតាងទីមួយនៃភស្តុតាងទាំងនេះ គឺឃើញមាននៅក្នុងព្រះគម្ពីរ។

ឃើញមានភស្តុតាងក្នុងព្រះគម្ពីរ

អំពើបាបគឺជាប្រធានបទធំមួយនៅក្នុងព្រះគម្ពីរ។ គម្ពីរលោកុប្បត្តិ ៣ មានកត់ត្រាទុកនូវ គ្រាដំបូងដែលមនុស្សធ្វើអំពើបាប។ ជំពូកទី៤ ក៏បន្តសាច់រឿងនេះ ដោយប្រាប់អំពីរបៀបដែលបញ្ហា បន្តប៉ះពាល់ទៅដល់កូនចៅនៃឪពុកម្តាយដំបូងរបស់យើង។ នៅត្រង់ចំណុចនេះ ព្រះជាម្ចាស់បានមានព្រះបន្ទូលដ៏គួរឲ្យប៉ះពាល់ចិត្តមួយទៅកាន់លោកកាអ៊ីនថា៖ " បាបក្រាបនៅមាត់ទ្វាររបស់អ្នក ដើម្បីជំរុញអ្នកអោយធ្វើតាមវា តែអ្នកត្រូវបង្ក្រាបវាវិញ" (គម្ពីរលោកុប្បត្តិ ៤:៧)។ ប៉ុន្តែ លោកកាអ៊ីនបានចុះចាញ់អារម្មណ៍ច្រណែន ស្អប់ និង ចិត្តបះបោររបស់លោក ហើយក៏បានសម្លាប់ប្អូនប្រុសរបស់ខ្លួនទៅ។

លំហាត់អនុវត្តន៍

---

១ ដោយប្រើពាក្យតែពីរឬបីម៉ាត់ ចូរប្រាប់ថាអ្វីជានិស្ស័យបាបរបស់លោកអដាំ និង នាងអេវ៉ា និង អំពើបាបរបស់លោកកាអ៊ីន? (គម្ពីរលោកុប្បត្តិ ៣:១១ និង ៤:៧)

.....

ម្តងហើយម្តងទៀត យើងបានឃើញពីបញ្ហានៃអំពើបាប នៅពេលដែលយើងអានព្រះគម្ពីរ។ ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យជាសំណេរ ដើម្បីដឹកនាំមនុស្សរបស់ទ្រង់ នៅក្នុងបទពិសោធន៍ដំបូងរបស់ពួកគេ (គម្ពីរនិក្ខមនំ ២០:១-១៧)។ ទ្រង់បានណែនាំលោកម៉ូសេបន្ថែមទៀត អំពីក្រឹត្យទាំងអស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ហើយបានប្រាប់យ៉ាងច្បាស់ៗអំពីរបៀបដែលអាចបង់រំដោះអំពើបាប ដោយការដឹកនាំប្រជាជនអ៊ីស្រាអែល ដើម្បីថ្វាយយញ្ញបូជាដ៏ត្រឹមត្រូវ សម្រាប់លោះបាបដែលពួកគេបានប្រព្រឹត្តិ (គម្ពីរលេវី

វិន័យ ៤-៧)។ ទ្រង់ថែមទាំងបានកំណត់ពេលមួយថ្ងៃក្នុងមួយឆ្នាំ ដែលពួកសាសន៍អ៊ីស្រាអែលទាំងមូលត្រូវតែដោះស្រាយជាមួយនឹងអំពើបាបរបស់ខ្លួន (គម្ពីរលេវីវិន័យ ១៦)។ កណ្ឌគម្ពីរទាំងប្រាំកណ្ឌដំបូង ក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់គឺហៅថាកណ្ឌគម្ពីរក្រឹត្យវិន័យ ព្រោះតែកណ្ឌគម្ពីរទាំងនោះមានផ្ទុក ក្រឹត្យវិន័យទាំងអស់របស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ដើម្បីការរស់នៅឲ្យបានវិសុទ្ធ ព្រមទាំងផ្ទុកការណែនាំរបស់ទ្រង់ដើម្បីទទួលបានការអត់ទោសបាបរបស់ពួកគេ។

កណ្ឌគម្ពីរប្រវត្តិសាស្ត្រ ចាប់ពីគម្ពីរយ៉ូស្វេ ដល់គម្ពីរអេសធើរ បានកត់ត្រាអំពីការបរាជ័យដ៏គួរឲ្យស្ងែកនៃមនុស្សរបស់ព្រះជាម្ចាស់ ក្នុងការស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ កណ្ឌគម្ពីរទាំងនេះបានបង្ហាញអំពីការប្រព្រឹត្តអំពើអាក្រក់ឡើងវិញ ការមិនស្តាប់បង្គាប់ ភាពចចេស និង ការបះបោរបស់សាសន៍អ៊ីស្រាអែល ទៅកាន់ព្រះជាម្ចាស់ និង ក្រឹត្យវិន័យរបស់ទ្រង់។

លំហាត់អនុវត្តន៍

២ ចូរប្រៀបធៀបគម្ពីរចៅហ្វាយ ២:៦-៧ ជាមួយនឹង គម្ពីរចៅហ្វាយ២:១០-១៩ ។ បន្ទាប់ពីការស្លាប់របស់លោកយ៉ូស្វេ តើប្រជារាស្ត្របានផ្លាស់ប្តូរយ៉ាងដូចម្តេច?

.....

៣ ចូរអានគម្ពីរចៅហ្វាយ ៣:៧,៩,១២,១៥; ៤:១; ៦:១។ តើរឿងអ្វីដែលកើតឡើងម្តងហើយម្តងទៀតនៅក្នុងខគម្ពីរទាំងនេះ?

.....

អ្នកនិពន្ធបានបង្ហាញពីទុក្ខព្រួយនៃអំពើបាបរបស់បុគ្គល៖ “ ឱព្រះជាម្ចាស់អើយ! សូមប្រណីសន្តោសទូលបង្គំផង...សូមលុបលាងកំហុសទូលបង្គំអោយបានស្អាតទាំងស្រុង សូមជំរះទូលបង្គំអោយបានបរិសុទ្ធ រួចពីបាប!...ទូលបង្គំមានកំហុសតាំងពីកំណើតមកហើយ។” (គម្ពីរទំនុកតម្កើង ៥១:១-២,៥) ។ ពួកព្យាការីក៏ទួញសោក ទាស់នឹងអំពីដែលជាមូលហេតុបង្កឲ្យមានការធ្លាក់ចុះរបស់សាសន៍អ៊ីស្រាអែល (គម្ពីរអេសេគាល ២៣ គម្ពីរយេរេមា ៥ គម្ពីរដានីយ៉ែល ៩:១-២៣)។

ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីបានកត់ត្រាអំពី អំពើក្បត់របស់លោកយូដាសអ៊ីស្ការីយ៉ុត (គម្ពីរម៉ាថាយ ២៦:១៤-១៦)។ ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីក៏បានបង្ហាញពីការរងទុក្ខរបស់ព្រះសង្គ្រោះនៃយើង ដែលបានទទួលយកបាបរបស់ពិភពលោកទាំងមូលដាក់លើអង្គទ្រង់ (គម្ពីរលូកា ២២:៣៩-៤៤ គម្ពីរយ៉ូហាន ១៩:១-៣, ១៨)។ គម្ពីរនេះមានរៀបរាប់អំពីរឿងដ៏រន្ធត់របស់លោកអាណាណាស និង សាភីរ៉ា (គម្ពីរកិច្ចការ ៥:១-១១)។ ភស្តុតាងដ៏ស្តែងៗមួយនៃធាតុពិតរបស់អំពើបាប គឺមានកត់ត្រាទុកនៅក្នុងគម្ពីរ៉ូម ១:១៨-៣២។ ខាងក្រោមនេះគឺជារបៀបដែលអំពើបាបត្រូវបានព្រះគម្ពីររៀបរាប់៖

> ដោយពួកគេយល់ថា មិនបាច់ស្គាល់ព្រះជាម្ចាស់យ៉ាងច្បាស់ ព្រះអង្គក៏បណ្តោយគេទៅតាមគំនិតឥតពិចារណារបស់ខ្លួន គឺអោយគេប្រព្រឹត្តអំពើដែលមិនត្រូវប្រព្រឹត្ត។ ចិត្តរបស់ពួកគេពោរពេញដោយគំនិតទុច្ចរិតគ្រប់យ៉ាង គំនិតអាក្រក់ គំនិតលោភលន់ គំនិតពាល ពេញទៅដោយចិត្តច្រណែនឈ្នានីស ចង់សម្លាប់គេ ឈ្លោះប្រកែក លឿចកិច្ចកល និងអបាយមុខ។ ពួកគេចូលចិត្ត

បរិហារកេរ្តិ៍គ្នា និយាយដើមគ្នា តាំងខ្លួនជាសត្រូវនឹងព្រះជាម្ចាស់ មានចិត្តកំរោលឃោរឃៅ មានអំនួតអួតបំប៉ោង ប្រសប់ខាងប្រព្រឹត្តអំពើអាក្រក់ មិនស្តាប់បង្គាប់ឪពុកម្តាយ។ ពួកគេជាមនុស្សល្ងីល្ងើមានចិត្តមិនទៀង ជាមនុស្សអត់ចិត្ត មិនចេះអាណិតអាសូរ។ ពួកគេស្គាល់ការវិនិច្ឆ័យរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ស្រាប់ហើយថា អ្នកណាប្រព្រឹត្តបែបនេះនឹងត្រូវទទួលទោសដល់ស្លាប់។ គេមិនត្រឹមតែប្រព្រឹត្តខ្លួនឯងប៉ុណ្ណោះទេ គឺថែមទាំងយល់ស្របជាមួយអ្នកដែលប្រព្រឹត្តអំពើបែបនោះផងដែរ។ (ខ២៨ ដល់ខ ៣២)

លំហាត់អនុវត្តន៍

៤ ចូរឲ្យនិយមន័យពីអំពើបាបតាមអ្វីដែលបានរៀបរាប់នៅក្នុងគម្ពីរ១យ៉ូហាន ៥:១៧ និង តាមការពិភាក្សារបស់យើង។

.....

យើញមាននៅក្នុងតាពចាំបាច់នៃរាជរដ្ឋាភិបាល

ព្រះគម្ពីរមិនត្រឹមតែបានបង្ហាញយើងអំពីឧទាហរណ៍ជាច្រើននៃធាតុពិតរបស់អំពើបាបប៉ុណ្ណោះទេ តែថែមទាំងបានផ្តល់ភស្តុតាង តាមរយៈភាពចាំបាច់នៃរាជរដ្ឋាភិបាលដែលមិនអាចចៀសបាន នៅក្នុងសង្គមរបស់យើង។ នៅក្នុងគម្ពីរចៅហ្វាយ ២១:២៥ បានចែកថា៖ " នៅគ្រានោះ ស្រុកអ៊ីស្រាអែលគ្មានស្តេចសោយរាជ្យទេ ម្នាក់ៗធ្វើអ្វីៗតាមតែខ្លួនយល់ឃើញ។" សូម្បីនៅគ្រានោះ ព្រះជាម្ចាស់បានប្រើប្រាស់ពួកចៅហ្វាយដើម្បីដឹកនាំជនជាតិអ៊ីស្រាអែល ដោយយោងទៅតាមទិសដៅរបស់ទ្រង់ ប៉ុន្តែនៅក្នុងគម្ពីរ១សាំយូអែល ៨ យើងឃើញថា ជនជាតិអ៊ីស្រាអែលបានសុំឲ្យលោកសាំយ៉ូអែល តែងតាំងស្តេចមួយអង្គដើម្បីដឹកនាំពួកគេ។ ពួកគេចង់មានរាជរដ្ឋាភិបាលដូចជាជាតិសាសន៍នានាដែលនៅជុំវិញគេដែរ (ខ៥) ។ ដោយសារតែប្រជាជនមិន សុខចិត្តស្តាប់បង្គាប់ព្រះជាម្ចាស់ទេ នោះនាំមានតម្រូវការរាជរដ្ឋាភិបាលមួយជាចាំបាច់។

ពេលខ្លះមនុស្ស នឹកស្រមៃចង់បានរាជរដ្ឋាភិបាលមួយដែលគេហៅថា "យូតូភា" (Utopia) (ដែនដីសុខក្សេមក្សាន្ត) ដែលបានកន្លែងមួយ ឬ ប្រទេសមួយ មាននៅក្នុងឧត្តមគតិ ដែលមានភាពយុត្តិធម៌ និងភាពសុខដុមយ៉ាងល្អ ឥតខ្ចោះនៅក្នុងសង្គម។ នៅក្នុងយូតូភា មនុស្សគ្រប់គ្នាធ្វើរឿងដែលគេត្រូវធ្វើ រួមចំណែកនៅក្នុងសុខមាលភាព របស់អ្នកដទៃផ្សេងទៀត ហើយរីករាយជាមួយនឹងរឿងល្អៗក្នុងជីវិតយ៉ាងពេញបរិបូរណ៌។ ទោះជាយ៉ាងណា សង្គមដ៏សុខក្សេមក្សាន្តមួយនេះមិនអាចកើតមាននៅលើផែនដីនេះបានឡើយ។ មនុស្សលោកមាននិស្ស័យ អាត្មានិយម និង បះបោរ។ អំពើបាបគឺជាធាតុពិតនៃជីវិត ដែលយើងត្រូវប្រឈមមុខជាមួយជារៀងរាល់ថ្ងៃ។ គ្មាននរណាម្នាក់អាចគេចផុតពីឥទ្ធិពលរបស់វាបានឡើយ។ ផលវិបាកដ៏គួរឲ្យក្រៀមក្រំនៃអំពើបាប ត្រូវបានផ្សព្វផ្សាយនៅក្នុងកាសែត និង តាមរយៈវិទ្យុ និង បណ្តាញផ្សព្វផ្សាយធំៗដទៃទៀត ដែលបង្ហាញយ៉ាងច្បាស់ពីតម្រូវការចាំបាច់នៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលនៅក្នុងសង្គមរបស់យើង។

អំពើបាបគឺមានពិត។ វាមិនមែនជាលទ្ធផលនៃអបិយជំនឿ ឬ កង្វះការអប់រំនោះទេ។ វាគឺជាលទ្ធផលដែលបានមកពីនិស្ស័យរបស់មនុស្សប្រុសស្រីដែលរស់នៅទាស់ប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ និង ផ្អែកទៅលើបំណងចិត្តដ៏អាក្រក់របស់ពួកគេ។

លំហាត់អនុវត្តន៍

៥ ចូរប្រាប់ពីភស្តុតាងពីរយ៉ាង នៃធាតុពិតរបស់អំពើបាប ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ព្រមទាំងឲ្យឧទាហរណ៍ សម្រាប់ភស្តុតាងនីមួយៗផងដែរ។

ខ. ដើមកំណើតនៃអំពើបាប

អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ទស្សនវិទូបានធ្វើការវែងញែក តើអំពើបាបគឺមានតាំងពីដើមរៀងមក ហើយតែងតែមានវត្តមាននៅជាមួយនឹងការល្អ ដែរឬអត់។ អ្នកខ្លះបានធ្វើការសន្និដ្ឋានថា ការប្រជែងគ្នារវាងភាពត្រឹមត្រូវ និង ភាពមិនត្រឹមត្រូវមានតាំងដើមរៀងមក ហើយនឹងបន្តទៅមុខទៀតអស់កល្បជានិច្ច។ តើធ្លាប់មានពេលមួយដែលមានតែការល្អកើតឡើងដែរឬទេ? ប្រសិនបើមាន តើនៅពេលណា ដែលអំពើបាបចាប់ផ្តើមបង្ហាញខ្លួនឡើង? ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនេះ យើងត្រូវក្រឡេកទៅមើលលើការសិក្សា អំពីដើមកំណើតរបស់អំពើបាប នៅក្នុងសាកលលោក និង នៅក្នុងពូជអម្បូរមនុស្ស។

នៅក្នុងសាកលលោក

វត្ថុបំណងទី២. *រៀបរាប់យ៉ាងត្រឹមត្រូវអំពីដើមកំណើតនៃអំពើបាប។*

នៅក្នុងមេរៀនទី៥ យើងបានពិភាក្សាអំពីអំពើបាបរបស់ពួកទេវតា ដែលនាំទៅរកការធ្លាក់ចុះរបស់ពួកគេ និង អំពីអ្វីដែលបទគម្ពីរបានថ្លែងអំពីដើមកំណើតរបស់អំពើបាបនៅក្នុងសាកលលោក។ ចូរយើងរំឭកយ៉ាងសង្ខេបពីការពិតទាំងនេះឡើងវិញ ដើម្បីឃើញពីរបៀបដែលការនេះទាក់ទងនឹងការរាលត្បាតអំពើបាបទៅក្នុងពូជមនុស្ស។ ដំបូងយើងត្រូវអានមេរៀនទី៥ ឡើងវិញ នៅក្នុងចំណុចមួយដែលមានចំណងជើងថា "លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា" ។ ខាងក្រោមនេះជាការសង្ខេបខ្លីនៃចំណុចនោះ៖

១. ពួកទេវតា ត្រូវបានបង្កើតឡើងមកជាក្រុមភាវៈ មានភាពវិសុទ្ធ ល្អឥតខ្ចោះ និង មានបុគ្គលិកលក្ខណៈដែលមានឆន្ទៈបែរទៅរកព្រះអាទិករបស់ពួកគេ។
២. ជាក់ស្តែងពួកទេវតាមានអំណាចនៃការជ្រើសរើស និង ការយល់ដឹងពីផលវិបាកនៃការមិនស្តាប់បង្គាប់។
៣. មានទេវតាមួយនៅក្នុងចំណោមពួកគេ បានទទួលបានតំណែងដ៏ខ្ពង់ខ្ពស់មួយ (គម្ពីរអេសេគាល ២៨:១២; គម្ពីរ២កូរិនថូស ៤:៤ គម្ពីរអេភេសូ ២:២)
៤. ជាក់ស្តែង សាតាំងគឺជាអ្នកដឹកនាំការបះបោរតាំងពីដំបូងរៀងមក (គម្ពីរយ៉ូហាន ៨:៤៤ គម្ពីរ១យ៉ូហាន៣:៨)។

៥. ដោយការមើលទៅលើពួកស្តេចនៅលើផែនដី ដែលហាក់បីដូចជាតំណាងឲ្យសាតាំង យើងសរុបមកថា អំពើបាបរបស់គេចាប់ផ្តើមជាមួយនឹងមហិចតា និង ភាពក្រអឺតក្រទម (អំណួត)។ (ចូរប្រៀបធៀប គម្ពីរអេសេគាល ២៨:១១-១៩ និង គម្ពីរអេសាយ១៤:១៣-១៤ ជាមួយនឹង គម្ពីរ១ធីម៉ូថេ ៣:៦)។

បទគម្ពីរនៅខាងលើនេះ ជួយយើងឲ្យយល់ថា សាតាំងមិនពេញចិត្តនឹងឋានៈរបស់ខ្លួនឯង នៅក្រោមព្រះជាម្ចាស់នោះទេ។ វាខ្វល់ខ្វាយ ជាមួយនឹងមហិចតារបស់ខ្លួន ជាជាងការគោរពបម្រើព្រះជាម្ចាស់។ ភាពស្រស់ស្អាតរបស់វាបាន បាំងភ្នែកវាដែលធ្វើឲ្យវាគិតថាវាអាចខ្ពស់លើសពីព្រះអាទិករ។ វាមានភាពអាត្មានិយម មានភាពទោមនស្ស និង ច្រណែន មិនត្រឹមតែចង់បានអ្វីដែលព្រះអាទិករបានប្រទានឲ្យវាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចង់បានអ្វីដែលទ្រង់ទុកសម្រាប់អង្គទ្រង់ផ្ទាល់ទៀតផង។ អាការៈនៃអំពើបាបដែលយើងឃើញនៅក្នុងសាតាំង គឺពិតជាឫសគល់នៃអំពើបាបដែលមាននៅក្នុងពួកទេវតាអាក្រក់ផ្សេងទៀតដែរ។

ទាំងអស់នេះ គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងរាល់គ្នា ព្រោះ នៅពេលដែលសាតាំង និងពួកទេវតារបស់វា បះបោរប្រឆាំងនឹងព្រះជាម្ចាស់ អំពើបាបបានក្លាយទៅជាគោលការណ៍មួយនៅក្នុងជីវិតដែលមនុស្សត្រូវប្រឈមមុខនៅក្នុងសាកលលោកនេះ។ អំពើបាបរបស់ពួកគេជាតំណាងឲ្យភាពផ្ទុយគ្នាទៅនឹងព្រះវរបិតានៃស្ថានបរមសុខដែលប្រកបដោយសេចក្តីស្រឡាញ់របស់យើង។ គោលបំណងរបស់សាតាំងពេលនេះ គឺរារាំងផែនការរបស់ព្រះជាម្ចាស់ នៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងសាកលលោកនេះ។ សាតាំងជាមេដឹងនាំ ប្រព័ន្ធលោកីយ៍មួយដែលមានគោលជំហរ ទាស់នឹងព្រះជាម្ចាស់ និង ក្រឹត្យវិន័យរបស់ទ្រង់។

លំហាត់អនុវត្តន៍

---

៦ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវ ដែលទាក់ទងនឹងដើមកំណើតអំពើបាបនៅក្នុងសាកលលោក។

ក) ព្រះជាម្ចាស់បានចាត់ឲ្យមានអំពើបាបនៅក្នុងសាកលលោកនេះ ដើម្បីជាការសាកល្បងភាពស្មោះត្រង់នៃស្នាព្រះហស្តរបស់ទ្រង់ ទៅចំពោះទ្រង់។

ខ) អំពើបាបគឺជាគោលការណ៍ដ៏អស់កល្បជានិច្ច ដែលត្រូវបានរចនាឡើងដើម្បីផ្តល់លំនឹងទៅដល់គោលការណ៍នៃសេចក្តីល្អ។

គ) អំពើបាបបានចាប់ផ្តើមនៅពេលដែល ភាវៈដែលព្រះជាម្ចាស់បង្កើតមកនោះ បានជ្រើសរើសមិនស្តាប់បង្គាប់ព្រះអាទិកររបស់ពួកគេ ហើយដើរតាមផ្លូវរបស់ខ្លួនឯង។

ឃ) អំពើបាបបានចាប់កំណើតនៅក្នុងសាកលលោកនេះ នៅពេលដែលសាតាំងចង់បានឋានៈខ្ពស់ជាងគេ ដោយព្រោះតែមហិចតា និង អំណួតរបស់វា។

ង) អំណាចនៃការជ្រើសរើស គឺចាំបាច់ខ្លាំងណាស់សម្រាប់ទេវតា ក៏ដូចជាមនុស្សផងដែរ ដោយព្រោះតែព្រះជាម្ចាស់ មិនបានបង្ខំឲ្យនរណាម្នាក់មកថ្វាយបង្គំទ្រង់នោះទេ។

នៅក្នុងអម្បូរមនុស្ស

ដូចដែលយើងបានឃើញហើយថា ព្រះជាម្ចាស់បានបង្កើតលោកអដាំមកដោយគ្មាននិស្ស័យបាបសោះឡើយ ទ្រង់បានដាក់គាត់នៅក្នុងបរិស្ថានមួយដែលសមស្រប និង បំពេញគ្រប់ទាំងតម្រូវការរបស់លោក។ ព្រះជាម្ចាស់ប្រទានឲ្យអដាំនូវគំនិតដ៏មានអំណាច និង ការល្បងលជាច្រើនដើម្បីឲ្យលោកអាចចំណាយពេល និង កម្លាំងរបស់លោក។ ទ្រង់ក៏បានប្រទានឲ្យលោកអដាំមាន អ្នកជំនួយ និង ដៃគូដែលសមស្របម្នាក់គឺនាងអេវ៉ា។ បន្ទាប់មកព្រះអាទិករបានដាក់ក្រឹត្យវិន័យដ៏សាមញ្ញខ្លះៗ ដើម្បីសង្កេត និង ដាស់តឿនលោកអដាំ និងនាងអេវ៉ាអំពីផលវិបាកនៃការមិនស្តាប់បង្គាប់។ បន្ទាប់មកទ្រង់បានយាងចុះមកដើម្បីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងមនុស្សដំបូងទាំងពីរនាក់។

ការដាស់តឿនរបស់ព្រះជាម្ចាស់ទៅកាន់លោកអដាំ និង នាងអេវ៉ា ត្រូវបានចាត់ទុកជាការសាកល្បងដ៏សាមញ្ញមួយ។ នៅក្នុងចំណោម អភ័យឯកសិទ្ធិ និង ការប្រោសប្រទានដ៏ច្រើនអនេក ពួកគេត្រូវបានហាមឃាត់ពីរឿងមួយប៉ុណ្ណោះ៖ ផ្លែនៃដើមឈើមួយដើម។ ការសាកល្បងនេះ គឺត្រូវបានបង្កើតឡើងដើម្បីបង្ហាញពីការស្តាប់បង្គាប់ និង មិនស្តាប់បង្គាប់របស់ពួកគេទៅចំពោះបំណងព្រះហឫទ័យរបស់ទ្រង់។ លោកអដាំ និង នាងអេវ៉ា មិនត្រូវបង្កើតឡើងឲ្យដូចជាមនុស្សយន្ត ដើម្បីរស់នៅក្នុងសម្រាប់សិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយគ្មានជម្រើសអ្វីទាល់តែសោះចំពោះបញ្ហាមួយនេះឡើយ។ ឆន្ទៈរបស់ពួកគេត្រូវតែមានទំនោរទៅរកព្រះជាម្ចាស់ ប៉ុន្តែដោយសារតែពួកគេមានអំណាចក្នុងការសម្រេចចិត្តទទួលយក ឬ ច្រានចោលទំនោរមួយនេះ ពួកគេអាចប្រើប្រាស់ឆន្ទៈសេរីរបស់ពួកគេ ហើយធ្វើការជ្រើសរើសប្រកបដោយការពិចារណាមួយ។ សមត្ថភាពមួយនេះ គឺជាលក្ខខណ្ឌចាំបាច់មួយ នៃការសាកល្បងមួយនេះ។

សាតាំងគ្មានអ្នកល្បួងវាទេ នៅពេលដែលវាបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ប៉ុន្តែចំណែកឯមនុស្សវិញ គឺមាន។ មិនយូរប៉ុន្មាន ក្រោយពេលដែលព្រះជាម្ចាស់បានដាក់លោកអដាំ និង នាងអេវ៉ានៅក្នុងសួនអេដែន សាតាំងបានចូលទៅឯនាងអេវ៉ា ហើយបញ្ជាក់ថា ព្រះជាម្ចាស់កំពុងតែលាក់បាំងរឿងមួយដែលល្អប្រសើរ និង មានប្រយោជន៍ពីនាង និង លោកអដាំ។ គួរឲ្យកត់សំគាល់ថា នាងអេវ៉ាមិនបានជំទាស់ទៅនឹងការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះទាស់នឹងព្រះជាម្ចាស់ឡើយ។ តាមពិតទៅ នៅពេលដែលសាតាំងចោទព្រះជាម្ចាស់ថាបានកុហកដោយថ្លែងថា “ទេ! អ្នកទាំងពីរនឹងមិនស្លាប់ទេ។” (គម្ពីរលោកុប្បត្តិ ៣:៤) នាងអេវ៉ាមិនបានជំទាស់ និង មិនបានថ្លឹងថ្លែងការនិយាយប្រឆាំងនឹងលក្ខណសម្បត្តិដ៏វិសុទ្ធរបស់ព្រះជាម្ចាស់នោះទេ។ ផ្ទុយទៅវិញ នាងបានគិតតែពីប្រយោជន៍ដែល*នាង*អាចនឹងទទួលបានពីការធ្វើតាមការណែនាំរបស់អ្នកល្បួងទៅវិញ។ វាបានទាក់ជាប់នឹងអារម្មណ៍របស់នាង ចំណង់របស់នាង និង មហិច្ឆតាដែលទើបនឹងកើតថ្មីរបស់នាង។

ដូច្នេះហើយ ដោយសកម្មភាពនៃឆន្ទៈរបស់នាងអេវ៉ា និងដោយសារតែការបោកបញ្ឆោតរបស់សាតាំង នាងក៏បានសម្រេចចិត្តធ្វើអ្វីដែលនាងចង់ ដោយមិនធ្វើអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យនោះឡើយ។ គម្ពីរលោកុប្បត្តិ ៣:១-៥ បានបង្ហាញថា នាងចង់ ១) បានអ្វីដែលព្រះជាម្ចាស់បានហាម ២) ដឹងពីអ្វីដែលព្រះជាម្ចាស់មិនបានបើកបង្ហាញ និង ៣) ក្លាយខ្លួនជាអ្វីដែលព្រះជាម្ចាស់មិនមានការបម្រុងទុកសម្រាប់នាងឡើយ។

ដូច្នេះនាងអេវ៉ាជ្រើសរើសខ្លួនឯង លើសព្រះជាម្ចាស់ នោះហើយគឺជាអំពើបាប។ នាងបានគិតអ្វីដែលនាងនឹងធ្វើរួចទៅហើយ។ ដោយមើលទៅលើផ្លែឈើនោះ យើងបានឲ្យហេតុផលថា ដោយសារតែផ្លែឈើនោះជាផ្លែឈើល្អ នោះគ្មានអ្វីខុសឆ្គងនោះទេ បើគ្រាន់តែបរិភោគវា។ នាងក៏បានឲ្យហេតុផលថា ដោយសារតែផ្លែឈើនោះវាស្រស់ស្អាត និង ឮថាអាចផ្តល់ការដឹងខុសត្រូវផងនោះ គ្រាន់តែបរិភោគប៉ុណ្ណឹង វាមិនខុសអ្វីនោះទេ។ ដូច្នេះហើយ នាងបានភ្លេចការពិតដ៏សំខាន់ជាងគេបំផុត ៖ *ព្រះជាម្ចាស់បានហាមឃាត់មិនឲ្យបរិភោគផ្លែឈើនោះ!* ដោយឃើញតែពីអ្វីដែលនាងចង់ឃើញ នាង និង លោកអដាំបានបរិភោគផ្លែឈើនោះដោយការមិនស្តាប់បង្គាប់នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងបើកចំហ។ ទោះបីជាពួកគេមានសតិបញ្ញាគ្រប់គ្រាន់នឹងឲ្យពួកគេយល់ពីផលវិបាកយ៉ាងណាក៏ដោយ ក៏ពួកគេមិនបានសូម្បីតែសួរថាតើព្រះជាម្ចាស់បានទទួលសិរីរុងរឿងដែរឬទេ ចំពោះសកម្មភាពរបស់ពួកគេនេះ។ ហេតុអ្វីបានជាពួកគេមិនពិចារណាឲ្យបានម៉ត់ចត់ជាងនេះ ចំពោះអ្វីដែលពួកគេធ្វើ?

ដូច្នេះបុព្វបុរសរបស់យើងមានចេតនាជ្រើសរើស ការមិនស្តាប់បង្គាប់តាមការដាស់តឿនរបស់ព្រះជាម្ចាស់។ ទោះបីជាពួកគេត្រូវបានសាតាំងល្បួងក៏ដោយ គ្មាននរណាបានបង្ខំពួកគេឲ្យប្រឆាំងការណែនាំរបស់ព្រះជាម្ចាស់នោះទេ ។ ទង្វើនៃការមិនស្តាប់បង្គាប់បែបនេះ បង្កើតបានទៅជាអំពើបាបនៅក្នុងអម្បូររបស់មនុស្ស (សូមមើលនៅក្នុងគម្ពីររ៉ូម ៥:១២) និងឥរិយាបថដែលនាំឲ្យអំពើបាបបន្តនៅក្នុងនិស្ស័យរបស់មនុស្ស ។ ខ្ញុំបានដឹងពីវា ចំណែកអ្នកក៏ដូចគ្នាដែរ។ ដូច្នេះហើយ អំពើបាបបានចូលមកក្នុងពិភពលោក និង ជះឥទ្ធិពលអាក្រក់មកលើមនុស្សលោក បំផ្លាញទំនាក់ទំនងដែលប្រកបដោយព្រះពររបស់មនុស្សជាមួយនឹងព្រះជាម្ចាស់។ អំពើបាបនៅតែបន្តឥទ្ធិពលរបស់វានៅលើ កូនចៅជំនាន់ក្រោយរបស់លោកអដាំ។ មនុស្សគ្រប់រូប ទទួលបានកេរ្តិ៍មរតកនៃនិស្ស័យបាបនេះពីលោកអដាំ ហើយបើមិនកែតម្រូវនោះទេ នឹងនាំទៅរកសេចក្តីស្លាប់ខាងវិញ្ញាណជាក់ជាមិនខាន។

លំហាត់អនុវត្តន៍

---

៧ ចូរអានគម្ពីរលោកុប្បត្តិ ៣:២២-២៣ និង គម្ពីររ៉ូម ៥:១២ ហើយឆ្លើយសំណួរទាំងនេះ៖

ក) តើអ្វីជាលទ្ធផលនៃអំពើបាបរបស់លោកអដាំ ទាក់ទងទៅនឹងជីវិតផ្ទាល់ខ្លួនរបស់គាត់?

.....

ខ) តើអ្វីជាលទ្ធផល ទៅចំពោះកូនចៅជំនាន់ក្រោយរបស់លោកអដាំ?

.....

៨ ដោយឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយពីមូលហេតុដែលសក្តិសមឲ្យព្រះជាម្ចាស់ ដាក់ទោសលោកអដាំ និង នាងអេវ៉ា ហើយតាមរយៈពួកគាត់ទាំងពីរនាក់ បានឆ្លងដល់អម្បូរមនុស្សទាំងមូល ។

គ. និស្ស័យរបស់អំពើបាប

វត្ថុបំណងទី៣. *ស្គាល់ពីទិដ្ឋភាពនៃអំពើបាប។*

តើវាមិនងាយទេឬអី បើអំពើបាបគឺជាសារធាតុមានរូប ដែលយើងអាចធ្វើការញែកចេញបាននោះ? យើងអាចអញ្ជើញអ្នកស្រាវជ្រាវ ពីរបីនាក់មកដើម្បីរកមើលសារធាតុគីមី ថ្នាំ ឬ សេរ៉ូមដើម្បីបំផ្លាញវាបាន។ បន្ទាប់មក ក្រុមអ្នកជំនាញអាចធ្វើដំណើរពីសហគមន៍មួយទៅសហគមន៍មួយ ដើម្បីចាក់ថ្នាំនោះ ដែលនឹងអាចបញ្ចប់អំណាច និង ផលវិបាករបស់វាបាន។ មិនយូរប៉ុន្មាន សង្គមនឹងអាចផ្លាស់ប្តូរទាំងស្រុង ហើយមនុស្សអាចរស់នៅដើម្បីសសើរតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់បាន។ យើងដឹងថា អំពើបាបមិនមែនជាមេរោគ ឬ ក៏ជាវីរុសនោះដែរ។ តើអ្វីជានិស្ស័យដ៏ពិតរបស់អំពើបាប?

យើងបានឃើញពីអត្ថន័យសង្ខេបនៃអំពើបាបនៅក្នុងទិដ្ឋភាពដំបូងបំផុតក្នុងមេរៀននេះហើយ វាគឺជាការមិនស្តាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាគឺជាអ្វីៗគ្រប់យ៉ាងដែលមនុស្សធ្វើខុស ។ វារាប់បញ្ចូលទាំង ការធ្វើអ្វីដែលមិនគួរធ្វើ និង មិនបានធ្វើអ្វីដែលយើងគួរតែធ្វើ។

ភាសាហេប្រឺនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ភាសាក្រិកដែលប្រើដើម្បីសរសេរ គម្ពីរសម្ព័ន្ធមេត្រីថ្មី បានប្រើប្រាស់ពាក្យយ៉ាងច្បាស់ៗ ដើម្បីរៀបរាប់អំពីសកម្មភាពនៃការធ្វើអំពើបាបទាស់នឹងព្រះជាម្ចាស់។ អ្នកប្រាជ្ញខាងព្រះគម្ពីរ ដែលបានសិក្សាការបង្កើតពាក្យ បានបកស្រាយពីផ្នត់គំនិតដែលនៅពីក្រោយការបង្កើតពាក្យទាំងនោះ។ ការសិក្សាពាក្យរបស់ពួកគេ បានផ្តល់ឲ្យយើងនូវការយល់ដឹងមួយអំពីអត្ថន័យនៃពាក្យថា *អំពើបាប។* ពាក្យនីមួយៗ បង្ហាញតាមរបៀបផ្សេងៗគ្នា អំពីសកម្មភាព ឬ ឥរិយាបថដែលបង្ករឲ្យមានការមិនសព្វព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ចូរយើងក្រឡេកទៅមើលពាក្យខ្លះៗ ។ (ពាក្យដែលបានប្រើនៅក្នុងការបកប្រែគម្ពីរ ជំនាន់ថ្មី ប្រហែលជាមិនដូចទៅនឹងពាក្យដែលបកមកពីពាក្យហេប្រឺ និងពាក្យក្រិក ដែលយើងរៀបរាប់ខាងក្រោមនេះទាំងស្រុងនោះទេ ។)

១. *អំពើរំលង* (គម្ពីររ៉ូម ៥:១៤-១៧, គកស២០១៦)។ យើងតែងតែឃើញ ផ្លាកសញ្ញាដែលសរសេរថា *ហាមចូល (រំលង)។* តើផ្លាកសញ្ញានោះមានន័យយ៉ាងដូចម្តេច? ការចូល ឬ រំលង មានន័យថា ការឆ្លងកាត់ ឬ បំពានកម្មសិទ្ធិផ្ទាល់ខ្លួនរបស់អ្នកដទៃ។ នៅពេលដែលនរណាម្នាក់ ដាក់ផ្លាកសញ្ញាដូចនេះ ពួកគេមិនចង់ឲ្យនរណាម្នាក់ផ្សេងទៀតឆ្លងកាត់លើកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ ដើម្បីរារាំងកុំឲ្យ មានការឆ្លោះរំលង ពួកគេអាចនឹងបិទបាំងកន្លែងដែលជាកម្មសិទ្ធិរបស់គេ ឬ កំណត់ព្រំប្រទល់យ៉ាងច្បាស់។ ជារឿយៗ ពួកគេបានដាក់បន្ថែមនៅលើផ្លាកសញ្ញារបស់ពួកគេ នូវទោសនៃការឆ្លោះរំលងនោះ។ ដូចគ្នាដែរ ព្រះជាម្ចាស់បានបង្កើតដែនកំណត់ខាងឯសីលធម៌ សម្រាប់មនុស្សដែលយើងរាល់គ្នាហៅថាច្បាប់នោះឯង។ នៅពេលដែលមនុស្សឆ្លោះរំលង ឬ ឆ្លងកាត់លើដែនកំណត់ទាំងនោះ ពួកគេបានប្រព្រឹត្តិបាបហើយ ពួកគេប្រឆើយកន្តើយចំពោះច្បាប់របស់ព្រះជាម្ចាស់ ។ ភាពគ្មានច្បាប់ទម្លាប់ គឺជាអំពើបាប (គម្ពីរ១យ៉ូហាន ៣:៤)។

២. *ខុសគោលដៅ* (គម្ពីរនិក្ខមនំ ២០:២០) ។ នៅពេលដែលមនុស្សធ្វើអំពើបាប ពួកគេបានបរាជ័យក្នុងការបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់ពួកគេ។ នៅក្នុងន័យនេះ អំពើបាបគឺជាការ*ខុសគោលដៅ* ។ ពួកគេធ្វើមិនដល់អ្វីដែលព្រះជាម្ចាស់ បានដាក់ផែនការសម្រាប់ពួកគេ។ *ការខុសគោលដៅ* គឺជាពាក្យមួយដែលទាក់ទងទៅនឹង ការបាញ់ធ្នូ នៅពេលដែលមនុស្សម្នាក់បាញ់មិនត្រូវចំណុចកណ្តាលនៃគោលដៅរបស់គេតម្រង់បាញ់ទៅនោះ។

៣. *ភាពអាត្មានិយម* (គម្ពីរទំនុកតម្កើង ១១៩:៣៦និង គម្ពីរ ភីលីព ២:៣) ។ ការមិនស្តាប់បង្គាប់លើកទីមួយ បានកើតឡើងដោយព្រោះតែភាពអាត្មានិយម ដ្បិតមនុស្សដំបូងបង្អស់ គេចង់បានអ្វីដែលគេគិតថា ព្រះជាម្ចាស់បានបដិសេធជាមួយនឹងពួកគេ។ វាបានទាក់ទាញ *ភាពឥតប្រយោជន៍* និង *អំណួត*របស់ពួកគេ។

៤. *ការបះបោរ* (គម្ពីរនិក្ខមនំ ២៣:២១ គម្ពីរ១សាំយ៊ូអែល ២៤:១១) ។ ការបះបោរគឺជាការមិនស្តាប់បង្គាប់ ឬ ការប្រឆាំងទាស់នឹងសិទ្ធិអំណាចរបស់នរណាម្នាក់។ ការបះបោរ គឺជា*ការចាកចេញឆ្ងាយ* ពីច្បាប់របស់ព្រះជាម្ចាស់។ លោកអេសាយ បានបង្ហាញពីការនេះ ដោយមានប្រសាសន៍ថា៖ "កាលពីមុនយើងទាំងអស់គ្នាសុទ្ធតែវង្វេងដូចចៀមដែលបែកចេញពីហ្វូង
ម្នាក់ៗដើរតាមផ្លូវរបស់ខ្លួនផ្ទាល់" (គម្ពីរអេសាយ ៥៣:៦) ។ នេះគឺគ្រាន់តែជាអ្វីដែលមនុស្សធ្វើនៅក្នុងពេលសព្វថ្ងៃនេះតែប៉ុណ្ណោះ។ គ្រប់គ្នាចង់ "ធ្វើរឿងរបស់ខ្លួនឯង" ដើរតាមបំណងចិត្តផ្ទាល់ខ្លួន។ រឿងដូចគ្នានេះ គឺកើតមានដូចគ្នានៅក្នុងសហគមន៍ និង ប្រទេសជាតិទាំងមូលផងដែរ។ មនុស្សមិនចង់ដើរតាមមាគ៌ាដែលព្រះជាម្ចាស់បានកំណត់ទុកសម្រាប់ពួកគេឡើយ។

៥. *ការប្រឡាក់* (គម្ពីរយ៉ាកុប ១:២៧ គកស២០១៦) ។ នៅពេលដែលមនុស្សធ្វើអំពើបាបដោយចេតនា ពួកគេបានដឹងច្បាស់ពីការធ្វើខុសរបស់ផងគេ ដ្បិតមនសិការរបស់ពួកគេ ថ្កោលទោសពួកគេ។ អារម្មណ៍មានកំហុស នេះហើយដែលត្រូវបានដាស់ឡើងដោយអំពើបាប ធ្វើឲ្យពួកគេដឹងពីភាពប្រឡាក់របស់ពួកគេ (ភាពមិនស្អាត)។ ពួកគេមានអារម្មណ៍កខ្វក់។ នោះគឺជាមូលហេតុដែលបទគម្ពីរ ថ្លែងពីតម្រូវការ នូវ*ការលាងសម្អាត* ឲ្យអស់ការប្រឡាក់នៃអំពើបាបនេះ (គម្ពីរទំនុកតម្កើង ៥១:២, ៧ គម្ពីរ១យ៉ូហាន ១:៧,គកស២០១៦)

សង្ខេបមកយ៉ាងខ្លី អំពើបាបគឺជាការបរាជ័យរបស់ស្មាព្រះហស្តរបស់ព្រះជាម្ចាស់ ក្នុងការស្តាប់បង្គាប់តាមច្បាប់របស់ទ្រង់។ អ្វីក៏ដោយ ឲ្យតែមិនមានគោលដៅក្នុងការតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺជាអំពើបាប (គម្ពីររ៉ូម ៣:២៣)។ អ្វីក៏ដោយ នៅក្នុងយើងរាល់គ្នាដែលមិនបង្ហាញ ឬ ផ្ទុយពីលក្ខណសម្បត្តិដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ គឺអំពើបាប។

លំហាត់អនុវត្តន៍

៩ ចូរផ្គូផ្គងពាក្យដែលតំណាងឲ្យទិដ្ឋភាពមួយនៃអំពើបាប (ខាងស្តាំ) ទៅនឹងនិយមន័យដែលត្រឹមត្រូវសម្រាប់ពាក្យនីមួយៗ (ខាងឆ្វេង)។

.....ក) ការចង់ដើរតាមផ្លូវផ្ទាល់ខ្លួន ដោយមិនចង់ចុះចូលជាមួយមាគ៌ាព្រះជាម្ចាស់ឡើយ។
.....ខ) ជាអ្វីដែលត្រូវការការលាងសម្អាត។
.....គ) បរាជ័យក្នុងការបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នៅក្នុងជីវិត។
.....ឃ) ការឆ្លងកាត់លើដែនកំណត់ដែលព្រះជាម្ចាស់បានហាមឃាត់។
.....ង) ការធ្វើទាស់នឹងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់ ការចាកចេញឆ្ងាយពីច្បាប់របស់ព្រះជាម្ចាស់។

១) អំពើរំលង
២) ខុសគោលដៅ
៣) ភាពអាត្មានិយម
៤) ការបះបោរ
៥) ការប្រឡាក់

ឃ. ផលវិបាកនៃអំពើបាប

វគ្គបំណងទី៤. *រៀបរាប់អំពីផលវិបាកនៃអំពើបាប។*

គម្ពីរលោកុប្បត្តិជំពូក៣ បានរំឭកឡើងវិញនូវផលវិបាកនៃអំពើបាបដំបូងគេបង្អស់។ ពិតដូចជាអ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលថា៖ "តែមិនត្រូវបរិភោគផ្លែឈើពីដើម ដែលនាំអោយស្គាល់ល្អស្គាល់អាក្រក់ឡើយ" ហើយទ្រង់ថែមទាំងព្រមានទៀតថា៖ "ដ្បិតថ្ងៃណាអ្នកបរិភោគផ្លែនោះ អ្នកមុខជាស្លាប់មិនខាន" (គម្ពីរលោកុប្បត្តិ ២:១៧)។ ដោយមិនគោរពតាមការព្រមានរបស់ព្រះជាម្ចាស់ និង ដោយការយកអ្វីដែលទ្រង់បានហាម លោកអដាំ និង នាងអេវ៉ាមិនអាចរំពឹងទុកថានឹងទទួលបានអ្វីទៀត ក្រៅពីផលវិបាកដែលទ្រង់បានសន្យានោះឡើយ។ ចូរក្រឡេកមើលបន្តិច ទៅលើផលវិបាកធំៗនៃអំពើបាបដើមដំបូងបង្អស់របស់មនុស្សជាតិ។

សម្ព័ន្ធភាពប្រេះស្រាំជាមួយនឹងព្រះជាម្ចាស់

ការយល់ដឹង និង ការទទួលស្គាល់ថា ពួកគេបានមិនស្តាប់បង្គាប់ព្រះជាម្ចាស់ដោយចេតនារបស់ពួកគេ បាននាំមកឲ្យលោកអដាំ និងនាងអេវ៉ានូវ អារម្មណ៍ថាមានទោសភ្លាមៗ។ ភាពគ្មានទោសរបស់ពួកគេបានបាត់ទៅហើយ ហើយមនសិការរបស់ពួកគេបានថ្កោលទោសចំពោះទង្វើរបស់ពួកគេ។ ពួកគេទទួលអារម្មណ៍ដឹងពីភាពអាក្រាតរបស់ខ្លួន ចំពោះមុខគ្នាទៅវិញទៅមក និង នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ផងដែរ ហើយពួកគេបានព្យាយាមលាក់ខ្លួនពីព្រះជាម្ចាស់ជាមួយនឹងភាពអាម៉ាស់។ នៅពេលដែលទ្រង់ ឲ្យពួកគេប្រឈមមុខនឹងអ្វីដែលពួកគេបានធ្វើ ពួកគេបានព្យាយាមបន្ទោសគ្នាទៅវិញទៅមក។ លោកអដាំបន្ទោសនាងអេវ៉ា ហើយនាងអេវ៉ាបានបន្ទោសសត្វពស់ (គម្ពីរលោកុប្បត្តិ ៣:១២-១៣) ហើយជាមួយនឹងការសារភាពបាបដ៏ខ្លោចផ្សាមួយនេះ

សម្ព័ន្ធភាពផ្ទាល់ខ្លួន ដ៏ស្រស់ស្អាតជាមួយព្រះជាម្ចាស់ក៏ត្រូវបានបញ្ចប់ ។ ពួកគេបានស្លាប់ ខាងឯវិញ្ញាណបាត់ទៅហើយ (គម្ពីរលោកុប្បត្តិ ២:១៧) និង ត្រូវបានបណ្តេញចេញពីសួនច្បារអេដែន ឲ្យទៅរស់នៅក្នុងជីវិតមួយដែលខុសស្រឡះ ពីអ្វីដែលដែលពួកគេបានស្គាល់នៅក្នុងពេលនោះ។

និស្ស័យដែលពេញដោយបាប

អំពើបាបរបស់លោកអដាំ និង នាងអេវ៉ា មិនត្រឹមតែបានបំផ្លាញដួងចិត្តរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏បានបំផ្លាញដួងចិត្តរបស់កូនចៅជំនាន់ក្រោយទាំងអស់របស់ពួកគេផងដែរ។ ព្រះគម្ពីរបានថ្លែងថា អំពើបាបតែមួយរបស់ពួកគេ គឺជាគោលការណ៍ដ៏ពុករលួយមួយដែលបានបន្តមកឲ្យមនុស្សគ្រប់គ្នាដែលជាកូនចៅជំនាន់ក្រោយ និង ទៅដល់មានគ្រប់គ្នាផងដែរ (គម្ពីររ៉ូម ៥:១២) ។ ដូច្នេះ ពិភពលោកទាំងមូលបានធ្លាក់នៅក្រោមអំណាចរបស់អំពើបាប (គម្ពីរកាឡាទី ៣:២២) ហើយជាមួយនឹងចំណងមួយនេះ យើងក៏បានក្លាយជា "មនុស្សជាប់ក្នុងសេចក្តីខ្ជាល់" (គម្ពីរអេភេសូ ២:៣ ពគប១៩៥៤) ។ និស្ស័យបាបនេះ រារាំងមនុស្សមិនឲ្យផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។ មនុស្សគ្រប់គ្នាធ្វើអ្វីដែលពួកគេធ្វើ ក៏ព្រោះតែនិស្ស័យដ៏ពុករលួយរបស់ពួកគេ ព្រោះតែអ្វីដែលជាពួកគេ។

ព្រះគម្ពីរបានថ្លែងថា ពួកយើងកើតមកជាមួយនឹងនិស្ស័យដ៏ពុករលួយមួយនេះ (គម្ពីរទំនុកតម្កើង ៥១:៥)។ យើងអាចនឹងគិតថា បុត្ររបស់ព្រះជាម្ចាស់គឺល្អឥតខ្ចោះ ហើយគ្មាននិស្ស័យបាបអ្វីទាល់តែសោះ។ ទោះជាយ៉ាងណា នៅពេលដែលយើងមើលទៅលើបងប្អូនប្រុសស្រី ឈ្លោះប្រកែកគ្នា យើង ដឹងថា ភាពអាត្មានិយម គឺជាទិដ្ឋភាពមួយនៅក្នុងនិស្ស័យរបស់មនុស្ស។ ទំនោររបស់ក្មេងដែលចេះតែចង់មិនស្តាប់បង្គាប់ក៏បានមកពីនិស្ស័យបាបរបស់ពួកគេផងដែរ។

លំហាត់អនុវត្តន៍

---

១០ ចូរផ្គូផ្គងបទគម្ពីរ (ខាងឆ្វេង) ទៅជាមួយនឹងទិដ្ឋភាពមួយរបស់យើងដែលត្រូវបានធ្វើឲ្យពុករលួយដោយអំពើបាប (ខាងស្តាំ)។

.....ក)	គម្ពីរ១ធីម៉ូថេ ៤:២ គម្ពីរទីតុស ១:១៥	១)	សតិបញ្ញា
.....ខ)	គម្ពីររ៉ូម ១:២៨ គម្ពីរ១កូរិនថូស ២:១៤ គម្ពីរ២កូរិនថូស ៤:៤ គម្ពីរអេភេសូ ៤:១៨	២)	វេទនាអារម្មណ៍ និង អារម្មណ៍
		៣)	ឆន្ទៈ
.....គ)	គម្ពីរអេភេសូ ២:១,៥; គម្ពីរកូឡូស ២:១៣,១៨	៤)	មនសិការ
.....ឃ)	គម្ពីរយេរេមា ១៧:៩-១០ គម្ពីរអេភេសូ ៤:១៩	៥)	វិញ្ញាណ (បានស្លាប់ទៅហើយ)
.....ង)	គម្ពីររ៉ូម ១:២៨; ៧:១៨-២០		

បទសំណេរទាំងអស់នេះ បង្ហាញយើងថា គ្រប់ទិដ្ឋភាពទាំងអស់នៅក្នុងជីវិតរបស់មនុស្សជាតិគឺ ត្រូវបានធ្វើឲ្យខូចបង់ដោយអំពើបាប ហើយនៅក្នុងស្ថានភាពបែបនេះ មនុស្សមិនអាចធ្វើអ្វីៗ ដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ។ នេះមិនមែនមានន័យថា មនុស្សដែលគ្មានព្រះជាម្ចាស់មិនអាចធ្វើ ឬ យល់ពីទង្វើល្អ និង មេត្តាធម៌ឡើយ។ នោះមានន័យថាមនុស្សមិនអាចធ្វើអ្វីឲ្យសមនឹងទទួលបានការគាប់ព្រះហឫទ័យព្រះជាម្ចាស់បានឡើយ ដរាបណាគេត្រូវបានប្រោសឲ្យរស់ ខាងឯវិញ្ញាណជាមុនសិន។ ភាពដូចនឹងព្រះជាម្ចាស់ នៅក្នុងពួកគេត្រូវបានបង្ខូចអស់ទៅហើយ។

ពួកយើងមិនត្រឹមតែទទួលរងផលវិបាក ដែលបានមកពីអំពើបាបរបស់លោកអដាំ និង ឥទ្ធិពលនៃនិស្ស័យបាបដែលយើងទទួលបានពីគាត់នោះទេ យើងក៏បានទទួលរងផលវិបាកនៃអំពើបាបរបស់ខ្លួនយើងផ្ទាល់ផងដែរ។ ប្រសិនបើខ្ញុំខ្ជិល ហើយមិនធ្វើការ ខ្ញុំនឹងទទួលរងនូវផលវិបាក (ហើយគ្រួសាររបស់ខ្ញុំក៏ដូចគ្នាដែរ)។

ជាញឹកញយ យើងត្រូវតែរងទុក្ខមិនត្រឹមតែលទ្ធផលនៃអំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏មានផលវិបាកនៃអំពើបាបរបស់អ្នកដទៃផងដែរ។ប្រជាជនដែលរស់នៅក្នុងប្រទេសដែលមានមន្ត្រីក្នុងរដ្ឋាភិបាលជាមនុស្សពុករលួយ មិនរីករាយជាមួយនឹងពរជ័យដែលរដ្ឋាភិបាលល្អត្រឹមត្រូវអាចផ្តល់ឲ្យនោះទេ។ កុមារដែលមានឪពុកជាមនុស្សប្រមឹក អាចរងការបំពានដែលអាចជាលទ្ធផលដែលបានមកពីគំនិតដែលបំពុលដោយស្រានោះ។ មនុស្សដែលស្លាប់នៅក្នុងគ្រោះថ្នាក់ចរាចរណ៍ ក៏ដោយព្រោះតែមនុស្សស្រវឹង។ សង្គមទូទៅ រងការបំពានពីសំណាក់ឧក្រិដ្ឋជន ហើយត្រូវបង់ថ្លៃសំរាប់ការចាប់មនុស្សទាំងអស់នោះឃុំឃាំងថែមទៀតផង។

នៅក្នុងមេរៀនទី៦ យើងបានឃើញថា ទិដ្ឋភាពល្អរបស់មនុស្សជាតិគឺត្រូវតែទទួលបានការកោតសរសើរ តែពេលនេះសូមមើលទៅលើទិដ្ឋភាពដែលគួរឲ្យខ្ពោចផ្សាវិញ។ មនុស្សជាតិដែលគ្មានព្រះជាម្ចាស់ គឺពុករលួយ។ ស្របពេលដែលយើងកំពុងរំកិលខិតចូលជិតដល់ថ្ងៃចុងក្រោយ យើងអាចរំពឹងថានឹងបានឃើញស្ថានភាពដ៏អាក្រក់នៅគ្រប់ទីកន្លែង។ តាមរយៈការជំរុញពីព្រះវិញ្ញាណ លោកសាវ័កប៉ូលបានសរសេរពាក្យពេចន៍ទាំងនេះ៖

> អ្នកត្រូវដឹងអោយច្បាស់ថា នៅពេលចុងក្រោយបង្អស់ នឹងមានគ្រាលំបាក មនុស្សម្នានឹងមានចិត្តអាត្មានិយម ស្រឡាញ់ប្រាក់ ក្រអឺតក្រទមអួតខ្លួន ប្រមាថព្រះជាម្ចាស់ មិនស្តាប់បង្គាប់ឪពុកម្តាយ រមិលគុណ បំផ្លាញអ្វីៗដែលជាសក្ការៈ គេជាមនុស្សអត់ចិត្ត គ្មានអធ្យាស្រ័យ និយាយមួលបង្កាច់ មិនចេះទប់ចិត្ត ឃោរឃៅ ស្អប់អំពើល្អ ជាមនុស្សមានចិត្តក្បត់ ឆាប់ច្រឡោត អួតបំប៉ោង ចូលចិត្តសប្បាយជាជាងស្រឡាញ់ព្រះជាម្ចាស់។ គេសំដែងអាការៈខាងក្រៅជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ ប៉ុន្តែ គេបដិសេធមិនទទួលស្គាល់ឫទ្ធានុភាព ដែលបានមកពីការគោរពប្រណិប័តន៍ព្រះអង្គនោះឡើយ។ ចូរចៀសចេញអោយឆ្ងាយ ពីមនុស្សប្រភេទនេះទៅ។(១ធីម៉ូថេ៣:១-១៥)

លំហាត់អនុវត្តន៍

១១ តើប្រយោគណាមួយនៅខាងក្រោមនេះដែលបកស្រាយអំពីផលវិបាកនៃអំពើបាបបានល្អជាងគេ?

ក) យើងរងទុក្ខសព្វថ្ងៃនេះ មិនមែនគ្រាន់តែ ដោយសារអំពើបាបរបស់លោកអដាំ និង និស្ស័យបាបដែលយើងបានស្នងនោះទេ ប៉ុន្តែក៏ជាផលវិបាកដែលបានមកពីអំពើបាបរបស់អ្នកដទៃផ្សេងទៀតផងដែរ។

ខ) មនុស្សគ្រប់គ្នា ទទួលរងផលវិបាកនៃអំពើបាបផ្ទាល់ខ្លួនរបស់គេ ប៉ុន្តែអំពើបាបរបស់គេគ្មានឥទ្ធិពលទៅលើជីវិតរបស់អ្នកដទៃឡើយ។

គ) ផលវិបាកនៃអំពើបាបនឹង កាត់បន្ថយនៅគ្រាចុងក្រោយ ពេលដែលមនុស្សទទួលបានការបំភ្លឺ។

ទំនួលខុសត្រូវខាងឯរូបកាយ

លោកអដាំ និង នាងអេវ៉ានៅក្នុងសួនអេដែន មិនដែលស្គាល់ជំងឺឈឺថ្កាត់អ្វីឡើយ។ មេរោគ វីរុស និង ជំងឺគ្រប់ប្រភេទទាំងអស់ បានលេចឡើងជាលទ្ធផលនៃអំពើបាប និង ត្រូវបានគេឃើញនៅក្នុងទំនាក់ទំនងរវាងអំពើបាប និង ការកាត់ទោស (គម្ពីរនិក្ខមនំ ១៥:២៦ គម្ពីរទុតិយកថា ២៨:៥៨-៦២)។ ការឈឺចាប់ ភាពអស់កម្លាំង និង ការបាក់បែករូបកាយ គឺជាទិដ្ឋភាពនៃដំណើរការដែលបានចាប់ផ្តើមឡើងដោយអំពើបាប ដែលចុងក្រោយនឹងនាំទៅរកសេចក្តីស្លាប់ខាងឯរូបកាយ (គម្ពីរលោកុប្បត្តិ ៣:១៦-១៩) ។ ការពិត សេចក្តីស្លាប់នៅតោងជាប់ជាមួយមនុស្ស គឺជាលទ្ធផលនៃការធ្លាក់ចុះរបស់មនុស្សជាតិ។ ដំណើរការនៃការរស់នៅក៏បានកំណត់ដោយ ភាពផ្ទុយគ្នារបស់សាតាំងទៅនឹងការខិតខំប្រឹងប្រែងរបស់យើង ដើម្បីបានឆ្ពោះទៅដល់ការរស់នៅសម្រាប់ព្រះជាម្ចាស់ និង បានផ្គាប់ព្រះហឫទ័យទ្រង់ផង (គម្ពីរលោកុប្បត្តិ ៣:១៥)។

បរិស្ថានដ៏កាចសាហាវមួយ

ដោយសារតែបណ្តាសារដែលបានមកពីអំពើបាប សាកលលោកទាំងមូលក៏ត្រូវបានរងទុក្ខ (គម្ពីរលោកុប្បត្តិ ៣:១៧-១៨) ។ ជីវិតសត្វបានបង្ហាញលក្ខណៈកាចសាហាវ។ គម្ពីរអេសាយ ១១:៦-៩ បង្ហាញថានៅក្នុងព្រះរាជដែលកំពុងយាងមកដល់របស់ព្រះជាម្ចាស់ សត្វព្រៃទាំងអស់នឹងបានពេញដោយសន្តិភាព មិនមែនកាចសាហាវនោះទេ។ ការនេះនាំឲ្យយើងជឿថារបៀបរបបនៅក្នុងព្រៃបច្ចុប្បន្ននេះគឺជាលទ្ធផលដែលបានមកពីបណ្តាសារនៃអំពើបាប សត្វខ្លាំងប្រមាញ់សត្វទន់ខ្សោយ ហើយភាពចុះសម្រុងគ្នានៅក្នុងធម្មជាតិក៏ត្រូវបានបង្ខូចអស់។

ជីវិតរុក្ខជាតិក៏បង្ហាញពីឥទ្ធិពលនៃអំពើបាបផងដែរ។ ស្រងែ និង បន្លាបានរីតត្បាតរុក្ខជាតិល្អ។ អាហារមិនលូតលាស់ ដោយគ្មានការខិតខំប្រឹងប្រែពីពីសំណាក់យើងឡើយ។ ការប្រឹងប្រែងរបស់យើងដើម្បីអាចទទួលបានអាហារ ពីបរិស្ថានជុំវិញខ្លួន បានធ្វើឲ្យខូចបង់លើរូបកាយរបស់យើងយ៉ាងខ្លាំង។ លោកសាវ៉កប៉ូលរៀបរាប់អំពីការនេះ តាមរបៀបដូចនេះ៖

> អ្វីៗសព្វសារពើដែលព្រះអង្គបង្កើតមក កំពុងតែអន្ទះអន្ទែង ទន្ទឹងរង់ចាំពេលដែលព្រះជាម្ចាស់នឹងបង្ហាញបុត្ររបស់ព្រះអង្គ ដ្បិតអ្វីៗទាំងអស់នោះបែរទៅជាឥតន័យ តែមិនមែនដោយចិត្តឯងទេ គឺព្រះជាម្ចាស់បានតំរូវដូច្នេះ។ ពិភពលោកនៅតែមានសង្ឃឹមថា ព្រះអង្គនឹងលោះអោយរួចផុតពីវិនាសអន្តរាយ ដើម្បីអោយមានសេរីភាព និងសិរីរុងរឿងនៃបុត្ររបស់ព្រះជាម្ចាស់។ យើងដឹងហើយថា មកទល់ថ្ងៃនេះ ពិភពលោកទាំងមូលកំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីដែលហៀបនឹងសំរាលកូន។ (គម្ពីររ៉ូម ៨:១៩-២២)

ការដាច់ចេញ និង ការដាក់ទោសអស់កល្បជានិច្ច

លទ្ធផលចុងក្រោយនៃអំពើបាបដែលយើងនឹងនិយាយនៅពេលនេះគឺជាលទ្ធផលមួយដែលគួរឲ្យក្រៀមក្រំបំផុត។ ព្រះគម្ពីរបង្ហាញថា មនុស្សបាបដែលមិនលន់តួទេនោះ នឹងត្រូវរងការដាក់ទោសអស់កល្បជានិច្ច។ ខ្ញុំពិតជាចង់ឲ្យមានលទ្ធផលខុសពីនេះណាស់ ប៉ុន្តែខ្ញុំក៏មិនហ៊ានបិទភ្នែករបស់ខ្ញុំធ្វើជាមើលមិនឃើញពាក្យដ៏ច្បាស់លាស់ទាំងអស់នោះដែរ។

លំហាត់អនុវត្តន៍

---

១២ ចូរបើកព្រះគម្ពីរអានមើលបទគម្ពីរទាំងនេះ ហើយ និយាយអំពីអ្វីដែលបទគម្ពីរបានបង្ហាញអំពីការដាក់ទោសដ៏អស់កល្បជានិច្ច។

ក) គម្ពីរម៉ាថាយ ២៥:៤១

ខ) គម្ពីរម៉ាកុស ៩:៤៨

គ) គម្ពីររ៉ូម ២:៨-៩

ឃ) គម្ពីរយ៉ូដាស ១៣

ង) គម្ពីរវិវរណៈ ១៤:១០-១១

ស្របពេលដែលយើងឃើញថា ពេលខ្លះអ្នកសរសេរព្រះគម្ពីរ បាននិយាយសំដៅទៅកាន់ការដាក់ទោសនេះថាជា*ការបំផ្លិចបំផ្លាញ* ការដាក់ទោសនេះនឹងស្ថិតនៅជាប់ជារៀងដ៏រាប (មើលគម្ពីរទំនុកតម្កើង ៥២:៥ គម្ពីរ២ថេស្សាឡូនិក ១:៦-៩)។ ចូរសំគាល់មើលនៅក្នុងគម្ពីរម៉ាថាយ ២៥:៤៦ ថា ពាក្យអស់កល្បជានិច្ចគឺត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់ទាំងស្ថានសួគ៌ និង ស្ថាននរក៖ ការដាក់ទោសដ៏អស់កល្បនិច្ច (ឋាននរក) ជីវិតអស់កល្ប (ឋានសួគ៌) ។ លុះត្រាតែមនុស្សប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយដោះស្រាយបញ្ហាអំពើបាបរបស់ពួកគេ បើពុំនោះទេពួកគេនឹងទទួលរងនូវការដាក់ទណ្ឌកម្មអស់កល្បជានិច្ច ដាច់ចេញពីវត្តមានរបស់ព្រះអម្ចាស់។ ។

១. ការស្រោចស្រង់មនុស្សមានបាប

វត្ថុបំណងទី៥. *បកស្រាយពីរបៀបដែលមនុស្សមានបាប ត្រូវបានស្រោចស្រង់ និង បកស្រាយពីលទ្ធផលនៃការស្រោចស្រង់។*

នៅកណ្តាលចំណោមភាពអស់សង្ឃឹម ពន្លឺនៃក្តីសង្ឃឹមមួយនឹងចែងចាំងឡើង។ ព្រះជាម្ចាស់ជាមួយសេចក្តីមេត្តាករុណារបស់ទ្រង់ បានប្រទានមធ្យោបាយឲ្យគេចផុតពីផលវិបាកនៃការស្លាប់ខាងឯវិញ្ញាណ។ ទ្រង់បានប្រទានរបៀបដែលអាចទទួលបានសិរីរុងរឿងអស់កល្បជានិច្ច នៅក្នុងព្រះវត្តមានរបស់ទ្រង់ សម្រាប់អស់អ្នកដែលនឹងទទួលយក ការប្រទានប្រកបដោយសេចក្តីមេត្តារបស់ទ្រង់។ អ្នក និង ខ្ញុំ អាចទទួលបានការស្រោចស្រង់ទាំងខាងឯវិញ្ញាណ និង ខាងឯរូបកាយ ហើយឥទ្ធិពលនៃអំពើបាបក៏អាចនឹងរំសាយចេញ។

ការស្រោចស្រង់ខាងឯវិញ្ញាណ

ព្រះជាម្ចាស់បានប្រទានការស្រោចស្រង់ខាងឯវិញ្ញាណរបស់យើង តាមរយៈការសុគតរបស់ព្រះបុត្រទ្រង់គឺព្រះយេស៊ូ ដែលបានធ្វើជាអ្នកជំនួសកន្លែងយើង ដើម្បីធ្វើការបង់ថ្លៃជួសបាបរបស់យើង។ ការនេះមានបកស្រាយនៅក្នុងគម្ពីរយ៉ូហាន ៣:១៦-១៧ ៖

> ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។ ព្រះជាម្ចាស់បានចាត់ព្រះបុត្រារបស់ព្រះអង្គ អោយយាងមកក្នុងលោកនេះ ពុំមែនដើម្បីដាក់ទោសមនុស្សលោកទេ គឺដើម្បីសង្គ្រោះមនុស្សលោក ដោយសារព្រះបុត្រាវិញ។

អ្នក និង ខ្ញុំ មានឱកាសទទួលបានការស្រោចស្រង់ខាងឯវិញ្ញាណ ប្រសិនបើយើងលន់តួបាបរបស់យើង និង ធ្វើការសម្រេចចិត្ត ចាកចេញពីគ្រប់អំពើបាបរបស់យើង។ ទោះជាយ៉ាងណា យើងត្រូវទទួលការប្រទានសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ ហើយទទួលយកសេចក្តីសន្យារបស់ទ្រង់ដើម្បីជួយយើងរាល់គ្នា។ ការនេះទាមទារឲ្យមានសកម្មភាពនៃជំនឿមួយ ដូចព្រះគម្ពីរបានថ្លែងថា៖ "ព្រះអង្គសង្គ្រោះបងប្អូនដោយសារព្រះគុណ តាមរយៈជំនឿ" (គម្ពីរអេភេសូ ២:៨) ។ តម្រូវការចុងក្រោយមួយនោះគឺថា យើងប្រកាសថា "ព្រះយេស៊ូពិតជាព្រះអម្ចាស់" (គម្ពីររ៉ូម ១០:៩) ។ នៅពេលដែលយើងជឿលើទ្រង់សារភាព និង លះបង់អំពើបាបរបស់យើង ហើយអនុញ្ញាតឲ្យព្រះយេស៊ូគង់ធ្វើជាព្រះអម្ចាស់ក្នុងជីវិតរបស់យើង នោះយើងនឹងត្រូវបានផ្លាស់ប្តូរ។ យើងទទួលបានជីវិតខាងឯវិញ្ញាណ (គម្ពីរអេភេសូ ២:១-៩ គម្ពីរកូឡូស ២:១៣) ហើយយើងក៏បានក្លាយទៅជាមនុស្សថ្មីនៅក្នុងព្រះគ្រិស្ត៖ "ប្រសិនបើអ្នកណាម្នាក់នៅរួមជាមួយព្រះគ្រិស្ត អ្នកនោះបានកើតជាថ្មី អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ" (គម្ពីរ២កូរិនថូស ៥:១៧) ។ លោកសាវ័កប៉ូល ដាស់តឿនអ្នកជឿឲ្យលះបង់និស្ស័យចាស់ចេញ ហើយដើរតាមព្រះជាម្ចាស់បង្កើតយើងសាជាថ្មីម្តងទៀត នៅក្នុងខ្លួនប្រាណថ្មីមួយដែលនឹងថ្វាយសិរីរុងរឿងទៅដល់ទ្រង់ (គម្ពីរអេភេសូ ៤:១៧-២៨ គម្ពីរកូឡូស ៣:១-១៧)

តាមរយៈការសុគតរបស់ទ្រង់ ព្រះអម្ចាស់នៃយើងបានបង់ថ្លៃទោសបាបរបស់យើង ព្រមទាំងបានរៃាប់ព្រះពិរោធដ៏ត្រឹមត្រូវរបស់ព្រះជាម្ចាស់ទាស់នឹងអំពើបាបនោះផងដែរ។ យើងបានក្លាយជាមនុស្សសុចរិត តាមរយៈទ្រង់។ ទ្រង់ធានាបាននូវការអត់ទោសសម្រាប់យើង ហើយប្រទានមកនូវការប្រោសលោះដ៏ពេញលេញ និង ឥតគិតថ្លៃ។ ទ្រង់ក៏ប្រទានិស្ស័យថ្មីសម្រាប់យើងផងដែរ។ ទោះបីជាយើងបានកើតមកជាមួយនឹងនិស្ស័យដ៏សៅហ្មងយ៉ាងនេះក្តី ទ្រង់បានទទួលយកយើងឲ្យចូលទៅក្នុងគ្រួសារដ៏វិសុទ្ធរបស់ព្រះជាម្ចាស់។ លើសពីនេះទៅទៀត ទ្រង់ប្រទានឲ្យយើងនូវឋានៈជាបុត្ររបស់ព្រះជាម្ចាស់ ហើយបានធ្វើឲ្យយើងក្លាយជាអ្នកស្នងមរតករបស់ព្រះជាម្ចាស់ផងដែរ (គម្ពីររ៉ូម ៨:១៧)។ ព្រះអម្ចាស់នៃយើងមិនត្រឹមតែបានធ្វើការរៀបចំទាំងនេះសម្រាប់ការស្រោចស្រង់វិញ្ញាណរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ដើរតួជាមេធាវីរបស់យើង ជាអ្នកសម្រុះសម្រួលដែលចាំជួយអង្វរ ទៅកាន់តុលាការដ៏ពេញដោយព្រះចេស្តា ហើយទូលសូមឲ្យទ្រង់មានព្រះហឫទ័យមេត្តាមកលើយើងរាល់គ្នាផងដែរ (គម្ពីរហេប្រឺ ៧:២៥ គម្ពីរ ១យ៉ូហាន ២:១)។

រួមជាមួយនឹងព្រះអំណោយទាននៃការសង្គ្រោះ មានទំនួលខុសត្រូវផ្សេងទៀតសម្រាប់អ្នកជឿថ្មី។ ពួកគេត្រូវ "ដើរនៅក្នុងពន្លឺ" (គម្ពីរ១យ៉ូហាន ១:៧ គម្ពីរយ៉ូហាន ១:៤-៩)។ ស្របពេលដែលគ្រិស្តបរិស័ទនឹងមិនអាចឈានទៅដល់ភាពល្អឥតខ្ចោះនៅក្នុងជីវិតនេះទេ ពួកគេអាចដើរនៅក្នុង*ពន្លឺ* ហើយស្តាប់បង្គាប់តាមពន្លឺនោះផងដែរ។ ពេលដែលពួកគេធ្វើយ៉ាងដូច្នេះ មានរឿងពីរយ៉ាងនឹងកើតមានឡើង ១) ពួកគេមានសម្ព័ន្ធភាពជាមួយនឹងអ្នកជឿដទៃទៀត និង ២) ពួកគេត្រូវបានជម្រះឲ្យជ្រះស្អាត ។ ការលាងជម្រះកើតមានឡើងនៅពេលដែលអ្នកអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញពីការធ្លាក់ចុះរបស់ពួកគេ កំហុសរបស់ពួកគេ ឬ អំពើបាបគ្រប់យ៉ាងរបស់ពួកគេ។ ពួកគេត្រូវបន្តសារភាពបាបទាំងនេះហើយបន្តគោលបំណងក្នុងការបដិសេធសេចក្តីល្បួង នៅពេលដែលពួកគេរស់នៅក្នុងក្រោមការគ្រប់គ្រងរបស់ព្រះវិញ្ញាណ (គម្ពីររ៉ូម ៨:៥)។ (សម្រាប់ការសិក្សាឲ្យបានកាន់តែច្បាស់លាស់ថែមទៀត អំពីគោលលទ្ធិនៃសេចក្តីសង្គ្រោះ សូមមើលនៅក្នុងវគ្គសិក្សារបស់សាកលវិទ្យាល័យគ្លូបល ដែលមានចំណងជើងថា *ជីវិតរស់នៅក្នុងព្រះគ្រិស្ត ៖ ការសិក្សាអំពើសេចក្តីសង្គ្រោះ)*

លំហាត់អនុវត្តន៍

១៣ ដោយផ្អែកទៅលើការសិក្សាទិដ្ឋភាពមួយនេះ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវរឿងបីយ៉ាងដែលព្រះយេស៊ូបានធ្វើសម្រាប់យើង តាមរយៈការសុគតនៅលើឈើឆ្កាងរបស់ទ្រង់។

ការស្រោចស្រង់ខាងឯរូបកាយ

ព្រះយេស៊ូមិនត្រឹមតែបានប្រទានការស្រោចស្រង់ខាងឯវិញ្ញាណសម្រាប់យើងប៉ុណ្ណោះទេ ប៉ុន្តែការសុគតរបស់ទ្រង់ នៅលើឆ្កាងក៏បានធ្វើឲ្យមានការស្រោចស្រង់ខាងឯ*រូបកាយ*របស់យើងផងដែរ។ ជំងឺដែលជាទិដ្ឋភាពមួយនៃបណ្តាសារ ក៏មិនអាចតោងជាប់មនុស្សជាតិបានទៀតដែរ នៅពេលដែលព្រះគ្រិស្តបានរងទុក្ខនៅលើឈើឆ្កាង។ ព្រះគម្ពីរបានបង្រៀនអំពី ការប្រោសឲ្យជា គឺជាទិដ្ឋភាពមួយនៃការស្រោច

ស្រង់ដែលទ្រង់បានសម្រេចបាន។ មានកំណាព្យដ៏ពិរោះរណ្តំខ្លះនៅក្នុងព្រះគម្ពីរ បានសរសេរសំដៅទៅលើការប្រោសជំងឺដែលព្រះទ្រង់បានប្រទាន៖

តាមពិតលោកបានរងទុក្ខវេទនាជំនួសយើង
លោកទទួលយកការឈឺចាប់របស់យើងមកដាក់លើខ្លួនលោក។

រីឯយើងវិញ យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក
ព្រះអង្គបានវាយ និងបន្ទាបបន្ថោកលោក។

ប៉ុន្តែ លោកត្រូវគេចាក់ទម្លុះព្រោះតែការបះបោររបស់យើង
លោកត្រូវគេជាន់ឈ្លី ព្រោះតែអំពើទុច្ចរិតរបស់យើង

លោកបានរងទារុណកម្មដើម្បីអោយយើងទទួលសេចក្តីសុខសាន្ត
ហើយដោយសារស្នាមរបួសរបស់លោកយើងក៏បានជាសះស្បើយ។
—គម្ពីរអេសាយ ៥៣:៤-៥

លំហាត់អនុវត្តន៍

---

១៤ ចូរបើកទៅមើលខគម្ពីរខាងក្រោម ហើយប្រាប់អំពីអ្វីដែលបទគម្ពីរនីមួយៗថ្លែងអំពីការប្រោសឲ្យជាដែលមកពីព្រះជាម្ចាស់។

ក) គម្ពីរម៉ាថាយ ៨:១៧

ខ) គម្ពីរ១ពេត្រុស ២:២៤

ព្រះយេស៊ូបានប្រោសមនុស្សមានជំងឺជាច្រើននាក់ ឲ្យបានជាសះស្បើយ នៅក្នុងគ្រប់ព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់នៅលើផែនដីនេះ។ ទ្រង់ក៏បានណែនាំអស់អ្នកដែលទ្រង់ចាត់បញ្ជូនទៅ ធ្វើព័ន្ធកិច្ច ក្នុងការចែកចាយដំណឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និង ធ្វើការប្រោសអ្នកជំងឺ (សូមមើលគម្ពីរម៉ាថាយ ១០:៧-៨ គម្ពីរម៉ាកុស ១៦:១៨ គម្ពីរលូកា ៩:១-២; ១០:៩)។

បន្ទាប់ពីព្រះយេស៊ូត្រូវបានលើកឡើង ទៅឯស្ថានបរមសុខ ការអស្ចារ្យនៃការប្រោសជំងឺ នៅតែបន្តធ្វើឡើងទៀត តាមរយៈអ្នកដែលដើរតាមទ្រង់។ កណ្ឌគម្ពីរកិច្ចការ មានពេញទៅដោយការអស្ចារ្យនៃការប្រោសជំងឺ។ លើសពីនេះទៅទៀត លោកយ៉ាកុបបង្រៀនថា ចាស់ព្រឹទ្ធាចារ្យនៅក្នុងក្រុមជំនុំគួរតែអធិស្ឋានសម្រាប់អ្នកឈឺ ហើយរំពឹងទុកថាព្រះជាម្ចាស់នឹងប្រោសពួកគេ (គម្ពីរយ៉ាកុប ៥:១៤) ។ ការនេះគឺស្របគ្នាជាមួយនឹង ព្រះបន្ទូលរបស់ព្រះយេស៊ូដែលថា ទ្រង់យាងមកដើម្បីឲ្យយើងអាចមានជីវិត "ពេញបរិបូណ៌" (គម្ពីរយ៉ូហាន១០:១០)។

ពិភពលោកនេះមិនទាន់រួចផុតពីជំងឺ និង ការរងទុក្ខទាំងអស់នោះទេ ប៉ុន្តែទីបន្ទាល់ដែលមាននៅក្នុងគ្រប់ប្រវត្តិសាស្ត្ររបស់ក្រុមជំនុំ គឺថាអស់អ្នកដែលទុកចិត្តលើព្រះយេស៊ូ អាចត្រូវបានប្រោសឲ្យជានៅក្នុងការឆ្លើយតបចំពោះសេចក្តីអធិស្ឋានដែលពេញដោយជំនឿ។ ដូច្នេះ យើងអាចទទួលបាននូវគុណប្រយោជន៍ខាងឯវិញ្ញាណ រូបកាយ និង ភាពអស់កល្បជានិច្ច ដោយព្រោះមានការប្រទានមកពីព្រះអម្ចាស់នៃយើង ដែលបានធ្វើនៅលើឈើឆ្កាងលើភ្នំកាល់វ៉ារី(គាល់កូថា,លលាដ៏ក្បាល)។ តាមរយៈលោកអដាំ អំពើបាបបានចូលមកក្នុងអម្បូររបស់មនុស្ស តែតាមរយៈព្រះយេស៊ូគ្រិស្ត យើងត្រូវបានរំដោះឲ្យមានសេរីភាពផុតពីបាប និង ឥទ្ធិពលរបស់អំពើបាប! សូមឲ្យយើងបើកដួងចិត្តរបស់យើង ដោយលើកតម្កើងទ្រង់ ដោយព្រោះព្រះអំណោយទាននៃការសង្គ្រោះដ៏អស្ចារ្យរបស់ទ្រង់!

លំហាត់អនុវត្តន៍

១៥ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយត្រឹមត្រូវដែលទាក់ទងនឹងការស្រោចស្រង់រូបកាយ និងវិញ្ញាណរបស់យើង។

ក) ទិដ្ឋភាពមួយដ៏សំខាន់ជាងគេបំផុតនៃការស្រោចស្រង់វិញ្ញាណ គឺថា ការនោះបាននាំយើងត្រឡប់ទៅរកទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ឡើងវិញ។

ខ) ដោយសារតែព្រះយេស៊ូបានសុគតនៅលើឈើឆ្កាង ក្នុងនាមជាអ្នកជំនួសបាបយើង ឥឡូវមនុស្សទាំងអស់គ្នា បានមានសេរីភាពផុតការផ្តន្ទាទោសនៃអំពើបាប។

គ) ការស្រោចស្រង់ខាងឯវិញ្ញាណទាមទារឲ្យមានការលន់តួ ងាកចេញពីបាប និង ការដើរនៅក្នុងពន្លឺ។

ឃ) ជំងឺគឺជាទិដ្ឋភាពមួយនៃបណ្តាសារ ដែលយើងរាល់គ្នាត្រូវតែទទួលស្គាល់ថាជាទិដ្ឋភាពមួយនៃជីវិត។

ង) ការប្រោសជំងឺពីព្រះជាម្ចាស់ គឺទាមទារឲ្យមានជំនឿ។

ច) ការដើរនៅក្នុងពន្លឺ នាំឲ្យមានការសម្អាតឲ្យផុតពីបាប និង មានការប្រកបទាក់ទងអ្នកជឿដទៃទៀត។

ឆ) មនុស្សជាច្រើនរាប់មិនអស់ តាំងពីជំនាន់សម័្ពន្ធមេត្រីថ្មីមកដល់បច្ចុប្បន្ននេះ ធ្លាប់បានឆ្លងកាត់ការប្រោសជំងឺមកពីព្រះជាម្ចាស់ ។

ជ) រឿងដ៏ចាំបាច់តែមួយគត់ ដើម្បីទទួលការប្រោសមកពីព្រះជាម្ចាស់ គឺការអធិស្ឋានរបស់ពួកចាស់ព្រឹទ្ធាចារ្យនៅក្នុងក្រុមជំនុំ។

ឈ) ផលវិបាកទាំងអស់ ដែលលោកអដាំបានទំលាក់មកលើអម្បូរមនុស្ស ត្រូវបានយកឈ្នះលើដោយការសុគតជួស របស់ព្រះយេស៊ូនៅលើឈើឆ្កាង។

ការប្រឡងឆ្លាស់ខ្លួន

ចម្លើយខ្លីៗ ៗ ចូរបំពេញប្រយោគខាងក្រោម។

១ ដើមកំណើតនៃអំពើបាបនៅក្នុងអម្បូររបស់មនុស្ស អាចត្រូវគេឃើញមានពីអំពើបាបរបស់ .....។

២ ដើមកំណើតនៃអំពើបាបនៅក្នុងសាកលលោកអាច ត្រូវបានគេឃើញមានតាំងពីការបះបោររបស់ .....។

៣ ភស្តុតាងពីរយ៉ាងនៃធាតុពិតរបស់អំពើបាប គឺ .....។

៤ មធ្យោបាយចាំបាច់ក្នុងការស្រោចស្រង់មនុស្សមានបាបគឺ.....។

៥ ផលវិបាកដែលគួរឲ្យក្រៀមក្រំ និង ធ្ងន់ធ្ងរជាងគេនៃអំពើបាបគឺ.....។

ត្រូវ/ខុស ៗ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ខាងមុខប្រយោគ ប្រសិនបើប្រយោគនោះត្រឹមត្រូវ ។ ចូរសរសេរ ខ ប្រសិនប្រយោគនោះមិនត្រឹមត្រូវ។

.....៦ ប្រសិនបើសាតាំងមិនបានប្រព្រឹត្តិបាបមុនដំបូងគេនោះទេ មនុស្សនឹងមិនអាចប្រព្រឹត្តិអំពើបាបបាននោះទេ។

.....៧ ក្រឹត្យវិន័យគឺចាំបាច់ណាស់ ព្រោះមនុស្សសុទ្ធតែមាននិស្ស័យបាប។

.....៨ ព្រះគម្ពីរបានផ្តល់នូវភស្តុតាងជាច្រើន អំពីការដែលមនុស្សមិនអាចផ្គាប់ព្រះទ័យព្រះជាម្ចាស់បានដោយខ្លួនឯង។

.....៩ យោងទៅតាមភស្តុតាងនៅក្នុងព្រះគម្ពីរ អំណួត និង ភាពអាត្មានិយម នាំឲ្យមានការធ្លាក់ចុះរបស់សាតាំង។

.....១០ យុទ្ធសាស្ត្ររបស់សាតាំនៅក្នុងពិភពលោកសព្វថ្ងៃនេះ គឺមានគម្រោងដែលខុសពីគម្រោងរបស់ព្រះជាម្ចាស់ទាំងស្រុង។

.....១១ ការបរិភោគផ្លែឈើដែលនាងអេវ៉ាបានធ្វើនោះ គឺជាអំពើបាបលុះត្រាតែផ្លែឈើនោះត្រូវបានព្រះជាម្ចាស់ហាមមិនឲ្យបរិភោគ។

.....១២ ដោយអំពើបាបបានចូលមកក្នុងពូជអម្បូររបស់មនុស្ស យើងក៏បានកើតមកជាមួយនឹងនិស្ស័យខាងវិញ្ញាណដែលបានស្លាប់បាត់ទៅហើយ។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៨ ចម្លើយរបស់អ្នកគួរតែបូករួមគំនិតទាំងនេះ៖ ព្រះជាម្ចាស់បានសម្រេចព្រះទ័យប្រទានឲ្យមនុស្សជាតិនូវសមត្ថភាព ក្នុងការជ្រើសរើសបម្រើព្រះជាម្ចាស់ដោយខ្លួនឯង។ ការនេះទាមទារឲ្យមានការសាកល្បងមួយ ដែលមានការធ្វើការជ្រើសរើសមួយ។ លោកអដាំ និង នាងអេវ៉ា ដែលជាឪពុកម្តាយដំបូងបង្អស់របស់មនុស្សរាល់គ្នា បានជ្រើសរើសដើរតាមបំណងចិត្តអាត្មានិយមរបស់ពួកគាត់ ដោយមិនជ្រើសការផ្ទេរចិត្តទៅរកព្រះជាម្ចាស់ឡើយ។ ដោយសារតែពួកគាត់បានប្រព្រឹត្តិអំពើបាបទាស់នឹងព្រះជាម្ចាស់ ដោយការមិនស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ទ្រង់ យើងក៏បានទទួលស្នងនិស្ស័យដែលពេញដោយបាបរបស់ពួកគាត់។ ការដាក់ទោសរបស់ព្រះជាម្ចាស់ គឺយុត្តិធម៌ណាស់ ព្រោះលោកអដាំ និង នាងអេវ៉ា ធ្វើការសម្រេចចិត្តដោយខ្លួនឯង ក្នុងការជ្រើសរើសរវាងព្រះជាម្ចាស់ និងអំពើអាក្រក់ ដោយដឹងស្រាប់ថា ពួកគាត់នឹងអាចទទួលផលវិបាកយ៉ាងជាក់ច្បាស់។

១ មិនស្តាប់បង្គាប់ព្រះជាម្ចាស់

៩ ក) ៣) ភាពអាត្មានិយម
ខ) ៥) ការប្រឡាក់
គ) ២) ខុសគោលដៅ
ឃ) ១) អំពើរំលង
ង) ៤) ការបះបោរ

២ មនុស្សជំនាន់ក្រោយប្រព្រឹត្តអំពើអាក្រក់ ដែលមិនគាប់ព្រះហឫទ័យព្រះអម្ចាស់ (ពួកគេប្រព្រឹត្តិបាបទាស់នឹងព្រះជាម្ចាស់)។

១០ ក) ៤) មនសិការ
ខ) ១) សតិបញ្ញា
គ) ៥) វិញ្ញាណ (បានស្លាប់ទៅហើយ)
ឃ) ២) វេទនារម្មណ៍ និង អារម្មណ៍
ង) ៣) ឆន្ទៈ

៣ ប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តិអំពើអាក្រក់ ដែលមិនគាប់នឹងព្រះទ័យព្រះជាម្ចាស់ ម្តងហើយម្តងទៀត។

១១ ក) យើងរងទុក្ខសព្វថ្ងៃនេះ មិនមែនគ្រាន់តែ ដោយសារអំពើបាបរបស់លោកអដាំ និងនិស្ស័យបាបដែលយើងបានស្នងនោះទេ ប៉ុន្តែក៏ជាផលវិបាកដែលបានមកពីអំពើបាបរបស់អ្នកដទៃផ្សេងទៀតផងដែរ។

៤ អំពើបាបគឺជាការមិនស្តាប់បង្គាប់ និង ការបរាជ័យក្នុងការប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់។ វាគឺជា អ្វីៗគ្រប់យ៉ាងដែលមនុស្សធ្វើខុស។

១២ ក) អស់អ្នកដែលត្រូវបណ្តាសារ នឹងត្រូវធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ចរួមជាមួយ មារសាតាំង និង ទេវតា(បរិវារ)របស់វា។

ខ) អស់អ្នកដែលត្រូវទទួលទោស នឹងត្រូវបានបោះចូលទៅក្នុងនរក ដែលជាកន្លែងមានដង្កូវមិនចេះងាប់ និង ភ្លើងមិនចេះរលត់។

គ) សម្រាប់អស់អ្នកដែលប្រព្រឹត្តិអំពើអាក្រក់ នឹងមាន ព្រះពិរោធ និងដាក់ទោសយ៉ាងធ្ងន់ ទុក្ខលំបាក ការតប់ប្រមល់ អន្ទះអន្ទែង។

ឃ) ការដាក់ទោសដ៏អស់កល្បជានិច្ច ក៏មានរួមបញ្ចូល ទីងងឹតសូន្យសុងដែរ។

ង) អស់អ្នកដែលបដិសេធព្រះជាម្ចាស់ នឹងត្រូវរងទុក្ខទោសនៅក្នុងភ្លើង និងក្នុងស្ពាន់ធ័រ ពួកគេនឹងត្រូវវេទនា ទាំងថ្ងៃទាំងយប់ ឥតស្រាកស្រាន្តឡើយ។

៥ ចម្លើយរបស់អ្នកអាចនឹងមានគំនិតទាំងនេះដែរ៖ ព្រះគម្ពីរបានផ្តល់នូវភស្តុតាងប្រវត្តិសាស្ត្រអំពីធាតុពិតនៃអំពើបាប ចាប់ផ្តើមពីអំពើបាបរបស់លោកអដាំ និង នាងអេវ៉ា លោកកាអ៊ីន ហើយបន្ទាប់មកទៀត មានអំពើបាបរបស់ជនជាតិអ៊ីស្រាអែលដែលកើតឡើងម្តងហើយម្តងទៀត។ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី គឺជាការកត់ត្រាអំពីការផ្តត់ផ្តង់របស់ព្រះជាម្ចាស់ សម្រាប់បញ្ហាអំពើបាប តាមរយៈព្រះយេស៊ូគ្រិស្ត ហើយក៏បានផ្តល់នូវឧទាហរណ៍ជាច្រើនអំពីអំពើបាប។ នៅគ្រប់ទីកន្លែងលើពិភពលោកនេះ សុទ្ធតែត្រូវការគ្រប់គ្រងដឹកនាំ ព្រោះមនុស្សដែលបានបណ្តោយឲ្យនូវតែម្នាក់ឯង មានភាពអាត្មានិយម និង ចង់តែបះបោរ។

១៣ ចម្លើយនៅក្នុងចំណោមចម្លើយខាងក្រោមនេះ ។ ទ្រង់បានរំសាយព្រះពិរោធរបស់ព្រះជាម្ចាស់ដែលមានចំពោះអំពើបាប ។ ទ្រង់បានបង់ថ្លៃជួសបំណុលបាបរបស់យើង ដោយបានធានាការអត់ទោស និង ប្រទានការប្រោសលោះដែលពេញបរិបូរណ៌ និង មិនឥតគិតថ្លៃ ។ ទ្រង់ប្រទាននិស្ស័យថ្មីមួយមកឲ្យយើង ហើយធ្វើឲ្យយើងក្លាយទៅជាបុត្រ និង ជាអ្នកស្នងសម្បត្តិរបស់ព្រះជាម្ចាស់។ ទ្រង់បានទូលអង្វរជំនួសយើងនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ហើយទ្រង់ប្រទានពន្លឺសម្រាប់ការធ្វើដំណើរប្រចាំថ្ងៃរបស់យើង។

៦ ចម្លើយគ) ឃ) និង ង) ជាចម្លើយត្រឹមត្រូវ។

១៤ ក) ទ្រង់បានទទួលភាពពិការ និង ជំងឺរបស់យើង។

ខ) ដោយសារតែស្នាមរបួសរបស់ទ្រង់ យើងបានជាសះស្បើយ។

៧ ក) លោកត្រូវបានកាត់ទោស ឲ្យស្លាប់។

ខ) សេចក្តីស្លាប់។

១៥ ចម្លើយក) គ) ង) ច) ឆ) និង ឈ) គឺជាចម្លើយត្រឹមត្រូវ។

ការប្រឡងក្នុងជំពូកទីពីរ

ឥឡូវនេះ ដោយអ្នកបានបញ្ចប់ជំពូកទីពីរ អ្នកអាចឆ្លើយនឹងសំណួរវាយតម្លៃជំពូកទីពីរបាន។ ចូរពិចារណាមេរៀនពីខាងលើ មុនពេលដែលអ្នកចាប់ផ្តើម។ ធ្វើតាមការណែនាំដ៏ប្រុងប្រយ័ត្ន ដើម្បីធ្វើការប្រឡងបន្ទាប់មក បន្តទៅជំពូកទីបី

ជំពូកទី ៥
ប្រព័ន្ធរបស់ព្រះជាម្ចាស់

<u>មេរៀន</u>

៨. បទគម្ពីរ៖ ការបើកបង្ហាញជាសំណេរ របស់ព្រះជាម្ចាស់

៩. ក្រុមជំនុំ៖ សហគមន៍នៃប្រជារាស្ត្រ របស់ព្រះជាម្ចាស់

១០. អនាគត៖ ការបើកបង្ហាញ រង្វាន់ និង ការសម្រាក

មេរៀនទី ៨ បទគម្ពីរ៖ ការបើកបង្ហាញជាសំណេរ របស់ព្រះជាម្ចាស់

នៅក្នុងមេរៀនមុន យើងបានរៀនអំពីការពិតជាច្រើនអំពីនិស្ស័យរបស់ព្រះជាម្ចាស់ និស្ស័យមនុស្ស និងដើមកំណើត ព្រមទាំងនិស្ស័យរបស់អំពើបាប យើងបានរៀនអំពីពួកទេវតា និង សកម្មភាពរបស់ពួកគេ និង ផែនការរបស់ព្រះជាម្ចាស់សម្រាប់ការប្រោសលោះ មនុស្សជាតិដែលបានធ្លាក់ចុះ។ អ្នកប្រាកដជាបានសំគាល់ឃើញហើយថា ប្រភពសំខាន់ៗសម្រាប់សេចក្តីបង្រៀនទាំងអស់នេះ គឺជាព្រះគម្ពីរ ដែលមានបទគម្ពីរដ៏វិសុទ្ធ។ ព្រះគម្ពីរ គឺជាការបើកសំដែងជាលក្ខណៈសំណេរ របស់ព្រះជាម្ចាស់ អំពីអង្គទ្រង់ និង ស្នាព្រះហស្តរបស់ទ្រង់។

នេះគឺជារឿងសមហេតុផលមួយ ក្នុងការជឿថា ព្រះជាម្ចាស់ដ៏ជាក្សត្រ ប្រកបដោយក្តីស្រឡាញ់ យុត្តិធម៌ និង មានភាពជាបុគ្គល ទ្រង់ពិតជាសព្វព្រះហឫទ័យបើកបង្ហាញអង្គទ្រង់ ទៅកាន់ភាវៈដែលចេះគិតពិចារណារបស់ទ្រង់ តាមរយៈការកត់ត្រាជាសំណេរនោះ។ ជាការអស្ចារ្យណាស់ ដែលយើងបានដឹងថា ទ្រង់បានជ្រើសរើសប្រើប្រាស់មនុស្សដែលចុះចូលជាមួយ បំណងព្រះហឫទ័យរបស់ទ្រង់ ធ្វើជាអ្នកនិពន្ធនៃបទគម្ពីរទាំងនោះ។ ជាការជម្រុញចិត្តមួយ ដែលយើងបានសិក្សាអំពីការពិតអំពីរបៀបដែលកំណត់ត្រាដែលសរសេរឡើងដោយមនុស្សជាង ៤០ នាក់ ក្នុងអំឡុងពេល ១៦០០ ឆ្នាំ គឺត្រូវបានរក្សាទុកដោយព្រះជាម្ចាស់ និង មានផ្ទុកនៅក្នុងព្រះគម្ពីររបស់យើងនេះ។

នៅពេលដែលយើងចាប់ផ្តើមសិក្សាជំពូកទី៣ យើងត្រូវពិចារណាអំពីការបើកសំដែងអំពីគោលបំណងនៃការប្រោសលោះរបស់ព្រះជាម្ចាស់ ដូចដែលបានកត់ត្រានៅក្នុងបទគម្ពីរ។ ទីពីរ យើងនឹងរំឭកអំពីភស្តុតាង ដែលបានផ្តល់ឲ្យយើងនូវការធានាអះអាងថា ព្រះគម្ពីរគឺពិតជាព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់មែន។ បន្ទាប់មកទៀត យើងនឹងសិក្សាអំពីក្រុមជំនុំ គម្រោងដែលព្រះជាម្ចាស់ប្រើប្រាស់ដើម្បីត្រាស់ហៅមនុស្សដែលមិនទាន់បានសង្គ្រោះ ឲ្យចូលមកឯទ្រង់ ដើម្បីបីបាច់ពួកគេនៅក្នុងជំនឿ និង ធ្វើឲ្យពួកគេបានក្លាយទៅជាសក្ខីភាពដ៏មានប្រសិទ្ធិភាព។ នៅក្នុងមេរៀនចុងក្រោយនៃមុខវិជ្ជានេះ យើងនឹងសិក្សាអំពីគោលដៅនៃការប្រោសលោះ ស្របពេលដែលយើងពិចារណាអំពីអនាគត។

គម្រោងមេរៀន

ក. តម្រូវការការបើកសម្តែងជាសំណេរ
ខ. ការបណ្តាលចិត្តឲ្យតែងបទគម្ពីរ
គ. ភាពផ្តាច់មុខនៃបទគម្ពីរ
ឃ. ការបកស្រាយបទគម្ពីរ
ង. អំណាចរបស់បទគម្ពីរ

វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. បកស្រាយពីមូលហេតុ ដែលព្រះជាម្ចាស់ចាំបាច់ត្រូវ ប្រទានការបើកសម្តែងអំពីអង្គទ្រង់ ជាសំណេរ។
២. កំណត់អត្ថន័យ និង រៀបរាប់អំពីភស្តុតាងនៃពាក្យថាការបណ្តាលចិត្តឲ្យតែងបទគម្ពីរឡើង។
៣. ប្រាប់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់ភាពផ្តាច់មុខនៃបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី ហើយពិភាក្សាអំពីបញ្ជីកណ្ឌគម្ពីរទាំងនោះ។
៤. ប្រាប់អំពីវិធីសាស្ត្រដែលត្រូវវិភាគវែកញែក និង បកប្រែបទគម្ពីរ។
៥. ប្រាប់ថាតើព្រះបន្ទូលរបស់ព្រះជាម្ចាស់គួរតែមានអំណាចនៅត្រង់កន្លែងណាក្នុងជីវិតរបស់យើង

សកម្មភាពក្នុងការសិក្សា

១. សិក្សាមេរៀនដោយផ្អែកទៅតាម ក្បួនដែលបានផ្តល់ជូននៅក្នុងមេរៀនទី១រួចមកហើយ។ ត្រូវតែប្រាកដថា អ្នកបានអានបទគម្ពីរយោងទាំងអស់ ដែលអ្នកបានឃើញ នៅក្នុងមេរៀន ហើយឆ្លើយរាល់សំណួរសិក្សាទាំងអស់យ៉ាងយកចិត្តទុកដាក់។
២. ស្វែងរកពាក្យថ្មីៗសម្រាប់អ្នក នៅក្នុងអក្ខរានុក្រមនូវពាក្យសំខាន់ណាមួយ ហើយសិក្សាអត្ថន័យរបស់ពាក្យនោះ។
៣. ធ្វើការប្រឡងផ្ទាល់ខ្លួន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក។

ពាក្យសំខាន់

សំណេរអវសាននៃលោកីយ៍	គោលលទ្ធិ	ការបណ្តាលចិត្ត
ដោយសិទ្ធិអំណាច	ការលើកឡើង	ទំនៀមទម្លាប់និយាយតគ្នា
សំណេរដើម	លិខិត	ដែលអាចទុកចិត្តបាន
បញ្ជីកណ្ឌគម្ពីរ	ភាពផ្តាច់មុខ	ការបើកសម្តែង
ការលាតត្រដាង	បំភ្លឺ	ធ្វើឲ្យមានសុពលភាព
ខុសឆ្គង	វិសមិតភាព	

ក. តម្រូវការការបើកសម្តែងជាសំណេរ

វត្ថុបំណងទី១. *បកស្រាយពីមូលហេតុ ដែលព្រះជាម្ចាស់ចាំបាច់ត្រូវ ប្រទានការបើកសំម្តែងអំពីអង្គទ្រង់ ជាសំណេរ។*

មនុស្សយើងភាគច្រើន មិនសូវជាចងចាំបានល្អនោះទេ។ ប្រសិនបើព្រះជាម្ចាស់ មកបង្ហាញអង្គទ្រង់នៅចំពោះមុខរបស់ខ្ញុំ ក្នុងពេលជាក់លាក់ណាមួយនៅក្នុងជីវិតរបស់ខ្ញុំ មិនយូរប៉ុន្មានខ្ញុំអាចនឹងមិនចាំច្បាស់ ចំពោះរឿងមួយចំនួននៅក្នុងការបើកសម្តែងរបស់ទ្រង់ជាក់ជាមិនខាន។ មិនយូរប៉ុន្មាន ការចងចាំរបស់ខ្ញុំ ទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនោះ នឹងត្រូវសាបរលាបទៅ។ ខ្ញុំប្រហែលជាអាចរំឭកឡើងវិញយ៉ាងស្រពិចស្រពិលនូវព័ត៌មានខ្លះអំពីការបើកសម្តែងរបស់ទ្រង់ ប៉ុន្តែខ្ញុំច្បាស់ណាស់ថា ព័ត៌មាននោះនឹងមិនច្បាស់លាស់ ហើយមិនអាចយកជាការបាននោះទេ។ ប្រសិនបើខ្ញុំរៀបរាប់សាឡើងវិញ នូវព័ត៌មានទាំងអស់ប្រាប់កូនភ្លាមៗ បន្ទាប់ពីការបើកសម្តែងនោះក៏ដោយ គាត់ច្បាស់ជាមិនអាចចងចាំរឿងគ្រប់យ៉ាងដែលខ្ញុំបាននិយាយប្រាប់នោះទេ។ ប្រសិនបើកូនរបស់ខ្ញុំ នឹងប្រាប់ព័ត៌មាននេះបន្តទៅកាន់កូនៗរបស់គេ ប៉ុន្មានឆ្នាំក្រោយមកទៀត ពេលវេលាដែលកន្លងទៅនោះ នឹងធ្វើឲ្យការចងចាំរបស់គេស្រអាប់ទៅ ហើយព្រមទាំងធ្វើឲ្យខុសសាច់រឿងនោះផងដែរ។ អ្នកឃើញហើយថា វិធីសាស្ត្រនៃការចែកចាយបន្តការបើកសម្តែងរបស់ព្រះជាម្ចាស់នេះ ពិតជាមិនអាចយកជាការបាននោះទេ។

ទំនៀមទម្លាប់និយាយតគ្នា របស់មនុស្ស រឿងទាំងប៉ុន្មានដែលប្រាប់តៗគ្នា ពីជំនាន់មួយទៅជំនាន់មួយ អាចនឹងផ្លាស់ប្តូរយ៉ាងខ្លាំង នៅពេលដែលពួកគេនិយាយប្រាប់គ្នាជាបន្តបន្ទាប់។ ដូច្នេះ ការនេះមិនមែនជាវិធីសាស្ត្រដែលអាចយកជាការបាន ដើម្បីរៀនអំពីព្រះជាម្ចាស់ និង បំណងព្រះហឫទ័យរបស់ទ្រង់នោះទេ។

ព្រះជាម្ចាស់ប្រកបដោយប្រាជ្ញាញាណ និង អស្ចារ្យរបស់យើង បង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង តាមរយៈការទំនុកបម្រុងរបស់ទ្រង់សម្រាប់យើង។ ទ្រង់បានប្រទានការផ្គត់ផ្គង់ទៅលើខាងឯរូបកាយរបស់យើង តាមរបៀបជាច្រើន ដូចជាតាមរយៈការបង្កើតដ៏អស្ចារ្យរបស់ទ្រង់ ឲ្យមានវដ្តទឹកដែលបំពេញបន្ថែម និង បន្សុទ្ធប្រភពទឹកនៅលើផែនដី។ ចំណែកឯវិធីរបស់ទ្រង់ក្នុងការបំពេញបន្ថែមអុកស៊ីសែននៅក្នុងបរិយាកាសវិញនោះ ក៏អស្ចារ្យខ្លាំងណាស់ដែរ។ នៅពេលដែលយើងដកដង្ហើម យើងបញ្ចេញឧស្ម័នកាបូនឌីអុកស៊ីត ស្របពេលជាមួយគ្នានោះ រុក្ខជាតិបញ្ចេញអុកស៊ីសែនទៅក្នុងខ្យល់វិញ។ យើងស្របយកឧស្ម័នអុកស៊ីសែន ដែលបានបញ្ចេញដោយរុក្ខជាតិ ហើយរុក្ខជាតិទាំងនេះស្របយកឧស្ម័នកាបូនឌីអុកស៊ីត ដែលវាយកទៅប្រើប្រាស់ដើម្បីផលិតអាហាររបស់វា។

ប្រសិនបើព្រះជាម្ចាស់បានផ្គត់ផ្គង់សម្រាប់ទិដ្ឋភាពរូបកាយរបស់យើងប្រកបដោយព្រះហឫទ័យទុកដាក់យ៉ាងនេះ ទ្រង់ក៏ប្រាកដជានឹងមិន រំពឹងឲ្យយើងដោះស្រាយបញ្ហាខាងឯវិញ្ញាណដោយគ្មានជំនួយមកពីទ្រង់នោះដែរ។ បើគ្មានការបើកសម្តែងពីព្រះជាម្ចាស់នោះទេ យើងនឹងមិនអាចសូម្បីតែដឹងអំពីស្ថានភាពដ៏គួរឲ្យអស់សង្ឃឹមរបស់យើង និង សេចក្តីត្រូវការជំនួយរបស់យើងនោះទេ។ ដើម្បីយល់ពីមូលហេតុដែលការបើកសម្តែងពីព្រះជាម្ចាស់មានភាពចាំបាច់ នោះយើងត្រូវដឹងថាពាក្យ*ការបើកសម្តែង* មានន័យយ៉ាងដូចម្តេចទាក់ទងនឹងព្រះជាម្ចាស់។ពាក្យនេះមានន័យថា ព្រះជាម្ចាស់*បង្ហាញ* ឬ *លាតត្រដាង* ទៅ

កាន់មនុស្សលោកនូវអ្វីដែលពួកគេមិនអាចដឹងអំពីទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់។ សូមចងចាំនិយមន័យពាក្យនេះ ក៏ដូចជាពាក្យសំខាន់ដទៃទៀតដែលយើងនឹងលើកមកបង្ហាញនៅក្នុងមេរៀននេះ។

លំហាត់អនុវត្តន៍

១ ចូរសរសេរនិយមន័យពាក្យ *ការបើកសម្តែង* ដែលទាក់ទងទៅនឹងព្រះជាម្ចាស់។ ចូរប្រើសៀវភៅកត់ត្រារបស់អ្នកសម្រាប់សរសេរចម្លើយ។

ដោយព្រះជាម្ចាស់ទ្រង់អស្ចារ្យ និង ប្រកបដោយសេចក្តីស្រឡាញ់ ហើយដោយសារតែយើងត្រូវការជំនួយយ៉ាងខ្លាំង ដើម្បីដោះស្រាយបញ្ហាអំពើបាបរបស់យើង យើងអាចរំពឹងចង់ឲ្យព្រះជាម្ចាស់ មានព្រះបន្ទូលយ៉ាងច្បាស់មកកាន់យើង ថាទ្រង់គឺជានរណា និង អ្វីដែលទ្រង់សព្វព្រះហឫទ័យឲ្យយើងធ្វើ។ លើសពីនេះទៅទៀត វាគឺជារឿងដែលសមហេតុផលបំផុត ដែលយើងត្រូវធានាឲ្យបានថា ការបើកសម្តែងនេះ ទទួលបានការការពារ ដើម្បីឲ្យមនុស្សអាចទទួលបាននូវចំណេះដឹង ដោយគ្មានភាពខុសឆ្គងត្រូវចំណុចណាមួយសោះឡើយ។ ដូច្នេះ យើងអាចដឹងនៅក្នុងចិត្តយើងថា ព្រះជាម្ចាស់បានប្រទានការបើកសម្តែងរបស់ទ្រង់ ដោយរក្សាទុកក្នុងទម្រុងជាសំណេរនោះ ព្រោះទ្រង់មានហេតុផលដ៏ល្អមួយ។

លំហាត់អនុវត្តន៍

២ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខចម្លើយត្រឹមត្រូវ។

ក) វាពិតជាចាំបាច់ណាស់ ដែលព្រះជាម្ចាស់ត្រូវប្រទានការបើកសម្តែងជាសំណេរអំពីអង្គទ្រង់នេះមក ដើម្បីឲ្យមនុស្សអាចដឹងពីអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ឃើញក្នុងគេ។

ខ) ទំនៀមទម្លាប់និយាយតគ្នា គឺជាវិធីមួយដែលគួរឲ្យទុកចិត្តបំផុតក្នុងការ ចែកចាយការបើកសម្តែងរបស់ព្រះជាម្ចាស់ពីជំនាន់មួយទៅជំនាន់មួយ។

គ) ទំនៀមទម្លាប់និយាយតគ្នា គឺត្រូវបានគេជ្រើសរើស ជំនួសឲ្យការកត់ត្រាជាសំណេរ ព្រោះការនេះអាចបន្តវិវត្តន៍ទៅមុខ និង ផ្លាស់ប្តូរឲ្យសមទៅនឹងតម្រូវការរបស់យើង។

ឃ) ការកត់ត្រាជាសំណេរ ផ្តល់ឲ្យយើងនូវខ្នាតគំរូជាក់លាក់មួយ ដែលរក្សាទុកបានយ៉ាងសុក្រឹតនូវអ្វីដែលបានកើតឡើង ដើម្បីឲ្យកុំយើងវង្វេង ឬ ភ្លេចនូវអ្វីដែលបានកើតឡើង។

ខ. ការបណ្តាលចិត្តឲ្យតែងបទគម្ពីរ

អត្ថន័យនៃ ពាក្យការបណ្តាលចិត្ត

វត្ថុបំណងទី២. *កំណត់អត្ថន័យ និង រៀបរាប់អំពីភស្តុតាងនៃពាក្យថាការបណ្តាលចិត្តឲ្យតែង បទគម្ពីរឡើង។*

យើងជឿថាបទគម្ពីរគឺជា ការបើកសម្តែងដែលមិនចេះខុស(ដែលគ្មានកំហុស) ត្រូវបានព្រះជាម្ចាស់បើកសម្តែងអំពីអង្គទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់ នៅក្នុងជីវិតរបស់មនុស្ស។ បទគម្ពីរទាំងនោះត្រូវបានសរសេរឡើងដោយមនុស្ស ក្រោមការ*បណ្តាលចិត្ត*មកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ បទគម្ពីរទាំងនោះគឺជាការសរសេរទំនាក់ទំនងរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ ដែលអាចរកឃើញបានតែនៅពេលដែលព្រះជាម្ចាស់បើកសម្តែង សេចក្តីទាំងនោះមកកាន់មនុស្សជាតិតែប៉ុណ្ណោះ។

ដោយពាក្យថា *បទគម្ពីរ* យើងចង់និយាយសំដៅទៅលើសំណេរ ដែលយើងបានស្គាល់ថា គម្ពីរសម្ពន្ធមេត្រីចាស់ និង គម្ពីរសម្ពន្ធមេត្រីថ្មី ឬ កណ្ឌគម្ពីរទាំង ៦៦ របស់ព្រះគម្ពីរនោះឯង។ (អ្នកខ្លះរាប់បញ្ចូលទាំង កណ្ឌគម្ពីរខុសឆ្គង ទៅក្នុងបញ្ជីកណ្ឌគម្ពីរ ដូច្នេះហើយគេទទួលស្គាល់សំណេរដ៏ពិសិដ្ឋ មួយទៀតដែលមានកណ្ឌច្រើនជាងនេះ)។

ដោយពាក្យថា *ការបណ្តាលចិត្ត* យើងចង់បានន័យថា កិច្ចការមួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលទ្រង់បានដឹកនាំ ឬ គ្រប់គ្រងលើអ្នកនិពន្ធនៃបទគម្ពីរ ក្នុងការជ្រើសរើសសាច់រឿងដែលត្រូវសរសេរបញ្ចូល និង ពាក្យដែលពួកគេបានសរសេរ។ វាគឺជាការប្រទានសិទ្ធិអំណាចដ៏ពិសេសមួយ សម្រាប់កិច្ចការដ៏ពិសេស។ ព្រះជាម្ចាស់បានដាក់ទៅក្នុងគំនិត និង ដួងចិត្តរបស់អ្នកសរសេរបទគម្ពីរ នូវអ្វីដែលទ្រង់សព្វព្រះទ័យឲ្យគេបង្ហាញ។ ពួកគេបានសរសេរបទគម្ពីរ ដោយស្ថិតនៅក្រោមការគ្រប់គ្រង និង ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានរក្សាពួកអ្នកនិពន្ធ មិនឲ្យពួកគេមានកំហុសឆ្គង និង ការលុបពាក្យគ្រប់បែបយ៉ាង នៅក្នុងការកត់ត្រាអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យពួកគេសរសេរនោះឡើយ។ ប៉ុន្តែ រឿងមួយដែលគួរឲ្យកត់សំគាល់ដែរនោះ គឺថា ព្រះជាម្ចាស់បានប្រើប្រាស់ បុគ្គលិកលក្ខណៈរបស់អ្នកនិពន្ធដែលជាមនុស្សនោះ នៅក្នុងការកត់ត្រា ការបើកសម្តែងរបស់ទ្រង់ដែរ។ របៀបសរសេរ ឬ ពាក្យនៅក្នុងកណ្ឌនីមួយៗ ដែលផ្ទុកនៅក្នុងបទគម្ពីរ គឺមាន<u>ឯកលក្ខណៈ</u> ទៅតាមអ្នកនិពន្ធ និង ទៅតាមលក្ខណសម្បត្តិជាមនុស្សរបស់គាត់។

អ្នកនិពន្ធដែលជាមនុស្សទាំងនេះ អាចនឹងមិនបានដឹងថា អ្វីដែលពួកគេបានសរសេរឡើងនោះ នឹងបានក្លាយទៅជាទិដ្ឋភាពមួយនៃកំណត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់។ ក៏ដូចគ្នាផងដែរ នៅពេលដែលមានការបណ្តាលចិត្ត ពួកគេបានសរសេរដោយការស្តាប់បង្គាប់ ហើយពួកគេមិនដែលសង្ស័យចំពោះ ពាក្យអ្វីដែលពួកគេប្រើនោះឡើយ។ ឧទាហរណ៍ ព្រះជាម្ចាស់សម្តែងមកកាន់លោកលូកា អំពីភាពចាំបាច់នៃការស្រាវជ្រាវ និង សើបអង្កេតរឿងរ៉ាវរបស់សាក្សី អំពីព្រះជន្មរបស់ព្រះយេស៊ូ ដើម្បីឲ្យលោកអាចនឹងសរសេរសាច់រឿងឡើងទៅតាមលំដាប់លំដោយ (គម្ពីរលូកា ១:១-៤) ។ លោកប៉ូលតែងតែបានសរសេរកណ្ឌគម្ពីរដែលឆ្លើយតបទៅនឹងសំណួររបស់ក្រុមជំនុំ ដើម្បីបង្រៀនដែលជាតម្រូវការចាំបាច់សម្រាប់ក្រុមជំនុំ និង ដើម្បីធ្វើការណែនាំទៅកាន់បុគ្គលណាម្នាក់ (គម្ពីរ១កូរិនថូស ១:១០-១៣; ៧:១ គម្ពីរកាឡា

ទី ១:៦-៧ គម្ពីរ១ធីម៉ូថេ ១:៣ គម្ពីរភីលីម៉ូន ១០) ។ ប៉ុន្តែអ្វីគ្រប់យ៉ាងដែលគាត់បានសរសេរឡើង គឺតាមរយៈការបណ្តាលចិត្តពីព្រះវិញ្ញាណដ៏វិសុទ្ធ។

ធាតុផ្សំពីរយ៉ាងនៃបទគម្ពីរនៅកណ្តាលគម្ពីរសម្ព័ន្ធមេត្រីថ្មី ផ្តល់ឲ្យយើងនូវការយល់ដឹងដ៏មានតម្លៃអំពីប្រភេទនៃការបណ្តាលចិត្តដែលអ្នកនិពន្ធទទួលបាន។ លោកប៉ុលមានប្រសាសន៍ថា៖ "គ្រប់អត្ថបទគម្ពីរសុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង" ។ នោះមានន័យថា អត្ថបទត្រូវបានបណ្តាលចិត្តឲ្យសរសេរដោយព្រះជាម្ចាស់។ លោកពេត្រុសក៏បានមានប្រសាសន៍ដូចខាងក្រោមនេះ៖

> គ្មាននរណាម្នាក់អាចបកស្រាយពាក្យរបស់ព្យាការី ដែលមានចែងទុកមកក្នុងគម្ពីរ តាមគំនិតរបស់ខ្លួនបានឡើយ ដ្បិតព្រះបន្ទូលដែលព្យាការីបានថ្លែងទុកមកនោះ មិនមែនចេញពីបំណងចិត្តរបស់មនុស្សទេ គឺព្រះវិញ្ញាណដ៏វិសុទ្ធវិញឯណោះ ដែលជំរុញចិត្តលោកទាំងនោះអោយថ្លែងព្រះបន្ទូលក្នុងព្រះនាមព្រះជាម្ចាស់។ (គម្ពីរ២ពេត្រុស ១:២០-២១)។

សម្រាប់អ្នកនិពន្ធផ្ទាល់ ក៏តែងតែនិយាយអំពីបទពិសោធន៍ជាមួយការបណ្តាលចិត្តរបស់ខ្លួនគាត់ ឬបទពិសោធន៍របស់អ្នកសរសេរបទគម្ពីរដទៃផ្សេងទៀតដែរ។ ពួកគាត់និយាយអំពីការនេះដោយប្រើពាក្យថា ៖ *ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកគេ។*

លំហាត់អនុវត្តន៍

---

៣ ចូរបើកព្រះគម្ពីរកខគម្ពីរនៅខាងក្រោមនេះ ហើយប្រាប់ពីអ្វីដែលបទគម្ពីរនីមួយៗបានថ្លែងដែលបានបង្ហាញថាព្រះជាម្ចាស់បានមានព្រះបន្ទូលតាមរយៈអ្នកនិពន្ធដែលជាមនុស្ស។

ក) គម្ពីរនិក្ខមនំ ១៧:១៤

ខ) គម្ពីរនិក្ខមនំ ២៤:៤

គ) គម្ពីរអេសាយ ៤៣:១

ឃ) គម្ពីរយេរេមា ១១:១

ង) គម្ពីរអេម៉ុស ១:៣, ៦, ៩

ច) គម្ពីរ១កូរិនថូស១៤:៣៧

ឆ) គម្ពីរ២ពេត្រុស ៣:១៥-១៦

ដូច្នេះ យើងឃើញថាការបណ្តាលចិត្តរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ មកលើអ្នកនិពន្ធជាមនុស្ស នៅក្នុងការសរសេរបទគម្ពីរនេះ គឺពិតជា*ការផ្តល់សិទ្ធិអំណាចដ៏ពិសេសមួយ សម្រាប់កិច្ចការដ៏ជាក់លាក់។*

លំហាត់អនុវត្តន៍

៤ ចូរជ្រើសរើសសេចក្តីបង្គ្រាប់ដែលត្រឹមត្រូវ សម្រាប់ប្រយោគនេះ ៖ *ការបណ្តាលចិត្តឲ្យតែងបទគម្ពីរ* សំដៅទៅលើ

ក) កិច្ចការដែលប្រកបដោយភាពច្នៃប្រឌិតគ្រប់បែបយ៉ាង ដែលផ្តែកទៅលើផ្នែរឿងរបស់ព្រះគម្ពីរ។

ខ) ការផ្តល់សិទ្ធិអំណាច ជាក់លាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់កិច្ចការដ៏ជាក់លាក់មួយ

គ) គ្រប់ទាំងគំនិត និង ទង្វើ ដែលបានកត់ត្រានៅក្នុងបទគម្ពីរ ថាត្រូវបានបណ្តាលចិត្តពីព្រះជាម្ចាស់។

ឃ) ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅលើមនុស្សដែលត្រូវបានជ្រើសតាំងឲ្យកត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់ ទាក់ទងនឹងអង្គទ្រង់ផ្ទាល់ ព្រមទាំងផែនការរបស់ទ្រង់ផងដែរ។

ង) រចនាបទ និង ពាក្យពេចន៍របស់អ្នកនិពន្ធបទគម្ពីរដែលជាមនុស្សលោក។

ច) ខ្លឹមសារ ទាំងអស់នៃបទគម្ពីរ រួមទាំងធាតុផ្សំដែលត្រូវបានជ្រើសរើសយកមកដាក់បញ្ចូល និង ពាក្យពេចន៍ដែលត្រូវបានជ្រើសរើស។

ឥស្តុតាងនៃការបណ្តាលចិត្ត

ចូរយើងបែរទៅមើល ការសិក្សាមួយអំពីភស្តុតាងនៃការបណ្តាលចិត្ត។ យើងនឹងពិចារណាអំពីការទទួលរបស់ព្រះយេស៊ូចំពោះព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ ការបំពេញតាមបទទំនាយរបស់ព្រះគម្ពីរ និង ភាពរួបរួមគ្នានៃសាច់រឿងនៅក្នុងព្រះគម្ពីរ។

១. *ព្រះយេស៊ូបានសម្តែងក្តីគោរព និង ការទទួលស្គាល់ចំពោះព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់។*

ព្រះយេស៊ូបានបង្ហាញព្រះទ័យរបស់ទ្រង់ ទៅលើគម្ពីរសម្ព័ន្ធមេត្រីចាស់ តាមរបៀបបីយ៉ាង។ ទីមួយ ទ្រង់បានអះអាងថា កណ្ឌគម្ពីរទាំងនោះនឹងនៅចិតថេរ ជារៀងរហូត (សូមមើលគម្ពីរម៉ាថាយ ៥:១៧-១៨ គម្ពីរលូកា ១០:២៦; ២១:២២ គម្ពីរយ៉ូហាន ១០:៣៥)។ ទីពីរ ទ្រង់បានមានព្រះបន្ទូលថា បទគម្ពីរទាំងនោះ ថ្លែងអំពីទ្រង់ (គម្ពីរម៉ាថាយ ២៦:២៤ គម្ពីរម៉ាកុស ៩:១២ គម្ពីរលូកា ១៨:៣១; ២៤:៤៤ គម្ពីរយ៉ូហាន ៥:៣៩)។ ទីបី ព្រះយេស៊ូបានបង្ហាញថា ទ្រង់បានទទួលស្គាល់សិទ្ធិអំណាចនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ ដោយធ្វើការដកស្រង់បទគម្ពីរទាំងនោះមកមានព្រះបន្ទូល (គម្ពីរម៉ាថាយ ៤:៤, ៧,១០;២១:១៣; ២៦:៣១)។

តើអ្នកបានកត់សំគាល់ទេថា ព្រះយេស៊ូមិនដែលសម្តែងគួសបញ្ជាក់ថាឃ្លាណាមួយ ឬ សេចក្តីបង្រៀនណាមួយនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ មានកំហុស ឬ មិនស័ក្តិសមនោះទេ? ប្រាកដណាស់ ទ្រង់ក៏អាចនឹង មានព្រះបន្ទូលអំពីទិដ្ឋភាពណាមួយ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ថាគ្មានការបណ្តាលពីព្រះជាម្ចាស់នោះទេ។ ប៉ុន្តែផ្ទុយទៅវិញ ទ្រង់បានសម្តែងការទទួលស្គាល់យ៉ាងពេញលេញ ចំពោះសំណេរដ៏ពិសិដ្ឋនេះ ដែលសាសន៍យូដាផ្ទាល់ក៏បានទទួលស្គាល់ថាបានទទួលការបណ្តាលចិត្តពីព្រះជាម្ចាស់ដែរ។

ការចុះចូល និង ការទទួលស្គាល់របស់ព្រះយេស៊ូ ចំពោះគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ការប្រើប្រាស់ព្រះគម្ពីរនោះដោយព្រះអង្គផ្ទាល់ គឺសុទ្ធតែជាភស្តុតាងយ៉ាងរឹងមាំ អំពីការបណ្តាលចិត្តពីអធិធម្មជាតិនៃព្រះគម្ពីរនោះ។

២. *បទទំនាយនៃព្រះគម្ពីរត្រូវបានបំពេញ*

ព្រះគម្ពីរមិនមែនគ្រាន់តែជាសៀវភៅមួយក្បាល ដែលត្រូវបានសរសេរឡើងដោយអ្នកនិពន្ធដែលមានអំណោនទានប៉ុណ្ណោះទេ។ ការបំពេញទៅតាមការទាយទុកជាមុនរបស់ព្រះគម្ពីរជាមួយនឹងភាពសុក្រឹតពេញលក្ខណៈ បានចង្អុលទៅកាន់ការរួមចំណែករបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រឹត្តិការណ៍ទាំងនេះមិនអាចត្រូវបានទាយទុកមុនដោយការអះអាងរបស់មនុស្សដែលគ្រាន់តែមានសតិបញ្ញាប៉ុណ្ណោះទេ។ ប៉ុន្តែ មានព្រឹត្តិការណ៍ជាច្រើនក៏ត្រូវបំពេញយ៉ាងអស្ចារ្យ ហើយមិនយូរមិនឆាប់ លំនឹងមួយនឹងត្រូវបានបំពេញបរិបូរណ៌ផងដែរ។

កន្លែងដែលព្រះយេស៊ូប្រសូត។ ភូមិដ៏តូចមួយ ដែលជាកន្លែងព្រះមេស្ស៊ីទ្រង់នឹងត្រូវប្រសូតនោះ ត្រូវបានញែកចេញជាពិសេសដោយព្យាការី មីកាតាំងពីប្រមាណ៧០០ឆ្នាំមុនពេលដែលព្រឹត្តិការណ៍នេះកើតឡើងទៅទៀត៖ "បេថ្លេហិមអេប្រាតាអើយ! ក្នុងចំណោមអំបូរទាំងប៉ុន្មាននៅស្រុកយូដា អ្នកតូចជាងគេមែន តែមេដឹកនាំដែលត្រូវគ្រប់គ្រងលើអ៊ីស្រាអែល ក្នុងនាមយើង នឹងកើតចេញមកពីអ្នក។ លោកនោះមានដើមកំណើត តាំងពីបុរាណកាលដ៏យូរលង់" (គម្ពីរមីកា ៥:២)។ សាកគិតទៅមើល រឿងទាំងនោះ គឺពិតជាបានកើតឡើងចំពោះលោកយ៉ូសែប និង នាងម៉ារី និង ចំពោះទីក្រុងនោះមែន។ បើប្រើទស្សនៈវិស័យរបស់មនុស្សសុទ្ធសាទធ្វើ មកគិត គេអាចនឹងនិយាយថា យ៉ូសែបនិង ម៉ារីស្ទើតែមិនអាចធ្វើរឿងនោះបាននោះទេ! ប៉ុន្តែមិនយូរប៉ុន្មាន បន្ទាប់ពីពួកគេបានទៅដល់ក្រុងនោះ ព្រះយេស៊ូបានប្រសូតមក។ ព្រះវិញ្ញាណដ៏វិសុទ្ធ ប្រកបដោយសព្វញ្ញុតញ្ញាណ ទ្រង់បានជ្រាបថាស្តេចដ៏វិសុទ្ធ នឹងមិនប្រសូតនៅក្រុងយេរូសាឡឹមឡើយប៉ុន្តែទ្រង់បែរជាប្រសូតនៅភូមិបេថ្លេហិមដ៏តូចមួយទៅវិញ។

ការក្បត់នឹងព្រះយេស៊ូ។ ខ្ញុំពិតជាស្ញើចក្នុងចិត្តណាស់ ដែលការក្បត់នឹងព្រះយេស៊ូនេះ ត្រូវបានអ្នកនិពន្ធធ្វើការទាយទុកជាមុន តាំងពីជាង១០០០ឆ្នាំមុនពេលដែលព្រះយេស៊ូទ្រង់ប្រសូតទៅទៀត។ គ្មាននរណាអាចនឹងគិតដល់ទៅថា ព្រះដែលត្រូវបានចាត់តាំង ដែលមានមនុស្សច្រើនជំនាន់រំពឹងចង់ឃើញ ក៏ជាព្រះដែលនឹងនាំសេចក្តីសង្គ្រោះមកដល់សាសន៍យូដា ជាព្រះដែលត្រូវបានចាត់ឲ្យមក ដោយព្រះជាម្ចាស់ដើម្បីធ្វើការគ្រងរាជ្យជារៀងរហូត អាចនឹងត្រូវមិត្តសម្លាញ់ និង ជាអ្នករួមការងារបានក្បត់ទ្រង់ទៅវិញ។ ប៉ុន្តែការនេះមានកត់ត្រាដើម្បីឲ្យមនុស្សគ្រប់ទាំងអស់បានអាន៖ "អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំជាអ្នកដែលទូលបង្គំបានទុកចិត្តហើយក៏បានបរិភោគបាយរបស់ទូលបង្គំផងនោះបានលើកកែងជើងទាស់នឹងទូលបង្គំដែរ" (គម្ពីរទំនុកតម្កើង ៤១:៩)។

របៀបនៃការសុគតរបស់ទ្រង់។ ការទាយទីបីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ គឺបានបង្ហាញពីទម្រង់មួយក្នុងការធ្វើគុតព្រះដែលត្រូវបានជ្រើសរើស ដែលមិនទាន់មានគេប្រើនៅក្នុងជំនាន់ដែលស្តេចដាវីតកំពុងសរសេរគម្ពីរទំនុកតម្កើងជំពូក២២នោះឡើយ។ សាសន៍យូដា នៅក្នុងជំនាន់ស្តេចដាវីតបានគប់សម្លាប់ជន

ឧក្រិដ្ឋដែលបានកាត់ទោសឲ្យស្លាប់។ គម្ពីរទំនុកតម្កើងជំពូក២២ បានទាញអំពីវិធីប្រហារជីវិតខុសពីនេះ ៖ "ពួកគេចាក់ទម្លុះដៃជើងទូលបង្គំ។" (ខ១៦)។ ការនេះប្រហែលជាចម្លែកណាស់សម្រាប់សាសន៍យូដា ប៉ុន្តែវាស្របទៅនឹងរូបភាពនៃការឆ្កាងរបស់ពួករ៉ូម៉ាំង យ៉ាងឥតខ្ចោះ។

ទំនាយក៏បានផ្តល់នូវសេចក្តីលំអិតអំពីការឆ្កាងព្រះយេស៊ូផងដែរ។ អ្នកក៏ប្រហែលជាបានចងចាំថា ព្រះជាម្ចាស់បានប្រទាន សេចក្តីណែនាំជាពិសេស អំពីការរៀបចំមនុស្សរបស់ទ្រង់សម្រាប់ការចាកចេញពីស្រុកអេស៊ីប។ សត្វចៀមសម្រាប់ធ្វើបុណ្យរំលង ត្រូវបានគេសម្លាប់ដើម្បីយកឈាមរបស់វាទៅលាបនៅលើទ្វារ។ ចំណែកឯសាច់របស់វាវិញ ក៏ត្រូវរៀបចំជាពិសេស គឺត្រូវអាំងទាំងមូលព្រះជាម្ចាស់ប្រហែលជាមានមូលហេតុជាច្រើនសម្រាប់ការណែនាំនេះ ប៉ុន្តែអ្វីដែលគេបានដឹងច្បាស់នោះ គឺថា៖ *មិនត្រូវបំបាក់ឆ្អឹងរបស់វាឡើយ* ។ ប្រសិនបើពួកគេចង់ស្ងោរសាច់នោះ គេត្រូវបំបាក់ឆ្អឹងនោះ ដើម្បីឲ្យបំណែកសាច់អាចធ្លាក់ចូលទៅក្នុងឆ្នាំងរបស់ពួកគេ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានជ្រាបថា សត្វចៀមសម្រាប់បុណ្យរំលងរបស់សាសន៍អ៊ីស្រាអែលគឺជាប្រភេទសត្វចៀម ដ៏ល្អឥតខ្ចោះសម្រាប់បុណ្យរំលង។ ដូច្នេះ មានពាក្យទំនាយតាំងពី១០០០ឆ្នាំមុនថ្ងៃប្រសូតរបស់ទ្រង់ ថ្លែងថា ទ្រង់ត្រូវគេវាយឲ្យមានរបួស ទ្រង់ត្រូវគេចាក់ទម្លុះ និងមួលបង្កាច់ ប៉ុន្តែ *គ្មានឆ្អឹងណាមួយត្រូវបាក់បែកឡើយ។*(ចូរប្រៀបធៀប គម្ពីរអេសាយ ៥២:១៣-១៥ និង ៥៣:១-១២ ជាមួយនឹងគម្ពីរទំនុកតម្កើង ៣៤:២០)។

លំហាត់អនុវត្តន៍

---

៥ ចូរអានគម្ពីរយ៉ូហាន ១៩:៣១-៣៧ ហើយថ្លែងប្រាប់អំពីអ្វីដែលយើងដឹង អំពីបទទំនាយដែលយើងទើបតែនឹងបានពិភាក្សាគ្នាហើយ ដោយសរសេរចម្លើយដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

ទំនាយដទៃផ្សេងទៀត ។ ទំនាយជាច្រើនផ្សេងទៀត បានកើតមានឡើងពិតៗ តាមរបៀបដែលគេមិនអាចបកស្រាយថាជារឿងចៃដន្យបាននោះទេ។ សូមមើលទៅកាន់ទំនាយជាច្រើន ដែលចាប់ផ្តើកើតមានឡើងនៅចំពោះមុខរបស់យើង ជាមួយនឹងការកើតជាថ្មីនៃសាសន៍អ៊ីស្រាអែល ទៅជាប្រទេសមួយ។ (សូមមើលគម្ពីរអេសាយ ៣៥:១-២ គម្ពីរអេសេគាល ៣៧ គម្ពីរសាការី ៨:៧-៨; ១០:៩) ។ មានការទំនាយជាច្រើននៅក្នុងគម្ពីរដានីយ៉ែល បានកើតមានឡើង ដែលមានអ្នកវិភាគសេរីបានខិតខំប្រឹង ថ្លែងថាការនោះ គឺគ្រាន់តែជាកំណត់ត្រាប្រវត្តិសាស្ត្រតែប៉ុណ្ណោះ មិនមែនជាបទទំនាយនោះទេ។ ពួកគេធ្វើការនេះមិនបានសម្រេចនោះទេ។ អ្នកប្រាជ្ញសម័យថ្មី កំពុងបន្តរកឃើញភស្តុតាងថ្មីៗដែលប្រាប់ថា លោកដានីយ៉ែលគឺពិតជាបានរស់នៅក្នុងជំនាន់ការគ្រប់គ្រងរបស់ក្រុងបាប៊ីឡូន ហើយការបើកសម្តែងដែលលោកទទួលបានមកអំពីរឿងអនាគត ក៏ត្រូវបានកត់ត្រានៅក្នុងអំឡុងឆ្នាំនោះដែរ។

៣. *ព្រះគម្ពីរមានសាច់រឿងរួមមួយដ៏អស្ចារ្យ*

ទោះបីជាព្រះគម្ពីរត្រូវបានសរសេរឡើងដោយអ្នកនិពន្ធចំនួន៤០នាក់ នៅក្នុងអំឡុងពេលប្រមាណ ១៦០០ ឆ្នាំក៏ដោយ កណ្ឌគម្ពីរនៅតែបង្ហាញសាច់រឿងដ៏សំខាន់តែមួយ៖ *ព្រះជាម្ចាស់ប្រោសលោះមនុស្សលោកតាមរយៈការបូជាព្រះជន្មព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រិស្ត* ។ នៅក្នុងបទគម្ពីរ មានប្រព័ន្ធនៃសេចក្តីបង្រៀនតែមួយ ខ្នាតគំរូសីលធម៌តែមួយ ផែនការនៃការសង្គ្រោះតែមួយ និង ផែនការដ៏ពិសិដ្ឋ

មួយនៅក្នុងយុគ្គសម័យ។ ផ្ទុយពីការផ្ទុយចាកពីគ្នា និង សាច់រឿងច្របូកច្របល់ កណ្ឌគម្ពីរទាំងអស់មានតួនាទីដើម្បីបំពេញ និង បង្គ្រប់ឲ្យគ្នាទៅវិញទៅមកតាមរបៀបដ៏ចុះសម្រុងគ្នា។ ការប្រមូលផ្តុំអស្ចារ្យនៃការបើកសម្តែង ដែលបង្ហាញឲ្យឃើញជាបន្តបន្ទាប់ តាមភាគដ៏ភាពរំជើបរំជួល ដែលនាំទៅដល់ចំណុចចុងបញ្ចប់ដ៏រំភើប នៅក្នុងជ័យជំនះលើសាតាំងក្នុងគ្រាចុងក្រោយ។ កណ្ឌនៅក្នុងព្រះគម្ពីរដែលខុសគ្នា ដូចជានៅក្នុងគម្ពីរលេវីនិយ និង គម្ពីរយ៉ូហានបង្កើតបានជារឿងតែមួយ សាច់រឿងតែមួយ កិច្ចការតែមួយ។ ចំណែកឯកណ្ឌគម្ពីរដំណឹងល្អទាំងបួន ផ្តល់ឲ្យយើងនូវសេចក្តីលំអិតអំពីព្រះជន្មរបស់ព្រះគ្រិស្ត ហើយបានបំភ្លឺយ៉ាងច្បាស់ទៅលើជ្រុងផ្សេងៗគ្នានៃលក្ខណសម្បត្តិ របស់ ព័ន្ធកិច្ចរបស់ទ្រង់។ យ៉ាងណាមិញ កណ្ឌគម្ពីរទាំងនោះ គឺជាចំណែករួមមកតែមួយ។

លំហាត់អនុវត្តន៍

---

៦ ដោយមិនបើកទៅមើល ចំណុចខាងលើ ចូរឆ្លើយនឹងសំណួរទាំងប៉ុន្មាននៅខាងក្រោមនេះ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) ចូររៀបរាប់ភស្តុតាងបីយ៉ាង អំពីការជំរុញនៃបទគម្ពីរ។

ខ) តើព្រះយេស៊ូ បង្ហាញថាទ្រង់ទទួលស្គាល់សិទ្ធិអំណាចរបស់គម្ពីរសម្ព័ន្ធមេត្រីចាស់ តាមរបៀបណា?

គ) ចូរផ្តល់ឧទាហរណ៍មួយ អំពីបទទំនាយនៅក្នុងព្រះគម្ពីរ ដែលត្រូវបានបំពេញរួច។

ឃ) តើសាច់រឿងចម្បងមួយនៃព្រះគម្ពីរដែល កើតឡើងតាំងពីគម្ពីរលោកុប្បត្តិ ដល់គម្ពីរវិវរណៈ?

គ. ភាពផ្គាច់មុខនៃបទគម្ពីរ

វគ្គបំណែងទី៣. *ប្រាប់ពីលក្ខណៈវិនិច្ឆ័យ សម្រាប់ភាពផ្គាច់មុខនៃបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និងសម្ព័ន្ធមេត្រីថ្មី ហើយពិភាក្សាអំពីបញ្ជីកណ្ឌគម្ពីរ។*

នៅពេលដែលយើង និយាយអំពី*ភាពផ្គាច់មុខ* នៃបទគម្ពីរ យើងចង់បានន័យថាព្រះគម្ពីរគឺជាសំណេរនៃការបើកសម្តែងយ៉ាង*គ្រប់លក្ខណៈ* របស់ព្រះជាម្ចាស់អំពីសេចក្តីពិតរបស់ទ្រង់។ យើងបានឃើញថាព្រះជាម្ចាស់បានប្រើប្រាស់អ្នកនិពន្ធដែលជាមនុស្សជាច្រើននាក់ ឲ្យកត់ត្រាការបើកសម្តែងរបស់ទ្រង់។ យើងក៏បានពិភាក្សាគ្នា អំពីវេលាដែលចូលរួមនៅក្នុងការសម្រេចបាន ការលាតត្រដាងអំពីព្រះជាម្ចាស់។ បន្ទាប់មកយើង បានប្រទះនឹងបញ្ហាសំខាន់ពីរយ៉ាង ៖ ១) តើការបើកសម្តែងនេះ សម្រេចបាននៅពេលណា? ២)តើការបើកសម្តែងអំពីព្រះជាម្ចាស់ នេះបានរួមមានអ្វីខ្លះ? ចូរឲ្យយើងបាន សិក្សាអំពីបញ្ហាទាំងនេះ។

ការសម្រេចបាន ការបើកសម្តែងអំពីព្រះជាម្ចាស់

យើងបានពិចារណា អំពីតរិយាបថរបស់ព្រះយេស៊ូទៅចំពោះគម្ពីរសម្ព័ន្ធមេត្រីចាស់ ទ្រង់បានបង្ហាញការទទួលរបស់ទ្រង់ ដោយការដកស្រង់យកបទគម្ពីរពីក្នុងគម្ពីរនោះជាច្រើនលើកច្រើនសា។ ទោះជាយ៉ាងណា នៅពេលជិតដល់ទីបញ្ចប់នៃព័ន្ធកិច្ចលើផែនដីរបស់ទ្រង់ ទ្រង់បានបង្ហាញថា ទ្រង់មានសេចក្តីពិតជាច្រើនផ្សេងទៀត ដើម្បីបង្ហាញទៅកាន់ពួកសាវ័ករបស់ទ្រង់។

> "ខ្ញុំមានសេចក្តីឯទៀតៗជាច្រើន ដែលត្រូវនិយាយប្រាប់អ្នករាល់គ្នា តែអ្នករាល់គ្នាពុំអាចទទួលនៅពេលនេះបានទេ។ កាលណាព្រះវិញ្ញាណនៃសេចក្តីពិតយាងមកដល់ ព្រះអង្គនឹងណែនាំអ្នករាល់គ្នាអោយស្គាល់សេចក្តីពិតគ្រប់ចំពូក ដ្បិតសេចក្តីផ្សេងៗដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីណាដែលទ្រង់ព្រះសណ្តាប់ឮ ព្រមទាំងមានព្រះបន្ទូលប្រាប់អោយអ្នករាល់គ្នាដឹង អំពីហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខផង។ ព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់ខ្ញុំ ព្រោះព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា។ អ្វីៗដែលព្រះបិតាមានទាំងប៉ុន្មានសុទ្ធតែជារបស់ខ្ញុំទាំងអស់។ ហេតុនេះហើយបានជាខ្ញុំពោលថា ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំយកមកប្រាប់អ្នករាល់គ្នា"។ (គម្ពីរយ៉ូហាន ១៦:១២-១៥)

នៅក្នុងខគម្ពីរនេះ យើងឃើញថាសេចក្តីពិតបន្ថែមទៀត នឹងត្រូវបានបើកបង្ហាញដោយព្រះវិញ្ញាណដ៏វិសុទ្ធ សេចក្តីពិតនេះ អាចនឹងរាប់បញ្ចូល *ព្រឹត្តិការណ៍នាពេលអនាគត* ("ហេតុការណ៍ដែលត្រូវកើតមាននៅថ្ងៃមុខ") *ការដឹកនាំ និង ការបំភ្លឺផ្លូវ* ("ព្រះអង្គទទួលសេចក្តីទាំងអស់ពីខ្ញុំ យកមកប្រាប់អ្នករាល់គ្នា") និង *សេចក្តីបង្រៀន* បន្ថែមទៀត ("អោយស្គាល់សេចក្តីពិតគ្រប់ចំពូក") ដែលចាំបាច់ក្នុងការរស់នៅក្នុងមាគ៌ាដែល *ផ្គាប់ព្រះទ័យរបស់ព្រះជាម្ចាស់* ("ព្រះអង្គនឹងសំដែងសិរីរុងរឿងរបស់ខ្ញុំ")។

រួមជាមួយការមានព្រះបន្ទូលរបស់ព្រះយេស៊ូ មានរឿងសំខាន់ៗពីរយ៉ាង៖

១. ទ្រង់សន្យាថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងសម្រេចការបើកសម្តែង ដោយដឹកនាំអ្នកដើរតាមទ្រង់ឲ្យស្គាល់សេចក្តីពិតគ្រប់ចំពូក (ខ១៣) ។ ទ្រង់នឹងជួយឲ្យពួកគេបានយល់ និងយកសេចក្តីបង្រៀនរបស់ទ្រង់ទៅប្រតិបត្តិ។

២. ទ្រង់មានព្រះបន្ទូលសំដៅទៅការបើកសម្តែងក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី តាំងពីមុនពេលដែលគម្ពីរនេះត្រូវបានបើកសម្តែងទៅកាន់អ្នកនិពន្ធ និង ត្រូវបានកត់ត្រាទៅទៀត។ អ្នកអាចនិយាយបានថា ទ្រង់បាន*បញ្ជាក់សុពលភាព*នៃគម្ពីរនេះទុកជាមុន។ ការ*បញ្ជាក់សុពលភាព* គឺបានន័យថា ការប្រកាសទទួលស្គាល់ និង ផ្តល់សិទ្ធិអំណាចឲ្យ។ តាមរបៀបនេះកិច្ចការរបស់អ្នកនិពន្ធគម្ពីរដំណឹងល្អ កណ្ឌគម្ពីរកិច្ចការ កណ្ឌគម្ពីរលិខិត និង កណ្ឌគម្ពីរវិវរណៈ ក៏ត្រូវបានទាយទុកមុន ត្រូវបានបកស្រាយ និង ទទួលស្គាល់។

អ្នកនិពន្ធដូចជា លោកប៉ូលបង្ហាញថាអ្វីដែលពួកគេសរសេរគឺបានទទួលពីការបើកសម្តែង។ ការនិយាយអំពីបទពិសោធន៍របស់លោក នៅក្នុងគម្ពីរអេភេសូ ៣:១-១២ លោកសាវ័កប៉ូលនិយាយថា លោក និង សាវ័កដទៃទៀត និង ព្យាការី គឺសុទ្ធតែបានទទួលបានពីការបើកបង្ហាញរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតមិនធ្លាប់បានដឹងពីមុនមក។ លោកពេត្រុសក៏បានឃើញពីតម្លៃនៃអ្វី ដែលព្រះវិញ្ញាណដ៏វិសុទ្ធ

បានបង្ហាញ និង បានជំរុញឲ្យធ្វើការកត់ត្រាទុកផងដែរ (គម្ពីរ២ពេត្រុស ១:២០-២១)។ នៅក្នុងគម្ពីរ២ពេត្រុស៣:១៥-១៦ លោកបាននិយាយចាត់ទុក កំណត់ត្រាសេចក្តីបង្រៀនពីគោលលទ្ធិ របស់លោកសាវ័កប៉ូលថាជា *បទគម្ពីរ*។

មកដល់ឆ្នាំ ៦៤ ឬ ៦៥ គ.ស រឿងរ៉ាវភាគច្រើននៅក្នុងគម្ពីរដំណឹងល្អ និង កណ្តាគម្ពីរសំបុត្រត្រូវបានសរសេរ និង ចែកចាយជាបន្តបន្ទាប់នៅក្នុងចំណោមក្រុមជំនុំ។ ប្រមាណ ២៥ ឬ ៣០ឆ្នាំក្រោយមក លោកសាវ័កយ៉ូហានបានទទួលនូវព្រះគម្ពីរវិវរណៈ។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានអនុញ្ញាតឲ្យសាវ័កយ៉ូហាន ទទួលការបើកសម្តែងនេះ ហើយក្រោយមកទៀត ទ្រង់ហាក់បីដូចជាបានសម្រេចការបើកសម្តែងដ៏ពិសិដ្ឋនេះ។ ឥឡូវនេះ បទគម្ពីរបានត្រូវសម្រេចយ៉ាងបរិបូរណ៌ហើយ យើងមិនត្រូវបានបន្ថែម ឬ ដកចេញអ្វីទៀតឡើយ។ ព្រះជាម្ចាស់បានបើកបង្ហាញបំណងព្រះហឫទ័យ និង គោលបំណងរបស់ទ្រង់ម្តងបន្តិចៗ ក្នុងអំឡុងពេលប្រមាណ ១៦០០ឆ្នាំ។ យើងមិនត្រូវបានអ្វីផ្សេងទៀតទេ។ ព្រះជាម្ចាស់បានមានព្រះបន្ទូល អំពីរឿងគ្រប់យ៉ាងដែលទ្រង់សព្វព្រះទ័យនឹងព្រះបន្ទូលមកកាន់យើងរាល់គ្នា ទាក់ទងនឹងអង្គទ្រង់ និង ផែនការរបស់ទ្រង់សម្រាប់យើង។

នេះបានន័យថា ការជំរុញជាពិសេសពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានធ្វើឲ្យព្រះបន្ទូលជាទម្រង់សំណេររបស់ព្រះជាម្ចាស់ កើតចេញជារូបរាងឡើងនោះ គឺមិនអាចកើតមានចំពោះយើងបានទេ ក្នុងពេលបច្ចុប្បន្ននេះ។ ការនោះគឺត្រូវបានរក្សាទុកផ្តាច់មុខសម្រាប់តែអ្នកនិពន្ធបទគម្ពីរតែប៉ុណ្ណោះ។ យើងអាចទទួលបានការជំរុញចិត្តពីព្រះជាម្ចាស់ ដើម្បីរួមចំណែកក្នុងការពង្រីកអាណាចក្ររបស់ព្រះជាម្ចាស់បាន ប៉ុន្តែយើងមិនអាចរួមចំណែកក្នុងការបើកសម្តែងជាសំណេររបស់ទ្រង់បាននោះឡើយ។ ក្រោយពីបានអានសិក្សា និង អនុវត្តតាមសេចក្តីបង្រៀននៃបទគម្ពីរ យើងអាចនិយាយដោយប្រាកដក្នុងចិត្តថា ព្រះជាម្ចាស់ពិតជាបានមានព្រះបន្ទូល *យ៉ាងច្បាស់* និង *យ៉ាងខ្ជាប់ខ្ជួន* មកកាន់យើង។ ទ្រង់បានបង្ហាញ *យ៉ាងគ្រប់គ្រាន់* នូវអ្វីដែលទ្រង់បានសព្វព្រះហឫទ័យទាក់ទងជាមួយយើង។ មិនចាំបាច់ត្រូវការ ឬ គិតអ្វីផ្សេងទៀតនោះទេ។

ជារឿងសំខាន់ណាស់ ដែលយើងត្រូវដឹងថាព្រះជាម្ចាស់នៅតែបន្តមានព្រះបន្ទូលមកកាន់ក្រុមជំនុំរបស់ទ្រង់ ក្នុងពេលបច្ចុប្បន្ននេះ។ តាមរយៈព្រះអំណោយទាននៃការធ្វើទំនាយ ព្រះវិញ្ញាណនៅតែបន្តប្រកាសទៅកាន់អ្នកជឿអំពីព្រះតម្រិះរបស់ព្រះជាម្ចាស់។ ទោះជាយ៉ាងណា បើការទស្សន៍ទាយទាំងនោះពិតជានឹងទទួលយកបានមែន វាត្រូវតែស្របគ្នាជាមួយនឹងព្រះបន្ទូល អាចបំភ្លឺ អាចដាស់តឿន និង អាចកំសាន្តចិត្តអ្នកជឿ (គម្ពីរ១កូរិនថូស ១៤:៣) ។ គ្មានការអ្វីដែលអាចជំនួស ឬក៏អាចទាស់នឹង ការបើកសម្តែងដែលព្រះបានប្រទានមកនៅក្នុងយុគសម័យរបស់ពួកសាវ័ក ដែលជាទិសដៅទូទៅសម្រាប់ក្រុមជំនុំបានសោះឡើយ។

លំហាត់អនុវត្តន៍

៧ យើងបានឃើញថា ព្រះយេស៊ូបានបញ្ជាក់ថាពិតនូវបទគម្ពីរសម្ព័ន្ធមេត្រីចាស់ តាមរយៈការលើកយកបទគម្ពីរទាំងនោះមកប្រើជារឿយៗ នៅក្នុងព័ន្ធកិច្ចរបស់ទ្រង់។ ចូរឆ្លើយនឹងសំណួរខាងក្រោមនេះ ដែលទាក់ទងនឹងបទគម្ពីរសម្ព័ន្ធមេត្រីថ្មី ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) តើបទគម្ពីរបង្ហាញអ្វីខ្លះ មកកាន់យើងដែលបញ្ជាក់ថាពិត ព្រះយេស៊ូទ្រង់បានដាក់ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មីជាបទគម្ពីរ ជាមុន?

ខ) តើព្រះយេស៊ូបានប្រាប់យើងថាអ្វីខ្លះជាសេចក្តីពិតបន្ថែមដែលត្រូវបើកបង្ហាញ ដែលអាចនឹងរាប់បញ្ចូលបាន?

គ) ចូរថ្លែងបទគម្ពីរពីរ ដែលបង្ហាញថាពួកសាវ័កផ្ទាល់ ក៏ដឹងថាអ្វីដែលពួកគេបាននឹងកំពុងតែសរសេរនោះ គឺជាការបើកសម្តែងពីព្រះជាម្ចាស់។

៨ ហេតុអ្វីបាន វាជារឿងសំខាន់ដែលយើងត្រូវដឹងថា ការបើកសម្តែងជាសំណេររបស់ព្រះជាម្ចាស់ដែលហៅថាព្រះគម្ពីរនោះ គឺជាការបើកសម្តែងដែលពេញបរិបូរណ៍របស់ព្រះជាម្ចាស់? ចូរប្រើប្រាស់សៀវភៅកត់ត្រារបស់អ្នកសម្រាប់ឆ្លើយនឹងសំណួរនេះ។

បញ្ជីកណ្ឌគម្ពីរ

ប្រមាណពី២០០០ឆ្នាំ បានកន្លងផុតទៅ តាំងពីការបើកសម្តែងបទគម្ពីរចុងក្រោយ។ ការបើកសម្តែងនោះ រួមមានការប្រោសលោះរបស់ព្រះជាម្ចាស់ ដូចដែលបានបង្ហាញនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ការអញ្ជើញចុងក្រោយរបស់ទ្រង់ ទៅកាន់មនុស្សលោក នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី។

អ្នកប្រហែលជាអាចសួរថា "តើកំណត់ត្រានៃសេចក្តីពិតដែលបានបើកបង្ហាញជាច្រើន អាចត្រូវបានគេចងក្រងទៅជាសៀវភៅមួយក្បាលបានយ៉ាងដូចម្តេច? តើគេបានធ្វើការចងក្រងនោះនៅពេលណា? តើមានស្តាប់ន គ្រឹះស្ថាន ឬ បុគ្គលណាដែលមានទំនួលខុសត្រូវក្នុងការចងក្រងព្រះគម្ពីរឡើង?" យើងនឹងពិចារណាអំពីសំណួរទាំងនេះ?

ការបង្កើតព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់

យើងចាត់ទុកកណ្ឌគម្ពីរទាំង៣៩នៃព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ថា ជា*បញ្ជីកណ្ឌគម្ពីរ* (canon) មួយ។ ពាក្យនេះគឺបានមកពីពាក្យក្រិក *ខានន(Kanon)* ដែលអត្ថន័យដើមគឺ "ម៉ែត្រវាស់ឬ បន្ទាត់"។ ក្រោយមកវាប្រែទៅជាមានន័យថា "បន្ទាត់វាស់ វិន័យ ឬខ្នាតគំរូមួយ"។ នៅពេលដែលយើងយកពាក្យនេះមកប្រើជាមួយនឹងបទគម្ពីរ ពាក្យថាបញ្ជីកណ្ឌគម្ពីរ (canon) នេះគឺសំដៅទៅលើកណ្ឌគម្ពីរដែលបានត្រូវបានវាស់វែងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាក់លាក់មួយ និង ត្រូវបានគេឃើញថាមានលក្ខណៈពេញលេញស្របតាមសេចក្តីកំណត់សម្រាប់ឲ្យកណ្ឌគម្ពីរនោះក្លាយជាការបើកសម្តែងដែលបណ្តាលឲ្យតែងរបស់ព្រះជាម្ចាស់។

ជាការសង្ខេបខ្លីៗ ទីចាប់ផ្តើមនៃការបើកសម្តែងរបស់ព្រះជាម្ចាស់ ត្រូវបានកត់ត្រាឡើងដោយលោកម៉ូសេ ប្រហែលជាក្នុងឆ្នាំ១៤៥០ មុនគ.ស។ ការលាតត្រដាងចុងក្រោយនៃគម្ពីរសម្ព័ន្ធមេត្រីចាស់ គឺត្រូវបានកត់ត្រានៅម្តុំចុងសតវត្សទី៥ មុនគ.ស។ លោកម៉ូសេត្រូវបានគេជឿថាជាអ្នកនិពន្ធកណ្ឌគម្ពីរដំបូងទាំងប្រាំ នៃគម្ពីរសម្ព័ន្ធមេត្រីចាស់ ដែលគេតែងតែហៅថា គម្ពីរ*ក្រឹត្យវិន័យ*។ បន្ទាប់មកទៀត នៅក្នុងគម្ពីររបស់សាសន៍ហេប្រឺ មានគម្ពីរ*ព្យាការី*។ កណ្ឌគម្ពីរទាំងនេះរួមមាន កណ្ឌគម្ពីរដែលបានលាតត្រដាងទៅកាន់អ្នកដែលធ្វើការនៅក្នុងតំណែងជាព្យាការី។ ចំណែកទីបីនៃកណ្ឌគម្ពីរ ដែលគេហៅថា កណ្ឌគម្ពីរ*សំណេរ*រួមមានសំណេរបីក្រុម ៖ ១) កណ្ឌគម្ពីរដែលសរសេរឡើងសម្រាប់កម្មវិធីជាក់លាក់ ដូចជា ពិធីជប់លៀងជាដើម (ឧទាហរណ៍ កណ្ឌគម្ពីរនាងអេសធើរ ត្រូវបានគេយកទៅអាននៅក្នុងកម្មវិធីជប់លៀង នៅបុណ្យពួរីម ២) កណ្ឌគម្ពីរកំណាព្យ (គម្ពីរទំនុកតម្កើង គម្ពីរសុភាសិត និង គម្ពីរយ៉ូប) និង ៣) កណ្ឌគម្ពីរប្រវត្តិសាស្ត្រដែលមិនមែនជាទំនាយ (គម្ពីរដានីយ៉ែល គម្ពីរអេសរ៉ា គម្ពីរនេហេមា និង គម្ពីរបាក្យត្រ ដែលត្រូវបានសរសេរឡើងដោយអ្នកដែលមិនធ្វើការនៅក្នុងតំណែងជាព្យាការីនោះទេ ទោះជាយ៉ាងណា លោកដានីយ៉ែលបានប្រើប្រាស់ព្រះអំណោយទានជាព្យាការីរបស់លោក)។ កណ្ឌគម្ពីរដែលបង្កើតបានទៅជាព្រះគម្ពីររបស់សាសន៍ហេប្រឺ គឺដូចទៅនឹងកណ្ឌគម្ពីរទាំង៣៩ ដែលយើងបានស្គាល់នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ផងដែរ។

ភស្តុតាងបានមកពីអ្នកប្រវត្តិសាស្ត្រសាសន៍យូដា លោកយ៉ូសេហ្វឹស (ឆ្នាំ៩៥ គ.ស) បានបង្ហាញថាកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ត្រូវបានគេចងក្រងមកតែមួយ ដោយមានការដឹកនាំពីលោកអេសរ៉ា និង សមាជិកដទៃទៀតនៅក្នុងមហាសាលាប្រជុំ នៅក្នុងសតវត្សទីប្រាំ មុនជំនាន់ព្រះគ្រិស្តទៅទៀត។ កណ្ឌគម្ពីរទាំង៣៩ ដែលរួមទាំងបីក្រុមដែលយើងបានលើកយកមកនិយាយនៅខាងលើ មានគម្ពីរក្រឹត្យវិន័យ គម្ពីរព្យាការី និង គម្ពីរសំណេរ ដែលមនុស្សរបស់ព្រះជាម្ចាស់ប្រកាន់យកជាវិន័យរបស់ពួកគេដែលប្រទានមកពីព្រះជាម្ចាស់ និងជាវិន័យតែមួយរបស់ពួកគេ សម្រាប់ជំនឿ និង ទង្វើរបស់ពួកគេ។ កំណត់ត្រាអំពីការពិភាក្សា នៅក្នុងសាលាបង្រៀននៅក្នុងក្រុង ចាមនា (Jamnia) នៅស្រុកភីលីស្ទីន ចន្លោះឆ្នាំ ៧០ និង ឆ្នាំ១០០ គ.ស ក៏បានទទួលស្គាល់វត្តមានរបស់ បញ្ជីកណ្ឌគម្ពីរទាំង៣៩ ដែលយើងហៅថា គម្ពីរសម្ព័ន្ធមេត្រីចាស់នេះ។

ការបង្កើតព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី

នៅក្នុងអំឡុងពេល ពីសតវត្សមុនជំនាន់ព្រះយេស៊ូ ជនជាតិអ៊ីស្រាអែលទទួលរងការគាប់សង្កត់ និងការប្រៀតប្រៀនដ៏ព្រៃផ្សៃ ពីជាតិសាសន៍ដទៃ។ ប្រជាជនបានឆ្ងល់ថា "ហេតុអ្វីបានជាព្រះជាម្ចាស់មិនលូកព្រះហស្តក្នុងរឿងនេះ? តើនឹងគ្មានសង្ឃឹម ថានឹងទទួលបានយុត្តិធម៌ទេឬអី?

ប្រៀបបានទៅនឹងការឆ្លើយតបទៅនឹងការចោទសួរដ៏តប់ប្រមល់ទាំងនេះ ក៏មានអក្សរសិល្ប៍មួយបានលេចឡើងដែលយើងហៅថា *សំណេរអំពីអវសានលោកីយ៍* (ទាក់ទងទៅនឹងការប្រាប់ទុកជាមុននូវព្រឹត្តិការណ៍ដែលពិភពលោកត្រូវបែកបាក់ និង ពេញដោយហិង្សា)។ កណ្ឌគម្ពីរផ្សេងៗទៀតហាក់បីដូចជាត្រូវបានគេអះអាងថា បានសរសេរឡើងដោយតួអង្គពីបុរាណនៅក្នុងព្រះគម្ពីរ។ សេចក្តីដែលគេហៅថាទំនាយទាំងនេះ បានថ្លែងថាព្រះជាម្ចាស់នឹងបំបែកប្រវត្តិសាស្ត្រនេះ ដោយការវិនិច្ឆ័យ ការដាក់ទោស

យ៉ាងហិង្សា ចំពោះមនុស្សអាក្រក់ ហើយទ្រង់ផ្តល់រង្វាន់ឲ្យមនុស្សសុចរិត។ស្របពេលដែល សំណេរអក្សរសិល្ប៍នេះមានតម្លៃខាងឯប្រវត្តិសាស្ត្រខ្លះ សំណេរនេះ មិនដែលត្រូវបានពួកសាសន៍យូដា និង ក្រុមជំនុំជំនាន់មុនទទួលស្គាល់ថាមានកម្រិតស្មើនឹងបទគម្ពីរនោះទេ។ គំរូមួយនៃអក្សរសិល្ប៍ប្រភេទនេះ គឺសំណេរម្យ៉ាងដែលគេហៅថា *អាប៉ូគ្រីហ្វា(Apocrypha)* ។

ផ្ទុយជាមួយនឹងរឿងទាំងនេះ ព្រះយេស៊ូបានយាងមកដើម្បីបម្រើ សុគត មានព្រះជន្មរស់ឡើងវិញ និង យាងឡើងទៅឯព្រះវរបិតាវិញ។ ទ្រង់បានយាងមកដើម្បីប្រទានក្តីសង្ឃឹម និង ពន្លឺទៅដល់លោកីយ៍ដែលត្រូវបានបាបធ្វើឲ្យទៅជាងងឹត។ ទោះជាយ៉ាងណា ទ្រង់មិនដាក់ទោសមនុស្សអាក្រក់ និង មិនប្រទានរង្វាន់ដល់មនុស្សសុចរិតសោះឡើយ។ ផ្ទុយទៅវិញទ្រង់បាន បង្កើតក្រុមជំនុំ ហើយបង្គាប់ឲ្យអ្នកជឿធ្វើការចែកចាយ ដំណឹងល្អនៅគ្រប់ទីកន្លែង។ ទ្រង់បានមានព្រះបន្ទូល យ៉ាងពិស្តារថា អ្នកដែលដើរតាមទ្រង់ត្រូវបានចែកចាយអ្វីៗទាំងអស់ដែលទ្រង់បានមានព្រះបន្ទូល (គម្ពីរម៉ាថាយ ២៨:២០) ។ ពិតណាស់ យើងក៏ត្រូវការកំណត់ត្រាអំពីអ្វីដែលទ្រង់បានមានព្រះបន្ទូលជាសំណេរខ្លះៗដែរ។

នៅពេលដែលក្រុមជំនុំដំបូងបានរីកលូតលាស់ជាច្រើន ហើយបានពង្រីកទៅដល់គ្រប់ទីកន្លែង អ្នកជឿក៏បានចាស់ទុំឡើងតាមរយៈព័ន្ធកិច្ចនៃការផ្សាយដំណឹងល្អ។ ព័ន្ធកិច្ចនេះ ត្រូវបានចាប់ផ្តើមឡើងដោយអស់អ្នកដែលបានដើរជាមួយព្រះអម្ចាស់ក្នុងអំឡុងពេលទ្រង់គង់នៅលើផែនដី ។ ស្របពេលដែលអ្នកជឿបានរីកលូតលាស់ខាងឯវិញ្ញាណ មានសំណួរជាច្រើនក៏បានលេចឡើងទាក់ទងនឹងការប្រើប្រាស់យ៉ាងពិតជាក់ស្តែងនៃព្រះគុណរបស់ព្រះជាម្ចាស់ទៅជាមួយនឹងបញ្ហាក្នុងជីវិតប្រចាំថ្ងៃ និងទៅជាមួយភាពខុសគ្នាខាងឯវប្បធម៌ ការទាមទារពីសង្គមជុំវិញ និង ទៅជាមួយនឹងអញ្ញទិដ្ឋិ (ផ្នត់គំនិត ឬ គោលលទ្ធិដែលផ្ទុយទៅនឹងជំនឿដែលបានគេទទួលស្គាល់ស្រាប់ហើយ) ។ ពួកគេអ្នកដឹកនាំសាវ័ក បានឆ្លើយតបទៅនឹងសេចក្តីត្រូវការនេះ ដោយសរសេរលិខិតណែនាំ (ហៅថា*គម្ពីរលិខិត)* ដែលត្រូវបានគេចែកចាយបន្តនៅក្នុងចំណោមក្រុមជំនុំ។ ច្បាស់ណាស់ សំណេរទាំងអស់នេះគឺត្រូវបានចាប់ផ្តើមឡើងដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ត្រូវបានទទួលស្គាល់ថាជាបទគម្ពីរដ៏ពិសិដ្ឋ (គម្ពីរ២ពេត្រុស ៣:១៥-១៦) ។ កំណត់ត្រាទាំងនេះត្រូវបានគេហៅថា ដំណឹងល្អ (គម្ពីរម៉ាថាយ គម្ពីរម៉ាកុស គម្ពីរលូកា និង គម្ពីរយ៉ូហាន)។

យើងក៏ត្រូវចាំដែរថា ស្របពេលជាមួយគ្នាដែលក្រុមជំនុំកំពុងពេញវ័យឡើង នឹងមាន "បងប្អូន" ក្លែងក្លាយ "សាវ័ក" ក្លែងក្លាយ និង "ពួកអ្នកប្រឆាំងព្រះគ្រិស្ត" បានចូលខ្លួនមក និង ផ្តល់គោលលទ្ធិរបស់ពួកគេ ឲ្យជ្រៀតចូលមកក្នុងក្រុមជំនុំ។ (សូមអានគម្ពីរ២កូរិនថូស ១១:១២-១៥ គម្ពីរកាឡាទី ១:៦-៩; ៣:១ គម្ពីរកូឡូស ជំពូក២ គម្ពីរ១ធីម៉ូថេ ៤:១-៣ គម្ពីរ២ថេស្សាឡូនិក ជំពូក២ គម្ពីរ២ពេត្រុស ជំពូក២ គម្ពីរ១យ៉ូហាន ២:១៨-១៩ និង គម្ពីរយ៉ូដាស ដែលមាននិយាយអំពីរឿងនេះ)។ ស្របពេលដែលបទគម្ពីរត្រូវបានចែកចាយ នោះក៏មានអក្សរសិល្ប៍ជាច្រើនប្រភេទទៀតក៏ត្រូវបានចែកចាយដែរ។ ដូច្នេះមិនយូរប៉ុន្មានក្រុមជំនុំបានបង្កើតជាមធ្យោបាយមួយក្នុងការបានសំគាល់បទគម្ពីរណាដែលមានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់ ហើយផ្តល់នូវកន្លែងសមរម្យមួយសម្រាប់គម្ពីរនោះនៅក្នុងព្រះវិហារ។ ប្រាកដណាស់ ការធ្វើយ៉ាងដូច្នេះ បានញែកបទគម្ពីរដាច់ដោយឡែកពីសំណេរអក្សរសិល្ប៍ដទៃផ្សេងទៀត។ ច្បាប់ (ឬ បញ្ជី) សម្រាប់បទគម្ពីរសម្ព័ន្ធមេត្រីថ្មីគឺមានដូចខាងក្រោមនេះ៖

១. បទគម្ពីរនោះត្រូវតែបានសរសេរឡើងដោយ ឬ គាំទ្រដោយសាវ័កមួយរូប។
២. សេចក្តីនៅក្នុងបទគម្ពីរនោះត្រូវ តែនិយាយអំពីតួអង្គខាងឯវិញ្ញាណ ដែលបទគម្ពីរនោះទទួលស្គាល់ថាមានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់មក។
៣. បទគម្ពីរនោះត្រូវតែបានទទួលស្គាល់ជាទូទៅ ដោយក្រុមជំនុំ ថាត្រូវបានបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់។

នៅពេលក្រុមជំនុំចាប់ផ្តើមលេចចេញជារូបរាងដំបូង កណ្ឌគម្ពីរទាំង២៧ នៃគម្ពីរសម្ព័ន្ធមេត្រីថ្មីត្រូវបានវាស់វែងដោយលក្ខណៈវិនិច្ឆ័យទាំងនេះ ហើយត្រូវបានវិនិច្ឆ័យតាមក្រៅផ្លូវការថាបានបណ្តាល ចិត្តឲ្យតែងពីព្រះជាម្ចាស់។ ការនេះត្រូវបានដាក់ជាផ្លូវការ នៅលើមូលដ្ឋានផ្លូវការ ពេលដែលក្រុមប្រឹក្សានៃក្រុងកាថែត (ក្រុមអ្នកដឹកនាំក្រុមជំនុំមួយក្រុម) បានប្រកាសនៅក្នុងឆ្នាំ ៣៩៧ ថាបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មី គឺជាកណ្ឌគម្ពីរទាំង២៧ ដែលត្រូវបានបូករួមនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីសព្វថ្ងៃនេះ។ ដូច្នេះ ក្រុមប្រឹក្សាក្រុមជំនុំបានត្រឹមតែបញ្ជាក់ទៅលើការនេះ នៅពេលក្រោយមកទៀតតែប៉ុណ្ណោះនូវអ្វីដែលអ្នកជឿដែលបានដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធបានទទួលស្គាល់ឃើញរួចមកហើយ។

លំហាត់អនុវត្តន៍

៩ ចូរប្រាប់ពីកាលបរិច្ឆេទប៉ាន់ប្រមាណ និង ក្រុមដែលទទួលខុសត្រូវក្នុងការរៀបចំពីបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធមេត្រីថ្មី។
   ក) គម្ពីរសម្ព័ន្ធមេត្រីចាស់
   ខ) គម្ពីរសម្ព័ន្ធមេត្រីថ្មី
១០ ចូរប្រាប់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់យើង អំពីលក្ខណៈវិនិច្ឆ័យទាំងបីយ៉ាង សម្រាប់ជ្រើសរើសសំណេររបស់ក្រុមជំនុំដំបូង ដែលត្រូវបូកបញ្ចូលនៅក្នុងបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធថ្មី។ (ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក)។

តារាងតម្រៀបចិត្តច្បាន នៃសំណៅដើម(ហត្ថសំណេរ)

ការបណ្តាលចិត្តឲ្យតែងជាពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាអ្វីដែលអ្នកនិពន្ធខិតខំយកមកប្រើជាមួយនឹងសំណេរដំបូង ឬ សំណៅដើម(ហត្ថសំណេរ) នៅពេលដែលពួកគេធ្វើការកត់ត្រាពីការបើកសម្តែងរបស់ព្រះជាម្ចាស់។ យើងមិនមានសំណៅដើមនៃព្រះគម្ពីរទៀតទេ ក្នុងពេលសព្វថ្ងៃនេះ ទោះជាយ៉ាងណា យើងមានច្បាប់ចម្លងល្អៗនៃឯកសារទាំងនោះជាច្រើន ។ ដោយសារតែមានភាពខុសគ្នាបន្តិចបន្តួចនៅក្នុងចំណោមច្បាប់ចម្លងទាំងនោះ យើងមិនអាចនិយាយបានថា ព្រះជាម្ចាស់ទ្រង់បានបណ្តាលចិត្តឲ្យតែងពីទ្រង់ឲ្យមានច្បាប់ចម្លងទាំងអស់នោះឡើយ។

ប៉ុន្តែ ទោះបីជាស្ថិតនៅក្នុងបញ្ហានៃការចម្លង និង ចែកចាយបន្តនូវបទគម្ពីរដ៏ពិសិដ្ឋនេះ ក៏យើងនូវតែឃើញភស្តុតាងជាច្រើនអំពីការការពារ និង ការថែរក្សារបស់ព្រះជាម្ចាស់។ តាមពិតទៅ ការរក្សាទុកនូវសំណេរដ៏សុក្រិត អស់រយៈពេលជាច្រើនជំនាន់នោះហើយ គឺជាការអស្ចារ្យនៃឧបការគុណរបស់ព្រះជាម្ចាស់។ អ្នកផ្ទាល់ក៏ប្រហែលជាអាចនឹងសួរថា៖ "តើសំណេរនោះមានភាពសុក្រិតកម្រិតណាទៅ បើមានភាពខុសគ្នាបន្តិចបន្តួចតែងតែកើតមានឡើងពីច្បាប់ចម្លងមួយទៅច្បាប់ចម្លងមួយទៀតយ៉ាងដូច្នេះ?" ដើម្បីឆ្លើយតបនឹងសំណួរនេះ យើងអាចឆ្លើយយ៉ាងចំៗ និង ប្រកបដោយការអះអាងយ៉ាងច្បាស់ថា៖ "ច្បាប់ចម្លងទាំងនោះគឺពិតជាអាចទុកចិត្តបានមែន! ភាពខុសគ្នាយ៉ាងដូច្នោះ មិនមានឥទ្ធិពលទៅលើជំនឿលើគោលលិទ្ធ ឬសេចក្តីបង្រៀន និង មិនផ្លាស់ប្តូរអ្វីសោះឡើយនៅក្នុងការយល់ដឹងរបស់យើងអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់។

ការពិតគឺថា មានអ្នកជំនាញជាច្រើននាក់ដែលបានចំណាយពេលរាប់សិបឆ្នាំ ធ្វើការប្រៀបធៀបសំណៅដើមចាស់ៗ ជាមួយនឹងគ្នាទៅវិញទៅមក និង ទៅជាមួយនឹងសំណៅដើមដែលគួរឲ្យទុកចិត្តដទៃផ្សេងទៀត។ ពួកអ្នកជំនាញទាំងនោះ បានបន្តការស្រាវជ្រាវបន្ថែមទៀត។ ការរកឃើញថ្មី នៃច្បាប់ចម្លងបុរាណរបស់សំណេរព្រះគម្ពីរ នៅក្បែរសមុទ្រស្លាប់បានបន្ថែមការបញ្ជាក់យ៉ាងអស្ចារ្យទៅលើកិច្ចការនេះ។

លទ្ធផលដែលបានមកពីការសើបអង្កេតរបស់អ្នកប្រាជ្ញនេះ អះអាងប្រាប់យើងថា យើងពិតជាមានសំណេរមួយដែលគួរឲ្យទុកចិត្តពិតមែន។ ការសើបអង្កេតនេះ បង្ហាញថា សំណេរដែលយើងមានសព្វថ្ងៃជាភាសាហេប្រឺ និង ភាសាក្រិកនេះ គឺពិតជាដូចទៅនឹងសំណៅដើម (ហៅថា *សំណេរដើម (*Autographs) ហើយបង្ហាញថាគោលលទ្ធិសំខាន់ទាំងអស់ នៃគម្ពីរសម្ព័ន្ធមេត្រីចាស់ និង ថ្មី គឺមិនខូចខាតឡើយ។ ព្រះជាម្ចាស់ ដែលបានបណ្តាលចិត្តឲ្យតែង មានការសរសេរអំពីការបើកសម្តែងរបស់ទ្រង់ទៅកាន់មនុស្សជាតិ ទ្រង់បានរក្សាទុកសំណេរនោះជាច្រើនជំនាន់។ យើងអាចទុកចិត្តបានថា ព្រះគម្ពីររបស់យើង គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។

នៅពេលដែលព្រះគម្ពីរបានបង្ហាញថា ដើម្បីទទួលបាននូវការបើកសម្តែងពីព្រះជាម្ចាស់ គឺចាំបាច់ទាមទារឲ្យមានការបណ្តាលចិត្តជាពិសេសមួយពីព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរ២ពេត្រុស ១:២០-២១) យើងមិនអាចធ្វើការសន្និដ្ឋានពីព្រះគម្ពីរបានទេ ថាការបណ្តាលចិត្តដូចគ្នានោះ គឺមានសម្រាប់អស់អ្នកដែលបានបកប្រែ ផ្ទេរបន្ត និង ចម្លងបទគម្ពីរដែរនោះទេ។ តាមរបៀបនេះ ខ្ញុំមិនចង់និយាយថា ការបកប្រែគឺមិនអាចទុកចិត្តបាននោះទេ។ ផ្ទុយទៅវិញ យើងដឹងថា ការបកប្រែភាគច្រើនបច្ចុប្បន្ននេះ និង ពីមុន ធ្លាប់តែ និង នៅតែឆ្លងកាត់ការពិនិត្យពិច័យ នៃការសិក្សាយ៉ាងជ្រៅជ្រះ។ ការបកប្រែភាគច្រើន គឺមានគុណភាពខ្ពស់ អស្ចារ្យ។ ទោះជាយ៉ាងណា ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ៗថា យើងមិនអាចយកការបកប្រែណាមួយ មកធ្វើជាសិទ្ធិអំណាចចុងក្រោយ នៅក្នុងជំនឿ និង ការប្រតិបត្តិរបស់យើងនោះឡើយ។ យើងត្រូវតែប្រៀបធៀប ការបកប្រែមួយទៅនិង ការបកប្រែមួយទៀត ព្រមទាំងពិចារណាអំពីភាពត្រឹមត្រូវនៃការបកប្រែនីមួយៗ នៅក្រោមការឆ្លុះបញ្ចាំងពីការសិក្សាយ៉ាងជ្រៅជ្រះ។

លំហាត់អនុវត្តន៍

១១ តើប្រយោគណាខ្លះ នៅខាងក្រោមនេះ ត្រឹមត្រូវ ទាក់ទងនឹងបញ្ជីកណ្ឌគម្ពីរ ដែលបានពិភាក្សានៅក្នុងមេរៀននេះ?

ក) ដោយហេតុតែយើងមិនមានសំណៅដើមនៃបទគម្ពីរ យើងមិនអាចដឹងច្បាស់ថា បញ្ជីកណ្ឌគម្ពីរនោះគឺជាព្រះបន្ទូលដែលបណ្ដាលចិត្តមកពីព្រះជាម្ចាស់នោះទេ។

ខ) ពាក្យថា *បញ្ជីកណ្ឌគម្ពីរ* បង្ហាញថាកណ្ឌទាំងអស់នៅក្នុងព្រះគម្ពីរ គឺបានស្របតាមខ្នាតគំរូមួយនេះ ៖ គឺថា កណ្ឌគម្ពីរទាំងនោះបានការបណ្ដាលចិត្តពីព្រះជាម្ចាស់។

គ) យើងអាចនឹងទទួលស្គាល់សេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ទាំងទំនុកចិត្ត ព្រោះព្រះជាម្ចាស់មិនត្រឹមតែបានបណ្ដាលចិត្តក្នុងការសរសេរបទគម្ពីរនោះទេ ប៉ុន្តែទ្រង់ក៏បានថែរក្សាបទគម្ពីរអស់រយៈពេលជាច្រើនសតវត្សរ៍មកដែរ។

ឃ) ព្រះជាម្ចាស់មិនត្រឹមតែបានបណ្ដាលចិត្តឲ្យអ្នកនិពន្ធនូវបទគម្ពីរតាមរបៀបពិសេសមួយប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បណ្ដាលចិត្តឲ្យអ្នកប្រាជ្ញដែលធ្វើការបកប្រែអត្ថបទគម្ពីរទៅជាភាសាផ្សេងៗ ដើម្បីឲ្យការបកប្រែទាំងអស់ សុទ្ធតែអាចទុកចិត្តបានទាំងស្រុង។

ង) អក្សរសិល្ប៍អំពីអវសានលោកីយ៍ខ្លះ ដូចជាអក្សរសិល្ប៍ អាប៉ូគ្រីហ្វា (Apocrypha) ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងបញ្ជីកណ្ឌគម្ពីរសម្ព័ន្ធចាស់ផងដែរ។

ច) គម្ពីរសម្ព័ន្ធមេត្រីចាស់របស់យើង គឺដូចគ្នាទៅនឹងគម្ពីរហេប្រឺដែរ។

ឆ) បញ្ជីកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ មាន៣៩កណ្ឌ ហើយសម្រាប់គម្ពីរសម្ព័ន្ធមេត្រីថ្មីមាន ២៧ កណ្ឌ។

ឃ. ការបកស្រាយបទគម្ពីរ

វត្ថុបំណងទី៤. *ប្រាប់អំពីវិធីសាស្ត្រដែលត្រូវដើម្បីវិភាគវែកញែក និង បកប្រែបទគម្ពីរ។*

ប្រហែលជានៅពេលដែលអ្នកអានបទគម្ពីរ អ្នកបានកត់សំគាល់ឃើញថា ខគម្ពីរខ្លះ និង ទិដ្ឋភាពខ្លះនៃបទគម្ពីរ មើលទៅដូចជាមិនបានបង្រៀនច្បាស់ អំពីសកម្មភាព និង បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ។ បទគម្ពីរទាំងនោះ ក៏មិនបានបង្ហាញពីអ្វីដែលទ្រង់បានរំពឹងទុកពីយើងរាល់គ្នាដែរ។ អ្នកអាចនឹង រកមិនឃើញការលើកឡើងអំពីព្រះជាម្ចាស់ផងដែរ។ ខ្ញុំតែងតែឆ្ងល់ណាស់ ឧទាហរណ៍តើកណ្ឌគម្ពីរសាស្តាអាចនឹងមានតម្លៃអ្វីទៅ ហើយតើហេតុអ្វីបានជាគម្ពីរនេះត្រូវបានរាប់បញ្ចូលទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ មានការលើកឡើងជាច្រើននៅក្នុងគម្ពីរនេះ ដែលផ្ទុយចាកពីសេចក្ដីបង្រៀននៅក្នុងទិដ្ឋភាពដទៃទៀតក្នុងបទគម្ពីរតែម្ដង។ នៅពេលដែលអ្នកអានកណ្ឌគម្ពីរនេះ អ្នកនឹងឃើញថាប្រធានបទ "អ្វីៗទាំងអស់សុទ្ធតែឥតន័យឥតខ្លឹមសារ" (១:២) មានចាក់ស្រេះនៅទូទាំងកណ្ឌគម្ពីរតែម្ដង។

នៅពេលដែលយើងបានអានទៅដល់ខគម្ពីរឬ ទិដ្ឋភាពនៃបទគម្ពីរបែបនេះ យើងត្រូវវិភាគបទគម្ពីរទាំងនោះដោយប្រុងប្រយ័ត្ន ដើម្បីធ្វើការបកស្រាយឲ្យបានត្រឹមត្រូវ។ យើងត្រូវអានអ្វីដែលនៅខាងមុខ និងអ្វីដែលនៅបន្ទាប់ពីខគម្ពីរទាំងនោះ។ នៅក្នុងករណីគម្ពីរសាស្តានេះ យើងមិនត្រូវកាត់

ផ្តាច់ប្រយោគទាំងនេះ ចេញពីកណ្ឌគម្ពីរទាំងមូល ឬ ព្រះគម្ពីរទាំងមូល ហើយយកប្រយោគទាំងនោះទៅប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតរបស់យើងនោះឡើយ។ យើងត្រូវអានកណ្ឌគម្ពីរសាស្តា ទាំងមូលដើម្បីបានយល់ពីអ្វីទៅជា "ភាពឥតន័យឥតខ្លឹមសារ" នោះ។ នៅពេលដែលយើងអានទៅដល់ជំពូកចុងក្រោយនៃកណ្ឌគម្ពីរនេះ សាររបស់កណ្ឌគម្ពីរទាំងមូលនឹងបានបង្ហាញឲ្យឃើញច្បាស់។ អ្នកនិពន្ធបានចង្អុលបង្ហាញយ៉ាងច្បាស់ៗថា *ពេលដាច់ចេញពីព្រះជាម្ចាស់* ជីវិតគឺពិតជាឥតប្រយោជន៍ និង ឥតន័យឥតខ្លឹមសារឡើយ។ បទពិសោធន៍បានបង្រៀនមេរៀនមួយទៅដល់គាត់ ដែលគាត់ស្វែងរកមធ្យោបាយដើម្បី បញ្ជូនបន្តមកកាន់យើងរាល់គ្នា ក្នុងទម្រង់ជាការណែនាំដ៏មានប្រយោជន៍៖

> ក្នុងពេលដែលអ្នកនៅក្មេងនៅឡើយ ត្រូវនឹកដល់ព្រះអាទិករបស់អ្នក ..... ត្រូវគោរពកោតខ្លាចព្រះជាម្ចាស់ ហើយកាន់តាមបទបញ្ជារបស់ព្រះអង្គ។ នេះហើយជាការដែលមនុស្សគ្រប់ៗរូបត្រូវធ្វើ។ ព្រះជាម្ចាស់នឹងវិនិច្ឆ័យកិច្ចការទាំងប៉ុន្មាន ដែលមនុស្សធ្វើទោះបីជាអំពើដែលគេធ្វើដោយលាក់កំបាំង ហើយជាការល្អ ឬអាក្រក់ក្តី។ (១២:១, ១៣-១៤)

ឧទាហរណ៍នេះ បង្រៀនយើងពីគោលការណ៍ដ៏មានតម្លៃមួយ៖ គ្រប់ទាំងបទគម្ពីរនីមួយៗ ត្រូវតែធ្វើការវិភាគ និង បកស្រាយនៅក្នុងពន្លឺនៃសេចក្តីបង្រៀនរបស់ព្រះគម្ពីរទាំងមូល។ ប្រសិនបើយើងរៀន និង ប្រើប្រាស់គោលការណ៍នេះ យើងនឹងកសាងជីវិតជាគ្រិស្តបរិស័ទរបស់យើង នៅលើគ្រឹះដ៏រឹងមាំមួយ។ យើងមិនហ៊ាន យកជីវិតរបស់យើង និង សកម្មភាពរបស់យើងទៅផ្អែកលើខគម្ពីរ ឬ អត្ថបទដកស្រង់ដាច់ដោយឡែកណាមួយឡើយ។ ប្រសិនបើយើងមិនដើរតាមគោលការណ៍នេះទេ យើងអាចមានបង្ហាញធ្ងន់ធ្ងរជាក់ជាមិនខាន។

ព្រះជាម្ចាស់ជួយយើងឲ្យបានយល់សេចក្តីបង្រៀននៃព្រះបន្ទូលរបស់ទ្រង់។ ព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់ មិនត្រឹមតែបានបណ្តាលចិត្តមនុស្សដែលបានសរសេរបទគម្ពីរប៉ុណ្ណោះទេ តែទ្រង់ក៏*បំភ្លឺ*គំនិតរបស់អស់អ្នកដែលអានបទគម្ពីរនោះផងដែរ។ នេះគឺមានន័យថា ព្រះវិញ្ញាណ*ជះពន្លឺ*នៅក្នុងគំនិតរបស់អ្នកជឿ ឲ្យយល់ពីអ្វីដែលពួកគេអាន។ បើគ្មានជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ គ្មាននរណាម្នាក់អាចយល់បទគម្ពីរត្រឹមត្រូវនោះទេ ព្រោះអំពើបាបបានធ្វើឲ្យគំនិតរបស់ពួកគេខ្មៅងងឹតទៅហើយ។ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិតនៅក្នុងពួកយើងហើយ ទ្រង់ធ្វើឲ្យយើងដឹងយ៉ាងច្បាស់អំពីសេចក្តីពិតដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយទ្រង់ជួយយើងឲ្យបកប្រែបទគម្ពីរបានយ៉ាងត្រឹមត្រូវ។ (សូមមើលនៅក្នុងគម្ពីររ៉ូម១:២១ គម្ពីរអេភេសូ ១:១៨; ៤:១៨ គម្ពីរ១កូរិនថូស ២:៦-១៦ និង គម្ពីរ១យ៉ូហាន២:២០,២៧)។

បន្ទាប់មក យើងឃើញថាព្រះគម្ពីរគឺជាការបើកសម្តែងរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សជាតិ។ ស្របពេលដែលការលើកឡើងខ្លះ ដែលមានកត់ត្រានៅក្នុងព្រះគម្ពីរមើលទៅហាក់បីដូចជាមានភាពផ្ទុយគ្នាក៏ដោយ តែនៅពេលដែលធ្វើការបកស្រាយនៅក្នុងពន្លឺនៃព្រះគម្ពីរទាំងមូល ការលើកឡើងទាំងអស់នោះនឹងមានន័យច្បាស់លាស់។ លើសពីនេះទៅទៀត ព្រះវិញ្ញាណដ៏វិសុទ្ធទ្រង់បានបំភ្លឺគំនិតរបស់យើង ដើម្បីឲ្យយើងអាចបកស្រាយព្រះបន្ទូលរបស់ព្រះជាម្ចាស់បានយ៉ាងត្រឹមត្រូវ ហើយព្រមទាំងយល់អំពីមេរៀនដែលទ្រង់សព្វព្រះទ័យបង្រៀនយើង។

លំហាត់អនុវត្តន៍

១២ ចូរបំពេញប្រយោគ៖ បទគម្ពីរនីមួយៗត្រូវតែទទួលការវិភាគ និង បកស្រាយនៅក្នុងពន្លឺ និង សេចក្តីបង្រៀននៃ.....

៦. សិទ្ធិអំណាចរបស់បទគម្ពីរ

វត្ថុបំណងទី៥. *ប្រាប់ថាតើព្រះបន្ទូលរបស់ព្រះជាម្ចាស់ គួរតែមានអំណាចនៅក្នុងត្រង់កន្លែងណាក្នុងជីវិតរបស់យើង។*

សំណួរដ៏មានសារៈសំខាន់មួយបានលេចឡើង នៅពេលយើងសិក្សាព្រះគម្ពីរ។ តើមានសារៈសំខាន់ប្រភេទណា ដែលអ្នកនឹងផ្តល់ទៅកាន់ព្រះគម្ពីរ បើគិតទាក់ទងនឹងជីវិត និង ឆន្ទៈរបស់យើង? បទគម្ពីរបានបង្ហាញតាំងពីដំបូងរហូត ដល់ចុងបញ្ចប់ អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងបញ្ហាមួយនេះ។ យើងដឹងថាបទគម្ពីរគឺ ត្រូវតែជាសិទ្ធិអំណាចចុងក្រោយបង្អស់ នៅក្នុងបញ្ហាខាងឯជំនឿ និង ការប្រតិបត្តិ (គម្ពីរ ២ធីម៉ូថេ ៣:១៦-១៧)។

កាលពីដើមឡើយ នៅក្នុងការទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយមនុស្ស ព្រះជាម្ចាស់ទ្រង់បានបង្ហាញ បំណងព្រះហឫទ័យ និង គោលបំណងរបស់ទ្រង់។ ទ្រង់ក៏អនុញ្ញាតឲ្យមនុស្សរបស់ទ្រង់ ដឹងថាទ្រង់បានរំពឹងឲ្យពួកគេស្គាល់ ក្រឹត្យវិន័យរបស់ទ្រង់ និង អនុវត្តទៅតាមក្រឹត្យវិន័យនោះ ៖ "ចំណែកឯអ្នករាល់គ្នាវិញ ត្រូវកាន់ និងប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបង្គាប់ដល់អ្នករាល់គ្នា ដោយឥតបន្ថែម ឬបន្ថយអ្វីឡើយ (គម្ពីរទុតិយកថា ១២:៣២) ។ ទ្រង់ថែមទាំងបានមានព្រះបន្ទូល ថាទ្រង់អាចនឹងល្បងលពួកគេដើម្បីឃើញថា តើពួកគេយល់ពីព្រះបន្ទូលរបស់ទ្រង់ ហើយធ្វើតាមព្រះបន្ទូលនោះដែរឬទេ (គម្ពីរទុតិយកថា ១៣:៣)។

ចុះប្រសិនបើមានព្យាការី ឬ អ្នកបកស្រាយសុបិន្តម្នាក់បានអញ្ជើញមកក្នុងតំបន់របស់អ្នក ព្រមទាំងបានធ្វើការអស្ចារ្យ ឬ បំពេញតាមសេចក្តីសន្យាតាមរបៀបពិសេសអស្ចារ្យមួយ។ តើការនោះនឹងអាចធ្វើឲ្យគាត់ ក្លាយជាព្យាការីដ៏ពិតម្នាក់ដែរឬទេ? មិនអាចទេ លុះត្រាតែអ្វីដែលបុគ្គលនោះនិយាយ គឺយោងទៅតាមអ្វីដែលព្រះជាម្ចាស់បានបង្រៀន នៅក្នុងព្រះបន្ទូលរួចមកហើយ (សូមមើល គម្ពីរទុតិយកថា ១៣:១-៣)។

គោលការណ៍នេះ គឺត្រូវបានលើកយកមកនិយាយម្តងហើយម្តងទៀត នៅពាសពេញបទគម្ពីរទាំងមូលតែម្តង។ យើងមិនត្រូវធ្វើឲ្យវង្វេង ដោយសារតែអច្ឆរិយវត្ថុ ទីសំគាល់ ការអស្ចារ្យ ដែលទាំងនេះគឺគ្រាន់តែជាការកំសាន្ត ឬ អ្វីដែលទាញយើងចេញពីសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នោះឡើយ។

មធ្យោបាយសម្រាប់យើងដើម្បីបន្តទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវគឺការរស់នៅតាមព្រះបន្ទូលរបស់ទ្រង់ ៖ « បើអ្នករាល់គ្នាកាន់តាមបញ្ញត្តិរបស់ខ្ញុំ នោះអ្នកនឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ » (យ៉ូហាន ១៥:១០) ។ យើងអាចបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះគ្រិស្ត ដោយការគោរពតាមព្រះហឫទ័យរបស់ទ្រង់ដែលបានបើកសម្តែង៖ « បើអ្នកធ្វើតាមសេចក្តីដែលខ្ញុំបង្គាប់អ្នករាល់គ្នា ជាមិត្តសម្លាញ់របស់ខ្ញុំហើយ» (យ៉ូហាន ១៥:១៤)។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាសេចក្តីពិត (គម្ពីរយ៉ូហាន ១៧:១៧)។ ដូច្នេះហើយ យើងត្រូវធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្លាយទៅជាសិទ្ធិអំណាចខ្ពស់ជាងគេនៅក្នុងជីវិតផ្ទាល់ខ្លួន និង ជីវិតរួមក្រុមជំនុំរបស់អ្នក។ នៅក្នុងអគារព្រះវិហាររបស់យើងជាច្រើន យើងបានដាក់ផទិកាចំណុចកណ្តាលនៃប្លង់ព្រោះតែកន្លែងនោះជាកន្លែងដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រូវបានចែកចាយ។ ការនេះបង្ហាញឲ្យឃើញពីអ្វីដែលអ្នកនិពន្ធ ដាវីឌ បានមានប្រសាសន៍ថា៖ "ដ្បិតទ្រង់បានដំកើងព្រះបន្ទូលទ្រង់ឲ្យធំលើសព្រះនាមទ្រង់ទៅទៀត" (គម្ពីរទំនុកតម្កើង ១៣៨:២ គម្ពីរ ពគប)។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺត្រូវដើរមុន គ្រប់ទិដ្ឋភាពនៅក្នុងជីវិតរបស់យើង។ យើងត្រូវបានដាក់សេចក្តីបង្រៀនរបស់ព្រះបន្ទូល នៅលើអ្វីដែលជារបស់គ្រួសារ និង មិត្តភក្តិ។ យើងត្រូវបានផ្តោតការយកចិត្តទុកដាក់ ទៅលើការព្រមាន និង ការដឹកនាំរបស់ព្រះបន្ទូល។ ព្រះបន្ទូលត្រូវតែគ្រប់គ្រងលើអារម្មណ៍របស់យើង។

ដូច្នេះ តើការដែលមានសេចក្តីបង្រៀនព្រះគម្ពីរដ៏រឹងមាំនៅក្នុងក្រុមជំនុំរបស់យើងនោះ មានសារៈសំខាន់យ៉ាងណាទៅ? យើងត្រូវជំរុញឲ្យមានសេចក្តីស្រឡាញ់នៅក្នុងដួងចិត្តរបស់អ្នកជឿ ទៅចំពោះសិក្សាជាលក្ខណៈប្រព័ន្ធ អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មនុស្សម្នាគួរតែចូលមករួមគ្នា នៅក្នុងដំណាក់របស់ព្រះជាម្ចាស់ មិនគ្រាន់តែសម្រាប់កម្មវិធី ឬ រឿងបុគ្គលណានោះទេ ប៉ុន្តែដោយសារពួកគេស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ។

> ស្មៅតែងតែក្រៀម ហើយផ្កាក៏ស្រពោន ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះនៃយើង នៅស្ថិតស្ថេរអស់កល្បជានិច្ច។ (គម្ពីរអេសាយ ៤០:៨)

លំហាត់អនុវត្តន៍

១៣ ដោយយោងទៅតាមអ្វីដែលយើង បានរៀននៅក្នុងចំណុចនេះ ចូរបកស្រាយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ថាតើសិទ្ធិអំណាចនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺតែងមានកន្លែងនៅត្រង់ណាក្នុងជីវិតរបស់យើង។

ការប្រឡងឆ្លាស់ខ្លួន

ផ្គូផ្គង។

១ ចូរផ្គូផ្គងពាក្យនីមួយៗ (ខាងស្តាំ) ទៅជាមួយនឹងនិយមន័យរបស់វា (ខាងឆ្វេង)។

.....ក) ការបញ្ជូនបន្តរឿងរ៉ាវ ដែលមិនមែនជាសំណេរ ពីជំនាន់មួយទៅជំនាន់មួយទៀត។

.....ខ) អ្វីដែលកើតមានឡើងនៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងឲ្យបានយល់ពីបទគម្ពីរ

.....គ) ជាសំណេរដើមដំបូងបង្អស់នៃបទគម្ពីរ

.....ឃ) ជាសកម្មភាពពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធក្នុងការដឹកនាំអ្នកនិពន្ធដែលបានសរសេរកណ្ឌនៃព្រះគម្ពីរ។

.....ង) ការលាតត្រដាងអំពីព្រះជាម្ចាស់ដោយអង្គទ្រង់ផ្ទាល់ និង សកម្មភាពរបស់ទ្រង់ ដែលពីមុនមកគ្មាននរណាម្នាក់បានដឹង

.....ច) ជាសំណេរដែលមានលក្ខណៈជាការប្រកាសទុកមុននូវព្រឹត្តិការណ៍ដ៏ហិង្សា និង ការបែកបាក់នៃលោកីយ៍

.....ឆ) ប្រព័ន្ធនៃរង្វាស់ដែលផ្អែកទៅលើលក្ខណៈវិនិច្ឆ័យជាក់លាក់ណាមួយ ដើម្បីកំណត់ថាបញ្ជីកណ្ឌគម្ពីរណាដែលត្រូវបានបណ្តាលចិត្តពីព្រះជាម្ចាស់។

១) អក្សរសិល្ប៍អរិសានលោកីយ៍
២) សំណេរដើម
៣) ប្រពៃណីនិយាយតៗគ្នា
៤) បញ្ជីកណ្ឌគម្ពីរ
៥) ការបណ្តាលចិត្តឲ្យតែង
៦) ការបំភ្លឺ
៧) ការបើកសម្តែង

ត្រូវ/ខុស។ ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅខាងមុខប្រយោគដែលមិនត្រឹមត្រូវ។

.....២ ក្រុមជំនុំគឺជាសិទ្ធិអំណាចចុងក្រោយបង្អស់ នៅក្នុងបញ្ហា ជំនឿ និង ការប្រតិបត្តិ។

.....៣ ដើម្បីយល់ពីសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងត្រូវតែធ្វើការវិភាគ និង បកស្រាយយ៉ាងប្រុងប្រយ័ត្ន ចំពោះអ្វីដែលបានសរសេរនៅក្នុងពន្លឺនៃសេចក្តីបង្រៀនដែលមាននៅក្នុងព្រះគម្ពីរទាំងមូល។

.....៤ ការបណ្តាលចិត្តឲ្យតែងសម្រាប់បទគម្ពីររួមមាន សំណេរដើម ច្បាប់ចម្លងនៃសំណេរដើម ការបកប្រែ និង កំណែថ្មីផ្សេងៗ។

.....៥ យើងមានការអះអាងបញ្ជាក់ថាព្រះគម្ពីររបស់យើងគឺពិតជាអាចទុកចិត្តបានថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រោះយើងឃើញពីភស្តុតាងដែលព្រះជាម្ចាស់បានរក្សាទុកសំណេរយ៉ាងសុក្រឹត ឆ្លងកាត់ជាច្រើនជំនាន់។

.....៦ គ្រប់កណ្ឌគម្ពីរទាំងអស់ ដែលត្រូវបានទទួលស្គាល់នៅក្នុង បញ្ជីកណ្ឌគម្ពីរ គឺត្រូវបានគេទទួលស្គាល់ថាជាការបណ្តាលចិត្តឲ្យតែងមកពីព្រះជាម្ចាស់។

.....៧ *ភាពផ្តាច់មុខ* នៃបទគម្ពីរមានន័យថា នៅក្នុងកណ្ឌគម្ពីរទាំង៦៦កណ្ឌ យើងទទួលបានការបើកសម្តែងជាការសរសេរយ៉ាងពេញលេញរបស់ព្រះជាម្ចាស់។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៧ ក) គម្ពីរយ៉ូហាន ១៦:១២-១៥

ខ) ការដឹកនាំ និង ការបំភ្លឺផ្លូវរបស់ព្យាការី និង សេចក្តីបង្រៀនបន្ថែមទៀត។

គ) គម្ពីរអេភេសូ ៣:៤-៥, ៩-១០ គម្ពីរ២ពេត្រុស ៣:១៥-១៦ គម្ពីរ២ពេត្រុស ១:២០-២១

១ ការបើកសម្តែងទាក់ទងនឹងព្រះជាម្ចាស់ មានន័យថា ព្រះជាម្ចាស់បានបង្ហាញទៅកាន់មនុស្ស អំពីអ្វីដែលពួកគេមិនអាចដឹងដោយខ្លួនឯង អំពីទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់។

៨ ព្រោះយើងនឹងដឹងថា យើងត្រូវច្រានចោលការបើកសម្តែងទាំងឡាយណាដែលមកតាមក្រោយដោយការបើកសម្តែងទាំងនោះ មិនស្របទៅតាមអ្វីដែលព្រះជាម្ចាស់បានបង្ហាញរួចមកហើយនោះទេ ហើយការបើកសម្តែងទាំងនោះក៏មិនថ្វាយសិរីរុងរឿងដល់ទ្រង់ដែរ។

២ ក) និង ឃ) គឺជាចម្លើយត្រឹមត្រូវ។

៩ ក) ប្រហែលឆ្នាំ៥០០ មុនគ.ស ដោយលោកអែសរ៉ា និង សមាជិកនៅក្នុងមហាសាលាប្រជុំ។

ខ) ឆ្នាំ៣៩៧ គ.ស ដោយក្រុមប្រឹក្សា ក្រុងកាថែត។

៣ ក) "ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកម៉ូសេថា៖ «ចូរកត់ត្រាព្រឹត្តិការណ៍នេះក្នុងក្រាំងមួយ ...."

ខ) "លោកម៉ូសេបានកត់ត្រាទុកនូវព្រះបន្ទូលទាំងប៉ុន្មានរបស់ព្រះអម្ចាស់។"

គ) "ទ្រង់មានព្រះបន្ទូលថា" (លោកអេសាយគឺជាអ្នកសរសេរ)

ឃ) "ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈលោកយេរេមាដូចតទៅ"

ង) "ព្រះអម្ចាស់មានព្រះបន្ទូលថា"

ច) "ប្រសិនបើនរណាម្នាក់នឹកស្មានថា ខ្លួនជាអ្នកថ្លែងព្រះបន្ទូល ឬស្មានថា ខ្លួនជាអ្នកទទួលអំណោយទានពីព្រះវិញ្ញាណ ត្រូវអោយអ្នកនោះទទួលស្គាល់ថា សេចក្តីដែលខ្ញុំសរសេរជូនមកបងប្អូននេះ ក៏ជាបទបញ្ជារបស់ព្រះអម្ចាស់ដែរ"

ឆ) "លោកប៉ូលជាបងប្អូនដ៏ជាទីស្រឡាញ់របស់យើង បានសរសេរមកជូនបងប្អូន តាមប្រាជ្ញាដែលព្រះជាម្ចាស់ប្រទានអោយលោកស្រាប់ហើយ។" (សូមសំគាល់មើល ខ១៦ ដែលលោកពេត្រុសទទួលស្គាល់អ្វីដែលលោកប៉ូលបានសរសេរ ថាជាបទគម្ពីរ។)

១០ សំណេរទាំងនោះត្រូវតែសរសេរឡើង ឬ គាំទ្រដោយសាវ័កមួយរូប។ ខ្លឹមសារនៅក្នុងសំណេរនោះត្រូវតែមានលក្ខណាខាងឯវិញ្ញាណ ដែលបង្ហាញថាសំណេរគឺពិតជាទទួលបានការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់មែន។ សំណេរនោះត្រូវតែបានទទួលស្គាល់ដោយក្រុមជំនុំទាំងមូល ថាជាការបណ្តាលចិត្តឲ្យតែងពីព្រះជាម្ចាស់។

៤ ខ) ការផ្តល់សិទ្ធិអំណាច ជាក់លាក់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់កិច្ចការដ៏ជាក់លាក់មួយ

ឃ) ការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅលើមនុស្សដែលត្រូវបានជ្រើសតាំងឲ្យកត់ត្រាអំពីការបើកសម្តែងរបស់ព្រះជាម្ចាស់ ទាក់ទងនឹងអង្គទ្រង់ផ្ទាល់ ព្រមទាំងផែនការរបស់ទ្រង់ផងដែរ។

ច) ខ្លឹមសារ ទាំងអស់នៃបទគម្ពីរ រួមទាំងធាតុផ្សំដែលត្រូវបានជ្រើសរើសយកមកដាក់បញ្ចូល និង ពាក្យពេចន៍ដែលត្រូវបានជ្រើសរើស។

១១ ខ), គ),ច) និង ឆ) ជាចម្លើយត្រឹមត្រូវ។

៥ ទោះបីជាតាមប្បធម៌ ត្រូវតែបំបាក់ឆ្អឹងដើម្បីពន្លឿនការស្លាប់របស់អ្នកដែលត្រូវគេឆ្កាងក៏ដោយ តែគេមិនចាំបាច់បំបាក់ឆ្អឹងរបស់ព្រះយេស៊ូឡើយ ព្រោះពួកទាហានបានឃើញថាទ្រង់បានសុគតរួចទៅហើយ ដូច្នេះផ្ទុយទៅវិញ ពួកគេបានចាក់ទម្លុះឆ្អឹងជំនីម្ខាងរបស់ទ្រង់ជាមួយនឹងលំពែងវិញ

១២ ព្រះគម្ពីរទាំងមូល ឬ ទាំងស្រុង។

៦ ក) ព្រះយេស៊ូបានបង្ហាញការគោរព និង ទទួលស្គាល់បទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ បទទំនាយនៅក្នុងព្រះគម្ពីរជាច្រើន ត្រូវបំពេញរួចទៅហើយ។ មានការរួបរួមមួយនៅក្នុងសាច់រឿងក្នុងព្រះគម្ពីរ។

ខ) ទ្រង់បានដកស្រង់យកបទគម្ពីរមកមានព្រះបន្ទូលជារឿយៗ។

គ) ឧទាហរណ៍មួយគឺ កន្លែងដែលព្រះយេស៊ូប្រសូត ដែលត្រូវបានប្រាប់ទុកជាមុនដោយ ព្យាការីមីកា ។ មួយទៀតគឺរបៀបដែលទ្រង់សុគត ត្រូវបានប្រាប់ទុកជាមុនដោយ ព្យាការីអេសាយ និង លោកដាវីឌ។

ឃ) ការប្រោសលោះមនុស្សជាតិ។

១៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយដូចតទៅនេះ៖ ព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់គួរតែជាសិទ្ធិអំណាចចុងក្រោយរបស់យើងនៅក្នុង បញ្ហានៃជំនឿ (ការជឿ)របស់យើង និង ការប្រតិបត្តិរបស់យើង។ ព្រះគម្ពីរគួរតែបានដឹកនាំទង្វើ គំនិត និង អារម្មណ៍របស់យើង។ យើងត្រូវសិក្សាព្រះគម្ពីរ ដោយចិត្តស្មោះត្រង់ និង យកសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទៅដាក់ក្នុងជីវិតរបស់យើងទាំងស្រុង។

មេរៀនទី ៩ ក្រុមជំនុំ៖ សហគមន៍នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់

តើអ្នកដែលមើលទៅកាន់ក្មេងលេងជាមួយគ្នា ហើយសំគាល់ឃើញពីភាពធម្មតាដែលពួកគេនៅជាមួយគ្នានោះដែរឬទេ? ការនេះបង្ហាញថា មនុស្សគឺជាភាវៈនៃសង្គម ហើយតាមធម្មជាតិរបស់យើង យើងត្រូវបង្កើតទំនាក់ទំនង និង មានការប្រកបរួបរួមជាមួយនឹងមនុស្សដទៃទៀតដែលដូចនឹងយើង។ ដូច្នេះហើយមិនចាំបាច់ឆ្ងល់ទេថា តើហេតុអ្វីបានជាព្រះយេស៊ូបង្កើតសហគមន៍នៃមនុស្សដែលមានគំនិតដូចគ្នា ដែលជាក្រុមជំនុំរបស់ទ្រង់នោះ នោះក៏ដើម្បីឲ្យតាមរយៈសហគមន៍នេះ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អាចនឹងបានសម្រេច។ ក្រុមជំនុំ គឺជាសហគម៍នៃមនុស្សរបស់ព្រះជាម្ចាស់ដែលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ដោយផ្អែកលើទំនាក់ទំនង់ផ្ទាល់ខ្លួនរបស់ពួកគេជាមួយនឹងព្រះយេស៊ូគ្រិស្ត។

លោកពេត្រុសបានប្រកាសថា៖ "ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែឥឡូវនេះជាសាសន៍របស់ព្រះវិញ" (គម្ពីរ១ពេត្រុស ២:១០ពគប)។ ពីមុនយើងស្ថិតនៅខាងក្រៅ អំពើបាបរបស់យើងបានរារាំងយើងពីព្រះជាម្ចាស់។ ទោះជាយ៉ាងណា នៅពេលដែលយើងបានទទួលស្គាល់ព្រះគ្រិស្ត។ ទំនាក់ទំនងថ្មីមួយនេះ ក៏បាននាំយើងចូលទៅក្នុងទំនាក់ទំនងថ្មីជាមួយនឹងអ្នកជឿដទៃទៀត។ យើងបានក្លាយជាទិដ្ឋភាពមួយនៃគ្រួសាររបស់ព្រះជាម្ចាស់ គឺក្រុមជំនុំរបស់ទ្រង់នោះឯង។

នៅក្នុងមេរៀននេះ យើងនឹងសិក្សាឧបករណ៍ដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីថ្វាយសិរីរុងរឿងទៅដល់ទ្រង់ ដើម្បីបីបាច់រក្សាជីវិតខាងឯវិញ្ញាណ និង ដើម្បីចែកចាយដំណឹងល្អនេះទៅកាន់មនុស្សដទៃទៀត។ នៅពេលដែលយើងកំពុងសិក្សាអំពីក្រុមជំនុំ និង ស្វែងយល់អំពីអត្ថន័យដ៏ពិតរបស់ក្រុមជំនុំ យើងនឹងអាចឃើញពីតម្លៃដែលព្រះអម្ចាស់បានដាក់ឲ្យក្រុមជំនុំ ដែលនាំឲ្យទ្រង់ឈានទៅដល់ការលះបង់ព្រះជន្មរបស់ទ្រង់ដើម្បីក្រុមជំនុំនោះ (គម្ពីរអេភេសូ ៥:២៥)។

គោលបំណងមេរៀន

ក. អ្វីដែលជាក្រុមជំនុំ
ខ. ពេលដែលក្រុមជំនុំចាប់ផ្តើម
គ. លក្ខណៈរបស់ក្រុមជំនុំ
ឃ. អ្វីដែលក្រុមជំនុំធ្វើ

ខគ្គុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់និយមន័យនៃពាក្យក្រុមជំនុំ និង បែងចែករវាងនិយមដែលមាននៅក្នុងព្រះគម្ពីរ និង និយមន័យដែលនៅក្រៅពីព្រះគម្ពីរ។
២. ប្រាប់អំពីព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរចំនួនពីរយ៉ាង ដែលបង្ហាញពីពេលដែលក្រុមជំនុំចាប់ផ្តើមកើតមានឡើង និង ធ្វើការរៀបរាប់អំពីសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿកាលពីជំនាន់មុន
៣. ស្គាល់លក្ខណៈដែលរៀបរាប់ពីនិស្ស័យរបស់ក្រុមជំនុំ។
៤. ពិភាក្សាអំពីការចូលរួមថ្វាយបង្គំ និង បកស្រាយពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់ក្នុងពេលថ្វាយបង្គំទ្រង់។
៥. បកស្រាយពីអត្ថន័យនៃពាក្យ *កសាងឡើង* និង ទំនាក់ទំនងរវាងព្រះអំណោយទាន និង ផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ និង ក្រុមជំនុំ។
៦. បកស្រាយពីរបៀបដែលសេចក្តីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងបេសកកម្មរបស់ក្រុមជំនុំ គួរតែត្រូវបានយកទៅដាក់ឲ្យប្រតិបត្តិ(អនុវត្ត)។

សកម្មភាពក្នុងការសិក្សា

១. ដើម្បីជាបង្អែកសម្រាប់មេរៀននេះ សូមអានគម្ពីរកិច្ចការជំពូក២ គម្ពីរ១កូរិនថូស ១២:១២-៣១ គម្ពីរ រ៉ូមជំពូក១២ គម្ពីរអេភេសូ ៤:១-១៦; ៥:២២-៣៣។
២. សិក្សាតាមលំដាប់លំដោយមេរៀន ដោយផ្អែកទៅតាមក្បួនដែលបានប្រាប់នៅក្នុងមេរៀនទី១។ បើកមើលនិយមន័យពាក្យសំខាន់ទាំងឡាយណាដែលថ្មីសម្រាប់អ្នក។

ពាក្យសំខាន់

រនាំង	ការកសាងឡើង	ទំនាក់ទំនង
ការបំផុស	តួនាទី	សង្គម
សហគមន៍	បញ្ញត្តិ	ជាសាកល
ភាពរស់រវើក		

ក. អ្វីដែលជាក្រុមជំនុំ

វត្ថុបំណងទី១. *ប្រាប់និយមន័យនៃពាក្យក្រុមជំនុំ និង បែងចែករវាងនិយមន័យដែលមាននៅក្នុងព្រះគម្ពីរ និង និយមន័យដែលនៅក្រៅពីព្រះគម្ពីរ។*

លំហាត់អនុវត្តន៍

---

១ ឧបមាថា អ្នកបានលើកយកពាក្យ*ក្រុមជំនុំ* ទៅនិយាយជាមួយអ្នកដែលមិនធ្លាប់បានឮពាក្យនេះពីមុនមក ហើយគាត់សួរទៅកាន់អ្នកថា៖ "តើ*ក្រុមជំនុំ* មានន័យយ៉ាងដូចម្តេច?" ដោយយោងទៅតាមបទពិសោធន៍របស់អ្នក ចូរសរសេរចម្លើយខ្លីមួយសម្រាប់សំណួរនេះនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ប្រសិនបើអ្នកដូចជាមនុស្សភាគច្រើន ក្នុងពេលសព្វថ្ងៃនេះ អ្នកប្រហែលជាឆ្លើយទៅកាន់សំណួរខាងលើនេះថា៖ "ក្រុមជំនុំគឺជាកន្លែងសម្រាប់ឲ្យមនុស្សមកជួបជុំគ្នាដើម្បីធ្វើការថ្វាយបង្គំ។" ប្រសិនបើអ្នកចង់ឲ្យកាន់តែច្បាស់លាស់ជាងនេះទៀត អ្នកប្រហែលជានឹងឆ្លើយថា៖ "ពាក្យថា *ក្រុមជំនុំ* សំដៅទៅលើស្ថាប័នមួយដែលបង្កើតឡើងពីមនុស្សមួយក្រុមដែលនៅកន្លែងផ្សេងៗពីគ្នា ដែលប្រកាន់យកទស្សនវិស័យគោលលទ្ធិដូចគ្នា ត្រូវបានដឹកនាំដោយក្រឹត្យវិន័យដូចគ្នា និង មានគោលដៅស្រដៀងគ្នា។

ចម្លើយទាំង ពីរនេះផ្តល់ឲ្យយើងនូវគំនិតខ្លះៗ អំពីរបៀបដែលពាក្យថា *ក្រុមជំនុំ* នេះ ត្រូវបានមនុស្សជាច្រើនឲ្យនិយមន័យ ហើយចម្លើយទាំងពីរនេះ ក៏អាចចាត់ទុកថាត្រឹមត្រូវ បើគិតតាមការយល់ដឹងសម័យថ្មីទៅលើ ពាក្យនេះ។ ទោះជាយ៉ាងណា នៅពេលដែលព្រះគម្ពីរថ្លែងពីក្រុមជំនុំ នោះពាក្យនេះន័យជាក់លាក់ជាងអ្វីដែលយើងបានឃើញនៅក្នុងចម្លើយទាំងនេះទៅទៀត។

តាមការពិត ព្រះគម្ពីរមិនមែនសំដៅទៅលើ*អគារ* ណាមួយថាជាក្រុមជំនុំដូចដែលយល់ឃើញសព្វថ្ងៃនេះទេ ប៉ុន្តែសំដៅទៅលើ*មនុស្ស* ដែលប្រកបរួបរួមនៅក្នុងក្រុមជំនុំនោះវិញ។ ព្រះគម្ពីរក៏មិនបានថ្លែងអំពីក្រុមជំនុំថាជា *ស្ថាប័ន* ណាមួយផងដែរ។ សព្វថ្ងៃ មនុស្សដែលសំគាល់ពាក្យ*ក្រុមជំនុំ* ទៅតាមរបៀបនេះគឺចងភ្ជាប់ពាក្យនេះទៅជាមួយនឹង និកាយ ដូចជាកាតូលិក បាទីស្ត មេតូឌីស ឬ និកាយដទៃផ្សេងទៀត។

នៅក្នុងអត្ថន័យរបស់ព្រះគម្ពីរ មាននិយមន័យចំនួនពីរយ៉ាងសម្រាប់ពាក្យថា *ក្រុមជំនុំ* នេះ។ ពាក្យឬសគល់ដែលបានបង្កើតបានជាពាក្យក្រិកថា *អ៊ីក្លេស៊ា (ekklesia)* ដែលប្រែមកថា "ក្រុមជំនុំ" នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី បានផ្តល់ឲ្យយើងនូវរូបភាពរបស់មនុស្សដែលបានឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ។ ដោយបានឆ្លើយតបទៅនឹងការត្រាស់របស់ទ្រង់ ហើយបានទទួលស្គាល់ថាព្រះយេស៊ូគឺជាព្រះអម្ចាស់ ពួកគេបានក្លាយជាសមាជិកគ្រួសាររបស់ទ្រង់ ។ ពួកគេប្តេជ្ញាចិត្ត ចំពោះកិច្ចការចែកចាយដំណឹងល្អ ដូចដែលព្រះអម្ចាស់របស់ពួកគេបានណែនាំទៅកាន់ពួកគេ។ ពួកគេគឺជាសហគមន៍ នៃអ្នកស្តាប់បង្គាប់ ដែលបានប្រមូលផ្តុំគ្នាដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ បើមើលទៅលើរូបភាពធំមួយ សហគមន៍នៃអ្នកជឿដែលបានទទួលស្គាល់ថាព្រះយេស៊ូគឺជាព្រះអម្ចាស់ ជាតំណាងឲ្យ *ក្រុមជំនុំទូ*

ទាំងសាកល តែម្តង នោះក៏ត្រូវបានគេហៅថា *ក្រុមជំនុំឥតរូប* នោះឯង។ ពាក្យនេះ គឺបូករួមបញ្ចូលអ្នកជឿទាំងអស់ នៅគ្រប់ទីកន្លែងដែលមានជំនឿដូចគ្នាទៅលើព្រះយេស៊ូ និង មានភាពស្មោះស្ម័គ្រជាមួយទ្រង់។

បើមើលមកលើរូបភាពតូចវិញ *ក្រុមជំនុំ* គឺសំដៅទៅលើការប្រមូលផ្តុំគ្នា ឬ ការជំនុំមនុស្ស។ អ្នកទាំងនេះគឺសុទ្ធតែជាអ្នកជឿដែលមកពីកន្លែងណាមួយ ដែលមានជំនឿ និង ភាពស្មោះស្ម័គ្រដូចគ្នាទៅចំពោះព្រះយេស៊ូគ្រិស្ត និង ជាអ្នកដែលជួបជុំគ្នាដើម្បីធ្វើការថ្វាយបង្គំរួមគ្នា។ ពួកអ្នកទាំងនោះ គឺគេហៅថា *ក្រុមជំនុំតាមតំបន់* ឬ *ក្រុមជំនុំមានរូប*។ ឧទាហរណ៍ជាក់ស្តែងអំពីក្រុមជំនុំតាមតំបន់ទាំងនេះ គឺឃើញមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី៖

> សូមជំរាបមកបងប្អូនទាំងអស់នៅក្រុងរ៉ូម ជាអ្នកដែលព្រះជាម្ចាស់ស្រឡាញ់ និងត្រាស់ហៅអោយធ្វើជាប្រជាជនដ៏វិសុទ្ធ។ (គម្ពីររ៉ូម ១:៧)
>
> សូមជំរាបមកក្រុមជំនុំ*របស់ព្រះជាម្ចាស់នៅក្រុងកូរិនថូស។ ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនអោយធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ (គម្ពីរ១កូរិនថូស ១:២)
>
> សូមជំរាបមកក្រុមជំនុំទាំងឡាយនៅស្រុកកាឡាទី។ (គម្ពីរកាឡាទី ១:២)
>
> សូមជំរាបមកប្រជាជនដ៏វិសុទ្ធ*ទាំងអស់ ដែលរួមជាមួយព្រះគ្រិស្តយេស៊ូនៅក្រុងភីលីព ព្រមទាំងអស់លោកអភិបាល និងអ្នកជំនួយសូមជ្រាប។ (គម្ពីរភីលីព ១:១)

អ្វីដែលសំខាន់នោះ យើងអាចនិយាយបានថា ក្រុមជំនុំដែលត្រូវបានលើកឡើងនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី គឺជាសហគមន៍នៃមនុស្សរបស់ព្រះជាម្ចាស់។ ពាក្យថា *សហគមន៍* គឺមានសារៈសំខាន់ណាស់ក្នុងការរៀបរាប់អំពីក្រុមជំនុំ ព្រោះពាក្យនេះនិយាយអំពីបុគ្គលអ្នកជឿ ដែលរួមគ្នាក្រោមគោលបំណង ធ្វើការប្រកបគ្នា និង ចែកចាយជាមួយគ្នា នៅពេលដែលពួកគេថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា។ សហគមន៍ខាងឯវិញ្ញាណនេះ គឺត្រូវរៀបរាប់នៅក្នុងគម្ពីរ កិច្ចការ ២:៤២-៤៧។

> សិស្សទាំងនោះព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមសាវ័ក* រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំប៉័ង* និងព្យាយាមអធិស្ឋាន។ មនុស្សម្នាកោតស្ញប់ស្ញែងគ្រប់ៗគ្នា ដ្បិតក្រុមសាវ័កបានសំដែងឫទ្ធិបាដិហារិយ៍ និងធ្វើទីសំគាល់ផ្សេងៗជាច្រើន។ អស់អ្នកដែលបានជឿលើព្រះអម្ចាស់មានចិត្តគំនិតតែមួយ ហើយយករបស់របរដែលខ្លួនមាន មកដាក់រួមគ្នាទាំងអស់។ គេលក់ទ្រព្យសម្បត្តិ និងអ្វីៗជារបស់ខ្លួនយកប្រាក់មកចែកគ្នាតាមសេចក្តីត្រូវការរបស់ពួកគេម្នាក់ៗ។ ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ* ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ។

ព្រះគម្ពីរបង្រៀនថា ក្រុមជំនុំគឺជាឧបករណ៍ដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីបំពេញមុខងារទាំងនេះ៖

១. ក្រុមជំនុំ ផ្តល់ឲ្យមានការថ្វាយបង្គំរួមគ្នា (គម្ពីរយ៉ូហាន ៤:២០-២៤ ហើយប្រៀបធៀបជាមួយគម្ពីរហេប្រឺ ១០:២៥)

២. ក្រុមជំនុំផ្តល់នូវការលូតលាស់សម្រាប់វិញ្ញាណរបស់អ្នកជឿ (គម្ពីរអេភេសូ ៤:១៣-១៦)។

៣. ក្រុមជំនុំពង្រីកដំណឹងល្អ អំពីសេចក្តីសង្គ្រោះដែលមាននៅក្នុងព្រះគ្រិស្ត ទៅកាន់មនុស្សដទៃទៀត (គម្ពីរម៉ាថាយ ១៦:១៨; ២៨:១៤; ២៨:១៨-២០)។

យើងនឹងចូលទៅមើលលើតួនាទីនីមួយៗ ឲ្យបានកាន់តែពេញលេញនូវទិដ្ឋភាពក្រោយទៀតក្នុងមេរៀននេះ។

ជាញឹកញាប់ យើងឃើញពាក្យថា *ក្រុមជំនុំរបស់ព្រះជាម្ចាស់* ឬ *ក្រុមជំនុំរបស់ព្រះគ្រិស្ត* នៅក្នុងបទគម្ពីរ។ ពាក្យទាំងអស់នេះ ចង្អុលបង្ហាញថា លក្ខណៈសំខាន់នៃការជំនុំនេះ មិនមែនមកពីសមាជិកនៃក្រុមជំនុំនោះទេ ប៉ុន្តែគឺមកពីព្រះសិរសា ព្រះគ្រិស្តយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ឯណោះវិញ។

ដូច្នេះ ក្រុមជំនុំគឺជាការប្រកបរួបរួមគ្នានៃមនុស្សមានបាបដែលបានប្រោះលោះ ដោយព្រះសង្គ្រោះតែមួយ ដែលបង្កើតឡើងដោយព្រះជាម្ចាស់។ ការប្រកបរួបរួមនៃអ្នកជឿនេះ គឺមានភាពតែមួយ ព្រោះសមាជិកគ្រប់រូបគឺសុទ្ធតែជាចំណែកមួយនៅក្នុងគ្នាទៅវិញទៅមក និងនៅក្នុងព្រះគ្រិស្តផង តាមរយៈការរួមមកតែមួយដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានមក។

កំណត់ត្រាគម្ពីរសម័ន្ធមេត្រីថ្មី បានកត់ត្រាថា អ្នកជឿថ្មីត្រូវបានគេជំរុញឲ្យធ្វើតាមការទទួលស្គាល់ព្រះយេស៊ូជាព្រះអម្ចាស់របស់ពួកគេជាមួយនឹងការជ្រមុជទឹក ដែលជារូបភាពបញ្ជាក់ពីការរួបរួមរបស់ពួកគេជាមួយព្រះគ្រិស្ត (សូមមើលនៅក្នុងគម្ពីរកិច្ចការ ២:៣៨; ៨:១២-១៣; ៩:១-១៩; ១០:៤៧- ៤៨)។ អ្នកជឿថ្មី ដែលបង្កើតបានជាក្រុមជំនុំតាមតំបន់ និង ដែលជាទិដ្ឋភាពនៃក្រុមជំនុំសាកល មានលក្ខណសម្បត្តិដូចតទៅ៖

១. ពួកគេគឺជាអ្នកជឿដ៏ពិត លើព្រះយេស៊ូ។
២. ពួកគេធ្វើតាមការទទួលស្គាល់ជំនឿរបស់ពួកគេ ជាមួយនឹងការជ្រមុជទឹក។
៣. ពួកគេត្រូវបានរៀបចំឲ្យក្លាយទៅជាសហគមន៍ដែលមានការប្រកបរួបរួមគ្នា ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។ (ចូរប្រៀបធៀបគម្ពីរកិច្ចការ ១៣:៤៣ ជាមួយនឹង ១៤:២៣)
៤. ពួកគេមានគោលបំណងមួយដែលខុសពីគេ៖ គឺដើម្បីចូលរួមជាមួយគ្នា ក្នុងការថ្វាយបង្គំរួម និង ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

លំហាត់អនុវត្តន៍

២ ចូរគូសរង្វង់ជុំវិញអក្សរ នៅខាងមុខចម្លើយនីមួយៗដែលជាឃ្លាបំពេញយ៉ាងត្រឹមត្រូវ សម្រាប់ប្រយោគដូចតទៅនេះ៖ ការប្រើប្រាស់ពាក្យថា *ក្រុមជំនុំ* នៅក្នុងព្រះគម្ពីរ បានរួមបញ្ចូលគំនិត និយាយពី

ក) អគារមួយខ្នង ដែលមនុស្សជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់។

ខ) ការជំនុំមនុស្សរបស់ព្រះជាម្ចាស់ ដែលជួបគ្នា និង ចែកចាយពីជំនឿដូចគ្នា និង ភាពស្មោះស្ម័គ្រដូចគ្នា ចំពោះព្រះយេស៊ូគ្រិស្ត។

គ) ការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ នៃអ្នកជឿដែលជឿទុកចិត្តលើព្រះសង្គ្រោះដូចគ្នា និង ជាអ្នកដែលមានការរួបរួម ជាមួយគ្នាទៅវិញទៅមក ក៏ដោយសារតែការរួបរួមរបស់ពួកគេជាមួយនឹងទ្រង់។

ឃ) ក្រុមសាសនា ស្ថាប័ន ឬ និកាយគ្រប់ប្រភេទ គ្រប់ទំហំ។

ង) សហគមន៍នៅទូទាំងពិភពលោកទាំងមូល នៃអ្នកជឿដែលបានទទួលស្គាល់ជំនឿដូចគ្នាទៅលើព្រះជាម្ចាស់ និង ទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូគ្រិស្ត។

ខ. ពេលដែលក្រុមជំនុំចាប់ផ្តើម

វត្ថុបំណងទី២. *ប្រាប់អំពីភស្តុតាងនៅក្នុងព្រះគម្ពីរចំនួនពីរយ៉ាង ដែលបង្ហាញពីពេលដែលក្រុមជំនុំចាប់ផ្តើមកើតមានឡើង និង ធ្វើការរៀបរាប់អំពីសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿកាលពីជំនាន់មុន។*

គំនិតដែលនិយាយអំពីសហគមន៍នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ គឺត្រូវបានគេឃើញមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ នៅក្នុងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែលថាក្រុមគ្រួសារលោកអប្រាហាំ នឹងក្លាយទៅជាមូលហេតុដែលធ្វើឲ្យផែនដីបានចម្រើនឡើង(គម្ពីរលោកុប្បត្តិ ១២:១-៣)។ ព្រះបន្ទូលសន្យានោះត្រូវបានបញ្ជាក់នៅក្នុងពេលដែលព្រះជាម្ចាស់ប្រោសលោះប្រជាជនអ៊ីស្រាអែល ពីចំណងទាសករពីស្រុកអេស៊ីប។ បន្ទាប់មកគោលគំនិត នៃសហគមន៍ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក៏បានកាន់តែត្រូវគេផ្តោតយ៉ាងច្បាស់ថែមទៀតនៅពេលដែល ទំនួលខុសត្រូវ និង ព្រះពរដែលមាននៅក្នុងការសន្យារវាងព្រះជាម្ចាស់ និង លោកអប្រាហាំ ត្រូវបានបញ្ជាក់បង្ហាញកាន់យ៉ាងច្បាស់ឡើង (ចូលប្រៀបធៀបគម្ពីរនិក្ខមនំ ១៩:៤-៦ ជាមួយនឹង គម្ពីរលោកុប្បត្តិ ២២:១៧-១៨)។

ប៉ុន្តែនៅក្នុងប្រវត្តិសាស្ត្រគម្ពីរសម្ព័ន្ធមេត្រីចាស់ ថ្លែងថាសាសន៍អ៊ីស្រាអែលបានបរាជ័យក្នុងបេសកកម្មរបស់គេ ក្នុងការឲ្យពរទៅដល់ផែនដីតាមរយៈទីបន្ទាល់ និង គំរូរបស់គេ។ ទោះបីជា សហគមន៍នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ បានមានវត្តមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់យ៉ាងណាក្តី ក៏ពួកគេនៅតែមិនសម្រេចបាននូវគោលបំណងដែលបម្រុងសម្រាប់ពួកគេដែរ។ ប៉ុន្តែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការត្រាស់ហៅប្រជារាស្ត្ររបស់ទ្រង់ចេញពីលោកីយ៍ ដើម្បីប្រោសលោះពួកគេពីអំពើបាប និងដើម្បីប្រទានសេចក្តីសង្គ្រោះឲ្យពួកគេគឺមិនទាន់បរាជ័យនៅឡើយទេ។ បំណងព្រះហឫទ័យនេះ នឹងអាច

សម្រេចបានតាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូ ជាបុត្រជាទីស្រឡាញ់ របស់ព្រះជាម្ចាស់។

ព្រះយេស៊ូបានណែនាំផ្នត់គំនិត នៃក្រុមជំនុំដែលជាសហគមន៍ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ នៅក្នុងពេលដែលទ្រង់ធ្វើព័ន្ធកិច្ចនៅលើផែនដី។ ទ្រង់បានមានព្រះបន្ទូល ដោយប្រើប្រយោគអនាគតកាលថា៖ "ខ្ញុំនឹងសង់ក្រុមជំនុំ*របស់ខ្ញុំ" (គម្ពីរម៉ាថាយ ១៦:១៨)។ លោកប៉ុលបង្ហាញនៅក្នុងគម្ពីរអេភេសូ ១:១៩-២៣ ថា ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅស្ថានសួគ៌វិញរបស់ព្រះអម្ចាស់នៃយើង បានកើតមានឡើងតាំងពីមុនពេលដែលក្រុមជំនុំអាចបង្កើតឡើងទៅទៀត ហើយព្រះយេស៊ូក៏ត្រូវបានលើកជាព្រះសិរសារបស់សហគមន៍ដែលបានប្រោសលោះ ដែល "ព្រះអង្គបានសំដែងមហិទ្ធិឫទ្ធិនេះ ដោយប្រោសព្រះគ្រិស្តអោយមានព្រះជន្មរស់ឡើងវិញ និងអោយគង់នៅខាងស្តាំព្រះអង្គនៅស្ថានបរមសុខ។ ....ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ អោយនៅក្រោមព្រះបាទារបស់ព្រះគ្រិស្ត ព្រមទាំងប្រទានអោយព្រះអង្គគង់នៅលើអ្វីៗទាំងអស់ ធ្វើជាសិរសាលើក្រុមជំនុំ ដែលជាព្រះកាយរបស់ព្រះអង្គ។" (ខ២០, ២២- ២៣)

ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត និង ការយាងឡើងទៅស្ថានសួគ៌ ក៏ជាការចាំបាច់ ដើម្បីឲ្យទ្រង់បាន ធ្វើការដឹកនាំ ក្នុងឋានៈជាបូជាចារ្យជាន់ខ្ពស់ដ៏អស់កល្បជានិច្ច សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ (ក្រុមជំនុំ)។ លើសពីនេះទៅទៀត ទ្រង់ក៏អាចប្រទានឲ្យ ក្រុមជំនុំនូវព្រះអំណោយទាន ដែលចាំបាច់សម្រាប់ ការប្រតិបត្តិរបស់ពួកគេ (សូមមើលគម្ពីរហេប្រឺ ៤:១៤-១៦; ៧:២៥ គម្ពីរអេភេសូ ៤:៧-១២)។

លំហាត់អនុវត្តន៍

---

៣ ដោយផ្អែកទៅលើបទគម្ពីរសម្ព័ន្ធមេត្រីថ្មីនៅខាងលើ តើប្រយោគមួយណាជាចម្លើយត្រឹមត្រូវ?

ក) ព្រះគម្ពីរបង្ហាញថាក្រុមជំនុំ គឺត្រូវបានបង្កើតឡើងដោយព្រះយេស៊ូ នៅអំឡុងពេលទ្រង់ធ្វើព័ន្ធកិច្ចរបស់ទ្រង់នៅលើផែនដី។

ខ) បទគម្ពីរផ្តល់នូវភស្តុតាងដែលបង្ហាញថា ការសុគត ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅស្ថានសួគ៌របស់ទ្រង់កើតឡើងមុនពេលដែលទ្រង់អាចបង្កើតក្រុមជំនុំរបស់ទ្រង់មកម្ល៉េះ។

តាមទម្លាប់ គេបានចាត់ទុកថាក្រុមជំនុំ បានចាប់ផ្តើមជាផ្លូវការនៅថ្ងៃបុណ្យថ្ងៃទីហាសិប ទោះបីជាអ្នកជឿបានជួបជុំគ្នាតាំងពីមុនពេលនេះទៅទៀត។ សូមមើលទៅលើភស្តុតាង៖

១. មុនពេលទ្រង់យាងត្រឡប់ទៅស្ថានសួគ៌វិញ ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសាវ័ករបស់ទ្រង់ថា៖ "មិនអោយចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ «គឺត្រូវរង់ចាំទទួលព្រះវិញ្ញាណ តាមព្រះបន្ទូលសន្យារបស់ព្រះបិតា ដូចខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយថា លោកយ៉ូហានបានធ្វើពិធីជ្រមុជ*អោយគេក្នុងទឹក ប៉ុន្តែ នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ" ។ (គម្ពីរកិច្ចការ១:៤-៥ ហើយសូមអាននៅគម្ពីរយ៉ូហាន ១:៤-១២;១៦:៧-៨, ១៣-១៥)។

២. បន្ទាប់មកព្រះយេស៊ូក៏បានសន្យាថា កាលណាពួកគេបានជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធហើយ សារ៉កនឹងក្លាយជាសក្ខីភាពដែលមានអំណាចអស្ចារ្យ សម្រាប់ដំណឹងល្អ ទាំងនៅទីជិតនិងទីឆ្ងាយ។ (គម្ពីរកិច្ចការ ១:៨)។

៣. ដោយធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ពួកសាវ័ក និង អ្នកជឿដែលកំពុងអធិស្ឋាននៅបន្ទប់ខាងលើ ក៏ត្រូវបានទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានយាងចុះមកនៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប និង បានសង់ដំណាក់របស់ទ្រង់នៅក្នុងជីវិតរបស់ពួកគេម្នាក់ (គម្ពីរកិច្ចការ ២:១-៤ ប្រៀបធៀបជាមួយនឹងគម្ពីរយ៉ូហាន ៧:៣៧-៣៩ ជាមួយនឹង ១៤:១៧)។

៤. លើសពីនេះទៅទៀត នៅក្នុងថ្ងៃនោះដែរ មានមនុស្សចំនួន៣០០០ នាក់បានឆ្លើយទៅនឹងសារដំណឹងល្អ និង បានក្លាយទៅជាទិដ្ឋភាពមួយនៃសហគមន៍អ្នកជឿ។ ដូច្នេះ ក្រុមជំនុំក៏ត្រូវបានបង្កើតឡើង និង ចាប់ផ្តើមមានតួនាទីជាសហគមន៍សម្រាប់ ការសរសើរតម្កើង សម្រាប់បីបាច់ថែរក្សា និង ផ្សាព្វផ្សាយដំណឹងល្អ ឬ ធ្វើជាសក្ខីភាព។

នោះ ការយាងមកដល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ បានកំណត់សំគាល់ទីចាប់ផ្តើមនៃសករាជថ្មី ដែលអ្នកជឿទទួលបានឫទ្ធានុភាពពីព្រះជាម្ចាស់ ដើម្បីធ្វើបន្ទាល់អំពីព្រះគុណនៃការសង្គ្រោះព្រះជាម្ចាស់ និង ការត្រាស់សម្រាប់សេចក្តីសង្គ្រោះជាសាកលរបស់ទ្រង់។ កណ្ឌគម្ពីរកិច្ចការ ប្រកាសថា ចាប់តាំងពីថ្ងៃដំបូងចាប់ផ្តើមដំបូងមក ពួកអ្នកជឿបានធ្វើសកម្មភាពជាគ្រួសារ ឬ សហព័ន្ធមួយរួចទៅហើយ។ ខាងក្រោមនេះ គឺលក្ខណសម្បត្តិខ្លះៗរបស់អ្នកជឿទាំងនោះ និង លក្ខណសម្បត្តិនៃក្រុមជំនុំដំបូងបង្អស់៖

១. ពួកគេមានខ្នាតគំរូគោលលទ្ធិមួយ ដែលជាសេចក្តីបង្រៀនរបស់ពួកសាវ័ក (គម្ពីរកិច្ចការ ២:៤២)។

២. ពួកគេមានសម្ព័ន្ធភាពជាមួយអ្នកជឿដទៃផ្សេងទៀត (គម្ពីរកិច្ចការ ២:៤២)។

៣. ពួកគេប្រតិបត្តិតាមបទបញ្ជា នៃការជ្រមុជទឹក និង ពិធីលាងព្រះអម្ចាស់ (គម្ពីរកិច្ចការ ២:៤១-៤២,៤៧; សូមមើលគម្ពីរម៉ាថាយ ២៨:១៩ គម្ពីរ១កូរិនថូស ១១:២៣-២៦)។

៤. ពួកគេបានជួបជុំគ្នា ដើម្បីធ្វើការថ្វាយបង្គំ និង ការអធិស្ឋានបើកចំហជាសាធារណៈ (គម្ពីរកិច្ចការ ២:៤៦; ៤:២៣-៣១)។

៥. ពួកគេជួយដល់មនុស្សខ្វះខាត (គម្ពីរកិច្ចការ ៤:៣២-៣៥; ៦:១-៧)។

៦. ពួកគេចាត់តាំងមនុស្ស ឲ្យទៅកន្លែងផ្សេងៗដើម្បីចែកចាយដំណឹងល្អ និង បង្កើតសហគមន៍អ្នកជឿថ្មី (គម្ពីរកិច្ចការ៨:១៤-១៧; ១១:២២)។

៧. ពួកគេសិក្សាអំពីទិដ្ឋភាពមួយនៃការចែកចាយដំណឹងល្អ បូករួមទាំងមនុស្សដែលដំណឹងល្អនៅបានទៅដល់ និង ការប្រតិបត្តិរបស់គ្រិស្តបរិស័ទថ្មីថ្មោង ហើយពួកគេបានបង្កើតខ្នាតគំរូគោលលទ្ធិសំខាន់ចាំបាច់សម្រាប់គ្រិស្តបរិស័ទ (គម្ពីរកិច្ចការ១១:១-៣, ១៨; ១៥:៤-៣៥)។

លំហាត់អនុវត្តន៍

៤ ចូរឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវរឿងពីរយ៉ាងដែលបានកើតឡើងនៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប ដែលបានផ្តល់ជាភស្តុតាងបញ្ជាក់ថា ក្រុមជំនុំបានចាប់ផ្តើមនៅក្នុងថ្ងៃនោះ មិនយូរប៉ុន្មានក្រោយពេលដែលព្រះយេស៊ូបានយាងត្រឡប់ទៅស្ថានសួគ៌វិញ (សូមមើលគម្ពីរកិច្ចការ ជំពូក២)។

៥ ចូររៀបរាប់ ចេញពីការចងចាំរបស់អ្នក នូវសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿដំបូងបង្អស់ ដែលបានផ្តល់ឲ្យពួកគេនូវលក្ខណសម្បត្តិនៃក្រុមជំនុំ ឬ រូបភាពមួយដែលរួបរួមគ្នា។ ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹងតារាងដែលយើងបានផ្តល់ជូននៅចំណុចខាងលើនេះ។ តើការរៀបរាប់នេះ ស្រដៀងទៅនឹងសកម្មភាពនៃក្រុមជំនុំតាមតំបន់របស់អ្នកដែរឬទេ?

គ. លក្ខណៈរបស់ក្រុមជំនុំ

វត្ថុបំណងទី៣. *ស្គាល់លក្ខណៈដែលរៀបរាប់ពីនិស្ស័យរបស់ក្រុមជំនុំ។*

នៅពេលដែលមនុស្សទទួលស្គាល់ព្រះគ្រិស្តជាព្រះអម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធក៏ប្រទានការសង្គ្រោះសម្រាប់ពួកគេ ព្រមទាំងភ្ជាប់ពួកគេជាមួយនឹងអស់អ្នកជឿនៅក្នុងសហគមន៍មួយដែលយើងហៅថាក្រុមជំនុំ ឬ *ព្រះកាយរបស់ព្រះគ្រិស្ត* នោះផងដែរ។ នៅក្នុងព្រះគម្ពីរ ក្រុមជំនុំត្រូវបានប្រៀបប្រដូចទៅនឹងព្រះកាយ កូនក្រមុំ អគារព្រះវិហារ មែកទំពាំងបាយជូរ និង ហ្វូងចៀម។ និមិត្តសញ្ញាទាំងនេះ គឺត្រូវបានយកមកប្រើប្រាស់ជាមួយនឹងបុគ្គលអ្នកជឿផង ក្រុមជំនុំតាមតំបន់ និងក្រុមជំនុំសាកលផងដែរ។

លំហាត់អនុវត្តន៍

៦ ចូរផ្គូផ្គងពាក្យ (ខាងស្តាំ) ទៅជាមួយនឹងបទគម្ពីរដែលរៀបរាប់អំពីពាក្យនោះ (ខាងឆ្វេង)។

.....ក) គម្ពីរលូកា ១៥:៤-១០ (ហ្វូងចៀម)	១) បុគ្គលអ្នកជឿម្នាក់ៗ
.....ខ) គម្ពីរ២កូរិនថូស ១១:២ (កូនក្រមុំ)	២) ក្រុមជំនុំតាមតំបន់
.....គ) គម្ពីរ១កូរិនថូស ៣:១៦-១៧ (អគារព្រះវិហារ)	៣) ក្រុមជំនុំសាកល
.....ឃ) គម្ពីរអេភេសូ ១:២២-២៣ (ព្រះកាយ)	
.....ង) គម្ពីរហេប្រឺ ១៣:២០ (ហ្វូងចៀម)	
.....ច) គម្ពីរយ៉ូហាន ១៥:១-៥ (មែកទំពាំងបាយជូរ)	

លំហាត់នេះបង្ហាញអ្វីម្យ៉ាងអំពីលក្ខណៈរបស់ក្រុមជំនុំ។ នៅពេលដែលបុគ្គលអ្នកជឿម្នាក់ នៅតែឯងគេមិនអាចបង្កើតជាក្រុមជំនុំបានឡើយ ព្រោះក្រុមជំនុំគឺជាតួខ្លួនមួយដែលផ្តុំឡើងពីបុគ្គលអ្នកជឿជាច្រើននាក់។ ប្រសិនបើយើងសំគាល់ក្រុមជំនុំ ថាជាគ្រឹះស្ថាន ឬ ស្ថាប័នមួយ យើងនឹងរវែងយ៉ាងឆាប់រហ័ស លែងដឹងថានេះគឺជាសហគមន៍នៃអ្នកជឿ ជាអ្នកជឿដែលបាន ចូលមករកគ្នានៅក្នុងទំនាក់ទំនងយ៉ាង

ស្និតរមួត ជាមួយគ្នាទៅវិញទៅមក ដែលជាលទ្ធផលបានមកទំនាក់ផ្ងាល់ខ្លួនរបស់ពួកគេជាមួយព្រះគ្រិស្ត។ អ្នកជឿទាំងនេះ បម្រើគ្នាទៅវិញទៅមក ស្រឡាញ់គ្នាទៅវិញទៅមក និង ជួយគ្នាទៅវិញទៅមកនៅក្នុងដំណើរជាគ្រិស្តបរិស័ទ។ ដូច្នេះលក្ខណៈ របស់ក្រុមជំនុំអាចត្រូវបានបកស្រាយបានតាមរបៀបពីរយ៉ាង។ ទីមួយ គឺមានជាប់ទាក់ទងទៅនឹងទំនងទំនងរបស់អ្នកជឿជាមួយគ្នាទៅវិញទៅមក។ ទីពីរ គឺការបង្ហាញឲ្យឃើញ នូវការរួបរួមរបស់អ្នកជឿជាមួយនឹងព្រះគ្រិស្ត។

១. *ក្រុមជំនុំ ជាប់ទាក់ទងរបស់អ្នកជឿជាមួយគ្នាទៅវិញទៅមក និង ទៅជាមួយព្រះគ្រិស្ត។*

នៅពេលមនុស្សមានបាបប្រឈមមុខជាមួយនឹងដំណឹងល្អ ពួកគេគឺឈរតែឯងនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។ ជម្រើសរបស់ពួកគេ នៅក្នុងការទទួល ឬ ច្រានចោលដំណឹងល្អ គឺជាជម្រើសផ្ងាល់ខ្លួនរបស់ពួកគេ ដែលមានតែគេម្នាក់ឯងប៉ុណ្ណោះដែលធ្វើការសម្រេចបាន។ មិនថាជម្រើសរបស់ពួកគេគឺជាអ្វី ពួកគេនឹងឃើញថា មានអ្នកដទៃផ្សេងទៀតក៏បានធ្វើការជ្រើសរើសដូចគេដែរ។ ដូច្នេះទោះបីជាសេចក្តីសង្គ្រោះគឺជាកិច្ចការផ្ងាល់ខ្លួន ប៉ុន្តែការនេះនៅតែមិនមែនជាបញ្ហាបុគ្គលនោះទេ។ ការសង្គ្រោះនាំយើងឲ្យបានចូលទៅក្នុងទំនាក់ទំនងផ្ងាល់ខ្លួនជាមួយព្រះយេស៊ូគ្រិស្ត និងជាមួយអ្នកជឿដទៃផ្សេងទៀត។ ទាំងពីរនេះគឺសុទ្ធតែមានភាពចាំបាច់នៅក្នុងការលូតលាស់ខាងឯវិញ្ញាណ និង ការអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រិស្ត នៅក្នុងបុគ្គលអ្នកជឿម្នាក់ៗ។

លោកប៉ូលបាននិយាយអំពីទំនាក់ទំនងជាមួយនឹងព្រះយេស៊ូគ្រិស្ត ដែលអ្នកជឿបានចូលខ្លួនទៅក្នុងទំនាក់ទំនងនោះក្នុងពេលដែលមានសេចក្តីសង្គ្រោះ៖ "ខ្ញុំបានជាប់ឆ្កាងរួមជាមួយព្រះគ្រិស្តដូច្នេះ មិនមែនខ្ញុំទៀតទេដែលរស់នៅ គឺព្រះគ្រិស្តទេតើ ដែលមានព្រះជន្មរស់នៅក្នុងរូបកាយខ្ញុំ។ រីឯជីវិតដែលខ្ញុំរស់ជាមនុស្សនាបច្ចុប្បន្នកាលនេះ ខ្ញុំរស់ដោយមានជំនឿទៅលើព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសំរាប់ខ្ញុំ។ (គម្ពីរកាឡាទី ២:២០) ។ លោកបានថ្លែងអំពីទំនាក់ទំនងរបស់អ្នកជឿជាមួយអ្នកជឿដទៃទៀត នៅពេលដែលលោកមានប្រសាសន៍ថា "យើងជាសរីរាង្គរបស់គ្នាទៅវិញទៅមក។" (គម្ពីរអេភេសូ ៤:២៥)។ នោះគឺមានន័យថា អ្នកជឿទាំងអស់ រួមជាមួយគ្នា បង្កើតបានជាក្រុមជំនុំ។

ដូច្នេះ បើមើលចេញពីជ្រុងមួយទៅ អ្នកជឿម្នាក់ គឺជាបុគ្គលដែលរស់នៅក្នុងទំនាក់ទំនងផ្ងាល់ខ្លួនជាមួយព្រះគ្រិស្ត រួមជាមួយនឹងទំនួលខុសត្រូវផ្ងាល់ខ្លួន ទៅលើជីវិតជាគ្រិស្តបរិស័ទរបស់គាត់។ តែបើមើលចេញពីជ្រុងមួយទៀត អ្នកជឿទាំងអស់លាយឡំចូលគ្នា នៅក្នុងការរួបរួមខាងឯវិញ្ញាណមួយ ដូច្នេះហើយពួកគេក៏មានទំនាក់ទំនងជាមួយព្រះគ្រិស្ត ដែលមានទំនួលខុសត្រូវ*រួមគ្នា*ទៅចំពោះទ្រង់។

លំហាត់អនុវត្តន៍

---

៧ បទគម្ពីរបានប្រៀបធៀបទំនាក់ទំនងរវាងព្រះគ្រិស្ត និង ក្រុមជំនុំ ទៅជាមួយនឹងព្រះសិរសា និង ព្រះកាយ។ ចូរអានគម្ពីរ ១កូរិនថូស ១២: ១២-២៧ គម្ពីរអេភេសូ ១:២២-២៣; ៤:៧-១៦ និង គម្ពីរកូឡូស ១:១៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខប្រយោគត្រឹមត្រូវ ដែលនិយាយអំពីព្រះកាយរបស់ព្រះគ្រិស្ត។

ក) នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត មានទិដ្ឋភាពជាច្រើន។

ខ) ទិដ្ឋភាពខ្លះនៅក្នុងព្រះកាយ គឺមិនសូវជាសំខាន់ដូចជាទិដ្ឋភាពដទៃផ្សេងទៀតទេ។

គ) អ្នកជឿតែម្នាក់អាចលូតលាស់ នៅក្នុងភាពពេញវ័យនៃគ្រិស្តបរិស័ទដោយ មិនបាច់ជាសមាជិកដ៏សកម្មនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តឡើយ។

ឃ) អ្នកជឿម្នាក់ៗ គឺជាទិដ្ឋភាពមួយនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។

ង) ព្រះគ្រិស្តគឺជាព្រះសិរសាលើគ្រប់អ្វីៗទាំងអស់សម្រាប់ក្រុមជំនុំ ដែលជាព្រះកាយរបស់ទ្រង់។

ច) អ្នកជឿម្នាក់ៗគឺជាទំនួលខុសត្រូវរបស់ព្រះគ្រិស្តតែមួយអង្គឯង។

ឆ) ប្រសិនបើសមាជិកនៃព្រះកាយ រងទុក្ខ សមាជិកដទៃនឹងទទួលអារម្មណ៍ឈឺចាប់ និងទុក្ខសោកជាមួយពួកគេដែរ។

ជ) ព្រះអំណោយទានដែលព្រះគ្រិស្ត បានប្រទានទៅកាន់ក្រុមជំនុំ គឺចាំបាច់ ដើម្បីឲ្យសមាជិកម្នាក់ៗអាចទទួលបាននូវការលូតលាស់ផ្ទាល់ខ្លួន។

បទគម្ពីរទាំងនេះ បង្រៀនយើងថាវាមិនមែនជារឿងចៃដន្យ ដែលថានៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី ជីវិតរបស់គ្រិស្តគឺជាបទពិសោធន៍រួមគ្នាមួយ។ អ្នកជឿថ្មីថ្មោងគឺត្រូវបានទាញឲ្យចូលគ្នាបានយ៉ាងរលូននៅក្នុងការថ្វាយបង្គំ ការប្រកបគ្នា និង ការធ្វើសក្ខីភាព។ តាមរយៈការកើតជាថ្មី និស្ស័យចាស់ដ៏អាត្មានិយមរបស់ពួកគេ ត្រូវបានដកចេញ ហើយពួកគេបានក្លាយទៅជាទិដ្ឋភាពមួយនៃសហគមន៍ដែលចេះ ខ្វល់ខ្វាយពីគ្នា និង ចែករំលែកគ្នា។

ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ការដើរតួជាដៃគូជាមួយអ្នកជឿដទៃនៅក្នុងព្រះកាយ ដែលចាំឆ្លើយតបទៅនឹងព្រះសិរសា គឺជាកិច្ចការមួយដែលទាមទារការយកចិត្តទុកដាក់ខ្លាំងណាស់។ តាមពិតទៅគឺថា ពួកយើងម្នាក់ៗមានទំនួលខុសត្រូវដែលលើសពីការជ្រើសរើសផ្ទាល់ខ្លួនរបស់យើងទៅទៀត ដែលនោះគឺជាទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយនឹងព្រះសិរសា ឬតម្លៃផ្ទាល់ខ្លួនរបស់យើង។ ឥឡូវនេះយើងមានតួនាទីជាទិដ្ឋភាពមួយនៃព្រះកាយរបស់ព្រះគ្រិស្ត។ នោះហើយជាមូលហេតុដែលលោកប៉ូលបានខ្វល់ខ្វាយនឹងក្រុមជំនុំនៅក្រុងកូរិនថូសជាខ្លាំង៖

> បងប្អូនអើយ ខ្ញុំសូមទូន្មានបងប្អូនក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត*ជាព្រះអម្ចាស់នៃយើងថា ចូរមានចិត្តគំនិតតែមួយ កុំបាក់បែកគ្នាឡើយ ត្រូវចុះសំរុងគ្នាទាំងស្រុងដោយមានគំនិតតែមួយ និងមានយោបល់តែមួយ។ (គម្ពីរ១កូរិនថូស ១:១០)។
>
> ក្នុងនាមជាទិដ្ឋភាពមួយនៃក្រុមជំនុំ ដែលជាសហព័ន្ធមួយដែលមានទំនាក់ទំនងទៅជាមួយនឹងព្រះគ្រិស្ត ខ្ញុំត្រូវមានការប្រាស្រ័យជាមួយនឹងដៃគូផ្សេងទៀតនៅក្នុងព្រះគ្រិស្ត បើសិនខ្ញុំចង់ប្រាស្រ័យជាមួយនឹងទ្រង់។ បន្ទាប់មក ដូចដែលបានបង្ហាញនៅក្នុងបទគម្ពីរ ក្រុមជំនុំគឺជា *មនុស្ស* ។ មនុស្សទាំងនេះ មានទំនាក់ទំនងជាមួយនឹងព្រះគ្រិស្ត ហើយតាមរយៈទ្រង់ពួកគេមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក។

២. *ក្រុមជំនុំគឺជាការស្តែងចេញដែលអាចមើលឃើញនឹងភ្នែក នៃការរួបរួមរបស់អ្នកជឿ ជាមួយនឹងព្រះគ្រិស្ត។*

ព្រះជាម្ចាស់បានរចនា ក្រុមជំនុំតាមរបៀបមួយដែល ធ្វើឲ្យមានលក្ខណៈអាចឲ្យគេដឹងបានតាមរយៈទំនាក់ទំនងរបស់អ្នកជឿ។ ដោយសារតែ ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រិស្ត គឺជាបទពិសោធន៍ខាងឯវិញ្ញាណ នោះមធ្យោបាយតែមួយគត់ដែលអាចធ្វើឲ្យទំនាក់ទំនងនោះក្លាយជាសេចក្តីពិតដែលគេអាចមើលឃើញ គឺមានតែតាមរយៈជីវិតរបស់យើងតែប៉ុណ្ណោះ។ យើងអាច ហើយក៏បានធ្វើការប្រាប់អ្នកដទៃអំពីអ្វីដែលយើងជឿ។ ប្រសិនបើជីវិតរបស់យើង គឺត្រូវបានសំគាល់ដោយសេចក្តីមេត្តា ចិត្តសប្បុរស និង សេចក្តីស្រឡាញ់ដ៏ពិតរបស់គ្រិស្តបរិស័ទ នោះមនុស្សម្នានឹងយល់ពីគំនិតដែលថា ទំនាក់ទំនងដែលមើលមិនឃើញរបស់យើងជាមួយព្រះគ្រិស្ត គឺមានពិតប្រាកដ។ ទោះជាយ៉ាងណា ប្រសិនបើយើងមិនរស់នៅដោយផ្អែកទៅលើ ទីបន្ទាល់ដែលយើងបានថ្លែង នោះអ្នកដែលមិនមែនជាគ្រិស្តបរិស័ទអាចនឹងនិយាយថា៖ "ទង្វើរបស់អ្នក ស្តែងចេញមកយ៉ាងខ្លាំងដែលខ្ញុំមិនអាចស្តាប់ឮអ្វីដែលអ្នកនិយាយនោះទេ!"

ការនេះក៏មានពិតផងដែរ នៅក្នុងជីវិតដែលរស់នៅរួមគ្នាក្នុងសហគមន៍នៃអ្នកជឿ។ ភាពពិតនៃទំនាក់ទំនងរវាងរូបកាយ (ក្រុមជំនុំ) និង សិរិសារ (ព្រះគ្រិស្តយេស៊ូ) គឺត្រូវបានឆ្លុះឲ្យឃើញនៅក្នុងជីវិតរបស់ក្រុមជំនុំ។ នោះគឺជាមូលហេតុដែលលោកប៉ុល ក្រើនរំឭកអ្នកជឿនៅក្រុងអេភេសូ ឲ្យ "ចូរបន្ទាបខ្លួន មានចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមកដោយសេចក្តីស្រឡាញ់។ ចូរយកចិត្តទុកដាក់រក្សាឯកភាពដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្តីសុខសាន្តធ្វើជាចំណងប្រាស្រ័យទាក់ទងគ្នា។ (គម្ពីរអេភេសូ ៤:២-៣)។

នៅក្នុងជំនាន់របស់លោកប៉ុល មានរនាំងដ៏ធំមួយនៅក្នុងសង្គម ដែលបានចែកផ្តាច់សាសន៍យូដា និង សាសន៍ដទៃ ព្រមទាំងទាសករ និង អ្នកដែលកើតមកក្នុងសេរីភាព។ ក្រៅពីដំណឹងល្អ គ្មានមធ្យោបាយណាផ្សេងទៀតដែលអាចយកឈ្នះលើរនាំងទាំងនេះបានទេ ប៉ុន្តែនៅក្នុងគម្ពីរអេភេសូ ២:១១-២២ បកស្រាយថា តាមរយៈឈើឆ្កាងរបស់ព្រះគ្រិស្តអ្វីៗទាំងអស់នេះ គឺត្រូវបានផ្លាស់ប្តូរ។ ទ្រង់បានកំទេចរនាំងរវាងសាសន៍យូដា និងសាសន៍ដទៃ ហើយបានធ្វើឲ្យពួកគេក្លាយជា "បងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ* និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។" (ខ១៩)។ ទំនាក់ទំនងជាមួយនឹងព្រះគ្រិស្តបានដកចេញ ភាពខុសគ្នានៅក្នុងសង្គម និង រួបរួមមនុស្សទាំងអស់ ដែលក្លាយជាទិដ្ឋភាពមួយនៅក្នុងក្រុមគ្រួសាររបស់ព្រះជាម្ចាស់។

ក្នុងនាមជាសមាជិកនៃព្រះកាយតែមួយ មនុស្សទាំងអស់ដែលមានប្រវត្តិសាស្ត្រក្នុងសង្គមផ្សេងៗពីគ្នា បានមករួបរួមគ្នា ខាងឯវិញ្ញាណ និង គោលបំណង (សូមមើលនៅក្នុងគម្ពីរភីលីព ២:២)។ ពួកគេត្រូវមានចិត្តសប្បុរស និង សេចក្តីមេត្តាករុណាចំពោះគ្នាទៅវិញទៅមក។ ព្រះយេស៊ូបានប្រទានឲ្យការកំណត់មួយនេះ មានកម្រិតស្មើនឹង *បទបញ្ជាថ្មី*៖ ខ្ញុំអោយបទបញ្ជាថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសិស្ស*របស់ខ្ញុំមែន»។" (គម្ពីរយ៉ូហាន ១៣:៣៤-៣៥)។

ដូច្នេះយើងឃើញថា ទំនាក់ទំនងរបស់អ្នកជឿ គឺត្រូវបានសំគាល់ដោយ*សេចក្តីស្រឡាញ់*។ គោលការណ៍មួយនេះគឺមានសារសំខាន់ណាស់ ដែលអាចត្រូវបានយកទៅប្រើប្រាស់ជារង្វាស់ដ៏សុក្រឹតមួយ សម្រាប់កំណត់ទំនាក់ទំនងរបស់មនុស្សម្នាក់ជាមួយព្រះជាម្ចាស់៖ " អ្នកណាអះអាងថាខ្លួនស្ថិតនៅក្នុងពន្លឺ តែស្អប់បងប្អូន អ្នកនោះស្ថិតនៅក្នុងសេចក្តីងងឹតនៅឡើយ" (គម្ពីរ១យ៉ូហាន ២:៩)។ លោកយ៉ូហានបានបន្តទៀតថា៖

> បើនរណាម្នាក់ពោលថា "ខ្ញុំស្រឡាញ់ព្រះជាម្ចាស់" តែស្អប់បងប្អូនរបស់ខ្លួន អ្នកនោះនិយាយកុហកហើយ។ អ្នកណាមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញ ក៏ពុំអាចស្រឡាញ់ព្រះជាម្ចាស់ដែលខ្លួនមើលពុំឃើញនោះបានដែរ។ យើងបានទទួលបទបញ្ជានេះពីព្រះអង្គថា «អ្នកណាស្រឡាញ់ព្រះជាម្ចាស់ អ្នកនោះក៏ត្រូវស្រឡាញ់បងប្អូនដែរ"។ (គម្ពីរ១យ៉ូហាន ៤:២០-២១)។

នេះគឺជាមូលហេតុដែលលោកប៉ូលស្តីបន្ទោស ចំពោះភាពច្រណែន និង ជម្លោះរវាងគ្រិស្តបរិស័ទនៅក្រុមកូរិនថូស ដែលបាននាំឲ្យពួកគេបែងចែកទៅជាក្រុមផ្សេងៗគ្នា ទាំងនិយាយថា "ខ្ញុំជាកូនចៅរបស់លោកប៉ូល!" ឬ "ខ្ញុំជាកូនចៅរបស់លោកអប៉ូឡូស!" (១កូរិនថូស ៣:៤)។ នេះមិនមែនជាឥរិយាបថរបស់គ្រិស្តបរិស័ទនោះទេ ប៉ុន្តែវាឥរិយាបថរបស់ទារកដែលមិនទាក់ទងខាងឯវិញ្ញាណនោះទេ។ បទបញ្ជា និងគំរូទាំងនេះ ជួយយើងឲ្យឃើញថា ប្រសិនបើយើងមិនចុះសម្រុងគ្នានោះទេ យើងក៏មិនចុះសម្រុងជាមួយព្រះជាម្ចាស់ផងដែរ។

លំហាត់អនុវត្តន៍

---

៨ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ លក្ខណៈរបស់ក្រុមជំនុំ ដែលជាសហគមន៍ខាងឯវិញ្ញាណមួយ អាចនឹងត្រូវចាត់ទុកថា

ក) មនុស្សមួយក្រុម ដែលព្យាយាមមានការរួបរួមជាមួយគ្នាទៅវិញទៅមក។

ខ) អ្នកជឿទាំងអស់ ដែលស្ថិតនៅក្នុងការរួបរួមមួយជាមួយព្រះគ្រិស្ត។

គ) ការរស់នៅ ទៅតាមបទពិសោធន៍ជាគ្រិស្តបរិស័ទជារៀងរាល់ថ្ងៃ។

៩ លក្ខណៈរបស់ក្រុមជំនុំ ក្នុងនាមជាការសម្តែងបង្ហាញឲ្យឃើញនឹងភ្នែកនូវទំនាក់ទំនងរបស់អ្នកជឿជាមួយនឹងព្រះគ្រិស្ត អាចកំណត់និយមន័យថា ជា

ក) ចំណងខាងឯវិញ្ញាណមួយនៃសេចក្តីស្រឡាញ់សម្រាប់ព្រះជាម្ចាស់។

ខ) កន្លែងមួយដែលមនុស្សចូលរួមគ្នាជាក្រុមដោយផ្អែកទៅតាម ជីវប្រវត្តិសាស្ត្រនៅក្នុងសង្គមផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធ្វើការថ្វាយបង្គំព្រះ។

គ) ការជំនុំគ្នារបស់ពួកអ្នកជឿនៅតាមតំបន់ ក្រោមទំនាក់ទំនងមួយនៃសហភាពជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើសេចក្តីស្រឡាញ់។

ដូច្នេះ យើងឃើញថា តាមរយៈលក្ខណៈធម្មជាតិ ក្រុមជំនុំជារឿងខាងឯវិញ្ញាណ។ ទោះជាយ៉ាងណា ក្រុមជំនុំក៏ជាសហគមន៍ជាក់ស្តែងពិតមួយ ដែលអ្នកជឿសម្តែងទំនាក់ទំនងរបស់ពួកគេទៅកាន់ព្រះអម្ចាស់របស់ពួកគេ និង ចំពោះគ្នាទៅវិញទៅមក។ ដូច្នេះ ក្រុមជំនុំគឺជាសហគមន៍មួយរបស់អ្នកជឿដែលយើងឃើញ និង ទទួលបាននូវបទពិសោធន៍នៃក្តីស្រឡាញ់ដ៏ពិត។ ដោយសេចក្តីស្រឡាញ់ គឺជាលក្ខណសម្បត្តិចម្បងបំផុត នៃទំនាក់ទំនងខាងឯវិញ្ញាណ ហើយក្តីស្រឡាញ់មួយនេះ ត្រូវបានស្តែងឡើងនៅក្នុងការជំនុំគ្នាតាមតំបន់នេះហើយ៖

> រីឯអ្នកដែលមិនចេះស្រឡាញ់ មិនបានស្គាល់ព្រះជាម្ចាស់ទេ ដ្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ព្រះជាម្ចាស់បានសំដែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គក្នុងចំណោមយើង គឺព្រះអង្គបានចាត់ព្រះបុត្រា តែមួយគត់របស់ព្រះអង្គអោយយាងមកក្នុងលោកនេះ ដើម្បីអោយយើងមានជីវិតដោយសារព្រះបុត្រា។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មានដូចតទៅនេះ មិនមែនយើងទេដែលបានស្រឡាញ់ព្រះអង្គ គឺព្រះអង្គទេតើដែលបានស្រឡាញ់យើង និងបានចាត់ព្រះបុត្រារបស់ព្រះអង្គអោយយាងមកបូជាព្រះជន្ម លោះយើងអោយរួចពីបាបផង។កូនចៅជាទីស្រឡាញ់អើយ ប្រសិនបើព្រះជាម្ចាស់បានស្រឡាញ់យើងដល់កំរិតនេះទៅហើយ យើងក៏ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដែរ។ (គម្ពីរ១យ៉ូហាន ៤:៨-១១)

លំហាត់អនុវត្តន៍

---

១០ ដោយផ្អែកទៅលើព័ត៌មានមាននៅក្នុងទិដ្ឋភាពខាងលើនេះ ចូរប្រាប់លក្ខណសម្បត្តិពីរយ៉ាង ដែលរៀបរាប់អំពីលក្ខណៈរបស់ក្រុមជំនុំ។

.....

.....

គ. *អ្វីដែលក្រុមជំនុំធ្វើ*

តើក្រុមជំនុំធ្វើអ្វីខ្លះ? តើអ្វីគឺជាគោលបំណងនៃវត្តមានរបស់ក្រុមជំនុំ? នៅក្នុងសំបុត្ររបស់លោកប៉ូល ទៅកាន់អ្នកជឿក្រុងអេភេសូ យើងដឹងថាព្រះជាម្ចាស់បង្កើតឲ្យសហគមន៍អ្នកជឿកើតចេញជារូបរាងមក ដើម្បីនាំសិរីរុងរឿងដល់ព្រះនាមរបស់ទ្រង់។ គោលបំណងធំបំផុតរបស់ទ្រង់ នៅក្នុងការប្រោសលោះយើង គឺដើម្បីឲ្យយើងអាច "លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ" (គម្ពីរអេភេសូ ១:៦,១២,១៤)។

របៀបដែលក្រុមជំនុំតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺចែកចេញជាបីទិសដៅ៖

១. *ទៅខាងលើ* នៅពេលដែលអ្នកជឿថ្វាយបង្គំទ្រង់

២. *ទៅខាងក្នុង* នៅពេលដែលអ្នកជឿកសាងគ្នាឡើងទៅវិញទៅមក

៣. *ទៅខាងក្រៅ* នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អ ជាមួយនឹងអ្នកមិនជឿ។

ក្រុមជំនុំថ្វាយបង្គំព្រះជាម្ចាស់

វត្ថុបំណងទី៤. *ពិភាក្សាអំពីការចូលរួមថ្វាយបង្គំ និង បកស្រាយពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់ក្នុងពេលថ្វាយបង្គំទ្រង់។*

ការថ្វាយបង្គំគឺជា សកម្មភាពមួយដែលយើងទទួលស្គាល់ភាពស័ក្តិសមរបស់ព្រះជាម្ចាស់ ក្នុងការទទួលបានការគោរពយ៉ាងជ្រាលជ្រៅ និង ការលើកតម្កើង។ នៅក្នុងការថ្វាយបង្គំរួមគ្នា អ្នកជឿលើកតម្កើង និង សម្តែងការគោរព ដោយផ្ទាល់ទៅចំពោះព្រះជាម្ចាស់ សម្រាប់ព្រះអំណោយទាន ប្រកបដោយព្រះគុណរបស់ទ្រង់ ទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ នៅក្នុង និង តាមរយៈព្រះអម្ចាស់យេស៊ូនៃយើង។ គោលបំណងនៃការថ្វាយបង្គំដ៏ពិតគឺមិនមែន មនុស្សទេ តែគឺជា*ព្រះជាម្ចាស់*វិញ ។ យើងថ្វាយបង្គំព្រះជាម្ចាស់ ដោយសារទ្រង់គឺជាទ្រង់ (លក្ខណសម្បត្តិរបស់ទ្រង់) និង អ្វីដែលទ្រង់ធ្វើ។

នៅក្នុងមេរៀនទី១ ដល់ទី៣ ក្នុងវគ្គសិក្សានេះ យើងបានមើលទៅលើមូលហេតុជាច្រើន ដែលព្រះជាម្ចាស់ទ្រង់ស័ក្តិសមទទួលការថ្វាយបង្គំរបស់យើង។ គម្ពីរទំនុកតម្កើង ១០៧:១-៣ ប្រាប់យើងថា "ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គមាន ព្រះហឫទ័យសប្បុរស ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ គួរអោយអស់អ្នកដែលព្រះអម្ចាស់ បានរំដោះមក ពោលសេចក្តីនេះ គឺអស់អ្នកដែលព្រះអង្គបានរំដោះ អោយរួចពីកណ្តាប់ដៃរបស់បច្ចាមិត្ត ហើយនាំពីប្រទេសនានាមកវិញ" ។

ព្រះយេស៊ូបានប្រកាសថា ព្រះជាម្ចាស់ស្វែងរកមនុស្សដែលនឹងថ្វាយបង្គំទ្រង់ "តាមវិញ្ញាណ និងតាមសេចក្តីពិត" (គម្ពីរយ៉ូហាន ៤:២៣)។ នេះបានន័យថា ការថ្វាយបង្គំរបស់យើងត្រូវតែប្រកបដោយភាពស្មោះត្រង់ និង ត្រូវផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូគ្រិស្ត។ ការថ្វាយបង្គំគឺជាការដែលវិញ្ញាណរបស់យើង មានសម្ព័ន្ធភាពជាមួយព្រះវិញ្ញាណរបស់ទ្រង់។ តាមរយៈការប្រទានសេចក្តីសង្គ្រោះមក ព្រះជាម្ចាស់បានដកចេញជារៀងរហូត នូវរាល់រនាំងដែលអាចនឹងរារាំងការរួបរួមរបស់យើងទៅជាមួយព្រះជាម្ចាស់ (សូមមើលគម្ពីរហេប្រឺ ៤:១៦; ១០:១៩-២២)។ ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទដ៏ពិតគឺមិនផ្អែកទៅលើអ្វីដែលយើងធ្វើសម្រាប់ព្រះជាម្ចាស់នោះទេ ប៉ុន្តែគឺផ្អែកទៅលើការយល់ដឹងរបស់យើង និង ការទទួលស្គាល់អ្វីដែលទ្រង់បានធ្វើសម្រាប់យើងតាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវិញ។

ការថ្វាយបង្គំរបស់យើងគឺមិនដូច អ្នកមិនជឿលើព្រះអម្ចាស់ ដែលនាំគ្នាទៅថ្វាយបង្គំព្រះដែលធ្វើពីឈើ ឬ ថ្មនោះទេ។ ការថ្វាយបង្គំរបស់ពួកគេ គឺមានគោលបំណងដើម្បីធ្វើឲ្យព្រះរបស់គេបាត់ខឹងនឹងពួកគេ ឬ ដើម្បីទទួលបានផលអ្វីម្យ៉ាងពីព្រះទាំងនោះប៉ុណ្ណោះ។ ទោះបីជា នៅពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ថ្វាយបង្គំទ្រង់ ពួកគេដឹងច្បាស់ថាទ្រង់បានប្រទានសេចក្តីមេត្តាករុណា និង ព្រះគុណសម្រាប់ពួកគេដោយឥតមានគិតថ្លៃអ្វីទាំងអស់ (គម្ពីរទំនុកតម្កើង ១១៨:១)។ ការថ្វាយបង្គំគឺជាការស្តែងចេញនូវការដឹងគុណទៅចំពោះព្រះជាម្ចាស់ សម្រាប់ព្រះគុណរបស់ទ្រង់។ ការនេះរាប់បញ្ចូលទាំងការសរសើរតម្កើង និង ការស្រឡាញ់ទ្រង់។

ស្របពេលដែលយើងអាច និង ធ្វើការថ្វាយបង្គំព្រះជាម្ចាស់ដូចខ្លួនឯង វាគឺជារឿងសំខាន់ណាស់ដែលយើងត្រូវដឹងពីតម្លៃនៃការថ្វាយបង្គំរួមគ្នា ដែលជាការសរសើរតម្កើង *ព្រមគ្នា* មួយទៅកាន់ព្រះជាម្ចាស់។ នៅពេលដែលគ្រួសាររបស់ព្រះជាម្ចាស់ ប្រមូលផ្តុំគ្នានៅក្នុងព្រះវត្តមានរបស់ទ្រង់ ដើម្បីតម្កើងសិរីរុងរឿងរបស់ទ្រង់ អ្នកជឿម្នាក់ៗអាចដឹងពីភាពរួមមកតែមួយនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ មាន*ភាពរស់រវើក* ខាងឯវិញ្ញាណមួយ នៅក្នុងការសហការគ្នាថ្វាយបង្គំ ដែលបុគ្គលតែម្នាក់មិនអាចទទួលបាន។ នេះមានន័យថា មានឫទ្ធានុភាពមួយកើតមានឡើងនៅពេលដែលយើងចូលរួមគ្នាដើម្បីថ្វាយបង្គំ ដែលឫទ្ធានុភាពនាំជាប្រយោជន៍ និង ពង្រឹងកម្លាំងអ្នកថ្វាយបង្គំម្នាក់ៗ។ យើងទទួលបានជំនួយនៅក្នុងការថ្វាយបង្គំព្រះជាម្ចាស់របស់ខ្ញុំ នៅពេលណាដែលខ្ញុំធ្វើការថ្វាយបង្គំទ្រង់ជាមួយអ្នកជឿដទៃទៀត។ ហេតុផលនោះហើយបានជា បទគម្ពីរបានជំរុញយើងថា៖ "តោងយើងមើលថែរក្សាគ្នាទៅវិញទៅមក ដើម្បីជួយដាស់តឿនគ្នាអោយមានចិត្តស្រឡាញ់ និងប្រព្រឹត្តអំពើល្អ។ មិនត្រូវលះបង់ការប្រជុំគ្នា ដូចអ្នកខ្លះធ្លាប់ធ្វើនោះឡើយ ផ្ទុយទៅវិញ យើងត្រូវលើកទឹកចិត្តគ្នាទៅវិញទៅមក" (គម្ពីរហេប្រឺ១០:២៤-២៥)។

ស្ថិតនៅក្នុងក្រោមការដឹកនាំ និង ការដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្នុងការថ្វាយបង្គំរួមគ្នា ក្រុមជំនុំព្យាយាមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមរយៈមធ្យោបាយផ្សេងដូចជាការច្រៀងបទចម្រៀង ការអធិស្ឋាន និងការធ្វើព័ន្ធកិច្ចតាមរយៈព្រះបន្ទូល។ ជារឿងសំខាន់ណាដែលយើងកត់ចំណាំថា ដោយគ្រាន់តែធ្វើតាមទម្រង់បែបបទនៃការថ្វាយបង្គំ មិនមែនមានន័យថា យើងបានថ្វាយបង្គំហើយនោះទេ។ យើងអាចរីករាយជាមួយ ភាពពិរោះរន្ធំនៃតន្ត្រី ជាមួយនឹងសមត្ថភាពរបស់អ្នកចែកចាយ ឬ បានសប្បាយដែលបាននៅជាមួយមនុស្សផ្សេងទៀត ហើយនៅតែមិនបានថ្វាយបង្គំព្រះជាម្ចាស់ដដែល។ ត្រូវចាំថា គោលបំណងចម្បងនៃការថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតគឺ ត្រូវតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ទ្រង់ត្រូវតែជាស្នូលកណ្តាលនៃការថ្វាយបង្គំរបស់យើង។

ការថ្វាយបង្គំរួមគ្នា គឺ ត្រូវបង្ហាញឡើងជាច្រើនលើកច្រើនសា នៅក្នុងព្រះគម្ពីរ។ សូមឲ្យយើងក្រឡេកទៅមើល ឧទាហរណ៍ខ្លះៗអំពីការនេះ៖

> លោកអែសរ៉ាលើកតម្កើងព្រះអម្ចាស់ ជាព្រះដ៏ឧត្តុង្គឧត្តម ហើយប្រជាជនទាំងមូលឆ្លើយតបវិញទាំងលើកដៃឡើងលើថា «អាម៉ែន! អាម៉ែន!» រួចក្រាបថ្វាយបង្គំព្រះអម្ចាស់អោនមុខដល់ដី។ (គម្ពីរនេហេមា ៨:៦)។

> អង្គប្រជុំទាំងមូលនាំគ្នាក្រាបថ្វាយបង្គំ រីឯអ្នកចំរៀងនាំគ្នាច្រៀង ជាមួយសំឡេងត្រែ រហូតទាល់តែគេថ្វាយតង្វាយដុតចប់សព្វគ្រប់។ (គម្ពីរ ២របាក្សត្រ ២៩:២៨)។

> ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ* ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ។ (គម្ពីរ កិច្ចការ ២:៤៦-៤៧)។

ពេលនោះ ខ្ញុំឮសត្វលោកទាំងប៉ុន្មាន នៅស្ថានសួគ៌ នៅលើផែនដី នៅក្រោមដី នៅក្នុងសមុទ្រ ព្រមទាំងអ្វីៗទាំងអស់ដែលនៅស្ថានទាំងនោះ បន្លឺសំឡេងឡើងថា: «សូមព្រះអង្គដែលគង់លើបល្ល័ង្ក និងកូនចៀមទទួលពាក្យសរសើរតម្កើងព្រះកិត្តិនាម សិរីរុងរឿង និងព្រះចេស្តា អស់កល្បជាអង្វែងតរៀងទៅ!»។ (គម្ពីរវិវរណៈ ៥:១៣)

បន្ថែមពីលើការច្រៀងចម្រៀង ការអធិស្ឋាន និង សរសើរតម្កើងព្រះជាម្ចាស់ ក្រុមជំនុំក៏ត្រូវថ្វាយបង្គំរួមគ្នាដោយការប្រតិបត្តិតាម បទបញ្ជាចំនួនពីរយ៉ាងដែលព្រះយេស៊ូបានបញ្ជាមក៖ ការជ្រមុជដោយទឹក និង ពិធីលៀងព្រះអម្ចាស់ ។ នៅក្នុងការជ្រមុជដោយទឹក អ្នកជឿថ្មី គឺត្រូវជ្រមុជនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ ទុកជាទីសំគាល់មួយនៃការផ្លាស់ប្រែនៅផ្នែកខាងក្នុង។ ពិធីលៀងព្រះអម្ចាស់ ត្រូវតែប្រតិបត្តិតាមដែរ ព្រះយេស៊ូបានមានព្រះបន្ទូលថា ៖ "ដើម្បីរំលឹកដល់ខ្ញុំ រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ។" ការស្តាប់បង្គាប់តាមរយៈការប្រតិបត្តិតាមបទបញ្ជាទាំងនេះ គឺជាសកម្មភាពនៃការថ្វាយបង្គំរួមគ្នាមួយ (សូមមើល គម្ពីរម៉ាថាយ ២៨:១៩ គម្ពីរ១កូរិនថូស ១១:២២-២៦)។

លំហាត់អនុវត្តន៍

---

១១ តើប្រយោគណាខ្លះ ក្នុងចំណោមប្រយោគខាងក្រោមនេះ ជាប្រយោគត្រឹមត្រូវទាក់ទងនឹងការថ្វាយបង្គំរួមគ្នា? ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយដែលអ្នកបានជ្រើសរើស។

ក) គោលបំណងនៃការថ្វាយបង្គំរួមគ្នា គឺដើម្បីរម្លាប់ព្រះពិរោធរបស់ព្រះជាម្ចាស់ និង ទទួលបានក្តីសន្តោសរបស់ព្រះជាម្ចាស់។

ខ) ការថ្វាយបង្គំនៅក្នុងព្រះវិញ្ញាណ និង សេចក្តីពិត គឺទាមទារឲ្យមានភាពស្មោះសរ និង ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូគ្រិស្ត។

គ) ការថ្វាយបង្គំរួមគ្នា ទាញអ្នកជឿឲ្យចូលមករកគ្នា នៅក្នុងការរួបរួម និង ឫទ្ធានុភាពតែមួយ។

ឃ) ការថ្វាយបង្គំដោយវិញ្ញាណគឺតែងតែផ្តោតទៅលើព្រះជាម្ចាស់។

ង) ការថ្វាយបង្គំរួមគ្នា គឺត្រូវបានបង្ហាញ និង បង្គាប់នៅក្នុងបទគម្ពីរ

១២ ចូរសរសេរពាក្យចំនួនបីពាក្យ ដែលបកស្រាយអំពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់នៅក្នុងការថ្វាយបង្គំ។

.....

ក្រុមជំនុំកសាងឡើងដោយខ្លួនឯង

វត្ថុបំណងទី៥. *បកស្រាយពីអត្ថន័យនៃពាក្យ កសាងឡើង និង ទំនាក់ទំនងរវាងព្រះអំណោយទាន និង ផលផ្លែនៃព្រះវិញ្ញាណ និង ក្រុមជំនុំ។*

ការពិតមួយដែលបានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ នៅពេលដែលយើងសិក្សាបទគម្ពីរទាក់ទងទៅនឹងតួនាទីរបស់ក្រុមជំនុំគឺថា៖ ព្រះជាម្ចាស់នៅតែបន្តដោះស្រាយជាមួយអ្នកជឿនៅក្នុង *សហគមន៍* ។ យើងយល់អំពីតួនាទីរបស់សហគមន៍នេះ បានយ៉ាងល្អប្រសើរ នៅពេលដែលយើងទាក់ទងជាមួយនឹងក្រុមជំនុំដោយប្រកាន់គោលគំនិតនៃរូបកាយ។ បទគម្ពីរ ប្រើប្រាស់រូបភាពនៃរូបកាយនេះ ដើម្បីបកស្រាយអំពីតួនាទីរបស់ក្រុមជំនុំ រូបកាយនោះគឺជារូបកាយខាងឯវិញ្ញាណ (សូមមើលគម្ពីររ៉ូម ១២:៤-៨ គម្ពីរ១កូរិនថូស១២:៤-៣១ និង គម្ពីរអេភេសូ ៤:៧-១៦)។ សមាជិកគ្រប់រូប និង ការចូលរួមរបស់ពួកគេគឺមានសារៈសំខាន់ណាស់ សម្រាប់ដំណើរការដែលប្រកបដោយសុខភាព សម្រាប់រូបកាយ។

រូបកាយរបស់មនុស្ស គឺជាភាវៈរស់ដ៏ស្មុគស្មាញខ្លាំងណាស់ ។ រូបកាយរបស់មនុស្សមានទិដ្ឋភាពជាច្រើន ដែលនីមួយៗមានតួនាទីខុសៗពីគ្នា។ ព្រះកាយរបស់ព្រះគ្រិស្ត ទៀតសោតក៏មានសរីរាង្គ(អវយវៈពគប)ជាច្រើនផងដែរ។ សរីរាង្គទាំងអស់មានព្រះអំណោយទាន ឬ សមត្ថភាពមួយ ឬ ច្រើន ដែលអាចអនុញ្ញាតឲ្យពួកគេចូលរួម នៅក្នុងសុខុមលភាពរបស់ព្រះកាយទាំងមូល។ តើព្រះអំណោយទានទាំងនោះគឺមានអ្វីខ្លះ? ការរៀបរាប់ជាចំណុចៗ នឹងបង្ហាញឲ្យឃើញពីភាពដោយឡែកគ្នានៃព្រះអំណោយទានដែលមានសម្រាប់សរីរាង្គនៃព្រះកាយរបស់ព្រះគ្រិស្ត។

1. គម្ពីររ៉ូម ១២:៤-៨ : ការថ្លែងព្រះបន្ទូល ការបម្រើ ការបង្រៀន ការលើកទឹកចិត្ត រួមចំណែកនៅក្នុងតម្រូវការរបស់អ្នកដទៃ ការដឹកនាំ និង ការចែកទាន។
2. គម្ពីរ១កូរិនថូស ១២:៨-១០: ការនិយាយប្រកបដោយប្រាជ្ញា ការនិយាយដោយយល់គំរោង ការលាក់កំបាំង ជំនឿ ព្រះអំណោយទានប្រោសមនុស្សឲ្យជាពីជំងឺ ឫទ្ធានុភាពធ្វើការអស្ចារ្យ ការថ្លែងព្រះបន្ទូល ចេះស្ទង់មើលវិញ្ញាណល្អឬ អាក្រក់ សមត្ថភាពនិយាយភាសាចម្លែក អស្ចារ្យ និង ការបកស្រាយភាសានោះ (សូមមើលនៅក្នុង ខ២៨ - ខ៣0)

វាគឺជារឿងសំខាន់ ដែលត្រូវបញ្ជាក់ថា បុគ្គលដែលមានព្រះអំណោយទាន ត្រូវបានផ្តល់ទៅឲ្យ *ក្រុមជំនុំ សហគមន៍*នៃអ្នកជឿ "ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង" (គម្ពីរអេភេសូ ៤:១២)។ នេះមានន័យថា អ្នកជឿរស់នៅក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើគ្នាទៅវិញទៅមក។ សរីរាង្គនីមួយៗនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តគឺសុទ្ធតែមានការបម្រើ ទេពកោសល្យ ឬ ត្រូវបានមានការចូលរួមខ្លះៗ សរីរាង្គនីមួយៗគឺសុទ្ធតែត្រូវការការចូលរួមពីសំណាក់សរីរាង្គដទៃផ្សេងទៀត។ សម្រាប់សរីរាង្គជារួមនៅក្នុងព្រះកាយវិញ ព្រះជាម្ចាស់បានប្រទានឲ្យមានពួកសាវ័ក អ្នកផ្សព្វផ្សាយដំណឹងល្អ គ្រូគង្វាល និង គ្រូបង្រៀន (គម្ពីរអេភេសូ ៤:១១)។

វាក៏ជារឿងសំខាន់ដែលយើងត្រូវ ចាំថា ព្រះកាយរបស់ព្រះគ្រិស្ត គឺជាភាវរស់ខាងឯវិញ្ញាណ ដែលរួបរួមជាមួយព្រះគ្រិស្ត។ នេះមានន័យថា ព្រះកាយគឺមិនមែនគ្រាន់តែជាបណ្តុំមនុស្សនោះទេ។ អស់អ្នកដែលជឿលើព្រះគ្រិស្ត គឺបានចូលរួមជាមួយព្រះកាយរបស់ទ្រង់ ព្រោះពួកគេក៏បានចូលរួមជាមួយនឹងព្រះ

សិរសាផងដែរ។ *ដោយសារតែសរីរាង្គទាំងអស់ គឺនៅជាមួយព្រះគ្រិស្ត នោះពួកគេក៏នៅជាមួយគ្នាទៅវិញទៅមកដែរ។* ព្រះកាយរស់នៅគឺដើម្បីបម្រើដល់ ព្រះសិរិសា។ នៅក្នុងរូបកាយរបស់មនុស្ស នៅពេលណាដែលខួរក្បាលស្លាប់ នោះក៏លែងត្រូវការខ្លួនប្រាណទៀតដែរ។ ប្រសិនបើព្រះគ្រិស្តមិនទទួលបានហាន:របស់ទ្រង់ជាព្រះសិរសាទេ នោះក៏លែងត្រូវការឲ្យមានព្រះកាយទៀតដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ក្រុមជំនុំនៅក្រុងសើដេសថា៖ "យើងស្គាល់កិច្ចការដែលអ្នកប្រព្រឹត្តនោះហើយ អ្នកមានឈ្មោះល្បីថារស់ តែតាមពិត អ្នកស្លាប់ទេតើ!" (គម្ពីរវិវរណៈ ៣:១)។ ក្រុមជំនុំត្រូវបានរក្សាទំនាក់ទំនងរបស់ពួកគេជាមួយព្រះសិរសា គឺព្រះយេស៊ូគ្រិស្ត តាមរយៈការថ្វាយបង្គំ ដើម្បីឲ្យក្រុមជំនុំអាចកសាងឡើងខ្លួនឯងបាន។ ការ*កសាងឡើង* មានន័យថា "ណែនាំ ឬ ធ្វើឲ្យវិញ្ញាណបានកាន់តែប្រសើរឡើង ជាការសាងសង់ ឬ បង្កើត"។

ព្រះជាម្ចាស់បានប្រទានភាពចុះសម្រុងគ្នា នៅក្នុងការរស់ខាងឯវិញ្ញាណ ដែលជាក្រុមជំនុំនេះ ។ នៅពេលដែលទិដ្ឋភាពខ្លះនៃខ្លួនប្រាណរបស់មនុស្ស ឆ្លើយតបទៅនឹងតម្រូវការនៃទិដ្ឋភាពនីមួយៗ នោះខ្លួនប្រាណខាងឯវិញ្ញាណ ក៏ឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលអ្នកជឿម្នាក់ផងដែរ។ប្រសិនបើសរីរាង្គណាមួយរងទុក្ខ នោះសរីរាង្គផ្សេងទៀតនឹងទទួលរងការឈឺចាប់ដូចគ្នា ប្រសិនបើមានសរីរាង្គណាមួយត្រេកអរសប្បាយ សរីរាង្គដទៃក៏នឹងទទួលបានអំណរសប្បាយដូចគ្នានោះដែរ (គម្ពីរ១កូរិនថូស ១២:២៤-២៦)។ ហេតុផលគឺយ៉ាងដូច្នេះ ៖ "ព្រះកាយទាំងមូលបានផ្គុំគ្នា និងភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មានដែលបំរើព្រះកាយ តាមកំរិតសមត្ថភាពរបស់សរីរាង្គនីមួយៗ ដើម្បីអោយព្រះកាយនោះចំរើន និងកសាងឡើង ក្នុងសេចក្តីស្រឡាញ់។" (គម្ពីរអេភេសូ ៤:១៦)។

ពេលខ្លះ ដំណើរការនៃការសាងសង់រូបកាយឡើង មានន័យថាក្រុមជំនុំត្រូវបន្សុទ្ធខ្លួនឯង។ ការនេះអាចនឹងត្រូវទាមទារឲ្យមានការអប់រំសមាជិកណាដែលបានប្រព្រឹត្តិអំពើបាប។ ព្រះយេស៊ូបានមានព្រះបន្ទូលអំពី ការនេះ (គម្ពីរម៉ាថាយ ១៨:១៥-២០) ហើយបានប្រទានការណែនាំសម្រាប់ដោះស្រាយជាមួយនឹងមនុស្សប្រភេទតាមរយៈវិញ្ញាណនៃក្តីស្រឡាញ់។ ទោះជាយ៉ាងណា ប្រសិនបើពួកគេបដិសេធមិនព្រមស្តាប់ ហើយលន់តួនោះទេ ពួកអ្នកទាំងនោះ ត្រូវតែបណ្តេញចេញពីសមាគមន៍នៃអ្នកជឿតែម្តង(សូមមើលផងដែរនៅក្នុងគម្ពីរ១កូរិនថូស ៥:៩-១៣ ដើម្បីធ្វើជាឧទាហរណ៍)។

មានតែតាមរយៈទំនាក់ទំនងរបស់អ្នកជឿជាមួយសមាជិកដទៃទៀតនៃព្រះកាយរបស់ព្រះគ្រិស្តនោះទេ ដែលព្រះវិញ្ញាណអាចបង្កើតផលផ្លែរបស់ទ្រង់បាន នៅក្នុងអ្នកជឿម្នាក់ៗ។ ផលផ្លែនៃព្រះវិញ្ញាណដូចដែលបានរៀបរាប់នៅក្នុងគម្ពីរកាឡាទី ៥:២២-២៣ គឺសំដៅទៅលើលក្ខណសម្បត្តិរបស់ព្រះគ្រិស្តដែលកើតមានឡើងនៅពេលដែលយើងបង្កើតទំនាក់ទំនងជាមួយជាគ្នាទៅវិញទៅមក។ ផលផ្លែទាំងនោះមាន សេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោសមេត្តា ជំនឿ (ភាពស្មោះត្រង់, គកស១៦) ចិត្តស្លូតបូត និង ចេះទប់ចិត្តខ្លួនឯង។

លំហាត់អនុវត្តន៍

១៣ ចូរបំពេញប្រយោគខាងក្រោម ៖

ក) ក្រុមជំនុំកសាងឡើងដោយខ្លួនឯង។ *ការកសាង* មានន័យថា.....

ខ) ទំនាក់ទំនងរវាងព្រះអំណោយទាននៃព្រះវិញ្ញាណ និង ក្រុមជំនុំគឺថា.....

.....

គ) ទំនាក់ទំនងរវាងផលផ្លែនៃព្រះវិញ្ញាណ និង ក្រុមជំនុំគឺថា.....

.....

គ្រិស្តបរិស័ទ គឺមិនមែនជាដំណើរឯកោ ឬ តែម្នាក់ឯងនោះទេ។ តាមរយៈការអានគម្ពីរកិច្ចការ បានបង្ហាញឲ្យឃើញថា ព្រះកាយរបស់ព្រះគ្រិស្តគឺ អ្នកជឿដែលប្រមូលផ្តុំគ្នាយ៉ាងមមាញឹក ធ្វើការថ្វាយបង្គំ និង ប្រកបគ្នា ក្នុងគោលបំណងដើម្បីតម្កើងសិរីរុងរឿងព្រះជាម្ចាស់ រីកលូតលាស់នៅក្នុងក្តីស្រឡាញ់របស់ទ្រង់ និង នាំអ្នកដទៃទៀតចូលមកឯព្រះរាជ្យរបស់ទ្រង់។ ក្រុមជំនុំ គឺសម្រាប់អស់អ្នកដែលបានប្តេជ្ញាចិត្ត ចំពោះការលូតលាស់ ការអភិវឌ្ឍ និង ការពេញវ័យរបស់សរីរាងនៃព្រះកាយរបស់ព្រះគ្រិស្ត។ នៅពេលការនេះកើតឡើង ក្រុមជំនុំនឹងត្រៀមខ្លួនជាស្រេចក្នុងការបំពេញមុខងារទីបីរបស់ខ្លួន នោះគឺការចែកចាយដំណឹងល្អជាមួយអ្នកមិនជឿ។

ក្រុមជំនុំផ្សព្វផ្សាយទៅកាន់ពិភពលោក

វត្ថុបំណងទី ៦. *បកស្រាយពីរបៀបដែលសេចក្តីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងបេសកកម្មរបស់ក្រុមជំនុំ គួរតែត្រូវបានយកទៅដាក់ឲ្យប្រតិបត្តិ។*

ព្រះរាជបញ្ជាទីមួយរបស់ព្រះយេស៊ូ ទៅកាន់អ្នកដែលមានតម្រូវការគឺ "ចូរមក" (គម្ពីរម៉ាថាយ ១១:២៨)។ នៅពេលដែលគេស្គាល់ ការអត់ទោស និង ការទទួលស្គាល់របស់ទ្រង់ហើយ ពួកគេត្រូវបានចាត់ឲ្យ "ចេញទៅ" (គម្ពីរម៉ាថាយ២៨:១៩)។ នៅពេលសមាគមន៍នៃអ្នកជឿដែលបានចូលរួមនៅក្នុងតំបន់នីមួយៗ ត្រូវបានកសាងឡើងខាងឯជំនឿរបស់គេហើយ គេត្រូវតែបង្វែរកម្លាំងរបស់គេ ទៅខាងក្រៅ គឺទៅកាន់លោកីយ៍ដែលមិនជឿ។ ព្រះជាម្ចាស់ប្រើប្រាស់មនុស្សដើម្បី ឈោងចាប់មនុស្ស! ក្រុមជំនុំ តម្កើងសិរីរុងរឿងព្រះជាម្ចាស់ នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អជាមួយអ្នកដទៃទៀត ពួកគេគឺចូលរួមនៅក្នុងការផ្សាយដំណឹងល្អ។ ពាក្យ*ផ្សព្វផ្សាយដំណឹងល្អ*មានន័យត្រង់ៗថា៖ "ការប្រកាសដំណឹងល្អ"។ ទំនួលខុសត្រូវ និង អភ័យឯកសិទ្ធិ របស់ក្រុមជំនុំគឺត្រូវធ្វើឲ្យការប្រទានសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សគ្រប់គ្នា ត្រូវបានគេដឹងឮ។

អ្នកជឿត្រូវបានត្រាស់ហៅឲ្យចេញទៅក្នុងលោកីយ៍ ក្នុងន័យមួយដែលថា ពួកគេមិនត្រូវបានគ្រប់គ្រងដោយតម្លៃ និង ភក្តីភាពរបស់លោកីយ៍ទៀតទេ។ យ៉ាងណាក៏ដោយ ពួកគេក៏ត្រូវបានចាត់ឲ្យនាំយកដំណឹងល្អទៅកាន់ពិភពរបស់អ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ។ ព្រះយេស៊ូបានអធិស្ឋាន ទៅកាន់ព្រះវរបិតាថា៖ " គេមិនកើតពីនិស្ស័យលោកីយ៍ទេ ដូចទូលបង្គំមិនកើតពីនិស្ស័យលោកីយ៍នេះ

ដែរ។... ទូលបង្គំចាត់គេអោយទៅក្នុងលោក ដូចព្រះអង្គបានចាត់ទូលបង្គំអោយមកក្នុងលោកដែរ។" (គម្ពីរយ៉ូហាន ១៧:១៦,១៨) ។ អ្នកជឿត្រូវផ្តាច់ខ្លួនរបស់ពួកគេចេញពី របៀបរស់នៅបែបអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ហើយនៅតែបន្តចូលរួមនៅក្នុងការផ្លាស់ប្តូររបៀបរស់នៅនោះដដែល។ ដោយសារតែគ្រិស្តបរិស័ទត្រូវបាន*ចាត់បញ្ជូនទៅ*ពួកយើងមានគំនិតអំពី *របសកកម្ម* ។

ព្រះគម្ពីរសម័ន្ធមេត្រីថ្មី ផ្តល់ឲ្យយើងឃើញពីវិសាលភាពនៃការផ្សព្វផ្សាយដំណឹងល្អ នៅក្នុងគម្ពីរម៉ាថាយ ១៣:៣៨។ ព្រះយេស៊ូប្រកាសថា៖ "ស្រែ គឺពិភពលោក" ។ ទ្រង់បានបង្គាប់អ្នកដើរតាមទ្រង់ជាមួយនឹងព្រះបន្ទូលយ៉ាងដូច្នេះថា៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ .... ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។" (គម្ពីរម៉ាថាយ ២៨:១៩-២០ ហើយក៏សូមមើលនៅក្នុងគម្ពីរម៉ាកុស ១៦:១៥)។ ដូច្នេះ ក្រុមជំនុំត្រូវបានដាក់តួនាទីឲ្យចែកចាយដំណឹងល្អ ជាមួយមនុស្សនៅគ្រប់ទីកន្លែង។

ទំនួលខុសត្រូវ ដើម្បីផ្សព្វផ្សាយដំណឹងល្អ គឺមិនមែនជាបញ្ហា រឿងជម្រើស សម្រាប់គ្រិស្តបរិស័ទនោះទេ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា នៅពេលដែលអ្នកជឿទទួលបានឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធហើយ ពួកគេមុខជាក្លាយជាសក្ខីភាពដ៏រស់រវើក "នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី" (គម្ពីរកិច្ចការ ១:៨)។ ព្រះជាម្ចាស់ទទួលបានការតម្កើងសិរីរុងរឿង នៅពេលមនុស្សបម្រើ និង ចូលមកបន្ថែមនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត ដ្បិតនៅក្នុងដំណើរការនេះ គ្រិស្តបរិស័ទ គឺបានក្លាយជាអ្នកជឿដែលមានប្រយោជន៍ និង មានផលផ្លែ ដែលព្រះគ្រិស្តបម្រុងសម្រាប់ពួកគេ (គម្ពីរយ៉ូហាន ១៥:១-៨)។

លំហាត់អនុវត្តន៍

---

១៤ កណ្ឌគម្ពីរកិច្ចការ ផ្តល់ឲ្យយើងនូវចំណេះដឹងខ្លះ អំពីរបៀបដែលយើងគួរមើលទៅកាន់ទំនួលខុសត្រូវរបស់យើង ក្នុងការចែកចាយដំណឹងល្អ។ ចូរអានខគម្ពីរទាំងនេះ ហើយប្រាប់ថា តើពួកសាវ័កបានឆ្លើយតបយ៉ាងដូចម្តេចនៅក្នុងព្រឹត្តិការណ៍នីមួយៗ៖

ក) គម្ពីរកិច្ចការ ៤:១៦-២០

ខ) គម្ពីរកិច្ចការ ៤:៣១

គ) គម្ពីរកិច្ចការ ៥:៤០-៤២

មានមនុស្សជាច្រើនកោដិ(បច្ចុប្បន្ន២០២៥ ប្រហែល៨.២កោដិ)នាក់នៅលើផែនដីនេះ។ មានការប៉ាន់ប្រមាណ មួយថា ប្រហែលជាពីរភាគបីនៃមនុស្សទាំងអស់នេះ មិនបានទទួលបន្ទាល់អំពីដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្តបានគ្រប់គ្រាន់នៅឡើយទេ។ ព្រះអម្ចាស់ដែលជាម្ចាស់ស្រែទ្រង់បាន ចាត់យើងឲ្យទៅប្រកាសដំណឹងល្អរបស់ទ្រង់ ទៅកាន់ពួកគេ។ ទ្រង់បានចាក់បង្ហូរព្រះវិញ្ញាណរបស់ទ្រង់មកលើពួកអ្នកបម្រើទ្រង់ ទូទាំងពិភពលោក ជំរុញពួកគេឲ្យថ្វាយខ្លួនរបស់ពួកគេដើម្បីធ្វើការងារផ្សព្វផ្សាយដំណឹងល្អដែលមិនទាន់បានចប់សព្វគ្រប់។ ទ្រង់មិនត្រឹមតែបានបំពាក់បំប៉ន់ក្រុមជំនុំ ជាមួយនឹងឫទ្ធានុភាពរបស់ព្រះវិញ្ញាណនោះទេ តែរួមជាមួយនឹងឧបករណ៍ដ៏មានប្រសិទ្ធិភាព ដើម្បីឲ្យក្រុមជំនុំអាចសម្រេចបាននូវ

បេសកកម្មរបស់ខ្លួន ដែលមានដូចជា វិទ្យុ ទូរទស្សន៍ សំណេរ និង ការប្រជុំផ្សព្វផ្សាយដំណឹងល្អធំៗ (នៅក្នុងវប្បធម៌របស់ប្រទេសខ្លះ)។ ដំណឹងល្អត្រូវបានប្រកាសជាលក្ខណៈទ្រង់ទ្រាយធំ ជាងពីមុន តាមរយៈមធ្យោបាយទាំងអស់នេះ។ ទោះជាយ៉ាងណា មធ្យោបាយដែលអស្ចារ្យជាងគេក្នុងការផ្សាយដំណឹងល្អ ទៅកាន់មនុស្សនៅក្នុងពិភពលោក គឺផ្អែកទៅលើសក្តីភាពដ៏មានប្រសិទ្ធិភាព និង គំរូដូចជាព្រះគ្រិស្ត នៅក្នុងអ្នកជឿម្នាក់ៗ ទៅតាមកន្លែងរៀងៗខ្លួនរបស់គេ។

បន្ទាប់មកទៀត គោលដៅរបស់យើងគឺគួរតែត្រូវមើលឲ្យឃើញថា បុគ្គលម្នាក់ៗដែលបាននាំមកឯព្រះគ្រិស្ត និងបាននាំចេញពីលោកីយ៍ ត្រូវបានចាត់ឲ្យត្រឡប់ទៅក្នុងលោកីយ៍វិញ ក្នុងនាមជាទូតម្នាក់សម្រាប់ព្រះគ្រិស្ត។ ជាមួយនឹងជំនឿថ្មី និង ខ្នាតគំរូថ្មី អ្នកជឿម្នាក់ៗត្រូវបានព្រះជាម្ចាស់បម្រុងឲ្យចូលទៅឯលោកីយ៍ម្តងទៀត ក្នុងនាមជាអ្នកតំណាងរបស់ទ្រង់ ប្រទានសេចក្តីសង្គ្រោះទៅដល់មនុស្សគ្រប់គ្នា។ តាមរបៀបនេះហើយ ដែលក្រុមជំនុំអាចបំពេញបេសកកម្មរបស់ខ្លួន ដោយការស្តាប់បង្គាប់ និង មានប្រសិទ្ធិភាព និង នាំយកសិរីរុងរឿងមកថ្វាយព្រះម្ចាស់ក្នុងពេលជាមួយគ្នានោះដែរ។

លំហាត់អនុវត្តន៍

---

១៥ ចូរឆ្លើយសំណួរខាងក្រោម យ៉ាងខ្លីៗ៖

ក) តើការបង្គាប់បញ្ជារបស់ព្រះគ្រិស្តទៅកាន់មនុស្សមានបាប គឺអ្វី? (ចូរប្រើពាក្យតែមួយ)

ខ) តើការបង្គាប់បញ្ជារបស់ព្រះគ្រិស្តទៅកាន់អ្នកជឿ គឺអ្វី? (ចូរប្រើពាក្យតែមួយ)

គ) តើអ្វីជារបស់សំខាន់ជាងគេ ដែលព្រះយេស៊ូបានប្រទានទៅកាន់ក្រុមជំនុំ សម្រាប់បំពេញបេសកកម្មរបស់ពួកគេ?

ឃ) តើអ្នកណាដែលត្រូវបានព្រះជាម្ចាស់ប្រើប្រាស់ដើម្បី ឈោងចាប់មនុស្សដែលបានបាត់បង់?

ង) ព្រះយេស៊ូបានមានព្រះបន្ទូលថាអ្នកជឿ មិនមែនកើតមកមាននិស្ស័យលោកីយ៍នោះទេ ។ តើទ្រង់មានចង់មានន័យយ៉ាងដូចម្តេច?

ច) តើទ្រង់ចង់មានន័យយ៉ាងដូចម្តេច នៅពេលដែលទ្រង់មានព្រះបន្ទូលថា អ្នកជឿគឺនៅក្នុងពិភពលោក?

ឆ) ឧទាហរណ៍មួយអំពីពួកសាវ័ក នៅក្នុងកណ្ឌគម្ពីរកិច្ចការ បង្រៀនយើងថា ទាក់ទងទៅនឹងបេសកកម្មរបស់ក្រុមជំនុំ តើពួកគេគួរមានឥរិយាបថយ៉ាងដូចម្តេច?

ការប្រឡងឆ្លាស់ខ្លួន

សំណួរពហុជម្រើសៗ ចូរជ្រើសរើសចម្លើយមួយដែលល្អបំផុត សម្រាប់សំណួរនីមួយៗ។

១ ការប្រើប្រាស់ពាក្យថា*ក្រុមជំនុំ* នៅក្នុងព្រះគម្ពីរ គឺសំដៅទៅលើ
- ក) ក្រុមមនុស្សដែលមានជំនឿស្រដៀងគ្នា។
- ខ) សហគមន៍មនុស្សដែលឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។
- គ) កន្លែងដែលមនុស្សជួបជុំគ្នា ដើម្បីថ្វាយបង្គំ។
- ឃ) ក្រុមមនុស្សដែលមានទស្សនៈគោលលទ្ធិដូចគ្នា។

២ ឧទាហរណ៍នៅក្នុងព្រះគម្ពីរអំពីក្រុមជំនុំ ដែលជាព្រះកាយដែលមានច្រើនទិដ្ឋភាព បញ្ជាក់ថា
- ក) មនុស្សដែលបានមកជួបជុំគ្នានៅក្នុងនាមព្រះនាមរបស់ព្រះជាម្ចាស់ បង្កើតបានទៅជាក្រុមជំនុំមួយ។
- ខ) មនុស្សម្នាក់ៗ នៅក្នុងទំនាក់ទំនងជាមួយព្រះគ្រិស្ត គឺជាក្រុមជំនុំរបស់ទ្រង់។
- គ) ក្រុមជំនុំគឺមានរួមបញ្ចូលមនុស្សជាច្រើននាក់ នៅក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយសារតែទំនាក់ទំនងជាលក្ខណៈបុគ្គលរបស់ពួកគេម្នាក់ជាមួយព្រះគ្រិស្ត។
- ឃ) ការជួបប្រជុំនីមួយៗគឺត្រូវបានរៀបចំឡើងតាមរបៀបដូចគ្នាទាំងអស់។

៣ ក្រុមជំនុំតាមតំបន់ ឬ ក្រុមជំនុំដែលអាចមើលឃើញ គឺសំដៅទៅលើ
- ក) ព្រះកាយទាំងមូលរបស់ព្រះគ្រិស្ត។
- ខ) អ្នកជឿដែលមកពីកន្លែងណាមួយ ដែលមានជំនឿដូចគ្នាទៅលើព្រះយេស៊ូគ្រិស្ត និង ជាអ្នកដែលបានជួបប្រជុំគ្នា ដើម្បីធ្វើការថ្វាយបង្គំ។
- គ) អ្នកជឿទាំងអស់ មកពីនិកាយតែមួយ។
- ឃ) ក្រុមជំនុំសាកល។

៤ ពាក្យថា*សហគមន៍* បានផ្តល់នូវគំនិតអំពី
- ក) រាជរដ្ឋាភិបាល
- ខ) ក្រុមជំនុំមួយដែលគេមិនអាចមើលឃើញ។
- គ) មនុស្សដែលមានគំនិតឧស្សាហ៍ពីគ្នា ក្នុងការធ្វើអ្វីមួយ។
- ឃ) ការចែករំលែក និង ការប្រកបរួមគ្នា។

៥ ព្រះគម្ពីរផ្តល់នូវភស្តុតាងថា ក្រុមជំនុំបានចាប់ផ្តើម
- ក) ក្នុងអំឡុងពេលដែលព្រះយេស៊ូធ្វើព័ន្ធកិច្ចនៅលើផែនដី។
- ខ) នៅក្នុងពេលដែលព្រះយេស៊ូយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ។
- គ) នៅថ្ងៃបុណ្យថ្ងៃទីហាសិប។
- ឃ) បន្ទាប់ពីលោកប៉ូលប្រែចិត្តជឿ។

៦ និស្ស័យខាងឯវិញ្ញាណរបស់ក្រុមជំនុំ គឺត្រូវបានស្តែងឲ្យឃើញនៅក្នុង

ក) ការបង្ហាញពីការរួបរួមរបស់ពួកអ្នកជឿ និង សេចក្តីស្រឡាញ់សម្រាប់គ្នាទៅវិញទៅមក។

ខ) ការគង់នៅរបស់ព្រះគ្រិស្តនៅក្នុងដួងចិត្តរបស់អ្នកជឿ។

គ) ព្រះអំណោយទាននៃព្រះវិញ្ញាណ។

ឃ) ការច្រៀង ការអធិស្ឋាន និង ការចែកចាយព្រះបន្ទូល។

៧ តើអ្វីជាភស្តុតាងល្អបំផុត ដែលបង្ហាញថាមនុស្សស្រឡាញ់ព្រះជាម្ចាស់?

ក) ពួកគេស្រឡាញ់អ្នកដទៃ។

ខ) ពួកគេចំណាយពេលវេលាជាច្រើនម៉ោង ក្នុងការអធិស្ឋាន និង ការថ្វាយបង្គំ។

គ) ពួកគេក្លាយជាសមាជិកនៃក្រុមជំនុំតាមតំបន់។

ឃ) ពួកគេធ្វើសក្ខីភាពទៅកាន់អ្នកមិនជឿ។

៨ ព្រះគម្ពីរបង្រៀនថា ព្រះអំណោយទាននៃព្រះវិញ្ញាណគឺត្រូវបានផ្តល់ទៅឲ្យ

ក) បុគ្គលណាដែលចង់មានព័ន្ធកិច្ចផ្ទាល់ខ្លួន។

ខ) ក្រុមជំនុំសម្រាប់ការកសាងឡើង ការប្រតិបត្តិការតាមរយៈអ្នកជឿ នៅពេលដែលពួកគេបម្រើគ្នាទៅវិញទៅមក។

គ) ដើម្បីឲ្យក្រុមជំនុំផ្សព្វផ្សាយដំណឹងល្អទៅកាន់ពិភពលោក។

ឃ) ដើម្បីបង្កើតបានទៅជាលក្ខណៈដូចជាព្រះគ្រិស្ត នៅក្នុងអ្នកដែលមានអំណោយទាន។

៩ នៅក្នុងឧទាហរណ៍ ដែលប្រាប់ថាក្រុមជំនុំគឺជាព្រះកាយរបស់ព្រះគ្រិស្ត យើងដឹងថា ក្រុមជំនុំលក្ខណៈរបស់ក្រុមជំនុំគួរបានមកពី

ក) សមាជិក

ខ) កិច្ចការ

គ) ព្រះសិរសា

ឃ) ការជួបជុំ និង ការប្រកបគ្នា

១០ **ចម្លើយខ្លីៗ** ។ ចូរបកស្រាយថាក្រុមជំនុំ មានគោលបំណងអ្វីខ្លះទាក់ទងនឹងចំណុចនីមួយៗខាងក្រោមនេះ៖

ក) ទាក់ទងនឹងព្រះជាម្ចាស់៖.....

ខ) ទាក់ទងនឹងក្រុមជំនុំខ្លួនឯងផ្ទាល់៖.....

គ) ទាក់ទងនឹងពិភពលោក៖.....

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៨ ខ) អ្នកជឿទាំងអស់ ដែលស្ថិតនៅក្នុងការរួបរួមមួយជាមួយព្រះគ្រិស្ត។

១ ចម្លើយរបស់អ្នក

៩ គ) ការជំនុំគ្នារបស់ពួកអ្នកជឿនៅតាមតំបន់ ក្រោមទំនាក់ទំនងមួយនៃសហភាពជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើសេចក្តីស្រឡាញ់។

២ ខ) ការជំនុំមនុស្សរបស់ព្រះជាម្ចាស់ ដែលជួបគ្នា និង ចែកចាយពីជំនឿដូចគ្នា និង ភាពស្មោះស្ម័គ្រដូចគ្នា ចំពោះព្រះយេស៊ូគ្រិស្ត។

គ) ការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ នៃអ្នកជឿដែលជឿទុកចិត្តលើព្រះសង្គ្រោះដូចគ្នា និង ជាអ្នកដែលមានការរួបរួម ជាមួយគ្នាទៅវិញទៅមក ក៏ដោយសារតែការរួបរួមរបស់ពួកគេជាមួយនឹងទ្រង់។

ង) សហគមន៍នៅទូទាំងពិភពលោកទាំងមូល នៃអ្នកជឿដែលបានទទួលស្គាល់ជំនឿដូចគ្នាទៅលើព្រះជាម្ចាស់ និង ទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូគ្រិស្ត។

១០ វាគឺជាទំនាក់ទំនងនៃក្តីស្រឡាញ់រវាងអ្នកជឿ និង ព្រះគ្រិស្ត។ គឺជាទំនាក់ទំនងនៃក្តីស្រឡាញ់របស់អ្នកជឿសម្រាប់គ្នាទៅវិញទៅមក។

៣ ខ) បទគម្ពីរនេះផ្តល់នូវភស្តុតាងដែលបង្ហាញថា ការសុគត ការមានព្រះជន្មរស់ និង ការយាងត្រឡប់ទៅស្ថានសួគ៌របស់ទ្រង់កើតឡើងតាំងពីមុនពេលដែលទ្រង់អាចបង្កើតក្រុមជំនុំរបស់ទ្រង់មកម្ល៉េះ។

១១ ចម្លើយទាំងអស់សុទ្ធតែត្រឹមត្រូវ លើកលែង ចម្លើយក)

៤ ពួកសិស្សបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដូចដែលព្រះយេស៊ូបានមានព្រះបន្ទូលសន្យា។ មនុស្សប្រមាណ ៣០០០នាក់ បានទទួលយកសារដំណឹងល្អ និង បានបន្ថែមទៅលើចំនួនរបស់អ្នកជឿ។

១២ ចម្លើយមួយណាក៏បាន៖ សិរីរុងរឿង កិត្តិយស ការគោរព ការសរសើរ ការអរព្រះគុណ និង ការស្តាប់បង្គាប់។

៥ ប្រៀបធៀបចម្លើយរបស់អ្នកជាមួយការរៀបរាប់របស់យើង នៅក្នុងមេរៀននេះ បន្ទាប់មកប្រៀបធៀបជាមួយនឹងតួនាទីនៅក្នុងក្រុមជំនុំតាមតំបន់របស់អ្នក។

១៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយទាំងនេះ៖

ក)ការកសាងឡើង ការបង្កើត ការណែនាំ ការធ្វើឲ្យប្រសើរឡើង ការពង្រឹងកម្លាំង ឬ ការអប់រំ។

ខ) ព្រះអំណោយទានដែលប្រទានទៅឲ្យក្រុមជំនុំ ឬ សម្រាប់ប្រយោជន៍របស់ក្រុមជំនុំជារួម។ ព្រះអំណោយទានត្រូវបានស្តែងចេញឡើងនៅក្នុងការថ្វាយបង្គំរួមគ្នា។

គ) ព្រះវិញ្ញាណបង្កើតបានជាផលផ្លែរបស់ទ្រង់ នៅក្នុងយើងរាល់គ្នា តាមរយៈទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ ផលផ្លែនៃព្រះវិញ្ញាណមិនអាចដុះបាន នៅក្រៅទំនាក់ទំនងនេះឡើយ។

៦ ក) ១) បុគ្គលអ្នកជឿម្នាក់ៗ

ខ) ២) ក្រុមជំនុំតាមតំបន់

គ) ២) ក្រុមជំនុំតាមតំបន់

ឃ) ៣) ក្រុមជំនុំសាកល

ង) ៣) ក្រុមជំនុំសាកល

ច) ១) បុគ្គលអ្នកជឿម្នាក់ៗ

១៤ ក) ពួកគេមិនអាចធ្វើអ្វីបានទេ ក្រៅតែពីការនិយាយអំពីអ្វីដែលគេបានឃើញ និង បានឮ។

ខ) ពួកគេបានថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យ៉ាងអង់អាចក្លាហាន។

គ) ពួកគេមិនបានឈប់ បង្រៀន និង ប្រកាសដំណឹងល្អដែលថាព្រះយេស៊ូគឺជាព្រះគ្រិស្តបានឡើយ។

៧ ក) ឃ) ង) ឆ) និង ជ) គឺជាចម្លើយត្រឹមត្រូវ។

១៥ ក) មក

ខ) ទៅ

គ) ព្រះវិញ្ញាណដ៏វិសុទ្ធ

ឃ) អ្នកជឿ (ក្រុមជំនុំ)

ង) អ្នកជឿបានកាត់ផ្តាច់ខ្លួនពីរបៀបរស់នៅរបស់លោកីយ៍ និង លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកីយ៍ទៀតហើយ។

ច) អ្នកជឿមានបេសកកម្ម សង្គ្រោះពិភពលោក ឬ ផ្សព្វផ្សាយដំណឹងល្អទៅកាន់ពិភពលោក។

ឆ) តរិយោបថមួយថា ក្រុមជំនុំត្រូវធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីចែកចាយដំណឹងល្អ ទៅកាន់លោកីយ៍ទាំងមូល។

មេរៀនទី ១០ អនាគត៖ ការបើកបង្ហាញ ខ្ចាន់ និង ការសង្រ្គោក

ព្រះគម្ពីរមានរឿងជាច្រើន និយាយអំពីការបំពេញតាមផែនការរបស់ព្រះជាម្ចាស់ សម្រាប់ប្រជារាស្ត្ររបស់ទ្រង់។ នៅក្នុងព្រះបន្ទូលដំបូងបង្អស់របស់ទ្រង់ បន្ទាប់ពីបុណ្យថ្ងៃទីហាសិប លោកពេត្រុសបានប្រកាសថានៅក្នុងថ្ងៃអនាគត ព្រះជាម្ចាស់នឹងស្រោចស្រង់អ្វីៗគ្រប់យ៉ាង (គម្ពីរកិច្ចការ ៣:២១)។ បន្ទាប់មក ជាមួយពាក្យដ៏គួរឲ្យជំរុញចិត្ត លោកសាវ័កប៉ូលបានបង្ហាញពីលក្ខណៈនៃអ្វីដែលត្រៀមទុកសម្រាប់គ្រិស្តបរិស័ទ នៅថ្ងៃមុខ (គម្ពីររ៉ូម ៨:១៨-២៥)។ លោកបានមានប្រសាសន៍ថា របស់សព្វសារពើ កំពុងតែទន្ទឹងរង់ចាំការបើកបង្ហាញ ផែនការនៃការប្រោសលោះរបស់ព្រះជាម្ចាស់។

តាំងពីពេលដែលមនុស្សជាតិបានធ្លាក់ចុះ ធម្មជាតិបានធ្លាក់ទៅក្រោមឥទ្ធិពលដ៏អាក្រក់ នៃបណ្តាសារ។ មនុស្សជាតិក៏បានស្រែកថ្ងូរ នៅក្រោមបន្ទុកនៃការបង្ខិតបង្ខំឲ្យរស់នៅដោយភាពខ្វះខាត ដែលបានមកពីផែនដីដែលត្រូវបណ្តាសារអំពើបាប និង ដ៏ចចេសរឹងរូសមួយនេះ។ ខ្លួនប្រាណរបស់យើងបានរងទុក្ខពីជំងឺ និង ការពុកផុយរលួយ។ ជាមួយនឹងត្រចៀកដែលផ្ទៀងស្តាប់ព្រះសូរសៀងព្រះអាទិករបស់យើង យើងរាល់គ្នា (រួមជាមួយនឹងស្មាព្រះហស្តរបស់ទ្រង់ផ្សេងទៀត) ទន្ទឹងរង់ចាំព្រះបន្ទូលដែលថ្លែងព្រះពរថា៖ "អ្វីៗទាំងអស់នឹងលែងត្រូវបណ្តាសាទៀតហើយ" (គម្ពីរវិវរណៈ ២២:៣)។ ពេលវេលានឹងឈានចូលមកដល់ នៅពេលដែលព្រះជាម្ចាស់នឹងដោះស្រាយជាមួយនឹងប្រភពដើមនៃបញ្ហាទាំងអស់នេះ។ មនុស្ស រួមទាំងសាតាំងផង នឹងត្រូវកាត់ទោស ហើយព្រះយេស៊ូនឹងយាងមកយកមនុស្សសុចរិតទៅជាមួយទ្រង់នៅឯស្ថានបរមសុខ។ នោះគឺជាសេចក្តីសង្ឃឹមដ៏មានពររបស់អ្នកជឿ!

នៅក្នុងមេរៀននេះ យើងនឹងពិភាក្សាគ្នាអំពីការបំពេញតាមបទទំនាយនៅក្នុងព្រះគម្ពីរ និង ការសម្រេចផែនការរបស់ព្រះជាម្ចាស់នៅថ្ងៃអនាគត។ នៅពេលដែលយើងពិចារណាអំពីបញ្ហាសំខាន់ៗទាំងអស់នេះ សូមឲ្យសេចក្តីសង្ឃឹមដែលព្រះបានប្រទានមក ជួយឲ្យអ្នកសិក្សាអំពីខ្លួនឯងឲ្យកាន់តែច្បាស់ និងបន្សុទ្ធខ្លួនឯងឲ្យល្អលះអស់នូវអ្វីៗដែលអាចរារាំងអ្នក ពីការត្រៀមខ្លួនសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់នៃយើង។

គោលបំណងមេរៀន

ក. សេចក្តីសង្ឃឹមដ៏មានពរ
ខ. ទុក្ខវេទនា
គ. ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត
ឃ. រយៈពេលមួយពាន់ឆ្នាំ
ង. ការវិនិច្ឆ័យសាតាំង និង មនុស្សអាក្រក់ដែលបានស្លាប់
ច. ការបង្កើតថ្មី

ខគម្ពីរបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. កំណត់និយមន័យពីសេចក្តីសង្ឃឹមដ៏មានពរ។
២. ពិភាក្សាថាតើ ព្រឹត្តិការណ៍នៃបទទំនាយណាខ្លះ នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩ និង អេម៉ុសជំពូក៩ បានកើតមានឡើងរួចទៅហើយ។
៣. បកស្រាយព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត និង សមរភូមិនៅឯ អើម៉ាគេដូន។
៤. បកស្រាយថាតើមានលក្ខខ័ណ្ឌអ្វីខ្លះ ដែលនឹងនាំឲ្យមានការបើកសម្តែងរបស់ព្រះគ្រិស្ត និង រៀបរាប់អំពីលទ្ធផលចុងក្រោយរបស់អ្នកដឹកនាំនៃគូបដិបក្សទាំងពីរ។
៥. ពិភាក្សាអំពីគោលបំណង និង រៀបរាប់អំពីលក្ខណសម្បត្តិនៃរាជ្យមួយពាន់ឆ្នាំ។
៦. បកស្រាយមូលហេតុដែលសាតាំង នឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយពាន់ឆ្នាំ និង បកស្រាយអំពីគោលបំណងនៃបល្ល័ង្កមួយធំពណ៌ស។
៧. ប្រាប់ពីមូលដ្ឋានគ្រឹះដែលអ្នករំពឹងទុកថាជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់បានបង្កើតឡើង។

សកម្មភាពក្នុងការសិក្សា

១. ដើម្បីជាបង្អែកសម្រាប់មេរៀននេះ សូមអានគម្ពីរម៉ាថាយ ២៤ គម្ពីរម៉ាកុស ១៣ គម្ពីរលូកា២១ គម្ពីរ ១កូរិនថូស ១៥ គម្ពីរ១ថេស្សាឡូនិក៤:១៣-១៧, ២ថេស្សាឡូនិក២:១-១២, និង គម្ពីរវិវរណៈ១៩។ ត្រូវប្រាកដផងដែរថា អ្នកបានបើករក និង អាន បទគម្ពីរយោងដទៃទៀត ដែលបានផ្តល់ជូននៅក្នុងមេរៀន។ ធ្វើការសិក្សាមេរៀន និង ការប្រឡងផ្ទាល់ខ្លួន ដូចធម្មតា។
២. បន្ទាប់ពីអ្នកបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី៨ ដល់ទី១០ (ជំពូកទី៣ឡើងវិញ)។ បន្ទាប់មកធ្វើ*ការប្រឡងជំពូកទីបី ។*

ពាក្យសំខាន់ៗ

គួរឲ្យស្អប់ខ្ពើម	បោះបង់	ការកែលំអរ
ការប្រមាថ	ការបែកខ្ញែក	ឆ្នាំសប្ប័ទ
ការប្រឈមមុខ	ការផុតពូជ	ការប្រមាថវត្ថុពិសិដ្ឋ(សក្ការៈ)
ការបំពេញ	ដែលមិនវិនាស	ពេលកំណត់
លើកជាព្រះ	ដែលអាចវិនាស	ជម្រះទោស

ក. សេចក្តីសង្ឃឹមដ៏មានពរ

វត្ថុបំណងទី១. *កំណត់និយមន័យសេចក្តីសង្ឃឹមដ៏មានពរ។*

នៅក្នុងសំបុត្ររបស់លោកសាវ័កប៉ូលទៅកាន់លោកទីតុស លោកថ្លែងថាដំណឹងល្អនៃព្រះគុណរបស់ព្រះជាម្ចាស់បានលេចមកឯមនុស្សគ្រប់គ្នា។ សំបុត្រនោះបានចោទជាចំណោទទៅកាន់ពួកគេជាមួយនឹងជម្រើសខាងឯសីលធម៌ ថាតើពួកគេនឹងនិយាយថា *ទេ* ទៅកាន់អំពើមិនបរិសុទ្ធ និង ចំណង់របស់លោកីយ៍ ហើយបែរមករស់នៅក្នុងជីវិតដែលចេះគ្រប់គ្រងខ្លួនឯង និង គោរពកោតខ្លាចព្រះជាម្ចាស់នៅក្នុងពេលបច្ចុប្បន្ននេះ នៅពេលដែលពួកគេកំពុងរងចាំ*សេចក្តីសង្ឃឹមដ៏មានពរ*ដៃរឬអត់។ លោកបានមានប្រសាសន៍ថា សេចក្តីសង្ឃឹមដ៏មានពរនោះ គឺជាការបង្ហាញប្រកបដោយសិរីរុងរឿង របស់ព្រះជាម្ចាស់ដ៏ធំអស្ចារ្យរបស់យើង និង ព្រះអង្គសង្គ្រោះព្រះយេស៊ូគ្រិស្ត (គម្ពីរទីតុស ២:១១-១៤)។ ការបើកបង្ហាញរបស់ទ្រង់ ក៏នឹងនាំមកនូវការបំផ្លិចបំផ្លាញសម្រាប់អំណាចទាំងអស់ដែលទាស់នឹងព្រះជាម្ចាស់។ នៅពេលដែលយើងចាប់ផ្តើមសិក្សា "រឿងចុងក្រោយ" ឬ ព្រឹត្តិការណ៍គ្រាចុងក្រោយ យើងនឹងបង្វែរការយកចិត្តទុកដាក់របស់យើងទៅលើសេចក្តីសង្ឃឹមដ៏មានពររបស់អ្នកជឿជាមុនសិន។

នៅប៉ុន្មានម៉ោងចុងក្រោយ មុនពេលដែលទ្រង់សុគត ព្រះអម្ចាស់នៃយើងទ្រង់បានបង្ហាញទៅកាន់ពួកសាវ័កទាំង១២នាក់ អំពីមូលដ្ឋានគ្រឹះសម្រាប់សេចក្តីសង្ឃឹមរបស់អ្នកជឿ។ ទ្រង់បានមានព្រះបន្ទូលអំពីដំណាក់របស់ព្រះវរបិតាទ្រង់ ដែលមានបន្ទប់យ៉ាងច្រើន។ ទ្រង់បានប្រាប់ទៅពួកគេ ថាទ្រង់ចាកចេញទៅដើម្បីរៀបចំកន្លែងសម្រាប់ពួកគេ (និងសម្រាប់អស់អ្នកដែលជឿលើទ្រង់)។ ទ្រង់ក៏បាន ធានាប្រាប់ពួកគេថា ពិតដូចជាការចាកចេញរបស់ទ្រង់ ទ្រង់ក៏នឹងយាងត្រឡប់មកវិញដើម្បីយកពួកគេទៅរស់នៅរួមជាមួយទ្រង់ផងដែរ (គម្ពីរយ៉ូហាន ១៤:១-៣)។

ព្រះបន្ទូលនៃក្តីសង្ឃឹមនេះ ត្រូវបានបញ្ជាក់បន្ថែមដោយទេវតាដែលបានលេចមកក្រោយពេលព្រះយេស៊ូទ្រង់បានយាងត្រឡប់ទៅឯស្ថានបរមសុខវិញ។ លោកបានថ្លែងថា៖ "ព្រះយេស៊ូនោះ ព្រះជាម្ចាស់បានលើកពីកណ្តាលចំណោមអ្នករាល់គ្នា ឡើងទៅស្ថានបរមសុខហើយ ព្រះអង្គនឹងយាងត្រឡប់មកវិញតាមរបៀបដូចដែលអ្នករាល់គ្នាបានឃើញទ្រង់យាងឡើងទៅស្ថានបរមសុខដែរ"(គម្ពីរកិច្ចការ ១:១១)។ លោកសាវ័កប៉ូល បានប្រកាសឡើង ដោយមានការបើកសម្តែងពីព្រះជាម្ចាស់ថា អ្នកជឿរងចាំ "ការប្រោសលោះ" រូបកាយរបស់គេយ៉ាងអន្ទះសារ (គម្ពីររ៉ូម ៨:២៣) ដែលរូបកាយនោះនឹងផ្លាស់ប្តូរនៅពេលព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តបង្ហាញអង្គទ្រង់មក (គម្ពីរភីលីព ៣:២០-២១)

បទគម្ពីរបង្ហាញថា ការយាងមកររបស់ព្រះអម្ចាស់ រួមមានពីរទិដ្ឋភាព ៖ ទី១) ការយាងមក*សម្រាប់*អ្នកជឿ និង ទី២) ការយាងមក*ជាមួយ*ពួកគេ(អ្នកជឿ)។ ការយាងមករបស់ទ្រង់*សម្រាប់*អ្នកជឿគឺត្រូវបានហៅថា "ការឆក់ឡើង(ការលើកឡើង)" ហើយការយាងមករបស់ទ្រង់*ជាមួយ*ពួកគេគឺហៅថា ការបើកសម្តែង។ ស្របពេលដែលយើងអធិប្បាយរឿងរ៉ាវ នៃព្រឹត្តិការណ៍នាគ្រាចុងក្រោយ យើងត្រូវពិភាក្សាគ្នាអំពីព្រឹត្តិការណ៍ទាំងពីរនេះ។ ដំបូង ចូរយើងពិចារណាអំពីការឆក់ឡើង និង រង្វាន់របស់អ្នកជឿ ហើយបន្ទាប់មកអំពីទំនាក់ទំនងនៃរឿងទាំងនេះជាមួយនឹងព្រឹត្តិការណ៍ផ្សេងទៀត។

លំហាត់អនុវត្តន៍

១ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ *សេចក្តីសង្ឃឹមដ៏មានពរ* គឺសំដៅទៅលើ

ក) ការបើកសម្តែងរបស់ព្រះគ្រិស្ត នៅពេលដែលទ្រង់យាងមក *ជាមួយ* មនុស្សរបស់ទ្រង់។

ខ) ការឆក់អ្នកជឿឡើងទៅ នៅពេលដែលព្រះគ្រិស្តយាងមក *សម្រាប់* ពួកគេ។

គ) ព្រឹត្តិការណ៍នាគ្រាចុងក្រោយទាំងអស់។

ការឆក់អ្នកជឿឡើងទៅ

នៅពេលព្រះជាម្ចាស់ ជាមួយនឹងប្រាជ្ញាញាណជាក្សត្ររបស់ទ្រង់ បានកំណត់ថាកិច្ចការនៃការចែកចាយដំណឹងល្អបានសម្រេចពេញបរិបូរណ៌ហើយ ទ្រង់នឹងចាប់ផ្តើម*ការជម្រះទោស* (ជាពេលមួយដែលអ្វីម្យ៉ាងត្រូវបានធ្វើឲ្យពេញលេញ និង ល្អឥតខ្ចោះ) នៅក្នុងផែនការរបស់ទ្រង់។

លំហាត់អនុវត្តន៍

២ ចូរប្រៀបធៀមគម្ពីរម៉ាថាយ ២៤:១៤ ជាមួយនឹង គម្ពីរម៉ាថាយ ២៤:៣៦។ យោងទៅតាមខគម្ពីរទាំងនេះ តើយើងអាចដឹងអ្វីខ្លះ អំពីគ្រាដែលព្រះយេស៊ូយាងត្រឡប់មកសម្រាប់អស់អ្នកដែលជារាស្ត្ររបស់ទ្រង់?

.....

នៅក្នុងគម្ពីរ១ថេស្សាឡូនិក ៤:១៧ យើងឃើញថា អ្នកជឿនឹងត្រូវបាន "លើកឡើង" (ឆក់យក) ទៅជួបព្រះអម្ចាស់នៅទីអាកាស ហើយត្រូវនាំទៅទីកន្លែងស្នាក់នៅ ដូចដែលបានសន្យានៅក្នុងគម្ពីរយ៉ូហាន ១៤:១-៣ ។ នៅក្នុងគម្ពីរ១កូរិនថូស ១៥:៥០-៥២ លោកប៉ូលបានបង្ហាញថា រូបកាយសាច់ឈាមរបស់អ្នកជឿទាំងអស់នឹងត្រូវបានផ្លាស់ប្តូរ ស្របពេលដែលរូបកាយដែលអាចស្លាប់របស់ពួកគេ ត្រូវបានប្រែមួយរំពេច ហើយត្រូវបានត្រៀមសម្រាប់ស្ថានបរមសុខ។ ព្រឹត្តិការណ៍នេះ នឹងកើតឡើងភ្លាមៗ។ ទោះបីជាអ្នកជឿនៅកន្លែងក៏ណាដោយ ពួកគេនឹងត្រូវបាន "លើកឡើង" ភ្លាមៗ។ ព្រះគម្ពីរបានប្រៀបធៀបព្រឹត្តិការណ៍ភ្លាមៗនេះ ទៅនឹងការចូលលួចរបស់ចោរនៅពេលយប់ (គម្ពីរ១ថេស្សាឡូនិក ៥:២)។

សារបន្ទូលសម្រាប់អ្នកជឿគឺពិតយ៉ាងដូច្នេះថា៖ ពួកគេត្រូវតែប្រុងប្រយ័ត្ន និង គ្រប់គ្រងខ្លួនឯង នៅពេលដែលពួកគេរស់ពីមួយថ្ងៃទៅមួយថ្ងៃ ត្រូវដឹងថាការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ នឹងធ្លាក់មកលើអស់អ្នកបដិសេធការប្រទានសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ (គម្ពីរ១ថេស្សាឡូនិក ៥:១-១១)។ ដូច្នេះសេចក្តីសង្ឃឹមរបស់អ្នកជឿគឺថា ១) ការប្រោសលោះឲ្យផុតពីព្រះពិរោធរបស់ព្រះជាម្ចាស់ដែលនឹងមកដល់ ២) អភ័យឯកសិទ្ធិ ក្នុងការមើលឃើញព្រះអម្ចាស់របស់ពួកគេ និង ៣) ត្រូវបានធ្វើឲ្យបានដូចជាទ្រង់ (គម្ពីរ១យ៉ូហាន ៣:២)។

លំហាត់អនុវត្តន៍

៣ ចូរអានគម្ពីរ១ថេស្សាឡូនិក ៤:១៣-១៧ ហើយបំពេញចន្លោះបន្ទាត់ដើម្បីបង្គ្រប់ប្រយោគទាំងនេះ។

ក) អ្នកជឿពីរប្រភេទដែលនឹងត្រូវបានឆក់យកឡើងទៅ៖ .....
និង .....

ខ) សេចក្តីសង្ឃឹមរបស់អ្នកជឿ ទៅលើការយាងត្រឡប់មករបស់ព្រះអម្ចាស់ គឺផ្អែកទៅលើ.....
.....

គ) លោកប៉ូលបានបង្ហាញថា អ្នកមិនជឿទួញសោក ដោយព្រោះតែពួកគេគ្មាន.....
.....ទៅលើការប្រោសរូបកាយឲ្យរស់ឡើងវិញ និងជីវិតអស់កល្បជានិច្ច។

ការសិក្សាស៊ីជម្រៅមួយទៅលើគម្ពីរ១កូរិនថូស ១៥:៥០-៥៤ បង្ហាញថា នឹងមានការផ្លាស់ប្តូរមួយចំនួនកើតឡើង ទៅក្នុងពេលនៃការឆក់យកអ្នកជឿឡើងទៅ។ នៅក្នុងពេលដែលមានការឆក់យកឡើងទៅ អ្នកជឿដែលកំពុងមានជីវិតរស់នៅឡើង នឹងផ្លាស់ប្តូរពីភាពសាច់ឈាមដែលអាចស្លាប់បាន ទៅជាមានភាពអមតៈ។ នេះមានន័យថា ពួកគេនឹងមិនអាចស្លាប់បាននោះទេ។ អ្នកជឿដែលបានស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យមានជីវិតរស់ជាមុនសិន ហើយបន្ទាប់មកពួកគេនឹងត្រូវបានផ្លាស់ប្តូរពី "ភាពដែលអាចវិនាស" (ដែលអាចផុយរលួយ ឬ កំទេច) ទៅជាមាន "ភាពមិនអាចវិនាស" (ដែលនឹងមិនផុយរលួយ) វិញ។ ដោយសារតែសាច់ និង ឈាមដែលជារូបកាយខាងឯសាច់ឈាមរបស់យើងបច្ចុប្បន្នមិនអាចទទួលស្នងព្រះរាជ្យរបស់ព្រះជាម្ចាស់បាន អ្វីដែលត្រូវធ្វើនោះគឺថាពួកគេនឹងត្រូវបានផ្លាស់ប្តូរឲ្យមានរូបកាយដែលមាន*សិរីរុងរឿង* ។ យើងមិនយល់អ្វីគ្រប់យ៉ាងអំពីរូបកាយដែលមានសិរីរុងរឿងទាំងនេះទេ ប៉ុន្តែយើងដឹងថារូបកាយទាំងអស់នោះ នឹងមិនទទួលការឈឺចាប់ មានជំងឺ ឬស្លាប់ទៀតទេ ហើយពួកគេនឹងរស់រានមានជីវិតអស់កល្បជានិច្ច។

ការឆក់យកនឹងកើតឡើងភ្លាមៗ ហើយគ្មាននរណាម្នាក់ដឹងពីពេលវេលាជាក់លាក់ លើកលែងតែព្រះជាម្ចាស់ យើងក៏ទទួលបានតម្រុយខ្លះអំពីពេលវេលាដែលការនោះនឹងកើតឡើង។ ព្រះយេស៊ូបានមានព្រះបន្ទូលថា នឹងមានទីសំគាល់ ឬ ភាពចលាចលនៅឯនគរស្ថានសួគ៌ ដែលអាចនឹងបង្កឲ្យមានភាពតានតឹង ឬ ទុក្ខព្រួយ នៅក្នុងប្រជាជាតិជាច្រើន។ លើសពីនេះទៅទៀត នឹងមានគ្រោះទុរភិក្ស ជំងឺ និងសង្គ្រាមកើតឡើង ថែមពីលើទីសំគាល់ដែលមាននៅឯស្ថានសួគ៌ (សូមមើលគម្ពីរលូកា ២១:១០,២៥-២៨)។ ព្រឹត្តិការណ៍ទាំងនេះ គឺគ្រាន់តែជាការផ្តល់សញ្ញាអំពីការ ខិតចូលជិតទៅដល់ទីបញ្ចប់។ អ្នកជឿបានដឹងតាមរយៈការទាំងនេះ ថា ការរួបរួមរបស់ពួកគេជាមួយនឹងព្រះគ្រិស្តក៏ជិតមកដល់ ក៏ដូចជា *ការរួបរួមគ្នាសាជាថ្មី* ជាមួយមិត្តជាទីស្រឡាញ់ និង សាច់ញាតិដែលបានទៅនៅជាមួយព្រះជាម្ចាស់មុននោះផងដែរ។

លំហាត់អនុវត្តន៍

៤ ចូរបកស្រាយយ៉ាងខ្លី អំពីអ្វីដែលនឹងកើតឡើងចំពោះរូបកាយសាច់ឈាមរបស់អ្នកដែលកំពុងរស់ និង អ្នកដែលបានស្លាប់ទៅ នៅក្នុងពេលដែលមានការឆក់យកឡើងទៅ។

.....

រង្វាន់របស់អ្នកជឿ

មានឯកសារយោងមួយចំនួននៅក្នុងព្រះគម្ពីរ បង្ហាញថាអ្នកជឿនឹងទទួលបានរង្វាន់ដោយផ្អែកទៅលើឥរិយាបថគ្រិស្តបរិស័ទរបស់ពួកគេ (សូមមើលគម្ពីរម៉ាថាយ ១៦:២៧ គម្ពីរ២យ៉ូហាន ខ៨ គម្ពីរវិវរណៈ ២២:១២)។ លោកប៉ូលបានមានប្រសាសន៍ទៅកាន់សមាជិកនៃក្រុមជំនុំក្រុងកូរិនថូសថា៖ "ដ្បិតយើងទាំងអស់គ្នានឹងត្រូវទៅឈរនៅមុខទីកាត់ក្តីរបស់ព្រះគ្រិស្ត" (គម្ពីរ២កូរិនថូស ៥:១០)។ ពាក្យថា *ទីកាត់ក្តី* គឺបានបកប្រែមកពីពាក្យ *ប៊ីម៉ា* (Bema) ហើយត្រូវបានគេស្គាល់យ៉ាងច្បាស់ថា *វេទិកាពិនិត្យពិច័យរង្វាន់* ។ ការបង្ហាញដ៏ល្អមួយអំពីវេទិកានេះគឺថា វេទិកាដូចទៅនឹងវេទិកាដែលចៅក្រមក្នុងការប្រកួតអូឡាំពិក ឈរពិនិត្យពិច័យការប្រកួត ដើម្បីឲ្យពួកគេអាចផ្តល់រង្វាន់សម្រាប់អ្នកឈ្នះ។ គោលបំណងនៃការពិនិត្យពិច័យនេះគឺ ដើម្បីឲ្យអ្នកជឿគ្រប់គ្នា មកប្រាប់អំពីរឿងរ៉ាវរបស់ពួកគេទៅកាន់ព្រះជាម្ចាស់ (គម្ពីររ៉ូម ១៤:១០-១២)។

ការវិនិច្ឆ័យទោសរបស់យើងដោយព្រះជាម្ចាស់ គឺជាការពិនិត្យពិច័យអំពីការបម្រើជាគ្រិស្តបរិស័ទរបស់យើង។ ការនោះមិនមែនជាស្រេចទៅលើ *បរិមាណ* នៃកិច្ចការដែលយើងបានធ្វើនោះទេ ប៉ុន្តែគឺទៅលើ *គុណភាព* នៃអ្វីដែលយើងបានធ្វើសម្រាប់ព្រះជាម្ចាស់ ដែលនឹងត្រូវបានពិនិត្យឡើងវិញ។ តើមានអ្វីខ្លះដែលជាការជំរុញការបម្រើរបស់យើង។ តើវាត្រូវបានធ្វើឡើងថ្វាយទៅកាន់ទ្រង់ដោយមិនគិតពីខ្លួនឯង ឬក៏យើងបានបម្រើ គ្រាន់តែដើម្បីបង្វែរការចាប់អារម្មណ៍មកកាន់ទេពកោសល្យ សមត្ថភាព និង ធនធានរបស់យើងនោះទេ? ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ៗ ថា គុណភាពនៃកិច្ចការរបស់យើង នឹងត្រូវបានពិនិត្យពិច័យ ហើយការបម្រើដែលឆ្លងផុតការល្បងល ជាប់ជា *ការបម្រើដែលមានគុណភាព* នឹងត្រូវទទួលបានរង្វាន់។ ការបម្រើដែលត្រូវបានជំរុញដោយភាពអាត្មានិយម និង អំណួត នឹងមិនត្រូវទទួលបានរង្វាន់នោះទេ(សូមមើលនៅក្នុង គម្ពីរ១កូរិនថូស ៣:១១-១៥)។

ទោះបីជា ពេលវេលានៃការពិនិត្យពិច័យ មិនត្រូវបាននរណាម្នាក់ដឹងជាក់ច្បាស់ ក៏មានអ្នកប្រាជ្ញខាងព្រះគម្ពីរខ្លះ ជឿថា គ្រានោះនឹងកើតឡើងបន្ទាប់ពីការឆក់ឡើងទៅ។ ស្របពេលអស់អ្នកដែលបដិសេធនឹងការសង្គ្រោះរបស់ព្រះជាម្ចាស់ កំពុងតែឆ្លងកាត់គ្រាមួយដែលពេញដោយអំពើទុច្ចរិត ទុក្ខព្រួយ និង ភាពចលាចល មិនដែលធ្លាប់ឃើញពីមុនមកនៅលើផែនដី អ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះអម្ចាស់នឹងត្រូវបានតម្កើងកិត្តិយស នៅក្នុងព្រះវត្តមានរបស់ទ្រង់។

លំហាត់អនុវត្តន៍

៥ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ បទគម្ពីរបង្រៀនយើងថា អ្នកជឿគ្រប់គ្នា នឹងត្រូវបានរៀបរាប់រឿងរ៉ាវនៃការបម្រើរបស់ផងគេទៅកាន់ព្រះជាម្ចាស់ និងបង្រៀនថា មនុស្សគ្រប់គ្នានឹង

ក) ទទួលបានរង្វាន់ដូចគ្នា ទោះបីជាការបម្រើរបស់ពួកគេ ធំ ឬ តូចប៉ុនណាក៏ដោយ។

ខ) ទទួលបានរង្វាន់មួយដែលផ្អែកទៅលើទាំង បរិមាណ និង គុណភាព នៃការបម្រើរបស់ពួកគេ។

គ) ទទួលបានរង្វាន់មួយដែលផ្អែកលើបំណងចិត្ត ឬ គុណភាពនៃការបម្រើរបស់គេ។

ឃ) បើទោះជារង្វាន់ ឬ ការដាក់ទោសនោះក៏ដោយ។

៦ ដោយឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក ចូរបកស្រាយខ្លីៗអំពីឃ្លានីមួយៗនៅខាងក្រោមនេះ។

ក) រូបកាយដែលមានសិរីរុងរឿងរបស់អ្នកជឿ។

ខ) ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត

គ) ការឆក់យកឡើងទៅ

ឃ) សេចក្តីសង្ឃឹមដ៏មានពរ

ង) ទីកាត់ក្តីរបស់ព្រះគ្រិស្ត

ខ. គ្រាមហាទេវតា

នៅក្នុងការថ្លែងព្រះបន្ទូលនៅភ្នំអូលីវ ដែលមានកត់ត្រានៅក្នុងគម្ពីរម៉ាថាយ ២៤ គម្ពីរម៉ាកុស ១៣ និងគម្ពីរលូកា ២១ ព្រះយេស៊ូបានមានបន្ទូលតបទៅនឹងសំណួរដែលពួកសាវ័កចោទសួរថា៖ តើពេលណាទើបព្រះវិហារក្នុងពេលបច្ចុប្បន្ននេះ នឹងត្រូវបានបំផ្លាញ? និង ២) តើនឹងមានអ្វី ជាសញ្ញាសំគាល់អំពីការយាងមកវិញរបស់ទ្រង់ និង អំពីគ្រាចុងក្រោយ?

ចម្លើយរបស់ព្រះយេស៊ូ សម្រាប់សំណួរដ៏សំខាន់ទាំងពីរសំណួរនេះ គឺត្រូវបានច្របល់ចូលលាយគ្នាដែលធ្វើឲ្យមានការលំបាកក្នុងការកំណត់ថាតើទិដ្ឋភាពណានៃចម្លើយរបស់ទ្រង់សំដៅទៅលើការបំផ្លាញព្រះវិហារ និង ការខ្ចាត់ខ្ចាយ (ការបែកខ្ញែក) របស់ពួកយូដា ជាព្រឹត្តិការណ៍មួយដែលនឹងកើតឡើងឆាប់ៗ និង ចម្លើយសំដៅទៅលើសញ្ញាសំគាល់ដែលនឹងមកមុនការយាងត្រឡប់របស់ព្រះយេស៊ូ នៅក្នុង "គ្រាចុងក្រោយ" ។

យើងទទួលបានជំនួយដ៏អស្ចារ្យមួយ នៅក្នុងការស្វែងយល់អំពីចម្លើយរបស់ព្រះយេស៊ូ ដោយទ្រង់បានមានព្រះបន្ទូលសំដៅទៅកាន់ទំនាយរបស់លោកដានីយ៉ែល ដែលបានប្រាប់អំពីព្រឹត្តិការណ៍នៃគ្រាចុងក្រោយយ៉ាងជាក់លាក់ (គម្ពីរម៉ាថាយ ២៤:១៥)។ នៅក្នុងទំនាក់ទំនងជាមួយនឹងការណ៍នេះ យើងនឹងទទួលបានផលប្រយោជន៍ពីការរំឭកអំពីប្រវត្តិសាស្ត្ររបស់ពួកយូដា និង ទំនាក់ទំនងរបស់ពួកគេទៅនឹងព្រឹត្តិការណ៍ ដែលយើងកំពុងសិក្សានៅពេលនេះ។

ព្រះជាម្ចាស់នឹងប្រទានឲ្យយើងនូវ គម្រោងទូទៅមួយនៃព្រឹត្តិការណ៍នាថ្ងៃអនាគត ដែលទាក់ទងនឹងពួកយូដា និង រាជធានីរបស់ពួកគេ គឺក្រុងយេរូសាឡឹម (គម្ពីរដានីយ៉ែល ៩:២៤-២៧)។ គម្រោងនេះគឺផ្អែកទៅលើ ការកំណត់ពេលវេលាមួយដែលរាប់បញ្ចូល ប្រវត្តិសាស្ត្ររបស់ពួកយូដា ក៏ដូចជាអនាគតរបស់ពួកគេផងដែរ។ ចូរអានគម្ពីរដានីយ៉ែល ជំពូក៩ ដើម្បីត្រៀមសម្រាប់ការពិភាក្សារបស់យើងអំពីព្រឹត្តិការណ៍ទាំងនេះ។

សេចក្តីសង្ខេបមួយរបស់ពួកយូដា នៅក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ និង បទទំនាយ

វគ្គបំណងទី២. *ពិភាក្សាថាតើ ព្រឹត្តិការណ៍នៃបទទំនាយណាខ្លះ នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩ និង អេម៉ុសជំពូក៩ បានកើតមានឡើងរួចទៅហើយ។*

និមិត្តរបស់លោកដានីយ៉ែល

បទគម្ពីរបានប្រាប់យើងថា ដោយសារតែភាពបរាជ័យរបស់ប្រជាជនយូដា ក្នុងការប្រតិបត្តិថ្ងៃសប្ប័ទនៅក្នុងទឹកដីរៀងរាល់ ប្រាំពីរឆ្នាំម្តង នោះព្រះជាម្ចាស់ដាក់បញ្ជត្តិឲ្យពួកគេរស់នៅក្នុងទឹកដីរបស់សត្រូវរបស់គេរយៈពេល៧០ឆ្នាំ។ (ចូរប្រៀបធៀប គម្ពីរលេវីវិន័យ ២៥:២-៧ និង ២៦:១៤-១៦,៣១-៣៥ ជាមួយនឹង គម្ពីរ២របាក្សត្រ ៣៦:២១ សម្រាប់ការបកស្រាយ អំពីឆ្នាំសប្ប័ទ និង លទ្ធផលដែលនឹងកើតមានឡើងនៅពេលដែលមិនប្រតិបត្តិតាមថ្ងៃនេះ។) អ្វីដែលយើងចង់បញ្ជាក់គឺថា ក្នុងរយៈ៤៩០ឆ្នាំហើយមនុស្សមិនបានបរាជ័យក្នុងការប្រកាន់ខ្ជាប់នូវការកំណត់របស់ឆ្នាំសប្ប័ទ។ គន្លឹះសំខាន់សម្រាប់ចូលទៅកាន់បទទំនាយដ៏ខ្លីប៉ុន្តែមានសារៈសំខាន់យ៉ាងខ្លាំងនេះ គឺស្ថិតនៅជុំវិញរយៈពេល ប្រាំពីរឆ្នាំ ចិតសិបដង ឬ ចិតសិប "អាទិត្យ" នៃឆ្នាំ (មួយអាទិត្យនៃឆ្នាំស្មើ ៧ឆ្នាំ) ដែលមាននិយាយនៅក្នុងខ ២៤-២៧។

ប្រជាជាតិអ៊ីស្រាអែល បានទម្លាប់ខ្លួនទៅនឹងរាល់ "អាទិត្យ" នៃឆ្នាំ ជារៀងរាល់ ឆ្នាំទីប្រាំពីរ ដែលជាឆ្នាំសប្ប័ទ នៃការសម្រាកនៃទឹកដី (គម្ពីរលេវីវិន័យ ២៥:៣-៤)។ បុណ្យឧបគំរប់ដ៏ធំនៃកំណែទម្រង់សង្គម និង សេដ្ឋកិច្ចគឺប្រារព្ធនៅរាល់ឆ្នាំទី៥០ ដែលយោងទៅតាម*អាទិត្យនៃឆ្នាំ* សំខាន់ៗជាច្រើននៃឆ្នាំនីមួយៗ គឺថាប្រាំពីរឆ្នាំ ប្រាំពីរដង ឬ ប្រាំពីរអាទិត្យនៃឆ្នាំ (សូមមើលនៅក្នុងគម្ពីរលេវីវិន័យ ២៥:៨-៩) ។ នៅក្នុងឆ្នាំទីហាសិបនេះ បំណុលទាំងអស់នឹងត្រូវបោះបង់ចោល ទាសករត្រូវដោះឲ្យមានសេរីភាព និង កម្មសិទ្ធិដីធ្លីនឹងត្រឡប់ទៅជារបស់ម្ចាស់ដើមវិញ។

ចិតសិបអាទិត្យនៅក្នុងទស្សនវិស័យនៃការធ្វើបទទំនាយ

" ព្រះអង្គបានកំណត់ពេលប្រាំពីរឆ្នាំ (អាទិត្យនៃឆ្នាំ) ចិតសិបដង សំរាប់ប្រជាជន (ពួកយូដា) និងក្រុងដ៏វិសុទ្ធរបស់លោក [ក្រុងយេរូសាឡឹម] ។"

គម្ពីរដានីយ៉ែល ៩:២៤-២៩



(ចំណាំ៖ មួយអាទិត្យ =7ឆ្នាំ)

នេះពិតជាការចម្លែកណាស់ ដែលក្រោយពេលត្រូវបានជាប់ជាទាសកអស់រយៈពេលជិត៧០ឆ្នាំ ទេវតាមួយអង្គក៏នឹងត្រូវបានចាត់បញ្ជូនមកដើម្បីធ្វើការប្រាប់ទៅកាន់មនុស្សតាមរយៈលោកដានីយ៉ែល អំពីការចាប់ផ្តើមនៅពេលវេលាថ្មីមួយដែលព្រះជាម្ចាស់ ដោះស្រាយបញ្ហាជាមួយនឹងពួកយូដា។ ដូចដែលយើងបានឃើញនៅក្នុងបទទំនាយរបស់លោកដានីយ៉ែលហើយថា ពេលវេលានេះ នឹងលាតសន្ធឹងឲ្យមានចំនួនឆ្នាំដូចទៅនឹងចំនួនដងដែលគេមិនគោរពតាមឆ្នាំសប្ប័ទដែរ ឬក៏ស្មើនឹង៤៩០ឆ្នាំ (នោះមានន័យថា ប្រាំពីរឆ្នាំ ចិតសិបដង)។ សូមយើងងាកមករំឭកយ៉ាងខ្លីៗ អំពីការពិតដែលបានផ្តល់ឲ្យឃើញនៅក្នុងនិមិត្តរបស់លោកដានីយ៉ែល ហើយបន្ទាប់មកយើងមើលទៅលើការបកស្រាយនិមិត្តមួយនេះ។

១. បទទំនាយដែលទាក់ទងនឹងមនុស្សរបស់លោកដានីយ៉ែល គឺពួកយូដា និង ទីក្រុងវិសុទ្ធរបស់លោក គឺក្រុងយេរូសាឡឹម (ខ.២៤)។

២. បទទំនាយដែលមានរាប់បញ្ចូលរយៈពេលប្រាំពីរឆ្នាំចិតសិបដង ឬ ប្រាំពីរអាទិត្យ ចិតសិបដង ។ ការណ៍នេះបង្ហាញពីរយៈពេលចំនួន៤៩០ឆ្នាំ។

៣. សកម្មភាពដែលត្រូវសម្រេចឲ្យបាននៅក្នុងរយៈពេលនេះ រួមមាន៖
   ក. ការបញ្ចប់អំពើរំលង
   ខ. បញ្ឈប់ការប្រព្រឹត្តិអំពើបាប
   គ. ការលន់តួសម្រាប់ភាពមានបាប
   ឃ. ការចាក់ប្រេងអភិសេកសម្រាប់អ្នកដែលវិសុទ្ធជាងគេ (ឬ ព្រះដ៏វិសុទ្ធជាងគេ)
   ង. ការនាំមកនូវភាពសុចរិតដ៏អស់កល្បជានិច្ច។ (ខ.២៤)

៤. អំឡុងពេលដែលត្រូវបានរាប់បញ្ចូលដំបូងបំផុតគឺ ប្រាំពីរឆ្នាំ ប្រាំពីរដង (៤៩ឆ្នាំ) និង ប្រាំពីរឆ្នាំ ហុកសិបពីរដង (៤៣៤ ឆ្នាំ) ដែលបូកសរុបទាំងអស់គឺប្រាំពីរ ហុកសិបប្រាំបួនដង (៤៨៣ឆ្នាំ សូមមើលខ. ២៥)។

៥. ពេលវេលា*ចាប់ផ្តើម*នៅចំណុចដ៏ជាក់លាក់មួយ៖ ការថ្លែងប្រកាសពីបញ្ញត្តិនៅក្នុងគ្រាជួសជុល និង សង់ក្រុងយេរូសាឡឹមឡើងវិញ។

៦. រយៈពេលនៃការចាប់ផ្តើមដំបូង បញ្ចប់ទៅជាមួយនឹងព្រឹត្តិការណ៍ដ៏ជាក់លាក់មួយ៖ ការយាងមកដល់របស់លោកដែលគេចាក់ប្រេងអភិសេក និង ការដាក់យកជីវិតរបស់លោក មិនយូរប៉ុន្មានក្រោយមក(ខ.២៥ ដល់ ខ.២៦)

៧. ទស្សនវិស័យរបស់ស្តេចពីរអង្គ៖ លោកដែលត្រូវគេចាក់ប្រេងអភិសេក (ព្រះយេស៊ូ) និង ស្តេចមួយដែលនឹងមក (អ្នកប្រឆាំងព្រះគ្រិស្ត,ពួកទទឹងនឹងព្រះគ្រីស្ទ) ដែលនឹងលើកគ្នាមកកំទេចទីក្រុង និងទីសក្ការៈ។

៨. បន្ទាប់មកនៅប្រាំពីរឆ្នាំ (មួយអាទិត្យរបស់)ឆ្នាំ ដែលផ្តោតសំខាន់ទៅលើការដែល*ស្តេចមួយអង្គដែលនឹងមកដល់* (អ្នកប្រឆាំងព្រះគ្រិស្ត) នឹងធ្វើការសន្យាជាមួយពួកយូដា។

ទោះជាយ៉ាងណាក្តី នៅពាក់កណ្តាលពេលប្រាំឆ្នាំនេះ មានន័យថាបីឆ្នាំកន្លះ ស្តេចដែលនឹងមកដល់តាមក្រោយនេះ នឹងក្បត់ពាក្យសន្យា ហើយថែមទាំងបញ្ឈប់រាល់សកម្មភាពសាសនាទាំងអស់របស់ពួកយូដា និង ធ្វើឲ្យមានភាពហិនហោច (បំផ្លាញ ធ្វើឲ្យអស់គ្មានសល់) នៅក្នុងព្រះវិហារ មុនពេលដែលសុគតទៅវិញ។

លំហាត់អនុវត្តន៍

៧ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបានពីខាងលើមក យើងអាចសន្និដ្ឋានបានថារយៈពេលដែលមាននៅក្នុងនិមិត្តរបស់លោកដានីយ៉ែល គឺផ្អែកទៅលើចំនួន នៃ

ក) រយៈពេលដែលពួកយូដាមិនបានប្រតិបត្តិតាម ឆ្នាំសប្ប័ទរបស់ពួកគេ។

ខ) ស្តេចដែលនឹងមកគ្រប់គ្រងលើពួកប្រជាជនយូដា។

គ) អាទិត្យនៅក្នុងមួយឆ្នាំ។

ការបកស្រាយនិមិត្ត

យើងនឹងបន្ត ជាមួយនឹងការបកស្រាយនៃនិមិត្តដ៏អស្ចារ្យមួយនេះ ដែលចាប់ផ្តើមជាមួយនឹងគម្ពីរដានីយ៉ែល ៩:២៥៖

> ដូច្នេះ សូមជ្រាប ហើយយល់អត្ថន័យនេះចុះ! ចាប់ពីពេលព្រះអម្ចាស់មានព្រះបន្ទូល ស្តីអំពីការរៀបចំសង់ក្រុងយេរូសាឡឹមឡើងវិញ រហូតដល់ពេលស្តេចដែលជាព្រះមេស្ស៊ី*យាងមកដល់មានរយៈពេលប្រាំពីរឆ្នាំប្រាំពីរដង ហើយនៅប្រាំពីរឆ្នាំហុកសិបពីរដងទៀត គេនឹងសង់ទីក្រុង និងកំពែងឡើងវិញ តែគ្រានោះជាគ្រាមួយដ៏សែនវេទនា។ លុះរយៈពេលប្រាំពីរឆ្នាំហុកសិបពីរដងនោះកន្លងផុតទៅ លោកដែលគេចាក់ប្រេងអភិសេក នឹងត្រូវគេដកជីវិត គ្មាននរណាការពារលោកទេ។ ប្រជាជាតិរបស់ស្តេចមួយអង្គនឹងលើកគ្នាមកកំទេចទីក្រុង និងទីសក្ការៈ។ នៅទីបញ្ចប់ ស្តេចនោះ នឹងទទួលទោសពីព្រះជាម្ចាស់។ ប៉ុន្តែ ស្តេចនោះនឹងបន្តធ្វើសឹកបំផ្លិចបំផ្លាញ រហូតដល់សោយទិវង្គតដូចបានកំណត់ទុក។ (ខ២៥ ដល់ ២៦)

ចូរសំគាល់មើលថា បទបញ្ជាដើម្បីឲ្យជួសជុល និង សាងសង់ក្រុងយេរូសាឡឹមឡើងវិញ ត្រូវបានផ្តល់មក "នៅឆ្នាំទីម្ភៃ នៃរជ្ជកាលព្រះចៅអើថាស៊ើកសេស" (គម្ពីរនេហេមា ២:១-៨)។ការត្រួតពិនិត្យមើលឡើងវិញយ៉ាងប្រុងប្រយ័ត្ន ទៅលើកំណត់ត្រាប្រវត្តិសាស្ត្រ ដែលបង្ហាញឲ្យឃើញពីកាលបរិច្ឆេទនៅក្នុងឆ្នាំ៤៤៥ មុខគ.ស អំពីការដាក់បញ្ជានេះ។ ទីក្រុងពិតជាបានសាងសង់ឡើងវិញពិតមែននៅក្នុងពេលដែលកំពុងមានបញ្ហា។ បន្ទាប់ពី ៤៣៤ឆ្នាំក្រោយមកទៀត ព្រះដែលត្រូវគេចាក់ប្រេងអភិសេកក៏បានលេចឡើងមកយ៉ាងជាក់ច្បាស់ទៅតាមបទទំនាយមែន។ អ្នកប្រាជ្ញខាងឯព្រះគម្ពីរបានគណនាយ៉ាងប្រុងប្រយ័ត្ន ហើយឃើញថា ៤៨៣ឆ្នាំគត់ បន្ទាប់ពីការដាក់បញ្ជារបស់ស្តេចអើថាស៊ើកសេស ព្រះយេស៊ូដែលជាអ្នកដែលត្រូវគេចាក់ប្រេងអភិសេក បានធ្វើការយាងចេញដោយភាពជោគជ័យ ទៅក្នុងក្រុងយេរូសាឡឹម

នៅគ្រាចុងក្រោយនៃព័ន្ធកិច្ចលើផែនដីរបស់ទ្រង់ (គម្ពីរលូកា ១៩:២៨-៣៨)។ បន្ទាប់មក មិនបានប៉ុន្មានថ្ងៃក្រោយមក ទ្រង់ក៏ត្រូវបានគេធ្វើគុត នៅក្នុងព្រឹត្តិការណ៍ដែលគេឆ្កាងទ្រង់។

ក្រោយមកទៀត នៅក្នុងនិមិត្តរបស់លោកដានីយ៉ែល មានទេវតាបានមកប្រាប់លោកថា មនុស្សរបស់ស្តេចដែលនឹងមកតាមក្រោយនឹងបំផ្លាញទីក្រុង និង ទីសក្ការៈ នៅក្រោយពេលព្រះដែលត្រូវគេចាក់ប្រេងអភិសេកត្រូវបានគេធ្វើគុត (ខ.២៦)។ ទិដ្ឋភាពមួយនេះនៃបទទំនាយត្រូវបានសម្រេចនៅក្នុងឆ្នាំ៧០ គ.ស នៅពេលដែលពួកទាហានរ៉ូម៉ាំងបំផ្លាញក្រុងយេរូសាឡិម កំទេចកំពែងក្រុង ហើយដុតទីសក្ការ (ព្រះវិហារ) ហើយបន្ទាប់មកវាយកំទេចទាំងថ្មដែលសាងសង់ព្រះវិហារនោះទៀតផង (គម្ពីរម៉ាថាយ ២៤:២)។ នៅក្នុងពេលនេះ ប្រទេសរបស់ពួកយូដា ដែលហៅថាអ៊ីស្រាអែលនេះ ក៏លែងមានវត្តមានជាប្រទេសដែលមានអធិបតេយ្យភាព (គ្រប់គ្រងដឹកនាំដោយខ្លួន) ទៀតហើយ។ ប្រជាជនរបស់សាសន៍នេះបានខ្ចាត់ខ្ចាយទៅដល់ចុងបំផុតនៃផែនដី ហើយគម្រោងការដ៏យូរអង្វែងដែលព្រះជាម្ចាស់បានមានព្រះបន្ទូលប្រាប់ទុកមុន (គម្ពីរដានីយ៉ែល ៩:២៤) ក៏ហាក់បីដូចជាត្រូវផ្អាកត្រឹមនោះដែរ។

ព្រឹត្តិការណ៍នៅប្រាំពីរឆ្នាំ ឬ អាទិត្យទីចិតសិបនៃឆ្នាំ ដែលនៅក្នុងនិមិត្តរបស់លោកដានីយ៉ែលមិនទាន់បានកើតឡើងនៅឡើយទេ។ រយៈពេលចុងក្រោយនៅក្នុងផែនការរបស់ព្រះជាម្ចាស់សម្រាប់ជាតិសាសន៍យូដានេះហើយ ដែលយើងត្រូវខ្វាយខ្វល់ជាពិសេស ទាក់ទងទៅនឹងគ្រាចុងក្រោយ។ ដូច្នេះ យើងត្រូវធ្វើការសិក្សា អ្វីដែលបានកើតឡើង ដែលធ្វើឲ្យខូតខាតគម្រោងពេលវេលាដែលព្រះជាម្ចាស់បានបង្កើតឡើង។ យើងនឹងចាប់ផ្តើម ជាមួយនឹងថ្ងៃដំបូងបង្អស់ របស់សាសន៍យូដា។

ព្រះជាម្ចាស់បានបង្ហាញយ៉ាងខ្លីហើយច្បាស់ៗ ទៅកាន់សាសន៍អ៊ីស្រាអែលនៅពេលដែលគេចូលទៅក្នុងទឹកដីសន្យាថា *ការស្តាប់បង្គាប់* តាមក្រឹត្យវិន័យរបស់ទ្រង់នឹងនាំមកនូវប្រយោជន៍ (សូមមើលគម្ពីរទុតិយកថា ២៨:១-១៤)។ ទ្រង់ក៏បានមានព្រះបន្ទូលយ៉ាងច្បាស់ៗ អំពីការអាក្រក់ដែលនឹងតាមជាប់*ការមិនបង្គាប់ស្តាប់*របស់ប្រជារាស្ត្រទ្រង់ (គម្ពីរលេវីវិន័យ ២៦:១៤-៤៥ គម្ពីរទុតិយកថា ២៨:១៥-៦៨)។ ព្រះគម្ពីរបានបង្ហាញថា ដោយសារតែការមិនស្តាប់បង្គាប់របស់ពួកគេ និង ភាពពេញដោយបាបដែលហាក់ដូចជាមិនអាចព្យាបាលបានរបស់ពួកគេនោះ ចុងក្រោយព្រះជាម្ចាស់បានអនុញ្ញាតឲ្យប្រជារាស្ត្ររបស់ទ្រង់ត្រូវបានខ្ចាត់ខ្ចាយ (បែកខ្ញែង ឬ បណ្តេញចេញ) ពីទឹកដីរបស់ពួកគេ។ បន្ទាប់ទ្រង់ធ្វើឲ្យទឹកដីនោះ ស្ងាត់សូន្យគ្មាននរណាម្នាក់រស់នៅ (គម្ពីរអេសាយ ៦:១១-១២; ១៧:៩; ៦៤:១០)។ នៅមុននេះ ការជាប់ជាទាសកររយៈពេល៧០ឆ្នាំមិនមានប្រយោជន៍ក្នុងការនាំយកប្រជារាស្ត្ររបស់ព្រះជាម្ចាស់កាន់ទ្រង់នោះទេ។ ដូច្នេះជាមួយនឹងការខ្ចាត់ខ្ចាយដែលកើតឡើងដោយការកាន់កាប់របស់ពួករ៉ូម៉ាំង ពួកសាសន៍យូដាបានក្លាយខ្លួនជា "ពួកវង្វេង" ហើយពួកគេរងទុក្ខសោកដែលគ្មាននរណាអាចប្រាប់បាន នៅពេលដែលពួកគេបានស្វែងរកកន្លែងដើម្បីជ្រកឲ្យផុតពីភាពកាចសាហាវរបស់សាសន៍ដទៃ។

ដូច្នេះ សាសន៍អ៊ីស្រាអែលជាសាសន៍ដែលព្រះជ្រើសរើស ត្រូវបានបណ្តេញចេញពីទឹកដីសន្យាមួយរយៈ។ ព្រះជាម្ចាស់ដែលមានក្តីស្រឡាញ់ និង ក្តីមេត្តា បានបង្ហាញថា ទ្រង់នឹងមិនបោះបង់ប្រជារាស្ត្ររបស់ទ្រង់ចោលទាំងស្រុងនោះទេ (គម្ពីរលេវីវិន័យ ២៦:៤៣-៤៥) ប៉ុន្តែទ្រង់នឹងត្រាស់ហៅពួកគេពីចុងបំផុតនៃផែនដីមកវិញ (គម្ពីរអេសាយ ១១:១១-១២)។ ទ្រង់នឹងប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាងដើម្បីប្រមូលពួកគេមកវិញ និង ដើម្បីដកពួកគេចេញពីផ្ទះបណ្តោះអាសន្នរបស់ពួកគេ ហើយនាំពួកគេទៅ

ទឹកដីដែលទ្រង់បានប្រទានទៅកាន់ "ឪពុក" របស់ពួកគេ គឺលោកអប្រាហាំដើម្បីឲ្យក្លាយជាកម្មសិទ្ធិរបស់គេអស់កល្បជានិច្ច (គម្ពីរយេរេមា ១៦:១៤-១៦)។

លំហាត់អនុវត្តន៍

៨ តើព្រឹត្តិការណ៍ (នៃការសម្រេចបទទំនាយរបស់លោកដានីយ៉ែល) អ្វីបានកើតឡើង និង កំណត់ទីបញ្ចប់របស់សាសន៍យូដា ដែលធ្វើឲ្យប្រជាជនបានខ្ចាត់ខ្ចាយទៅដល់ចុងបំផុតនៃផែនដី។

.....

ការត្រឡប់មកអ៊ីស្រាអែលវិញ

វាពិតជាគួរឲ្យចាប់អារម្មណ៍ណាស់ ដែលនៅដើមសតវត្សថ្មីនេះ បន្ទាប់មានការបៀតបៀនយ៉ាងខ្លាំងអស់ជាច្រើនសតវត្សមក ក៏នៅតែមានពួកយូដាខ្លួនឯង យល់ឃើញថា ពួកគេមិនត្រូវបានគេស្អប់ខ្លាំងនោះទេ ។ ដូច្នេះហើយបានជាពួកគេ បានស្នាក់នៅយ៉ាងស្កប់ចិត្ត នៅតាមកន្លែងផ្សេងៗក្នុងពិភពលោក។ ជាលទ្ធផល ពួកគេមានទំនោរងាកទៅរកការបាត់បង់ ផ្នត់គំនិតនៃការជាប់ពាក់ព័ន្ធរបស់ពួកគេកាលពីសម័យបុរាណ ទៅនឹងទឹកដីសន្យា។

ទោះជាយ៉ាងណា ក៏នៅតែមានអ្នកដឹកនាំសាសន៍យូដាម្នាក់ដែលរស់នៅទ្វីបអ៊ឺរ៉ុប លោកបណ្ឌិត ធាអ៊ូរ ហ៊ឺស្សល (Theodore Herzl) មិនអាចនៅស្ងៀមបាននោះទេ នៅពេលដែលលោកបានឃើញការកើនឡើងនៃការបៀតបៀននៅក្នុងប្រទេស រ៉ូស៊ី នៅជិតចុងបញ្ចប់សតវត្សទីដប់ប្រាំបួន។ ដោយជឿថារឿងរ៉ាវនឹងអាចឈានទៅរកភាពធ្ងន់ធ្ងរជាងនេះទៅទៀតសម្រាប់ប្រជាជនរបស់លោក លោកបានព្យាយាមបាននាំឲ្យពួកគេចាប់អារម្មណ៍ទៅលើផ្នត់គំនិតមួយអំពីការបង្កើតទឹកដីកំណើតរបស់ពួកគេមួយនៅប្រទេសប៉ាគីស្ថាន។ ការខិតខំព្យាយាមរបស់លោកបង្កើតបានទៅជា "ចលនាស៊ីយ៉ូន" សម័យថ្មី ប៉ុន្តែក្រោយមកត្រូវបានបរាជ័យ។ ជាឧទាហរណ៍ពួកយូដា នៅប្រទេសអាល្លឺម៉ង បាននិយាយថា "ពួកយើងមិនបានដឹងអ្វីអំពីស៊ីយ៉ូននោះទេ ។ ប្រទេសអាល្លឺម៉ងគឺជាប្រទេសភីលីស្ទីនសម្រាប់យើង ហើយ ទីក្រុងមុយនិចគឺជាក្រុងយេរូសាឡឹមសម្រាប់យើង។

ស្របពេលដែលពិភពលោកបានវិវត្តន៍ឈានទៅរកភ្លើងសង្គ្រាមនៅអ៊ឺរ៉ុប ពួកយូដាក៏បានឃើញថាជីវិតរបស់គេកាន់តែពិបាកខ្លាំងទៅៗ។ បន្ទាប់មកនៅក្នុងសង្គ្រាមលោកលើកទី១ ចលនាស៊ីយ៉ូន បានដាក់សំពាធទៅលើរដ្ឋាភិបាលអង់គ្លេសជាខ្លាំង ដែលនាំឲ្យមានចេញ *សេចក្តីប្រកាសបាលហ្វ័រ* (Balfour Declaration)។ សេចក្តីប្រកាសនេះ ស្នើឲ្យប្រទេសអង់គ្លេសគាំទ្រការបង្កើតទឹកដីកំណើតផ្ទាល់ខ្លួនមួយសម្រាប់ពួកយូដា នៅប្រទេសភីលីស្ទីន ។ នៅពេលដែលពួកអង់គ្លេសបានចូលទៅគ្រប់គ្រងលើទឹកដីដ៏វិសុទ្ធ ក្រោយសង្គ្រាមចប់ ពួកយូដាក៏ត្រូវបានលើកទឹកចិត្តឲ្យភៀសខ្លួនទៅប្រទេសភីលីស្ទីន។ មានពួកយូដាជាច្រើននាក់ បានត្រឡប់មកនៅរួមគ្នាជាមួយនឹងពួកអារ៉ាប់ ដែលបានរស់នៅលើទឹកដីនោះរាប់សិបសតវត្សមកហើយ។

មិនយូរប៉ុន្មាន នៅសង្គ្រាមលោកលើកទី២ បាននាំឲ្យមានការគម្រាមកំហែង និង ការបៀតបៀនដល់ពួកយូដាយ៉ាងច្រាកដ។ នៅអ៊ឺរ៉ុប ការនេះមានភាពធ្ងន់ធ្ងរខ្លាំងណាស់ ដែលមានពួកយូដាជាច្រើនបានគិតថា ក្តីសង្ឃឹមតែមួយគត់ដើម្បីឲ្យពួកគេរស់រានមានជីវិតបាន គឺមានតែការចាកចេញពីអ៊ឺរ៉ុប ហើយវិលត្រឡប់ទៅទឹកដីពីបុរាណរបស់ពួកគេវិញ។ ក្រោយចប់សង្គ្រាមលោកលើកទី២ ពួកយូដាជាច្រើនអ្នកបានចាកចេញពីផ្ទះបណ្តោះអាសន្នរបស់ពួកគេ វិលទៅភីលីស្ទីនវិញ។ ដល់ពាក់កណ្តាលខែ ឧសភា ឆ្នាំ ១៩៤៨ ការវិលត្រឡប់មកវិញរបស់ពួកយូដាក៏បាន ដាក់ប្រកាសជាថ្ងៃកំណើតនៃរដ្ឋអ៊ីស្រាអែល បច្ចុប្បន្ននេះ។ មិនយូរក្រោយមក បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩:១៤-១៥ ក៏ចាប់ផ្តើមបានសម្រេចកើតមានពិតប្រាកដមែន។

> ពេលនោះ យើងនឹងនាំអ៊ីស្រាអែល ជាប្រជារាស្ត្ររបស់យើងដែលជាប់ជាឈ្លើយ អោយត្រឡប់មកវិញ។ ពួកគេនឹងសង់ក្រុងទាំងប៉ុន្មានដែលខូចខាត ដើម្បីស្នាក់នៅ។ ពួកគេនឹងដាំទំពាំងបាយជូរ ហើយផឹកស្រាពីចំការទំពាំងបាយជូរនោះ។ ពួកគេនឹងធ្វើចំការ ហើយបរិភោគផលផ្លែពីចំការនោះដែរ។ យើងនឹងអោយពួកគេរស់នៅយ៉ាងស្ថិតស្ថេរលើទឹកដីរបស់ខ្លួន គ្មាននរណាអាចបណ្តេញពួកគេចេញពីស្រុកដែលយើងបានប្រគល់អោយពួកគេនេះទៀតឡើយ» - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់ជាព្រះរបស់អ្នក។

ទឹកដីនោះហាក់បីដូចជា ឥតបានការ អស់រយៈពេលជិត ២០០០ឆ្នាំមកហើយ។ ព្រះជាម្ចាស់បានមានព្រះបន្ទូលថា ទឹកដីនេះនឹងត្រូវរីកស្គុសស្គាយឡើងដូចជាផ្កា (គម្ពីរអេសាយ ៣៥:១-២)។ បទទំនាយរបស់លោកហោរាអេសាយ ក៏ត្រូវបានសម្រេច។ កន្លែងដែលធ្លាប់តែត្រូវបោះបង់ចោល ត្រូវបានយកត្រឡប់មកវិញ ហើយទីក្រុងដែលបានបែកបាក់ ក៏មានមនុស្សឡើងវិញ មានការកសាងជាថ្មី ហើយពង្រឹងឲ្យមាំមួងទៀត (គម្ពីរអេសេគាល ៣៦:៣៣-៣៦ សូមមើលនៅក្នុងគម្ពីរអេសាយ ៦១:៤ផងដែរ) ។ មានប្រវត្តិវិទូម្នាក់បានសំគាល់ឃើញថា សង្គ្រាមលោកលើកទីមួយគឺជាការរៀបចំ ទឹកដីសន្យាសម្រាប់ពួកយូដា ហើយសង្គ្រាមលោកលើកទី ២ បានរៀបចំពួកយូដាសម្រាប់ទឹកដីរបស់ពួកគេ ហើយសង្គ្រាមដែលនឹងកើតឡើងក្នុងថ្ងៃអនាគត នឹងរៀបចំពួកយូដាសម្រាប់ព្រះជាម្ចាស់របស់ផងគេ។

បើអ្នកណា យកចិត្តទុកដាក់ជាមួយនឹងបញ្ហានៅ តំបន់មជ្ឈិមបូព៌ា គេដឹងថា ជាមួយនឹងការវិលត្រឡប់មកវិញរបស់ពួកយូដា ចូលក្នុងទឹកដីពីបុរាណរបស់ពួកគេ ពួកភីលីស្ទីនជាច្រើនដែលបានរស់នៅទីនោះជាយូរមកហើយ ត្រូវបានគេផ្លាស់ទីកន្លែងរស់នៅ ហើយបានក្លាយជាជនភៀសខ្លួនដែលមានចំនួនច្រើនជាងគេនៅក្នុង ប្រទេសផ្សេងៗទៀតនៅតំបន់មជ្ឈិមបូព៌ានោះ។ ការនេះជាមូលហេតុដែលបណ្តាលឲ្យមានការកើនឡើងនូវភាពតានតឹង និងការប្រេះឆា រវាងពួកយូដា និង ប្រទេសជិតខាងក្នុងតំបន់អារ៉ាប់។ យើងនឹងឃើញនៅពេលក្រោយ ថានេះគឺជាកត្តាដែលនឹងចូលរួមនៅក្នុងការបានបំពេញបទទំនាយដែលទាក់ទងនឹងតំបន់មជ្ឈិមបូព៌ា។

ដោយចងចាំបទទំនាយនេះនៅក្នុងចិត្ត ឥឡូវនេះយើងនឹងបែរទៅរកខ្លឹមសាររបស់គម្ពីរដានីយ៉ែល ៩:២៧ ដែលនិយាយអំពីស្តេចដែលនឹងយាងមក និង ការសម្រេចបាននូវអ្វីដែលព្រះជាម្ចាស់បានដាក់បញ្ញត្តិនៅក្នុងខទី២៤។

លំហាត់អនុវត្តន៍

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខព្រឹត្តិការណ៍ទំនាយដែលបានកើតឡើងរួចហើយ ដូចដែលបានបកស្រាយនៅក្នុងទិដ្ឋភាពខាងលើនេះ ។

ក) ការនិរទេសរបស់ពួកយូដាអស់រយៈពេល៧០ឆ្នាំ គឺដោយសារតែការមិនស្តាប់បង្គាប់។

ខ) ការជួសជុល និង ការសាងសង់ក្រុងយេរូសាឡឹមឡើងវិញ គឺកើតឡើងក្រោយការជាប់ជាទាសកររយៈពេល៧០ឆ្នាំ។

គ) ការយាងមកររបស់លោកដែលគេចាក់ប្រេងអភិសេក។

ឃ) ការមកដល់នៃអ្នកប្រឆាំងនឹងព្រះគ្រិស្ត។

ង) ការសម្លាប់លោកដែលគេចាក់ប្រេងអភិសេក។

ច) មនុស្សរបស់ស្តេចដែលកំពុងយាងមក កំទេចទីក្រុងវិសុទ្ធ និង ព្រះវិហារ។

ឆ) ទីបញ្ចប់ជាអធិបតេយ្យភាព របស់សាសន៍យូដា។

ជ) បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩ ដែលប្រាប់ថាប្រទេសអ៊ីស្រាអែល នឹងត្រូវបានស្រោចស្រងឡើងវិញម្តងទៀត ហើយប្រជារាស្ត្រគេនឹងត្រឡប់មកធ្វើចំការ និង ដាំទំពាំងបាយជូរម្តងទៀត។

ឈ) សេចក្តីសន្យារបស់ប្រជារាស្ត្រសាសន៍យូដា និង ស្តេចដែលកំពុងយាងមក ដែលត្រូវបានបំផ្លាញបានពីរយៈពេលបីឆ្នាំកន្លះ។

អាទិត្យទីចិតសិបរបស់លោកដានីយ៉ែល

វត្ថុបំណងទី៣. *បកស្រាយព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត និងសមរភូមិនៅឯអើម៉ាគេដូន។*

យើងបានឃើញហើយថា ក្រោយពេលមានការសម្លាប់ព្រះអង្គដែលគេចាក់ប្រេងអភិសេកនោះរួចហើយ ប្រទេសអ៊ីស្រាអែល ក៏ត្រូវបានបញ្ចប់ដែរ។ នៅក្នុងអំឡុងពេលជាមួយគ្នានេះដែរ ក្រុមជំនុំក៏បានកើតឡើង ហើយបានចាប់ផ្តើមធ្វើបេសកកម្មដែលព្រះជាម្ចាស់បានប្រទានមក។លោកសាវ័កប៉ូលបានធ្វើការប្រកាសនៅក្នុងគម្ពីររ៉ូមជំពូក៩ ដល់១១ថា ព្រះជាម្ចាស់មិនបានលះបង់ចេញ**ពី**សាសន៍អ៊ីស្រាអែលទាំងស្រុងនោះទេ ។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានោះដែរ ទ្រង់បានចាត់ឲ្យក្រុមជំនុំ ធ្វើជាឧបករណ៍ផ្សព្វផ្សាយដំណឹងល្អរបស់ទ្រង់ នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អជាមួយមនុស្សទាំងអស់នៅក្នុងពិភពលោក។ នៅក្នុងចន្លោះពេលរវាងការសម្លាប់ព្រះអង្គដែលគេចាក់ប្រេងអភិសេក និង ការបំពេញ (ការសម្រេចបាន)ផែនការរបស់ព្រះជាម្ចាស់ទៅថ្ងៃអនាគត សម្រាប់ពួកអ៊ីស្រាអែល ក្រុមជំនុំបានបន្តតួនាទីទៅមុខទៀតដដែល។

ភស្តុតាងនៅក្នុងព្រះគម្ពីរបានចង្អុលបង្ហាញទៅកាន់ការពិតដែលថាក្រុមជំនុំគឺកំពុងតែរងចាំព្រះអម្ចាស់ដែលកំពុងយាងមកដើម្បីលើកយកពួកគេទៅ (គម្ពីរ១កូរិនថូស ១៥:៥០-៥២ គម្ពីរ

១ថេស្សាឡូនិក ៤:១៣-១៧)។ ទោះបីជាយ៉ាងណា បើមើលទៅហាក់បីដូចជា ស្តេចមួយអង្គដែលនឹងមកដល់នោះ ត្រូវបានព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការតាមរយៈក្រុមជំនុំ ដើម្បីបង្ខាំង ឬ ឃាត់មិនឲ្យធ្វើតាមផែនការអាក្រក់បាន (គម្ពីរ២ថេស្សាឡូនិក ២:១-១២)។ នៅពេលដែលក្រុមជំនុំត្រូវបានឆក់យកឡើង ឬ ចាប់យកឡើងទៅ អាទទឹងច្បាប់ ក៏នឹងចេញមុខមក។ បន្ទាប់មកព្រះជាម្ចាស់នឹងបង្វែរព្រះទ័យទុកដាក់របស់ទ្រង់ទៅលើពួកអ៊ីស្រាអែលសាជាថ្មីម្តងទៀត ស្របពេលដែលព្រឹត្តិការណ៍នៃអាទិត្យទីចិតសិបរំកិលខិតទៅរកក្តីសម្រេច។

យើងបានសំគាល់ឃើញថាព្រះគម្ពីរដានីយ៉ែល គឺចែងឡើងទាក់ទងនឹងពួកយូដា។ នៅពេលដែលលោកយេរេមាសង្កេតមើលអំឡុងពេលនេះ លោកប្រៀបធៀបការឆ្លងកាត់របស់ពួកអ៊ីស្រាអែលទៅនឹងការឈឺចាប់ដែលម្តាយត្រូវអត់ទ្រាំនៅពេលគាត់ឆ្លងទន្លេ (គម្ពីរយេរេមា ៣០:១-១១)។ បើនិយាយអំពីការរងទុក្ខ គ្មានពេលណាមួយនៅក្នុងប្រវត្តិសាស្ត្រអាចប្រៀបជាមួយនឹងអំឡុងពេលមួយនេះឡើយ ពេលនេះគឺជា "ថ្ងៃដែលកូនចៅរបស់យ៉ាកុបត្រូវឈឺចុកចាប់យ៉ាងខ្លាំង"។ នេះមានន័យថា "ថ្ងៃដែលសាសន៍អ៊ីស្រាអែលត្រូវឈឺចាប់" ។ តើបញ្ហាទាំងអស់នេះនឹងចូលមកដោយរបៀបណា?

អ្នកប្រឆាំងនឹងព្រះគ្រិស្ត

បើអ្នកនៅចាំគម្ពីរដានីយ៉ែល ៩:២៦ ដែលថ្លែងអំពីស្តេចមួយដែលនឹងមកដល់ ហើយនៅក្នុងខ២៧ បានបង្ហាញអំពីសកម្មភាពរបស់ស្តេចនោះ។ យើងឃើញថា ស្តេចនោះនឹងធ្វើការសន្យាជាមួយនឹងមនុស្សជាច្រើន រយៈពេល "មួយអាទិត្យ" (៧ឆ្នាំ) ។ ជាក់ស្តែង ភាពតានតឹងនៅ មជ្ឈិមបូព៌ា រវាងសាសន៍យូដា និង ប្រទេសសាសន៍អារ៉ាប់ជិតខាងរបស់ពួកគេនឹងបន្តរហូតដល់ពេលដែលគ្រាមានវិបត្តិធំបំផុតចាប់ផ្តើមកើតឡើង ហើយការនេះនឹងច្បាស់ជាគំរាមកំហែងដល់សន្តិភាពពិភពលោក។ នៅត្រង់ចំណុចនេះ ស្តេចមួយដែលនឹងយាងមកដល់ (អ្នកប្រឆាំងនឹងព្រះគ្រិស្ត) នឹងឈានទៅរកការបង្កើតឲ្យបាននូវសុខសន្តិភាព។ ភាពជោគជ័យខាងឯការទូតរបស់ស្តេចនោះ នឹងត្រូវបានគេចាត់ទុកជាជ័យជម្នះដ៏ធំមួយ ហើយមនុស្សម្នានៅក្នុងពិភពលោកនឹងប្រកាសថាស្តេចនោះគឺជាស្តេចដែលគ្មានអ្នកណាប្រៀបស្មើរ (គម្ពីរវិវរណៈ ១៣:៤)។

អ៊ីស្រាអែលនឹងរំពឹងឲ្យអ្នកបង្កើតសន្តិភាពរូបនេះ រក្សាសន្តិភាពសម្រាប់ពួកគេ។ ដោយគ្មានកង្វល់ក្នុងការត្រៀមវិស័យយោធាឲ្យមានភាពខ្លាំងក្លា ប្រជាជនសាសន៍យូដានឹងអាចបង្វែរលុយ និង កម្លាំងរបស់ពួកគេទៅលើគោលដៅដែលបានសន្តិភាព ដូចជា៖ ការអភិវឌ្ឍទឹកដី ការលើកស្ទួយកម្រិតនៃការរស់នៅរបស់ពួកគេ និង ការស្វែងរកលំនៅនិងការងារសម្រាប់មនុស្សដែលគ្មានទីលំនៅជាច្រើននាក់។ ការធ្វើការសន្យាសន្តិភាពនេះ នឹងធ្វើឲ្យអ្នកផ្តល់សន្តិភាពត្រូវបានគេចាត់ទុកថា៖ "អាទទឹងច្បាប់,មនុស្សទទឹងច្បាប់" (គម្ពីរ២ថេស្សាឡូនិក ២:៣)។

នៅក្នុងមួយរយៈពេល អ្វីនឹងដំណើរការបានយ៉ាងល្អនៅក្នុងតំបន់ទាំងមូល ប៉ុន្តែបានពាក់កណ្តាលការសន្យានេះ ស្តេចមួយនោះនឹងក្បត់ពាក្យសន្យារបស់គេ (គម្ពីរដានីយ៉ែល ៩:២៧)។ អត្ថបទព្រះគម្ពីរបានថ្លែងថា ស្តេចនោះនឹងបញ្ឈប់លែងឲ្យមានសាសនា និង សិទ្ធិជាប្រជាជននៅ

អ៊ីស្រាអែល។ នៅក្នុងកន្លែងថ្វាយបង្គំតាមក្រឹត្យវិន័យរបស់ពួកគេ ក៏ត្រូវបានស្តេចនោះធ្វើ*ការប្រមាថដែលគួរឲ្យស្អប់ខ្ពើមយ៉ាងខ្លាំង* (ការបំពានដែលគួរឲ្យស្អប់ និង អាក្រក់ជាទីបំផុតនៅក្នុងកន្លែងសក្ការៈសម្រាប់ព្រះជាម្ចាស់) នៅក្នុងព្រះវិហារ។ ដោយស្តេចនេះនឹងតាំងខ្លួនឯងជាព្រះ (ប្រកាសថាខ្លួនជាព្រះជាម្ចាស់) និង ទាមទារឲ្យគេថ្វាយបង្គំខ្លួន (សូមមើលនៅក្នុងគម្ពីរ២ថេស្សាឡូនិក ២:៤,៨-១១ គម្ពីរវិវរណៈ ១៣:១៣-១៥) យើងឃើញថាស្តេចនេះនឹងតាំងរូបភាពរបស់ខ្លួននៅក្នុងព្រះវិហារ ហើយតម្រូវឲ្យពួកយូដាថ្វាយបង្គំ បើគេមិនចង់ស្លាប់។ ស្តេចនេះនឹងទទួលជំនួយពីភ្នាក់ងារពិសេសដែលត្រូវបានគេហៅថា "មន្ត្រីខាងឃោសនា"។ ព្យាការីក្លែងក្លាយនេះ នឹងសម្តែងការអស្ចារ្យ និងមានពេញដោយអំណាច ការអាក្រក់ក៏នឹងជះឥទ្ធិពលលើមនុស្សដែរ (គម្ពីរវិវរណៈ ១៣:១៣; ១៦:១៣)។

ព្រះយេស៊ូព្រះបន្ទូលអំពី ទង្វើនៃការប្រមាថដ៏ធំនេះ ដោយហៅវាថា " សេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ" (ពាក្យក្នុងគម្ពីរពគប) ។ ទ្រង់បានធ្វើការដាស់តឿនថា៖ "កាលណាអ្នករាល់គ្នាឃើញសេចក្តីដែលហោរាដានីយ៉ែលបានទាយទុក គឺជាសេចក្តីស្អប់ខ្ពើមដែលបង្ខូចបំផ្លាញ វាឈរនៅក្នុងទីបរិសុទ្ធ ....នោះត្រូវឲ្យពួកអ្នកដែលនៅស្រុកយូដារត់ចេញទៅឯភ្នំ (គម្ពីរម៉ាថាយ ២៤:១៥-១៦ *ពគប*) ។ តាមរយៈភាសានិមិត្តសញ្ញាដែលពេញដោយឫទ្ធានុភាព យើងបានដឹងអំពីសេចក្តីរន្ធត់ដែលពួកយូដានឹងត្រូវឆ្លងកាត់ នៅពេលដែលប្រព័ន្ធសង្គមដ៏អាក្រក់នៅគ្រាចុងក្រោយព្យាយាមបំផ្លាញប្រទេសអ៊ីស្រាអែល (សូមមើលនៅក្នុងគម្ពីរវិវរណៈ ១២:១៣-១៧ គម្ពីរដានីយ៉ែល ១២:១,៦-៧)។

នៅក្នុងពេលជាមួយគ្នានេះដែរ នឹងមានភាពវឹកវរ និង ការលំបាកជាច្រើនសម្រាប់អ្នកដែលមិនមែនជាសាសន៍យូដា ដ្បិតនឹងមានការវិនិច្ឆ័យបីដងបន្តបន្ទាប់គ្នា ធ្លាក់មកលើមនុស្សដែលរស់នៅលើផែនដី។ គម្ពីរវិវរណៈជំពូក ៦,៨,៩,១៥ និង ១៦ បានរៀបរាប់ អំពីការកើនឡើងនៃព្រះពិរោធរបស់ព្រះជាម្ចាស់ ដែលទ្រង់ចុះមកគ្របលើអាណាចក្ររបស់ "ស្តេចមួយអង្គដែលនឹងមកដល់" ស្របពេលដែលវេលាចេះតែរំកិលទៅមុខ។

នៅពេលដែលស្តេចមួយដែលអាក្រក់នោះ ស្វែងរកការបំពេញកម្លាំងសម្រាប់ខ្លួនឯង ស្តេចនោះនឹងប្រើប្រាស់ប្រព័ន្ធនៅក្នុងពិភពលោកនេះ ដើម្បីគ្រប់គ្រងលើហិរញ្ញវត្ថុ និង ឥតទានទាំងអស់។ តាមរយៈមធ្យោបាយនេះ ស្តេចនោះនឹងអាចបង្ខិតបង្ខំមនុស្សឲ្យទទួលការដឹកនាំរបស់ខ្លួន ដោយព្រោះតែគ្មាននរណាម្នាក់អាចធ្វើជំនួញអ្វីបាននោះទេ ដរាបណាគេបានទទួលសញ្ញាសំគាល់ដែលស្តេចអង្គនេះបានកំណត់ឲ្យ (គម្ពីរវិវរណៈ ១៣:១៦-១៧)។ ស្របពេលដែលស្តេចអង្គនេះ ខំប្រឹងប្រែងកសាងរដ្ឋាភិបាលនៃពិភពលោករួមមួយ នោះគេនឹងជួបប្រទះការជំទាស់ប្រឆាំង។ ដូច្នេះ នឹងមានសង្គ្រាមមួយកើតឡើងនៅពាក់កណ្តាលរយៈពេលប្រាំពីរឆ្នាំនៃការគ្រប់គ្រងរបស់ស្តេចនេះ។

ដោយមានការបណ្តាលចិត្តដោយព្រះវិញ្ញាណឲ្យធ្វើការទស្សន៍ទាយ លោកអេសេគាលបានបង្ហាញថា សហព័ន្ធនៃប្រទេសភាគខាងជើង នឹងមកគ្រប់ដណ្តប់លើប្រទេសអ៊ីស្រាអែល ដែលកំពុងតែរីករាយជាមួយនឹងសុខសុវត្ថិភាពដែលអាទទឹងច្បាប់បានផ្តល់ឲ្យ។ កងទ័ពជាច្រើនកោះករនៅក្នុងសង្គ្រាមនេះគេរំពឹងថានឹងអាចកំទេចអ៊ីស្រាអែលបាន ប៉ុន្តែពួកគេមិនបានគិតដល់ព្រះហឫទ័យទុកដាក់របស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់នោះទេ ។ នៅពេលមានការវាយលុកកើតមានឡើង ព្រះជាម្ចាស់បានការពារប្រជារាស្ត្ររបស់ទ្រង់ ហើយស្ទើរតែបានកំទេចកងកម្លាំងឈ្លានពានទាំងអស់តែម្តង

(គម្ពីរអេសេគាល ៣៨-៣៩)។ កងកម្លាំងផ្សេងទៀតក៏មានភាពចលាចលខ្លួនឯង ហើយអាទទឹងច្បាប់ក៏បានបង្ខំចិត្តដើម្បីប្រកាសការពារនូវសិទ្ធិគ្រប់គ្រងរបស់វា។

អើម៉ាគេដូន

ក៏ដូចគ្នានេះដែរ លោកដានីយ៉ែល បានកត់សំគាល់ឲ្យឃើញថាការទាស់ប្រឆាំង នឹងលេចឡើងនៅកន្លែងផ្សេងៗ។ ការនេះធ្វើឲ្យអាទទឹងច្បាប់ នៅតែបន្តដំណើរទៅបំផ្លាញអ្នកទាស់ប្រឆាំងនឹងវា (គម្ពីរដានីយ៉ែល ១១:៤០-៤៥)។ ជាក់ស្តែង រដ្ឋាភិបាលពិភពលោករួមមួយរបស់គេ នឹងត្រូវបានបំផ្លាញដោយការបែកបាក់ (ការមិនយល់ស្របគ្នា) នៅពេលដែលគ្រាចុងក្រោយខិតចូលមកដល់។ នៅគ្រាដែលពេលវេលាចុងក្រោយជិតចូលមកដល់ ព្រះជាម្ចាស់នឹងត្រាស់ហៅកងទ័ពទាំងអស់ក្នុងពិភពមករួមគ្នា ហើយធ្វើចំបាំងចុងក្រោយដ៏ធំអស្ចារ្យមួយនៅក្នុងប្រវត្តិសាស្ត្រ នៅកន្លែងមួយដែលគេហៅថា *អើម៉ាគេដូន* (គម្ពីរវិវរណៈ ១៦:១៦)។

យ៉ាងណាមិញ នៅអើម៉ាគេដូន បញ្ហានឹងមិនត្រូវបានសម្រេចដោយអាវុធទំនើបៗរបស់មនុស្ស ចំនួនរបស់កងទ័ព ឬ ការប្តេជ្ញាចិត្តរបស់អ្នកចំបាំងឡើយ។ *ព្រះជាម្ចាស់នឹង ធ្វើឲ្យកងទ័ពភ្ញាក់ផ្អើលនៅពេលដែលទ្រង់ធ្វើការវាយប្រហារ។* លទ្ធផលគឺនឹងគួរឲ្យខ្លាច ដែលមិនអាចបកស្រាយបាននោះទេ (សូមមើលនៅក្នុងគម្ពីរវិវរណៈ:១៩:១៩-២១)។

មនុស្សក្រអឺតក្រទម នឹងមិនត្រឹមតែប្រមាថព្រះជាម្ចាស់នៅក្នុងការប្រយុទ្ធប៉ុណ្ណោះទេ ប៉ុន្តែមកដល់ចំណុចត្រង់នេះ ពួកគេក៏ស្ទើរតែនឹងបំផ្លាញអ៊ីស្រាអែលទៅហើយ។ ទោះជាយ៉ាងណា នៅពេលដែលព្រះអម្ចាស់យេស៊ូនៃយើងទ្រង់យាងមកដល់ នោះនឹងមានរឿងជាច្រើនកើតឡើង។ ស្របពេលដែល អ៊ីស្រាអែលទទួលរងការបំភ្លិចបំផ្លាញពីសំណាក់ពួកខ្មាំងសត្រូវ ពួកគេស្រាប់តែទទួលបានការផ្លាស់ប្តូរ ដួងចិត្តរបស់ពួកគេ (សូមមើលនៅក្នុងគម្ពីរសាការី ១៤:៤-៥,១២-១៥)។ ព្រះអង្គ (ព្រះយេស៊ូ) ដែលនឹងដឹកនាំនៅក្នុងសង្គ្រាម មិនមែនជានរណាផ្សេងទៀតទេ គឺព្រះអង្គដែលពួកឪពុករបស់ពួកគេបានបដិសេធនោះឯង។ ឥឡូវព្រះអង្គដែលត្រូវបានគេចាក់ទម្លុះនេះ ទ្រង់បាននាំមកនូវការប្រោសលោះប្រកបដោយចេស្តា។ ជាមួយនឹងការបង្ហាញព្រះកាយរបស់ទ្រង់ ប្រជារាស្ត្រយូដាដែលបានរស់រានមានជីវិត ក៏ត្រូវបានបំបាក់ដោយវិញ្ញាណសោកសង្រេង (គម្ពីរសាការី ១២:១០- ១៣:១) ហើយពួកគេទទួលយកព្រះអង្គដែលបានយាងមកនៅក្នុងព្រះនាមព្រះអម្ចាស់។ ឥឡូវនេះ ចំណុចសំខាន់ជាច្រើនផ្សេងទៀតនៃផែនការរបស់ព្រះជាម្ចាស់ដែលកត់ត្រានៅក្នុងគម្ពីរដានីយ៉ែល ៩:២៤ ត្រូវបានលើកយកមកបង្ហាញ ស្របពេលដែលយើងនឹងឃើញអំពីការនេះនៅក្នុងទិដ្ឋភាពបន្ទាប់ទៀតនេះ។

លំហាត់អនុវត្តន៍

១០ តើការលើកឡើងមួយណា ក្នុងចំណោមខាងក្រោមនេះ ជាចម្លើយត្រឹមត្រូវ ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងសម័យរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត និង ក្នុងសម័យសង្គ្រាមនៃអើម៉ាគេដូន?

ក) ឈ្មោះផ្សេងៗទៀតរបស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត គឺ *ស្តេចមួយដែលនឹងមកដល់* និង *មនុស្សទទឹងច្បាប់*។

ខ) លោកដែលគេចាក់ប្រេងអភិសេកនោះ គឺសំដៅទៅលើព្រះយេស៊ូគ្រិស្ត។

គ) នៅពេលដែលក្រុមជំនុំបានកើតឡើង ព្រះជាម្ចាស់បានលែងទទួលស្គាល់ប្រជាជាតិយូដាទាំងស្រុងរួចទៅហើយ។

ឃ) មុនពេលស្តេចមួយដែលនឹងមកដល់ លេចឡើងមក ក្រុមជំនុំនឹងត្រូវបាន "ចាប់យកទៅ" ឬ ត្រូវបានឆក់យកទៅ។

ង) អ៊ីស្រាអែលនឹងត្រូវបានលើកលែងពីការបានវិនិច្ឆ័យទោស និង ទុក្ខវេទនានៅគ្រាចុងក្រោយ។

ច) អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងសម្រេចបានការសន្យាសន្តិភាពរយៈពេលប្រាំពីរឆ្នាំ ជាមួយនឹងអ៊ីស្រាអែល ដែលនេះនឹងក្លាយជាអំឡុងពេលមួយដែលមានសន្តិភាពអស្ចារ្យ និង ចម្រុងចម្រើនពាសពេញពិភពលោក។

ឆ) បទគម្ពីរបញ្ជាក់ថា អ្នកប្រឆាំងនឹងព្រះគ្រិស្ត នឹងបំភ្លេចការសន្យារបស់គេជាមួយនឹងអ៊ីស្រាអែល ព្រមទាំងបំពានព្រះវិហារដ៏វិសុទ្ធថែមទៀតផង។

ជ) អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹង បានគ្រប់គ្រងលើពិភពលោកទាំងមូល ហើយបង្ខំឲ្យមនុស្សគ្រប់គ្នាទទួលយកសញ្ញារបស់ខ្លួន បើសិនជាចង់ធ្វើជំនួញអ្វីមួយ។

ឈ) អ្នកដែលធ្វើការវាយប្រហារដំបូងគេ នៅក្នុងសមរភូមិនៃអើម៉ាគេដូន គឺជាពួកទាហានដែលកំពុងប្រមូលផ្តុំគ្នា រួមជាមួយនឹងអាវុធដ៏ខ្លាំងពូកែរបស់គេ។

ញ) ព្រះយេស៊ូគ្រិស្តនឹងយាងមកឯប្រជាជាតិយូដា ក្នុងនាមជាព្រះអម្ចាស់របស់ពួកគេក្នុងពេលណាមួយ។

គ. ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត

វត្ថុបំណងទី ៤. *បកស្រាយថាតើមានលក្ខខ័ណ្ឌអ្វីខ្លះ ដែលនឹងនាំឲ្យមានការបើកសម្តែងរបស់ព្រះគ្រិស្ត និង ផ្ទឹបភាប់អំពីលទ្ធផលចុងក្រោយរបស់អ្នកដឹកនាំនៃគូបដិបក្សទាំងពីរ។*

លក្ខខ័ណ្ឌ

ស្របពេលដែលព្រឹត្តិការណ៍នៃគ្រាមហាវេទនា កំពុងដែលកើតមានឡើង អ្នកជឿគឺកំពុងតែនៅជាមួយនឹងព្រះអម្ចាស់របស់ពួកគេ។ ស្របពេលដែលចំណងនៃអំពើអាក្រក់ ផុសផុលឡើង ហើយភាពមានបាបរបស់មនុស្សលោកកាន់តែឈានទៅដល់កំពូលដ៏ខ្ពស់បំផុត ទិដ្ឋភាពទីពីរនៃការយាងមករបស់ព្រះអម្ចាស់ក៏នឹងកើតឡើង នោះគឺការបើកសម្តែងរបស់ទ្រង់ទៅកាន់មនុស្សដែលនៅក្នុងលោកីយ៍ និង ទៅ

កាន់ទាហារដែលបានប្រមូលផ្តុំនៅលើផែនដី (គម្ពីរវិវរណៈ ១:៧; ១៩:១១-២១)។ នៅក្នុងពេលនេះ អ្នកជឿក៏មកជាមួយនឹងព្រះអម្ចាស់ នៅពេលដែលទ្រង់ត្រឡប់មកលើផែនដី (គម្ពីរកូឡុស ៣:៤)។

បន្ទាប់មកទៀត នៅក្នុងពេលនេះ លក្ខខ័ណ្ឌពីរយ៉ាងនឹងឈានទៅរកកម្រិតមួយដែលគេមិនអាចទទួលយកបាន។ លក្ខខ័ណ្ឌទីមួយគឺ *ការមិនគោរពកោតខ្លាចព្រះជាម្ចាស់ និង ភាពអាត្មានិយមរបស់មនុស្សលោក។* នោះហើយជាហេតុដែលមានទេវតាពីររូប ស្រែកឡើងថា ផលផ្លែបានទុំអស់ហើយ (គម្ពីរវិវរណៈ ១៤:១៥)។ ពេលវេលានៃការប្រមូលផលយ៉ាងពិនិត្យពិច័យ បានមកដល់ហើយ។ ព្រះជាម្ចាស់ដែលបានប្រទានឲ្យមនុស្សនូវសេរីភាព ក្នុងការសម្រេចចិត្ត ពេលនេះនឹងមិនអនុញ្ញាតឲ្យពួកគេធ្វើតាមបំណងចិត្តដ៏រឿចវេររបស់ពួកគេទៀតទេ។ អស់អ្នកដែលសង្ស័យ និង អ្នកមិនជឿ ដែលទាស់នឹងគ្រប់ផ្នត់គំនិតអំពីព្រះជាម្ចាស់ដ៏វិសុទ្ធនឹងត្រូវបានបំបិទឲ្យស្ងាត់។ បញ្ហាអំពើបាប ត្រូវបានដោះស្រាយឲ្យរួចស្រេចជារៀងរហូត។ ជាការឆ្លើយតបទៅនឹងអ្វីដែលទេវតាទាំងពីរនោះ បានប្រកាសឡើង ទេវតាផ្សេងទៀតនឹងថ្លែងឡើងតាមបែបប្រៀបធៀបថា បោះកាំបិតរបស់លោកមកលើផែនដី ផ្លែទំពាំងបាយជូរនៅលើផែនដីក៏កាត់រួចរាល់ជាស្រេច ហើយលោកបោះផ្លែទំពាំងបាយជូរទៅក្នុងធុងបញ្ចាន់ផ្លែ ជាធុងនៃព្រះពិរោធដ៏ខ្លាំងរបស់ព្រះជាម្ចាស់ (គម្ពីរវិវរណៈ ១៤:១៩)។

លក្ខខ័ណ្ឌទីពីរ ដែលព្រះជាម្ចាស់នឹងមិនបានទ្រាំតទៅទៀតបាននោះគឺ *ការបៀតបៀនទៅលើអ៊ីស្រាអែល។* ដូចដែលយើងបានឃើញហើយថា មនុស្សទទឹងច្បាប់នឹងធានាឲ្យបានថា ការសម្លាប់ផ្តាច់ពូជ (ការបំផ្លាញទាំងស្រុង) នៃបងប្អូនរបស់ព្រះអម្ចាស់ ក្លាយទៅជាគោលដៅដំបូងរបស់គេ ។ ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងមិនបាននៅស្ងៀមរហូតដែរ នៅពេលដែលបំណងដ៏អាក្រក់នេះចាប់ផ្តើមជាសកម្មភាពឡើង។ ការលូកព្រះហស្តរបស់ទ្រង់ក៏នឹងមកដល់ ដែលនឹងជួយឲ្យការយាងមកររបស់ទ្រង់នៅលើផែនដីនេះកើតឡើងបាន។

លំហាត់អនុវត្តន៍

---

១១ (ចូរជ្រើសរើសចម្លើយមួយ)។ ភាសាប្រៀបធៀបនៅក្នុងគម្ពីរវិវរណៈ ១៤:១៩ មាននៃថាពេលវេលានឹងមកដល់ ពេលណាដែលព្រះជាម្ចាស់នឹង

ក) បំផ្លាញជីវិតរុក្ខជាតិទាំងអស់នៅលើផែនដី។

ខ) នាំមកនូវការវិនិច្ឆ័យចុងក្រោយ ដល់មនុស្សមានបាបទាំងឡាយណាដែលបដិសេធមិនទទួលយកទ្រង់។

គ) ឆក់យកក្រុមជំនុំឡើងទៅ។

ឃ) ធ្វើឲ្យមនុស្សអាក្រក់បំផ្លាញខ្លួនឯង។

ព្រឹត្តិការណ៍

នៅក្នុងការយាងមកដំបូងរបស់ទ្រង់ ព្រះយេស៊ូបានយាងមកជាបាវបម្រើដែលរងទុក្ខ។ ទ្រង់បានយាងមកក្នុងភូមិដ៏តូចមួយ មិនសូវមានអ្នកណាស្គាល់ ដោយគ្មានការប្រារព្ធពិធី ឬការរៀបចំទទួលពិសេសណាមួយនោះទេ។ មានតែអ្នកគង្វាលពីរបីនាក់ប៉ុណ្ណោះ ដើម្បីថ្វាយសិរីរុងរឿងដែលបានលេចឡើងនៅជ្រលងភ្នំក្នុងស្រុកយូដា នៅពេលដែលពួកទេវតានៃស្ថានសួគ៌ាស្វាគមន៍ការប្រសូតរបស់ទ្រង់ (គម្ពីរលូកា ២:៨-១៥)។ ទោះជាយ៉ាងណា នៅក្នុងការយាងត្រឡប់មកជាលើកទីពីររបស់ទ្រង់ ទ្រង់នឹងយាងមកនៅក្នុងស្រុកដដែលនោះ ជាមួយនឹងសិរីរុងរឿង និង កិត្តិយសដ៏អស្ចារ្យ។ នៅលើកនេះ ទ្រង់នឹងមិនអង្វរមនុស្សទៀតនោះទេ។ ទ្រង់នឹងយាងមកដើម្បីកំទេច ដើម្បីយកជ័យជម្នះ និង ដើម្បីកាន់កាប់សិទ្ធិអំណាចរបស់ទ្រង់ដោយបង្ខំតែម្តង។

មនុស្សម្នានឹងបានឃើញ កងទ័ពនៃស្ថានបរមសុខ នៅពេលដែលពួកគេអមដំណើរព្រះយេស៊ូ ដែលជាអ្នកដឹកនាំពួកគេ។ ពួកគេនឹងរួមចំណែកនៅក្នុងការ តតាំង (មុខទាល់នឹងមុខ) រវាងព្រះអម្ចាស់នៃយើងជាមួយនឹងកងពលរបស់មនុស្សទទឹងច្បាប់។ ចូរឲ្យយើងបានកត់សំគាល់យ៉ាងខ្លីនៅត្រង់ អ្វីដែលនឹងសម្រេចបាន នៅក្នុងការបើកសម្តែងរបស់ព្រះអម្ចាស់នៃយើង។

១. គោលដៅភ្លាមៗ នឹងជាការបញ្ចប់សង្គ្រាមរបស់ពួកបះបោរ ដែលបានផ្ទុះឡើងក្នុងទ្រង់ទ្រាំងទូទាំងសាកលលោក។ (គម្ពីរវិវរណៈ ១៦:១២-២១; ១៩:១១-២១)។

២. ព្រះអម្ចាស់នៃយើង នឹងបើកសម្តែងអង្គទ្រង់ក្នុងនាមជាស្តេចលើស្តេច និង ព្រះអម្ចាស់លើព្រះអម្ចាស់ ។ សាតាំងដែលបានគ្រប់គ្រងលើនគរទាំងអស់នៅក្នុងពិភពលោក នៅក្នុងពេលបច្ចុប្បន្ននេះ នឹងត្រូវបានដកចេញ ហើយព្រះយេស៊ូដែលជាស្តេចពេញសិទ្ធិ ទ្រង់នឹងឡើងគ្រងតំណែងជាស្តេចរបស់ទ្រង់។

៣. ព្រះយេស៊ូនឹងបង្ករឲ្យអ្នកដឹកនាំនៅក្នុងកងពលរបស់សាតាំង អស់អំណាច នៅពេលដែលទ្រង់យកពួកគេទៅឃុំនៅក្នុងបឹងភ្លើងយ៉ាងឆាប់រហ័សបំផុត។ (គម្ពីរវិវរណៈ ១៩:១៩-២១)។

៤. ពិតណាស់ ដូចដែលយើងបានឃើញហើយថា ការបានសង្គ្រោះអ៊ីស្រាអែលនឹងជាអាទិភាពចម្បងជាងគេ។ ព្រឹត្តិការណ៍នៃការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់នៃយើង នឹងនាំឲ្យពួកយូដាបែរត្រឡប់ទៅរកព្រះជាម្ចាស់ ជាមួយនឹងការលន់តួ និង ទុក្ខសោករបស់គេ។ ការសម្អាតខាងឯវិញ្ញាណឲ្យបានថ្មីឡើងវិញ នឹងកើតឡើង មិនដូចជាអ្វីដែលធ្លាប់កើតមាននៅក្នុងប្រវត្តិសាស្ត្រឡើយ ៖ មនុស្សដែលខ្វាក់ខាងឯវិញ្ញាណទាំងអស់នេះ នឹងលះបង់ដួងចិត្តដ៏រឹងទទឹងរបស់ពួកគេ ហើយទទួលយកដួងចិត្តដែលមានសាច់ឈាមជាមួយនឹងឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ជួយពួកគេក្នុងការប្រកាន់ខ្ជាប់ច្បាប់វិន័យនៃព្រះអាទិករបស់ពួកគេ (គម្ពីរអេសេគាល ៣៦:២៦-២៧) ។

៥. ចុងក្រោយ ការយាងមករបស់ព្រះអម្ចាស់នៃយើងដែលប្រកបដោយសិរីរុងរឿង នឹងនាំឲ្យមានការសម្រេចបាននូវនគរនៃភាពសុចរិតជាសាកលមួយ និងជានគរដែលមានអាយុកាលមួយពាន់ឆ្នាំ ឬ សហស្សវត្សរ៍ ។ ការបង្ហាញដែលច្បាស់ជាងគេបំផុត អំពីលក្ខខ័ណ្ឌក្នុងការចូលទៅក្នុងនគរមួយនេះ គឺផ្អែកទៅលើបទគម្ពីរដែលមានចែងនៅក្នុងគម្ពីរម៉ាថាយ២៥:៣១-៤៦។ បើយើងមើលទៅ ហាក់

បីដូចជារាល់ការប្រព្រឹត្តិទាំងអម្បាល់ម៉ាន ទាក់ទងនឹងពួកយូដាដែលជាបងប្អូនរបស់ព្រះអម្ចាស់ នោះ នឹងក្លាយជាការកំណត់ការចូលទៅក្នុងនគរនេះ (សូមមើលគម្ពីរម៉ាថាយ ២៥:៤០) និង គម្ពីរ លោកុប្បត្តិ ១២:១-៣)។ រយៈពេលមួយសហស្សវត្សរ៍ នឹងក្លាយជាប្រធានបទដែលត្រូវពិចារណាបន្ត ទៀត។

លំហាត់អនុវត្តន៍

---

១២ តើអ្វីជា លក្ខខ័ណ្ឌពីរយ៉ាងធំជាងគេដែលនឹងនាំឲ្យមានការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត នៅក្នុងគ្រានៃការប្រោសលោះ ដែលនឹងត្រឡប់មកលើផែនដីវិញជាមួយទ្រង់?

.....

១៣ តើអ្វីនឹងជាលទ្ធផលសម្រាប់ស្តេចរបស់កងពលបដិបក្សទាំងពីរ នៅពេលដែលពួកគេបានមកជួបទល់មុខគ្នាក្នុងគ្រាចុងក្រោយ?

.....

ឃ. រយៈពេលមួយសហស្សវត្សរ៍

វត្ថុបំណងទី៥. *ពិភាក្សាអំពីគោលបំណង និង រៀបរាប់អំពីលក្ខណសម្បត្តិនៃរាជ្យមួយឆ្នាំ។*

គោលបំណងផ្សេងៗនៃរាជ្យមួយពាន់ឆ្នាំ

ព្រះគម្ពីរបានថ្លែងអំពី គ្រាមួយនៃក្តីសុចរិត និង សន្តិភាព យុត្តិធម៌ និង ភាពសំបូរហូរហៀរ ដែលមានទាក់ទងនឹងការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់នៃយើង (គម្ពីរអេសាយ២:១-៤; ៦៥:២០-២២ គម្ពីរមីកា ៤:១-៥)។ នៅក្នុងគម្ពីរវិវរណៈ ២០:១-៧ ចែងថាអំឡុងពេលនោះ គឺមានរយៈពេល១០០០ឆ្នាំ។ ទោះជាយ៉ាងណា ព្រះរាជ្យត្រូវបានលើកយកទៅនិយាយនៅក្នុងព្រះគម្ពីរតាមរបៀបជាច្រើន។ នៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ គឺមាននិយាយអំពីព្រះរាជ្យដែលនឹងមកដល់ (គម្ពីរម៉ាថាយ ៦:១០) ស្របពេលជាមួយគ្នានោះ ព្រះគម្ពីរលូកា ១៩:១១ ព្រះរាជ្យនេះត្រូវបានហៅថា " ព្រះរាជ្យរបស់ព្រះជាម្ចាស់"។ គម្ពីរវិវរណៈ១១:១៥ និយាយអំពី "ព្រះរាជ្យរបស់ព្រះអម្ចាស់នៃយើង និង ព្រះគ្រិស្តរបស់ព្រះអង្គ"។ គម្ពីរដានីយ៉ែល ជំពូក៧ ហៅព្រះរាជ្យនេះថា "អំណាចគ្រប់គ្រងរបស់លោកនៅស្ថិតស្ថេរអស់កល្បជានិច្ចឥតសាបសូន្យ" និង "រាជសម្បត្តិរបស់លោកមិនត្រូវរលាយដែរ" (ខ១៤)។

តើគោលបំណងរបស់ព្រះរាជ្យនេះ គឺជាអ្វី? ទីមួយ កាលដើមដំបូងបង្អស់ ព្រះជាម្ចាស់បានបង្កើតសណ្តាប់ធ្នាប់ខាងឯសីលធម៌ ដែលត្រូវបានដាក់ទៅក្រោមការល្បួងពីសាតាំង និង ផែនដីក៏ធ្លាក់ទៅក្រោមចំណងនៃវិញ្ញាណអាក្រក់មួយនេះ។ ដូច្នេះ វាគឺជាការចាំបាច់ណាស់ ដែលសិរីរុងរឿងរបស់ព្រះជាម្ចាស់ត្រូវបានស្តារឡើង (ជួយការពារ បង្ហាញថាពិត ឬ ត្រឹមត្រូវ) តាមរយៈជ័យជម្នះលើអំណាចគ្រប់គ្រងរបស់សាតាំង។ នៅពេលដែលឥទ្ធិពលនៃបណ្តាសារត្រូវបានស្រាយចេញ ហើយសាតាំងក៏ត្រូវបានឃុំឃាំង មនុស្សជាតិនឹងអាចមានសេរីភាព ក្នុងការប្រតិបត្តិសេចក្តីស្រឡាញ់ ភាពយុត្តិធម៌ និង ការយកចិត្ត

ទុកដាក់លើព្រះអម្ចាស់ នៅពេលដែលទ្រង់គ្រងរាជ្យនៅក្នុងសមភាព និង សេចក្តីពិត។ ជាលទ្ធផល មនុស្សជាតិនឹងថ្វាយភាពស្មោះត្រង់របស់គេ ទៅកាន់ព្រះអម្ចាស់។ នៅក្នុងព្រះរាជ្យនៃក្តីសន្តោសមេត្តា របស់ទ្រង់ ព្រះអម្ចាស់នៃយើងនឹងបង្ហាញថា សេចក្តីត្រូវការរបស់យើង ត្រូវបានបំពេញជាស្រេច បង្ហាញថា យុត្តិធម៌មានពិត និង បង្ហាញថាសន្តិភាព និង ភាពចុះសម្រុងគ្នាពិតជាអាចកើតឡើងទៅបាននៅលើផែនដីនេះ។

ទីពីរ សម័យកាលនៃព្រះរាជ្យគឺមានភាពចាំបាច់ក្នុងការបំពេញតាមបទទំនាយ។ ព្រះជាម្ចាស់បានសន្យាទៅកាន់ដាវីឌថា កូនចៅជំនាន់ក្រោយរបស់លោក នឹងបានគ្រប់គ្រងជារៀងរហូត (គម្ពីរ២សាំយ៊ូអែល ៧:៨-១៧ គម្ពីរទំនុកតម្កើង ៨៩:៣-៤,១៩-៣៧ គម្ពីរយេរេមា ៣៣:១៤-២៦)។ ដូចដែលយើងបានឃើញហើយថា មានការបកស្រាយមួយនៅក្នុងការគ្រប់គ្រងនេះ គឺថាបទទំនាយនេះនៅ មិនទាន់សម្រេចនៅឡើយ។ ពេលវេលាមួយបានមកដល់ ដែលព្រះយេស៊ូបានប្រសូតចេញពីនាងម៉ារី ដែលជាកូនចៅរបស់ដាវីឌ ប៉ុន្តែទ្រង់មិនបានគ្រងរាជ្យនៅលើបល្ល័ង្ករបស់ស្តេចដាវីឌនៅអ៊ីស្រាអែលឡើយ។ ដូច្នេះ បទទំនាយនេះ នៅតែត្រូវរងចាំការសម្រេចនៅថ្ងៃអនាគត ។ (សូមមើលនៅក្នុងគម្ពីរដានីយ៉ែល ២:៣៤-៣៥, ៤៤-៤៥ និងគម្ពីររ៉ូម៨:១៨-២៥ សម្រាប់បទទំនាយដែលទាក់ទងនឹងការនេះ)។

លក្ខណាសម្បត្តិនៃព្រះរាជ្យ

ឯកសារយោងជាច្រើននៅក្នុងបទគម្ពីរ បានជួយឲ្យយើងបានយល់ដឹងបន្ថែមទៀត អំពីការគ្រប់គ្រង និង ស្ថានភាពខាងឯវិញ្ញាណ ដែលនឹងកើតមាន នៅពេលដែលព្រះអង្គដែលគេចាក់ប្រេងអភិសេកឡើងគ្រងរាជ្យ។ ចូរសិក្សាការទាំងនេះ ដោយយកចិត្តទុកដាក់។

១. នឹងមានការឡើងគ្រងរាជ្យដ៏ពិតជាក់ស្តែងមួយនៅលើផែនដី (គម្ពីរសាការី ១៤:៩)។

២. គ្រានោះ នឹងរាប់បញ្ចូលមនុស្សទាំងអស់ដែលនៅមានជីវិតលើផែនដី (គម្ពីរទំនុកតម្កើង ៧៣:៨-១១ គម្ពីរដានីយ៉ែល៧:១៤ គម្ពីរម៉ាថាយ២៥:៣១-៣២)។

៣. ដោយឥទ្ធិពលនៃបណ្តាសារត្រូវបានស្រាយចេញ ទឹកដីនឹងងាយដាំដុះបង្កើតជាអាហារ។ ពេលនោះនឹងគ្មានគ្រោះទុរភិក្ស ឬ ការខ្វះអាហារទៀតទេ (គម្ពីរអេសាយ ៣៥:១ គម្ពីរមីកា ៤:១-៤)។

៤. ក្រឹត្យវិន័យរបស់ព្រះអម្ចាស់នឹងត្រូវ មនុស្សគ្រប់គ្នាគោរពប្រតិបត្តិ។ ស្របពេលដែលការគ្រប់គ្រងនេះពេញដោយក្តីសប្បុរស និង សន្តោសមេត្តា ក៏វានឹងនៅតែមានភាពមុឺងម៉ាត់ផងដែរ។ ការវិនិច្ឆ័យ និង ការយុត្តិធម៌ឥតខ្ចោះ នឹងកើតមានឡើង។ អ្នកណាម្នាក់ដែលបដិសេធមិនស្តាប់បង្គាប់តាម នឹងត្រូវដាក់ទោស (គម្ពីរទំនុកតម្កើង២:៩ គម្ពីរអេសាយ១១:៤; ៦៥:២០ គម្ពីរសាការី ១៤:១៦-១៩)។

៥. អ្វីដែលស្តេចនៃនគរលើផែនដីនេះយកព្រះទ័យទុកដាក់ ច្បាស់ជាអស់អ្នកដែលឆ្លងផុតគ្រាមហាវេទនា ទាំងសាសន៍យូដា និងសាសន៍ដទៃ។

៦. សន្តិភាពនឹងក្លាយជាលក្ខណាសម្បត្តិដំបូងនៃនគរដែលដឹកនាំដោយបុត្រានៃសន្តិភាពអង្គនេះ។ ដោយគ្មានឥទ្ធិពលអាក្រក់របស់សាតាំង នោះនឹងគ្មានសង្គ្រាមកើតឡើងទៀតទេ (គម្ពីរអេសាយ ១១:៦-៧)។

៧. ពិតណាស់ អ្នកជឿដែលបានប្រោសលោះហើយ នឹងជួយបម្រើការងារនៅក្នុងនគរនេះ។ ពួកសាវ័កនឹងគ្រប់គ្រងលើអ៊ីស្រាអែល ហើយមើលទៅដាវីឌនឹងត្រូវ ប្រោសឲ្យរស់ឡើងវិញ ហើយនឹងបម្រើការជា អនុប្រឹក្សាភិបាល ដែលនៅក្រោមព្រះអម្ចាស់នៃយើង (គម្ពីរ១កូរិនថូស ៦:២-៣ គម្ពីរវិវរណៈ៥: ១០ គម្ពីរម៉ាថាយ ១៩:២៨; ២៥:៣១ គម្ពីរយេរេមា ៣០:៩ គម្ពីរអេសេគាល ៣៧:២៤-២៥)។

៨. ពិភពរបស់សត្វ នឹងបានផ្លាស់ប្តូរយ៉ាងអស្ចារ្យបំផុត។ សត្វសាហាវនឹងបានស្លូត ហើយសត្វស្លូតក៏នឹងមិនខ្លាចទៀតដែរ។ ពួកវានឹងរស់នៅជាមួយគ្នាដោយសន្តិភាព (គម្ពីរអេសាយ ១១:៦-៩)។

៩. មនុស្សនឹងប៉ង់ប្រាថ្នាចង់បានព្រះជាម្ចាស់ និង រឿងរ៉ាវខាងឯវិញ្ញាណ។ ពួកគេនឹងសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីឲ្យព្រះតម្រិះរបស់ទ្រង់បានស្តែងឡើងនៅគ្រប់ទីកន្លែង (គម្ពីរអេសាយ ២:៣; ១១:៩ គម្ពីរសាការី ៨:២០-២៣)។

លំហាត់អនុវត្តន៍

---

១៤ តើចម្លើយមួយណានៅខាងក្រោមនេះ ជាគោលបំណងនៃព្រះរាជ្យមួយពាន់ឆ្នាំ?

ក) ដើម្បីផ្តល់ឲ្យសាតាំង ឬ មនុស្សអាក្រក់ដែលបានស្លាប់ទៅហើយ នូវឱកាសជាលើកចុងក្រោយសម្រាប់ធ្វើការលន់តួ និង បែរត្រឡប់មករកព្រះជាម្ចាស់វិញ។

ខ) ដើម្បីបំពេញតាមបទទំនាយដែលទាក់ទងនឹងកូនចៅជំនាន់ក្រោយរបស់ស្តេចដាវីឌ។

គ) ដើម្បីការពារសិរីរុងរឿងរបស់ព្រះជាម្ចាស់ និង សម្រេចឲ្យបានថាមាគ៌ារបស់ទ្រង់គឺជាមាគ៌ាដ៏ពិត និង ត្រឹមត្រូវតែមួយគត់។

១៥ ចូរលើកឡើងពីស្ថានភាពនៃលក្ខណសម្បត្តិនៃព្រះរាជ្យមួយពាន់ឆ្នាំនៅខាងក្រោមនេះ ដោយសរសេរដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ក) ពិភពរបស់សត្វ

ខ) ក្រឹត្យវិន័យរបស់ព្រះអម្ចាស់

គ) ទីកន្លែងសម្រាប់ព្រះរាជ្យ

ឃ) អ្នកជឿបានប្រោសលោះ ដែលត្រឡប់មកជាមួយព្រះគ្រិស្ត

ង) ស្តេចដាវីឌ

ច) សាសន៍យូដា និង សាសន៍ដទៃ ដែលបានឆ្លងផុតគ្រាមហាវេទនា

ឆ) ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង រឿងរ៉ាវខាងឯវិញ្ញាណ

ជ) ការបង្កើតអាហារ

១៦. ការវិនិច្ឆ័យសាតាំង និង មនុស្សអាក្រក់ដែលបានស្លាប់

វត្ថុបំណងទី៦. *បកស្រាយមូលហេតុដែលសាតាំង នឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយសហស្សវត្សរ៍ និង បកស្រាយអំពីគោលបំណងនៃបល្ល័ង្កមួយធំពណ៌ស។*

ការឃោសបញ្ឆោតចុងក្រោយរបស់សាតាំង

នៅចុងបញ្ចប់រយៈពេលមួយសហស្សវត្សរ៍ សាតាំងនឹងត្រូវបានដោះលែងពីការឃុំឃាំង (គម្ពីរវិវរណៈ ២០:៧-១០) ។ សាតាំងនឹង ចេញទៅពាសពេញផែនដីទាំងមូលដើម្បីបញ្ឆោតចិត្តមនុស្សម្តងទៀត ដោយជំរុញឲ្យមានការប្រឆាំងបះបោរទាស់នឹងព្រះអម្ចាស់។ យើងត្រូវបានប្រាប់ឲ្យដឹងថា នឹងមានមនុស្សជាច្រើនចូលរួមជាមួយជួរទ័ពរបស់សាតាំង ហើយវាយប្រឆាំងទាស់នឹងមនុស្សរបស់ព្រះជាម្ចាស់នៅក្នុងរាជធានីរបស់ពួកគេ។

អ្នកប្រហែលជាអាចនឹងសួរថា "តើអាចទៅរួចដែរឬ ដែលមនុស្សរស់នៅក្រោមការគ្រប់គ្រងរបស់ព្រះយេស៊ូជាក្សត្រហើយ នៅតែអាចក្បត់នឹងទ្រង់ ហើយថែមទាំងជឿថាខ្លួនគេអាចយកឈ្នះនៅក្នុងការទាស់ប្រឆាំងនឹងទ្រង់បានថែមទៀតនោះ?" អ្នកត្រូវចាំថា នៅក្នុងអំឡុងពេលមួយសហស្សវត្សរ៍ សាតាំងត្រូវបានឃុំឃាំង។ មនុស្សទាំងអស់នឹងត្រូវបានតម្រូវឲ្យស្តាប់ប្រតិបត្តិតាមក្រឹត្យវិន័យរបស់នគរព្រះ។ទោះបីក្នុងរយៈពេលមនុស្សស្តាប់បង្គាប់ព្រះអម្ចាស់នៃយើង ក៏នឹងមានមនុស្សជាច្រើនមិនជ្រើសរើសយកព្រះគុណនៃការសង្គ្រោះរបស់ទ្រង់ឡើយ។ ព្រះជាម្ចាស់មិនបង្ខំពួកគេឲ្យទទួលព្រះសង្គ្រោះនោះទេ។ ដូច្នេះគ្រាចុងក្រោយនៃព្រះរាជ្យនេះ មានមនុស្សជាច្រើននឹងបង្ហាញយ៉ាងច្បាស់ ថាមិនបានជឿទៅលើព្រះគ្រិស្តសម្រាប់ការសង្គ្រោះរបស់ពួកគេឡើយ។ បន្ទាប់មកនៅពេលដែលសាតាំងលេចមកជាមួយនឹងការបោកបញ្ឆោតថែមទៀត ដែលជាការកុហកដ៏ធំនោះ ពួកគេនឹងមានឱកាសក្នុងការបះបោរមិនខាន។ ពួកគេនឹងមានសិទ្ធិក្នុងការប្រកាន់សិទ្ធិរបស់ពួកគេ ដើម្បីធ្វើការជ្រើសរើស។

ការបះបោរនេះ នឹងកើតមានឡើងជុំវិញពិភពលោក ហើយនឹងកាន់តែធំទៅៗ រហូតដល់ពេលដែលសាតាំង ដឹកនាំកងទ័ពទៅច្បាំងនឹងជុំវិញរបស់ប្រជារាស្ត្រនៃព្រះជាម្ចាស់។ ទោះជាយ៉ាងណា ព្រះជាម្ចាស់នឹងធ្វើការដាក់ទោសដោយភ្លើងទៅលើពួកអ្នកបះបោរ ហើយពួកគេនឹងត្រូវឆាបឆេះ។ សាតាំងដែលជាអ្នកដឹកនាំពួកគេ នឹងត្រូវឃុំឃាំងជារៀងរហូត ហើយត្រូវដាក់នៅក្នុងបឹងភ្លើង ជាមួយនឹងសត្វតិរច្ឆាននិងព្យាការីក្លែងក្លាយ ជាកន្លែងដែលពួកគេរងទុក្ខវេទនាដោយសារតែវិញ្ញាណបះបោររបស់ពួកគេ។

ការវិនិច្ឆ័យនៃបល្ល័ង្កពណ៌សធំមួយ

ក្រោយពីមានការបះបោររបស់សាតាំងនេះហើយ ពេលវេលានៃការវិនិច្ឆ័យទោសក៏នឹងមកដល់។ ពេលនោះនឹងជាពេលដ៏អស្ចារ្យមួយ ដែលអ្វីៗសព្វសារពើកំរើកឡើង ដោយសារតែព្រះចេស្តានៃព្រះវត្តមានរបស់ព្រះជាម្ចាស់។ ចំពោះអស់អ្នកដែលបានស្លាប់ទៅ ទាំងមិនបានទទួលស្គាល់សេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ គេនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញ ដើម្បីឈរនៅចំពោះ បល្ល័ង្កពណ៌សដ៏ធំអស្ចារ្យ (គម្ពីរវិវរណៈ ២០:១១-១៥)។ អស់អ្នកដែលបានស្លាប់ទៅនៅក្នុងព្រះគ្រិស្ត គេនឹងត្រូវបានត្រាស់ហៅម្តងទៀត ដោយត្រូវបានប្រោសឲ្យរស់នៅពេលដែលក្រុមជំនុំត្រូវបានឆក់យកឡើងទៅ (គម្ពីរ១ថេស្សាឡូនិក ៤:១៣-១៧)។

អស់ដែលឈរនៅចំពោះ បល្ល័ង្កសដ៏ធំអស្ចារ្យ នឹងត្រូវបានវិនិច្ឆ័យ ដោយផ្អែកលើកិច្ចការដែលគេធ្វើ និង ថាតើឈ្មោះរបស់គេមាននៅក្នុងសៀវភៅនៃជីវិតដែរឬអត់។ នៅពេលដែលការវិនិច្ឆ័យចាប់ផ្តើម នឹងមានការពិនិត្យឡើងវិញនូវកិច្ចការរបស់មនុស្សម្នាក់ៗ។ បន្ទាប់មកនឹងមានការពិនិត្យពិច័យ ដើម្បីដឹងថាតើឈ្មោះរបស់គាត់គឺមាននៅក្នុងសៀវភៅនៃជីវិតឬទេ។ ដោយសារតែមនុស្សទាំងនេះបានស្លាប់ទៅទាំងដែលមិនបានទទួលសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ ឈ្មោះរបស់ពួកគេក៏នឹងមិនឃើញមាននៅក្នុងសៀវភៅនៃជីវិតដែរ។ បន្ទាប់ពីនោះ បើយោងទៅតាមយុត្តិធម៌ដ៏ល្អឥតខ្ចោះ អ្នកមិនជឿម្នាក់ៗ នឹងត្រូវទទួលការដាក់ទោសឲ្យជាប់ឃុំឃាំងអស់កល្បជានិច្ច នៅក្នុងបឹងភ្លើង។ ការបោះបង់នេះ គឺមិនត្រឹមតែទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ចនោះទេ ប៉ុន្តែក៏ទៅក្នុងកន្លែងងងឹតអន្ធកា និង គួរឲ្យរន្ធត់ផងដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលអំពីការដ៏គួរឲ្យរន្ធត់នេះ ហើយទ្រង់ថែមទាំងបានបង្ហាញថា វានឹងធ្វើឲ្យមនុស្សសម្រក់ទឹកភ្នែក និង សង្កៀតធ្មេញរបស់ពួកគេ (គម្ពីរម៉ាថាយ៨:១២; ១៣:៤២; ២២:១៣; ២៤:៥១; ២៥:៣០)។ ក្រោយមកទៀត តាមរបៀបនេះ ព្រះជាម្ចាស់បញ្ចប់ការអាក្រក់ ហើយលុបវាចោលជារៀងរហូត។

លំហាត់អនុវត្តន៍

---

១៦ ចូរបំពេញប្រយោគខាងក្រោម៖

ក) មូលហេតុដែលសាតាំងនឹងត្រូវបានដោះលែងមួយរយៈពេលខ្លី បន្ទាប់ពីរយៈពេលមួយសហស្សវត្សរ៍ នោះគឺដើម្បី.....

ខ) គោលបំណងនៃការវិនិច្ឆ័យពីបល្ល័ង្កពណ៌សដ៏ធំអស្ចារ្យ គឺដើម្បី.....

ច. ការបង្កើតថ្មី

វគ្គបំណែងទី៧. *ប្រាប់ពីមូលដ្ឋានគ្រឹះដែលអ្នករំពឹងទុកថាជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់បានបង្កើតឡើង។*

លោកសាវ័កពេត្រុសបានលើកឡើងនៅក្នុងសំណេររបស់លោកថា អ្វីៗនឹងត្រូវបានឆេះឡើង។ វាហាក់បីដូចជាផែនដីនឹងត្រូវបានឆ្លងកាត់ការកែតម្រូវ (ផ្លាស់ប្តូរ ឬ ធ្វើឲ្យថ្មីឡើង) ដោយសារភ្លើង (គម្ពីរអេសាយ ៦៥:១៧ គម្ពីរ២ពេត្រុស ៣:៧)។ ទោះជាយ៉ាងណា លោកសាវ័កបាននិយាយថា ក្រោយពីភាពចលាចលខ្លាំងនេះហើយ យើងនឹងទន្ទឹងរងចាំ " ផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលមានសុទ្ធតែសេចក្តីសុចរិតវិញ។ (គម្ពីរ២ពេត្រុស ៣:១០-១៣ គម្ពីរពេគប)។ ដូច្នេះហើយ ព្រះជាម្ចាស់នឹង នាំប្រជាជនស្មោះត្រង់របស់ទ្រង់ទៅក្នុងស្ថានព្រះហស្តដ៏មានសិរីរុងរឿង និង ស្ថិតស្ថេរអស់កល្បជានិច្ច។

នៅក្នុងអំឡុងពេលមួយសហស្សវត្សរ៍ ដែលជាយុគសម័យដ៏ល្អឯក អ្នកជឿនឹងឈានឆ្ពោះទៅផុតយុគសម័យនេះ ចូលទៅក្នុងយុគសម័យថ្មីមួយដែលព្រះជាម្ចាស់គឺជាអ្វីៗគ្រប់ទាំងអស់។ នៅក្នុងការបង្កើតថ្មីនេះ ព្រះជាម្ចាស់នឹងសង់ដំណាក់របស់ទ្រង់នៅលើផែនដី។ ទីក្រុងដែលទ្រង់បានរៀបចំគឺល្អហួសការថ្លែង (គម្ពីរ១កូរិនថូស ២:៩-១០) ទីក្រុងនោះ ល្អស្អាតលើសអ្វីៗគ្រប់យ៉ាងដែលយើងធ្លាប់ឃើញពីមុនមក (គម្ពីរវិវរណៈ ជំពូក២១-២២)។

ជីវិតអស់កល្បជានិច្ចដែលមនុស្សបានយល់ឃើញ គឺមិនមែនជាអ្វីដែលគ្មានការផ្លាស់ប្តូរ ឬប្រែប្រួលនោះទេ ហើយព្រះជាម្ចាស់ផ្ទាល់ ទ្រង់ក៏មិនឈប់សម្រាក នៅពេលដែលផែនការរបស់ទ្រង់បានសម្រេចនោះដែរ។ ទ្រង់គឺជាព្រះជាម្ចាស់ដែលមានព្រះជន្មរស់ ហើយយើងត្រូវតែបានដូចទ្រង់! ទ្រង់បានបង្កើតសាកលលោកដ៏ធំល្វឹងល្វើយ ដែលហាក់បីដូចជាបន្តការផ្លាស់ប្តូរហូតតទៅ។ ឥឡូវនេះយើងឃើញពីការនេះព្រាលៗប៉ុណ្ណោះ តែនៅក្នុងយុគសម័យក្រោយៗទៀត យើងនឹងមានពេលរហូតតទៅ ក្នុងការយល់ដឹងពីការអស្ចារ្យនៃ ស្នាព្រះហស្តជាបន្តបន្ទាប់របស់ទ្រង់ (គម្ពីរ១កូរិនថូស ១៣:១២)។ យើងនឹងអាចរួមច្រៀងជាមួយមនុស្សជំនាន់មុន ជុំវិញរាជបល្ល័ង្កនៅពេលដែលពួកគេច្រៀងថ្វាយការសរសើរទៅកាន់ព្រះជាម្ចាស់នៃយើង៖ "បពិត្រព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ព្រះអង្គសមនឹងទទួលសិរីរុងរឿង ព្រះកិត្តិនាម និងឫទ្ធានុភាព ដ្បិតព្រះអង្គបានបង្កើតរបស់សព្វសារពើមក អ្វីៗទាំងអស់សុទ្ធតែកើតមាន ហើយនៅស្ថិតស្ថេរដោយសារព្រះហឫទ័យរបស់ព្រះអង្គ"។ (គម្ពីរវិវរណៈ ៤:១១)។

យើងត្រូវត្រឡប់ទៅមើលប្រវត្តិសាស្ត្រដែលបានលាតត្រដាង តាំងពេលដែលទេវតាបាននិយាយថាព្រះយេស៊ូនឹងយាងមកម្តងទៀត (គម្ពីរកិច្ចការ ១:១១)។ មានរឿងជាច្រើនបានកើតឡើង! មានបទទំនាយជាច្រើន បានកើតឡើងមានពិត។ មានព្រឹត្តិការណ៍ជាច្រើនបានរុញច្រានយើង ឲ្យបានមកដល់ពេលដែលយើងកំពុងតែឈរនេះ៖ "*គឺយើងឈរនៅលើដំណាក់កាលចុងក្រោយបំផុត នៃផែនការរបស់ព្រះជាម្ចាស់*"។ យើងមានអំណរ ដ្បិតយើងខិតជិតដល់ថ្ងៃនៃការប្រោសលោះចុងក្រោយហើយ។ យើងត្រូវចងចាំជានិច្ចថា ការបង្កើតថ្មីកំពុងតែរងចាំពួកយើង ជាមួយនឹងព្រះយេស៊ូជាស្តេចរបស់យើង! ព្រះយេស៊ូបានមានព្រះបន្ទូលថា " ចូរស្តាប់ យើងនឹងមកដល់ក្នុងពេលឆាប់ៗ អ្នកណាប្រតិបត្តិតាមសេចក្តីដែលមានថ្លែងទុកក្នុង

សៀវភៅនេះ អ្នកនោះមានសុភមង្គលហើយ!” (គម្ពីរវិវរណៈ ២២:៧) ។ បន្ទាប់មកយើងរាល់គ្នា ដែលជាផលនៃការប្រោសលោះរបស់ព្រះអម្ចាស់ ទូលតបថា៖ “អាម៉ែន ។ សូមព្រះអម្ចាស់យេស៊ូយាងមក!”

លំហាត់អនុវត្តន៍

១៧ ចូរពិនិត្យមើលខ្លួនឯង នៅពេលដែលយើងបញ្ចប់មេរៀននេះ ហើយសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នកនូវគោលជំហរដែលអ្នករំពឹងទុកថាបានក្លាយជាទិដ្ឋភាពមួយនៃការបង្កើតថ្មីដែលព្រះជាម្ចាស់នឹងបង្កើតឡើង (សូមមើលនៅក្នុងគម្ពីរវិវរណៈ ២២:១២-១៧)។

នៅពេលដែលយើងបញ្ចប់ការសិក្សានេះ យើងត្រូវតែចងចាំនៅក្នុងចិត្តថា ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពិតជាមានតម្លៃខាងឯក្រមសីលធម៌មួយមែន ជាពិសេសនៅក្នុងព្រះបន្ទូលអំពីបទទំនាយ៖

> កូនចៅជាទីស្រឡាញ់អើយ! ពេលនេះ យើងទាំងអស់គ្នាជាបុត្ររបស់ព្រះជាម្ចាស់ ហើយដែលយើងនឹងទៅជាយ៉ាងណាៗនោះព្រះអង្គពុំទាន់សំដែងអោយយើងដឹងនៅឡើយទេ។ ប៉ុន្តែ នៅពេលព្រះគ្រិស្តយាងមកដល់ យើងនឹងបានដូចព្រះអង្គដែរ ដ្បិតព្រះអង្គមានភាពយ៉ាងណា យើងនឹងឃើញព្រះអង្គយ៉ាងនោះ។ អ្នកណាមានសេចក្តីសង្ឃឹមលើព្រះអង្គបែបនេះ អ្នកនោះបានជំរះខ្លួនអោយបរិសុទ្ធ* ដូចព្រះអង្គបរិសុទ្ធដែរ។ (គម្ពីរ១យ៉ូហាន៣:២-៣)

ការប្រឡងផ្ចាល់ខ្លួន

ត្រូវ- ខុស។ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ប្រសិនបើប្រយោគនោះជាចម្លើយត្រឹមត្រូវ។ សរសេរអក្សរ ខ ប្រសិនបើប្រយោគខុស។

.....១ ព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅលើផែនដី បន្ទាប់ពីមានការឆក់យកឡើងទៅ គេហៅថា៖ "ព្រះពរនៃក្តីសង្ឃឹម" ។

.....២ ការឆក់យកឡើងទៅ និង ការលើកសម្តែងរបស់ព្រះគ្រិស្ត គឺជាព្រឹត្តិការណ៍ពីរដាច់ដោយឡែកពីគ្នា ។ នៅក្នុងការយាងមកលើកទីមួយ ទ្រង់យាងមក*ដើម្បី*មនុស្ស របស់ទ្រង់ ហើយនៅក្នុងការយាងមកជាលើកទីពីរ ពួកមនុស្សទាំងនោះនឹងយាងមក*ជាមួយ*ទ្រង់ ដែរ

.....៣ ថ្ងៃ និង ម៉ោងដែលព្រះយេស៊ូនឹងយាងមក អាចធ្វើការកំណត់បានដោយសិក្សា ការរាប់រៀបអំពីបញ្ហើនីមួយៗមានវត្ថុ "៧" នៅក្នុងគម្ពីរដានីយ៉ែលជំពូក ៩។

.....៤ អ្នកជឿទាំងមនុស្សស្លាប់ និង មនុស្សរស់ សុទ្ធតែត្រូវបានរាប់បញ្ចូលទៅក្នុងការឆក់យកឡើងទៅ។

.....៥ ព្រះគម្ពីរបានបង្ហាញថា នឹងមានកម្រិតនៃរង្វាន់សម្រាប់អ្នកជឿគ្រប់គ្នា។

.....៦ បទទំនាយភាគច្រើននៅក្នុងគម្ពីរដានីយ៉ែលជំពូក៩ គឺបានសម្រេចរួចទៅហើយ។

.....៧ *ព្រះអង្គដែលគេចាក់ប្រេងអភិសេកដែលត្រូវគេធ្វើគុត* គឺនិយាយសំដៅទៅអ្នកប្រឆាំងនឹងព្រះគ្រិស្ត។

.....៨ គ្រាមហាវេទនា នឹងមានរយៈពេលប្រាំពីរឆ្នាំ ហើយបានពាក់កណ្តាលរយៈពេលប្រាំឆ្នាំនេះ អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងក្បត់សន្យាដែលគេធ្វើជាមួយពួកយូដា។

.....៩ អ៊ីស្រាអែលត្រូវបានខ្ចាត់ខ្ចាយចេញពីទឹកដីសន្យាដោយព្រោះតែការមិនស្តាប់បង្គាប់។

.....១០ ការកើតជាថ្មីរបស់សាសន៍អ៊ីស្រាអែល នៅខែឧសភាក្នុងឆ្នាំ១៩៤៨ គឺជាការបំពេញតាមបទទំនាយមួយ។

.....១១ អ្នកប្រឆាំងនឹងព្រះគ្រិស្តនឹងនាំយកសន្តិភាពយ៉ាងមានស្ថេរភាពមកឲ្យពិភពលោក ក្នុងរយៈពេល១០០០ឆ្នាំ។

.....១២ មានតែប្រជាជនយូដាតែប៉ុណ្ណោះដែលនឹង តម្រូវឲ្យមានសញ្ញាសំគាល់របស់អ្នកប្រឆាំងនឹងព្រះគ្រិស្ត ដើម្បីឲ្យពួកគេអាចធ្វើមុខជំនួញបាន។

.....១៣ អើម៉ាគេដូន នឹងក្លាយទៅសមរភូមិដ៏គួរឲ្យខ្លាចមួយ រវាងសាសន៍យូដា និង សត្រូវរបស់គេ ដែលក្នុងសមរភូមិនោះ ក្រុងយេរូសាឡឹមនឹង ប្រជាជនក្នុងនោះនឹងត្រូវបំផ្លាញ។

.....១៤ ការលើកសម្តែងរបស់ព្រះយេស៊ូគ្រិស្តនឹងកើតឡើង នៅពេលដែលមានការបៀតបៀនពួកយូដា និង ការមិនគោរពកោតខ្លាចព្រះជាម្ចាស់របស់មនុស្សលោក ឈានដល់កម្រិតធ្ងន់ធ្ងរមួយ។

.....១៥ នៅក្នុងការលើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត មនុស្សទទឹងច្បាប់ និង ទ័ពរបស់គេ នឹង ចាញ់សង្គ្រាម ហើយព្រះយេស៊ូនឹងត្រូវបានលើកសម្តែងជាស្តេចលើអស់ទាំងស្តេច និង ជាព្រះអម្ចាស់លើអស់ទាំងអម្ចាស់។

ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៩ ក) ការនិរទេសរបស់ពួកយូដាអស់រយៈពេល៧០ឆ្នាំ គឺដោយសារតែការមិនស្តាប់បង្គាប់។
ខ) ការជួសជុល និង ការសាងសង់ក្រុងយេរូសាឡឹមឡើងវិញ គឺកើតឡើងក្រោយការជាប់ជាទាសកររយៈពេល៧០ឆ្នាំ។
គ) ការយាងមកបស់លោកដែលគេចាក់ប្រេងអភិសេក។
ង) ការសម្លាប់លោកដែលគេចាក់ប្រេងអភិសេក។
ច) មនុស្សរបស់ស្តេចដែលកំពុងយាងមក កំទេចទីក្រុងដ៏វិសុទ្ធ និង ព្រះវិហារ។
ឆ) ទីបញ្ចប់ជាអធិបតេយ្យភាព របស់សាសន៍យូដា។
ជ) បទទំនាយនៅក្នុងគម្ពីរអេម៉ុស ៩ ដែលប្រាប់ថាប្រទេសអ៊ីស្រាអែល នឹងត្រូវបានស្រោចស្រងឡើងវិញម្តងទៀត ហើយប្រជារាស្ត្រគេនឹងត្រឡប់មកធ្វើចំការ និង ដាំទំពាំងបាយជូរម្តងទៀត។

១ ខ) ការឆក់យកអ្នកជឿឡើងទៅ នៅពេលដែលព្រះគ្រិស្តយាងមក សម្រាប់ពួកគេ។

១០ ក), ខ), ឃ), ឆ), ជ) និង ញ) ជាចម្លើយត្រឹមត្រូវ។

២ ការយាងត្រឡប់មកវិញរបស់ទ្រង់នឹង មកដល់មិនយូរប៉ុន្មានក្រោយពេលដំណឹងល្អ ត្រូវបានចែកចាយទៅកាន់ពិភពលោកទាំងមូល។ គ្មាននរណាម្នាក់ដឹងថាថ្ងៃណា ឬ ម៉ោងណានោះទេ។

១១ ខ) នាំមកនូវការវិនិច្ឆ័យចុងក្រោយ ដល់មនុស្សមានបាបទាំងឡាយណាដែលបដិសេធមិនទទួលយកទ្រង់។

៣ ក) មនុស្សស្លាប់ , មនុស្សរស់
ខ) ព្រះបន្ទូលរបស់ព្រះអម្ចាស់ផ្ទាល់
គ) សេចក្តីសង្ឃឹម

១២ ការមិនគោរពកោតខ្លាចព្រះជាម្ចាស់ ឬ ភាពពេញដោយបាប និង ភាពអាត្មានិយមជាច្រើនរបស់មនុស្សជាតិ ព្រមទាំងការបៀតបៀនយ៉ាងខ្លាំងទៅលើសាសន៍អ៊ីស្រាអែល។

៤ មនុស្សទាំងពីរប្រភេទនេះ នឹងទទួលបានរូបកាយថ្មីប្រកបដោយសិរីរុងរឿង ដែលមិនចេះស្លាប់ និង មិនចេះរលាយសាបសូន្យ។

១៣ សាតាំង និង កងទ័ពរបស់វា នឹងត្រូវដកចេញពីការកាន់អំណាច និង ត្រូវបោះចូលទៅក្នុងបឹងភ្លើង។ ព្រះយេស៊ូនឹងឡើងគ្រង់ដំណែងពេញសិទ្ធិរបស់ទ្រង់ ក្នុងនាមជាស្តេចលើអស់ទាំងស្តេច និង ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។

៥ គ) ទទួលបានរង្វាន់មួយដែលផ្អែកលើបំណងចិត្ត ឬ គុណភាពនៃការបម្រើរបស់គេ។

១៤ ខ) ដើម្បីបំពេញតាមបទទំនាយដែលទាក់ទងនឹងកូនចៅជំនាន់ក្រោយរបស់ស្តេចដាវីឌ។
គ) ដើម្បីការពារសិរីរុងរឿងរបស់ព្រះជាម្ចាស់ និង សម្រេចឲ្យបានថាមាគ៌ារបស់ទ្រង់គឺជាមាគ៌ាដ៏ពិត និង ត្រឹមត្រូវតែមួយគត់។

៦ ក) ជារូបកាយមិនចេះស្លាប់ មិនចេះរលាយសាបសូន្យ ដែលត្រូវជំនួសរូបកាយខាងឯសាច់ឈាម នៅក្នុងពេលនៃការឆក់យកឡើងទៅ។

ខ) នៅពេលដែលព្រះយេស៊ូយាងត្រឡប់មកជាមួយមនុស្សរបស់ទ្រង់ ដើម្បីបង្កើតព្រះរាជ្យរបស់ទ្រង់។

គ) នៅពេលដែលព្រះយេស៊ូយាងមកដើម្បីមនុស្សរបស់ទ្រង់៖ អ្នកស្លាប់នៅក្នុងព្រះគ្រិស្តនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញជាមុនសិន បន្ទាប់មកអ្នកជឿដែលកំពុងមានជីវិតរស់ នឹងត្រូវបានលើកឡើងទៅគាល់ទ្រង់នៅលើអាកាស។

ឃ) ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត (ការឆក់អ្នកជឿឡើងទៅ)។

ង) "ទីកាត់ក្តី" ដែលព្រះយេស៊ូនឹងវិនិច្ឆ័យកិច្ចការរបស់អ្នកជឿ ហើយនឹងមានការប្រទានរង្វាន់ដោយផ្អែកលើគុណភាពនៃជីវិត និង ការបម្រើក្នុងនាមជាគ្រិស្តបរិស័ទរបស់ពួកគេ។

១៥ ក) សត្វទាំងអស់នឹងរស់នៅជាមួយគ្នា ប្រកបដោយសន្តិភាព។

ខ) នឹងត្រូវបានគេស្តាប់បង្គាប់ ហើយនឹងមានការវិនិច្ឆ័យ និង យុត្តិធម៌ដ៏ល្អឥតខ្ចោះ។

គ) ផែនដី

ឃ) នឹងគ្រងរាជ្យជាមួយព្រះគ្រិស្ត

ង) នឹងបម្រើការជាអនុប្រឹក្សាភិបាល របស់ព្រះគ្រិស្ត

ច) នឹងស្ថិតនៅក្រោមអំណាច របស់ស្តេចនៃស្ថានបរមសុខ

ឆ) នឹងត្រូវទទួលបានការចាប់អារម្មណ៍ និង ធ្វើការសិក្សា

ជ) នឹងបានពេញបរិបូរណ៌

៧ ក) រយៈពេលដែលពួកយូដាមិនបានប្រតិបត្តិតាម ឆ្នាំសប្ប័ទរបស់ពួកគេ។

១៦ ក) ដើម្បីផ្តល់ឲ្យមនុស្សដែលរស់នៅលើផែនដី នូវឱកាសក្នុងការ សម្រេចចិត្តជ្រើសរើសយកព្រះជាម្ចាស់ ឬ ទាស់ប្រឆាំងនឹងទ្រង់។

ខ) ធ្វើឲ្យមានការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ទៅលើមនុស្សអាក្រក់ ដោយផ្អែកលើ ថាតើឈ្មោះរបស់ពួកគេ មានសរសេរចុះនៅក្នុងសៀវភៅនៃជីវិតឬអត់។

៨ ការបំផ្លាញព្រះវិហារ នៅក្នុងឆ្នាំ៧០ គ.ស។

១៧ ចម្លើយរបស់អ្នក។ ការបង្កើតថ្មីគឺសម្រាប់អស់អ្នកដែលទទួលស្គាល់ព្រះយេស៊ូជាព្រះអម្ចាស់នៃជីវិតរបស់ពួកគេ ដែលមានឈ្មោះកត់ទុកក្នុងសៀវភៅនៃជីវិត នឹងទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់។

សូមចូលរួមអបអរសាទរ

ឥឡូវនេះអ្នកបានបញ្ចប់មេរៀននៅក្នុងជំពូកចប់សព្វគ្រប់ហើយ។ យើងសង្ឃឹមថាវាជាជំនួយ ដ៏ល្អ សម្រាប់អ្នក។ ចូររំឭកមេរៀនទាំងអស់នៅក្នុងជំពូកទី៣ ហើយធ្វើ*ការវាយប្រឡងជំពូកទីបីនេះ*។

អក្ខរានុក្រម

នៅក្នុងប្រអប់ជួរឈរដែលនៅខាងស្តាំដៃមានផ្តុំកលេខមេរៀននៅក្នុងសៀវភៅសិក្សាដោយខ្លួនឯងនេះ ដែលពាក្យនោះត្រូវបានយកមកប្រើដំបូងគេបង្អស់

ពាក្យគន្លឹះ	និយមន័យ	មេរៀន
ការកសាងឡើង edification	សកម្ម ឬ ដំណើរការនៃការណែនាំ ឬ ធ្វើឲ្យរីកចម្រើនខាងឯវិញ្ញាណ ការកសាងឡើង	៩
ការកែលំអ renovation	សភាពមួយដែលត្រូវបានជួយឲ្យមានជីវិតឡើងវិញ ឬ ជួលជុលឲ្យមានសភាពល្អប្រសើរឡើងវិញ	១០
ការចេញថ្លៃជួស atoned	ការសងឲ្យសមនឹងការធ្វើខុស ការបាត់បង់ ឬ របួស	៧
ការចាប់បដិសន្ធិ incarnation	ព្រះដែលបានមកចាប់យកទម្រង់ជាមនុស្ស ការរួបរួមរវាងនិស្ស័យជាព្រះ និង និស្ស័យជាមនុស្សរបស់ព្រះយេស៊ូ	៣
ការបណ្តាលចិត្ត inspiration	ឥទ្ធិពលរបស់ព្រះជាម្ចាស់	៨
ការបង្កើតឡើងវិញ regeneration	ការកើតឡើងវិញខាងឯវិញ្ញាណ ការទទួលបាននៅក្នុងជីវិតខាងឯវិញ្ញាណថ្មី និង ប្រសើរជាងមុន	៤
ការបើកសម្តែង revelation	ការលាតត្រដាងរបស់ព្រះជាម្ចាស់អំពីអង្គទ្រង់ និង បំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ស្នាព្រះហស្តរបស់ទ្រង់	៨
ការបំភ្លឺ illumination	ការធ្វើឲ្យច្បាស់ ការបកស្រាយ ការយល់ដឹង	៤
ការបំភ្លឺឲ្យច្បាស់ enlightening	ការប្រាប់ ការណែនាំ ការផ្តល់នូវសេចក្តីពិត និង ចំណេះដឹង	៤

ការបះបោរ rebellion	ការតតាំង ឬ ប្រឆាំងទាស់នឹងអំណាច ឬ ការគាប់សង្កត់ កុប្បកម្ម	៥
ការបែកខ្ញែក dispersion	សកម្ម ឬ ដំណើរការ នៃការខ្ចាត់ខ្ចាយ បែកបាក់ ឬ ពង្រាយ	១០
ការបំពេញ consummation	ការនាំមកនូវភាពឥតខ្ចោះ ឬ ភាពពេញលេញ	១០
ការប្រឈមមុខ confrontation	ការជួបមុខទាល់នឹងមុខជាមួយនឹងកម្លាំងដែលផ្ទុយ	១០
ការប្រមាថ blasphemy	ពាក្យសំដីអាក្រក់ ឬ មិនគោរពចំពោះព្រះជាម្ចាស់ និង វត្ថុសក្ការៈ	១០
ការប្រោសលោះ redemption	សកម្មភាពនៃការទិញត្រឡប់មកវិញ ឬ ជួយសង្គ្រោះជីវិត	៣
ការបំផុស challenge	អ្វីដែលដាស់ឲ្យមានចំណាប់អារម្មណ៍ គំនិត ឬ សកម្មភាពប្រជែង	៩
ការបំពុល pollution	ភាពមិនស្អាតស្អំ ដែលមិនបរិសុទ្ធ ឬ កខ្វក់	៧
ការផុតពូជ extinction	សកម្ម ឬ ដំណើរការនៃការបញ្ចប់ ឬ លុបចេញពីអត្ថិភាព	១០
ការពិសោធន៍មើល probation	ការល្បងល ឬ ការសាកល្បង ឥរិយាបថ លក្ខណសម្បត្តិ ឬ គុណសម្បត្តិ	៥
ការជ្រមុជ immersion	ការជ្រមុជទឹកដោយដាក់ខ្លួនក្នុងទឹកទាំងស្រុង (នៅក្នុងទឹក) ត្រូវបានគ្របដណ្តប់ជិត	៤
ការថែរក្សា maintenance	ការជួសជុលឲ្យល្អជានិច្ច ការរក្សានៅក្នុងអត្ថិភាព ឬ បន្តទៅមុខ ការគាំពារ ឬ លើកកំពស់	២
ការយល់ស្រប concurrence	ការព្រមព្រៀង ការប្រកាន់គំនិតតែមួយ ការធ្វើការរួមគ្នា ការប្រតិបត្តិរួមគ្នា	២

ការរក្សាទុក preservation	ការរក្សាមិនឲ្យរលួយ ឬ របួស ការរក្សាសុវត្ថិភាព	២
ការរសាយចិត្ត frustrate	រារាំងពីការធ្វើឲ្យសម្រេចអ្វីមួយ មិនឲ្យទទួលបានអ្វីទាំងអស់ ធ្វើឲ្យឥតប្រយោជន៏ ឬ គ្មានតម្លៃ	៧
ការរួបរួម unity	ភាពតែមួយ ឯកភាព	១
ការរំដោះបាប atonement	ការផ្សះផ្សាររបស់ព្រះជាម្ចាស់ជាមួយនឹងអ្នកមានបាប តាមរយៈការរងទុក្ខ និង ការសុគតរបស់ព្រះគ្រិស្ត	២
ការលើកទឹកចិត្ត motivation	ដំណើរការនៃការគិត ឬ អារម្មណ៍ដែលនាំឲ្យនរណាម្នាក់ធ្វើសកម្មភាពអ្វីមួយ	៤
ការលាតត្រដាង disclosure	ដែលធ្វើឲ្យដឹង ឬ បង្ហាញឲ្យដឹង	៨
ការលើកឡើង elevating	ការលើកឲ្យខ្ពស់លើសទីតាំងធម្មតា ការលើកតំណែង ឬ ឋានៈ ការលើកគុណភាព	៨
ការលើកឡើងទៅស្ថានសួគ៌ ascension	ការក្រោក ឬ ធ្វើដំណើរឡើងទៅលើ	៣
ការសម្តែងបង្ហាញ manifestations	របស់ដែលបង្ហាញ ឬ លាតត្រដាងយ៉ាងច្បាស់	១
ការសម្របសម្រួល compromise	លះបង់ទិដ្ឋភាពមួយនៃអ្វីដែលមនុស្សម្នាក់ជឿ	២
ការស្តារឡើងវិញ restoration	ការធ្វើឲ្យមានស្ថានភាពដូចពីមុន	៧
ការអនុញ្ញាត enablement	អំណាច គុណភាព ឬ មធ្យោបាយដើម្បីធ្វើអ្វីម្យ៉ាង	៤
ការអន្តរាគមន៍ intervention	ការមកជ្រៀតជ្រែក ការមកចន្លោះកណ្តាលឬ និយាយជួសមុខឲ្យនរណាម្នាក់	៥

ក្លែងខ្លួន impersonate	ធ្វើពុតជា , សំដែងជាតួ	៥
ក្លែងបន្លំ counterfeit	ការចម្លងតាមដើម្បីបោកប្រាស់ មិនពិត លាក់ពុត	៧
កំពូល supreme	ហាន: អស្ចារ្យជាងគេ ឬសិទ្ធិអំណាចខ្ពស់ជាងគេ	២
កំពូលមនុស្ស superhuman	ដែលលើស ឬ ផុតអំណាច ឬបទពិសោធន៍មនុស្ស ធម្មតា	៥
កំណាច diabolical	ព្រៃផ្សៃ ឬអាក្រក់ខ្លាំង ពួកទុច្ចរិត អាក្រក់ មានជាប់ទាក់ទងទៅនឹងអារក្ស និង កិច្ចការអាក្រក់របស់អារក្ស	៥
ខុសឆ្គង distorted	បំភ្លឺការពិត សំដែងខុស កាច់ពត់ឲ្យខុសទ្រង់ទ្រាយ (ដូចជាការយល់ឃើញ ឬ គំនិតខុសឆ្គង)	៨
ខ្ជាប់ខ្ជួន immutable	មិនផ្លាស់ប្តូរ មិនអាចផ្លាស់ប្តូរបាន	១
ខ្សែស្រឡាយ Lineage ancestry	ពូជពង្សនៅក្នុងខ្សែលោហិតដូនតាដូចគ្នា កូនចៅជំនាន់ក្រោយរបស់ដូនតាដូចគ្នា ខ្សែគ្រួសារ	៣
គុណលក្ខណៈ attributes	ជាគុណសម្បត្តិដែលចាត់ទុកថាជារបស់បុគ្គល ឬ វត្ថុណាមួយ លក្ខណសម្បត្តិ	១០
គួរឲ្យស្អប់ខ្ពើម abominable	គួរឲ្យស្អប់ខ្ពើម៖ ធ្វើឲ្យមានការមិនចូលចិត្តខ្លាំង, គួរឲ្យខ្ពើមរអើម, ការប្រមាថ៖ មិនគោរពវត្ថុសក្ការៈ នៅគ្រាមានទុក្ខវេទនា ការបំពានដ៏គួរឲ្យស្អប់ និង ដ៏អាក្រក់បំផុតនៅក្នុងព្រះដំណាក់របស់ព្រះជាម្ចាស់។	១០
គោលលទ្ធិ doctrine	អ្វីដែលបានបង្រៀនទុកជាការពិត ជំនឿ សេចក្តីពិតដែលមានចែងនៅក្នុងព្រះគម្ពីរ	៨
គ្រឿងបណ្តុំ(សមាសភាគ) components	ទិដ្ឋភាពទាំងអស់ដែលបង្កើតបានជារបស់មួយពេញលេញ	៤

ចម្លែក extraordinary	ប្លែកពីធម្មតា មិនធម្មតាឬ គួរឲ្យកត់សំគាល់ខ្លាំង	៣
ចូលរួម corporate	បង្កើតបានជាខ្លួនមួយ សហព័ន្ធ បូកចូលគ្នា	៤
ឆ្នាំសប្ប័ទ Sabbath Year (sabbatical year)	ការសម្រាកមួយឆ្នាំសម្រាប់ដី ដែលប្រតិបត្តិរៀងរាល់ឆ្នាំទីប្រាំពីរ នៅក្នុងសាសន៍យូដាសម័យបុរាណ	១០
ឆ្អែត ផ្សៀមជោក saturate	បំពេញឲ្យអស់ពីសមត្ថភាព	៤
ជម្រះទោស vindicated	សងសឹក បញ្ជាក់ថាពិត ឬ ត្រឹមត្រូវ	១០
ជាសាកល universal	សម្រាប់មនុស្សទាំងអស់គ្រប់ទីកន្លែង	៩
ជីវិតដែលអាចស្លាប់ mortal	អាយុជីវិតមានកំណត់ ប្រាកដជាស្លាប់នៅក្នុងពេលណាមួយ	៣
ជោគវាសនា destiny	អំណាចដែលគេជឿថា ជាអ្នកកំណត់ហេតុការណ៍ អ្វីដែលនឹងកើតឡើងទោះបីជាមានការខិតខំប្រឹងប្រែងរារាំងយ៉ាងណាក៏ដោយ។	៥
ដាក់បញ្ញត្តិ prescribe	ដាក់វិន័យដើម្បីឲ្យធ្វើតាម បញ្ជា ប្រាប់ផ្លូវ ផ្តល់យោបល់	៤
ដើមកំណើត origin	ប្រភព ទីចាប់ផ្តើម របស់ដែលអ្វីម្យ៉ាងកើតចេញមកអំពី	៤
ដែលឆបោក deceptive	មានចេតនាធ្វើឲ្យវង្វេង រៀបរាប់អំពីអ្វីដែលមិនមែនជាការពិត	៧
ដែលជាសត្រូវ hostile	គ្មានមិត្តភាព ដែលប្រឆាំង	៧

ដែលមានមនសិការ conscientious	ធ្វើអ្វីមួយដែលខ្លួនដឹងថាជារឿងត្រឹមត្រូវ យ៉ាងយកចិត្តទុកដាក់	៦
ដែលមានសារៈសំខាន់ substantial	មានសារធាតុ ឬ ខ្លឹមសារ	១
ដែលមិនវិនាស imperishable	មិនចេះពុកផុយ មិនអាចធ្វើឲ្យពុកផុយ	១០
ដែលអាចវិនាស perishable	អាចនឹង ឬ រងនូវការផុយរលួយ	១០
ដោយសិទ្ធិអំណាច authoritative	បែបផ្លូវការ មានសិទ្ធិអំណាចពីចំណេះដឹងរបស់អ្នកជំនាញ ផ្តល់សិទ្ធិឲ្យគេស្តាប់បង្គាប់ ឬ គោរពតាម	៨
ដោយឡែក distinct	មិនដូចគ្នា ដាច់ចេញពីគ្នា ខុសគុណភាព និង ប្រភេទ	១
ដែលអាចទុកចិត្តបាន reliable	ស័ក្តិសមទទួលការជឿទុកចិត្ត អាចពឹងផ្អែកបាន	៨
តួនាទី functions	បំពេញហាន: ឬ កាតព្វកិច្ច ធ្វើការទទួលខុសត្រូវ	៩
ត្រាប់ imitate	ធ្វើតាមគំរូ ព្យាយាមឲ្យដូច	៧
ទំនាក់ទំនង relationship	សភាព ឬ លក្ខណ ដែលមានការតភ្ជាប់ ភាពជាបងប្អូន	៩
ទំនោរចិត្ត inclination	ការងាកទៅរកលក្ខណសម្បត្តិ ឬ ស្ថានភាពមួយ ការផ្ទៀងឆ្ពោះទៅរកអ្វីម្យ៉ាង	៧
ធ្វើឲ្យមានសុពលភាព validate	ការគាំទ្រថាមានសុវត្ថិភាព ឬ ពិតប្រាកដ ការផ្តល់នូវអំណាចស្របច្បាប់ដើម្បី បញ្ជាក់	៨
និរន្តរភាព (អនន្តភាព) eternity	រយៈពេលដែលគ្មានទីចាប់ផ្តើម និង ទីបញ្ចប់ ភាពគ្មានទីបំផុត	១

ឋានអាទិទេព celestial	មានទាក់ទងនឹងស្ថានសួគ៌ ជារបស់ ឬ ជាកម្មសិទ្ធិនៃស្ថានសួគ៌	៥
បង្កើត create	ធ្វើឲ្យកើតឡើង នាំឲ្យមានអត្ថិភាព	២
បច្ចាមិត្ត adversary	សត្រូវ អ្នកដែលទាស់ ឬ ប្រឆាំងជាមួយនរណាម្នាក់ទៀត	៥
បញ្ញាត្តិ ordinances	ការប្រតិបត្តិដែលបានបង្គាប់ឲ្យធ្វើតាម ពិធី ឬ ច្បាប់វិន័យ	៩
បញ្ជីកណ្ឌគម្ពីរ canon	តារាងបញ្ជីផ្លូវការនៃកណ្ឌគម្ពីរ ដែលទទួលស្គាល់ដោយក្រុមជំនុំគ្រិស្តបរិស័ទ ថាជារបស់ពិត និង ត្រូវបានជំរុញឲ្យសរសេរដោយព្រះវិញ្ញាណដ៏វិសុទ្ធ	៨
បុព្វបុរស ancestry	ខ្សែស្រឡាយនៃមនុស្សដែលមនុស្សម្នាក់ កើតបន្តមក	៣
បំភ្លឺ illumines	ធ្វើឲ្យភ្លឺ ឬ ច្បាស់	៨
បោះបង់ desolate	កិរិយាសព្ទ៖ ក្បត់ ធ្វើឲ្យខ្ទេចខ្ទាំ។ គុណនាម៖ សោះកក្រោះ គ្មានភាពរស់រវើក។	១០
ប្រពៃណីនិយាយតគ្នា oral traditions	ជំនឿ គំនិត ទំនៀម និង គោលិទ្ធ(សេចក្តីបង្រៀន) ដែលឪពុកម្តាយប្រាប់បន្តមកកូនចៅជំនាន់ក្រោយតាមរយៈការនិយាយ	៨
ផលវិបាក consequences	ចម្លើយ ឬ ឥទ្ធិពល លទ្ធផល	៦
ផ្សះផ្សា **reconcile**	នាំឲ្យមានមេត្រីភាពជាថ្មីឡើងវិញ រំងាប់អស់ភាពខុសគ្នា និង ភាពមិនចុះសម្រុងគ្នា	៣
ពិគ្រោះ deliberate	គិតទុកជាមុខយ៉ាងយកចិត្តទុកដាក់ រៀបចំទុកជាមុន ធ្វើឡើងដោយចេតនា	៧

ពិន័យ **penalty**	ការដាក់ទោសដែលធ្វើឡើងដោយច្បាប់	៣
ពេលកំណត់ time frame	អំឡុងពេលដែលកំណត់ដោយទីចាប់ផ្តើម និង ទីបញ្ចប់ នៃព្រឹត្តិការណ៍ជាក់លាក់ណាមួយ	១០
ព្រះត្រៃឯក Trinity	ភាពរួមគ្នានៃព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងលក្ខណជាព្រះជាម្ចាស់តែមួយ	១
ព្រះមហាក្សត្រ sovereign	ឋានៈ អ្នកគ្រប់គ្រងកំពូល ឬ តំណែងខ្ពស់ជាងគេ	១
ពហុភាព plurality	ចំនួនច្រើនជាង ភាគច្រើន មួយចំនួនធំ	៤
ពុករលួយ corrupt	អសីលធម៌ អំពើអាក្រក់ កំណាច	៧
ភាពជាព្រះ deity	និស្ស័យជាព្រះ ព្រះជាម្ចាស់	៣
ភាពទៀងត្រង់ **uprightness**	សភាពល្អ ស្មោះត្រង់ ភាពយុត្តិធម៌	២
ភាពបះបោរ rebelliousness	សភាព ឬ ស្ថានភាពដែលមានការតតាំង ឬ ការបះបោរ មិនស្តាប់បង្គាប់	៧
ភាពប្រហាក់ប្រហែលគ្នា resemblance	ភាពដូចគ្នា ភាពស្រដៀងគ្នាទិដ្ឋភាពខាងសំបកក្រៅ	៦
ភាពពិសេសតែមួយ uniqueness	លក្ខណៈមិនធម្មតា ឬ មានតែមួយប្រភេទ	១
ភាពផ្តាច់មុខ exclusiveness	ស្ថានភាពដែលមិនត្រូវបានបែងចែក ឬ រំលែកជាមួយអ្វីផ្សេង ជ្រើសរើសដោយប្រុងប្រយ័ត្ន។	៨
ភាពយុត្តិធម៌ justice	ភាពស្មើគ្នា ភាពត្រឹមត្រូវ ភាពស្របច្បាប់ ស័ក្តិសមនឹងទទួលរង្វាន់ ឬ ទោសទណ្ឌ	២

ភាពរស់រវើក dynamic	ប្រកបដោយកម្លាំងខ្លាំង មានថាមពល ទាក់ទង ជាមួយនឹងកម្លាំង និង ថាមពល	៩
ភាពវិសុទ្ធ holiness	គុណតម្លៃ ឬ ស្ថានភាពដែលមានដួងចិត្តបរិសុទ្ធ ឥត ខ្ចោះខាងឯវិញ្ញាណ សភាពលក្ខណៈពិសេសដាច់គេ និង ថ្វាយដាច់សម្រាប់ព្រះជាម្ចាស់	២
ភាពវិសេស distinctions	គុណភាព ឬ លក្ខណៈពិសេស ប្រសើរប្លែក	១
ភាពសាមញ្ញ simplicity	លក្ខណៈមួយដែលមិនមានការបែងចែកជាច្រើន ចំណែក	១
ភាពសុចរិត righteousness	ស្ថានភាពនៃការធ្វើត្រឹមត្រូវ ឬ បង្ហាញអាកប្បកិរិយា ត្រឹមត្រូវ	២
ភាពអមតៈ immortality	សភាពដែលនៅរស់ជារៀងរហូត	៦
ភ្នាក់ងារ agents	អ្នកដែលមានអំណាចធ្វើសកម្មជួស ឬ តំណាងឲ្យ នរណាម្នាក់	៥
មនសិការ conscience	អារម្មណ៍ដឹងខុស ដឹងត្រូវ គំនិត និង អារម្មណ៍នៅក្នុង មនុស្សម្នាក់ដែលប្រាប់គាត់អំពីអ្វីដែលខុសឆ្គង	៦
មនុស្សក្រោមបង្គាប់ subordinate	ឋានៈទាប ឬ មិនសូវសំខាន់	៦
មនុស្សជាតិ humanity	មនុស្ស, ពូជមនុស្ស	៣
មហន្តរាយ disastrous	ធ្វើឲ្យមានទុក្ខសោក និង ការបាត់បង់យ៉ាងច្រើន	៥
មិនចេះខុស(ដែលមិនភ្លាំងភ្លាត់) infallible	គ្មានកំហុស អាចទុកចិត្តបានទាំងស្រុង	៦

មិនស៊ីជម្រៅ superficial	នៅលើផ្ទៃខាងក្រៅ មិនពិតត្រង់	៤
រងឥទ្ធិពល subjected	ដាក់នៅក្រោមអំណាច ឬ ឥទ្ធិពល	៣
រនាំង barriers	របស់ដែលនៅបាំងផ្លូវ ខណ្ឌចែករបស់មួយចេញពីរបស់មួយទៀត	៩
រូបធាតុ matter	ធាតុដើមដែលមាននៅក្នុងលំហ មានទម្ងន់ និងអាចបង្ហាញលក្ខណៈជារឹង រាវ ឬ ឧស្ម័ន	១
លក្ខណៈរបស់ **ascribed**	ចាត់ទុកថាជារបស់នរណាម្នាក់ គិតថាមកពីនរណាម្នាក់ ឬ អ្វីមួយ	៤
លក្ខណៈវិសេសន៍ essence	អ្វីដែលបង្កើតបានជារបស់មួយ ទិដ្ឋភាពមួយឬច្រើនដែលចាំបាច់	១
លិខិត **epistles**	សំបុត្រ ជាទូទៅវែង និង ពេញដោយការណែនាំ	៨
លើកជាព្រះ deify	ធ្វើឲ្យក្លាយជាព្រះ បង្កើតវត្ថុសក្ការៈ	១០
វិវត្តន៍ evolve	អភិវឌ្ឍទៅមុខ ដោះស្រាយ លាតត្រដាង	៦
វិសមិតភាព(ភាពមិនស៊ីសង្វាក់គ្នា ភាពមិនប្រក្រតី) inconsistency	មិនអាចរក្សានូវគោលការណ៍ ឬ ទិសដៅសកម្មភាពឲ្យនៅដដែល	៨
វេទយិតភាព sensibility	សមត្ថភាពក្នុងទទួលអារម្មណ៍ បង្ហាញអារម្មណ៍	៤
សក្តានុពល potential	ការដែលអាចកើតឡើង សមត្ថភាពអាចលេចចេញជារូបរាង	៤

សង្គម social	តែងតែបង្កើតបានជាការសហប្រតិបត្តិការ ឬ មាន ទំនាក់ទំនងពឹងផ្អែកគ្នាទៅវិញទៅមក ជាមួយអ្នកដទៃ	៩
សន្មត់ assume	ទទួលយក យកដាក់ខ្លួន	៥
សព្វញ្ញុតញ្ញាណ omniscience	មានចំណេះដឹងគ្រប់យ៉ាង	១
សព្វត្ថិភាព(សព្វដ្ឋភាព សព្វវត្តមាន) omnipresence	មានវត្តមាននៅគ្រប់ទីកន្លែង	១
សព្វានុភាព omnipotence	មានអំណាចគ្រប់ទាំងអស់	១
សម្ភារ material	អ្វីដែលបង្កើតបានជារបស់មួយ ខាងសាច់ឈាម មិនមែនខាងឯវិញ្ញាណ	១
សមហេតុផល rational	ដែលមានហេតុផល អាចគិត និង មានអំណះអំណាងច្បាស់លាស់	៥
សរសើរតម្កើង glorified	លើកតម្កើងដល់សិរីរុងរឿងនៃស្ថានបរមសុខ	៥
សហគមន៍ community	ក្រុមមនុស្សដែលមានចំណាប់អារម្មណ៍ ឬ គោលដៅដូចគ្នា	៩
សារធាតុ substance	អ្វីដែលមាននៅក្នុងរបស់មួយ ទិដ្ឋភាពដែលពិត ចម្បង ឬសំខាន់របស់អ្វីមួយ	១
សីលធម៌ moral	ត្រឹមត្រូវ លក្ខណៈ ឬ ឥរិយាបថល្អ	២
សេចក្តីមេត្តាករុណា merciful	បង្ហាញពីចិត្តល្អ លើសពីការទាមទាររបស់យុត្តិធម៌	២

សំណេរអវសាននៃលោកីយ៍ apocalyptic	រៀបរាប់អំពីសំណេរមួយក្រុមដែលទស្សន៍ទាយអំពីព្រឹត្តិការណ៍នៃការបំផ្លាញពិភពលោក	៨
សំណេរដើម autographs	សំណៅដើមនៃសំណេរដែលមានក្នុងបញ្ជីកណ្ឌគម្ពីរ	៨
ស្មាក្តី advocate	អ្នកដែលការពារ ឬ និយាយជួសដើម្បីប្រយ័ត្នរបស់នរណាម្នាក់	៤
ស្មើភាពគ្នា equality	ភាពដូចគ្នា ទាំងបរិមាណ ទំហំ ចំនួន តម្លៃ កម្រិត និងហាន:	៤
អធិធម្មជាតិ supernatural	ដែលលើស ឬ ផុតពីអ្វីដែលមាននៅក្នុងធម្មជាតិ ឬ ធម្មតា	៣
អនុរាស្ត្រ (រងឥទ្ធិពល) subjects	អស់អ្នកដែលនៅក្រោមអំណាច ការគ្រប់គ្រង ឬ ឥទ្ធិពលរបស់នរណាម្នាក់	៥
អន្តរាគមន៍ intervene	មកនៅចន្លោះរវាង ធ្វើជាអ្នកចចារ	២
អមតៈ immortal	នៅរស់ជារៀងរហូត	១
អរូប immaterial	ខាងឯវិញ្ញាណ មិនមែនខាងឯសាច់ឈាម	១
និរន្ត (អស់កល្បជានិច្ច) eternal	ដែលគ្មានទីចាប់ផ្តើម ឬ ទីបញ្ចប់ ជាអចិន្ត្រៃយ៍	១
អាណាចក្រ realm	ព្រះរាជាណាចក្រ	៥
អំពើកាមគុណ carnality	បែបលោកីយ៍ ទាក់ទងនឹងតណ្ហាខាងឯរូបកាយ ទាក់ទងនឹងការខ្វះខាតខាងវិញ្ញាណ	៤
អះអាងបញ្ជាក់ confirmed	ធ្វើបង្កើតឡើងយ៉ាងរឹងមាំ ជានិរន្ត	៥

អ្នកតំណាង representative	ភ្នាក់ងារ អ្នកដែលត្រូវបានជ្រើសរើសឲ្យនិយាយ ឬ ធ្វើជំនួសនរណាម្នាក់	៣
អ្នកបកប្រែ interpreter	អ្នកបកស្រាយអត្ថន័យនៃអ្វីម្យ៉ាង	៤
អ្នកប្រមាថវត្ថុពិសិដ្ឋ	អ្នកដែលប្លន់យកទ្រព្យសម្បត្តិពិសិដ្ឋ	
អ្នកត្រួតពិនិត្យ monitor	អ្វីដែលដាស់តឿន ឬ ណែនាំ	៦
អ្នកសម្របសម្រួល mediator	អ្នកដែលមានជ្រៀតជ្រែករវាងអ្នកដទៃ ដើម្បីនាំឲ្យមានការផ្សះផ្សារ	៣
អ្នកសម្រុះសម្រួល intercessor	អ្នកអង្វរករ ឬ សុំការលើកលែងសម្រាប់នរណាម្នាក់	៣
ឧត្តម exalted	ត្រូវបានសរសើរ គោរព ផ្តល់សិរីរុងរឿង លើកឡើង តម្កើងឡើងការយកព្រះទ័យទុកដាក់ និង ជំនួយពីព្រះជាម្ចាស់	២
ឧបការគុណ គុណូបការៈ providence	ការយកព្រះទ័យទុកដាក់ និង ជំនួយពីព្រះជាម្ចាស់	២

ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន

មេរៀនទី១

១ ក) វិញ្ញាណ

២ ក) រស់នៅក្នុងជីវិតមួយដែលជាទីសព្វព្រះហឫទ័យសម្រាប់ព្រះជាម្ចាស់ និង ទុកចិត្តទ្រង់ថា ជួយខ្ញុំនៅក្នុងគ្រប់បញ្ហាគ្រប់បែបយ៉ាងដែលខ្ញុំប្រឈមមុខ។

៣ គ) អាចប្រទានឲ្យយើងនូវគ្រប់តម្រូវការដែលយើងមានផងដែរ។

៤ គ) ព្រះប្រាជ្ញាញាណរបស់ទ្រង់

៥ ខ

៦ ខ

៧ ត

៨ ត

៩ ត

១០ ខ

មេរៀនទី២

១ ត

២ ខ

៣ ត

៤ ខ

៥ ត

៦ ត

៧ ខ

៨ ត

៩ ត

១០ ត

១១ ត

១២ ខ

១៣ ត

១៤ ខ

មេរៀនទី៣

១ ក) ដែនកំណត់របស់មនុស្ស និង ព្រះនាមជាមនុស្សរបស់ទ្រង់

ខ) មានបុព្វបុរសជាមនុស្ស

ឃ) សណ្ឋាន និង ការលូតលាស់ជាមនុស្ស

២ ខ) អាកប្បកិរិយារបស់ទ្រង់ ការអះអាងរបស់ទ្រង់ និង គុណសម្បត្តិរបស់ទ្រង់បង្ហាញថា ទ្រង់លើសពីមនុស្សធម្មតា។

៣ ឃ) ពិតជាព្រះជាម្ចាស់ ហើយពិតជាមនុស្ស។

៤ ខ) គឺជាអង្គព្រះជាម្ចាស់ដែលចាប់យកភាពជាមនុស្ស។

៥ ក) ដើម្បីជំរុញឲ្យផែនការនៃការប្រោសលោះមនុស្សជាតិរបស់ព្រះជាម្ចាស់មានដំណើរការ។

៦ ក) គឺជាកិច្ចការដែលទ្រង់សព្វព្រះទ័យទទួលយក ដើម្បីបង់លោះទោសបាបរបស់យើង។

៧ ក) ព្រះគ្រិស្តត្រូវចាប់យករូបកាយជាមនុស្សដែលអាចស្លាប់ ដើម្បីទ្រង់អាចបង់លះទោសបាបរបស់យើងរាល់គ្នា។

ខ) ការនេះបានបង្ហាញ ពីព្រះវរបិតានៃស្ថានបរមសុខទៅកាន់មនុស្ស។

ឃ) នៅក្នុងការចាប់ដិសន្ធិនេះ ព្រះគ្រិស្តបានប្រទានឲ្យយើងនូវគំរូមួយយ៉ាងល្អ។

៨ ខ) សម្លាប់និស្ស័យបាបរបស់ពួកគេ ព្រោះការសង្គ្រោះអនុញ្ញាតឲ្យពួកគេអាចរស់នៅក្នុងជីវិតដ៏វិសុទ្ធមួយបាន។

៩ ក) រាជកិច្ចនេះបង្ហាញពីការទទួលយករបស់ព្រះវរបិតា នូវការបូជារបស់ព្រះគ្រិស្ត ថាជាការទូលអង្វរជំនួសបាបរបស់មនុស្ស។

ខ) រាជកិច្ចនេះបញ្ជាក់ពីភាពជាព្រះរបស់ព្រះអម្ចាស់នៃយើង។

ឃ) ព្រះគ្រិស្តគឺជាមហាបូជាចារ្យដ៏ខ្ពង់ខ្ពស់របស់យើងដែល ចាំទូលអង្វរជំនួសយើងនៅក្នុងព្រះវត្តមានរបស់ព្រះវរបិតា។

ង) រាជកិច្ចនេះជាការធានាសម្រាប់គ្រិស្តបរិស័ទ ថាពួកគេនឹងត្រូវបានប្រោសឲ្យរស់ពីស្លាប់ឡើងវិញនៅពេលព្រះគ្រិស្តយាងត្រឡប់មកវិញ។

១០ ក) ទិដ្ឋភាពថ្មីមួយនៃព័ន្ធកិច្ចរបស់ព្រះគ្រិស្ត៖ ក្នុងនាមជាព្រះអង្គសង្គ្រោះ ទ្រង់ថែទាំ និង កសាងក្រុមជំនុំ ហើយព្រះវត្តមានរបស់ទ្រង់គឺមាននៅគ្រប់ទីកន្លែងទាំងអស់។

មេរៀនទី៤

១ ត

២ ត

៣ ត

៤ ខ

៥ ត

៦ ខ

៧ ខ

៨ ត

៩ ខ

១០ ត

១១ ខ

១២ ត

១៣ ត

១៤ ត

១៥ ខ

១៦ ត

១៧ ត

១៨ ខ

១៩ ត

២០ ខ

មេរៀនទី៥

១ ត

២ ត

៣ ខ

៤ ត

៥ ត

៦ ត

៧ ខ

៨ ត

៩ ត

១០ ត

១១ ខ

១២ ត

១៣ ខ

១៤ ត

១៥ ត

មេរៀនទី៦

១ ខ) លោកគឺជាស្នាព្រះហស្តពិសេសមានតែមួយ របស់ព្រះជាម្ចាស់ ដែលបានលើកឲ្យខ្ពស់លើសភាវៈដទៃផ្សេងទៀត និង ទទួលបានព្រះពរពីព្រះជាម្ចាស់។

២ គ) ដូចនឹងព្រះជាម្ចាស់ត្រង់ បុគ្គលិកលក្ខណៈ សីលធម៌ និង ការដឹងពីសង្គម និងសមត្ថភាពក្នុងការគ្រប់គ្រង។

៣ ក) ទិន្នភាពខាងរូបី និង អរូបី។

៤ ខ) ព្រលឹង

៥ ខ) ជីវិតអរូបី

៦ ក), ខ), គ) និង ឃ) គឺជាចម្លើយត្រឹមត្រូវ

៧ គ) អារម្មណ៍ប្រាប់ទៅកាន់មនុស្សម្នាក់ឲ្យធ្វើសកម្មភាព តាមរបៀបណាមួយ ឬ តាមរបៀបផ្សេងទៀត។

៨ ក) មានការយល់ដឹងអំពីការពិតនៃបញ្ហាដែលចោទឡើង។

៩ ខ) ថ្លឹងថ្លែងសកម្មភាព ផ្ទុយនឹងខ្នាតគំរូនៃចរិយាមាយាទរបស់បុគ្គលម្នាក់។

១០ គ) ព្រះគុណរបស់ព្រះជាម្ចាស់ដែលនាំមកនូវការសង្គ្រោះ និង ការអនុញ្ញាតឲ្យស្តាប់បង្គាប់ទ្រង់។

១១ គ) ខ្លួនប្រាណរបស់យើងនឹងស្លាប់ ព្រលឹង ឬ វិញ្ញាណរបស់អ្នកជឿនឹងបាននៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ភ្លាមៗ ហើយនៅក្នុងពេលដែលព្រះយេស៊ូយាងមកជាលើកទីពីរ ពួកគេនឹងទទួលបាននូវរូបកាយការប្រោសឲ្យមានជីវិត ប្រកបដោយសិរីរុងរឿង ចំណែកអ្នកមិនជឿ នឹងត្រូវឆ្លងកាត់ការកាត់ទោស នៅក្នុងនរកអស់កល្បជានិច្ច។

មេរៀនទី៧

១ លោកអដាំ និង នាងអេវ៉ា

២ សាតាំង និង ទេវតារបស់វា

៣ ភស្តុតាងដែលព្រះគម្ពីរបានផ្តល់ឲ្យ និង តម្រូវការឲ្យមានការគ្រប់គ្រងនៅក្នុងសង្គម។

៤ លន់តួបាប លះបង់ចោលអំពើបាប ទទួលយកសេចក្តីសង្គ្រោះដែលព្រះជាម្ចាស់ប្រទានឲ្យតាមរយៈព្រះយេស៊ូគ្រិស្ត និង ដើរនៅក្នុងពន្លឺ។

៥ ការបែកចេញពីព្រះជាម្ចាស់ជារៀងរហូត ជាមួយនឹងការដាក់ទោសអស់កល្បជានិច្ច។

៦ ខ (ព្រះជាម្ចាស់គ្រោងប្រទានឲ្យមនុស្សជាតិទទួលបានសិទ្ធិក្នុងការជ្រើសរើស មានទំនាក់ទំនងជាមួយទ្រង់)

៧ ត

៨ ត

៩ ត

១០ ខ (វាក្លែងបន្លំតាមផែនការរបស់ព្រះជាម្ចាស់)។

១១ ត

១២ ត

មេរៀនទី៨

១ ក) ៣) ប្រពៃណីនិយាយតៗគ្នា

ខ) ៦) ការបំភ្លឺ

គ) ២) សំណេរដើម

ឃ) ៥) ការបណ្តាលចិត្ត

ង) ៧) ការបើកសម្តែង

ច) ១) អក្សរសិល្ប៍អរិសានលោកីយ៍

ឆ) ៤) បញ្ជីកណ្ឌគម្ពីរ

២ ខ

៣ ត

៤ ខ

៥ ត

៦ ត

៧ ត

មេរៀនទី៩

១ ខ) សហគមន៍មនុស្សដែលឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។

២ គ) ក្រុមជំនុំគឺមានរួមបញ្ចូលមនុស្សជាច្រើននាក់ នៅក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយសារតែទំនាក់ទំនងជាលក្ខណៈបុគ្គលរបស់ពួកគេម្នាក់ជាមួយព្រះគ្រិស្ត។

៣ ខ) អ្នកជឿដែលមកពីកន្លែងណាមួយ ដែលមានជំនឿដូចគ្នាទៅលើព្រះយេស៊ូគ្រិស្ត និង ជាអ្នកដែលបានជួបប្រជុំគ្នា ដើម្បីធ្វើការថ្វាយបង្គំ។

៤ ឃ) ការចែករំលែក និង ការប្រកបរួមគ្នា។

៥ គ) នៅថ្ងៃបុណ្យថ្ងៃទីហាសិប។

៦ ក) ការបង្ហាញពីការរួបរួមរបស់ពួកអ្នកជឿ និង សេចក្តីស្រឡាញ់សម្រាប់គ្នាទៅវិញទៅមក។

៧ ក) ពួកគេស្រឡាញ់អ្នកដទៃ។

៨ ខ) ក្រុមជំនុំសម្រាប់ការកសាង ការប្រតិបត្តិការណ៍តាមរយៈអ្នកជឿ នៅពេលដែលពួកគេបម្រើគ្នាទៅវិញទៅមក។

៩ គ) ព្រះសិរសា

១០ ក) ក្រុមជំនុំថ្វាយបង្គំព្រះជាម្ចាស់ ដោយការសរសើរតម្កើង ការគោរពយ៉ាងជ្រាលជ្រៅ

ការលើកព្រះកិត្តិនាម និង ការស្តាប់បង្គាប់។

ខ) ក្រុមជំនុំកសាងខ្លួនឯង (ពង្រឹងកម្លាំង សាងសង ប្រៀនប្រដៅ បណ្តុះបណ្តាល និង ថែរក្សាសមាជិក)។

គ) ក្រុមជំនុំនាំយកសារនៃដំណឹងល្អរបស់ព្រះយេស៊ូទៅកាន់ពិភពលោក (ផ្សព្វផ្សាយទៅកាន់ពិភពលោក)

មេរៀនទី១០

១ ខ

២ ត

៣ ខ

៤ ត

៥ ត

៦ ត

៧ ខ

៨ ត

៩ ត

១០ ត

១១ ខ

១២ ខ

១៣ ខ

១៤ ត

១៥ ត

ការប្រឡងតាមដំពូក

ការណែនាំ

នៅពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកទៅតាមដំពូកនីមួយៗហើយ ចូរឆ្លើយសំណួរប្រឡងតាមដំពូក ដោយប្រើប្រាស់ក្រដាសចម្លើយទៅតាមលំហាត់ប្រឡងដំពូកនីមួយៗ ដើម្បីកត់ត្រាចម្លើយរបស់អ្នក។

សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយតែមួយគត់ដែលល្អជាងគេសម្រាប់សំណួរនីមួយៗ។ ចូរដាក់ពណ៌ខ្មៅទៅលើប្រអប្បោះចម្លើយដែលអ្នកជ្រើសរើស។ *ត្រូវតែប្រាកដថាលេខនៅក្នុងក្រដាសចម្លើយដូចទៅនឹងលេខនៅក្នុងសំណួរដែលអ្នកឆ្លើយ។*

ឧទាហរណ៍

១ ការកើតជាថ្មីគឺមានន័យថា

ក) មានអាយុតិច

ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ

គ) ចាំផ្តើមឆ្នាំថ្មី

ឃ) ស្វែងរកក្រុមជំនុំផ្សេងមួយទៀត

ចម្លើយដែលត្រឹមត្រូវគឺ ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ ដូច្នេះអ្នកត្រូវដាក់ពណ៌ខ្មៅនៅក្នុងចន្លោះអក្សរ ខ យ៉ាងដូច្នេះ៖

ការប្រគល់ ចម្លើយសម្រាប់ការប្រឡង

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ និង បានឆ្លើយសំណួរប្រឡងទាំងអស់ហើយ សូមផ្ញើក្រដាសចម្លើយរបស់អ្នកទៅឲ្យគ្រូ ឬ ការិយាល័យដែលនៅក្នុងតំបន់របស់អ្នកដើម្បីធ្វើការកែសម្រួល។

ក្រដាសចម្លើយការប្រឡងតាមជំពូក

CS3131 ថ្មគ្រឹះនៃសេចក្តីពិត

ព័ត៌មានរបស់សិស្ស

ឈ្មោះ.....

លេខសំគាល់របស់សិស្ស.....

(សូមរក្សាចន្លោះនេះឲ្យនៅទទេ បើអ្នកមិនស្គាល់លេខរបស់អ្នក)

អាសយដ្ឋាន.....

.....

.....

ប្រទេស.....

អ៊ីម៉ែល.....

ចូរជាតពណ៌ខ្មៅដោយប្រុងប្រយ័ត្ននៅក្នុងចន្លោះចម្លើយត្រឹមត្រូវ របស់សំណួរដែលមានលេខដូចគ្នា។

ជំពូកទីមួយ

๑	ក	ខ	គ	ឃ	
๒	ក	ខ	គ	ឃ	
๓	ក	ខ	គ	ឃ	
๔	ក	ខ	គ	ឃ	
๕	ក	ខ	គ	ឃ	
๖	ក	ខ	គ	ឃ	
๗	ក	ខ	គ	ឃ	
๘	ក	ខ	គ	ឃ	
๙	ក	ខ	គ	ឃ	
๑๐	ក	ខ	គ	ឃ	
๑๑	ក	ខ	គ	ឃ	
๑๒	ក	ខ	គ	ឃ	
๑๓	ក	ខ	គ	ឃ	
๑๔	ក	ខ	គ	ឃ	
๑๕	ក	ខ	គ	ឃ	
๑๖	ក	ខ	គ	ឃ	
๑๗	ក	ខ	គ	ឃ	
๑๘	ក	ខ	គ	ឃ	
๑๙	ក	ខ	គ	ឃ	
๒๐	ក	ខ	គ	ឃ	

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប្រើ

ថ្ងៃទី .....ពិន្ទុ.....

ដំណាកទីពីរ

១	ក	ខ	គ	ឃ	
២	ក	ខ	គ	ឃ	
៣	ក	ខ	គ	ឃ	
៤	ក	ខ	គ	ឃ	
៥	ក	ខ	គ	ឃ	
៦	ក	ខ	គ	ឃ	
៧	ក	ខ	គ	ឃ	
៨	ក	ខ	គ	ឃ	
៩	ក	ខ	គ	ឃ	
១០	ក	ខ	គ	ឃ	
១១	ក	ខ	គ	ឃ	
១២	ក	ខ	គ	ឃ	
១៣	ក	ខ	គ	ឃ	
១៤	ក	ខ	គ	ឃ	
១៥	ក	ខ	គ	ឃ	
១៦	ក	ខ	គ	ឃ	
១៧	ក	ខ	គ	ឃ	
១៨	ក	ខ	គ	ឃ	
១៩	ក	ខ	គ	ឃ	
២០	ក	ខ	គ	ឃ	

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប៉ុណ្ណោះ

ថ្ងៃទី .....ពិន្ទុ.....

ដំណាកទីបី

១	ក	ខ	គ	ឃ	
២	ក	ខ	គ	ឃ	
៣	ក	ខ	គ	ឃ	
៤	ក	ខ	គ	ឃ	
៥	ក	ខ	គ	ឃ	
៦	ក	ខ	គ	ឃ	
៧	ក	ខ	គ	ឃ	
៨	ក	ខ	គ	ឃ	
៩	ក	ខ	គ	ឃ	
១០	ក	ខ	គ	ឃ	
១១	ក	ខ	គ	ឃ	
១២	ក	ខ	គ	ឃ	
១៣	ក	ខ	គ	ឃ	
១៤	ក	ខ	គ	ឃ	
១៥	ក	ខ	គ	ឃ	
១៦	ក	ខ	គ	ឃ	
១៧	ក	ខ	គ	ឃ	
១៨	ក	ខ	គ	ឃ	
១៩	ក	ខ	គ	ឃ	
២០	ក	ខ	គ	ឃ	

សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ តែប៉ុណ្ណោះ

ថ្ងៃទី .....ពិន្ទុ.....

ការប្រឡងជំពូកទីមួយ

១ គុណលក្ខណៈរបស់ព្រះជាម្ចាស់ដែលបង្ហាញពីភាពជាបុគ្គលរបស់ទ្រង់ គឺ
   ក) លក្ខណៈខាងឯសាច់ឈាម សង្គម និង វិញ្ញាណ
   ខ) សមត្ថភាពក្នុងការគិត មានអារម្មណ៍និង ធ្វើការសម្រេចចិត្ត
   គ) ភាពដែលអាចឲ្យគេចូលមករក អាចឃើញ និង យល់ពីទ្រង់បាន។
   ឃ) លក្ខណសម្បត្តិដ៏អាថ៌កំបាំង ដូចដែលបានឃើញនៅក្នុងព្រះរូបសំណាក់ពីបុរាណមក។

២ ការមើលទៅកាន់បុគ្គលិកលក្ខណៈរបស់មនុស្ស បង្រៀនយើងអំពីបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ ព្រោះ
   ក) យើងដឹងនៅក្នុងចិត្តយើងយ៉ាងច្បាស់ ថាព្រះជាម្ចាស់ជាព្រះបែបណាទៅហើយ។
   ខ) បុគ្គលិកលក្ខណៈរបស់មនុស្សគឺដូចជាបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់ទាំងស្រុង
   គ) បុគ្គលិកលក្ខណៈរបស់យើងឆ្លុះបញ្ចាំងពីអ្វីដែលយើងចង់ឃើញពីព្រះជាម្ចាស់។
   ឃ) យើងត្រូវបង្កើតមកឲ្យមានសណ្ឋានរបស់ព្រះជាម្ចាស់ និង មានលក្ខណៈស្រដៀងទ្រង់។

៣ នៅពេលដែលយើងនិយាយអំពីចំណុចពិសេសដោយឡែក ភាពសាមញ្ញ និង ការរួមមកតែមួយរបស់ព្រះជាម្ចាស់ យើងចង់បានន័យថា
   ក) ព្រះជាម្ចាស់តែមួយ។
   ខ) ព្រះជាម្ចាស់ដែលធំជាងគេនៅក្នុងចំណោមព្រះជាច្រើន។
   គ) ស្មើរតែដូចទៅនឹង ភាវៈដែលជាស្នាព្រះហស្តរបស់ទ្រង់។
   ឃ) ទ្រង់មានភាពខុសគ្នាដាច់ស្រឡះ។

៤ រឿងពិតមួយអំពីព្រះជាម្ចាស់ដែលមនុស្សអាចដឹងបាន តាមរយៈការបើកសម្តែងរបស់ព្រះជាម្ចាស់តែមួយគត់នោះគឺ សេចក្តីបង្រៀនអំពី
   ក) ការរួមមកតែមួយរបស់ព្រះជាម្ចាស់
   ខ) ភាពឧត្តុង្គឧត្តមរបស់ព្រះយេស៊ូ
   គ) ការរួមបីមកតែមួយ ឬ ត្រីឯក
   ឃ) ពេលវេលាជាក់លាក់ដែលព្រះយេស៊ូនឹងយាងត្រឡប់មកវិញ។

៥ នៅពេលដែលយើងនិយាយថាព្រះជាម្ចាស "ខ្ជាប់ខ្ជួន" យើងចង់មានន័យថា ទ្រង់គឺ
   ក) នៅតែល្អឥតខ្ចោះ
   ខ) នៅតែបន្តបង្កើត
   គ) អាថ៌កំបាំងសម្រាប់យើង
   ឃ) មិនចេះផ្លាស់ប្រែ

៦ ដោយទ្រង់ជាព្រះដ៏វិសុទ្ធ នោះអ្វីគ្រប់យ៉ាងដែលទ្រង់ធ្វើគឺ
   ក) ត្រឹមត្រូវ និង ល្អ
   ខ) ស្លូតបូត និង រាបសា
   គ) ជាអាថ៌កំបាំងសម្រាប់យើង
   ឃ) តែងតែចាំចាប់កំហុស

៧ យោងទៅតាមគម្ពីររ៉ូម ១:១៨-២០ កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងការបង្កើតគឺជាការបើកសម្តែងទូទៅនៃ
   ក) ភាពវិសុទ្ធ និង ភាពយុត្តិធម៌របស់ទ្រង់
   ខ) ក្តីស្រឡាញ់ក្នុងនាមជាឪពុកសម្រាប់អ្វីៗទាំងអស់ដែលទ្រង់បង្កើត។
   គ) ឫទ្ធានុភាពដ៏អស់កល្បជានិច្ច និង និស្ស័យជាព្រះជាម្ចាស់របស់ទ្រង់។
   ឃ) ឫទ្ធានុភាពដ៏អស់កល្បជានិច្ច និង ភាពសុចរិតរបស់ទ្រង់។

៨ គម្ពីរ២កូរិនថូស ៥:១៧ ប្រាប់យើងថា កិច្ចការនៃការបង្កើតរបស់ព្រះជាម្ចាស់ គឺនៅតែបន្តធ្វើឡើងនៅ
   ក) កាឡាក់ស៊ីដ៏សែនឆ្ងាយ
   ខ) ជីវិតរបស់ទេវតា
   គ) ចំណុចកណ្តាលនៃផែនដី
   ឃ) អស់អ្នកដែលទទួលព្រះគ្រិស្ត

៩ កិច្ចការរបស់ព្រះជាម្ចាស់ ក្នុងការសម្រេចបំណងព្រះហឫទ័យដ៏ឧត្តមរបស់ទ្រង់នៅក្នុងស្នាព្រះហស្តរបស់ទ្រង់ គឺត្រូវបានគេហៅថា
   ក) បុព្វជ្ឈាកម្ម
   ខ) ការទស្សន៍ទាយ
   គ) ដែលមានចិត្តចង្អៀត
   ឃ) ឧបការគុណ

១០ នៅពេលដែលមានរឿងកើតឡើងដែលយើងមិនអាចយល់បាន យើងត្រូវ
   ក) ទុកចិត្តលើក្តីស្រឡាញ់ និង ព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដើម្បីឲ្យទ្រង់ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។
   ខ) ទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យអ្វីៗ បានសមតាមអ្វីដែលយើងចង់បាន។
   គ) មិនត្រូវបណ្តោយឲ្យខ្លួនយើង មានអារម្មណ៍ខឹង និង មួម៉ៅឡើយ។
   ឃ) បោះបង់ចោល និង ដាក់ខ្លួនយើងឲ្យរងទុក្ខ ឬទទួលភាពអយុត្តិធម៌ទៅចុះ។

១១ ការចាប់បដិសន្ធិ គឺមានភាពចាំបាច់ណាស់ ដើម្បីឲ្យព្រះជាម្ចាស់អាច
ក) ឆ្លងកាត់សេចក្តីល្បួង អំពើបាប និង ភាពទន់ខ្សោយរបស់មនុស្សដោយផ្ទាល់។
ខ) ប្រទាននូវការបូជា ដើម្បីបង់ថ្លៃជួសអំពើបាបរបស់យើង។
គ) ក្លាយទៅជាអ្វីម្យ៉ាងដែលយើងអាចថ្វាយបង្គំបាន។
ឃ) ត្រួតពិនិត្យមើល តម្លៃនៃស្នាព្រះហស្តរបស់ទ្រង់។

១២ នៅក្នុងគម្ពីរម៉ាថាយ និង លូកា ពង្សាវតាររបស់ព្រះយេស៊ូបង្ហាញថាទ្រង់
ក) មានបុព្វបុរសដែលជាមនុស្ស ដែលមានភាពល្បីល្បាញ តែឈ្មោះប៉ុណ្ណោះ។
ខ) គ្រាន់តែសម្តែងជាទិដ្ឋភាពមួយនៃមនុស្សតែប៉ុណ្ណោះ។
គ) កើតមកពីគ្រួសារដែលមិនច្បាស់លាស់មួយ។
ឃ) មានបុព្វបុរសជាមនុស្សពិតៗ។

១៣ ចូរអានគម្ពីរម៉ាកុស ២:៥ ។ តើអ្វី ជាសិទ្ធិជាព្រះ ដែលព្រះយេស៊ូបានប្រើប្រាស់?
ក) ទ្រង់បានបង្កើតជីវិតថ្មី
ខ) ទ្រង់បានដកយកជីវិតរបស់មនុស្ស
គ) ទ្រង់បានអត់ទោសបាបរបស់បុរសម្នាក់
ឃ) ទ្រង់បានធ្វើឲ្យព្យុះស្ងប់

១៤ សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ អំពីការចាប់បដិសន្ធិ បង្ហាញថា ព្រះយេស៊ូ
ក) ជាព្រះជាម្ចាស់គ្រប់លក្ខណៈ និង មនុស្សគ្រប់លក្ខណៈ។
ខ) ពិតជាព្រះជាម្ចាស់ តែមិនមែនជាមនុស្សពិតនោះទេ។
គ) បានលះបង់និស្ស័យជាមនុស្សរបស់ទ្រង់ ដើម្បីទទួលបាននិស្ស័យរបស់ព្រះ។
ឃ) គឺពិតជាមនុស្ស នៅមុនពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយក្លាយជាព្រះពិត ប្រាកដក្រោយពេលទ្រង់មានព្រះជន្មរស់ឡើងវិញ។

១៥ ចំណុចដ៏សំខាន់មួយនៃការចាប់បដិសន្ធិ គឺថា តាមរយៈព្រះយេស៊ូយើងឃើញ
ក) ថាព្រះជាម្ចាស់ អាចនឹងមានដែនកំណត់បែបណា។
ខ) ថាព្រះជាម្ចាស់មានឫទ្ធានុភាព តែទ្រង់ស្ថិតនៅឆ្ងាយបែបណា។
គ) ព្រះពិរោធរបស់ព្រះជាម្ចាស់ មកលើពួកយើង
ឃ) ការបើកសម្តែងយ៉ាងពេញលេញ អំពីព្រះជាម្ចាស់ និង ក្តីស្រឡាញ់របស់ទ្រង់។

១៦ គម្ពីរម៉ាថាយ ២៨:១៩ បានបង្ហាញថាព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ ដោយសារតែ
ក) ការចូលរួមរបស់ទ្រង់ជាមួយនឹងការជ្រមុជទឹក។
ខ) ការចូលរួមរបស់ទ្រង់ជាមួយនឹងព្រះវរបិតា និង ព្រះរាជបុត្រា
គ) ការដែលទ្រង់ព្រមឲ្យហៅព្រះនាមទ្រង់ ក្រោយព្រះវរបិតា និង ព្រះរាជបុត្រា
ឃ) លក្ខណៈដែលមិនអាចមើលឃើញ របស់ទ្រង់ និង លទ្ធភាពក្នុងការធ្វើកិច្ចការ ប្រកបដោយឫទ្ធានុភាព នៅក្នុងធម្មជាតិ។

១៧ គម្ពីររ៉ូម៨:២៧ និយាយសំដៅទៅទិដ្ឋភាពមួយណានៃបុគ្គលិកលក្ខណៈរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
ក) បំណងព្រះហឫទ័យ
ខ) ព្រះប្រាជ្ញាញាណ
គ) មនោសញ្ចេតនា
ឃ) ភាពអាថ៌កំបាំង

១៨ គម្ពីរអេភេសូ ៤:៣០ លក្ខណសម្បត្តិផ្ទាល់មួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធគឺ
ក) ការដែលទ្រង់អាចទទួលភាពសោកសៅ។
ខ) ការដែលទ្រង់អាចបង្ហាញសេចក្តីស្រឡាញ់។
គ) មានការអត់ធ្មត់ជាមួយនឹងអំពើបាប។
ឃ) ចេះកំប្លែងលេង

១៩ គម្ពីរយ៉ូហាន ១៦:១៣ និយាយអំពីមុខងារដ៏មានសារៈសំខាន់របស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់អ្នកជឿ ក្នុងនាមជា
ក) អ្នកវិនិច្ឆ័យទោស នៅពេលដែលយើងប្រព្រឹត្តិអំពើបាប។
ខ) ព្រះដែលចាំដាក់ទោសយើង។
គ) ជាមិត្តជិតដិតរបស់យើង។
ឃ) ជាគ្រូម្នាក់។

២០ ទំនាក់ទំនងដ៏ស្និតរមួតរវាងព្រះវិញ្ញាណដ៏វិសុទ្ធ និង អ្នកជឿ គឺត្រូវបានគេហៅថា
ក) ការលិចចុះ ការបំពេញ និង ការជ្រមុជ
ខ) មិត្តភាពយ៉ាងស្និទ្ធស្នាល
គ) ការដើរនៅក្នុងជំនឿ
ឃ) ការល្បងលដ៏អស្ចារ្យមួយ។

ការប្រឡងជំពូកទីពីរ

១ នៅក្នុងភាសាដើម របស់ព្រះគម្ពីរ ពាក្យថា "ទេវតា" គឺមានន័យថា
   ក) ភាវៈដ៏វិសុទ្ធ
   ខ) អ្នកនាំសារ
   គ) មានគ្រប់ឫទ្ធានុភាព
   ឃ) ភាវៈដែលមានស្លាប

២ យើងអាចធ្វើការសន្និដ្ឋាន ចេញពីក្នុងភស្តុតាងនៃព្រះគម្ពីរអំពីដើមកំណើតរបស់ទេវតា ដែលថា ពួកគេ
   ក) ភាវៈដែលត្រូវបានបង្កើតមកឲ្យមានជីវិតអមតៈ នឹងមិនបាត់ទៅណាឡើយ។
   ខ) អំបូរភាវៈដ៏អាថ៌កំបាំង ដែលស្រដៀងទៅនឹងអាទិទេពដែរ។
   គ) ភាវៈមិនចេះស្លាប់ ដែលតែងតែមានជីវិតជារៀងរហូត។
   ឃ) វិញ្ញាណរបស់មនុស្សដែលត្រូវបានធ្វើឲ្យមានសិរីរុងរឿង។

៣ ទេវតាអាក្រក់គឺត្រូវបានបង្ហាញឲ្យឃើញ តាមរយៈភាពចចេស និង ការបះបោររបស់ពួកគេ ដែលមានន័យថាពួកគេ
   ក) គឺអាក្រក់តាំងតែពីដើមមក ប៉ុន្តែបានលាក់បាំងនិស្ស័យអាក្រក់របស់ពួកគេ។
   ខ) គឺត្រូវបានបង្កើតមកបែបនេះ ហើយពួកគេមិនអាចផ្លាស់ប្តូរបានទេ។
   គ) ធ្វើការជ្រើសរើស ប្រឆាំងនឹងព្រះជាម្ចាស់ និង ត្រូវបានប្រឈមមុខនឹងការកាត់ទោសអស់កល្បជានិច្ច។
   ឃ) ស្ថិតនៅក្នុងដំណាក់កាលដកពិសោធន៍ បន្ទាប់ពីនេះ ពួកគេនឹងមានឱកាសលន់តួបាប។

៤ យោងទៅតាមគម្ពីរម៉ាកុស ជំពូក៨:៣៨ ទេវតាដ៏វិសុទ្ធគឺនៅជាមួយព្រះជាម្ចាស់នា ស្ថានបរមសុខ ហើយនឹង
   ក) ត្រឡប់មកវិញជាមួយព្រះគ្រិស្តដែលប្រកបដោយសិរីរុងរឿងរបស់ទ្រង់។
   ខ) ប្រយុទ្ធជាមួយនឹងពួកទេវតាអាក្រក់ដែលប្រឆាំងទាស់នឹងព្រះគ្រិស្ត។
   គ) នាំយកអ្នកជឿដែលបានស្លាប់ទៅឯនគរឋានសួគ៌។
   ឃ) ចាកចេញពីព្រះជាម្ចាស់នៅគ្រាចុងក្រោយ។

៥ គម្ពីរ១ពង្សាវតាក្សត្រ២២:១៩ បង្ហាញថាទេវតាដ៏វិសុទ្ធគឺនៅជុំវិញ
   ក) អស់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់ ដើម្បីការពារអ្នកទាំងនោះ។
   ខ) អារក្សដើម្បីរារាំងកិច្ចការរបស់វា។
   គ) បល្ល័ង្ករបស់ព្រះជាម្ចាស់នៅឯនគរឋានសួគ៌។
   ឃ) ទេវតាអាក្រក់ដែលពួកគេបានឃុំឃាំង។

៦ ចូរអានគម្ពីរម៉ាថាយ ២៦:៥៣ ។ តើអ្វីខ្លះ ដែលបទគម្ពីរនេះប្រាប់អំពី ការរៀបចំនៃពួកទេវតាដ៏វិសុទ្ធ?

ក) គ្មានអ្វីនៅក្នុងខគម្ពីរនេះ ប្រាប់អំពីរបៀបដែលពួកទេវតាត្រូវបានរៀបចំបែបណានោះទេ។
ខ) ពួកទេវតាប្រហែលជា ត្រូវបានរៀបចំ ជាមួយនឹងរចនាសម្ព័ន្ធស្រដៀងទៅនឹងភូមិរបស់មនុស្ស។
គ) ពាក្យយោធាថា "កងពល" បង្ហាញថាពួកទេវតាត្រូវបានរៀបចំឲ្យដូចជាទាហាន។
ឃ) យោងតាមបរិបទនេះ យើងជឿថា ពួកទេវតាត្រូវបានរៀបចំជាក្រុមចម្រៀង។

៧ គម្ពីរដានីយ៉ែល ១០:១៣,២០ បញ្ជាក់ថាទេវតាលេចមក ដើម្បីជះឥទ្ធិពលទៅលើ
ក) អារម្មណ៍របស់មនុស្ស
ខ) ភាវៈដែលនៅឯឋានបរមសុខ។
គ) ព្រះតម្រិះដ៏ឧត្តមរបស់ព្រះជាម្ចាស់។
ឃ) ប្រទេសជាតិ និង កិច្ចការជាតិ។

៨ នៅក្នុងសាច់រឿងអំពីការបង្កើត ក្នុងគម្ពីរលោកុប្បត្តិ បង្ហាញថា មានតែមនុស្សប៉ុណ្ណោះដែលត្រូវបានបង្កើត
ក) ដោយកិច្ចការពិសេសរបស់ព្រះជាម្ចាស់។
ខ) ជាមួយនឹងសមត្ថភាពក្នុងការបរិភោគ។
គ) នៅថ្ងៃទីបី។
ឃ) នៅថ្ងៃទីប្រាំ។

៩ នៅពេលដែលយើងនិយាយថា យើងត្រូវបានបង្កើតមកឲ្យមានសណ្ឋានដូចព្រះជាម្ចាស់ យើងមានន័យថា យើងគឺជា
ក) ការចម្លងពីលក្ខណៈខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់សុទ្ធសាធ។
ខ) ភាវៈដែលអាចស្រឡាញ់គ្នាទៅវិញទៅមក។
គ) ភាវៈដែលមានបុគ្គលិកលក្ខណៈ ភាវៈ ដែលមានវិចារណញ្ញាណ និង មានភាពរីករាយ។
ឃ) ភាវៈដែលមានបុគ្គលិកលក្ខណៈ ភាវៈដែលមានវិចារណញ្ញាណ និង មានសីលធម៌។

១០ ទោះបីជាព្រះជាម្ចាស់ជាស្តេចលើចក្រវាឡ ទ្រង់បានប្រទានឲ្យមនុស្សនូវ
ក) ទំនួលខុសត្រូវជាមួយនឹងអំណាចដែលប្រកបប្រាជ្ញាញាណ និង យុត្តិធម៌នៅលើពិភពលោក។
ខ) សេរីភាពក្នុងការគ្រប់គ្រងលើការបង្កើតផ្សេងទៀតនៅក្នុងពិភពលោក។
គ) បទបញ្ជាឲ្យគ្រប់គ្រងលើរបស់មានជីវិតទាំងអស់ផ្សេងទៀត។
ឃ) បទបញ្ជាឲ្យបង្កើតលោហៈធាតុ។

១១ ឆន្ទៈ និង មនសិការរបស់យើង បូករួមបញ្ចូលគ្នាបង្កើតបានជា
ក) ទិដ្ឋភាពនៃអារម្មណ៍ក្នុងខ្លួនយើង។
ខ) ទិដ្ឋភាពនៃសីលធម៌ក្នុងខ្លួនយើង។
គ) ទិដ្ឋភាពអរូបីរបស់យើង។
ឃ) ទិដ្ឋភាពបញ្ញារបស់យើង។

១២ "សម្លេងដែលនៅខាងក្នុង" ដែលធ្វើឲ្យមានសកម្មភាពនៃសីលធម៌គឺ
ក) បំណងចិត្តរបស់យើង
ខ) ប្រាថ្នារបស់យើង
គ) មនសិការរបស់យើង
ឃ) គំនិតប្រកបដោយវិចារណញ្ញាណរបស់យើង

១៣ អំណាចដែលយើងមានក្នុងការធ្វើការជ្រើសរើស រឿងត្រឹមត្រូវ និង រឿងខុសឆ្គង គឺជា
ក) មនសិការរបស់យើង
ខ) សេរីភាពរបស់យើង
គ) គំនិតរបស់យើង
ឃ) ឆន្ទៈរបស់យើង

១៤ យោងទៅតាមគម្ពីរ២កូរិនថូស ៥:៦-៨ នៅពេលដែលរូបកាយរបស់គ្រិស្តបរិស័ទស្លាប់ទៅ ព្រលឹងរបស់គាត់នឹង
ក) ទៅនៅជាមួយនឹងព្រះគ្រិស្តភ្លាមៗ
ខ) ចូលទៅក្នុងសភាពមួយដូចការសម្រាន្តលក់ រងចាំការយាងត្រឡប់របស់ព្រះគ្រិស្ត។
គ) លែងមានវត្តមានទៀតហើយ ប៉ុន្តែនឹងត្រូវបង្កើតជាថ្មីម្តងទៀត នៅពេលព្រះគ្រិស្តយាងត្រឡប់មកវិញ។
ឃ) ត្រូវបានស្រូបចូលទៅក្នុងព្រលឹងរបស់ព្រះជាម្ចាស់ ហើយក្លាយទៅជាតែមួយ ក្នុងទ្រង់។

១៥ អំពើបាបអាចត្រូវបាន កំណត់និយមថា ជាការមិនស្តាប់បង្គាប់ និង ភាពបរាជ័យក្នុងការ
ក) ធ្វើតាមក្រឹត្យវិន័យរបស់ក្រុមជំនុំ។
ខ) ធ្វើតាមច្បាប់របស់ព្រះជាម្ចាស់។
គ) ស្តាប់តាមមនសិការរបស់យើង។
ឃ) ធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវ។

១៦ ដើមកំណើតនៃអំពើបាបគឺត្រូវបានគេឃើញនៅក្នុង
ក) ព្រះជាម្ចាស់
ខ) សាតាំង
គ) លោកអដាំ
ឃ) ទេវតារបស់សាតាំង

១៧ ជារឿងចាំបាច់ណាស់ ដែលព្រះជាម្ចាស់ត្រូវហាមឃាត់មិនឲ្យលោកអដាំ និង នាងអេវ៉ាបរិភោគផ្លែឈើមួយប្រភេទ ព្រោះ

ក) ទ្រង់មិនសព្វព្រះហឫទ័យឲ្យពួកគេយល់អំពីរឿងគ្រប់យ៉ាងនោះទេ។

ខ) ផ្លែឈើ នោះ គឺគ្រោះថ្នាក់សម្រាប់ពួកគេ។

គ) ពួកគេត្រូវការប្រើប្រាស់ឆន្ទៈសេរីរបស់ពួកគេ ហើយធ្វើការជ្រើសរើសតាមព្រះជាម្ចាស់ ឬប្រឆាំងទ្រង់។

ឃ) ទ្រង់សព្វព្រះហឫទ័យឲ្យពួកគេដឹងថា ពួកគេស្ថិតក្រោមក្តីមេត្តារបស់ទ្រង់ ហើយគ្មានសេរីភាពឆន្ទៈនោះទេ។

១៨ នាងអេវ៉ាប្រព្រឹត្តិអំពើបាប ព្រោះនាង

ក) ចង់ស្វែងរកភាពរំជើបរំជួល

ខ) នាងគិតស្មានថាខ្លួនឆ្លាត។

គ) ជ្រើសរើសយកខ្លួនឯងមុនព្រះជាម្ចាស់

ឃ) ស្អប់អដាំ

១៩ ទាក់ទងទៅនឹងអំពើបាប "អំពើរំលង" គឺបានន័យថា

ក) ឆ្លងកាត់ព្រំដែនដែលព្រះជាម្ចាស់បានកំណត់

ខ) មិនអាចធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន។

គ) តម្កើងខ្លួនឯង

ឃ) ការចេះអត់ទោស

២០ យោងតាមគម្ពីររ៉ូម ៨:១៩-២២ អំពើបាប បានជះឥទ្ធិពលទៅលើ

ក) តែមនុស្សប៉ុណ្ណោះ។

ខ) តែមនុស្ស និង ទេវតាប៉ុណ្ណោះ។

គ) តែមនុស្ស និង សត្វប៉ុណ្ណោះ។

ឃ) ស្នាព្រះហស្តទាំងអស់នៅក្នុង សាកលលោក។

ការប្រឡងជំពូកទីបី

១ នៅពេលដែលនិយាយអំពីព្រះជាម្ចាស់ ពាក្យថា "ការបើកសម្តែង" មានន័យថាព្រះជាម្ចាស់
   ក) បណ្តាលចិត្តឲ្យយើងយល់ពីទ្រង់ តាមរយៈអ្វីដែលយើងងាយមើលឃើញនៅក្នុងធម្មជាតិ
   ខ) លាតត្រដាងមកកាន់យើង ពីអ្វីដែលយើងមិនអាចយល់ អំពីទ្រង់។
   គ) បំភ្លឺយើងតាមរយៈវិញ្ញាណរបស់យើង អំពីការពិតដែលយើងបានយល់រួចហើយ។
   ឃ) បំភ័យយើង ដោយប្រាប់យើងពីអ្វីដែលនឹងកើតឡើងនៅថ្ងៃអនាគត។

២ កំណត់ត្រាជាសំណេរ គឺល្អជាងប្រពៃណីនិយាយតគ្នា ព្រោះកំណត់ត្រាជាសំណេរ
   ក) មិនផ្លាស់ប្តូរឡើយ ក្រោយពេលវាត្រូវបានសរសេរឡើង។
   ខ) មិនងាយនឹងភ្លេច។
   គ) មិនងាយនឹងផ្លាស់ប្តូរទេ។
   ឃ) តែងតែសុក្រិត។

៣ ការនិយាយថាព្រះជាម្ចាស់ "បានបណ្តាលចិត្តឲ្យ" តែងបទគម្ពីរ មានន័យថា ព្រះវិញ្ញាណដ៏វិសុទ្ធ
   ក) មានព្រះបន្ទូលប្រាប់អ្នកនិពន្ធ អំពីអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់បាន និង ដឹកនាំផ្លូវពួកគេក្នុងការសរសេរផងដែរ។
   ខ) បញ្ជាផ្តាច់ការ ទៅលើគ្រប់ពាក្យដូចដែលមានសរសេរនៅក្នុងព្រះគម្ពីរ។
   គ) ប្រទានឲ្យអ្នកនិពន្ធព្រះគម្ពីរនូវគំនិតផុសផុល ធ្វើការចែកចាយបន្ត។
   ឃ) ប្រើប្រាស់តែពាក្យពិសេស សម្រាប់ធ្វើការសរសេរបទគម្ពីរ។

៤ គម្ពីរ២ធីម៉ូថេ៣:១៦ ប្រាប់យើងថាគ្រប់បទគម្ពីរទាំងអស់គឺ
   ក) ពិតទាក់ទាញគួរឲ្យចង់អានណាស់។
   ខ) ស័ក្តសមនឹងយកមកវែងញែកណាស់។
   គ) ព្រះជាម្ចាស់បានបណ្តាលចិត្តឲ្យតែង។
   ឃ) មានអាថ៌កំបាំងណាស់។

៥ "ភាពផ្តាច់មុខ" នៃបទគម្ពីរ មានន័យថាព្រះគម្ពីរគឺ
   ក) ការបើកសម្តែងជាសំណេរទាំងស្រុងរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះ។
   ខ) ជាសៀវភៅតែមួយគត់ដែលថ្លែងប្រាប់អំពីដើមកំណើតរបស់ព្រះជាម្ចាស់។
   គ) ការបើកសម្តែងជាលើកចុងក្រោយរបស់ព្រះជាម្ចាស់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។
   ឃ) ការបើកសម្តែងតែមួយគត់ អំពីសេចក្តីពិតរបស់ព្រះជាម្ចាស់។

៦ នៅក្នុងច្បាប់ចម្លង និង ច្បាប់ដែលរក្សារបស់បទគម្ពីរ មានភស្តុតាងអំពី
ក) មានភាពខុសគ្នាខាងឯគោលលិទ្ធ យ៉ាងខ្លាំង នៅក្នុងហត្ថសំណេរនីមួយៗ។
ខ) សំណេរដែលមិនគួរឲ្យទុកចិត្តជាច្រើន ដែលធ្វើឲ្យខូចតម្លៃនៃព្រះគម្ពីរ។
គ) ភាពមិនខុសគ្នាសោះឡើយ រវាងហត្ថសំណេរនីមួយៗ។
ឃ) ការការពារ និង ការថែទាំយ៉ាងច្បាស់របស់ព្រះជាម្ចាស់ ក្នុងការរក្សាឲ្យហត្ថសំណេរនៅតែអាចទុកចិត្តបាន។

៧ ការបណ្តាលចិត្តឲ្យតែងពីព្រះវិញ្ញាណដ៏វិសុទ្ធ នៃបទគម្ពីរគឺមានតែនៅក្នុង
ក) ហត្ថសំណេរដើមក្នុងសំណេរព្រះគម្ពីរតែប៉ុណ្ណោះ។
ខ) ការបកប្រែដំបូងទៅជាភាសាផ្សេងៗ នៃសំណេរព្រះគម្ពីរតែប៉ុណ្ណោះ។
គ) ការបកប្រែនៃសំណេរព្រះគម្ពីរដោយអ្នកប្រាជ្ញខ្លាំងបំផុត ទៅជាភាពថ្មីមួយទៀតប៉ុណ្ណោះ។
ឃ) កណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ដោយលោកម៉ូសេ និង កណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីដោយលោកប៉ូលប៉ុណ្ណោះ។

៨ បទគម្ពីរនីមួយៗ ត្រូវតែបានវិភាគ និង បកប្រែ តាមរយៈពន្លឺនៃ
ក) សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទាំងមូល។
ខ) ប្រពៃណីនៃក្រុមជំនុំទាំងមូល។
គ) កន្លែងត្រូវបានគេរកឃើញនៅក្នុងបរិបទខគម្ពីរនោះ។
ឃ) ចំណេះដឹងដែលល្អជាងគេ ដែលផ្អែកលើការសិក្សាភាសាដើម។

៩ ក្រុមជំនុំគឺជាការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដ៏ពិសិដ្ឋ របស់មនុស្សរួមគ្នា
ក) នៅក្នុងសេចក្តីសង្ឃឹមដូចគ្នា ថានឹងបានជីវិតមួយដែលល្អប្រសើរ។
ខ) ទាំងស្រុងទៅលើរបៀបថ្វាយបង្គំ របស់ពួកគេ។
គ) ផ្អែកលើការយល់ស្របគ្នាទៅលើគោលលទ្ធិ។
ឃ) ទៅវិញទៅមក និង ជាមួយព្រះជាម្ចាស់។

១០ គម្ពីរអេភេសូ១:១៩-២៣ បញ្ជាក់ថាក្រុមជំនុំមិនអាចនឹងបង្កើតបាននោះទេ រហូតក្រោយពី
ក) ពួកសាវ័កត្រូវបានបែកខ្ញែក ដោយការបៀតបៀន។
ខ) ថ្ងៃបុណ្យថ្ងៃទីហាសិប ដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការជំពូក២
គ) ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅនគរស្ថានសួគ៌វិញរបស់ព្រះគ្រិស្ត។
ឃ) ពួកសាវ័កដំបូងទាំងដប់ពីររូបស្លាប់អស់ទៅ។

១១ គ្រិស្តបរិស័ទភាគច្រើន យល់ស្របគ្នាថា ក្រុមជំនុំចាប់ផ្តើមជាផ្លូវការ
ក) នៅពេលដែលព្រះយេស៊ូប្រសូត
ខ) នៅពេលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
គ) នៅពេលដែលព្រះយេស៊ូប្រែព្រះកាយរបស់ទ្រង់។
ឃ) នៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប ដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការជំពូក ២។

១២ យោងតាមគម្ពីរយ៉ូហាន៤:២៣ ការថ្វាយបង្គំរបស់ក្រុមជំនុំ ត្រូវតែធ្វើឡើង
ក) ជាមួយការយកចិត្តយ៉ាងខ្លាំងទៅលើ ដែនកំណត់នៃកញ្ចប់ថវិកា។
ខ) យោងទៅតាមពិធីសាសនាសុទ្ធសាធ។
គ) នៅក្នុងព្រះវិញ្ញាណ និង សេចក្តីពិត។
ឃ) នៅក្នុងទីសាធារណៈ។

១៣ ការថ្វាយបង្គំរួមគ្នា គឺមានសារៈសំខាន់ណាស់ សម្រាប់ក្រុមជំនុំ ព្រោះពួកអ្នកជឿគឺ
ក) ជាទិដ្ឋភាពនៃសហគមន៍របស់ព្រះជាម្ចាស់ ដូចទៅនឹងបុគ្គលគ្រប់រូបដែរ។
ខ) មិនសំខាន់សម្រាប់ផែនការរបស់ព្រះជាម្ចាស់ ក្នុងការថ្វាយបង្គំនោះទេ។
គ) មិនអាចថ្វាយបង្គំព្រះជាម្ចាស់ តែម្នាក់ឯងផ្ទាល់ខ្លួនទេ។
ឃ) អាចធ្វើជាសក្ខីភាពនៅក្នុងទីសាធារណៈតែប៉ុណ្ណោះ។

១៤ គម្ពីរអេភេសូ ៤:១១-១៣ បង្រៀនយើងថា អ្នកជឿមានសារៈសំខាន់នៅក្នុងក្រុមជំនុំ ដើម្បី
ក) ទទួលបានការចាប់អារម្មណ៍ និង ការគោរព សម្រាប់ខ្លួនគេផ្ទាល់។
ខ) ពង្រឹង ឬ "កសាង" ព្រះកាយរបស់ព្រះគ្រិស្តទាំងមូល។
គ) នាំការចាប់អារម្មណ៍មកកាន់ក្រុមជំនុំ ដើម្បីឲ្យអ្នកដទៃអាចជឿដែរ។
ឃ) ធ្វើកិច្ចការថែទាំ ទាំងអស់ដើម្បីឲ្យអគារព្រះវិហារនៅតែអាចដំណើរបន្ត។

១៥ នៅពេលព្រះគ្រិស្ត យាងមកសម្រាប់អ្នកជឿ គេហៅថា
ក) ការឆក់យកអ្នកជឿឡើងទៅ
ខ) ការបើកសម្តែងរបស់ព្រះយេស៊ូគ្រិស្ត។
គ) ទុក្ខវេទនារបស់អ្នកជឿគ្រប់គ្នា។
ឃ) ការយាងត្រឡប់មកវិញរបស់ព្រះគ្រិស្ត ប្រកបដោយឫទ្ធានុភាព និង សិរីរុងរឿង។

១៦ យោងតាមគម្ពីរ១កូរិនថូស១៥:៥០-៥៤ អ្នកជឿដែលនៅមានជីវិតរស់ នៅក្នុងនៃការឆក់យកឡើងទៅ នឹងផ្លាស់ប្តូរពីរ
ក) មនុស្សទៅជាទេវតា
ខ) មនុស្សដែលអាចស្លាប់ ទៅជាអមតៈ
គ) ពេញដោយទុក្ខព្រួយ ទៅជាមានអំណរ
ឃ) ខ្មាសអៀន ទៅជាមានភាពមោះមុត

១៧ ដើម្បីយល់ពី ពេលកំណត់នៃគ្រាចុងក្រោយ បទទំនាយសំខាន់ៗនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ គឺត្រូវបានគេឃើញមាននៅក្នុង
ក) គម្ពីរសុភាសិត
ខ) គម្ពីរទំនុកតម្កើង
គ) ដានីយ៉ែល
ឃ) យ៉ាកុប

១៨ បទទំនាយនៅក្នុងគម្ពីរដានីយ៉ែលជំពូក៩ ស្តីអំពី "ស្តេចដែលនឹងមកដល់" នៅក្នុងថ្ងៃចុងក្រោយ របស់អ៊ីស្រាអែល។ យើងក៏ស្គាល់ស្តេចនោះថាជា

ក) សាតាំង

ខ) អ្នកប្រឆាំងនឹងព្រះគ្រិស្ត

គ) ស្តេចដ៏អាថ៌កំបាំង

ឃ) អារក្សដែលមកពីទិសខាងកើត

១៩ នៅពេលដែលព្រះអម្ចាស់យាងត្រឡប់មកវិញ ប្រកបដោយឫទ្ធានុភាព និង សិរីរុងរឿង ទ្រង់នឹង បង្កើត

ក) ប្រព័ន្ធរដ្ឋាភិបាលប្រជាធិបតេយ្យជាសាកលមួយ ។

ខ) ព្រះរាជ្យដ៏សុចរិត ដែលចេញពីអ៊ឺរ៉ុបខាងលិចមក។

គ) សន្តិភាពដ៏ខ្លីមួយ បន្ទាប់មកសង្គ្រាមនៅអើម៉ាគេដូន។

ឃ) ព្រះរាជ្យដ៏សុចរិតជាសាកលមួយ ដែលមានរយៈពេលមួយពាន់ឆ្នាំ។

២០ យោងតាមគម្ពីរវិវរណៈ ២១:២២ យើងនឹងចំណាយពេលអស់កល្បជានិច្ច

ក) នៅលើផែនដីបន្ទាប់ពីព្រះជាម្ចាស់ ស្រោចស្រង់ហើយ។

ខ) ទីដ៏សែនឆ្ងាយនៅជ្រុងម្ខាងទៀត នៃចក្រវាឡ។

គ) ជាមួយព្រះជាម្ចាស់នៅក្នុងផ្ទៃមេឃថ្មី និង ផែនដីថ្មី។

ឃ) ជាមួយព្រះជាម្ចាស់នៅលើផែនដីថ្មី ប៉ុន្តែផ្ទៃមេឃដដែល។

អថសាឧកថា

យើងសង្ឃឹមថាការសិក្សាមួយនេះបានធ្វើឲ្យអ្នកគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹង ព្រះជាម្ចាស់។ បន្ទាប់ពីបានសិក្សាមេរៀននេះរួច និង បានឆ្លើយគ្រប់សំណួរទាំងអស់ តើអ្នកធ្លាប់បានសួរខ្លួនឯងទេថា " តើខ្ញុំពិតជាគ្រិស្តបរិស័ទពិតប្រាកដម្នាក់ ដែរឬទេ? តើខ្ញុំស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ពិតជាគង់នៅក្នុងជីវិតរបស់ខ្ញុំ ដែរឬទេ?" យើងចង់ផ្តល់ឲ្យអ្នកនូវឱកាសក្នុងពេលនេះ ដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់បានប្រព្រឹត្តខុស។ យើងធ្លាប់ធ្វើឲ្យខ្លួនឯង ព្រមទាំងអ្នកដទៃឈឺចាប់។ ព្រះគម្ពីរហៅការនោះថា ជាអំពើបាប ហើយយើងរាល់គ្នាសុទ្ធតែមានទោស៖ "គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" (គម្ពីររ៉ូម ៣:២៣) ។ អំពើបាបរបស់យើងបានរារាំងយើងមិនឲ្យស្គាល់ព្រះជាម្ចាស់ ថាជាឪពុកដែលពេញដោយក្តីស្រឡាញ់។ ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់យើងណាស់ ទោះបីយើងមានបាបក្តី។ ទ្រង់ស្រឡាញ់យើងខ្លាំងណាស់ បានជាទ្រង់ចាត់បុត្រារបស់ទ្រង់មកសុគតសម្រាប់យើងរាល់គ្នា។ " ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។"
(គម្ពីរយ៉ូហាន៣:១៦)។ នៅពេលដែលទ្រង់សុគត ព្រះយេស៊ូបានទទួលយក ការដាក់ទោសដែលយើងសមនឹងទទួលបាន ដោយសារបាបរបស់យើង។

តើអ្នកចង់ធ្វើឲ្យប្រាកដថា ព្រះយេស៊ូជាព្រះសង្គ្រោះរបស់អ្នកដែរឬទេ? វាសាមញ្ញណាស់៖

- ទទួលស្គាល់ថាអ្នកជាមនុស្សបាបទុគ៌ត ដែលបែកចេញពីព្រះជាម្ចាស់ ហើយទូលសូមឲ្យទ្រង់លើកលែងឲ្យអ្នក។
- ជឿលើព្រះយេស៊ូ ឲ្យអស់ពីដួងចិត្តរបស់អ្នក ហើយធ្វើឲ្យទ្រង់ជ្រាបថា អ្នកពិតជាបានទទួលទ្រង់ជាព្រះសង្គ្រោះរបស់អ្នកមែន។

អ្នកអាចទូលទៅកាន់ព្រះជាម្ចាស់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ដោយថាតាមការអធិស្ឋានដូចតទៅនេះ៖

បពិត្រព្រះយេស៊ូ ទូលបង្គំដឹងថាទូលបង្គំជាមនុស្សមានបាប។ សូមទ្រង់ប្រណីសន្តោសឲ្យទូលបង្គំផង។ ទូលបង្គំជឿថាទ្រង់គឺជាបុត្រដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ។ ទូលបង្គំសូមអរព្រះគុណទ្រង់សម្រាប់ការសុគតនៅលើឈើឆ្កាងសម្រាប់បាបរបស់ទូលបង្គំ។ សូមយាងមកគង់ក្នុងជីវិតរបស់ទូលបង្គំ។ ប្រោសឲ្យទូលបង្គំទៅជាមនុស្សដែលពិតប្រាកដនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមសោយរាជ្យជាព្រះអម្ចាស់នៃជីវិតរបស់ទូលបង្គំនៅថ្ងៃនេះ។ សូមអរព្រះគុណទ្រង់សម្រាប់ការសង្គ្រោះទូលបង្គំ។

ប្រសិនបើអ្នកអធិស្ឋានតាមសេចក្តីអធិស្ឋាននេះ ហើយមានបំណងរកវាដាក់នៅក្នុងចិត្តរបស់អ្នកពិតមែន នោះបាបរបស់អ្នកត្រូវលើកលែង ហើយអ្នកមានជីវិតអស់កល្បជានិច្ចផងដែរ។ ព្រះយេស៊ូគឺជាព្រះអម្ចាស់នៃជីវិតរបស់អ្នក។ ព្រះគម្ពីរបានថ្លែងថា "បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត* ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (គម្ពីរ១យ៉ូហាន ១:៩)។

ក្រមួចសំណួរសម្រាប់សិស្ស

សូមអាន និងបំពេញសំណួរនៅក្នុងទំព័រខាងក្រោម ហើយដាក់ស្នើវា មិនថាអ្នកជាសិស្សដែលចុះឈ្មោះ ឬ គ្រាន់តែជាអ្នកដែលចង់អភិវឌ្ឍខ្លួនឯង។ សូមព្រះជាម្ចាស់ប្រទានពរអ្នក ស្របពេលដែលដំណើរនៃជំនឿរបស់អ្នកបន្តទៅមុខ!

សំណួរសម្រាប់និស្សិត

CS3131KHM ថ្នាក្រិ:នៃសេចក្តីពិត

ឈ្មោះរបស់អ្នក.....

អាសយដ្ឋាន.....

.....

អ៊ីម៉ែល.....

លេខទូរស័ព្ទ(មិនដាក់ក៏បាន).....

១ តើអ្នកអធិស្ឋានដើម្បីទទួលយកព្រះយេស៊ូជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះ ជាលើកដំបូងនៅក្នុងពេលដែលអ្នកកំពុងសិក្សាមុខវិជ្ជានេះឬ?

❑ បាទ/ចាស ❑ ទេ

បើមែន សូមចែករំលែករឿងរបស់អ្នក.....

.....

.....

២ តើមុខវិជ្ជានេះបានជួយអ្នកឲ្យនាំនរណាម្នាក់ចូលទៅកាន់ព្រះគ្រិស្តដែរឬទេ?

❑ បាទ/ចាស ❑ ទេ

៣ តើមុខវិជ្ជានេះបានពង្រឹងកម្លាំងអ្នកក្នុងនាមជាគ្រិស្តបរិស័ទដែរឬទេ?

❑ បាទ/ចាស ❑ ទេ

បើពិតមែន តើវាដោយរបៀបណា? .....

.....

.....

៤ តើអ្នកអាចនឹងណែនាំមុខវិជ្ជានេះទៅកាន់អ្នកដទៃបានដែរឬទេ?

❑ បាទ/ចាស ❑ ទេ

សូមឲ្យព័ត៌មាននៃមិត្តភក្តិម្នាក់របស់អ្នក ហើយយើងនឹងទាក់ទងគេអំពីរបៀបដែលគេអាចរៀនរបស់ទាំងនេះបាន។

ឈ្មោះមិត្តរបស់អ្នក.....

អាសយដ្ឋាន.....

.....

អ៊ីម៉ែល.....

លេខទូរស័ព្ទ (មិនឲ្យក៏បាន).....

សេចក្តីណែនាំសម្រាប់ការប្រឡងចុងក្រោយ

សម្រាប់តែនិស្សិតដែលបានចុះឈ្មោះជាផ្លូវការ

- រំឭកឡើងវិញនូវកម្មវត្ថុ លំហាត់អនុវត្តន៍ ការប្រឡងផ្ទាល់ខ្លួន និង ការប្រឡងតាមជំពូក
- សូមផ្ញើការប្រឡងចុងក្រោយ និងសំណួរសម្រាប់និស្សិតរបស់អ្នកទៅឲ្យគ្រូរបស់អ្នក និង ការិយាល័យថ្នាក់ជាតិ។

ឥឡូវនេះដោយសារអ្នកបានបញ្ចប់ការសិក្សាមុខវិជ្ជានេះ យើងលើកទឹកចិត្តអ្នកឲ្យចាប់ផ្តើមសិក្សាមុខវិជ្ជាបន្ទាប់ទៀត នៅក្នុងកម្មវិធីនេះ ឬសុំគ្រូរបស់អ្នក ឲ្យណែនាំមុខវិជ្ជាសិក្សាមួយផ្សេងទៀត។